ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា (ច.ស.វ.ក) កំណែ២

សីហា ២០២៣

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

បុព្វកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានបង្ហាញនូវលទ្ធផលចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា (ច. ស.វ.ក) កម្រិត៥ខ្ទង់ កំណែ២ ។ ការធ្វើបច្ចុប្បន្នភាព (ច.ស.វ.ក) គឺមានគោលបំណងធ្វើយ៉ាងណាដើម្បីធ្វើឲ្យប្រសើរឡើងនូវចំណាត់ថ្នាក់វិស័យសេដ្ឋកិច្ចកម្ពុជាកាន់តែមានសុក្រិត្យភាព និងមានសង្គតភាពល្អគ្រប់ជ្រុងជ្រោយស្របតាមការរីកចម្រើននៃស្ថានភាពសេដ្ឋកិច្ចនៅកម្ពុជា ក៏ដូចជាស្របតាមចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចអន្តរជាតិ។ ច.ស.វ.ក គឺជាឯកសារមាន សារៈសំខាន់ និងតម្រូវការចាំបាច់បំផុតសម្រាប់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ក្រសួង ស្ថាប័នផ្សេងៗ និងអ្នកស្រាវជ្រាវនានាក្នុងការធ្វើប្រព្រឹត្តិកម្មទិន្នន័យជំរឿន និងអង្កេតគំរូនានា។

យោងតាមការចាំបាច់ និងអាយុកាលនៃចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា (ច.ស.វ.ក) កំណែ១ មានរយៈពេលជាង ១០ឆ្នាំ មកហើយ។ ម្យ៉ាងទៀត វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ បានធ្វើជំរឿនសេដ្ឋកិច្ចឆ្នាំ២០២១ ចំនួនអង្គភាពសេដ្ឋកិច្ចបានកើនឡើងជាង ២៥% ដូច្នេះក្រសួងផែនការ ចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាព ច.ស.វ.ក កំណែ១ លេខកូដថ្នាក់រង ៥ខ្ទង់ ដើម្បីបំពេញបន្ថែមលើវិស័យសេដ្ឋកិច្ចដែលបានកើតឡើងនាពេលបច្ចុប្បន្ន។ ច.ស.វ.ក កំណែ២ នឹងត្រូវបានប្រើប្រាស់សម្រាប់ការធ្វើប្រព្រឹត្តកម្មទិន្នន័យស្ថិតិ ឧទាហរណ៍ ជំរឿនសេដ្ឋកិច្ច ជំរឿនប្រជាជន ជំរឿនកសិកម្ម អង្កេតកសិកម្ម អង្កេតកម្លាំងពលកម្ម អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា។ ល។

ចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា (ច.ស.វ.ក) កំណែ២ ដែលបោះពុម្ពផ្សាយឆ្នាំ២០២៣ គឺជាឯកសារមានសង្គតភាពស្របតាមលក្ខណៈជាតិ និងអន្តរជាតិ ដោយហេតុថា បានកែសម្រួលទាំងផ្នែកបច្ចេកទេស ថ្នាក់រង និងកំណែអក្ខរាវិរុទ្ធផ្សេងៗ ជាតុចូលដែលទទួលបានពី ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន បានអញ្ជើញចូលរួមពិភាក្សាក្នុងអង្គសិក្ខាសាលា និងកិច្ចប្រជុំពិគ្រោះយោបល់ច្រើនលើក។ ការបោះពុម្ព ច.ស.វ.ក ឆ្នាំ២០២២ បង្ហាញពីភាពរីកចម្រើន និងកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារបច្ចេកទេស វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ។ ច.ស.វ.ក ត្រូវបានពិនិត្យ និងសម្រេចដោយ គណៈកម្មាធិការសម្របសម្រួលស្ថិតិ និងក្រុមប្រឹក្សាស្ថិតិ ខ្ញុំសង្ឃឹមថា សៀវភៅចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា (ច.ស.វ.ក) កំណែ២ ដែលបានធ្វើបច្ចុប្បន្នភាពនេះ អាចយកទៅបម្រើជាប្រយោជន៍ដល់ក្រុមអ្នកប្រើប្រាស់ និងអ្នកស្រាវជ្រាវផ្នែកស្ថិតិនានា។

ខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការគាំទ្រដល់ការងារស្ថិតិ ព្រមទាំងបានផ្តល់ធនធានហិរញ្ញវត្ថុ ដើម្បីរៀបចំធ្វើបច្ចុប្បន្នភាពចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា (ច.ស.វ.ក) កំណែ២។

ខ្ញុំក៏សូមកោតសរសើរអស់ពីចិត្ត ចំពោះឯកឧត្តម **សន ស៊ីថន** រដ្ឋលេខាធិការ ក្រសួងផែនការ លោកជំទាវ **ប៉ែន សុភា** អតីតរដ្ឋលេខាធិការ ក្រសួងផែនការ ឯកឧត្តម **ហ៊ាច ភាណុល** អនុរដ្ឋលេខាធិការ ក្រសួងផែនការ លោកជំទាវ **ហាច់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ប្រធានក្រុមការងារធ្វើបច្ចុប្បន្នភាព ច.ស.វ.ក កំណែ២ ឯកឧត្តម **ឃិន សុខលក្ខណ៍** ទីប្រឹក្សាក្រសួង អគ្គនាយករង និងជាអនុប្រធានទី១ ឯកឧត្តម **ទៀវ រ៉ុងសារ** ទីប្រឹក្សាក្រសួង អគ្គនាយករង និងជាអនុប្រធានទី២ ឯកឧត្តម **លឹម ពេញ** ទីប្រឹក្សាក្រសួង និងជាប្រធាននាយកដ្ឋានស្តង់ដារស្ថិតិ និងវិភាគស្ថិតិ និងជាសមាជិកអចិន្ត្រៃយ៍ ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិកក្រុមការងារចងក្រងចំណាត់ថ្នាក់ស្តង់ដារមុខរបរនៅកម្ពុជា កំណែ១ និងការធ្វើបច្ចុប្បន្នភាពចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា កំណែ២ និងក្រុមការងារបច្ចេកទេស នៃវិទ្យាស្ថានជាតិស្ថិតិ ចំពោះការខិតខំសម្រេចជោគជ័យលើការងារនេះ។

ជាទីបញ្ចប់ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងសមាជិក សមាជិការ នៃបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានផ្តល់ជាតុចូលក្នុងការធ្វើបច្ចុប្បន្នភាព ច.ស.វ.ក កំណែ២ ដល់ក្រុមការងារនៃវិទ្យាស្ថានជាតិស្ថិតិ សម្រេចបានជោគជ័យដ៏ត្រចះត្រចង់។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ
ប្រធានក្រុមប្រឹក្សាស្ថិតិ

កិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន**

ក្រសួងផែនការ
រាជធានីភ្នំពេញ
ខែសីហា ឆ្នាំ ២០២៣

អារម្ភកថា

ចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា (ច.ស.វ.ក) កំណែ២ គឺជាឧបករណ៍ស្ថិតិចាំបាច់សម្រាប់ការផលិតទិន្នន័យស្ថិតិជំរឿន និងអង្កេត ដូចជាជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២។ តាមច្បាប់ស្តីពីស្ថិតិឆ្នាំ ២០១៥ វិទ្យាស្ថានស្ថិតិជាតិត្រូវកំណត់ស្តង់ដារស្ថិតិជាតិដែលទាក់ទងទៅនឹងចំណាត់ថ្នាក់ទស្សនៈទាន និយមន័យ និងអង្គពិនិត្យពិចារណាស្ថិតិដើម្បីចៀសវាងការភាន់ច្រឡំពីសំណាក់អ្នកប្រើប្រាស់ទិន្នន័យ និងការជាន់គ្នាក្នុងការផលិតទិន្នន័យស្ថិតិផ្លូវការ ជាពិសេសចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ច គឺត្រូវបានប្រើប្រាស់ដើម្បីសម្គាល់សកម្មភាពសេដ្ឋកិច្ចរបស់អង្គភាពសេដ្ឋកិច្ច និងដើម្បីធ្វើជាមូលដ្ឋានក្នុងការទាញតារាងស្ថិតិតាមវិស័យ និងចរិតលក្ខណៈរបស់អង្គភាពសេដ្ឋកិច្ច។

វិទ្យាស្ថានជាតិស្ថិតិបានចាប់ផ្តើមធ្វើការបង្កើតចំណាត់ថ្នាក់នេះដំបូងក្នុងឆ្នាំ២០០៨ ដោយមានការជួយគាំទ្រពីវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់ប្រទេសក្នុងតំបន់អាស៊ាន និងអាស៊ីអាគ្នេយ៍ (ERIA) ។ នៅពេលនោះវិទ្យាស្ថានជាតិស្ថិតិសម្រេចបានផ្នែកកម្មន្តសាល ហើយបន្ទាប់មកយើងបានពង្រីកចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា (ច.ស.វ.ក) បន្ថែមលើវិស័យផ្សេងៗទៀតដែលមានជំនាញការ លោកស្រី ពិន ពិន។ ដោយមានការជួយឧបត្ថម្ភគាំទ្រពីសហគមន៍អឺរ៉ុប ច.ស.វ.ក ត្រូវបានបង្កើតរួចរាល់ និងបោះពុម្ពលើកដំបូងជាភាសាខ្មែរ និងភាសាអង់គ្លេស ឆ្នាំ២០១២។ លទ្ធផលចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា (ច.ស.វ.ក) ឆ្នាំ២០១២ ត្រូវបានបង្កើតឡើងដោយផ្អែកលើលំនាំចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចអន្តរជាតិ (ច.ស.វ.អ) កំណែ៤ (ISIC .Rev4) ជាមូលដ្ឋាន។ យោងលទ្ធផលជំរឿនសេដ្ឋកិច្ចឆ្នាំ២០២១ ច.ស.វ.ក កំណែ១ នេះត្រូវបានធ្វើបច្ចុប្បន្នភាពឡើងវិញដោយបានពិនិត្យ និងកែតម្រូវលើផ្នែកអក្ខរាវិរុទ្ធ និងបន្ថែមលើលេខកូដចំណាត់ថ្នាក់រងកម្រិត៥ខ្ទង់ ផ្អែកទៅលើស្ថានភាពសេដ្ឋកិច្ចរីកចម្រើននៅប្រទេសកម្ពុជា ជាពិសេស គឺតាមរយៈការធ្វើឲ្យមានភាពសាមញ្ញ និងសង្ខេបដើម្បីកម្រិតលេខរបស់ថ្នាក់រងឲ្យទៅជាលេខដែលចាំបាច់ និងអាចគ្រប់គ្រងបានសម្រាប់ប្រទេសកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមការងារដែលដឹកនាំដោយឯកឧត្តម **ឃិន សុវណ្ណភ័ណ្ឌ** ទីប្រឹក្សាក្រសួង អគ្គនាយករង និងជាអនុប្រធានទី១ ឯកឧត្តម **ទៀវ រ៉ុខសារ** ទីប្រឹក្សាក្រសួង អគ្គនាយករង និងជាអនុប្រធានទី២ ឯកឧត្តម **ជា ចាន់តុលា** ទីប្រឹក្សាក្រសួង អគ្គនាយករង និងជាអនុប្រធាន លោកជំទាវ **សូរ្យ សុវណ្ណចរិយា** ទីប្រឹក្សាក្រសួង អគ្គនាយករង និងជាអនុប្រធាន ឯកឧត្តម **លឹម ពេញ** ទីប្រឹក្សាក្រសួង ជាប្រធាននាយកដ្ឋានស្តង់ដារ និងវិភាគស្ថិតិ និងជាសមាជិកអចិន្ត្រៃយ៍ លោក **ខៀវ ខេមរិន្ទ** អគ្គនាយករង លោក **សុខ បូរិទ្ធ** និងលោកស្រី **ឃិត វីរីយ៉ា** អនុប្រធាននាយកដ្ឋានស្តង់ដារ និងវិភាគស្ថិតិ ជាសមាជិកក្រុមការងារ ឯកឧត្តម លោក លោកស្រី ជាសមាជិកក្រុមការងាររចងក្រងចំណាត់ថ្នាក់ស្តង់ដារមុខរបរនៅកម្ពុជា កំណែ១ និងការធ្វើបច្ចុប្បន្នភាពចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា កំណែ២ និងក្រុមការងារបច្ចេកទេស នៃវិទ្យាស្ថានជាតិស្ថិតិ ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី អញ្ជើញមកពីក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធ ចំពោះការខិតខំសម្រេចជោគជ័យលើការងារនេះ។

ជាទីបញ្ចប់ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន និងសមាជិក សមាជិកានៃបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ដែលបានផ្តល់ជាតុចូលក្នុងការធ្វើបច្ចុប្បន្នភាព ច.ស.វ.ក កំណែ២ ដល់ក្រុមការងារ នៃវិទ្យាស្ថានជាតិស្ថិតិ សម្រេចបានជោគជ័យដ៏ត្រចះត្រចង់នេះ។

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុក
អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ
ប្រធានគណៈកម្មាធិការសម្របសម្រួលស្ថិតិ

ហង់ លីណា

ក្រសួងផែនការ
រាជធានីភ្នំពេញ
ខែសីហា ឆ្នាំ ២០២៣

មាតិកា

ទំព័រ

បុព្វកថា...i
អារម្ភកថា...ii
មាតិកា..iii
កំណត់សម្គាល់បច្ចេកទេស..iv
ជំពូក ក	កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១
ជំពូក ខ	ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ ១៦
ជំពូក គ	កម្មន្តសាល ២៨
ជំពូក ឃ	ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយទឹក និងប្រព័ន្ធខ្យល់ត្រជាក់...............១៤៧
ជំពូក ង	ការផ្គត់ផ្គង់ទឹកស្អាត ការគ្រប់គ្រងនិងកែច្នៃទឹកស្អុយនិងកាកសំណល់............ ១៥០
ជំពូក ច	សំណង់.. ១៦១
ជំពូក ឆ	អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្ត
	និងទោចក្រយានយន្តគ្រប់ប្រភេទ...១៧៤
ជំពូក ជ	ការដឹកជញ្ជូន និងការស្តុកទុក ១៩៥
ជំពូក ឈ	សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ...................................២០៩
ជំពូក ញ	ព័ត៌មានវិទ្យា និងទូរគមនាគមន៍...២១៤
ជំពូក ដ	សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង ២៣៥
ជំពូក ឋ	សកម្មភាពអចលនទ្រព្យ ២៤៤
ជំពូក ឌ	សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស ២៤៦
ជំពូក ឍ	សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ ២៦៣
ជំពូក ណ	រដ្ឋបាលសាធារណៈ កិច្ចការពារសាធារណៈ
	និងកាតព្វកិច្ចសន្តិសុខសង្គម ២៨១
ជំពូក ត	ការអប់រំ..២៨៧
ជំពូក ថ	សកម្មភាពទាក់ទងសុខភាព និងការងារសង្គមកិច្ច ២៩២
ជំពូក ទ	សិល្បៈ ការកម្សាន្ត និងការលម្ហែ ៣០១
ជំពូក ធ	សកម្មភាពសេវាកម្មផ្សេងទៀត ៣០៩
ជំពូក ន	សកម្មភាពគ្រួសារជានិយោជិតនិងសកម្មភាពផលិតទំនិញនិងផ្គត់ផ្គង់ សេវាកម្ម ដែលមិន
	អាចញែកដាច់ពីគ្នារបស់គ្រួសារសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ៣១៩
ជំពូក ប	សកម្មភាពរបស់អង្គការ និងស្ថាប័នអន្តរជាតិ.................................៣២៣
ឧបសម្ព័ន្ធ ១ .... ៣២៥
ឧបសម្ព័ន្ធ ២..៣២៧
ឧបសម្ព័ន្ធ ៣.. ៣២៩
ឧបសម្ព័ន្ធ ៤ .... ៣៣០
ឧបសម្ព័ន្ធ ៥ ....៣៣៣

កំណត់សម្គាល់បច្ចេកទេស

១. គោលបំណង និងវិសាលភាព នៃការធ្វើចំណាត់ថ្នាក់

នៅក្នុងការស្រាវជ្រាវបាតុភូតសេដ្ឋកិច្ច ការវិភាគលើសមាសភាគទាំងអស់ ក្នុងពេលដំណាលគ្នាតែមួយមិនមែនសុទ្ធតែអាចធ្វើឡើងបាននោះឡើយ។ ដើម្បីធ្វើការវិភាគ គេត្រូវបែងចែកជាក្រុមនូវសមាសភាគមួយចំនួន ដោយផ្អែកទៅតាមលក្ខណៈជាក់លាក់របស់ក្រុមសកម្មភាពសេដ្ឋកិច្ច។ ដោយហេតុនេះហើយ រាល់ការបរិយាយនានាជាទម្រង់ស្ថិតិ អំពីដំណើរការសេដ្ឋកិច្ច ទាមទារនូវការធ្វើចំណាត់ថ្នាក់ជាប្រព័ន្ធឲ្យបានច្បាស់លាស់។

ឯកសារ ចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចកម្ពុជា (ច.ស.វ.ក) នេះ គឺជាស្តង់ដារមូលដ្ឋានមួយ សម្រាប់ធ្វើចំណាត់ថ្នាក់លើសកម្មភាពសេដ្ឋកិច្ចទាំងឡាយ នៅក្នុងប្រទេសកម្ពុជា។ គោលបំណងចម្បងនៃឯកសារនេះ គឺចង់បង្ហាញពីសំណុំនៃចំណាត់ថ្នាក់គ្រប់ប្រភេទសកម្មភាពសេដ្ឋកិច្ចនានា ដែលជាតម្រូវការចាំបាច់សម្រាប់ប្រើប្រាស់ ក្នុងការងារប្រមូលស្ថិតិនិងបទបង្ហាញស្ថិតិ។ ឈរលើមូលហេតុនេះ ច.ស.វ.ក បានបង្កើតសំណុំនៃចំណាត់ថ្នាក់ជាច្រើន ដោយផ្អែកទៅតាមប្រភេទសកម្មភាពសេដ្ឋកិច្ច ដែលអង្គភាពឬស្ថាប័នទាំងឡាយកំពុងធ្វើ។ ការឲ្យនិយមន័យនៃចំណាត់ថ្នាក់នីមួយៗ ត្រូវបានធ្វើឡើងដោយយោងតាមដំណើរការនៃសកម្មភាពសេដ្ឋកិច្ច របស់អង្គភាពឬស្ថាប័ននីមួយៗ និងទៅតាមដំណើរការនៃការបរិយាយសកម្មភាពសេដ្ឋកិច្ចនេះ នៅក្នុងទម្រង់ស្ថិតិ។

ច.ស.វ.ក គឺជាការធ្វើចំណាត់ថ្នាក់មួយបែប ដែលផ្អែកលើប្រភេទនៃសកម្មភាពសេដ្ឋកិច្ច ហើយមិនផ្អែកលើប្រភេទ នៃមុខទំនិញឬសេវាកម្មនោះទេ។ ការធ្វើប្រតិបត្តិការរបស់ស្ថាប័នមួយ គឺជាប្រភេទនៃសកម្មភាពសេដ្ឋកិច្ច ដែលស្ថាប័ននោះពាក់ព័ន្ធ។ ប្រភេទនៃប្រតិបត្តិការនេះ គឺជាមូលដ្ឋានប្រើសម្រាប់ធ្វើចំណាត់ថ្នាក់ លើសកម្មភាពរបស់ស្ថាប័នមួយនោះ ហើយបង្កើតបានជា «វិស័យ» មួយ។ ពាក្យថា «វិស័យ» សំដៅដល់សំណុំនៃស្ថាប័នផលិតកម្មទាំងឡាយ ដែលមានប្រភេទនៃសកម្មភាពប្រតិបត្តិការចម្បង ដូចគ្នាឬស្រដៀងគ្នា។

ជាគោលការណ៍ គេពុំអាចបង្កើតទំនាក់ទំនងដាច់ខាត(ឬហៅម្យ៉ាងទៀតថា «ទំនាក់ទំនងមួយទល់មួយ») រវាងប្រភេទនៃសកម្មភាពផលិតកម្ម និងប្រភេទនៃផលិតផល បានឡើយ។ ក្នុងន័យនេះ ច.ស.វ.ក មិនមែនប្រើសម្រាប់ប្រមូលយកទិន្នន័យរបស់ផលិតផល ឲ្យបានល្អិតល្អន់នោះទេ។ ច.ស.វ.ក ក៏មិនមែនប្រើសម្រាប់បង្ហាញពីភាពខុសគ្នានានា ពាក់ព័ន្ធនឹងប្រភេទកម្មសិទ្ធិ ប្រភេទនីតិបុគ្គល ឬប្រភេទនៃមធ្យោបាយប្រើសម្រាប់ប្រតិបត្តិការសកម្មភាពនោះដែរ ពីព្រោះថា លក្ខខណ្ឌទាំងនោះមិនទាក់ទងនឹងប្រភេទនៃសកម្មភាពទេ។ ស្ថាប័នដែលមានប្រភេទសកម្មភាពដូចគ្នា ត្រូវបានចាត់ចូល ក្នុងចំណាត់ថ្នាក់ដូចគ្នានៅក្នុងច.ស.វ.ក ដោយមិនប្រកាន់ ថាតើស្ថាប័ននោះជាប្រភេទ សាជីវកម្ម ក្រុមហ៊ុនឯកកម្មសិទ្ធិ ឬជាអង្គភាពរដ្ឋនោះឡើយ ហើយក៏មិនប្រកាន់ ថាតើសហគ្រាសមេមួយនោះ មានបុត្រសម្ព័ន្ធមួយឬច្រើន យ៉ាងណានោះទេ។ ស្រដៀងគ្នានេះដែរ ស្ថាប័នកម្មន្តសាលត្រូវបានចាត់ថ្នាក់ ដោយយោងតាមប្រភេទសកម្មភាពសេដ្ឋកិច្ចចម្បង ដែលស្ថាប័ននោះពាក់ព័ន្ធ ជាអាទិ៍ ថាតើការងារនោះធ្វើឡើង ដោយប្រើម៉ាស៊ីនឬដោយដៃ ឬផលិតក្នុងរោងចក្រ ឬក្នុងផ្ទះ ឬយ៉ាងណានោះ។

ច.ស.វ.ក កំណែ២ គ្របដណ្តប់រាល់សកម្មភាពសេដ្ឋកិច្ចដែលត្រូវបានចាត់ថ្នាក់ទៅតាមប្រភេទជា ២១ ផ្នែក ដូចជា៖

(ក)　កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

(ខ)　ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ

(គ)　កម្មន្តសាល

(ឃ) ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយទឹក និងប្រព័ន្ធខ្យល់ត្រជាក់
(ង) ការផ្គត់ផ្គង់ទឹកស្អាត ការគ្រប់គ្រងនិងកែច្នៃទឹកស្អុយនិងកាកសំណល់
(ច) សំណង់
(ឆ) អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្ត និងទោចក្រយានយន្តគ្រប់ប្រភេទ
(ជ) ការដឹកជញ្ជូន និងការស្តុកទុក
(ឈ) សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ
(ញ) ព័ត៌មានវិទ្យា និងទូរគមនាគមន៍
(ដ) សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង
(ឋ) សកម្មភាពអចលនទ្រព្យ
(ឌ) សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស
(ឍ) សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ
(ណ) រដ្ឋបាលសាធារណៈ កិច្ចការពារសាធារណៈ និងកាតព្វកិច្ចសន្តិសុខសង្គម
(ត) ការអប់រំ
(ថ) សកម្មភាពទាក់ទងសុខភាព និងការងារសង្គមកិច្ច
(ទ) សិល្បៈ ការកម្សាន្ត និងការលម្ហែ
(ធ) សកម្មភាពសេវាកម្មផ្សេងទៀត
(ន) សកម្មភាពគ្រួសារជានិយោជិត និងសកម្មភាពផលិតទំនិញ និងផ្គត់ផ្គង់សេវាកម្ម ដែលមិនអាចញែកដាច់ពីគ្នា របស់គ្រួសារ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន
(ប) សកម្មភាពរបស់អង្គការ និងស្ថាប័នអន្តរជាតិ។

ការធ្វើចំណាត់ថ្នាក់នេះក៏ពិចារណាផងដែរ ចំពោះបណ្តាសកម្មភាពសេដ្ឋកិច្ច ដែលត្រូវបានអង្កេតឃើញ ក្នុងពេលធ្វើជំរឿនសេដ្ឋកិច្ចឆ្នាំ២០២២ និងមានការយកចិត្តទុកដាក់យ៉ាងប្រុងប្រយ័ត្ន ទៅលើវិស័យដែលមានសក្តានុពលខ្ពស់ ថ្វីបើវិស័យនេះស្ថិតក្នុងស្ថានភាពកំពុងអភិវឌ្ឍក៏ដោយ តែត្រូវបានរំពឹងថានឹងមានស្ថិរភាព ហើយអាចដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យសេដ្ឋកិច្ចជាតិ នៅអនាគតដ៏ខ្លីខាងមុខ។

២. លក្ខខណ្ឌ នៃការធ្វើចំណាត់ថ្នាក់

ឯកសារ ច.ស.វ.ក កំណែ២ នេះ ត្រូវបានតាក់តែងឡើងដោយប្រើប្រាស់«ចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចអន្តរជាតិ (ច.ស.វ.អ)» កំណែ៤ ដែលចេញផ្សាយដោយ«អង្គភាពស្ថិតិ នៃអង្គការសហប្រជាជាតិ» មកធ្វើជាឯកសារយោងគោល និងជាមូលដ្ឋានគ្រឹះសម្រាប់ធ្វើការប្រៀបធៀបជាលក្ខណៈអន្តរជាតិ។ លក្ខណៈនៃរចនាសម្ព័ន្ធ របស់ ច.ស.វ.អ មួយភាគធំ ត្រូវបានរក្សាទុកដដែល ថ្វីបើមានការកែសម្រួលខ្លះៗ ដើម្បីបន្សុីជាមួយនឹងស្ថានភាព និងតម្រូវការជាក់ស្តែងស្ថានភាពសេដ្ឋកិច្ចកម្ពុជា។ ការកែសម្រួលទាំងនោះមានដូចជា ៖ (ក)បំបែកបន្ថែមទៀតនូវកម្រិតក្រុម (លេខសម្គាល់ ៣ ខ្ទង់) និងកម្រិតថ្នាក់ (លេខសម្គាល់ ៤ ខ្ទង់)មួយចំនួននៃ ច.ស.វ.អ ហើយដាក់លេខសម្គាល់ដាច់ដោយឡែកសម្រាប់វិស័យដែលមានសារៈសំខាន់ខ្លាំង ចំពោះសេដ្ឋកិច្ចជាតិ (ខ) ដំឡើងកម្រិត នៃចំណាត់ថ្នាក់របស់វិស័យធំៗ ឲ្យស្ថិតនៅកម្រិតខ្ពស់ជាងមុន និងទម្លាក់កម្រិត

នៃចំណាត់ថ្នាក់របស់វិស័យ ដែលផ្តល់ប្រយោជន៍តិចតួចដល់សេដ្ឋកិច្ច និង (គ) ពង្រីកការធ្វើចំណាត់ថ្នាក់ហួតដល់លេខ ៥ ខ្ទង់ ដោយបំបែកកម្រិតថ្នាក់ឲ្យទៅជាកម្រិតថ្នាក់រង។

ច.ស.វ.អ កំណែ៤ លក្ខណៈនៃសកម្មភាពសេដ្ឋកិច្ចរបស់ស្ថាប័នផលិតកម្ម ត្រូវបានយកមកពិចារណាយ៉ាងល្អិតល្អន់ ខណៈពេលដែលធ្វើចំណាត់ថ្នាក់នៅកម្រិតក្រុម សម្រាប់ដាក់ចូលក្នុង ច.ស.វ.ក កំណែ២ នេះ។ លក្ខណៈទាំងនោះរួមមាន៖ (ក) ប្រភេទនៃសេវាកម្ម និងទំនិញដែលត្រូវបានផលិត (ខ) ការប្រើប្រាស់ទំនិញនិងសេវាកម្ម និង (គ) វត្ថុធាតុដើមដំណើរការ និងបច្ចេកវិទ្យានៃការផលិត។ លក្ខណៈបន្សំផ្សេងទៀតនៃសកម្មភាពសេដ្ឋកិច្ចក៏ត្រូវបានយកមកពិចារណាផងដែរ ជាអាទិ៍ លក្ខណៈដូចគ្នានៃការគ្រប់គ្រងឬភាពជាម្ចាស់កម្មសិទ្ធិ ភាពខុសគ្នានៃទំហំ និងសកម្មភាពរបស់ស្ថាប័ន និងសារៈសំខាន់នៃសកម្មភាពរបស់ស្ថាប័ននៅក្នុងសេដ្ឋកិច្ចជាតិ។

លក្ខណៈបន្សំនៃសកម្មភាពសេដ្ឋកិច្ចរបស់ស្ថាប័ន និងសារៈសំខាន់នៃសកម្មភាពសេដ្ឋកិច្ចទាំងនេះនៅក្នុងសេដ្ឋកិច្ចជាតិ សុទ្ធសឹងជាលក្ខខណ្ឌចម្បងៗ ដែលត្រូវបានប្រើសម្រាប់កំណត់និយមន័យ ឲ្យដល់កម្រិតថ្នាក់និងថ្នាក់រងរបស់ ច.ស.វ.ក មួយនេះ។ លក្ខខណ្ឌពាក់ព័ន្ធនឹងលក្ខណៈបន្សំនៃសកម្មភាពសេដ្ឋកិច្ចរបស់ស្ថាប័ន ត្រូវបានប្រើប្រាស់ដើម្បីធានាថា រាល់ស្ថាប័នដែលត្រូវបានចាត់ចូល ក្នុងកម្រិតថ្នាក់ឬអនុថ្នាក់ មានប្រភេទសកម្មភាពដូចគ្នា តាមដែលអាចធ្វើបាន។ រីឯលក្ខខណ្ឌទាក់ទងនឹងសារៈសំខាន់នៃសកម្មភាពសេដ្ឋកិច្ចវិញ ត្រូវបានបង្កើតឡើង ក្នុងគោលបំណងធានាឲ្យបានថា ចំណាត់ថ្នាក់នេះពិតជាត្រូវបានធ្វើឡើង ដោយផ្អែកតាមតម្រូវការនិងទិដ្ឋភាពជាក់ស្តែងរបស់ប្រទេស។ ជាទូទៅ ប្រភេទសកម្មភាពសេដ្ឋកិច្ចទាំងឡាយណា ដែលរួមចំណែកយ៉ាងសំខាន់ដល់សេដ្ឋកិច្ចជាតិ ត្រូវបានចាត់ចូលក្នុងកម្រិតថ្នាក់និងថ្នាក់រងដាច់ដោយឡែក ដោយផ្អែកតាមលក្ខខណ្ឌដូចជា៖ (ក)ទំហំទឹកប្រាក់នៃផលិតកម្ម, (ខ)ចំនួនសហគ្រាសដែលចូលរួមក្នុងសកម្មភាពផលិតកម្មនោះ, និង (គ)សមត្ថភាពដែលអាចបំពេញលក្ខខណ្ឌនាំចេញផលិតផលទៅក្រៅប្រទេស។

និយមន័យសម្រាប់កំណត់កម្រិតថ្នាក់និងថ្នាក់រង នៅក្នុងច.ស.វ.កឆ្នាំ២០១១ ត្រូវបានធ្វើឡើងដោយផ្អែកតាមលក្ខខណ្ឌ៖ (១)ផលិតកម្មនៃមុខទំនិញនិងសេវាកម្ម ដែលត្រូវបានចាត់ចូលក្នុងកម្រិតថ្នាក់ឬថ្នាក់រងណាមួយនោះ ត្រូវតែតាងឲ្យមួយភាគធំនៃផលិតផល របស់ស្ថាប័នផលិតកម្មទាំងអស់ដែលពាក់ព័ន្ធ និង (២)កម្រិតថ្នាក់នេះត្រូវតែរាប់បញ្ចូល នូវស្ថាប័នដែលផលិតមុខទំនិញនិងសេវាកម្ម ដែលត្រូវនឹងលក្ខណៈរបស់ថ្នាក់នេះ។ លក្ខខណ្ឌទី១ត្រូវបានបង្កើតឡើង ដើម្បីធានាឲ្យបាននូវលក្ខណៈឯកសណ្ឋាន ឬភាពស្រដៀងគ្នាតាមដែលអាចធ្វើបាន របស់ស្ថាប័នដែលត្រូវបានចាត់ចូល ក្នុងកម្រិតថ្នាក់ឬថ្នាក់រងណាមួយនោះ។ ចំណែកឯលក្ខខណ្ឌទី២វិញ ត្រូវបានបង្កើតឡើងសម្រាប់បំពេញបន្ថែមឲ្យលក្ខខណ្ឌទី១។ លក្ខខណ្ឌទាំងពីរនេះគឺជាដែនកំណត់នៃភាពលម្អិតនៃការធ្វើចំណាត់ថ្នាក់ ដោយហេតុថា ការកំណត់និយមន័យឲ្យដល់កម្រិតថ្នាក់ឬថ្នាក់រង ត្រូវបានតម្រូវឲ្យធ្វើឡើងដោយផ្អែកលើ លក្ខណៈបន្សំនៃសកម្មភាពសេដ្ឋកិច្ចចម្បង ដែលស្ថាប័នដែលត្រូវចាត់ថ្នាក់នោះពាក់ព័ន្ធ។

៣. សមាសភាគស្ថិតិ នៃការធ្វើចំណាត់ថ្នាក់

សមាសភាគដែលត្រូវបានចាត់ចូល ក្នុងការធ្វើចំណាត់ថ្នាក់វិស័យសេដ្ឋកិច្ច មិនមែនជាផលិតផលនោះទេ ប៉ុន្តែគឺជាស្ថាប័នផលិតកម្មដែលអាចជា៖ គ្រឹះស្ថាន សហគ្រាស ឬក្រុមហ៊ុន គ្រួសារ ឬអង្គភាពប្រតិបត្តិការ។ ដោយហេតុថា ការជ្រើសយកប្រភេទសមាសភាគស្ថិតិណាមួយមកប្រើប្រាស់ ទាក់ទងខ្លាំងទៅនឹងប្រភេទនៃស្ថិតិដែលត្រូវប្រមូលយក សមាសភាគស្ថិតិដែលមានលក្ខណៈសមស្រប សម្រាប់ការធ្វើចំណាត់ថ្នាក់ ចាំបាច់ត្រូវបំពេញឲ្យបាននូវលក្ខខណ្ឌ៖ (ក)មានលក្ខណៈឯកសណ្ឋានខាងសកម្មភាពសេដ្ឋកិច្ច (ខ)មានទិន្នន័យដាច់ដោយឡែកស្តីពីសកម្មភាព របស់សាមីស្ថាប័ននីមួយៗទាំងនោះ ដែលអាចឲ្យគេយកបាន និងដែលត្រូវបានចងក្រងឡើងយ៉ាងត្រឹមត្រូវ និង (គ)មានកម្រិតស្វ័យភាពខ្លះ។ ស្វ័យភាពនេះមិនតម្រូវឲ្យមានលក្ខណៈដាច់ខាតនោះទេ។ ជាឧទាហរណ៍ ប្រសិនបើស្ថាប័នមួយឬគណៈគ្រប់គ្រងរបស់ស្ថាប័ននោះ ត្រូវបានអនុញ្ញាត ឲ្យមាន

សិទ្ធិកំណត់គោលដៅអាជីវកម្មរបស់ខ្លួន និងមានសិទ្ធិទិញឬលក់ដោយសេរីនៅលើទីផ្សារ ស្ថាប័នមួយនោះត្រូវបានចាត់ទុកថាជាសមាសភាគមួយច្បាស់លាស់។

សមាសភាគស្ថិតិត្រូវបានចាត់ថ្នាក់ជាប្រភេទខុសៗគ្នាដូចខាងក្រោម៖

ក) *សមាសភាគប្រភេទគ្រឹះស្ថាន៖* គឺជាអង្គភាពសេដ្ឋកិច្ចជាក់លាក់មួយ ដែលស្ថិតនៅក្រោមការគ្រប់គ្រងតែមួយ ឬម្ចាស់កម្មសិទ្ធិតែមួយ ពោលគឺ ស្ថិតក្រោមស្ថាប័នស្របច្បាប់តែមួយ ដែលពាក់ព័ន្ធក្នុងសកម្មភាពតែមួយ ឬសកម្មភាពចម្បងណាមួយ ប្រព្រឹត្តិទៅនៅលើទីតាំងជាក់លាក់មួយ។

ខ) *សមាសភាគប្រភេទសកម្មភាព៖* គឺជាសហគ្រាស ឬផ្នែកនៃសហគ្រាស ដែលពាក់ព័ន្ធក្នុងសកម្មភាពសេដ្ឋកិច្ចតែមួយ ឬសកម្មភាពសេដ្ឋកិច្ចចម្បងណាមួយ ដោយពុំប្រកាន់អំពីទីតាំងភូមិសាស្ត្រ ដែលសកម្មភាពទាំងនោះកើតឡើង។ សមាសភាគប្រភេទសកម្មភាពនេះ មានលក្ខណៈខុសពីប្រភេទគ្រឹះស្ថាននៅត្រង់ថា ប្រភេទសកម្មភាពនេះពុំប្រកាន់អំពីទីតាំងភូមិសាស្ត្រ នៃការអនុវត្តសកម្មភាពសេដ្ឋកិច្ចឡើយ ពោលគឺ អាចមានលក្ខណៈពហុសណ្ឋានខាងទីតាំង(ទីតាំងច្រើនកន្លែង)។

គ) *សមាសភាគបច្ចេកទេស៖* អាចជាផ្នែក ឬការិយាល័យនៃគ្រឹះស្ថាន ដែលពាក់ព័ន្ធដោយផ្ទាល់ ជាមួយនឹងច្រវ៉ាក់ផលិតកម្មទាំងមូល នៃទំនិញឬសេវាកម្មរបស់ខ្លួន ឬជាមួយនឹងដំណាក់កាលណាមួយ នៃចង្វាក់ផលិតកម្មទំនិញឬសេវាកម្មនោះ។ ផ្នែកឬការិយាល័យនៃរោងចក្រវេចខ្ចប់សាច់ ដែលផលិតចេញជាខ្លាញ់ជ្រូក សាច់ជ្រូកប្រឡាក់ ឬសាច់កំប៉ុង (ពោលគឺ ខ្សែចង្វាក់ផលិតកម្មផ្តេក) គឺជាឧទាហរណ៍នៃប្រភេទចង្វាក់ផលិតកម្មទាំងមូល របស់សមាសភាគបច្ចេកទេស។ ផ្នែកនៃរោងចក្រវាយនភណ្ឌ ដែលរវៃអំបោះ និងចាក់អាវ ។ល។ (ពោលគឺ ខ្សែចង្វាក់ផលិតកម្មបញ្ឈរ) គឺជាឧទាហរណ៍នៃប្រភេទដំណាក់កាលមួយនៃចង្វាក់ផលិតកម្មរបស់សមាសភាគបច្ចេកទេស។

ឃ) *សមាសភាគមូលដ្ឋាន៖* គ្រប់ដណ្តប់លើគ្រប់សកម្មភាពសេដ្ឋកិច្ច ប្រតិបត្តិការដោយសហគ្រាសមួយ នៅលើទីតាំងមួយជាក់លាក់។ សមាសភាគមូលដ្ឋានខុសប្លែកពីសមាសភាគប្រភេទគ្រឹះស្ថាន នៅត្រង់លក្ខណៈពហុសណ្ឋាននៃសកម្មភាពសេដ្ឋកិច្ច(សកម្មភាពសេដ្ឋកិច្ចច្រើន)។ លក្ខខណ្ឌតម្រូវនៃសមាសភាគមូលដ្ឋាននេះគឺថា ស្ថាប័នត្រូវស្ថិតក្រោមម្ចាស់កម្មសិទ្ធិតែមួយ និងនៅលើទីតាំងតែមួយកន្លែង។

ង) *សមាសភាគចំណុះ៖* ផ្គត់ផ្គង់ទាំងស្រុងឬជាចម្បង នូវទំនិញប្រើប្រាស់ទូទៅនិងសេវាកម្ម ទៅឲ្យស្ថាប័នមេ។ ទំនិញនិងសេវាកម្មទាំងនោះ គឺគ្រាន់តែជាជំនួយដល់សកម្មភាពផលិតកម្ម របស់គ្រឹះស្ថាននានា ដែលជាបុត្រសម្ព័ន្ធរបស់ស្ថាប័នមេនោះ ពោលគឺ មិនត្រូវបានបំប្លែងឲ្យទៅជា បំណែកណាមួយនៃផលិតផល ដែលស្ថាប័នមេនោះផលិតឡើយ។ បណ្តាសមាសភាគខាងក្រោមនេះ មិនត្រូវបានចាត់ទុកជាសមាសភាគចំណុះទេ ប៉ុន្តែគួរចាត់ទុកថាជាគ្រឹះស្ថានដាច់ដោយឡែក សម្រាប់ធ្វើចំណាត់ថ្នាក់ទៅតាមសកម្មភាពសេដ្ឋកិច្ចរបស់គ្រឹះស្ថានទាំងនោះ ប្រសិនបើទិន្នន័យនៃសកម្មភាពរបស់អង្គភាពទាំងនេះ អាចស្វែងរកបាន។

១. ស្ថាប័នដែលផលិតទំនិញឬបំពេញការងារ ដែលជាផ្នែកមួយនៃការបង្កើតមូលធន

២. ស្ថាប័នដែលផលិតទំនិញ ឬសេវាកម្ម មិនត្រឹមតែសម្រាប់ការប្រើប្រាស់របស់ស្ថាប័នមេប៉ុណ្ណោះទេ តែថែមទាំងលក់ផលិតផលទាំងនោះមួយចំនួនធំទៅឲ្យស្ថាប័នដទៃទៀត និង

៣. ស្ថាប័នផលិតទំនិញ ដែលជាផ្នែកមួយនៃគ្រឿងបង្គុំ នៃផលិតផលសម្រេចរបស់ស្ថាប័នមេ ជាអាទិ៍ ការផលិតប្រអប់ កំប៉ុងឬវត្ថុស្រដៀងនេះ ។ល។ ដោយផ្នែកមួយនៃសហគ្រាស ដែលវេចខ្ចប់ផលិតផលផ្ទាល់របស់ខ្លួន។

ឧទាហរណ៍នៃសមាសភាគចំណុះនេះ មានដូចជា៖ ការិយាល័យរដ្ឋបាលកណ្តាល ឃ្លាំងស្តុកឥវ៉ាន់ យានដ្ឋាន ហាងជួសជុល ឬរោងចក្រផលិតអគ្គិសនី ដែលផ្គត់ផ្គង់ជាចម្បងឲ្យគ្រឹះស្ថានផ្សេងទៀត នៃសហគ្រាសតែមួយ។

ច) *សមាសភាគប្រភេទសហគ្រាស៖* គឺជានីតិបុគ្គល ឬបណ្តុំនៃនីតិបុគ្គល ដែលប្រតិបត្តិ និងគ្រប់គ្រងដោយផ្ទាល់ឬដោយប្រយោល នូវមុខងារចាំបាច់ទាំងអស់សម្រាប់ដំណើរការសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួន។ នីតិបុគ្គលអាចជា សាជីវកម្ម ក្រុមហ៊ុនសហភាគហ៊ុន សហករណ៍ ស្ថាប័នមិនរកប្រាក់ចំណេញ ក្រុមហ៊ុនឯកកម្មសិទ្ធិនិងប្រភេទនីតិបុគ្គលស្រដៀងនេះ។ រីឯបណ្តុំនៃនីតិបុគ្គលវិញ គឺជាក្រុមឬបណ្តុំនៃបណ្តាស្ថាប័ន ដែលស្ថិតក្រោមកម្មសិទ្ធិឬការគ្រប់គ្រង របស់ភាគីដែលមានគោលដៅផលប្រយោជន៍រួម។ ដូច្នេះ លក្ខខណ្ឌចម្បងរបស់សមាសភាគប្រភេទសហគ្រាសនេះ គឺថាត្រូវមានម្ចាស់កម្មសិទ្ធិតែមួយ ឬការគ្រប់គ្រងតែមួយ។ ថ្វីបើយ៉ាងនេះ សមាសភាគនេះអាចមានលក្ខណៈពហុសណ្ឋាន ទាំងខាងប្រភេទសកម្មភាពសេដ្ឋកិច្ច និងទាំងខាងទីតាំង ពោលគឺ អាចមានសកម្មភាពសេដ្ឋកិច្ចនិងទីតាំងច្រើន។

៤. វិធាននៃការធ្វើចំណាត់ថ្នាក់លើសមាសភាគស្ថិតិ

៤.១. វិធានទូទៅ

ជាទូទៅ ការធ្វើចំណាត់ថ្នាក់លើសមាសភាគស្ថិតិមួយ ត្រូវបានកំណត់ដោយសកម្មភាពចម្បងឬសំណុំនៃសកម្មភាពរបស់សមាសភាគស្ថិតិនោះ។ សកម្មភាពបន្ទាប់បន្សំរបស់សមាសភាគស្ថិតិ ពុំត្រូវបានយកមកពិចារណា ក្នុងការធ្វើចំណាត់ថ្នាក់នេះឡើយ។ សកម្មភាពចម្បងរបស់សមាសភាគស្ថិតិ ជាទូទៅអាចកំណត់បាន តាមរយៈមុខទំនិញឬប្រភេទសេវាកម្ម ដែលសមាសភាគនោះលក់ឬផ្គត់ផ្គង់ ទៅឲ្យសមាសភាគស្ថិតិផ្សេងទៀតឬអ្នកប្រើប្រាស់។ ទោះជាយ៉ាងនេះក្តី ដើម្បីធ្វើបំណែងចែកចំណាត់ថ្នាក់សកម្មភាពនៅក្នុង ច.ស.វ.ក គេគួរប្រើប្រាស់ សេចក្តីបរិយាយនិងពន្យល់អំពីលក្ខណៈ នៃកម្រិតថ្នាក់នីមួយៗរបស់ច.ស.វ.ក ដែលបានកំណត់ដោយផ្អែកតាមលក្ខណៈនៃ ផលិតផលសម្រេចដែលផលិតបាន(ធាតុចេញ) វត្ថុធាតុដើមដែលត្រូវបានប្រើសម្រាប់ផលិត(ធាតុចូល) និងដំណើរការផលិតកម្ម។ តាមទ្រឹស្តី សកម្មភាពចម្បងអាចត្រូវបានកំណត់ឡើង ដោយយោងតាមតម្លៃបន្ថែម នៃទំនិញឬសេវាកម្មដែលបានផ្គត់ផ្គង់។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង គេពិបាកយកព័ត៌មានអំពីតម្លៃបន្ថែមនេះណាស់។ ក្នុងករណីនេះ លក្ខខណ្ឌខាងក្រោមត្រូវបានយកមកប្រើជំនួសវិញ ដើម្បីកំណត់អំពីសកម្មភាពចម្បងរបស់សមាសភាគស្ថិតិ៖

(១) លក្ខខណ្ឌជំនួសផ្អែកតាមធាតុចេញ៖

១.១. ទំហំទឹកប្រាក់នៃផលិតផលដុល របស់សមាសភាគស្ថិតិ ទាំងជាប្រភេទទំនិញនិងសេវាកម្ម ដែលត្រូវគ្នានឹងបំណែងចែកចំណាត់ថ្នាក់របស់សកម្មភាពនីមួយៗ និង

១.២. ទំហំទឹកប្រាក់នៃការលក់ទំនិញឬសេវាកម្ម ដែលត្រូវគ្នានឹងបំណែងចែកចំណាត់ថ្នាក់របស់សកម្មភាពនីមួយៗ។

(២) លក្ខខណ្ឌជំនួសផ្អែកតាមធាតុចូល៖

២.១. ចំនួនប្រាក់ឈ្នួលនិងប្រាក់ខែសម្រាប់ចំណាយលើសកម្មភាពផ្សេងៗ

២.២. ចំនួនម៉ោងធ្វើការដែលសកម្មភាពនីមួយៗត្រូវការ និង

២.៣. ចំនួនបុគ្គលិកដែលប្រើប្រាស់សម្រាប់បំពេញសកម្មភាពនីមួយៗ។

៤.២. ការធ្វើចំណាត់ថ្នាក់ចំពោះស្ថាប័នដែលមានសកម្មភាពដាច់ពីគ្នាច្រើន

ប្រសិនស្ថាប័នមួយ ពាក់ព័ន្ធក្នុងប្រភេទសកម្មភាពដាច់ពីគ្នាច្រើន ដែលពុំអាចបែងចែកស្ថាប័ននោះ ឲ្យទៅជាសមាសភាគស្ថិតិដាច់ដោយឡែកពីគ្នាបាន (ឧ. ផលិតកម្មនំដុតត្រូវបានបញ្ចូលជាមួយផលិតកម្មនំសូកូឡា) នោះគេគួរចាត់ស្ថាប័នប្រភេទនេះ ឲ្យចូលក្នុងចំណាត់ថ្នាក់របស់ច.ស.វ.កមួយប្រភេទ ដែលលក្ខណៈរបស់វាមានតម្លៃបន្ថែមច្រើនបំផុត ដោយប្រើប្រាស់វិធីសាស្ត្រ "ពីកម្រិតខ្ពស់មកទាប"។ ក្នុងករណីនេះ គេត្រូវកំណត់ប្រភេទចំណាត់ថ្នាក់ដែលមានកម្រិតខ្ពស់បំផុត (លេខសម្គាល់ ១ ខ្ទង់) ឲ្យបានជាមុនសិន បន្ទាប់មកប្រភេទលេខសម្គាល់ ២ ខ្ទង់ (ផ្នែក) បន្តមកប្រភេទលេខសម្គាល់ ៣ ខ្ទង់ (ក្រុម) និងជាចុងក្រោយគឺលេខសម្គាល់ ៤ ខ្ទង់ និង ៥ ខ្ទង់។

៤.៣. ការធ្វើចំណាត់ថ្នាក់ចំពោះស្ថាប័នដែលមានខ្សែចង្វាក់ផលិតកម្មបញ្ឈរ

ខ្សែចង្វាក់ផលិតកម្មបញ្ឈរ កើតមានឡើងនៅពេលដែល ស្ថាប័នមួយបំពេញសកម្មភាពសម្រាប់រាល់ដំណាក់កាលនៃចង្វាក់ផលិតកម្ម ហើយធាតុចេញនៃដំណាក់កាលផលិតកម្មមួយ ក្លាយជាធាតុចូលនៃដំណាក់កាលផលិតកម្មបន្ទាប់។ ស្ថាប័នដែលមានខ្សែចង្វាក់ផលិតកម្មបែបនេះ គួរត្រូវបានធ្វើចំណាត់ថ្នាក់ ដោយផ្អែកតាមប្រភេទផលិតផលសម្រេចរបស់ស្ថាប័ននោះ លើកលែងតែក្នុងបរិបទមួយ ដែលតម្រូវឲ្យបំពេញលក្ខខណ្ឌផ្សេងទៀត។ ជាឧទាហរណ៍ ការធ្វើអាជីវកម្មយកដីឥដ្ឋ រួមជាមួយនឹងផលិតកម្មឥដ្ឋ ត្រូវបានចាត់ចូលក្នុងប្រភេទ«ផលិតកម្មឥដ្ឋ» រីឯការកាប់ឈើ រួមបញ្ចូលជាមួយនឹងការអារឈើ ត្រូវចាត់ចូលក្នុងប្រភេទ«ការអារឈើ»។

៤.៤. ការធ្វើចំណាត់ថ្នាក់ចំពោះស្ថាប័នផ្តល់សេវាជួសជុលនិងថែទាំ

ច.ស.វ.ក បានបង្កើតចំណាត់ថ្នាក់ដាច់ដោយឡែក ចំពោះសកម្មភាពជួសជុលគ្រប់ប្រភេទ។ ថ្វីបើយ៉ាងនេះ សកម្មភាពជួសជុលនិងថែទាំនេះ ពុំត្រូវបានចាត់ចូលទៅក្នុងចំណាត់ថ្នាក់តែមួយប្រភេទនោះឡើយ។ ពោលគឺ សកម្មភាពទាំងនេះត្រូវបានធ្វើចំណាត់ថ្នាក់ ដោយផ្អែកលើប្រភេទនៃឧបករណ៍ ដែលត្រូវជួសជុលឬថែទាំ ដូចជា៖ (១)ការជួសជុលរថយន្ត និងម៉ូតូ ត្រូវបានចាត់ចូលក្នុងកម្រិតថ្នាក់ ៤៥២០ និង ៤៥៤០ រៀងគ្នា (២)ការជួសជុលកុំព្យូទ័រ និងឧបករណ៍ខាងទូរគមនាគមន៍ ត្រូវបានចាត់ចូលក្នុងកម្រិតក្រុម ៩៥១ (៣)ការជួសជុលរបស់របរប្រើប្រាស់ក្នុងផ្ទះនិងផ្ទាល់ខ្លួន ត្រូវបានចាត់ចូលក្នុងកម្រិតក្រុម ៩៥២ (៤)ការជួសជុលគ្រឿងម៉ាស៊ីននិងបរិក្ខារផ្សេងទៀត ត្រូវបានចាត់ចូលក្នុងកម្រិតក្រុម ៣៣១ និង (៥)ការជួសជុលអគារនិងប្រភេទសំណង់ដទៃទៀត ត្រូវបានចាត់ចូលក្នុងកម្រិតផ្នែក ៤៣។

៥. រចនាសម្ព័ន្ធ និងប្រព័ន្ធដាក់លេខសម្គាល់

ច.ស.វ.អ កំណែ៤ របស់អង្គការសហប្រជាជាតិ កាន់តែមានលក្ខណៈលម្អិតជាង ច.ស.វ.អ កំណែ៣។ ប្រភេទចំណាត់ថ្នាក់ដែលមានកម្រិតខ្ពស់(កម្រិត«ជំពូក»)ជាច្រើន ត្រូវបានបង្កើតឡើង ពិសេសសម្រាប់សកម្មភាពប្រភេទសេវាកម្ម។ ការប្រើប្រាស់តួអក្សរសម្រាប់សម្គាល់«ជំពូក» ត្រូវបានរក្សាទុកដដែល ដើម្បីចៀសវាងការកែប្រែរចនាសម្ព័ន្ធលេខសម្គាល់របស់ច.ស.វ.ក។

ការបំបែកប្រភេទចំណាត់ថ្នាក់ឲ្យមាន ៥ កម្រិត ត្រូវបានរក្សាទុកដដែលនៅក្នុងច.ស.វ.ក។ កម្រិតទី១នៃការបំបែកនេះ ត្រូវបានហៅថា«ជំពូក»។ កម្រិតជំពូកត្រូវបានតាងដោយតួអក្សរ រីឯកម្រិតចំណាត់ថ្នាក់ផ្សេងទៀត ត្រូវបានតាងដោយលេខ ដែលគេអាចអានបានដូចតទៅ៖ ខ្ទង់ទី១និងទី២នៃលេខសម្គាល់ បញ្ជាក់អំពីកម្រិត«ផ្នែក»របស់ចំណាត់ថ្នាក់, លេខបីខ្ទង់ដំបូងបញ្ជាក់អំពីកម្រិត«ក្រុម» លេខបួនខ្ទង់ដំបូងបញ្ជាក់អំពីកម្រិត«ថ្នាក់» ហើយលេខទាំងប្រាំខ្ទង់បញ្ជាក់អំពីកម្រិត«ថ្នាក់

វង»នៃចំណាត់ថ្នាក់។ ឯកសារ ច.ស.វ.ក កំណែ២ បោះពុម្ពលើកទី២ ឆ្នាំ២០២៣ ៖ ត្រូវបានចាត់ថ្នាក់ជា ២១ ជំពូក (ចាប់ពីអក្សរ **ក** រហូតដល់ អក្សរ **ប**) ៨៩ ផ្នែក ២៣៧ ក្រុម ៤៦០ ថ្នាក់ និងថ្នាក់រងចំនួន ៨៦៦ ។ ឋានានុក្រម នៃចំណាត់ថ្នាក់គឺ៖ ជំពូក ផ្នែក ក្រុម ថ្នាក់ និងថ្នាក់រង។

ជំពូក ក ៖ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

កម្រិត	ច.ស.វ.ក
ជំពូក	១
ផ្នែក	៣
ក្រុម	១២
ថ្នាក់	៣៦
ថ្នាក់រង	១០៨

ជំពូកនេះរាប់បញ្ចូលការធ្វើអាជីវកម្មធនធានធម្មជាតិ មានបន្លែនិងសត្វ ដែលរួមមាន៖ សកម្មភាពនៃការដាំដុះដំណាំ ការចិញ្ចឹម និងការបង្កាត់ពូជសត្វ ការប្រមូលផលព្រៃឈើ និងរុក្ខជាតិផ្សេងៗ និងផលិតផលសត្វឬសត្វ ពីកសិដ្ឋានឬពីជម្រកធម្មជាតិ។

ជំពូកនេះរាប់បញ្ចូលផងដែរនូវ ផលិតកម្មសត្វនិងដំណាំ ការប្រមាញ់ និងសកម្មភាព សេវាកម្មដែលទាក់ទងនឹងរុក្ខកម្មនិងការកាប់ឈើ។

ផ្នែក ០១ ៖ ផលិតកម្មដំណាំ និងសត្វ ការប្រមាញ់ និងសកម្មភាពសេវាកម្មដែលទាក់ទង

ផ្នែកនេះរាប់បញ្ចូលសកម្មភាពចម្បងចំនួនពីរ គឺផលិតកម្មនៃផលិតផលដំណាំ និងផលិតកម្មនៃផលិតផលសត្វ ទាំងជាទម្រង់សរីរាង្គ និងទម្រង់បង្កាត់ពូជតាមហ្សេណេទិច។

ផ្នែកនេះរាប់បញ្ចូលផងដែរ នូវសកម្មភាពសេវាកម្មបន្ទាប់បន្សំ ទាំងសម្រាប់កសិកម្ម ការប្រមាញ់ និងសម្រាប់ការដាក់អន្ទាក់ និងសកម្មភាពដែលទាក់ទង។

សកម្មភាពកសិកម្មមិនរាប់បញ្ចូលនូវ ការកែច្នៃផលិតផលកសិកម្ម ដែលត្រូវបានចាត់ថ្នាក់នៅក្នុងផ្នែក ១០ និង ១១ (ការផលិតផលិតផលម្ហូបអាហារ និងភេសជ្ជៈ) និងផ្នែក ១២ (ការផលិតផលិតផលថ្នាំជក់) ពេលគឺហួសពីការងាររៀបចំផលិតផលសម្រាប់លក់លើទីផ្សារបឋម។ ទោះជាយ៉ាងនេះក្តីការរៀបចំផលិតផលសម្រាប់លក់លើទីផ្សារបឋមត្រូវបានរាប់បញ្ចូលក្នុងផ្នែកនេះ។

ផ្នែកនេះមិនរាប់បញ្ចូលការស្ថាបនាទីកសិដ្ឋាន (ឧ.៖ ការពង្រាបដីកសិកម្ម ការធ្វើប្រព័ន្ធធារាសាស្ត្រ ការរៀបចំស្រែ។ល។) ដែលត្រូវបានចាត់ថ្នាក់ក្នុងជំពូក«ច» (សំណង់) និងមិនរាប់បញ្ចូលអ្នកទិញនិងសមាគមកសិករ ដែលពាក់ព័ន្ធនឹងសកម្មភាពរកទីផ្សារសម្រាប់ផលិតផលកសិដ្ឋាន ដូចបានចាត់ថ្នាក់ក្នុងជំពូក«ឆ»។

ក្រុម ០១១ ៖ ការដាំដុះដំណាំរយៈពេលខ្លី

ក្រុមនេះរាប់បញ្ចូលនូវការដាំដុះដំណាំអាយុកាលខ្លី ពោលគឺដំណាំដែលអាចនៅរស់មិនលើសពី ២ រដូវដាំដុះ។ ការដាំដុះដំណាំទាំងនេះសម្រាប់ធ្វើពូជ ក៏ត្រូវបានរាប់បញ្ចូលក្នុងក្រុមនេះផងដែរ។

ក្រុម ០១២ ៖ ការដាំដុះដំណាំអចិន្ត្រៃយ៍

ក្រុមនេះរាប់បញ្ចូលនូវការដាំដុះដំណាំ**អចិន្ត្រៃយ៍** ពោលគឺដំណាំដែលអាចនៅរស់លើសពី ២ រដូវដាំដុះ មិនថាងាប់ហើយដុះឡើងវិញនៅរដូវនីមួយៗ ឬបន្តដុះជាលជាជរាបនោះឡើយ។ ការដាំដុះដំណាំទាំងនេះសម្រាប់ធ្វើពូជ ក៏ត្រូវបានរាប់បញ្ចូលក្នុងក្រុមនេះដែរ។

ក្រុម ០១៣ ៖ ការបណ្តុះរុក្ខជាតិ

ក្រុមនេះរាប់បញ្ចូល នូវផលិតកម្មរុក្ខជាតុដើមមានជីវិតប្រើសម្រាប់ដាំដុះ រួមមានដូចជា កំណាត់រុក្ខជាតិ ខ្នែងរុក្ខជាតិ និងពន្លករុក្ខជាតិ ដែលត្រូវបានប្រើប្រាស់សម្រាប់បណ្តុះរុក្ខជាតិដោយផ្ទាល់ ឬសម្រាប់បំបៅលើមែករុក្ខជាតិដើម្បីដាំដុះសំដៅផលិតចេញជាដំណាំ។

ក្រុម ០១៤ ៖ ផលិតកម្មសត្វ

ក្រុមនេះរាប់បញ្ចូលការចិញ្ចឹម (ការធ្វើកសិដ្ឋាន) និងការបង្កាត់ពូជសត្វគ្រប់ប្រភេទ លើកលែងសត្វទឹក។

ក្រុមនេះមិនរាប់បញ្ចូលសេវាកម្មគាំទ្រការបង្កាត់ពូជដូចជា៖ សេវាកម្មដាក់បាបង្កាត់(មើល ០១៦២) ការថែរក្សានិងការឲ្យចំណីដល់សត្វកសិដ្ឋាន(មើល ០១៦២) និងផលិតកម្មស្បែកសត្វពីទីសត្តឃាត(មើល ១០១០)។

ក្រុម ០១៦ ៖ សកម្មភាពគាំទ្រ ដល់កសិកម្មនិងការងារក្រោយប្រមូលផលដំណាំ

ក្រុមនេះរាប់បញ្ចូល នូវសកម្មភាពបន្ទាប់បន្សំ សម្រាប់គាំទ្រដល់ផលិតកម្មកសិកម្ម និងសកម្មភាពស្រដៀងគ្នានឹងកសិកម្ម ដែលមិនមានគោលបំណងខាងផលិតកម្ម (បានដល់កិច្ចការប្រមូលផលផលិតផលកសិកម្ម) ប្រព្រឹត្តិឡើងទាំងក្រោមទម្រង់ជាការបង់តម្លៃឈ្នួលដាក់ស្តែង ឬតាមកិច្ចសន្យា។ សកម្មភាពក្រោយប្រមូលផលដំណាំ ដែលមានគោលបំណងរៀបចំផលិតផលកសិកម្ម សម្រាប់លក់លើទីផ្សារបឋម ក៏ត្រូវបានចាត់ចូលក្នុងក្រុមនេះដែរ។

ក្រុម ០១៧ ៖ ការប្រមាញ់ ការដាក់អន្ទាក់ និងសកម្មភាពសេវាកម្មដែលទាក់ទង

ក្រុមនេះរាប់បញ្ចូលនូវ៖ ការប្រមាញ់ និងការដាក់អន្ទាក់សត្វសម្រាប់អាជីវកម្ម ការចាប់សត្វ (ស្លាប់ ឬរស់) សម្រាប់ជាអាហារ យករោម យកស្បែក ឬប្រើនៅក្នុងការស្រាវជ្រាវ ដាក់នៅក្នុងសួនសត្វ ឬធ្វើជាសត្វចិញ្ចឹម និងផលិតកម្មស្បែកសត្វល្មូន ឬរោមសត្វស្លាប តាមរយៈសកម្មភាពប្រមាញ់ ឬដាក់អន្ទាក់។

ជំពូក ក ៖ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ផ្នែក ០១ ៖ ផលិតកម្មដំណាំនិងសត្វ ការប្រមាញ់ និងសកម្មភាពដែលទាក់ទង

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
០១១			**ការដាំដុះដំណាំរយៈពេលខ្លី**
	០១១១(១)		ការដាំដុះដំណាំធញ្ញជាតិ (លើកលែងស្រូវ) ដំណាំសណ្តែកបន្លែ និងដំណាំសណ្តែកប្រេង
		០១១១១	ការដាំដុះដំណាំពោត
		០១១១២	ការដាំដុះដំណាំសណ្តែកបន្លែ(២)
		០១១១៣	ការដាំដុះដំណាំសណ្តែកប្រេង(៣)
		០១១១៤	ការដាំដុះដំណាំសណ្តែកប្រេង(៣)
		០១១១៩	ការដាំដុះដំណាំធញ្ញជាតិដទៃទៀត ដែលពុំបានរាប់បញ្ចូល
	០១១២(៤)		ការដាំដុះដំណាំស្រូវ
		០១១២០	ការដាំដុះដំណាំស្រូវ
	០១១៣(៥)		ការដាំដុះដំណាំបន្លែនិងដំណាំអម្បូរត្រសក់ផ្អែម ដំណាំយកឫសនិងមើម
		០១១៣១	ការដាំដុះដំណាំបន្លែយកដើម និងស្លឹក(៦)
		០១១៣២	ការដាំដុះដំណាំបន្លែយកផ្លែ(៧)
		០១១៣៣	ការដាំដុះដំណាំអម្បូរត្រសក់ផ្អែម(៨)
		០១១៣៤	ការដាំដុះដំណាំផ្សិត
		០១១៣៥	ការដាំដុះដំណាំបន្លែគ្រាប់
		០១១៣៦	ការដាំដុះដំណាំបន្លែគ្រាប់ផ្សេងទៀត

		០១១៣៧	ការដាំដុះដំណាំយកឫស ឬមើម[៩]
	០១១៤		ការដាំដុះដំណាំអំពៅ
		០១១៤០	ការដាំដុះដំណាំអំពៅ

(១) **រាប់បញ្ចូល** ការដាំដុះដំណាំចម្រុះស្ថិតក្នុងផ្នែកកសិកម្ម
មិនរាប់បញ្ចូល ការដាំដុះដំណាំពោតសម្រាប់ចំណីសត្វ (មើល ០១១៩៩)។
(២) **រាប់បញ្ចូល** ការដាំដុះដំណាំសណ្តែកបារាំង សណ្តែកគួរ។ល។
(៣) **រាប់បញ្ចូល** ការដាំដុះដំណាំសណ្តែកសៀង សណ្តែកដី ល្ង ផ្កាឈូករ័ត្ន ពោតសម្រាប់ចំណីសត្វ ។ល។
(៤) **រាប់បញ្ចូល** ការដាំដុះដំណាំស្រូវ (ដំណើបនិងខ្សាយ) ប្រភេទសរីរាង្គ និងបង្កាត់ពូជតាមហ្សេណេទិច។
(៥) **មិនរាប់បញ្ចូល** ការដាំដុះ៖ (ក) មេផ្សិត (មើល ០១៣០៣), (ខ) ម្ទេសនិងគ្រឿងហិរផ្សេងទៀត និង ដំណាំក្រអូប (មើល ០១២៨)។
(៦) **រាប់បញ្ចូល** ការដាំដុះដំណាំទំពាំងបារាំង ស្ពៃក្តោប ស្ពៃចង្កឹះ សាឡាត់ ។ល។
(៧) **រាប់បញ្ចូល** ការដាំដុះដំណាំត្រសក់ ប៉េងប៉ោះ ។ល។
(៨) **រាប់បញ្ចូល** ការដាំដុះដំណាំឪឡឹក ត្រសក់ស្រូវ ។ល។
(៩) **រាប់បញ្ចូល** ការដាំដុះដំណាំដំឡូងមី ដំឡូងផ្អែម (ដំឡូងជ្វា ដំឡូងត។ល។) ការ៉ុត ខ្ទឹមស ក្តួចឬ ដំឡូងឈើផ្សេងទៀត ។ល។

ជំពូក ក ៖ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ផ្នែក ០១ ៖ ផលិតកម្មដំណាំនិងសត្វ ការប្រមាញ់ និងសកម្មភាពដែលទាក់ទង

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	០១១៥		ការដាំដុះដំណាំថ្នាំជក់
		០១១៥០	ការដាំដុះដំណាំថ្នាំជក់
	០១១៦[១]		ការដាំដុះដំណាំសរសៃ
		០១១៦០	ការដាំដុះដំណាំកប្បាស និងដំណាំសរសៃដទៃទៀត
	០១១៩[២]		ការដាំដុះដំណាំរយៈពេលខ្លីដទៃទៀត
		០១១៩១	ការដាំដុះដំណាំផ្កា រាប់ទាំងផលិតកម្មផ្កាដែលកាត់ពីដើម ក្រពុំផ្កា និងគ្រាប់ផ្កា
		០១១៩២	ការដាំដុះដំណាំសាគូ
		០១១៩៩	ការដាំដុះដំណាំរយៈពេលខ្លីដទៃទៀត ដែលពុំបានរាប់បញ្ចូល
០១២			ការដាំដុះដំណាំអចិន្ត្រៃយ៍
	០១២១		ការដាំដុះដំណាំទំពាំងបាយជូរ
		០១២១០	ការដាំដុះដំណាំទំពាំងបាយជូរ[៣]
	០១២២		ការដាំដុះដំណាំផ្លែឈើតំបន់ត្រូពិច និងអនុតំបន់ត្រូពិច
		០១២២១	ការដាំដុះដំណាំចេក
		០១២២២	ការដាំដុះដំណាំស្វាយ
		០១២២៣	ការដាំដុះដំណាំធុរេន
		០១២២៤	ការដាំដុះដំណាំសាវម៉ាវ
		០១២២៥	ការដាំដុះដំណាំមៀន
		០១២២៦	ការដាំដុះដំណាំល្ហុង
		០១២២៧	ការដាំដុះដំណាំម្នាស់
		០១២២៨	ការដាំដុះដំណាំស្រកានាគ

(១) **រាប់បញ្ចូល** (ក) ការដាំដុះកប្បាស
(ខ) ការដាំដុះក្រចៅ និងដំណាំសរសៃដទៃទៀតសម្រាប់ផលិតវាយនភណ្ឌ
(គ) ការដាំដុះដំណាំពពួកផ្ទៃសម្រាប់វេញជាខ្សែ

(ឃ) ការដាំដុះដំណាំដើម្បីយកជាងវេញជាខ្សែ (ឧ. ដើមស៊ីហ្សាល់) និងដំណាំសរសៃសម្រាប់ផលិតវាយនភណ្ឌដទៃទៀតក្នុងពពួកអាហ្គាវ (ប្រទាលម្យ៉ាង)
(ង) ការដាំដុះចេកអាបាកា និងដំណាំតំណជាតិប្រភេទសរសៃ (ឧ. ដើមរ៉ាមីយ៉េ) ដទៃទៀតសម្រាប់ផលិតវាំនភណ្ឌ
(ច) ការដាំដំណាំសរសៃដទៃទៀត។

(២) **មិនរាប់បញ្ចូល** ការដាំដុះរុក្ខជាតិគ្រឿងទេស រុក្ខជាតិយកក្លិន និងរុក្ខជាតិឱសថនិងថ្នាំពុល ដែលមានរយៈពេលខ្លី (មើល ០១២៨)។
(៣) **មិនរាប់បញ្ចូល** ការផលិតស្រា (មើល ១១០២)។

ជំពូក ក ៖ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ផ្នែក ០១ ៖ ផលិតកម្មដំណាំនិងសត្វ ការប្រមាញ់និងសកម្មភាពដែលទាក់ទង

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
		០១២២៩	ការដាំដុះផ្លែឈើតំបន់ត្រូពិច និងអនុតំបន់ត្រូពិចដទៃទៀត ដែលពុំបានរាប់បញ្ចូល (១)
	០១២៣		ការដាំដុះដំណាំក្រូច
		០១២៣១	ការដាំដុះក្រូចថ្លុង
		០១២៣២	ការដាំដុះក្រូចឆ្មារ
		០១២៣៣	ការដាំដុះក្រូចឃ្វិច និងក្រូចពោធិ៍សាត់
		០១២៣៩	ការដាំដុះដំណាំក្រូចដទៃទៀត ដែលពុំបានរាប់បញ្ចូល
	០១២៤		ការដាំដុះដំណាំហូបផ្លែ និងមានគ្រាប់
		០១២៤១	ការដាំដុះត្របែក
		០១២៤៩	ការដាំដុះដំណាំហូបផ្លែ និងមានគ្រាប់ដទៃទៀត ដែលពុំបានរាប់បញ្ចូល
	០១២៥[២]		ការដាំដុះដាំណាំហូបផ្លែនិងគ្រាប់ ប្រភេទដើមឈើនិងចុល្លព្រឹក្សដទៃទៀត
		០១២៥១	ការដាំដុះដំណាំហូបផ្លែ[៣]
		០១២៥២	ការដាំដុះដំណាំហូបគ្រាប់
		០១២៥៣	ការដាំដុះស្វាយចន្ទី និងគ្រាប់ផ្លែឈើដែលអាចហូបបានដទៃទៀត
		០១២៥៩	ការដាំដុះដំណាំហូបផ្លែ ប្រភេទដើមឈើនិងចុល្លព្រឹក្សដទៃទៀត[៤]
	០១២៦[៥]		ការដាំដុះដំណាំផ្លែដែលមានជាតិប្រេង
		០១២៦១	ការដាំដុះដំណាំដូងប្រេង (ចម្ការធំ និងចម្ការតូច)
		០១២៦២	ការដាំដុះដំណាំដូង (ចម្ការធំ និងចម្ការតូច)
	០១២៧		ការដាំដុះដំណាំសម្រាប់ផលិតភេសជ្ជៈ
		០១២៧១	ការដាំដុះដំណាំកាហ្វេ
		០១២៧២	ការដាំដុះដំណាំតែ
		០១២៧៣	ការដាំដុះដំណាំកាកាវ
		០១២៧៩	ការដាំដុះដំណាំសម្រាប់ផលិតភេសជ្ជៈដទៃទៀត ដែលពុំបានរាប់បញ្ចូល
	០១២៨		ការដាំដុះរុក្ខជាតិគ្រឿងទេស រុក្ខជាតិយកក្លិន និងរុក្ខជាតិឱសថនិងថ្នាំពុល
		០១២៨១	ការដាំដុះដំណាំម្រេច
		០១២៨២	ការដាំដុះដំណាំម្ទេស

(១) **រាប់បញ្ចូល** ល្មុត លាំងសាតគ្រប់ប្រភេទ ចម្ប៉ាដាក់ ខ្នុរ មង្ឃុត រកាំ សិរមាន់ ផ្លែប័រ ល្ហុង ។ល។
(២) **មិនរាប់បញ្ចូល** ការដាំដុះដំណាំដូង (មើល០១២៦៣)
(៣) **រាប់បញ្ចូល** ស្ត្របឺរី ប្លូបឺរី គីវី និងពពួកដំណាំហូបផ្លែ (សាច់ផ្លែ) ដទៃទៀត។
(៤) **រាប់បញ្ចូល** ការដាំដុះដំណាំសណ្តែកឡូកាស ។ល។

(៥) **មិនរាប់បញ្ចូល** ការដាំដុះសណ្តែកសៀង សណ្តែកដី និងសណ្តែកប្រេងដទៃទៀត (មើល ០១១១)។

ជំពូក ក ៖ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ផ្នែក ០១ ៖ ផលិតកម្មដំណាំនិងសត្វ ការប្រមាញ់និងសកម្មភាពដែលទាក់ទង

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
		០១២៨៣	ការដាំដុះដំណាំចន្ទន៍គ្រឹះស្នា
		០១២៨៤	ការដាំដុះដំណាំខ្ទឹ
		០១២៨៥	ការដាំដុះដំណាំរុក្ខជាតិប្រើជាចម្បងសម្រាប់ធ្វើទឹកអប់ ឱសថឬថ្នាំសម្លាប់សត្វល្អិត ថ្នាំសម្លាប់ផ្សិត ឬសម្រាប់គោលបំណងស្រដៀងគ្នា[១]
		០១២៨៩	ការដាំដុះរុក្ខជាតិគ្រឿងទេស និងរុក្ខជាតិយកក្លិនដទៃទៀត ដែលពុំបានរាប់បញ្ចូល[២]
	០១២៩		ការដាំដុះដំណាំ**អចិន្ត្រៃយ៍**ដទៃទៀត
		០១២៩១	ការដាំដុះដំណាំកៅស៊ូ (ចម្ការធំ)
		០១២៩២	ការដាំដុះដំណាំកៅស៊ូ (ចម្ការតូច)
		០១២៩៣	ការដាំដុះដំណាំដើមឈើដើម្បីដកយករុក្ខរស[៣]
		០១២៩៤	ការដាំដុះដំណាំដើមត្នោត
		០១២៩៥	ការដាំដុះដំណាំដើមស្លា
		០១២៩៦	ការដាំដុះដំណាំដើមរំហែល
		០១២៩៩	ការដាំដុះដំណាំអាយុកាលវែងដទៃទៀត ដែលពុំបានរាប់បញ្ចូល[៤]
០១៣			**ការបណ្តុះរុក្ខជាតិ**
	០១៣០[៥]		ការបណ្តុះរុក្ខជាតិ
		០១៣០១	ការបណ្តុះរុក្ខជាតិដោយគ្រាប់[៦]
		០១៣០២	ការបណ្តុះរុក្ខជាតិដោយវិធីសាស្ត្រដទៃទៀត[៧]

(១) **រាប់បញ្ចូល** ការដាំដុះស្លឹកគ្រៃ ស្លឹកតើយ ។ល។
មិនរាប់បញ្ចូល (ក) ការដាំដុះដំណាំដើមពុកមាត់ឆ្មា (មើល ០១២៨៩)
(ខ) ការដាំដុះដំណាំដើមអន្ទង់ស (មើល ០១២៨៩)។

(២) **មិនរាប់បញ្ចូល** (ក) ការដាំដុះដំណាំដើមពុកមាត់ឆ្មា
(ខ) ការដាំដុះដំណាំដើមអន្ទង់ស
(គ) ការដាំដុះដំណាំដើមអុបឆឹយ ដើមក្លាំពូ ។ល។

(៣) **មិនរាប់បញ្ចូល** ការប្រមូលយករុក្ខរសរបស់ដើមឈើ ឬជ័រឈើស្រដៀងនឹងជ័រកៅស៊ូពីក្នុងព្រៃ (មើល ០២៣០)។

(៤) **រាប់បញ្ចូល** (ក) ការដាំដុះដំណាំដើមស្រល់សាប៉ាំង (ដើមគ្រិស្មាស់)
(ខ) ការដាំដុះដំណាំរុក្ខជាតុដើមនៃប្រភេទស្រល់នេះ ប្រើជាចម្បងសម្រាប់ដាំដុះ។

(៥) **មិនរាប់បញ្ចូល** ការដាំដុះដំណាំរុក្ខជាតិសម្រាប់ផលិតកម្មគ្រាប់ពូជ (មើលក្រុម ០១១ និង ០១២)។

(៦) **រាប់បញ្ចូល** រុក្ខជាតិសម្រាប់តុបតែង និងស្មៅបន្សាំ។

(៧) **រាប់បញ្ចូល** ការដាំដុះដំណាំរុក្ខជាតិរស់ សម្រាប់យកគល់មើម មើមនិងឫស មែកនិងស្លឹក មេផ្សិត
មិនរាប់បញ្ចូល ដំណើរការនៃការថែទាំកូនឈើព្រៃ (មើល ០២១០៣)។

ជំពូក ក ៖ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ផ្នែក ០១ ៖ ផលិតកម្មដំណាំនិងសត្វ ការប្រមាញ់និងសកម្មភាពដែលទាក់ទង

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
០១៤			ផលិតកម្មសត្វ
	០១៤១[១]		ការចិញ្ចឹមគោ និងក្របី
		០១៤១១	ការចិញ្ចឹម ការបង្កាត់ពូជ និងផលិតកម្មគោនិងក្របី
		០១៤១២	ផលិតកម្មទឹកដោះគោស្រស់ពីគោឬក្របី
		០១៤១៣	ផលិតកម្មទឹកកាមគោឬក្របី
	០១៤២[២]		ការចិញ្ចឹមសេះ និងសត្វក្នុងអម្បូរដូចគ្នាដទៃទៀត
		០១៤២០	ការចិញ្ចឹម និងការបង្កាត់ពូជសេះ លា សេះទេស ឬលាទេស
	០១៤៤[៣]		ការចិញ្ចឹមចៀម និងពពែ
		០១៤៤១	ការចិញ្ចឹម ការបង្កាត់ពូជ និងផលិតកម្មចៀម និងពពែ
		០១៤៤២	ការផលិតទឹកដោះស្រស់របស់សត្វចៀម និងពពែ
	០១៤៥		ការចិញ្ចឹមជ្រូក
		០១៤៥០	ការចិញ្ចឹម ការបង្កាត់ពូជ និងផលិតកម្មជ្រូក
	០១៤៦[៤]		ការចិញ្ចឹមបសុបក្សី
		០១៤៦១	ការចិញ្ចឹម ការបង្កាត់ពូជ និងផលិតកម្មកូនមាន់ និងមាន់សម្រាប់យកសាច់
		០១៤៦២	ការចិញ្ចឹម ការបង្កាត់ពូជ និងផលិតកម្មទា
		០១៤៦៣	ការចិញ្ចឹម ការបង្កាត់ពូជ និងផលិតកម្មក្ងាន
		០១៤៦៤	ការចិញ្ចឹម ការបង្កាត់ពូជបសុបក្សីដទៃទៀត ដែលពុំបានរាប់បញ្ចូល
		០១៤៦៥	ផលិតកម្មស៊ុតមាន់
		០១៤៦៦	ផលិតកម្មស៊ុតទា
		០១៤៦៩	ផលិតកម្មស៊ុតបសុបក្សីដទៃទៀត ដែលពុំបានរាប់បញ្ចូល

(១) **មិនរាប់បញ្ចូល** ការកែច្នៃទឹកដោះ (មើល ១០៥០)។
(២) **រាប់បញ្ចូល** សេះប្រណាំង
មិនរាប់បញ្ចូល ដំណើរការនៃការប្រណាំង និងការជិះសេះ (មើល ៩៣១៩)។
(៣) **មិនរាប់បញ្ចូល** ការកែច្នៃទឹកដោះ (មើល ១០៥០)។
(៤) **មិនរាប់បញ្ចូល** ផលិតកម្មស្លាបសត្វ ឬរោមសត្វ (មើល ១០១០)។
(៥) **រាប់បញ្ចូល** ការចិញ្ចឹម និងការបង្កាត់ពូជត្រចៀកកាំ។

ជំពូក ក ៖ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ផ្នែក ០១ ៖ ផលិតកម្មដំណាំនិងសត្វ ការប្រមាញ់និងសកម្មភាពដែលទាក់ទង

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	០១៤៩[១]		ការចិញ្ចឹមសត្វប្រភេទដទៃទៀត
		០១៤៩១	ដំណើរការកន្លែងចិញ្ចឹមសិប្បីសត្វ ដូចជា ខ្យង។ល។
		០១៤៩២	ការចិញ្ចឹមដង្កូវនាង និងផលិតកម្មសម្បុកដង្កូវនាង
		០១៤៩៣	ការចិញ្ចឹមឃ្មុំ និងផលិតកម្មទឹកឃ្មុំនិងក្រមួនឃ្មុំ
		០១៤៩៩	ការចិញ្ចឹមសត្វដទៃទៀត រាប់ទាំងសត្វប្លែកៗ និងសត្វមានជីវិតដទៃទៀត[២]
០១៦			**សកម្មភាពគាំទ្រ ដល់កសិកម្មនិងការងារក្រោយប្រមូលផលដំណាំ**
	០១៦១[៣]		សកម្មភាពគាំទ្រដល់ផលិតកម្មដំណាំ
		០១៦១០	សកម្មភាពកសិកម្មតាមការបង់ថ្លៃឈ្នួលដាក់ស្តែង ឬតាមកិច្ចសន្យា[៤]

(១) **មិនរាប់បញ្ចូល**
(ក) ផលិតកម្មស្បែកដែលបានមកពីការប្រមាញ់ និងការដាក់អន្ទាក់ (មើល០១៧០)
(ខ) ការដំណើរការកន្លែងចិញ្ចឹមកង្កែប កន្លែងចិញ្ចឹមក្រពើ កន្លែងចិញ្ចឹមឈ្លើងសមុទ្រ (មើល ០៣២២៥, ០៣២៣២, ០៣២១៩)
(គ) ការដំណើរការកន្លែងចិញ្ចឹមត្រី (មើល ០៣២១១,០៣២២១)
(ឃ) ការបង្ហឹកសត្វចិញ្ចឹមកម្សាន្ត (មើល៩៦០៩៤)

(២) **រាប់បញ្ចូល** បក្សីអ៊ីមូស សត្វល្អិត ទន្សាយ និងសត្វដែលមានរោមដទៃទៀត។

(៣) **មិនរាប់បញ្ចូល**
(ក) សកម្មភាពក្រោយពេលប្រមូលផលដំណាំកសិកម្ម (មើល ០១៦៣)
(ខ) សកម្មភាពរបស់ក្សេត្រវិទូ និងសេដ្ឋវិទូកសិកម្ម (មើល ៧៤៩០០)
(គ) ការថែរក្សាដីដើម្បីឲ្យនៅមានសភាពជីវចម្រុះល្អប្រសើរ (មើល ៨១៣០០)
(ឃ) ការរៀបចំតាំងបង្ហាញ ឬពិព័រណ៍ផលិតផលកសិកម្ម (មើល ៨២៣០០)

(៤) **រាប់បញ្ចូល**
(ក) ការរៀបចំទីកសិកម្ម ការប្រមូលផល ការគ្រប់គ្រងកត្តាចង្រៃបំផ្លាញដំណាំ (រួមទាំងទន្សាយ) ដែលពាក់ព័ន្ធនឹងកសិកម្ម ។ល។
(ខ) ការដំណើរការឧបករណ៍ស្រោចស្រព ដែលពាក់ព័ន្ធនឹងកសិកម្ម
(គ) ការថែទាំដីដើម្បីឲ្យនៅមានសភាពល្អ សម្រាប់ការងារកសិកម្ម។

ជំពូក ក ៖ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ផ្នែក ០១ ៖ ផលិតកម្មដំណាំនិងសត្វ ការប្រមាញ់និងសកម្មភាពដែលទាក់ទង

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	០១៦២[១]		សកម្មភាពគាំទ្រដល់ផលិតកម្មសត្វ
		០១៦២០	សកម្មភាពគាំទ្រដល់ផលិតកម្មសត្វ តាមការបង់ថ្លៃឈ្នួលជាក់ស្តែង ឬតាមកិច្ចសន្យា[២]
	០១៦៣[៣]		សកម្មភាពក្រោយប្រមូលផលដំណាំ
		០១៦៣០	ការរៀបចំផលដំណាំសម្រាប់ទីផ្សារ បន្ទាប់ពីប្រមូលផលរួច[៤]
	០១៦៤[៥]		ការកែច្នៃគ្រាប់ពូជសម្រាប់បណ្តុះ
		០១៦៤០	ការកែច្នៃគ្រាប់ពូជសម្រាប់បណ្តុះ

(១) **រាប់បញ្ចូល**
- (ក) សកម្មភាពរបស់ជាងផលិតទ្រនាប់ជើងសេះ (អ្នកជំនាញខាងថែក្រចកជើងសេះ)
- (ខ) សកម្មភាពផ្តល់ចំណីក្នុងកន្លែងចិញ្ចឹមសត្វ ដោយគ្មានការថែរក្សាសុខភាព
- (គ) សកម្មភាពសាកល្បងមកលើហ្វូងសត្វ សកម្មភាពកៀងហ្វូងគោ សកម្មភាពចិញ្ចឹមគោ និងសកម្មភាពគ្រៀវបសុបក្សី
- (ឃ) សកម្មភាពទាក់ទងនឹងការបង្កាត់ពូជបែបសិប្បនិម្មិត

មិនរាប់បញ្ចូល
- (ក) ការបែងចែងទីធ្លាសម្រាប់តែការផ្តល់ចំណីសត្វតែម្យ៉ាង (មើល ៦៨១០១)
- (ខ) សកម្មភាពរបស់ពេទ្យសត្វ (មើល ៧៥០០)
- (គ) ការចាក់ថ្នាំបង្ការជំងឺឲ្យសត្វ (មើល ៧៥០០)
- (ឃ) ការជួលសត្វ (ឧ. ជួលជាហ្វូង) (មើល ៧៧៣០)
- (ង) សកម្មភាពសេវាដើម្បីជំរុញឲ្យមានការប្រមាញ់និងការដាក់អន្ទាក់ សម្រាប់ធ្វើពាណិជ្ជកម្ម (មើល ៩៣១៩៩)
- (ច) ការផ្តល់ចំណីឲ្យសត្វចិញ្ចឹម (មើល ៩៦០៩៤)។

(២) **រាប់បញ្ចូល**
- (ក) សកម្មភាពដើម្បីជំរុញឲ្យមានការបង្កាត់/ផ្សាំ ការលូតលាស់ ទទួលទិន្នន័យពីសត្វ
- (ខ) សកម្មភាពទាក់ទងទៅនឹងការបង្កាត់ពូជបែបសិប្បនិម្មិត
- (គ) សកម្មភាពផ្តល់ចំណីក្នុងកន្លែងចិញ្ចឹមសត្វ ដោយគ្មានការថែរក្សាសុខភាព
- (ឃ) សកម្មភាពសាកល្បងមកលើហ្វូងសត្វ សកម្មភាពកៀងហ្វូងគោ សកម្មភាពចិញ្ចឹមគោ និងសកម្មភាពគ្រៀវបសុបក្សី។

(៣) **មិនរាប់បញ្ចូល**
- (ក) ការរៀបចំផលិតផលកសិកម្មរបស់អ្នកផលិត (មើលក្រុម ០១១ និង ០១២)
- (ខ) ការរក្សាផ្លែឈើនិងបន្លែ រួមមានការសម្ងួតយកទឹកចេញដោយប្រើមធ្យោបាយសិប្បនិម្មិត (មើល ១០៣០)
- (គ) ការចំហុយ និងការសម្ងួតថ្នាំជក់ (មើល ១២០០)
- (ឃ) សកម្មភាពផ្នែកទីផ្សារ សម្រាប់អ្នកជំនួញរកកម្រៃជើងសា និងសហកណ៍ (មើលផ្នែក ៤៦)
- (ង) ការលក់ដុំនូវវត្ថុធាតុដើមកសិកម្ម (មើល ៤៦២០)។

(៤) **រាប់បញ្ចូល** ការសម្អាត ការកាត់តម្រឹម ការបែងចែកគុណភាព ការសម្លាប់មេរោគ ការយកគ្រាប់កប្បាសចេញ។

(៥) **រាប់បញ្ចូល**
- (ក) សកម្មភាពក្រោយប្រមូលផលដំណាំទាំងអស់ ដែលមានគោលបំណងបង្កើនគុណភាពផ្នែកបង្កាត់/ផ្សាំ គ្រាប់ពូជ ដោយការយកវត្ថុធាតុដើមដែលមិនមែនជាគ្រាប់ពូជចេញ គ្រាប់ពូជតូចខុសខ្នាត គ្រាប់ពូជដែលរងការខូចខាតដោយសារបច្ចេកទេស ឬ

ដោយសារសត្វល្អិត និងគ្រាប់ពូជដែលមិនទាន់ពេញវ័យ និងធ្វើឲ្យកម្រិតសំណើមរបស់គ្រាប់ពូជឲ្យដល់កម្រិតមួយដែលមានសុវត្ថិភាពសម្រាប់ការរក្សាទុកគ្រាប់ពូជ

(ខ) ការសម្ងួត ការសម្អាត ការបែងចែកគុណភាព និងការព្យាបាលគ្រាប់ពូជរហូតដល់ពេលនាំគ្រាប់ពូជយកទៅលក់ក្នុងទីផ្សារ

(គ) ការព្យាបាលគ្រាប់ពូជដែលឆ្លងកាត់ការបង្កាត់ពូជ

មិនរាប់បញ្ចូល

(ក) ការបណ្តុះគ្រាប់ពូជ (មើលក្រុម ០១១ និង ០១២)

(ខ) ដំណើរការចម្រាញ់គ្រាប់ពូជដើម្បីយកប្រេង (មើល ១០៤១)

(គ) ការស្រាវជ្រាវដើម្បីអភិវឌ្ឍ ឬកែច្នៃគ្រាប់ពូជបែបថ្មី (មើល ៧២១០)។

ជំពូក ក ៖ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ផ្នែក ០១ ៖ ផលិតកម្មដំណាំនិងសត្វ ការប្រមាញ់និងសកម្មភាពដែលទាក់ទង

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
០១៧			**ការប្រមាញ់ ការដាក់អន្ទាក់ និងសកម្មភាពសេវាកម្មដែលទាក់ទង**
	០១៧០[១]		ការប្រមាញ់ ការដាក់អន្ទាក់ និងសកម្មភាពសេវាកម្មដែលទាក់ទង
		០១៧០០	ការប្រមាញ់ ការដាក់អន្ទាក់ និងសកម្មភាពសេវាកម្មដែលទាក់ទង

(១) **រាប់បញ្ចូល** ផលិតកម្មស្បែកដែលបានមកពីការប្រមាញ់ និងការដាក់អន្ទាក់

មិនរាប់បញ្ចូល
- (ក) ផលិតកម្មស្បែករោមសត្វ ស្បែកសត្វលូនឬបក្សី ដែលបានមកពីការធ្វើកសិដ្ឋាន (មើល ០១៤៩)
- (ខ) ការចិញ្ចឹមសត្វសម្រាប់ប្រើក្នុងការលេងល្បែង ដែលបានមកពីការធ្វើកសិដ្ឋាន (មើល ០១៤៩)
- (គ) ការចាប់ត្រីបាឡែន (មើល ០៣១១)
- (ឃ) ផលិតកម្មស្បែកដែលបានមកពីកន្លែងសត្តឃាត (មើល ១០១០)
- (ង) ការប្រមាញ់សម្រាប់សកម្មភាពកីឡា ឬកម្សាន្ត និងសកម្មភាពដែលទាក់ទង (មើល ៩៣១៩៩)
- (ច) សកម្មភាពដើម្បីជំរុញឲ្យមានការប្រមាញ់ និងការដាក់អន្ទាក់ (មើល ៩៣១៩៩)។

ផ្នែក ០២ ៖ រុក្ខកម្ម និងការកាប់ឈើ

ផ្នែកនេះរាប់បញ្ចូលទាំង ផលិតកម្មឈើមូលសម្រាប់ផ្គត់ផ្គង់ដល់ឧស្សាហកម្មកែច្នៃឈើ (ផ្នែក ១៦ និង ១៧ នៃច.ស.វ.ម) និងអាជីវកម្មនិងការប្រមូលនូវអនុផលព្រៃឈើ។ ក្រៅពីផលិតកម្មឈើហុប សកម្មភាពរុក្ខកម្មបង្កើតចេញជាផលិតផលដែលឆ្លងកាត់ដំណើរការកែច្នៃតិចតួច ដូចជា អុសដុត ធ្យូងឈើ កំណាត់ឈើ និងឈើមូលប្រើប្រាស់ក្នុងទម្រង់មិនកែច្នៃ (ឧ. ឈើរណែងឬចន្ទល់ ឈើសម្រាប់ផលិតក្រដាស ។ល។)។ សកម្មភាពរុក្ខកម្មនេះអាចត្រូវបានធ្វើឡើងនៅក្នុងព្រៃធម្មជាតិ ឬព្រៃដែលមនុស្សដាំ។

ក្រុម ០២១ ៖ វនវប្បកម្ម និងសកម្មភាពរុក្ខកម្មដទៃទៀត

ក្រុមនេះរាប់បញ្ចូលសកម្មភាពដាំដុះដើមឈើឈរ ដូចជា៖ ការដាំ ការដាំឡើងវិញ ការផ្សាំ ការរំលែក(កុំឲ្យក្រាស់ពេក) និងការអភិរក្ស នូវព្រៃឈើនិងដើមឈើ ការដាំព្រៃគុម្ពោត ឈើសម្រាប់ផលិតក្រដាស និងឈើអុសដុត និងដំណើរការបណ្តុះកូនឈើ។ សកម្មភាពទាំងនេះ អាចត្រូវបានធ្វើឡើងនៅក្នុងព្រៃធម្មជាតិ ឬព្រៃដែលមនុស្សដាំ។

ក្រុម ០២២ ៖ ការកាប់ឈើ

ក្រុមនេះរាប់បញ្ចូលនូវ៖ ផលិតកម្មឈើមូលសម្រាប់ផ្គត់ផ្គង់ដល់ឧស្សាហកម្មកែច្នៃឈើ, ផលិតកម្មឈើមូលប្រើប្រាស់ក្នុងទម្រង់មិនកែច្នៃ (ដូចជា ឈើរណែងឬចន្ទល់ ឈើរបង ឈើបង្គោល) ការប្រមូលនិងផលិតកម្មអុសដុត និងផលិតកម្មធ្យូងឈើដែលធ្វើឡើងនៅក្នុងព្រៃ (ដោយប្រើវិធីសាស្ត្របែបបុរាណ)។ ផលិតផលដែលកើតចេញពីសកម្មភាពទាំងនេះ អាចមានទម្រង់ជាឈើហុប កំណាត់ឈើ ឬអុសដុត។

ក្រុម ០២៣ ៖ ការប្រមូលអនុផលព្រៃឈើ

ក្រុមនេះរាប់បញ្ចូលការប្រមូលយកផលពីព្រៃឈើ (ដែលផលនោះមិនមែនជាដើមឈើ) និងរុក្ខជាតិដទៃទៀតដែលដុះក្នុងព្រៃ។

ក្រុម ០២៤ ៖ សេវាកម្មគាំទ្រដល់សកម្មភាពរុក្ខកម្ម

ក្រុមនេះរាប់បញ្ចូលនូវការអនុវត្តសកម្មភាព ដែលជាចំណែកនៃសកម្មភាពរុក្ខកម្ម ដោយផ្អែកតាមការបង់ថ្លៃឈ្នួលជាក់ស្តែង ឬតាមកិច្ចសន្យា។

ជំពូក ក ៖ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ផ្នែក ០២ ៖ រុក្ខកម្ម និងការកាប់ឈើ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
០២១			វនវប្បកម្ម និងសកម្មភាពរុក្ខកម្មដទៃទៀត
	០២១០[១]		វនវប្បកម្ម និងសកម្មភាពរុក្ខកម្មដទៃទៀត
		០២១០០	ការដាំព្រៃឈើរាប់បញ្ចូលទាំងការដាំដុះដើមឈើ[២]
០២២			ការកាប់ឈើ
	០២២០[៣]		ការកាប់ឈើ
		០២២០០	ការកាប់ឈើ
០២៣			ការប្រមូលអនុផលព្រៃឈើ
	០២៣០[៤]		ការប្រមូលអនុផលព្រៃឈើ
		០២៣០០	ការប្រមូលអនុផលព្រៃឈើ[៥]
០២៤			សេវាកម្មគាំទ្រដល់សកម្មភាពរុក្ខកម្ម
	០២៤០[៦]		សេវាកម្មគាំទ្រដល់សកម្មភាពរុក្ខកម្ម
		០២៤០០	សេវាកម្មគាំទ្រដល់សកម្មភាពរុក្ខកម្ម[៧]

(១) **មិនរាប់បញ្ចូល**
(ក) ការដាំដុះដើមស្រល់សាប៉ាំង ឬដើមគ្រិស្មាស់ (មើល ០១២៩៩)
(ខ) ការប្រមូលអនុផលព្រៃឈើធម្មជាតិ (មើល ០២៣០)
(គ) ផលិតកម្មកំណាត់ឈើ និងបន្ទះឈើ (មើល ១៦១០)។

(២) **រាប់បញ្ចូល**
(ក) ការដាំដុះដើមឈើបន្ថែម សម្រាប់ជួសឲ្យមានព្រៃក្រាស់ឡើងវិញ
(ខ) ការដាំដុះព្រៃឈើ
(គ) ការដាំដុះដើមឈើតាមផ្លូវធំៗ តាមឆ្នេរសមុទ្រ ឬនៅទីវាល
(ឃ) ការដាំដុះដើមឈើសម្រាប់ផលិតក្រដាស និងអុសដុត
(ង) ការប្រមូលដើមរុក្ខជាតិព្រៃ
(ច) ការបណ្តុះកូនឈើសម្រាប់ដាំព្រៃឈើ។

(៣) **មិនរាប់បញ្ចូល**
(ក) ការដាំដុះដើមស្រល់សាប៉ាំង ឬដើមគ្រិស្មាស់ (មើល ០១២៩៩)
(ខ) ការដាំដុះដើមឈើឈរ៖ ការដាំ ការដាំឡើងវិញ ការផ្សាំ ការរំលែក(កុំឲ្យក្រាស់ពេក) និងការអភិរក្ស នូវព្រៃឈើនិងដើមឈើ (មើល ០២១០១)
(គ) ការប្រមូលអនុផលព្រៃឈើធម្មជាតិ (មើល ០២៣០០)
(ឃ) ផលិតកម្មកំណាត់ឈើនិងបន្ទះឈើ ដែលមិនទាក់ទងនឹងការកាប់ឈើ (មើល ១៦១០)
(ង) ផលិតកម្មធ្យូងឈើតាមរយៈការចំហុយរម្លាយសាច់ឈើ (មើល ២០១១៩)។

រាប់បញ្ចូល ការប្រមូលសម្បកឈើ (អម្បូរនៅលើគោក អម្បូរដើមកោងកាង និងអុសដុត)។

(៤) **មិនរាប់បញ្ចូល**
(ក) ផលិតកម្មតាមផែនការ (គឺមិនតាមធម្មជាតិដែលមានស្រាប់) នូវមុខណាមួយនៃផលិតផលទាំងនេះ (មើលផ្នែក ០១)
(ខ) ការដាំដុះផ្សិត (មើល ០១១៣៤)
(គ) ការដាំដុះឈើហូបផ្លែ(ឬសាច់ផ្លែ) ឬឈើហូបគ្រាប់ (មើល ០១២៥)
(ឃ) ការប្រមូលអុសដុត (មើល ០២២០០)។

(៥) **រាប់បញ្ចូល**
(ក) ការប្រមូលផ្តៅឬឫស្សី
(ខ) ការប្រមូលសម្បុកបក្សី
(គ) ការប្រមូលសាគូព្រៃ
(ឃ) ការប្រមូលរុក្ខសេពីរុក្ខជាតិព្រៃ
(ង) ខ្សែឫសរសៃ ផ្លែឈើ ស្លឹកឈើ និងប្រេងពីដើមឈើក្នុងព្រៃ

(ច)　　ក្រមួនឃ្មុំ និងទឹកឃ្មុំ។

(៦)　**មិនរាប់បញ្ចូល**　ដំណើរការបណ្ដុះកូនឈើព្រៃ (មើល ០២១០០)។

(៧)　**រួមបញ្ចូល**សេវាកម្មផ្តល់ដល់នាយកដ្ឋានរុក្ខាប្រមាញ់ ឬក្រុមហ៊ុនកាប់ឈើ។

ផ្នែក ០៣ ៖ ការនេសាទ និងវារីវប្បកម្ម

ផ្នែកនេះរាប់បញ្ចូលការចាប់ធនធានជលផល និងវារីវប្បកម្ម ពោលគឺរាប់ទាំងការប្រើប្រាស់ឧបករណ៍នេសាទនានានៅក្នុងដែនសមុទ្រ ដែនទឹកភ្លាវ និងដែនទឹកសាប ក្នុងគោល ដៅចាប់យកឬប្រមូលយកនូវ ត្រី សត្វអម្បូរសម្បករឹង(ក្ដាម បង្កង ។ល។) សិប្បីសត្វ ព្រមទាំងផលិតផលនិងវារីជាតិសមុទ្រដទៃទៀត (ឧ. វារីរុក្ខជាតិ គុជខ្យង ពពុះសមុទ្រ ។ល។)។

សកម្មភាពពាក់ព័ន្ធនឹងដំណើរការផលិតកម្ម សម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន (ឧ. ការបង្កាត់ពូជគ្រំសមុទ្រ (អ័យស្ទ័រ) សម្រាប់ផលិតកម្មគុជខ្យង) ក៏ត្រូវបានរាប់បញ្ចូលក្នុងផ្នែកនេះ ផងដែរ។

ផ្នែកនេះមិនរាប់បញ្ចូលនូវ ការសាងសង់និងការជួសជុលកប៉ាល់ និងទូក (៣០១១ និង ៣៣១៥) និងសកម្មភាពនេសាទជាលក្ខណៈកីឡា និងការកម្សាន្ត (៩៣១៩)។ ការកែច្នៃត្រីសត្វអម្បូរសម្បករឹង ឬសិប្បីសត្វ មិនថាប្រព្រឹត្តិទៅក្នុងរោងចក្រនៅដីគោក ឬរោងចក្រនៅលើ កប៉ាល់ (១០២០) មិនត្រូវបានរាប់បញ្ចូលក្នុងផ្នែកនេះឡើយ។

ក្រុម ០៣១ ៖ ការនេសាទ

ក្រុមនេះរាប់បញ្ចូល "ការចាប់ធនធានជលផល" ពោលគឺសំដៅដល់សកម្មភាពប្រមាញ់ និងប្រមូលយក នូវវារីជាតិមានជីវិតនានា (ភាគច្រើនលើសលប់គឺ ត្រី សត្វអម្បូរសម្បករឹង និងសិប្បីសត្វ) ដែលរាប់បញ្ចូលទាំងរុក្ខជាតិមានប្រភពពីដែនមហាសមុទ្រ តំបន់ឆ្នេរសមុទ្រ ឬដែនទឹកសាប សម្រាប់បំពេញតម្រូវការប្រើប្រាស់របស់មនុស្ស និងគោលបំណងផ្សេងទៀត ដោយប្រើដៃ ឬនេសាទុបករណ៍ផ្សេងៗ ដូចជា សំណាញ់ មង និងអន្ទាក់។ សកម្មភាពទាំងនេះអាចត្រូវបានធ្វើឡើងនៅតំបន់ក្បែរច្រាំងសមុទ្រ (ឧ. ការប្រមូលសិប្បីសត្វ ដូចជាគ្រំចំពុះទា និងអ័យស្ទ័រ) ឬដោយការរាយសំណាញ់នៅតាមច្រាំង ឬដោយការប្រើទូកតូចឬធំនៅក្នុងដែនទឹកសាប តំបន់ឆ្នេរសមុទ្រ និងដែនសមុទ្រ។ អ្វីដែលខុសប្លែកពីវារីវប្បកម្ម (ក្រុម ០៣២) នោះគឺថា ធនធានជលផលដែលត្រូវចាប់យកនេះ ជាធម្មតា មានលក្ខណៈជាសម្បត្តិសាធារណៈ គឺពុំបាច់ពិចារណាថាតើមាន ឬពុំមានសិទ្ធិអាជីវកម្មឡើយ នៅពេលធ្វើសកម្មភាពប្រមូលផល។ សកម្មភាពទាំងនេះក៏រាប់បញ្ចូលផងដែរ នូវការនេសាទនៅក្នុងប្រភពទឹក ដែលធនធានជល ផលត្រូវបានបង្កើតឡើងវិញ។

ក្រុម ០៣២ ៖ វារីវប្បកម្ម

ក្រុមនេះរាប់បញ្ចូល "វារីវប្បកម្ម" ពោលគឺសំដៅដល់ ដំណើរការផលិតកម្មដែល ទាក់ទងនឹងការចិញ្ចឹម (រាប់ទាំងការប្រមូលផលផងដែរ) វារីជាតិ (ត្រី សត្វអម្បូរសម្បករឹង សិប្បីសត្វ វារីរុក្ខជាតិ ក្រពើ ក្រពា និងថលជលិកសត្វ) ដោយប្រើបច្ចេកទេសដែលជួយបង្កើនផលិតកម្មវារីជាតិទាំងនោះ ឲ្យលើសពីសមត្ថភាពផលិតកម្មដោយធម្មជាតិ (ឧ. ការដាក់កូនពូជចិញ្ចឹមជាទៀងទាត់ ការផ្តល់ចំណី និងការការពារពីសត្វដែលចង់យាយី)។

ការចិញ្ចឹមនេះសំដៅដល់ការបីបាច់ថែរក្សាក្នុងលក្ខខណ្ឌបង្ខាំងទុកនូវវារីជាតិទាំងនោះ ចាប់តាំងពីនៅតូចរហូតដល់ពេញវ័យ។ ជាងនេះទៀត"វារីវប្បកម្ម"ក៏បង្កប់ផងដែរនូវអត្ថន័យនៃប្រភេទកម្មសិទ្ធិគឺ ឯកជន សាជីវកម្ម ឬរដ្ឋ ចំពោះវារីជាតិទាំងនោះ រាប់តាំងពីដំណាក់កាលចិញ្ចឹមដំបូង រហូតដល់ប្រមូលផល។

ជំពូក ក ៖ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ផ្នែក ០៣ ៖ ការនេសាទ និងវារីវប្បកម្ម

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
០៣១			ការនេសាទ
	០៣១១[១]		ការនេសាទក្នុងដែនទឹកប្រៃ
		០៣១១១	ការនេសាទត្រីសមុទ្រ[២]
		០៣១១២	ការនេសាទបង្គា
		០៣១១៣	ការនេសាទក្តាមសមុទ្រ
		០៣១១៤	ការនេសាទត្រីមឹក
		០៣១១៥	ការប្រមូលសម្បកសិប្បីសត្វសមុទ្រ និងគុជខ្យង
		០៣១១៩	ការនេសាទត្រីសមុទ្រដទៃទៀត ដែលពុំបានរាប់បញ្ចូល
	០៣១២[៣]		ការនេសាទក្នុងដែនទឹកសាប
		០៣១២១	ការនេសាទត្រីទឹកសាប
		០៣១២២	ការនេសាទបង្កងទឹកសាប បង្គា និងសត្វអម្បូរសម្បករឹងដទៃទៀត
		០៣១២៩	ការនេសាទត្រីទឹកសាបដទៃទៀត ដែលពុំបានរាប់បញ្ចូល

(១) **មិនរាប់បញ្ចូល**
- (ក) ការនេសាទថនិសត្វសមុទ្រ លើកលែងត្រីបាឡែន (មើល ០៣១១១)។ ឧ. លោមមច្ឆា ផ្សោទឹក (មើល ០១៧០)
- (ខ) ការកែច្នៃត្រី សត្វអម្បូរសម្បករឹង(បង្គា ក្តាម។ល។) និងសិប្បីសត្វ នៅក្នុងរោងចក្រលើកប៉ាល់ ឬរោងចក្រលើដីគោក (មើល ១០២០)
- (គ) ការជួលទូកកម្សាន្តដែលមានក្រុមនាវិកដើរសមុទ្រនិង ការដឹកជញ្ជូនតាមផ្លូវទឹក។ ឧ. សម្រាប់ដំណើរស្ទូចត្រីកម្សាន្ត (មើល ៥០១១០)
- (ឃ) សេវាកម្មត្រួតពិនិត្យ ការពារ និងល្បាតដល់ការនេសាទ (មើល ៨៤២៣៩)
- (ង) ការហាត់ស្ទូចត្រីសម្រាប់សកម្មភាពកីឡា ឬការកម្សាន្ត និងសកម្មភាពដែលទាក់ទង (មើល ៩៣១៩៩)
- (ច) ប្រតិបត្តិការការពារ ដល់ការនេសាទជាលក្ខណៈកីឡា (មើល ៩៣១៩៩)។

(២) **រាប់បញ្ចូល** ការនេសាទត្រីបាឡែន។

(៣) **មិនរាប់បញ្ចូល**
- (ក) ការកែច្នៃត្រី សត្វអម្បូរសម្បករឹង និងសិប្បីសត្វ (មើល ១០២០)
- (ខ) សេវាកម្មត្រួតពិនិត្យ ការពារ និងល្បាតដល់ការនេសាទ (មើល ៨៤២៣៩)
- (គ) ការហាត់ស្ទូចត្រីសម្រាប់សកម្មភាពកីឡា ឬការកម្សាន្ត និងសកម្មភាពដែលទាក់ទង (មើល ៩៣១៩៩)
- (ឃ) ប្រតិបត្តិការការពារ ដល់ការនេសាទជាលក្ខណៈកីឡា (មើល ៩៣១៩៩)។

ជំពូក ក ៖ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ផ្នែក ០៣ ៖ ការនេសាទ និងវារីវប្បកម្ម

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
០៣២			**វារីវប្បកម្ម**
	០៣២១[(១)]		វារីវប្បកម្មក្នុងទឹកប្រៃ
		០៣២១១	ការចិញ្ចឹមត្រីក្នុងទឹកសមុទ្រ[(២)]
		០៣២១២	ផលិតកម្មកូនសត្វពពួកគ្រំ(អ័យស្ទ័រ គ្រំចំពុះទា ។ល។) កូនបង្កង កូនបង្គា កូនត្រី
		០៣២១៣	ការដាំដុះសារាយសមុទ្រ និងរុក្ខជាតិផ្សេងទៀតដែលអាចញ៉ាំបាន
		០៣២១៤	ការចិញ្ចឹមសត្វអម្បូរសម្បករឹង ពពួកគ្រំនិងសិប្បីសត្វផ្សេងទៀត និងវារីសត្វសមុទ្រដទៃទៀត
		០៣២១៥	សកម្មភាពវារីវប្បកម្មនៅក្នុងទឹកភ្លាវ
		០៣២១៩	វារីវប្បកម្មក្នុងទឹកប្រៃដទៃទៀត ដែលពុំបានរាប់បញ្ចូល
	០៣២២[(៣)]		វារីវប្បកម្មក្នុងទឹកសាប
		០៣២២១	ការចិញ្ចឹមត្រីនៅក្នុងទឹកសាប
		០៣២២២	ការចិញ្ចឹមបង្គា បង្កងទឹកសាប នៅក្នុងទឹកសាប
		០៣២២៣	ការចិញ្ចឹមក្រពើ និងក្រពា
		០៣២២៤	វារីវប្បកម្មក្នុងទឹកសាប សម្រាប់តាំងលម្អ
		០៣២២៥	ការចិញ្ចឹមកង្កែប
		០៣២២៩	វារីវប្បកម្មក្នុងទឹកសាបដទៃទៀត ដែលពុំបានរាប់បញ្ចូល

(១) **មិនរាប់បញ្ចូល** (ក) ការចិញ្ចឹមកង្កែប (មើល ០៣២២៥)
(ខ) ប្រតិបត្តិការការពារ ដល់ការនេសាទជាលក្ខណៈកីឡា (មើល ៩៣១៩៩)។

(២) **រាប់បញ្ចូល** ការចិញ្ចឹមត្រីទឹកប្រៃសម្រាប់តាំងលម្អ។

(៣) **មិនរាប់បញ្ចូល** (ក) សកម្មភាពវារីវប្បកម្ម នៅក្នុងទីស្តុកទឹកប្រៃ (មើល ០៣២១៩)
(ខ) ប្រតិបត្តិការការពារ ដល់ការនេសាទជាលក្ខណៈកីឡា (មើល ៩៣១៩៩)។

(៤) **រាប់បញ្ចូល** ការចិញ្ចឹមត្រីទឹកសាបសម្រាប់តាំងលម្អ
ការចិញ្ចឹមត្រីក្នុងប្រឡាយទឹក។

ជំពូក ខ ៖ ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ

កម្រិត	ច.ស.វ.ក
ជំពូក	១
ផ្នែក	៦
ក្រុម	១០
ថ្នាក់	១៣
ថ្នាក់រង	២៨

ប្រតិបត្តិការធនធានរ៉ែគឺជាការធ្វើសកម្មភាពបុរេសនាស្វែងរក រុករក និងការធ្វើអាជីវកម្មធនធានរ៉ែ។

ជំពូកនេះរាប់ញ្ចូលនូវអាជីវកម្មរ៉ែត្បូងថ្ម និងត្បូងភក់ ប្រេងកាត និងអាជីវកម្មរ៉ែលោហៈ និងធនធានរ៉ែដ៏ទៃផ្សេងៗទៀត។

ជំពូកនេះរាប់បញ្ចូលផងដែរនូវសកម្មភាពគាំទ្រដល់ដំណើការប្រព្រឹត្តកម្ម ដូចជាសកម្មភាពបំបែក ការកិន ការសម្អាត ការសម្ងួត ការបែងចែកតាមប្រភេទ ការបន្សុទ្ធ និងការចម្រាញ់ចេញជាផលិតផលសម្រេច។ ប្រតិបត្តិការធនធានរ៉ែ ត្រូវបានចាត់ថ្នាក់ជា ផ្នែក ក្រុម ថ្នាក់ និងថ្នាក់រងទៅតាមប្រភេទរ៉ែចម្បងៗដែលត្រូវបានផលិត។ ផ្នែក ០៥ និង ០៦ ផ្តោតលើសកម្មភាពអាជីវកម្មរ៉ែឥន្ធនៈហ្វូស៊ីល(ដែលកើតឡើងពីធម្មជាតិ) ដូចជា ត្បូងថ្ម ត្បូងភក់ និងប្រេងកាត ។ ផ្នែក ០៧ និង ០៨ ផ្តោតលើសកម្មភាពអាជីវកម្មរ៉ែលោហៈ និងធនធានរ៉ែដ៏ទៃផ្សេងទៀត។

ចំណែកឯផ្នែក ០៩ បង្ហាញអំពីប្រភេទខ្លះៗ នៃសកម្មភាពបច្ចេកទេសនៅក្នុងជំពូកនេះពិសេសទាក់ទងនឹងការទាញយកជាតុអ៊ីដ្រូកាបួ ប្រព្រឹត្តិឡើងដោយអង្គភាពជំនាញក្រោមទម្រង់ជាសេវាកម្មខាងឧស្សាហកម្ម សម្រាប់ផ្គត់ផ្គង់ដល់ភាគីទីបី។

ជំពូកនេះមិនរាប់បញ្ចូលនូវការកែច្នៃវត្ថុធាតុរ៉ែ ដែលត្រូវបានធ្វើនិស្សារណកម្មរួច (មើលជំពូក «គ» កម្មន្តសាល) ការប្រកដបនូវ ទឹកធម្មជាតិ និងទឹកឧនិដ ដែលយកចេញពីប្រភពទឹកជ្រោះ និងអណ្តូងទឹក (មើលថ្នាក់ ១១០៤) ឬការបំបែក ការកិនឬសកម្មភាពប្រព្រឹត្តិកម្មផ្សេងទៀតទៅលើវត្ថុធាតុរ៉ែ និងប្រេងកាតវត្ថុធាតុដើមគីមី និងថ្ម ដែលត្រូវបានធ្វើឡើងដាច់ដោយឡែកពីសកម្មភាពអាជីវកម្មរ៉ែនិងថ្ម (មើលថ្នាក់ ២៣៩៩)។ ជំពូកនេះក៏មិនរាប់បញ្ចូលផងទេ នូវការយកវត្ថុធាតុរ៉ែដែលត្រូវបានធ្វើនិស្សារណកម្មរួចមកប្រើប្រាស់ដោយគ្មានការបំប្លែងបន្ថែមទៀតសម្រាប់ការងារសំណង់ (មើលជំពូក«ច» សំណង់)ការប្រមូល ការបន្សុទ្ធ និងការចែកចាយទឹក (មើលថ្នាក់ ៣៦០០) សកម្មភាពរៀបចំ ឬបោសសម្អាតកន្លែងអាជីវកម្មរ៉ែនិងថ្ម (មើលថ្នាក់ ៤៣១២) និងសកម្មភាពអង្កេតខាងរូបភូគព្ភសាស្ត្រ ខាងភូគព្ភសាស្ត្រ និងខាងរលករញ្ជួយដី (មើលថ្នាក់ ៧១១០)។

ផ្នែក ០៥ ៖ អាជីវកម្មរ៉ែត្បូងថ្ម និងត្បូងភក់

ផ្នែកនេះរាប់បញ្ចូលនូវ សកម្មភាពនិស្សារណកម្មរ៉ែឥន្ធនៈរឹង ដែលត្រូវបានប្រព្រឹត្តឡើងតាមរយៈការធ្វើអាជីវកម្មនៅក្រោមដីឬលើដី និងសកម្មភាពប្រព្រឹត្តិកម្មនានា (ឧ. ការបែងចែកគុណភាព ការសម្អាត ការបង្ហាប់ និងសកម្មភាពផ្សេងទៀតដែលចាំបាច់សម្រាប់សម្រួលដល់ការដឹកជញ្ជូន។ល។) ដែលធ្វើឲ្យផលិតផលអាចចូលក្នុងទីផ្សារបាន។

ផ្នែកនេះមិនរាប់បញ្ចូលនូវ ការចំហុយកាកត្បូងថ្ម(មើល ១៩១០) សេវាកម្មគាំទ្រដល់អាជីវកម្មរ៉ែត្បូងថ្មនិងត្បូងភក់ (មើល ០៩៩០) ឬផលិតកម្មដុំត្បូងថ្ម(មើល ១៩២០)។

ក្រុម ០៥១ ៖ អាជីវកម្មរ៉ែថ្មរ៉ែផ្សេងថ្ម

ក្រុមនេះរាប់បញ្ចូលការធ្វើអាជីវកម្មយករ៉ែផ្សេងថ្ម ប្រព្រឹត្តិឡើងនៅក្រោមដីឬលើដី ដោយប្រើប្រាស់វិធីសាស្ត្រ និង សម្អាត បែងចែកទំហំ បែងចែកប្រភេទ បង្ហាប់ ។ល។ នូវរ៉ែផ្សេងថ្ម ក្នុងគោលបំណងធ្វើចំណាត់ថ្នាក់ បង្កើនគុណភាព ឬសម្រួលដល់ការដឹកជញ្ជូនឬស្តុកទុក។

ក្រុម ០៥២ ៖ អាជីវកម្មរ៉ែផ្សេងភក់

ក្រុមនេះរាប់បញ្ចូលការធ្វើអាជីវកម្មរ៉ែផ្សេងភក់ ប្រព្រឹត្តិឡើងនៅក្រោមដីឬលើដី ដោយប្រើប្រាស់វិធីសាស្ត្រ សម្អាត សម្ងួត កិនឲ្យម៉ត់ បង្ហាប់ នូវរ៉ែផ្សេងភក់ ក្នុងគោលបំណងបង្កើនគុណភាព ឬសម្រួលដល់ការដឹកជញ្ជូនឬស្តុកទុក។

ជំពូក ខ ៖ ប្រតិបត្តិការជនជានរ៉ែ
ផ្នែក ០៥ ៖ អាជីវកម្មរ៉ែថ្មូងថ្ម និងធ្យូងភក់

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
០៥១			**អាជីវកម្មរ៉ែធ្យូងថ្ម**
	០៥១០(១)		អាជីវកម្មរ៉ែធ្យូងថ្ម
		០៥១០០	អាជីវកម្មរ៉ែធ្យូងថ្ម
០៥២			**អាជីវកម្មរ៉ែធ្យូងភក់**
	០៥២០(២)		អាជីវកម្មរ៉ែធ្យូងភក់
		០៥២០០	អាជីវកម្មរ៉ែធ្យូងភក់

(១) **រាប់បញ្ចូល**
(ក) ការស្វែងរុករករ៉ែនៅក្រោមដីឬលើដី
(ខ) ការសម្អាត ការបែងចែកទំហំ ការបែងចែកប្រភេទ ការកិនឲ្យហ្មត់ ការបង្ហាប់។ល។ នូវរ៉ែធ្យូងថ្ម ក្នុងគោលបំណងធ្វើចំណាត់ថ្នាក់ បង្កើនគុណភាព ឬសម្រួលដល់ការដឹកជញ្ជូន ឬស្តុកទុក

មិនរាប់បញ្ចូល
(ក) អាជីវកម្មរ៉ែធ្យូងភក់ (មើល ០៥២០០) និងការជីកយករុក្ខជាតិរលួយ ដែលប្រើសម្រាប់ធ្វើជីឬដុតជំនួសធ្យូង (មើល ០៨៩២០)
(ខ) សកម្មភាពគាំទ្រសម្រាប់អាជីវកម្មរ៉ែធ្យូងថ្ម (មើល ០៩៩០០)
(គ) ការជីកសាកល្បងដើម្បីធ្វើអាជីវកម្មរ៉ែធ្យូងថ្ម (មើល ០៩៩០០)
(ឃ) ឡផលិតឥន្ធនៈរឹង (មើល ១៩១០០)
(ង) សកម្មភាពការងារប្រព្រឹត្តិឡើង សម្រាប់អភិវឌ្ឍឬរៀបចំឧបករណ៍ធ្វើអាជីវកម្មរ៉ែធ្យូងថ្ម (មើល៤៣១២១)។

(២) **រាប់បញ្ចូល**
(ក) ការធ្វើអាជីវកម្មរ៉ែ
(ខ) ការសម្អាត ការសម្ងួត ការកិនឲ្យហ្មត់ ការបង្ហាប់ នូវរ៉ែធ្យូងភក់ ក្នុងគោលបំណងបង្កើនគុណភាព ឬសម្រួលដល់ការដឹកជញ្ជូនឬស្តុកទុក

មិនរាប់បញ្ចូល
(ក) អាជីវកម្មរ៉ែធ្យូងថ្ម (មើល ០៥១០០)
(ខ) ការជីកយករុក្ខជាតិរលួយ ដែលប្រើសម្រាប់ធ្វើជីឬដុតជំនួសធ្យូង (មើល ០៨៩២០)
(គ) ការជីកសាកល្បងដើម្បីធ្វើអាជីវកម្មរ៉ែធ្យូងភក់ (មើល ០៩៩០០)
(ឃ) សកម្មភាពគាំទ្រសម្រាប់អាជីវកម្មរ៉ែធ្យូងភក់ (មើល ០៩៩០០)
(ង) សកម្មភាពការងារប្រព្រឹត្តិឡើង សម្រាប់អភិវឌ្ឍឬរៀបចំឧបករណ៍ធ្វើអាជីវកម្មរ៉ែធ្យូងថ្ម (មើល ៤៣១២១)។

ផ្នែក ០៦ ៖ ផលិតកម្មប្រេងកាត

ផ្នែកនេះរាប់បញ្ចូលនូវ ផលិតកម្មប្រេងកាត ការទាញយកប្រេងកាតចេញពីស្រទាប់សិលា ឬសិលាសែល និងសិលាខ្សាច់ និងផលិតឧស្ម័នធម្មជាតិនិងការទាញយកអ៊ីដ្រូកាបួរ។ ផ្នែកនេះរាប់បញ្ចូលសកម្មភាពប្រតិបត្តិការឬអភិវឌ្ឍន៍ការដ្ឋានប្រេងកាតដូចជា ៖ សកម្មភាពខួង ការបញ្ចប់ និងបំពាក់សម្ភារៈនៅលើអណ្តូងខួង សកម្មភាពប្រតិបត្តិការម៉ាស៊ីនញែក ការប្រើប្រាស់ឧបករណ៍ចម្រោះប្រេង ប្រពន្ធ័ប្រមូលប្រេងកាត (Field Gathering) សកម្មភាពពាក់ព័ន្ធនឹងការដំឡើងប្រព័ន្ធបំពង់បង្ហូរប្រេងកាត និងសកម្មភាពដទៃទៀត ក្នុងការរៀបចំប្រេងកាត ដើម្បីដឹកជញ្ជូនពីកន្លែងផលិតកម្ម។

ផ្នែកនេះមិនរាប់បញ្ចូលសកម្មភាពគាំទ្រដល់ផលិតកម្មប្រេងកាតដូចជាសេវាកម្មសម្រាប់ការដ្ឋានប្រេងកាតផ្អែកតាមការបង់ថ្លៃឬតាមកិច្ចសន្យា សកម្មភាពរុករក និងសកម្មភាពខួងអណ្តូងប្រេងកាតសម្រាប់ធ្វើតេស្ត (មើល ០៩១០)។ ផ្នែកនេះក៏មិនរាប់បញ្ចូលនូវការចម្រាញ់ប្រេងកាត(មើល១៩២០) និងសកម្មភាពអង្កេតខាងភូគព្ភសាស្រ្តនិងស៊ីស្មិក(មើល៧១១០)។

ក្រុម ០៦១ ៖ ផលិតកម្មប្រេងឆៅ

ក្រុមនេះរាប់បញ្ចូលការយកប្រេងកាតឆៅ។

ក្រុម ០៦២ ៖ ផលិតកម្មឧស្ម័នធម្មជាតិ

ក្រុមនេះរាប់បញ្ចូលនូវ ផលិតកម្មឧស្ម័នអ៊ីដ្រូកាបួ (ឧស្ម័នធម្មជាតិ) ផលិតកម្មខុនដុនសេត (Condensates) ការញែកយកជាតុអ៊ីដ្រូកាបួរ និងការដកជាតុស្ពាន់ធ័រពីឧស្ម័នធម្មជាតិ។

ជំពូក ខ ៖ ប្រតិបត្តិការជនជានរ៉ែ
ផ្នែក ០៦ ៖ ផលិតកម្មប្រេងកាត និងឧស្ម័នធម្មជាតិ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
០៦១			**ផលិតកម្មប្រេងឆៅ**
	០៦១០[១]		ផលិតកម្មប្រេងឆៅ
		០៦១០០	ផលិតកម្មប្រេងឆៅ
០៦២			**ផលិតកម្មឧស្ម័នធម្មជាតិ**
	០៦២០[២]		ផលិតកម្មឧស្ម័នធម្មជាតិ
		០៦២០០	ផលិតកម្មឧស្ម័នធម្មជាតិ

(១) **មិនរាប់បញ្ចូល**
- (ក) សកម្មភាពគាំទ្រដល់ផលិតកម្មប្រេងឆៅ (មើល ០៩១០០)
- (ខ) ការស្វែងរុករកប្រេងកាត (មើល ០៩១០១)
- (គ) សកម្មភាពចម្រាញ់ប្រេងកាត (មើល ១៩២០០)
- (ឃ) ការទាញយកឧស្ម័នអិលភីជី (LPG) ក្នុងពេលចម្រាញ់ប្រេងកាត (មើល ១៩២០១)
- (ង) សកម្មភាពប្រតិបត្តិការបំពង់បង្ហូរ (មើល៤៩៣០០)។

(២) **រាប់បញ្ចូល** ការយកឧស្ម័នប្រភេទមេតាន អេតាន ប៊ុយតានឬប្រូប៉ាន

មិនរាប់បញ្ចូល
- (ក) ការស្វែងរុករកប្រេងកាត និងសកម្មភាពគាំទ្រដល់ផលិតកម្មប្រេងកាត (មើល ០៩១០០)
- (ខ) ការទាញយកឧស្ម័នអិលភីជី (LPG) ក្នុងពេលចម្រាញ់យកប្រេងកាត (មើល ១៩២០១)
- (គ) ផលិតកម្មឧស្ម័នសម្រាប់សកម្មភាពឧស្សាហកម្ម (មើល ២០១១១)
- (ឃ) សកម្មភាពប្រតិបត្តិការបំពង់បង្ហូរ (មើល ៤៩៣០០)។

ផ្នែក ០៧ ៖ អាជីវកម្មរ៉ែលោហៈ

ផ្នែកនេះរាប់បញ្ចូល សកម្មភាពប្រតិបត្តិការអាជីវកម្មរ៉ែលោហៈ តាមរយៈវិធីសាស្ត្រអណ្តូងរ៉ែបើក និងអណ្តូងរ៉ែក្រោមដីនិងការរុករករ៉ែនៅបាតសមុទ្រ។ល។ ផ្នែកនេះរាប់បញ្ចូលផងដែរ នូវប្រតិបត្តិការពាក់ព័ន្ធនឹងប្រព្រឹត្តិកម្មរ៉ែលោហៈ ដូចជា ការបំបែក ការកិន ការសម្អាត ការសម្ងួត ការចម្រាញ់ចេញជាផលិតផលរ៉ែ ។

ផ្នែកនេះមិនរាប់បញ្ចូលនូវសកម្មភាពពាក់ព័ន្ធនឹងការផលិតនោះទេ ដូចជា ការដុតដែកស៊ុលហ្វាត(មើល ២០១១) ផលិតកម្មអាលុយមីញ៉ូមអុកស៊ីត(មើល ២៤២០) និងប្រតិបត្តិការរំលាយរ៉ែនៅក្នុងឡដែក(មើល ២៤១០ និង ២៤២០)។

ក្រុម ០៧១ ៖ អាជីវកម្មរ៉ែដែក

ក្រុមនេះរាប់បញ្ចូលសកម្មភាពអាជីវកម្មរ៉ែដែលមានសមាសធាតុរ៉ែដែកច្រើន និងសកម្មភាពប្រព្រឹត្តិកម្ម។

ក្រុម ០៧២ ៖ អាជីវកម្មរ៉ែលោហៈដែលមិនមែនដែក

ក្រុមនេះរាប់បញ្ចូលសកម្មភាពអាជីវកម្មរ៉ែលោហៈដែលគ្មានសមាសធាតុរ៉ែដែក។

ជំពូក ខ ៖ ប្រតិបត្តិការធនធានរ៉ែ
ផ្នែក ០៧ ៖ អាជីវកម្មរ៉ែលោហៈ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
០៧១			**អាជីវកម្មរ៉ែដែក**
	០៧១០		អាជីវកម្មរ៉ែដែក
		០៧១០០	អាជីវកម្មរ៉ែដែក
០៧២			**អាជីវកម្មរ៉ែលោហៈដែលមិនមែនដែក**
	០៧២៩[១]		អាជីវកម្មរ៉ែលោហៈដែលមិនមែនដែក
		០៧២៩១	អាជីវកម្មរ៉ែសំណប៉ាហាំង
		០៧២៩២	អាជីវកម្មរ៉ែទង់ដែង
		០៧២៩៣	អាជីវកម្មរ៉ែអាលុយមីញ៉ូមបុកស៊ីត
		០៧២៩៤	អាជីវកម្មរ៉ែទីតានីញ៉ូមអុកស៊ីត
		០៧២៩៥	អាជីវកម្មរ៉ែមាស
		០៧២៩៩	អាជីវកម្មរ៉ែអលោហៈដទៃទៀតដែលពុំបានរាប់បញ្ចូល[២]

(១) **មិនរាប់បញ្ចូល** (ក) ការធ្វើអាជីវកម្មរ៉ែអ៊ុយរ៉ាញ៉ូម និងអាជីវកម្ម Thorium (មើល ០៧២១)

(ខ) ផលិតកម្មអាលុយមីញ៉ូមអុកស៊ីត និងការចម្រាញ់ជាតិនីកែលនិងទង់ដែង (មើល ២៤២០០)។

(២) **រាប់បញ្ចូល** អាជីវកម្ម និងប្រព្រឹត្តិកម្មយករ៉ែលោហៈដែលពុំមានជាតុដែកភាគច្រើន៖ សំណ ស័ង្កសី ម៉ង់កាណែស លោហធាតុក្រូមមេនីកេល លោហធាតុកូបល ក្រុមលោហធាតុគីមីពណ៌សប្រាក់ ក្រុមដែកធុនធ្ងន់ដែលមិនឆ្លងចន្លេក្រោម ១៥០ អង្សាសេ ក្រុមលោហធាតុដែកពណ៌សភ្លឺ ។ល។

ផ្នែក ០៨ ៖ ប្រតិបត្តិការធនធានរ៉ែផ្សេងទៀត

ផ្នែកនេះរាប់បញ្ចូល សកម្មភាពទាញយកដីល្បាយខ្សាច់ រ៉ែ ខ្សាច់សំណង់ និងថ្មសំណង់។ ប្រភេទផលិតផលរ៉ែទាំងនេះភាគច្រើនត្រូវបានប្រើសម្រាប់ជាវត្ថុធាតុដើមផ្គត់ផ្គង់ក្នុងវិស័យសំណង់ (ឧ. ខ្សាច់ ថ្ម ។ល។) ការផលិតសម្ភារៈ (ឧ. ដីឥដ្ឋ ម្នាងសិលា កំបោរស ។ល។) ការផលិតសារធាតុគីមី ។ល។

ផ្នែកនេះមិនរាប់បញ្ចូលការកែច្នៃ (លើកលែងតែ ការបំបែក ការកិន ការកាត់ ការសម្អាត ការសម្ងួត ការបែងចែកប្រភេទ និងការលាយ) នូវធនធានរ៉ែដែលបានទាញយក។

ក្រុម ០៨១ ៖ ប្រតិបត្តិការទាញយកថ្មសំណង់ ខ្សាច់ និងដីឥដ្ឋ

ក្រុមនេះរាប់បញ្ចូល ៖ សកម្មភាពទាញយក បំបែក កាត់ នូវផ្ទាំងថ្មនិងថ្មសម្អាង ដូចជា ថ្មម៉ាប ថ្មក្រានីត ថ្មខ្សាច់ ។ល។ សកម្មភាពទាញយកខ្សាច់ និងគ្រួស ។

ក្រុម ០៨៩ ៖ ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ ដទៃទៀតដែលពុំបានរាប់បញ្ចូល

ក្រុមនេះរាប់បញ្ចូលនូវសកម្មភាពអាជីវកម្មធនធានរ៉ែសម្រាប់ផលិតជាផលិតផលជីកសិកម្ម និងផលិតអំបិល ។ល។

ជំពូក ខ ៖ ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ
ផ្នែក ០៨ ៖ ប្រតិបត្តិការធនធានរ៉ែផ្សេងទៀត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
០៨១			ប្រតិបត្តិការទាញយកថ្ម ខ្សាច់ និងដីឥដ្ឋ
	០៨១០[១]		ប្រតិបត្តិការយកថ្ម ខ្សាច់ និងដីឥដ្ឋ
		០៨១០១	សកម្មភាពទាញយក បំបែក កាត់ និងអារនូវផ្ទាំងថ្មនិងថ្មសម្អាង ដូចជា ថ្មម៉ាប ថ្មក្រានីត ថ្មសំណង់ ខ្សាច់សំណង់ និងដីល្បាយខ្សាច់ ។ល។
		០៨១០២	សកម្មភាពអាជីវកម្មថ្មកំបោរ
		០៨១០៣	សកម្មភាពទាញយក ខ្សាច់សម្រាប់បម្រើការក្នុងវិស័យឧស្សាហកម្ម និងសំណង់
		០៨១០៤	សកម្មភាពទាញយកថ្មនិងគ្រួស
		០៨១០៥	សកម្មភាពទាញយកខ្សាច់ប្រភេទផ្សេងទៀត[២]
		០៨១០៦	សកម្មភាពទាញយកដីឥដ្ឋ

(១) **មិនរាប់បញ្ចូល** (ក) ការយករ៉ែខ្សាច់កាកប្រេងកាត (បេទីមសម្រាប់ក្រាលថ្នល់, មើល ០៦១០២)
(ខ) ការធ្វើអាជីវកម្មរ៉ែគីមីនិងរ៉ែសម្រាប់ធ្វើជីកសិកម្ម (មើល ០៨៩១)
(គ) ការផលិតថ្មកំបោម៉ាញេស្យូមកាបូណាត (មើល ២៣៩៤២)
(ឃ) ការកាត់ ខាត់អោយស្រួច នូវផលសម្រេចពីថ្ម (មើល ២៣៩៦០)។

(២) **រាប់បញ្ចូល** ខ្សាច់ស៊ីលីកា។

ជំពូក ខ ៖ ប្រតិបត្តិការធនធានរ៉ែ
ផ្នែក ០៨ ៖ ប្រតិបត្តិការធនធានរ៉ែផ្សេងទៀត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
០៨៩			ប្រតិបត្តិការធនធានរ៉ែ ដទៃទៀតដែលពុំបានរាប់បញ្ចូល
	០៨៩១[១]		សកម្មភាពអាជីវកម្មរ៉ែគីមីនិងរ៉ែសម្រាប់ធ្វើជីកសិកម្ម
		០៨៩១១	សកម្មភាពយករ៉ែផូស្វាតធម្មជាតិ
		០៨៩១២	សកម្មភាពយករ៉ែប៉ូតាស់ធម្មជាតិ រ៉ែម៉ាញ៉េស្យូមស៊ុលហ្វាតធម្មជាតិ
		០៨៩១៣	សកម្មភាពយករ៉ែដែលមានពណ៌ដី រ៉ែដែលមានជាតុកាល់ស្យូមហ្វ្លរ៉ាយ និងរ៉ែប្រភេទផ្សេងទៀត ដែលមានប្រយោជន៍ខាងធ្វើជាសារជាតុគីមី
	០៨៩២[២]		សកម្មភាពជីកយករុក្ខជាតិរលួយ(ដែលប្រើសម្រាប់ធ្វើជីឬដុតជំនួសធ្យូង)
		០៨៩២០	សកម្មភាពជីកយករុក្ខជាតិរលួយ(ដែលប្រើសម្រាប់ធ្វើជីឬដុតជំនួសធ្យូង)
	០៨៩៣[៣]		សកម្មភាពផលិតអំបិល
		០៨៩៣១	សកម្មភាពផលិតអំបិលពីទឹកសមុទ្រឬប្រភពទឹកប្រៃដទៃទៀត
		០៨៩៣២	សកម្មភាពបំបែក បន្សុទ្ធ និងរែងយកអំបិល របស់ផលិតករអំបិល
	០៨៩៩		សកម្មភាពផ្សេងទៀត នៃប្រតិបត្តិការនិងអាជីវកម្មធនធានរ៉ែ ដទៃទៀតដែលពុំបានរាប់បញ្ចូល
		០៨៩៩១	សកម្មភាពយករ៉ែថ្មបងធម្មជាតិ សម្រាប់ធ្វើខ្មៅដៃ
		០៨៩៩២	សកម្មភាពយករ៉ែត្បូងថ្មមានតម្លៃ
		០៨៩៩៩	សកម្មភាពផ្សេងទៀត នៃប្រតិបត្តិការនិងអាជីវកម្មធនធានរ៉ែ ដទៃទៀតដែលពុំបានរាប់បញ្ចូល[៤]

(១) **មិនរាប់បញ្ចូល** (ក) ការផលិតអំបិល (មើល ០៨៩៣)
(ខ) ការដុតដែកស៊ុលផួរ (មើល ២០១១០)
(គ) ការផលិតជីសំយោគ និងសមាសធាតុនីត្រូសែន (មើល២០១២)។

(២) **មិនរាប់បញ្ចូល** (ក) សេវាកម្មគាំទ្រដល់ការយករុក្ខជាតិរលួយ (ដែលប្រើសម្រាប់ធ្វើជីឬដុតជំនួសធ្យូង (មើល ០៩៩០០)
(ខ) ការផលិតវត្ថុធាតុពីរុក្ខជាតិពុករលួយប្រភេទនេះ (មើល ២៣៩៩)។

(៣) **មិនរាប់បញ្ចូល** ការកែច្នៃអំបិលឲ្យទៅជាអំបិលបរិភោគ (ឧ. អំបិលអ៊ីយ៉ូដ) (មើល ១០៧៩០)។

(៤) **រាប់បញ្ចូល** ការយកធនធានរ៉ែនិងវត្ថុធាតុដទៃទៀត (ឧ. ជំរម្រាក់ធម្មជាតិ និងគ្រួសល្អិតសម្រាប់ធ្វើថ្នល់ ជំរម្រាក់ធម្មជាតិប្រភេទរឹង សិលាក្វាត្ស ម៉ៃកា តាល់ក៍ វត្ថុធាតុដែលអាចប្រើសម្រាប់ខាត់វត្ថុរឹង រ៉ែប្រភេទស៊ីលីកាត ។ល។)។

ផ្នែក ០៩ ៖ សកម្មភាពសេវាគាំទ្រសម្រាប់ប្រតិបត្តិការធនធានរ៉ែ និងប្រេងកាត

ផ្នែកនេះរាប់បញ្ចូលសេវាគាំទ្របច្ចេកទេស ផ្តល់សម្រាប់ប្រតិបត្តិការធនធានរ៉ែ និងប្រេងកាតដោយផ្អែកតាមការបង់ថ្លៃឈ្នួលសេវាកម្ម ឬតាមកិច្ចសន្យាព្រមព្រៀងរវាងអ្នកជួលនិងអ្នកផ្តល់សេវា។ ពេលគឺរាប់បញ្ចូលសកម្មភាពរួមមានការយកសំណាករ៉ែ ការអង្កេតភូគសាស្ត្រ ខួងរណ្តៅ។ សេវាស្វែងរុករករ៉ែ និងប្រេងកាតតាមរយៈវិធីសាស្ត្រប្រពៃណីនិងធម្មតាជាអាទិ៍៖ ការយកសំណាកនិងការអង្កេតភូគពសាស្ត្រ រាប់ទាំងការខួងអណ្តូងផង ការខួងអណ្តូងប្រេងកាតសម្រាប់ធ្វើតេស្ត ការខួងឡើងវិញចំពោះអណ្តូងប្រេង ប្រភពរ៉ែលោហៈនិងអលោហៈ។ ប្រភេទសេវាគាំទ្រឯកទេសឯទៀតមានដូចជា ការសាងសង់គ្រឹះអណ្តូងប្រេងនិងឧស្ម័ន ការភ្ជាប់បំពង់ផ្ទស់ដោយស៊ីម៉ង់ត៍ ការសម្អាត ការដុសលាង និងការបូមទឹកចេញពីអណ្តូងប្រេង ការបង្ហូរនិងបូមរ៉ែពីអណ្តូង សេវាយកចេញពីអណ្តូងរ៉ែ ។ល។

ក្រុម ០៩១ ៖ សកម្មភាពគាំទ្រសម្រាប់ផលិតកម្មប្រេងកាត

ក្រុមនេះរាប់បញ្ចូលសេវាផលិតកម្មប្រេងកាត ដោយផ្អែកតាមការបង់ថ្លៃឈ្នួលឬតាមកិច្ចសន្យា សេវាពន្លត់អគ្គិភ័យនៅទីតាំងផលិតកម្មប្រេងកាត។

ក្រុម ០៩៩ ៖ សកម្មភាពគាំទ្រសម្រាប់ប្រតិបត្តិការធនធានរ៉ែផ្សេងទៀត

ក្រុមនេះរាប់បញ្ចូលសេវាគាំទ្រដោយផ្អែកលើការបង់ថ្លៃឈ្នួលសេវាកម្មឬតាមកិច្ចសន្យាព្រមព្រៀងគ្នារវាងអ្នកជួលនិងអ្នកផ្តល់សេវាដែលជាតម្រូវការរបស់ប្រតិបត្តិការធនធានរ៉ែនៃផ្នែក ០៥ ០៧ និង ០៨ ។

ជំពូក ខ ៖ ប្រតិបត្តិការធនធានរ៉ែ
ផ្នែក ០៩ ៖ សកម្មភាពសេវាគាំទ្រសម្រាប់ប្រតិបត្តិការធនធានរ៉ែ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
០៩១			**សកម្មភាពគាំទ្រសម្រាប់ផលិតកម្មប្រេងកាត**
	០៩១០[១]		ផលិតកម្មប្រេងកាត
		០៩១០០	ផលិតកម្មប្រេងកាត [២]
០៩៩			**សកម្មភាពគាំទ្រសម្រាប់ប្រតិបត្តិការធនធានរ៉ែផ្សេងទៀត**
	០៩៩០[៣]		សកម្មភាពគាំទ្រសម្រាប់ប្រតិបត្តិការធនធានរ៉ែផ្សេងទៀត
		០៩៩០០	សេវាគាំទ្រដោយផ្អែកលើការបង់ថ្លៃឈ្នួលសេវាកម្មឬតាមកិច្ចសន្យាព្រមព្រៀងគ្នារវាងអ្នកជួលនិងអ្នកផ្តល់សេវានៃផ្នែក ០៥ ០៧ និង ០៨[៤]

(១) **មិនរាប់បញ្ចូល**
(ក) សកម្មភាពសេវាប្រព្រឹត្តិឡើងដោយប្រតិបត្តិករនៃទីតាំងផលិតកម្មប្រេងកាត (មើល ០៦១០, ០៦២០)
(ខ) ការជួសជុលបែបឯកទេស នូវម៉ាស៊ីនរុករករ៉ែ (មើល ៣៣១២០)
(គ) ការពង្រាវនិងការបំលែងប្រេងកាតសម្រាប់គោលបំណងដឹកជញ្ជូនដែលប្រព្រឹត្តិឡើងនៅក្រៅទីតាំងផលិតកម្មប្រេងកាត (មើល ៥២២១៩)
(ឃ) ការអង្កេតខាងរូបភូគព្ភសាស្ត្រ ភូគព្ភសាស្ត្រ និងខាងវលករញ្ជួយដី (មើល ៧១១០០)។

(២) **រាប់បញ្ចូល**
(ក) សេវាស្វែងរុករកដែលជាប់ទាក់ទងជាមួយផលិតកម្មប្រេងកាត (ឧ.វិធីសាស្ត្របុរេសនាធម្មតាដូចជាការអង្កេតបែបភូគព្ភសាស្ត្រនៅទីតាំងបុរេសនាអណ្តូងរ៉ែសក្តានុពល)
(ខ) ការខួងទ្រេតនិងខួងឡើងវិញ ការចាប់ផ្តើមខួងអណ្តូង ការតម្លើងបមខួង ការជួសជុលនិងការរុះរើ ការភ្ជាប់បំពង់ផ្ទស់ដោយស៊ីម៉ងត៍ ការបូមវត្ថុរាវក្នុងអណ្តូង ការបិទអណ្តូងនិងការបោះបង់ចោលអណ្តូង។ល។
(គ) ការពង្រាវនិងការបំប្លែងឧស្ម័នធម្មជាតិសម្រាប់គោលបំណងដឹកជញ្ជូនដែលប្រព្រឹត្តិឡើងនៅក្រៅផលិតកម្មប្រេងកាត
(ឃ) សេវាបូមប្រេងកាតនិងធ្វើទបង្ហូរ ផ្អែកតាមការបង់ថ្លៃឈ្នួលសេវាឬតាមកិច្ចសន្យាបន្ត
(ង) ការខួងអណ្តូងសម្រាប់ធ្វើតេស្តទាក់ទងនឹងផលិតកម្មប្រេងកាត ។

(៣) **មិនរាប់បញ្ចូល**
(ក) ប្រតិបត្តិការកន្លែងយកធនធានរ៉ែផ្អែកតាមការបង់ថ្លៃឈ្នួលឬតាមកិច្ចសន្យាព្រមព្រៀងគ្នារវាងអ្នកជួលនិងអ្នកផ្តល់សេវាកម្ម (មើលផ្នែក ០៥ ០៧ ឬ ០៨)
(ខ) ការជួសជុលបែបឯកទេស នូវម៉ាស៊ីនរុករករ៉ែ (មើល ៣៣១២០)
(គ) សេវាអង្កេតបែបរូបភូគព្ភសាស្ត្រ ផ្អែកតាមការបង់ថ្លៃឈ្នួលឬតាមកិច្ចសន្យា (មើល ៧១១០០)។

(៤) **រាប់បញ្ចូល**
(ក) សេវារុករករ៉ែ (ឧ. វិធីសាស្ត្ររកអណ្តូងរ៉ែតាមប្រពៃណី ដូចជា ការសង្កេតបែបភូគព្ភសាស្ត្រនៅកន្លែងអណ្តូងរ៉ែសក្តានុពល)
(ខ) សេវាបូមនិងធ្វើទបង្ហូរ ផ្អែកតាមការបង់ថ្លៃឈ្នួលឬតាមកិច្ចសន្យា
(គ) ការបោះប្រហោងសាកល្បង និងការខួងសាកល្បង
(ឃ) សេវាកម្មសម្អាត។

ជំពូក គ ៖ កម្មន្តសាល

កម្រិត	ច.ស.វ.ក
ជំពូក	១
ផ្នែក	២៦៤
ក្រុម	៧១
ថ្នាក់	១៧៦
ថ្នាក់រង	២៦១

ជំពូកនេះគ្រប់ដណ្តប់ជាទូទៅលើសកម្មភាពឧស្សាហកម្ម ឬសកម្មភាពពាក់ព័ន្ធនឹងផលិតកម្ម ទ្រង់ទ្រាយតូច និងទ្រង់ទ្រាយធំ (កម្មន្តសាល)។

ជំពូកមួយនេះត្រូវបានចែកចេញជា ២៤ ផ្នែកសំខាន់ៗ ដូចជា៖ ផលិតកម្មនៃផលិតផលម្ហូបអាហារ កម្មន្តសាលភេសជ្ជៈ កម្មន្តសាលផលិតផលថ្នាំជក់ កម្មន្តសាលវាយនភ័ណ្ឌ កម្មន្តសាលសម្លៀកបំពាក់ កម្មន្តសាលស្បែកនិងផលិតផលស្បែកដទៃទៀត កម្មន្តសាលនៃឈើ និងផលិតផលពីឈើនិងឈើស្មោលើកលែងតែគ្រឿងសង្ហារិម កម្មន្តសាលរបស់របរពីចំបើង និងវត្ថុជាតុក្រង កម្មន្តសាលក្រដាសនិងផលិតផលក្រដាស ការបោះពុម្ព និងការផលិតសារឡើងវិញនូវឯកសារដែលបានថតចម្លងទុក កម្មន្តសាលធ្យូងកក់ និងផលិតផល កាកសំណល់ប្រេងកាតឆៅចម្រាញ់រួច កម្មន្តសាលគីមី និងផលិតផលគីមី កម្មន្តសាលឱសថសារជាតុគីមីសម្រាប់ព្យាបាលនិងផលិតផលថ្នាំធ្វើពីរុក្ខជាតិ កម្មន្តសាលផលិតផលពីកៅស៊ូនិងប្លាស្ទិក កម្មន្តសាលផលិតផលពីរ៉ែអលោហៈដទៃទៀត កម្មន្តសាល លោហជាតុមូលដ្ឋាន កម្មន្តសាល ផលិតផលពីលោហជាតុកែច្នៃលើកលែងម៉ាស៊ីននិងបរិក្ខារ កម្មន្តសាលផលិតផលកុំព្យូទ័រអេឡិចត្រូនិក និងអុបទិក កម្មន្តសាល បរិក្ខារអគ្គិសនី កម្មន្តសាល គ្រឿងម៉ាស៊ីននិងបរិក្ខារដែលពុំបានរាប់បញ្ចូល កម្មន្តសាលយានយន្ត រ៉ឺម៉កសណ្តោងនិងរ៉ឺម៉កពាក់កណ្តាលសណ្តោង កម្មន្តសាលបរិក្ខារដឹកជញ្ជូនដទៃទៀត កម្មន្តសាលគ្រឿងសង្ហារិម កម្មន្តសាលផ្សេងៗទៀត និងការជួសជុលនិងដំឡើងម៉ាស៊ីន និងគ្រឿងបរិក្ខាររបស់ម៉ាស៊ីន។

ជំពូក គ ៖ កម្មន្តសាល
ផ្នែក ១០ ៖ ផលិតកម្មនៃផលិតផលម្ហូបអាហារ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
១០១			**ការកែច្នៃ និងថែរក្សាទុកសាច់**
	១០១០		សត្តឃាត និងការវេចខ្ចប់សាច់ (លើកលែងបសុបក្សី)
		១០១០១	សត្តឃាត និងការវេចខ្ចប់សាច់គោ និងសាច់ក្របី
		១០១០២	សត្តឃាត និងការវេចខ្ចប់សាច់ជ្រូក
		១០១០៩	សត្តឃាត និងការវេចខ្ចប់សាច់ ដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- ដំណើរការរបស់សត្តឃាតដ្ឋាន ដែលពាក់ព័ន្ធនឹងការសម្លាប់ ការបកស្បែក និងការវេចខ្ចប់៖ សាច់គោ សាច់ជ្រូក កូនចៀម ទន្សាយ ចៀម អូដ្ឋ ។ល។
- ផលិតកម្មសាច់ស្រស់ សាច់ទាំងមូល
- ផលិតកម្មសាច់ស្រស់ សាច់ដោយកាត់ជាដុំ
- ផលិតកម្មសាច់ស្រស់ សាច់តាមផ្នែក។

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	១០១១		សត្តឃាត និងការវេចខ្ចប់សាច់បសុបក្សី
		១០១១១	សត្តឃាត និងការវេចខ្ចប់សាច់មាន់
		១០១១២	សត្តឃាត និងការវេចខ្ចប់សាច់ទា
		១០១១៣	សត្តឃាត និងការវេចខ្ចប់សាច់ក្អួច
		១០១១៩	សត្តឃាតនិងការវេចខ្ចប់សាច់បក្សាបក្សីដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- ដំណើរការរបស់សត្តឃាតដ្ឋាន ដែលពាក់ព័ន្ធនឹងការសម្លាប់ ការបកស្បែក និងការវេចខ្ចប់
- ផលិតកម្មសាច់បសុបក្សីស្រស់ សាច់ទាំងមូល
- ផលិតកម្មសាច់បសុបក្សីស្រស់ សាច់កាត់ជាដុំ
- ផលិតកម្មសាច់បសុបក្សីស្រស់ សាច់តាមផ្នែក

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	១០១២		ការកែច្នៃ និងថែរក្សាសាច់និងផលិតផលសាច់សត្វបសុបក្សី
		១០១២១	ផលិតកម្មសាច់បង្អក
		១០១២២	ផលិតកម្មសម្ងួត ប្រឡាក់ ឬឆ្អើរសាច់
		១០១២៣	ផលិតកម្មសាច់អាំង
		១០១២៤	ផលិតកម្មផ្អកសាច់
		១០១២៥	ផលិតកម្មសាច់ក្រក
		១០១២៦	ផលិតកម្មប្រហិត
		១០១២៩	ការកែច្នៃ និងការរក្សាសាច់និងផលិតផលសាច់សត្វបសុបក្សី ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- ផលិតកម្មសាច់ស្រស់ បង្កក ឬត្លាសេសាច់ទាំងមូល
- ផលិតកម្មសាច់ស្រស់ បង្កក ឬត្លាសេសាច់ដោយកាត់ជាដុំ
- ផលិតកម្មសាច់ស្រស់ បង្កក ឬត្លាសេសាច់តាមផ្នែក
- ផលិតកម្មសម្ងួត ប្រឡាក់ ឬឆ្អើរសាច់
- ផលិតកម្មផលិតផលសាច់៖ សាច់ក្រក សាឡាមី(សាច់ក្រកសាច់ជ្រូកលាយសាច់គោ) ផាត់ឌីញ ប៉ូឡូញ៉ា សាច់ប៉ាតេ សាច់រីលែតស៍ សាច់ស្ងោរ

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរនូវ៖

- ការសម្លាប់និងការកែច្នៃត្រីបាឡែន ប្រព្រឹត្តទៅនៅលើគោកឬលើកប៉ាល់ពិសេស
- ផលិតកម្មស្បែកសត្វដែលបានពីសត្តឃាតដ្ឋាន រាប់ទាំងការបោចរោមសត្វ
- ការចំហៀរខ្លាញ់ជ្រូក និងខ្លាញ់ដែលអាចបរិភោគបាន ពីប្រភពខ្លាញ់សត្វ
- ការកែច្នៃគ្រឿងក្នុងសត្វ
- ផលិតកម្មកាត់រោមចៀម
- ផលិតកម្មស្លាបសត្វ និងរោមសត្វ។

១០២ **ការកែច្នៃនិងរក្សាទុកសាច់ត្រី សន្ទវន្តសត្វ(បង្កង ក្តាម) និងសិប្បីសត្វ(ខ្យង គ្រុំ)**

១០២០ ការកែច្នៃនិងការរក្សាទុក នូវសាច់ត្រីនិងផលិតផលត្រី (ស្រស់ បង្កក ឬត្លាសេ)

១០២០១ ការកែច្នៃនិងការថែរក្សាទុកសាច់ត្រីទុកដោយត្លាសេ ត្លាសេក្នុងកម្រិតខ្ពស់
១០២០២ ផលិតកម្មសម្ងួត ប្រឡាក់ ឬឆ្អើរត្រី
១០២០៣ ផលិតកម្មប្រហុកផ្អក
១០២០៤ ផលិតកម្មប្រហិតត្រី
១០២០៩ ការកែច្នៃ និងការរក្សាទុកសាច់ត្រី និងផលិតផលសាច់ត្រី សាច់ត្រីស្រស់ បង្កក ឬត្លាសេ ដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- ការរៀបចំ និងថែរក្សាសាច់ត្រី ដោយត្លាសេ ត្លាសេកម្រិតខ្ពស់ សម្ងួត ឆ្អើរ ប្រឡាក់ ត្រាំទឹកអំបិល ។ល។
- ផលិតកម្មផលិតផលត្រី៖ ការចម្អិនត្រី ពន្លះសាច់ត្រី ពងត្រី ពងត្រីប្រឡាក់ ពងត្រីប្រឡាក់ផ្សំគ្រឿង ។ល។
- ផលិតកម្មអាហារពីត្រី សម្រាប់ចំណីមនុស្សនិងចំណីសត្វ
- ផលិតកម្មអាហារនិងអាហារដែលរលាយ ចេញពីត្រី

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរ៖

- សកម្មភាពកប៉ាល់ដែលពាក់ព័ន្ធតែការកែច្នៃ និងរក្សាទុកត្រី។

១០២១ ១០២១០ ផលិតកម្មត្រីខកំប៉ុង

ថ្នាក់នេះរាប់បញ្ចូល៖

- ការច្រកត្រីចូលក្នុងកំប៉ុង។

១០២២ ១០២២០ ការកែច្នៃ និងការថែរក្សា សន្តវន្តសត្វ(បង្កង ក្តាម) និងសិប្បីសត្វ(ខ្យង គ្រុំ)

ថ្នាក់នេះរាប់បញ្ចូល៖

- ការរៀបចំ និងថែរក្សា សន្តវន្តសត្វ និងសិប្បីសត្វ ដោយក្លាសេ ក្លាសេកម្រិតខ្ពស់ សម្ងួត ឆ្អើរ ប្រឡាក់ ត្រាំទឹកអំបិល ។ល។

១០២៣ ១០២៣០ ផលិតកម្ម សន្តវន្តសត្វ និងសិប្បីសត្វកំប៉ុង

ថ្នាក់នេះរាប់បញ្ចូល៖

- ការច្រកសន្តវន្តសត្វនិងសិប្បីសត្វ ចូលក្នុងកំប៉ុង។

១០២៤ ១០២៥០ ផលិតកម្ម និងការកែច្នៃសារ៉ាយសមុទ្រ

ថ្នាក់នេះរាប់បញ្ចូល៖

- ការកែច្នៃសារ៉ាយសមុទ្រ។

១០២៩ ការកែច្នៃនិងរក្សាទុក សាច់ត្រីនិងផលិតផលគ្រឿងសមុទ្រ ដទៃទៀតដែលពុំបានរាប់បញ្ចូល

១០២៩១ ការកែច្នៃផលិតផលគ្រឿងសមុទ្រចំហុយ

១០២៩២ ផលិតកម្មត្រីសមុទ្រក្រៀម (បង្គារ មឹក)

១០២៩៣ ផលិតកម្មកាពិ

១០២៩៩ ការកែច្នៃនិងរក្សាទុក ផលិតផលត្រីនិងគ្រឿងសមុទ្រ ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- ផលិតកម្មអាហារ និងអាហារដែលលាយបាន ធ្វើពីសត្វសមុទ្រឯទៀតដែលមិនមែនសម្រាប់ចំណីមនុស្ស។

១០៣ ការកែច្នៃនិងការរក្សាទុក ផ្លែឈើនិងបន្លែ

១០៣០ ការកែច្នៃនិងការរក្សាទុក ផ្លែឈើនិងបន្លែ

១០៣០១ ការកែច្នៃនិងការរក្សាទុកផ្លែឈើ

១០៣០២ ការកែច្នៃនិងការរក្សាទុកបន្លែ

១០៣០៣ ការកែច្នៃនិងការរក្សាទុកគ្រាប់ផ្លែឈើក្រៀម

១០៣០៩ ការកែច្នៃនិងការរក្សាទុក ផ្លែឈើនិងបន្លែ ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលអាហារដែលមានជាតុផ្សំចម្បងពីផ្លែឈើ ឬបន្លែ លើកលែងតែអាហារដាក់ចាន ដែលក្លាសេ ឬច្រកកំប៉ុង
- ការថែរក្សាផ្លែឈើ គ្រាប់ផ្លែឈើ ឬបន្លែ៖ ក្លាសេ សម្ងួត ត្រាំក្នុងប្រេង ឬទឹកខ្មេះ ។ល។
- កម្មន្តសាលផលិតផលអាហារ ពីផ្លែឈើឬបន្លែ
- កម្មន្តសាលដំណាប់ផ្លែឈើ ដំណាប់ម៉ាម៉ាឡែដ និងចាហួយ
- ការកែច្នៃ និងថែរក្សាដំឡូង៖
    - កម្មន្តសាលក្លាសេដំឡូងរៀបចំរួច
    - កម្មន្តសាលដកជាតិទឹកពីដំឡូងកិនរួច
    - កម្មន្តសាលអាហារសម្រន់ពីដំឡូង
    - កម្មន្តសាលដំឡូងស្រួយ
    - កម្មន្តសាលម្សៅដំឡូង និងអាហារពីដំឡូង
- លីងគ្រាប់ផ្លែឈើ
- កម្មន្តសាលអាហារ និងម្សៅពីគ្រាប់ផ្លែឈើ។

១០៣១ ផលិតកម្មផ្លែឈើនិងបន្លែច្រកកំប៉ុង

១០៣១១ ផលិតកម្មបន្លែច្រកកំប៉ុង

១០៣១២ ផលិតកម្មផ្លែឈើច្រកកំប៉ុង

ថ្នាក់នេះរាប់បញ្ចូល៖

- ការច្រក ផ្លែឈើ គ្រាប់ផ្លែឈើ ឬបន្លែក្នុងកំប៉ុង។

១០៣២ ផលិតកម្មទឹកផ្លែឈើឬទឹកបន្លែ

១០៣២១ ផលិតកម្មទឹកផ្លែឈើ

១០៣២២ ផលិតកម្មទឹកបន្លែ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលទឹកផ្លែឈើ ឬទឹកបន្លែ។

១០៣៩ ផលិតកម្មទឹកផ្លែឈើឬទឹកបន្លែ ដទៃទៀតដែលពុំបានរាប់បញ្ចូល

១០៣៩១ ផលិតកម្មផលិតផលសណ្តែកសៀងផ្អាប់

១០៣៩២ ផលិតកម្មតៅហ៊ូ

១០៣៩៩ ផលិតកម្មផលិតផលផ្លែឈើ ឬបន្លែ ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- ឧស្សាហកម្មចិតសម្បកដំឡូង
- ផលិតកម្មកុងសង់ត្រេតពីផ្លែឈើស្រស់ ឬបន្លែដូចជា៖
    - សាឡាដ
    - បន្លែដែលកាត់ ឬចិតសម្បករួច
    - តៅហ៊ូ (គ្រាប់សណ្តែក)។

១០៤ **កម្មន្តសាលប្រេងនិងខ្លាញ់ ដែលបានពីបន្លែនិងសត្វ**

១០៤០ កម្មន្តសាលប្រេងនិងខ្លាញ់ ដែលបានពីបន្លែនិងសត្វ (លើកលែងប្រេងដូងប្រេង ប្រេងដូង និងប្រេងពោត)

១០៤០១ កម្មន្តសាលប្រេងដែលបានពីបន្លែ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលប្រេងឆៅពីបន្លែ៖ ប្រេងអូលីវ ប្រេងសណ្តែក ប្រេងគ្រាប់ផ្កាឈូករ័ត្ន ប្រេងគ្រាប់កប្បាស ប្រេងរ៉េប ប្រេងកូលសា ឬម៉ាស្តាត ប្រេងធ្មៃ ។ល។
- កម្មន្តសាលប្រេងចម្រាញ់ពី៖ ប្រេងអូលីវ ប្រេងសណ្តែក ។ល។
- ការកែច្នៃប្រេងបន្លែ ៖ ការកៀបយកប្រេង ការស្ងោររម្ងាស់ ការដកជាតិទឹកចេញ ការបញ្ចូលអ៊ីដ្រូហ្សែន ។ល។
- កម្មន្តសាលនៃក្រណាត់សំឡី នំខេកប្រេង និងផលិតផលដទៃទៀតនៅសល់ក្នុងផលិតកម្មប្រេង

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលប្រេងចម្រាញ់ចេញពីរុក្ខជាតិសម្រាប់គ្រឿងសម្អាង (មើល ២០២៩)
- ការព្យាបាលដោយប្រើប្រេង និងសារធាតុខ្លាញ់តាមដំណើរការគីមី (មើល ២០២៩)។

១០៤១ ១០៤១០ កម្មន្តសាលប្រេងដូង នំធ្វើពីសាច់ដូងស្ងួតអាហារ និងនំគ្រាប់តូចៗធ្វើពីសាច់ដូង

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលប្រេងដូង នំធ្វើពីសាច់ដូងស្ងួត អាហារ និងនំគ្រាប់តូចៗធ្វើពីសាច់ដូង។

១០៤២ ១០៤២០ កម្មន្តសាលប្រេងពីដូងប្រេង

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលប្រេងពីដូងប្រេង

១០៤៣ ១០៤៣០ កម្មន្តសាលប្រេងពោត

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលប្រេងពោត

១០៤៤ ១០៤៤០ កម្មន្តសាលប្រេង និងខ្លាញ់ដែលបានពីសត្វ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលប្រេងនិងខ្លាញ់ នៅឆៅនិងចម្រាញ់រួចពីសត្វ
- កម្មន្តសាលប្រេងនិងខ្លាញ់សត្វ ដែលមិនអាចបរិភោគបាន
- ការចម្រាញ់ខ្លាញ់និងប្រេង ចេញពីត្រី និងថនិកសត្វសមុទ្រដទៃទៀត

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ការចំហៀវ និងចម្រាញ់ខ្លាញ់ជ្រូក និងខ្លាញ់ដែលអាចបរិភោគបាន ពីសត្វដទៃទៀត(មើល ១០១០)។

១០៤៩ ១០៤៩០ កម្មន្តសាលប្រេង និងខ្លាញ់ដែលបានពីបន្លែនិងសត្វ ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលម្សៅដែលពុំទាន់បានដកជាតិខ្លាញ់ចេញ ឬអាហារពីគ្រាប់ផ្លែរុក្ខជាតិ និងគ្រាប់រុក្ខជាតិប្រេង ឬប្រេងកន្ទក់
- កម្មន្តសាលម៉ាហ្គារីន
- កម្មន្តសាលល្បាយ (ប្រេង-ខ្លាញ់) និងការលាយស្រដៀងគ្នា
- កម្មន្តសាលខ្លាញ់សមាសអាចបរិភោគបាន

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលប្រេងចម្រាញ់ចេញពីរុក្ខជាតិសម្រាប់គ្រឿងសម្អាង (មើល ២០២៩)
- ការព្យាបាលដោយប្រើប្រេង និងសារធាតុខ្លាញ់តាមរយៈដំណើរការបែបគីមី (មើល ២០២៩)។

១០៥ កម្មន្តសាលផលិតផលធ្វើពីទឹកដោះគោ

១០៥០ ១០៥០០ ការកែច្នៃទឹកដោះគោស្រស់និងកម្មន្តសាលនៃក្រែម

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលទឹកដោះគោរាវស្រស់ ទឹកដោះគោដែលធ្វើប៉ាស្ទ័រកម្ម សម្លាប់មេរោគរួច ទឹកដោះលាយ ក្រែមស្មើសាច់ ប្រព្រឹត្តកម្មតាមវិធីអ៊ុលត្រាកម្តៅ
- កម្មន្តសាលភេសជ្ជៈមានមូលដ្ឋានពីទឹកដោះគោ
- កម្មន្តសាលក្រែមធ្វើពីទឹកដោះគោរាវស្រស់ ប៉ាស្ទ័រកម្មរួច សម្លាប់មេរោគរួច លាយក្រែមស្មើសាច់រួច។

១០៥១ ១០៥១០ កម្មន្តសាលទឹកដោះម្សៅនិងទឹកដោះគោខាប់ឬទឹកដោះគោបង្អួត (បំពេញផ្សំបញ្ចូលគ្នាឬលាយសារឡើងវិញ)

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលទឹកដោះគោស្ងួត ឬទឹកដោះគោខាប់ទោះជាផ្អែម និងមិនផ្អែមក៏ដោយ
- កម្មន្តសាលទឹកដោះគោ ឬក្រែមជាទម្រង់ជារឹង។

១០៥២ កម្មន្តសាលការ៉េមនិងការ៉េមប្រអប់ទឹកកកអនាម័យ ការ៉េមដើមនិងទឹកកករសជាតិដទៃទៀត

១០៥២១ កម្មន្តសាលការ៉េម

១០៥២២ កម្មន្តសាលការ៉េមប្រអប់ទឹកកក ការ៉េមដើម និងទឹកកករសជាតិដទៃទៀត

១០៥២៩ កម្មន្តសាលការ៉េមការ៉េមប្រអប់ទឹកកកអនាម័យការ៉េមដើម និងទឹកកករសជាតិដទៃទៀត ដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលការ៉េម និងទឹកកកដែលអាចបរិភោគបានដទៃទៀត ដូចជា ទឹកកកមានរសជាតិផ្សេងៗ។

១០៥៣ ១០៥៣០ កម្មន្តសាលផលិតផលពីទឹកដោះគោដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលប៊ឺរ
- កម្មន្តសាលទឹកដោះគោជូរ
- កម្មន្តសាលហ្វ្រូម៉ាស និងទឹកដោះគោខាប់
- កម្មន្តសាលទឹកដោះគោថ្លា
- កម្មន្តសាលកាសេអ៊ីន ឬឡាក់តូស។

១០៦ **កម្មន្តសាលផលិតផលពីការកិនគ្រាប់ធញ្ញជាតិម្សៅ អាមីដុង និងផលិតផលធ្វើពីម្សៅអាមីដុង**

១០៦១ កម្មន្តសាល ផលិតផលពីការកិនគ្រាប់ធញ្ញជាតិ (លើកលែងអង្ករ/ពោត)

១០៦១១ ការកែច្នៃគ្រាប់ធញ្ញជាតិដែលបានកិន លើកលែងអង្ករ/ពោត

១០៦១៩ កម្មន្តសាល ផលិតផលពីការកិនគ្រាប់ធញ្ញជាតិដទៃទៀត (លើកលែងអង្ករ/ពោត) ដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- ការកិនគ្រាប់ធញ្ញជាតិ៖ ផលិតកម្មម្សៅមីម្សៅហ្រ្គូត កិនស្រូវសាលីពូតជាដុំ ស្រូវរ៉ៃ ស្រូវអូត ឬគ្រាប់ធញ្ញជាតិដទៃទៀត
- ការកិនបន្លែ៖ ផលិតកម្មម្សៅ ឬអាហារពីបន្លែក្រៀម ឫសមើម ឬគ្រាប់ផ្លែឈើដែលអាចបរិភោគបាន
- កម្មន្តសាលអាហារពេលព្រឹកពីគ្រាប់ធញ្ញជាតិ
- កម្មន្តសាលម្សៅលាយ និងម្សៅលាយស្រេច និងម្សៅលាយទឹកសម្រាប់ធ្វើនំប៉ុង នំខេក នំប៊ីស្គីត ឬនំអំបែង

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលម្សៅដំឡូងបារាំង និងអាហារ(មើល ១០៣១)
- ការកិនពោតសើម (មើល ១០៦៣)។

១០៦២ កម្មន្តសាលម្សៅអាមីដុង និងផលិតផលពីម្សៅអាមីដុង (លើកលែងអង្ករ/ពោត)

១០៦២១ កម្មន្តសាលម្សៅ

១០៦២២ កម្មន្តសាលផលិតផលធ្វើពីម្សៅ

១០៦២៩ កម្មន្តសាលម្សៅអាមីដុងនិងផលិតផលធ្វើពីម្សៅអាមីដុង ដទៃទៀត (លើកលែងអង្ករ/ពោត)ដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលគ្លុយកូស ទឹកស៊ីរ៉ូគ្លុយកូស ម៉ាល់តូស អ៊ីនុយលីន ។ល។
- កម្មន្តសាលគ្លុយតិន
- កម្មន្តសាលម្សៅអាមីដុងពីដំឡូងមីនិងម្សៅអាមីដុងជំនួសពីដំឡូងមី ហើយរៀបចំរួច

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលឡាក់តូស (ជាតិស្ករពីទឹកដោះគោ) (មើល ១០៥៩)
- ផលិតកម្មស្ករអំពៅ ឬពីផៃថាវស្ករ(មើល ១០៧២)
- កម្មន្តសាលប្រេងពោត (មើល ១០៤៤)

១០៦៣ ការកិនអង្ករ/ពោត និងកម្មន្តសាលម្សៅពីអង្ករ/ពោត

១០៦៣១ ការកិនស្រូវ

១០៦៣២ ការកិនពោត

១០៦៣៣ កម្មន្តសាលម្សៅពីអង្ករ/ពោត

ថ្នាក់នេះរាប់បញ្ចូល៖

- ការកិនគ្រាប់ធញ្ញជាតិ៖ ផលិតកម្មម្សៅមី ម្សៅហ្គ្រូត អាហារ ឬនំគ្រាប់តូចៗធ្វើពីពោត
- ការកិនស្រូវ៖ ផលិតកម្មបកសម្បក កិន ស្រិត ធ្វើឲ្យរលោង សោរឆ្អិនល្អ ឬកែច្នៃអង្ករ ផលិតកម្មម្សៅអង្ករ

ថ្នាក់នេះក៏បានបញ្ចូលផងដែរនូវ៖

- កម្មន្តសាលម្សៅអាមីដុងពីអង្ករ និងពោត
- ការកិនពោតសើម។

១០៧ កម្មន្តសាលនៃផលិតផលអាហារផ្សេងទៀត

១០៧១ កម្មន្តសាលនំដុត

១០៧១១ កម្មន្តសាលនំប៉័ង

១០៧១២ កម្មន្តសាលនំខេក និង/ឬអាហារសម្រន់

១០៧១៣ កម្មន្តសាលអំបុកខ្មែរ

១០៧១៩ កម្មន្តសាលនំដុតដទៃទៀតដែលពុំបានរាប់បញ្ចូល

ក្រុមនេះរាប់បញ្ចូលនូវកម្មន្តសាល នំដុតស្រស់ ក្លាសេ និងស្ងួត។

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលនំប៉័ង និងនំប៉័ងរ៉ូល
- កម្មន្តសាលនំស្រស់ធ្វើពីម្សៅប៉ាស្រ្ទី នំខេក នំផាយ នំតាត ។ល។
- កម្មន្តសាលនំក្រៀម នំប៊ីស្គីត និង ផលិតផលនំដុត "ស្ងួត" ដទៃទៀត
- កម្មន្តសាលនំប៉ាស្រ្ទីរក្សាទុកបានយូរ និងនំខេក
- កម្មន្តសាលផលិតផលអាហារសម្រន់ (នំគុកគី នំស្រួយនំប្រឹតហ្សែល ។ល។) ដែលផ្អែម ឬប្រៃ
- កម្មន្តសាលពោត
- កម្មន្តសាលផលិតផលនំដុតក្លាសេ ដូចជា នំអំបែង នំពុម្ព នំរ៉ូល ។ល។

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលផលិតផលពីម្សៅមី (ប៉ាស្តា) (មើល ១០៧៤)
- កម្មន្តសាលអាហារសម្រន់ពីដំឡូង (មើល ១០៣១)
- ការកម្តៅនំដុតសម្រាប់ពិសារភ្លាមៗ (មើលផ្នែក៥៦)។

១០៧២　　　　កម្មន្តសាលស្ករ

១០៧២១　កម្មន្តសាលស្ករត្នោត

១០៧២២　កម្មន្តសាលស្ករស/ស្ករអំពៅ

១០៧២៩　កម្មន្តសាលស្ករដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ឬការចម្រាញ់ស្ករស (ជាតិស្ករក្នុងរុក្ខជាតិ) និងផលិតផលជំនួសស្ករដែលបានមកពីទឹកអំពៅ ឆៃថាវស្ករ ដើមឈើម៉ាផល និងត្នោត
- កម្មន្តសាលទឹកស្ករស៊ីរ៉ូ
- កម្មន្តសាលទឹករង្វៀ
- ការផលិតទឹកស៊ីរ៉ូម៉ាផល និងស្ករ

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលគ្លុយកូស ទឹកស៊ីរ៉ូគ្លុយកូស ម៉ាល់តូស(មើល ១០៦២)។

១០៧៣　១០៧៣០　កម្មន្តសាលកាកាវសូកូឡានិងស្ករគ្រាប់

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលកាការ ប៊ីកាការ ខ្លាញ់កាការ ប្រេងកាការ
- កម្មន្តសាលសូកូឡា និងស្ករសូកូឡា
- កម្មន្តសាលស្ករគ្រាប់ ៖ ស្ករតាំងម៉ៃ ស្ករហិល ស្ករមានលាយគ្រាប់សណ្តែកដី ឬគ្រាប់ផ្លែឈើផ្សេងៗ ស្ករស្អិតសម្រាប់ចាក់ស្រោចលើនំ ស្ករសូកូឡា ។ល។
- កម្មន្តសាលស្ករកៅស៊ូ
- ការរក្សាស្ករ ដែលមានក្នុងផ្លែឈើ គ្រាប់ផ្លែឈើ សម្បកផ្លែឈើ និងផ្នែកផ្សេងទៀតនៃដើមឈើ
- កម្មន្តសាលស្ករគ្រាប់ជាថ្នាំ និងស្ករថ្នាំបៀម

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ផលិតកម្មស្ករស (ជាតិស្ករក្នុងរុក្ខជាតិ)(មើល ១០៧២)

១០៧៤ កម្មន្តសាលមីម៉ាការ៉ូនី មីសរសៃ មីកូស្កូស និងផលិតផលម្សៅមីស្រដៀងគ្នា

១០៧៤១ កម្មន្តសាលគុយទាវ

១០៧៤២ កម្មន្តសាលមី

១០៧៤៩ កម្មន្តសាលមីម៉ាការ៉ូនី មីសរសៃ មីកូស្កូស និងផលិតផលម្សៅមីស្រដៀងគ្នានោះដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលប៉ាស្តា ដូចជា មីម៉ាការ៉ូនី មីសរសៃទោះបីជាចម្អិន ឬមិនចម្អិន ឬវេចខ្ចប់ ក៏ដោយ
- កម្មន្តសាលផលិតផលមីកូស្កូស
- កម្មន្តសាលប៉ាស្តាដែលច្រកដាក់កំប៉ុង ឬក្លាសេ

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលរៀបចំវេចខ្ចប់មីកូស្កូស នោះទេ (មើល ១០៧៥)
- កម្មន្តសាលទឹកស៊ុបដែលមានប៉ាស្តា (មើល១០៧៩)។

១០៧៥ ១០៧៥០ កម្មន្តសាលអាហាររៀបចំរួច និងអាហារវេចខ្ចប់ដាក់ចាន

ថ្នាក់នេះរាប់បញ្ចូល ទាំងអាហារដែលធ្វើរួច និងដាក់ចាន (ឧ. អាហាររៀបចំរួច ផ្សំគ្រឿងរួច និងចម្អិនរួច)។ អាហារដាក់ចានទាំងនេះ ត្រូវបានកែច្នៃរួចសម្រាប់រក្សាទុក ដូចជា ក្លាសេ ឬច្រកដាក់កំប៉ុង ហើយជាធម្មតាខ្ចប់រួច និងបិទស្លាកសញ្ញាសម្រាប់លក់វិញ ជាដើម។ ថ្នាក់នេះមិនរាប់បញ្ចូល នូវការរៀបចំអាហារសម្រាប់ការប្រើប្រាស់ភ្លាមៗទេ ដូចជា នៅក្នុងភោជនីយដ្ឋាន។ គេអាចចាត់ទុកជាអាហារដាក់ចានបាន គឺអាហារដែលមានគ្រឿងផ្សំចម្បងយ៉ាងតិចឲ្យបាន ២ មុខ (លើកលែងតែដាក់គ្រឿង ។ល។)

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលអាហារដាក់ចានពីសាច់ ឬបសុបក្សី
- កម្មន្តសាលអាហារដាក់ចានពីត្រី រួមទាំងត្រី និងបន្ទះសាច់ត្រី
- កម្មន្តសាលអាហារដាក់ចានពីបន្លែរៀបចំរួច
- កម្មន្តសាលអាហារច្រកកំប៉ុងចម្អិនរួច និងអាហាររៀបចំរួចរក្សាទុកក្នុងកញ្ចប់សុញ្ញកាស
- កម្មន្តសាលអាហាររៀបចំរួចឯទៀត (ដូចជា អាហារពេលល្ងាចមើលទូរទស្សន៍ ។ល។)
- កម្មន្តសាលភីហ្សាក្លាសេ ឬភីហ្សារក្សាទុកដទៃទៀត

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលអាហារស្រស់ និងអាហារផ្សំពីគ្រឿងផ្សំសំខាន់តែមួយមុខ (មើលផ្នែក ១០)
- ការលក់ដុំនូវម្ហូបអាហារដែលបានរៀបចំរួច (មើល ៤៦៣០)
- ការលក់រាយនូវម្ហូបអាហារដែលបានរៀបចំរួចក្នុងហាងលក់ទំនិញ (មើល ៤៧១១, ៤៧១២)
- សកម្មភាពសេវាកម្មតាមកិច្ចសន្យាអាហារ (មើល ៥៦២៩)។

១០៧៦ កម្មន្តសាលកាហ្វេតែនិងឱសថរុក្ខជាតិសម្រាប់ផុង

១០៧៦១ កម្មន្តសាលកាហ្វេ

១០៧៦២ កម្មន្តសាលតែ

១០៧៦៩ កម្មន្តសាលកាហ្វេតែនិងឱសថរុក្ខជាតិដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- ការដកយកជាតិកាហ្វេអ៊ីនពីកាហ្វេ និងការលីងកាហ្វេ
- ផលិតកម្មនៃផលិតផលពីកាហ្វេ៖
  - កាហ្វេគ្រាប់
  - កាហ្វេដែលរលាយក្នុងទឹក
  - កុងសង់ត្រេត កាហ្វេ និងចម្រាញ់កាហ្វេ
- កម្មន្តសាលផលិតផលជំនួសកាហ្វេ
- ការលាយតែ និងម៉ាតេ
- កម្មន្តសាលនៃការចម្រាញ់ និងគ្រឿងរៀបចំជាស្រេចពីតែ ឬម៉ាតេជាមូលដ្ឋាន

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរនូវ៖

- កម្មន្តសាលទឹកផុងពីរុក្ខជាតិឱសថ (ជីអង្កាម រុក្ខជាតិវ័រវែន ឆាម៉ូមីល ។ល។)។

១០៧៧ កម្មន្តសាលគ្រឿងទេសដែលបានកែច្នៃ ទឹកជ្រលក់គ្រឿងផ្សំផ្សេងៗ និងផលិតផលសម្រាប់ធ្វើម្ហូបផ្សេងទៀត

១០៧៧១ កម្មន្តសាលគ្រឿងទេសដែលបានកែច្នៃ និងគ្រឿងផ្សំផ្សេងៗ

១០៧៧២ កម្មន្តសាលទឹកជ្រលក់

១០៧៧៣ កម្មន្តសាលទឹកខ្មេះ

១០៧៧៩ កម្មន្តសាលគ្រឿងទេសដែលបានកែច្នៃទឹកជ្រលក់គ្រឿងផ្សំផ្សេងៗ និងផលិតផលសម្រាប់ធ្វើម្ហូបដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលគ្រឿងទេស ទឹកជ្រលក់ និងគ្រឿងផ្សំផ្សេងៗ៖ ទឹកម៉ាយ៉ូណែស, ម្សៅម៉ាស្តាត, និងអាហារម៉ាស្តាតរៀបចំរួច
- កម្មន្តសាលទឹកខ្មេះ
- កម្មន្តសាលទឹកឃ្មុំសិប្បនិម្មិត និងស្ករតាំងម៉ែ

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរ៖

- កម្មន្តសាលចម្រាញ់យកទឹកដមពី សាច់ ត្រី សន្លៃន្តសត្វ ឬសិប្បីសត្វ
- ការកែច្នៃអំបិលទៅជាអំបិលពិសារ ដូចជា អំបិលអ៊ីយ៉ូដ
- កម្មន្តសាលកុងសង់ត្រេត សិប្បនិម្មិត។

១០៧៩ ១០៧៩០ កម្មន្តសាលផលិតផលចំណីអាហារផ្សេងទៀត ដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលទឹកស៊ុប និងទឹកសាច់ម្ទាស់
- កម្មន្តសាលអាហារពិសេស ដូចជា៖
  - o អាហារសម្រាប់កូនក្មេង
  - o ទឹកដោះគោបំប៉ន និងអាហារបំប៉ន
  - o អាហារទារក
  - o អាហារដែលមានគ្រឿងផ្សំលាយស្មើសាច់
- កម្មន្តសាលអាហាររៀបចំរួចដែលអាចខូច ឬរលួយ ៖
  - o សាំងវិច
  - o ភីហ្សាស្រស់ (មិនទាន់ចម្អិន)

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរនូវ៖

- កម្មន្តសាលមេដំបែ
- កម្មន្តសាលទឹកដោះមិនមែនទឹកដោះគោ និងអាហារជំនួសប្រូម៉ា

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ការដាំដុះដំណាំគ្រឿងទេស (មើល ០១២៨)
- កម្មន្តសាល អ៊ីនូលីន(មើល ០១៦២)
- កម្មន្តសាលអាហារផ្សំគ្រឿងរួចដែលងាយខូច ធ្វើពីផ្លែឈើ និងបន្លែ (ឧ. សាឡាដ បន្លែចិត សម្បករួច តៅហ៊ូ) (មើល ១០៣៩)
- ការផលិតភីស្សាបែបបង្កក (មើល ១០៧៥)
- កម្មន្តសាលស្រាស្ពីរីត ស្រាបៀរ ស្រាទំពាំងបាយជូរ និងភេសជ្ជៈ (មើលផ្នែក ១១)
- ការរៀបចំផលិតផលពីរុក្ខជាតិ សម្រាប់ប្រើប្រាស់ជាឱសថ
- ផលិតកម្មនៃផលិតផលទឹកកកដែលមិនមែនជាម្ហូបអាហារ ដើម្បីគោលបំណង (ឧ. ក្លាសេ) (មើល ៣៥៣០)។

១០៨ កម្មន្តសាលចំណីសត្វសម្រេច

១០៨០		កម្មន្តសាលចំណីសត្វសម្រេច
	១០៨០១	កម្មន្តសាលចំណីបសុបក្សី
	១០៨០២	កម្មន្តសាលចំណីជ្រូក
	១០៨០៣	កម្មន្តសាលចំណីត្រី
	១០៨០៩	កម្មន្តសាលចំណីសត្វរៀបចំរួច ដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលចំណីសត្វរៀបចំរួច សម្រាប់សត្វចិញ្ចឹម រាប់បញ្ចូលទាំង ឆ្កែ ឆ្មា បក្សី ត្រី ។ល។
- កម្មន្តសាលចំណីសត្វរៀបចំរួចសម្រាប់ក្នុងកសិដ្ឋាន រួមទាំង កុងសង់ត្រេតចំណីសត្វ ចំណីបន្ថែមរបស់សត្វ
- ចំណីរៀបចំរួចដែលមិនទាន់លាយគ្នា (ចំណីតែមួយមុខ) សម្រាប់សត្វក្នុងកសិដ្ឋាន

ថ្នាក់នេះក៏បានរាប់បញ្ចូលផងដែរ៖

- ប្រព្រឹត្តិកម្មកាកសំណល់ពីសត្តឃាតដ្ឋានដើម្បីផលិតជាចំណីសត្វ

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ផលិតកម្មចំណីពីត្រីសម្រាប់ធ្វើជាចំណីសត្វ (មើល ១០២)
- កម្មន្តសាលនំពីប្រេងធញ្ញជាតិ (មើល ១០៤២)
- លទ្ធផលសកម្មភាពនៃផលិតផលបន្ទាប់បន្សំ ដែលអាចប្រើជាចំណីសត្វបាន ដោយគ្មានប្រព្រឹត្តកម្មពិសេស ឧ. គ្រាប់រុក្ខជាតិមានប្រេង (មើល ១០៤៩) កាកសំណល់ពីការកិនគ្រាប់ធញ្ញជាតិ (មើល ១០៦) ។ល។

ជំពូក គ ៖ កម្មន្តសាល

ផ្នែក ១១ ៖ កម្មន្តសាលភេសជ្ជៈ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
១១០			**កម្មន្តសាលភេសជ្ជៈ**
	១១០១		ការបិត ការបន្សុទ្ធ និងការលាយស្រាស្ពីរីត
		១១០១០	ការបិត ការបន្សុទ្ធ និងការលាយស្រាស្ពីរីត

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលភេសជ្ជៈមានជាតិអាកុល ដោយការបិទ អាចពិសារបាន៖ ស្រាវីស្គី ប្រេនឌី ស្រាហ្សីន លីគឺរ ស្រាលាយ ។ល។
- ការលាយស្រាស្ពីរីត
- ផលិតកម្មស្រាស្ពីរីតណឺត

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលអេទីលអាកុល (មើល ២០១១)
- កម្មន្តសាលភេសជ្ជៈមានជាតិអាកុលដែលមិនប្រើវិធីបិត (មើល ១១០២, ១១០៣)
- ការច្រកដប និងបិទស្លាកសញ្ញា (មើល ៤៦៣០) (ប្រសិនបើសកម្មភាពនោះជាផ្នែកនៃការលក់ដុំ) (មើល ៨៩២២) (ប្រសិនបើសកម្មភាពនោះមានទម្រង់ជាការយកកម្រៃ ឬផ្អែកលើកិច្ចសន្យា)។

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	១១០២		កម្មន្តសាលស្រា (វ៉ាញ)
		១១០២១	កម្មន្តសាលស្រាស្បាកឃ្លីង (ស្រាគ្រឿងផ្សំចំរុះ ពពុះ)
		១១០២២	កម្មន្តសាលស្រាទឹកត្នោត
		១១០២៣	កម្មន្តសាលស្រាទំពាំងបាយជូរ
		១១០២៩	កម្មន្តសាលស្រា (វ៉ាញ) ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលស្រា
- កម្មន្តសាលស្រាគ្រឿងផ្សំចំរុះ ពពុះ
- កម្មន្តសាលស្រាពីក្នុងសង់ត្រេតទឹកដមទំពាំងបាយជូរ
- កម្មន្តសាលភេសជ្ជៈមានជាតិអាល់កុល ដែលបានមកពីការឡើងមេ តែមិនមែនដោយវិធីបិត៖ ស្រា-ស សាកេ ស្រាស៊ីឌ័រ ស្រាភើរី ស្រាមីឌ ស្រាផ្លែឈើ ដទៃទៀត ភេសជ្ជៈចម្រុះដែលមានជាតិអាកុល
- កម្មន្តសាល ស្រាវែរមូត និងស្រដៀងគ្នា

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរ៖

- ការលាយស្រា (វ៉ាញ)
- កម្មន្តសាលស្រាដែលមានជាតិអាកុលទាប ឬគ្មានជាតិអាកុល

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលទឹកខ្មេះ (មើល ១០៧៧)
- ការច្រកដប និងការបិតស្លាកសញ្ញា (មើល ៤៦៣០) (ប្រសិនបើសកម្មភាពនោះជាផ្នែកនៃការលក់ដុំ) (មើល ៨៩២២) (ប្រសិនបើសកម្មភាពនោះមានទម្រង់ជាការយកកម្រៃ ឬផ្អែកលើកិច្ចសន្យា)។

១១០៣ កម្មន្តសាលស្រាម៉ល់និងម៉ល់

១១០៣១ កម្មន្តសាលស្រាបៀរ

១១០៣៩ កម្មន្តសាលស្រាម៉ល់និងម៉ល់ ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- ការផលិតស្រាម៉ល់ ដូចជា ស្រាបៀរ អាលេ ពកទ័រ និងស្តោត
- កម្មន្តសាលម៉ល់

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរនូវ៖

- កម្មន្តសាលស្រាបៀរដែលមានជាតិអាកុលទាប ឬគ្មានជាតិអាកុល។

១១០៤ កម្មន្តសាលភេសជ្ជៈគ្មានជាតិអាកុល ទឹកមានសារធាតុរ៉ែ និងទឹកដែលច្រកដបផ្សេងៗទៀត

១១០៤១ កម្មន្តសាលភេសជ្ជៈគ្មានជាតិអាកុល

១១០៤២ ការផលិតទឹកសូដា

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលភេសជ្ជៈគ្មានជាតិអាកុល លើកលែងតែស្រាបៀរ និងស្រាទំពាំងបាយជូរគ្មានជាតិអាកុល
- កម្មន្តសាលភេសជ្ជៈគ្មានជាតិអាកុល
    - ទឹកគ្មានជាតិអាកុលឬមានជាតិផ្អែម៖ លីម្មូណាត ទឹកក្រូច កូឡា ទឹកផ្លែឈើ ភេសជ្ជៈប៉ូវកម្លាំង។

១១០៥ ១១០៥០ កម្មន្តសាលទឹកបរិសុទ្ធ និងទឹករ៉ែ

ថ្នាក់នេះរាប់បញ្ចូល៖

- ផលិតកម្មនៃទឹកខនិជនិងទឹកបរិសុទ្ធច្រកដបដទៃទៀត។

១១០៩ ១១០៩០ កម្មន្តសាលភេសជ្ជៈ ដទៃទៀតដែលពុំបានរាប់បញ្ចូល

ជំពូក គ ៖ កម្មន្តសាល
ផ្នែក ១២ ៖ កម្មន្តសាលផលិតផលថ្នាំជក់

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
១២០			**កម្មន្តសាលផលិតផលថ្នាំជក់**
	១២០០		កម្មន្តសាលបារីនិងស៊ីហ្គា
		១២០០០	កម្មន្តសាលបារីនិងស៊ីហ្គា

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលផលិតផលថ្នាំជក់ និងផលិតផលជំនួសថ្នាំជក់ ៖ បារីគ្រប់ប្រភេទ។

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	១២០៩		កម្មន្តសាលផលិតផលថ្នាំជក់ដទៃទៀតដែលពុំបានរាប់បញ្ចូល
		១២០៩០	កម្មន្តសាលផលិតផលថ្នាំជក់ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាំនេះរាប់បញ្ចូល៖

- កម្មន្តសាលផលិតផលថ្នាំជក់ និងផលិតផលជំនួសថ្នាំជក់៖ ថ្នាំជក់សម្រាប់ខ្សៀរ ថ្នាំជក់សម្រាប់ចុក ថ្នាំជក់សម្រាប់ហឺត
- កម្មន្តសាលថ្នាំជក់លាយស្មើសាច់ ឬផលិតសារឡើងវិញ

ថ្នាំនេះមិនរាប់បញ្ចូល៖

- ការបូតទងថ្នាំ និងការសម្ងួតសន្លឹកថ្នាំឡើងវិញ។

ជំពូក គ ៖ កម្មន្តសាល

ផ្នែក ១៣ ៖ កម្មន្តសាលវាយនភ័ណ្ឌ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
១៣១			**ការរវៃ ការត្បាញ និងការធ្វើឲ្យសម្រេច នូវផលិតផលវាយនភ័ណ្ឌ**
	១៣១១		ការរៀបចំ និងការរវៃសរសៃអំបោះ
		១៣១១១	ការរវៃវាយនភ័ណ្ឌកប្បាស
		១៣១១២	ការរវៃវាយនភ័ណ្ឌសូត្រ
		១៣១១៩	ការរៀបចំ និងការរវៃសរសៃអំបោះ ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- ការរៀបចំដំណើរការសរសៃអំបោះ៖
  - ខា និងសម្អាតសរសៃសូត្រ
  - សម្អាតខ្លាញ់ និងដាក់ជាតិកាបូនរោមសត្វ និងការជ្រលក់ពណ៌រោមសត្វដែលកោររួច (រោមចៀម)
  - ការពន្លា និងការសិតសរសៃពីរោមសត្វគ្រប់ប្រភេទ និងសរសៃរុក្ខជាតិ និងសរសៃសំយោគ
- ការរវៃ និងកម្មន្តសាលអំបោះ ឬចេសសម្រាប់ការត្បាញ និងដេរ សម្រាប់ធ្វើពាណិជ្ជកម្ម និងការកែច្នៃបន្ថែមទៀត
  - វាយនភ័ណ្ឌកម្មត្រកួញ វេញ ចងជាបាច់ ជ្រលក់សរសៃអំបោះសំយោគ ឬសិប្បនិម្មិត

ថ្នាក់នេះក៏បញ្ចូលផងដែរ៖

- កម្មន្តសាលអំបោះពីក្រដាស

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ការរៀបចំដំណើរការបញ្ចូលគ្នាជាមួយកសិកម្ម ឬការដាំដុះ (មើលផ្នែក ០១)
- ការត្រាំទឹក ដើម្បីបកសម្បករុក្ខជាតិសរសៃ (ដើមក្រចៅ ដើមធ្មៃ ស្រកីដូង ។ល។) (មើល ០១១៦)
- ការប្រឡេះគ្រាប់កប្បាស (មើល ០១៦៣)
- កម្មន្តសាលសរសៃសំយោគ ឬសិប្បនិម្មិត និងខ្សែពួរ (សម្រាប់អួស ទាញ) កម្មន្តសាលសរសៃអំបោះទោល (រួមទាំង សរសៃអំបោះដែលស្វិតខ្លាំង និងសរសៃអំបោះសម្រាប់ធ្វើកម្រាលព្រំ) ពីសរសៃសំយោគ ឬសិប្បនិម្មិត (មើល ២០៣០)
- កម្មន្តសាលសរសៃសំឡីកែវ (មើល ២៣១០)

	១៣១២		តម្បាញក្រណាត់
		១៣១២១	តម្បាញក្រណាត់កប្បាស

១៣១២២ តម្បាញក្រណាត់សូត្រ

១៣១២៩ តម្បាញក្រណាត់ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលតម្បាញប្រភេទក្រណាត់ពីកប្បាសទូទៅ ប្រភេទក្រណាត់ខ្សៀន ក្រណាត់ប្រភេទសរសៃគ្រើម ឬពីសូត្រ រួមទាំងសរសៃចម្រុះ ឬពីសរសៃសំយោគ ឬសរសៃសិប្បនិម្មិត
- កម្មន្តសាលក្រណាត់កប្បាសទូទៅផ្សេងទៀត ដោយប្រើផ្ទៃ វ៉ាមី ហែម ក្រចៅ សរសៃរឹងដោយលាយបញ្ចូលគ្នានឹងសរសៃពិសេស

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរនូវ៖

- កម្មន្តសាលតម្បាញក្រណាត់រោមទន់ ឬកាំម្វី ក្រណាត់កន្សែងពោះគោ ស្បៃ ។ល។
- កម្មន្តសាលក្រណាត់ត្បាញធ្វើពីសរសៃកែវ
- កម្មន្តសាលក្រណាត់ត្បាញធ្វើពីសរសៃអំបោះកាបូន និងចេស
- អាវ៉ាមីត
- កម្មន្តសាលរោមសត្វក្លែងក្លាយ ធ្វើដោយត្បាញ

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលក្រណាត់ចាក់ ដោយម្ជុលមួយ ឬច្រើន (មើល ១៣៩១)
- កម្មន្តសាលក្រណាត់កម្រាល (មើល១៣៩៣)
- កម្មន្តសាលក្រណាត់មិនធ្វើដោយត្បាញ និងសង្កត់ភ្ជាប់គ្នា (មើល ១៣៩៩)
- កម្មន្តសាលក្រណាត់មានធ្មេញឈើតូចៗ (មើល ១៣៩៩)។

១៣១៣ ១៣១៣០ ការធ្វើសម្រេចវាយនភ័ណ្ឌ

ថ្នាក់នេះរាប់បញ្ចូល៖

- ការធ្វើឲ្យមានពណ៌ស និងការជ្រលក់ពណ៌លើសរសៃវាយនភ័ណ្ឌ សរសៃអំបោះ ផ្ទាំងក្រណាត់ ឬរបស់ធ្វើពីក្រណាត់រួមទាំង សម្លៀកបំពាក់
- ការតុបតែង ការសម្ងួត ការបាញ់ចំហាយទឹក ការធ្វើឲ្យជ្រួញ ការប៉ះ ការទាញបន្តឹង ការកិនបង្ហាប់ឲ្យរលើបក្រណាត់ និងរបស់ធ្វើពីក្រណាត់ រួមទាំង សម្លៀកបំពាក់។

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរនូវ៖

- ការធ្វើខោខូវប៊ិយឲ្យស
- ជីបផ្នត់ និងការងារស្រដៀងៗគ្នា លើក្រណាត់
- ការធ្វើពុំឲ្យជ្រាបទឹក ការពាសស្រទាប់ ការភ្ជួរកៅស៊ូ ឬការភ្ជោកសម្លៀកបំពាក់
- ការបោះពុម្ពដោយពុម្ពស្បៃ លើក្រណាត់ និងសម្លៀកបំពាក់

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលផ្ទាំងក្រណាត់ ដែលភ្ជោក ពាស ស្រោបពីលើ ឬអ៊ុតជាមួយកៅស៊ូ ដែលកៅស៊ូ

ជាជាតុផ្សំសំខាន់ (មើល ២២១៩)។

១៣៩ **កម្មន្តសាលវាយនភ័ណ្ឌដទៃទៀត**

១៣៩១ កម្មន្តសាលផ្ទាំងក្រណាត់ចាក់ដោយម្ជុលច្រើន ឬមួយ

១៣៩១១ កម្មន្តសាលក្រណាត់ចាក់ ប៉ាក់ និងព្រំ

១៣៩១៩ កម្មន្តសាលផ្ទាំងកំណាត់ចាក់ដោយម្ជុលច្រើនឬមួយ ដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល និងដំណើរការចាក់ក្រណាត់ដោយម្ជុលច្រើន ឬមួយ៖
    - ផ្ទាំងក្រណាត់រោមកាំម្ពី និងក្រណាត់សម្រាប់ធ្វើកន្សែងពោះគោ
    - ស្បៃ និងក្រណាត់តុបតែងបង្អួចពីប្រភេទក្រណាត់ចាក់ ដែលផលិតដោយម៉ាស៊ីនចាក់ជរ ឬម៉ាស៊ីនស្រដៀងគ្នា
    - ក្រណាត់ចាក់ ដទៃទៀត

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរ៖

- កម្មន្តសាលរោមសត្វក្លែងក្លាយដែលបានពីការចាក់

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលស្បៃ និងក្រណាត់តុបតែងបង្អួច ពីប្រភេទក្រណាត់ ដែលផលិតពីម៉ាស៊ីនចាក់ជរ មានក្បាច់ប្រហោងឬម៉ាស៊ីនស្រដៀងគ្នា (មើល១៣៩៩)
- កម្មន្តសាលសម្លៀកបំពាក់ចាក់ (មើល ១៤៣០)។

១៣៩២ ១៣៩២០ កម្មន្តសាលរបស់តុបតែងពីវាយនភ័ណ្ឌលើកលែងសម្លៀកបំពាក់

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលនៃរបស់តុបតែងធ្វើពីវត្ថុធាតុវាយនភ័ណ្ឌ រួមទាំងផ្ទាំងក្រណាត់ចាក់៖
    - ភួយ រាប់បញ្ចូលទាំង ព្រំសម្រាប់ធ្វើដំណើរ
    - កម្រាលគ្រែ តុ បន្ទប់ទឹក ឬផ្ទះបាយ
    - កម្រាលដេកមានច្រើនស្រទាប់ ខ្នើយផ្អែក ពូកសម្រាប់អង្គុយ ខ្នើយ កាបូបសម្រាប់ដេក ។ល។
- កម្មន្តសាលរបស់តុបតែងសម្រាប់បំពាក់គ្រឿងសង្ហារិម៖
    - វាំងនន វាំងននចាប់ក្បាច់ វាំងននក្រាស់ កម្រាលពូក គម្រងគ្រឿង សង្ហារិម និង ម៉ាស៊ីន ។ល។
    - សំពត់លាបជ័រមិនជ្រាបទឹក ក្រណាត់តង់ សម្ភារៈបោះជំរុំ ក្រណាត់ក្តោងទូក ក្រណាត់បាំងពន្លឺ ក្រណាត់គ្របឡាន ម៉ាស៊ីន ឬគ្រឿងសង្ហារិមដទៃទៀត ។ល។
    - ទង់ជាតិ បដា ទង់ផ្កាលា ។ល។
    - ក្រណាត់ជូតធូលី ក្រណាត់ជូតចាន និងរបស់របរស្រដៀងគ្នា អាវសុវត្ថិភាព ឆ័ត្រយោង ។ល។

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរ៖

- កម្មន្តសាលគ្រឿងបំណែកវាយនភ័ណ្ឌរបស់ក្មួយអគ្គិសនី
- កម្មន្តសាលព្រំមានរូបភាពដាក់តាំងព្យួរត្បាញដោយដៃ
- កម្មន្តសាលគម្របកៅស៊ូកង់រថយន្ត

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលរបស់វាយនភ័ណ្ឌសម្រាប់ប្រើប្រាស់ផ្នែកបច្ចេកទេស (មើល ១៣៩៩)។

១៣៩៣ កម្មន្តសាលកម្រាលព្រំនិងព្រំតូចៗ

១៣៩៣១ កម្មន្តសាលកម្រាលព្រំ និងកន្ទេល

១៣៩៣៩ កម្មន្តសាលកម្រាលព្រំនិងព្រំតូចៗដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលកម្រាលពីវាយនភ័ណ្ឌ ដូចជា៖ ព្រំ ព្រំតូច និងកន្ទេល កម្រាលឥដ្ឋ
- កម្មន្តសាលកម្រាលឥដ្ឋចាក់ដោយកី

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលកន្ទេល និងការចាក់កន្ទេលពីវត្ថុធាតុសម្រាប់ក្រង/ត្បាញ (មើល ១៦២៩)
- កម្មន្តសាលកម្រាលឥដ្ឋធ្វើពីឈើស្នោ (មើល ១៦២៩)
- កម្មន្តសាលកម្រាលឥដ្ឋមិនទ្រុឌ (ជាក់ថយ) ដូចជា វីនីល លីណូលៀម (មើល ២២២៩)។

១៣៩៤ កម្មន្តសាលខ្សែពួរធំ (សម្រាប់នាវា) ខ្សែពួរខ្សែរវេញ និងការចាក់សំណាញ់

១៣៩៤១ កម្មន្តសាលសំណាញ់ មង អួន អន្ទង់ ថ្នង

១៣៩៤៩ កម្មន្តសាលខ្សែពួរធំ(សម្រាប់នាវា) ខ្សែពួរខ្សែរវេញ និងការចាក់សំណាញ់ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលខ្សែរវេញ ខ្សែពួរធំ (សម្រាប់នាវា) និង ខ្សែកាបពីសរសៃវាយនភ័ណ្ឌ ឬស្រដៀងគ្នាដែលភ្ជោក ឬមិនភ្ជោកពាសស្រទាប់ គ្រប ស្រោបពីបន្ទះកៅស៊ូ ឬប្លាស្ទិក
- កម្មន្តសាលខ្សែរវេញ ខ្សែពួរនាវា ឬខ្សែពួរដោយចងទាក់
- កម្មន្តសាលផលិតផលនៃខ្សែពួរ ឬសំណាញ់៖ សំណាញ់នេសាទខែលកប៉ាល់ការពារការទង្គិចជាមួយផែ កន្ត្រកសំណាញ់លើកផ្ទេរទំនិញ ខ្សែពួរលើកដាក់ឥវ៉ាន់ ខ្សែពួរ ឬខ្សែកាបដែលប្រើជាមួយកងលោហធាតុ ។ល។

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលសំណាញ់គ្របសក់ (មើល ១៤១៣)
- កម្មន្តសាលខ្សែភ្លើង (មើល ២៥៩៥)។

១៣៩៩ ១៣៩៩០ កម្មន្តសាលវាយនភ័ណ្ឌ ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូលសកម្មភាពទាំងអស់ដែលពាក់ព័ន្ធនឹង កម្មន្តសាលវាយនភ័ណ្ឌ ឬផលិតផលវាយនភ័ណ្ឌ ដែលមិនបានបញ្ជាក់ក្នុងកន្លែងណាមួយនៃផ្នែក ១៣ ឬ ១៤ ទាក់ទងទៅនឹងការកែច្នៃបរិមាណច្រើនផង និងភាពប្លែកគ្នាច្រើនយ៉ាងនៃមុខទំនិញដែលបានផលិត។

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ក្រណាត់ត្បាញធ្មេញឈើតូច រួមទាំងផ្ទាំងក្រណាត់ដែលគេធ្វើឲ្យជ្រួញ ប៉ុន្តែពុំមានរសាត់
- កម្មន្តសាល ស្លាកពាណិជ្ជសញ្ញា ឬស្លាកសញ្ញាសម្គាល់លើសម្លៀកបំពាក់។ល។
- កម្មន្តសាល ជរសម្រាប់តុបតែងលម្អ ៖ ជរសម្រាប់ចងសក់ រំយោល បន្ទោងលម្អ ។ល។
- កម្មន្តសាលផ្ទាំងក្រណាត់ពីសរសៃសង្កត់ភ្ជាប់គ្នា
- កម្មន្តសាលស្បៃ និងផ្ទាំងស្បៃដទៃទៀតពីជរ ពីក្រណាត់ប៉ាក់ ជាផ្ទាំង ជាបន្ទះវែង ឬជារូបរាងផ្សេងៗ
- កម្មន្តសាលសរសៃអំបោះលាយជាមួយលោហធាតុ ចេសកៅស៊ូ និងខ្សែពួរស្រោបដោយវត្ថុធាតុវាយនភ័ណ្ឌ អំបោះវាយនភ័ណ្ឌ ឬបន្ទះស្រោប ភ្លោក ពាស ឬស្រោបរឹតដោយកៅស៊ូ ឬប្លាស្ទិក
- កម្មន្តសាលអំបោះកង់ឡាន ឬធ្វើពីអំបោះសំយោគ ដែលស្វិតខ្លាំង
- កម្មន្តសាលក្រណាត់ដែលធ្វើប្រព្រឹត្តកម្មរួច ឬពាសដទៃទៀត ដូចជា ក្រណាត់មានស្នាម ក្រណាត់ទ្រនាប់សម្រាប់ជាងគំនូរ ក្រណាត់ទ្រនាប់គ្របសៀវភៅ ក្រណាត់រឹងឯទៀតដែលស្រដៀងគ្នា ក្រណាត់ពាសជាមួយកាវ ឬជាមួយសារធាតុអាមីឡាសើស
- កម្មន្តសាលគ្រឿងវាយនភ័ណ្ឌដទៃទៀត ៖ ប្រឆេះចង្កៀង ប្រឆេះចង្កៀងម៉ាំងសុង ទុយោទឹកពីក្រណាត់ ខ្សែពានអូស ឬខ្សែពាននាំ ខ្សែក្រវាត់ (ទោះជាមាន ឬគ្មានការធ្វើឲ្យមាំដោយបន្ថែមលោហធាតុ ឬវត្ថុធាតុផ្សេងទៀត ក្រណាត់ច្រោះ ក្រណាត់តម្រង ។ល។)

- កម្មន្តសាលក្រណាត់តុបតែងគ្រឿងយន្ត
- កម្មន្តសាលបន្ទះក្រណាត់ភ្ជាប់ទៅនឹងសម្ពាធ
- កម្មន្តសាលក្រណាត់ផ្ទាំងសម្រាប់វិចិត្រករ និងក្រណាត់មានស្នាមគំនូស
- កម្មន្តសាលខ្សែចងស្បែកជើង
- កម្មន្តសាលក្រណាត់ផាត់ម្សៅ និងស្រោមដៃអត់ម្រាម

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលកម្រាលដែលផលិតដោយកីចាក់(មើល ១៣៩៣)
- កម្មន្តសាលក្រណាត់ជាសាច់សំឡី និងរបស់របរពីសាច់សំឡី៖ កន្សែងអនាម័យ សំឡីអនាម័យ ។ល។ (មើល ១៧០៩)
- កម្មន្តសាលខ្សែពានអូស ឬខ្សែពាននាំធ្វើពីក្រណាត់ ឬពីអំបោះ ឬខ្សែពួរ ភ្ជោក ពាស ស្រទាប់ ឬអ៊ុតកៅស៊ូ ដែលកៅស៊ូជាធាតុផ្សំសំខាន់ (មើល ២២១៩)
- កម្មន្តសាលបន្ទះ ឬសន្លឹកកៅស៊ូសែលុយឡា ឬប្លាស្ទិកផ្សំជាមួយក្រណាត់ដើម្បីធ្វើឲ្យកាន់តែមាំ (មើល ២២១៩ ២២២៩)
- កម្មន្តសាលក្រណាត់ពីលោហធាតុត្បាញ (មើល ២៥៩៩)។

ជំពូក គ ៖ កម្មន្តសាល
ផ្នែក ១៤ ៖ កម្មន្តសាលសម្លៀកបំពាក់

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
១៤១			**កម្មន្តសាលសម្លៀកបំពាក់ លើកលែងសម្លៀកបំពាក់ធ្វើពីរោមសត្វ**
	១៤១០	១៤១០១	កម្មន្តសាលសម្លៀកបំពាក់ (លើកលែងជាសម្លៀកបំពាក់ស្រាប់ឬកាត់)

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលសម្លៀកបំពាក់ធ្វើពីស្បែក ឬសមាសធាតុស្បែក រួមទាំង គ្រឿងបន្សំពីស្បែក សម្រាប់ការងារឧស្សាហកម្ម ដូចជា អៀមស្បែកសម្រាប់ជាងផ្សារ
- កម្មន្តសាលសម្លៀកបំពាក់ការដ្ឋាន
- កម្មន្តសាលសម្លៀកបំពាក់ខាងក្រៅផ្សេងទៀត ពីក្រណាត់ត្បាញ ក្រណាត់ចាក់ដោយម្ជុលច្រើន ឬមួយមិនមែនត្បាញ ។ល។ សម្រាប់ បុរស ស្ត្រី និងកូនក្មេង ៖
  - o អាវម៉ង់តូ សម្លៀកបំពាក់ឈុត (អាវធំ) សម្លៀកបំពាក់មួយឈុត អាវងារពាក់ពីខាងក្រៅ ខោ សំពត់ ។ល។
- កម្មន្តសាលសម្លៀកបំពាក់ខាងក្នុង និងសម្លៀកបំពាក់រាត្រីធ្វើពីក្រណាត់ត្បាញ ឬចាក់ ក្រណាត់ជរ ។ល។ សម្រាប់បុរស ស្ត្រី និងកូនក្មេង ៖
  - o អាវសឺមី អាវយឺតខ្លី ខោក្នុង (បុរស) ខោខ្លី ភីហ្សាម៉ា រ៉ូបគេងយប់ រ៉ូបជប់លៀង អាវស្រី អាវស្តើងក្នុង អាវទ្រនាប់ស្រីៗ អាវរឹបរាង ។ល។
- កម្មន្តសាលសម្លៀកបំពាក់សម្រាប់ទារក សម្លៀកបំពាក់កីឡា ឈុតខោអាវសម្រាប់ជិះស្គី សម្លៀកបំពាក់ហែលទឹក ។ល។

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	១៤១១		ការកាត់ដេរសម្លៀកបំពាក់បុរស និងរ៉ូបស្ត្រី
		១៤១១១	ការកាត់ដេរសម្លៀកបំពាក់បុរស និងរ៉ូបស្ត្រីបែបប្រពៃណី
		១៤១១៩	ការកាត់ដេរសម្លៀកបំពាក់បុរស និងរ៉ូបស្ត្រី ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- ការកាត់ដេរសម្លៀកបំពាក់បុរស និងរ៉ូបស្ត្រីតាមការចង់បានរបស់អតិថិជន។

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	១៤១២	១៤១២០	កម្មន្តសាលសម្ភារៈបន្ទាប់បន្សំដែលមានជាតុផ្សំចម្បងធ្វើពីវាយនភ័ណ្ឌ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលមួក និងមួកកន្តឹប
- កម្មន្តសាលសម្ភារៈបន្ទាប់បន្សំដទៃទៀត ៖ ស្រោមដៃ ខ្សែក្រវាត់ កន្សែងបង់ក ក្រវ៉ាត់ក ឬ ខ្សែចងសក់ ។ល។

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរ៖

- កម្មន្តសាលមួកធ្វើពីរោមសត្វ
- កម្មន្តសាលស្បែកជើងធ្វើពីវាយនភ័ណ្ឌ ដោយពុំមានទ្រនាប់បាត

- កម្មន្តសាលគ្រឿងបំណែកសម្រាប់ផលិតផលដែលបានរៀបរាប់ខាងលើ។

១៤២ កម្មន្តសាលរបស់របរធ្វើពីរោមសត្វ

១៤២០ ១៤២០០ កម្មន្តសាលទំនិញ វត្ថុធ្វើអំពីរោមសត្វ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលរបស់របរធ្វើពីស្បែករោមសត្វ៖
  - សម្លៀកបំពាក់ធ្វើពីរោមសត្វ និងគ្រឿងបន្សំសម្លៀកបំពាក់
  - គ្រឿងផ្គុំពីស្បែករោមសត្វ ដូចជា ៖ ស្បែករោមសត្វតូចៗសម្រាប់លម្អ បន្ទះកម្រាល បន្ទះវែង ។ល។
  - របស់របរធ្វើពីស្បែករោមសត្វ ដូចជា ៖ ព្រំតូចៗពួកអង្គុយតូចៗអត់មានញាត់អ្វីខាងក្នុង ក្រណាត់ខាត់រំលីង ប្រើក្នុងឧស្សាហកម្ម

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ផលិតកម្មស្បែករោមសត្វឆៅ (មើលក្រុម ០១៤ និង ០១៧)
- ផលិតកម្មស្បែករោមសត្វធំៗឆៅ និងស្បែកសត្វឆៅ (មើល ១០១៣)
- កម្មន្តសាលរោមសត្វក្លែងក្លាយ (ក្រណាត់ដែលមានរោមវែងៗបានពីការត្បាញ ឬចាក់) (មើល ១៣១២, ១៣៩១)
- កម្មន្តសាលមួករោមសត្វ (មើល ១៤១៣)
- កម្មន្តសាលសម្លៀកបំពាក់តុបតែងជាមួយរោមសត្វ (មើល ១៤១១)
- ការតុបតែង និងការជ្រលក់ពណ៌រោមសត្វ (មើល ១៥១១)
- កម្មន្តសាលស្បែកជើងកវែង ឬស្បែកជើងដែលមានលាយរោមសត្វដោយឡែក (មើល ១៥២០)។

១៤៣ កម្មន្តសាលសម្លៀកបំពាក់ចាក់ (ដោយម្ជុលច្រើន ឬមួយ)

១៤៣០ ១៤៣០០ កម្មន្តសាលសម្លៀកបំពាក់ចាក់ ប៉ាក់ និងតម្បាញ (ដោយម្ជុលច្រើន ឬមួយ)

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលសម្លៀកបំពាក់ចាក់ ដោយម្ជុលច្រើន ឬម្ជុលមួយ និងរបស់តុបតែងដោយផ្ទាល់ ដូចជា៖ អាវយឺតពាក់ស៊ក អាវយឺតដៃវែងកវាលមានឡេវ អាវយឺតដៃវែងកវាលគ្មានឡេវ អាវកាក់ និងអាវស្រជៀងគ្នា
- កម្មន្តសាលស្រោមជើង រួមមាន ស្រោមជើងធម្មតា បា និងខោជាប់អាវរឹតរាង

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ការផលិតផ្ទាំងក្រណាត់ចាក់ (មើល ១៣៩១)។

ជំពូក គ ៖ កម្មន្តសាល

ផ្នែក ១៥ ៖ កម្មន្តសាលស្បែកនិងផលិតផលស្បែកដទៃទៀត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
១៥១			**ការសម្លាប់ស្បែក ការតុបតែងស្បែក កម្មន្តសាលវ៉ាលីស កាបូបយួរដៃ កែបសេះ និងបង្ហៀរសេះ ការតុបតែងនឹងជ្រលក់ពណ៌រោមសត្វ**
	១៥១១	១៥១១០	ការសម្លាប់ស្បែក និងការតុបតែងស្បែក ការតុបតែង និងជ្រលក់ពណ៌រោមសត្វ

ថ្នាក់នេះរាប់បញ្ចូល៖

- ការសម្លាប់ ការជ្រលក់ពណ៌ និងការតុបតែង ស្បែកសត្វធំៗ និងស្បែកសត្វ
- កម្មន្តសាលស្បែកទន់ ស្បែកជ្រលក់ពណ៌រួច ស្បែកមិនទាន់សម្លាប់ តែបានជ្រលក់ពណ៌រួច ស្បែករីងក្លីរលោង ឬស្បែកមានបញ្ចុះលោហធាតុ
- កម្មន្តសាលស្បែកសមាស
- ការធ្វើឲ្យទៅជាកម្ទេច ការកាត់រោមសត្វ ការបោចរោមសត្វ ការដុសលាង ការសម្លាប់ ការធ្វើឲ្យមានពណ៌ស និងការជ្រលក់ពណ៌ស្បែករោមសត្វ និងស្បែកធំៗដែលមានរោមសត្វ

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ផលិតកម្មស្បែកសត្វធំៗ និងស្បែកសត្វ ដែលជាផ្នែកនៃការចិញ្ចឹម (មើលក្រុម ០១៤)
- ផលិតកម្មស្បែកសត្វធំៗ និងស្បែកសត្វ ដែលជាផ្នែកមួយនៃការធ្វើសត្តឃាត(មើល ១០១៣)
- កម្មន្តសាលសម្លៀកបំពាក់ធ្វើពីស្បែក (មើល ១៤១១)
- កម្មន្តសាលស្បែកក្លែងក្លាយ (សិប្បនិម្មិត) ដែលមិនមានមូលដ្ឋានពីស្បែកធម្មជាតិ (មើល ២២១៩ ២២២៩)។

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	១៥១២		កម្មន្តសាលវ៉ាលី កាបូបយួរដៃនិងផលិតផលស្រដៀង កែបសេះ និងបង្ហៀរសេះ
		១៥១២១	កម្មន្តសាលវ៉ាលី កាបូបយួរដៃ និងកាបូបស្ពាយក្រោយ
		១៥១២៩	កម្មន្តសាលវ៉ាលី កាបូបយួរដៃនិងផលិតផលស្រដៀង កែបសេះ និងបង្ហៀរសេះ ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលវ៉ាលី កាបូបយួរដៃ និងផលិតផលដូចគ្នាធ្វើពីស្បែក ស្បែកសមាស ឬផ្សំពីវត្ថុធាតុដទៃទៀត ដូចជា សន្លឹកប្លាស្ទិក ឬវត្ថុវាយនភ័ណ្ឌ សរសៃចម្រិនរួច ឬក្រដាសកាតុងដែលប្រើប្រាស់បច្ចេកទេសដូចគ្នានឹងស្បែក
- កម្មន្តសាលកែបសេះ និងបង្ហៀរសេះ
- កម្មន្តសាលខ្សែនាឡិកាដៃដែលពុំមែនធ្វើពីលោហៈ (ក្រណាត់ ស្បែក ប្លាស្ទិក)

- កម្មន្តសាលរបស់របរផ្សេងៗទៀតនៃស្បែក ឬស្បែកសមាសៈ ខ្សែក្រវាត់សុវត្ថិភាពពេលបើកបរ ខ្សែចងឥវ៉ាន់ ។ល។
- កម្មន្តសាលខ្សែចងស្បែកជើងធ្វើពីស្បែក
- កម្មន្តសាលខ្សែតី និងរំពាត់វាយសេះ

ថ្នាក់នេះមិនរាប់បញ្ចូលៈ

- កម្មន្តសាលសម្លៀកបំពាក់ពីស្បែក (មើល ១៤១១)
- កម្មន្តសាលស្រោមដៃ និងមួកធ្វើពីស្បែក (មើល ១៤១៣)
- កម្មន្តសាលស្បែកជើង (មើល ១៥២០)
- កម្មន្តសាលកែបកង់ (មើល ៣០៩២)
- កម្មន្តសាលខ្សែនាឡិកាដៃធ្វើពីលោហធាតុមានតម្លៃ (មើល ៣២១១)
- កម្មន្តសាលខ្សែនាឡិកាដៃធ្វើពីលោហធាតុមិនមានតម្លៃ (មើល ៣២១២)
- កម្មន្តសាលខ្សែក្រវាត់សុវត្ថិភាពសម្រាប់អ្នកឡើងបង្គោលភ្លើង និងខ្សែក្រវាត់ដទៃទៀតសម្រាប់ការប្រើប្រាស់ក្នុងពេលបំពេញការងារ (មើល ៣២៩០)។

១៥២ កម្មន្តសាលស្បែកជើង

១៥២០ កម្មន្តសាលស្បែកជើង

១៥២០១ កម្មន្តសាលស្បែកជើងធ្វើពីស្បែក

១៥២០៩ កម្មន្តសាលស្បែកជើងដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូលៈ

- កម្មន្តសាលស្បែកជើងសម្រាប់ប្រើប្រាស់ទូទៅពីគ្រប់វត្ថុធាតុដោយការកែច្នៃរបៀបណាក៏ដោយ រួមទាំងការបោះពុម្ព (មើលករណីលើកលែងខាងក្រោម)
- កម្មន្តសាលផ្នែកស្បែកនៃស្បែកជើង ៖ កម្មន្តសាលផ្នែកខាងលើ និងមួយផ្នែកនៃផ្នែកខាងលើរបស់ស្បែកជើង និងគ្រឿងបំណែកនៃផ្នែក ខាងលើនេះ ទ្រនាប់ខាងក្រៅ និងទ្រនាប់ខាងក្នុងនៃបាតស្បែកជើង កែងស្បែកជើង ។ល។
- កម្មន្តសាលស្រោមខ្នងជើង ស្រោមក្បាលជង្គង់ និងស្រដៀងគ្នា

ថ្នាក់នេះមិនរាប់បញ្ចូលៈ

- កម្មន្តសាលស្បែកជើងធ្វើពីវាយនភ័ណ្ឌ ដោយគ្មានប្រើបាត (មើល ១៤១៣)
- កម្មន្តសាលផ្នែកឈើនៃស្បែកជើង (កែងស្បែកជើង និងចុងស្បែកជើង) (មើល ១៦២៩)
- កម្មន្តសាលស្បែកជើងកៅស៊ូកវែង និងកែងស្បែកជើង និងបាតស្បែកជើង និងផ្នែកកៅស៊ូនៃស្បែកជើង (មើល ២២១៩)
- កម្មន្តសាលស្បែកជើងស្គី (មើល ៣២៣០)
- កម្មន្តសាលស្បែកជើងពេទ្យសម្រាប់សម្រួលប្រព័ន្ធឆ្អឹងខ្នង (មើល ៣២៥០)។

ជំពូក គ ៖ កម្មន្តសាល

ផ្នែក ១៦ ៖ កម្មន្តសាលនៃឈើ និងផលិតផលពីឈើនិងឈើស្មោលើក លែងតែគ្រឿងសង្ហារិម, កម្មន្តសាលរបស់របរពីចំបើង និងវត្ថុជាតុក្រង

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
១៦១			**ការអារឈើនិងការឈូសឈើ**
	១៦១០	១៦១០០	ការអារឈើនិងការឈូសឈើ

ថ្នាក់នេះរាប់បញ្ចូល៖

- ការអារឈើ ការឈូស និងកែច្នៃពីឈើហ៊ុបទៅជាឈើអារ និងមានរូបរាង
- ការច្រៀក ការបកសម្បក ឬចិញ្ច្រាំឈើហ៊ុប
- កម្មន្តសាលឈើកំណល់ផ្លូវរថភ្លើង
- កម្មន្តសាល ឈើកម្រាលដែលមិនទាន់ដំឡើង
- កម្មន្តសាលសរសៃឈើ ម្សៅឈើ ដុំចម្រៀកឈើ និងកម្ទេច
- ឈើល្អិតៗ

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរនូវ៖

- ការសម្ងួតឈើ
- ការត្រាំ ឬប្រព្រឹត្តិកម្មឈើជាមួយគីមីសម្រាប់ថែរក្សា ឬជាមួយវត្ថុធាតុដទៃទៀត

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ការកាប់ឈើហ៊ុប និងផលិតកម្មឈើដុលមិនទាន់កែច្នៃ (មើល ០២២០)
- កម្មន្តសាល បន្ទះឈើស្តើងសម្រាប់ធ្វើជាក្តារបន្ទះ ក្តារ និងក្តារសម្រាប់បិត (មើល ១៦២១)
- កម្មន្តសាល ក្បឿងឈើ ក្តារឈើប្រក ឈើស៊ុម ឈើមានក្បាច់លម្អ (មើល ១៦២២)។

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
១៦២			**កម្មន្តសាលផលិតផលឈើ ឈើស្មោ ចំបើង និងវត្ថុធាតុក្រង**
	១៦២១	១៦២១០	កម្មន្តសាលចំនៀរឈើ និងក្តារបន្ទះឈើស្តើង

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលបន្ទះចំនៀរឈើស្តើងសម្រាប់ធ្វើជាក្តារបន្ទះ ឬក្នុងគោលបំណងឯទៀត៖ ធ្វើឲ្យរលោង ដាក់ពណ៌ ពាសត្រាំ ធ្វើឲ្យរឹង (ដោយមានក្រដាស ឬក្រណាត់ពីក្រោយ) ធ្វើជាទម្រង់ក្បាច់
- កម្មន្តសាលក្តារបន្ទះ៖ បន្ទះចំនៀរឈើស្តើងសម្រាប់បិត និងក្តារឬផ្ទាំងឈើបិតជាស្រទាប់ ស្រដៀងគ្នា
- កម្មន្តសាលក្តារពីកម្ទេចឈើល្អិត និងក្តារពីសរសៃឈើ
- កម្មន្តសាលឈើរឹងបានពីការសង្កត់កម្ទេចឈើ
- កម្មន្តសាលឈើស្រទាប់បិតការឈើពីស្រទាប់ចំនៀរឈើស្តើង។

១៦២២ កម្មន្តសាលឈើសម្រាប់សាងសង់ និងឈើដំណាប់ភ្ជាប់

១៦២២១ កម្មន្តសាល ទ្វារបង្អួច គម្របនិងគ្រោងទ្វារបង្អួច

១៦២២២ កម្មន្តសាលការ៉ូឈើសម្រាប់ធ្វើផ្ទៃក្រាល

១៦២២៩ កម្មន្តសាលឈើសំណង់ និងឈើដំណ ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលទំនិញពីឈើទុកប្រើប្រាស់ជាមូលដ្ឋាននៅក្នុងឧស្សាហកម្ម ៖
  - ធ្នឹម ផ្ទោង គ្រឿងដំបូល
  - គ្រឿងឈើដំបូលផ្គុំដំឡើងរួច ដែលភ្ជាប់តាមរបៀបបិទការ ឬភ្ជាប់ដោយលោហធាតុ
  - ទ្វារ បង្អួច ស្លាបព្រិល និងស៊ុមដែលមាន ឬគ្មានគ្រឿងដែកភ្ជាប់ ដូចជា ត្រចៀកទ្វារ សោទ្វារ ។ល។
  - ជណ្តើរ បង្កាន់ដៃ
  - ឈើស៊ុម ឈើមានក្បាច់ ក្បឿងឈើ ក្តារឈើប្រក
  - ការ៉ូឈើក្រាល បន្ទះឈើក្រាល ។ល។ ដែលផ្គុំជាផ្ទាំង
- កម្មន្តសាល គ្រោងអាគារដែលរៀបចំទុកសាងសង់ ឬផ្នែករបស់វា ដែលធ្វើពីឈើភាគច្រើន
- កម្មន្តសាលផ្ទះចល័ត
- កម្មន្តសាលផ្ទាំងឈើសម្រាប់ខណ្ឌចែកបន្ទប់ (លើកលែងផ្ទាំងដែលអាចឈរដោយខ្លួនឯងបាន)

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលក្តារកម្រាលមិនទាន់ផ្គុំ (មើល ១៦១០)
- កម្មន្តសាលទូដាក់ឥវ៉ាន់ផ្ទះបាយ ទូសៀវភៅ ទូព្យួរខោអាវ ។ល។ (មើល ៣១០០)
- កម្មន្តសាលផ្ទាំងឈើខណ្ឌចែកបន្ទប់ ដាក់បញ្ឈរចោលខ្លួនឯងបាន (មើល ៣១០០)

១៦២៣ ១៦២៣០ កម្មន្តសាលធុងឈើ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលកេសដាក់ឥវ៉ាន់ ប្រអប់ ឡាំង ធុង និងប្រដាប់ដាក់ឥវ៉ាន់ធ្វើពីឈើដទៃទៀត
- កម្មន្តសាល ប៉ាឡែត ឡាំងមានជើងប៉ាឡែតស្រាប់ និងឡាំងផ្ទុកឥវ៉ាន់ដទៃទៀត
- កម្មន្តសាលធុងបារ៉ែល ធុងឈើធំៗ បំពង់វែង និងផលិតផលធុងឈើដទៃទៀត
- កម្មន្តសាល រ៉ូឡូឈើសម្រាប់មូរខ្សែកាប

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលវ៉ាលីស (មើល ១៥១២)
- កម្មន្តសាលកេសដែលធ្វើពីវត្ថុធាតុក្រង (មើល ១៦២៩)។

១៦២៩ ១៦២៩០ កម្មន្តសាលផលិតផលឈើផ្សេងទៀត កម្មន្តសាលរបស់របរធ្វើពីឈើស្នោ ចំបើងនិងវត្ថុធាតុក្រង

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលផលិតផលធ្វើពីឈើផ្សេងៗ៖
  - ឈើធ្វើដង និងតួសម្រាប់ឧបករណ៍ផ្សេងៗ អំបោស ជក់
  - ស្បែកជើងឈើកវែង ឬផ្នែកឈើនៃស្បែកជើង(កែងស្បែកជើង)
  - ទំពក់ព្យួរសម្លៀកបំពាក់ពីឈើ
  - ឈើស៊ុមកញ្ចក់ និងស៊ុមរូបភាព
  - ឈើស៊ុម សម្រាប់ផ្ទាំងគំនូររបស់ជាងគំនូរ
  - គ្រឿងប្រដាប់ប្រើក្នុងផ្ទះ និងផ្ទះបាយពីឈើ
  - រូបចម្លាក់ និងគ្រឿងតុបតែងពីឈើ ផ្ទាំងលម្អពីឈើ
  - ប្រអប់ឈើដាក់គ្រឿងអលង្ការ គ្រឿងកាំបិតឈើ និងប្រភេទស្រដៀងគ្នា
  - ត្រសាល់ ហុង ខ្នារអំបោះ ស្ពូលរុំចេស និងប្រភេទស្រដៀងគ្នា ដែលធ្វើពីឈើ
  - ដងឆត្រ ឈើច្រត់ និងប្រភេទស្រដៀងគ្នា
  - ដុំឈើសម្រាប់កម្មន្តសាលខ្សៀបារី
  - របស់ធ្វើពីឈើដទៃទៀត
- ការកែច្នៃឈើស្នោធម្មជាតិ កម្មន្តសាលពំនូតដុំឈើស្នោ
- កម្មន្តសាល របស់របរពីស្នោធម្មជាតិ ឬពំនូតស្នោ រួមមានកម្រាលស្នោ
- កម្មន្តសាលវត្ថុធាតុក្រង ឬចាក់៖ កន្ទេល កម្រាល កញ្ច្រែងវែង កេស ។ល។
- កម្មន្តសាល ធ្វើកន្ត្រក និងធ្វើកញ្ច្រែង
- កម្មន្តសាល ដុំឈើសម្រាប់ដុត ធ្វើពីពំនូតឈើ (អាចម៍រណារ) ឬពីវត្ថុធាតុជំនួស ដូចជា ដើមកាហ្វេ ឬសណ្តែក

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលកន្ទេល ឬកម្រាល ធ្វើពីវត្ថុធាតុវាយនភ័ណ្ឌ (មើល ១៣៩២)
- កម្មន្តសាលវ៉ាលីស (មើល ១៥១២)
- កម្មន្តសាលស្បែកជើងឈើ (មើល ១៥២០)
- កម្មន្តសាលឈើគូស (មើល ២០២៩)
- កម្មន្តសាលទូនាឡិកា (មើល ២៦៥២)
- កម្មន្តសាលត្រសាល់ ឬខ្នារុំអំបោះ ដែលជាផ្នែកមួយសម្រាប់ម៉ាស៊ីនតម្បាញ (មើល ២៨២៦)
- កម្មន្តសាលគ្រឿងសង្ហារិម (មើល ៣១០០)
- កម្មន្តសាលប្រដាប់ក្មេងលេងពីឈើ (មើល ៣២៤០)
- កម្មន្តសាលពោងការពារជីវិតពីឈើស្នោ (មើល ៣២៩០)
- កម្មន្តសាលជក់ និងអំបោស (មើល ៣២៩០)
- កម្មន្តសាលមឈូស (មើល ៣២៩០)។

ជំពូក គ ៖ កម្មន្តសាល

ផ្នែក ១៧ ៖ កម្មន្តសាលក្រដាសនិងផលិតផលក្រដាស

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
១៧០			**ការផលិតក្រដាសនិងផលិតផលពីក្រដាស**
	១៧០១		កម្មន្តសាលម្សៅក្រដាស ក្រដាសនិងក្រដាសកាតុង
		១៧០១១	កម្មន្តសាលកេសក្រដាស
		១៧០១២	កម្មន្តសាលក្រដាសសរសេរ
		១៧០១៩	កម្មន្តសាលក្រដាសនិងផលិតផលក្រដាសដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលម្សៅក្រដាស ប្រភេទដែលត្រូវបានលាយឲ្យស លាយឲ្យសពាក់កណ្តាល ឬមិនបានលាយឲ្យស ដោយប្រើវិធីលាយតាមបែបមេកានិក បែបគីមី (រលាយឬមិនរលាយក្នុងទឹក) ឬបែបពាក់កណ្តាលគីមី
- កម្មន្តសាលម្សៅក្រដាសពីកម្ទេចសំឡី
- ការយកជាតិពណ៌ចេញនៅក្នុងកម្មន្តសាលម្សៅក្រដាស ពីក្រដាសប្រើរួច
- កម្មន្តសាលក្រដាស និងក្រដាសកាតុង ដើម្បីប្រើប្រាស់ក្នុងដំណើរការឧស្សាហកម្មបន្តទៀត

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរ៖

- ការកែច្នៃបន្តក្រដាស និងក្រដាសកាតុង៖
  - ការពាស ការស្រោប និងការជ្រលក់ក្រដាស និងក្រដាសកាតុង
  - កម្មន្តសាលក្រដាសភ្លឺ និងក្រដាស់ទក់
  - កម្មន្តសាលក្រដាសច្រើនស្រទាប់ និងក្រដាសសម្រាប់ខ្ចប់ម្ហូបអាហារ ទោះជាក្រដាស ឬក្រដាសកាតុងក៏ដោយ
- កម្មន្តសាលក្រដាសធ្វើដោយដៃ
- កម្មន្តសាលក្រដាសកាសែត និងក្រដាសសម្រាប់បោះពុម្ព ឬក្រដាសសម្រាប់សរសេរដទៃទៀត
- កម្មន្តសាលក្រដាសសែលុយឡូ និងក្រដាសក្រឡាពីសរសៃក្រដាស
- កម្មន្តសាលក្រដាសផ្តាម ឬក្រដាសស្តង់ស៊ីលជារមូរ ឬផ្ទាំងធំ

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលក្រដាសទឹករលក និងក្រដាសកាតុង (មើល ១៧០២)
- កម្មន្តសាលរបស់ពីក្រដាស ក្រដាសកាតុង ឬម្សៅក្រដាស សម្រាប់កែច្នៃបន្តទៀត (មើល ១៧០៩)
- កម្មន្តសាលក្រដាសដែលពាស ឬជ្រលក់ ហើយការពាស ឬជ្រលក់នេះ គឺជាធាតុផ្សំដ៏សំខាន់ មើលថ្នាក់ដែលកម្មន្តសាលដែលមានការលាបពណ៌ ឬការជ្រលក់ត្រូវបានចាត់ថ្នាក់
- កម្មន្តសាលក្រដាសខាត់ (មើល ២៣៩៩)។

	១៧០២	១៧០២០	កម្មន្តសាលក្រដាសទឹករលក ក្រដាសកាតុង និងប្រអប់ធ្វើពីក្រដាស និងពីក្រដាសកាតុង

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលក្រដាសទឹករលក និង ក្រដាសកាតុង
- កម្មន្តសាលប្រអប់ពីពីក្រដាសកាតុងបត់
- កម្មន្តសាលប្រអប់ពីក្រដាសរឹង
- កម្មន្តសាលប្រអប់ផ្សេងទៀត ពីក្រដាស ឬពីក្រដាសកាតុង
- កម្មន្តសាលការ៉ុង និងស្បៀងឃ្នូរពីក្រដាស
- កម្មន្តសាលសឺមីឯកសារ និងរបស់របរស្រដៀងគ្នា

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលស្រោមសំបុត្រ (មើល ១៧០៩)
- កម្មន្តសាលរបស់របរដោយការចាក់ពុម្ព ឬសង្កត់ម្សៅក្រដាស (ដូចជា ប្រអប់ខ្ចប់ស៊ុត ចានធ្វើពីម្សៅក្រដាសចាក់ពុម្ព) (មើល ១៧០៩)។

១៧០៩ ១៧០៩០ កម្មន្តសាលរបស់របរផ្សេងទៀតធ្វើពីក្រដាស និងពីក្រដាសកាតុង

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលក្រដាសអនាម័យប្រើប្រាស់ក្នុងផ្ទះ និងប្រើប្រាស់ផ្ទាល់ខ្លួន និងផលិតផលធ្វើពីក្រដាសទន់ស្តើង៖
  - ក្រដាសជូតសម្អាត
  - ក្រដាសកន្សែងដៃក្រដាសកន្សែងធំ ក្រដាសកន្សែងទ្រាប់ការពារប្រឡាក់ពេលបរិភោគ
  - ក្រដាសអនាម័យក្នុងបន្ទប់ទឹក
  - ក្រដាសកន្សែងអនាម័យ និងក្រដាស់ជក់ទឹក ក្រដាស់កន្សែងទ្រនាប់ ក្រដាសកន្សែងក្រដាសសម្រាប់ទារក
  - ពែង ចាន និងថាស ពីក្រដាស
- កម្មន្តសាលផ្ទាំងក្រដាសពីសំឡីកប្បាស និងប្រភេទរបស់របរធ្វើពីសំឡីកប្បាស ដូចជា៖ សំឡីអនាម័យសម្រាប់នារី ក្រដាសសំឡីសម្រាប់បិទរបួស ។ល។
- កម្មន្តសាលក្រដាសសម្រាប់ប្រើក្នុងការបោះពុម្ព និងសរសេរ
- កម្មន្តសាលក្រដាសសម្រាប់បោះប្រើក្នុងការព្រីនដោយកុំព្យូទ័រ
- កម្មន្តសាលក្រដាសសម្រាប់ប្រើក្នុងការសរសេរ ហើយផ្តាមដោយខ្លួនឯង
- កម្មន្តសាលក្រដាស សម្រាប់ប្រើក្នុងស្តង់ស៊ីល និងផ្តាម
- កម្មន្តសាលក្រដាសដែលស្អិតស្រេច
- កម្មន្តសាលស្រោមសំបុត្រ និងក្រដាសសរសេរជាស្រោមសំបុត្រ

- កម្មន្តសាលសៀវភៅចុះឈ្មោះ សៀវភៅគណនេយ្យ ក្រូណូ សៀវភៅអាល់ប៊ុម និងស្រដៀងគ្នាសម្រាប់ប្រើក្នុងវិស័យអប់រំ និងជំនួញ
- កម្មន្តសាលប្រអប់ ថង់ កាបូបដៃ និងសៀវភៅដៃ ដែលមានផ្ទុកសម្ភារៈកត់ត្រា
- កម្មន្តសាលក្រដាសបិទជញ្ជាំង និងរបស់របរស្រដៀងគ្នា សម្រាប់បិទលើជញ្ជាំង រួមទាំងមានពាសប្លាស្ទិកពីលើ និងក្រដាសបិតជញ្ជាំងពីវាយនភ័ណ្ឌ
- កម្មន្តសាលស្លាកពាណិជ្ជសញ្ញា
- កម្មន្តសាលក្រដាស និងពីក្រដាសកាតុង
- កម្មន្តសាលត្រសាល់ រមូរ ហុង ។ល។ ធ្វើពីក្រដាស និងពីក្រដាសកាតុង
- កម្មន្តសាលថាសដាក់ស៊ុត និងសម្រាប់វេចខ្ចប់ដទៃទៀតពីការចាក់ពុម្ពម្សៅក្រដាស ។ល។
- កម្មន្តសាលក្រដាសរូបរាងប្លែកៗសម្រាប់លេង ឬតុបតែង

ថ្នាក់នេះមិនរាប់បញ្ចូលៈ

- កម្មន្តសាលក្រដាស ឬក្រដាសកាតុងទំហំធំ (មើល ១៧០១)
- ការបោះពុម្ពលើផលិតផលក្រដាស (មើល ១៨១១)
- កម្មន្តសាលសន្លឹកបៀរ (មើល ៣២៤០)
- កម្មន្តសាលប្រដាប់ក្មេងលេងនិងតុក្កតា ធ្វើពីក្រដាសឬពីក្រដាសកាតុង (មើល ៣២៤០)។

ជំពូក គ ៖ កម្មន្តសាល

ផ្នែក ១៨ ៖ ការបោះពុម្ពនិងការផលិតសារឡើងវិញ នូវឯកសារដែលបានថតចម្លងទុក

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
១៨១			**ការបោះពុម្ព និងសេវាកម្មទាក់ទងនឹងការបោះពុម្ព នូវឯកសារដែលបានថតចម្លងទុក**
	១៨១១	១៨១១០	ការបោះពុម្ព

ថ្នាក់នេះរាប់បញ្ចូល៖

- ការបោះពុម្ពលើកាសែត ទស្សនាវដ្តី និងព្រឹត្តិបត្រដទៃទៀត សៀវភៅ និង ខិត្តបណ្ណ ចម្រៀង និងអត្ថបទចម្រៀង ផែនទី សៀវភៅផែនទី បដា សៀវភៅកាតាឡុក ពាណិជ្ជកម្ម សៀវភៅណែនាំ និងការផ្សព្វផ្សាយដោយបោះពុម្ពដទៃទៀត តែមប្រៃសណីយ៍ តែមបង់ពន្ធ ឯកសារកម្មសិទ្ធ មូលប្បទានបត្រ និងក្រដាសប្រាក់ដទៃ សៀវភៅកំណត់ហេតុ ប្រក្រតិទិន ទម្រង់បែបបទអាជីវកម្ម និងសម្ភារៈបោះពុម្ពក្នុងគោលបំណងធ្វើពាណិជ្ជកម្ម សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន និងសម្ភារៈបោះពុម្ពដទៃ ដោយការបោះពុម្ពជាអក្សរដោយមានតុល្យភាព និងបោះពុម្ពជារូបភាពដែលអាចបត់បែនបាន និងការបោះពុម្ពដទៃទៀត ម៉ាស៊ីនថតចម្លង ម៉ាស៊ីនបោះពុម្ពរបស់កុំព្យូទ័រ បោះពុម្ពឲ្យចេញអក្សរគ្រើម ។ល។ រួមទាំង ការបោះពុម្ពបែបលឿនផងដែរ
- ការបោះពុម្ពដោយផ្ទាល់ទៅលើវាយនភ័ណ្ឌ ប្លាស្ទិក កែវ លោហៈ ឈើ និងសេរ៉ាមិក (លើកលែងតែការបោះពុម្ពស្បែលើវាយនភ័ណ្ឌ និងសម្លៀកបំពាក់)

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ការបោះពុម្ព នៅលើវាយនភ័ណ្ឌ និងសម្លៀកបំពាក់ (មើល ១៣១៣)
- កម្មន្តសាលវត្ថុធ្វើពីក្រដាស ដូចជា សំណុំសៀវភៅ (មើល ១៧០៩)
- ការបោះពុម្ពផ្សាយនូវសម្ភារៈដែលបានបោះពុម្ព (មើលក្រុម ៥៨១)
- ការថតចម្លងឯកសារ (មើល ៨២១៩)។

	១៨១២	១៨១២០	សេវាកម្មផ្សេងៗដែលទាក់ទងនឹងការបោះពុម្ព

ថ្នាក់នេះរាប់បញ្ចូល៖

- ការផ្គុំគ្នានៃសន្លឹកក្រដាសដែលបានបោះពុម្ព ដូចជា ការធ្វើជាសៀវភៅ ខិត្តបណ្ណ ទស្សនាវដ្តី កាតាឡុក ។ល។ តាមរយៈការបត់ ផ្គុំគ្នា ដេរ បិទកាវ ដាក់ផ្គុំតាមលំដាប់ ដេរដាន បិទដោយប្រើកាវស្អិត តុបតែង បោះពុម្ពអក្សរពណ៌មាស
- ការរៀបអក្សរបោះពុម្ព តម្រៀបតួអក្សរ តម្រៀបរូបភាព បញ្ចូលទិន្នន័យមុនពេលបោះពុម្ព រួមមាន ស្កេន និងការចាំតួអក្សរដោយប្រើពន្លឺអេឡិកត្រូនិចបន្ថែម
- សកម្មភាពបង្កើតបន្ទះថតរូប រួមទាំង ការរៀបចំរូបភាព និងការរៀបចំបន្ទះថតរូប (សម្រាប់ដំណើរការបោះពុម្ពដោយតួអក្សរ និងការបោះពុម្ពដោយមានតុល្យភាព)
- ការឆ្លាក់ ឬឆ្លិតរូបពីចម្លាក់ពីផ្ទាំងរូបភាពធំៗ
- ការកែច្នៃចាន ធ្វើដោយផ្ទាល់មកលើចាន (រួមទាំង ចានដែលធាប់ទទួលរងពន្លឺផង)
- ការរៀបចំចាន និងពុម្ពសម្រាប់ការវាយត្រា និងបោះពុម្ព

- ផលិតកម្មនៃសំណៅឯកសារ
- សកម្មភាពបែបសិល្បៈ រួមទាំងការរៀបចំថ្មសម្រាប់ឆ្លាក់ និងដុំឈើដែលត្រៀមរួចជាស្រេច
- ផលិតកម្មផលិតផលរីប្រូក្រាហ្វិច
- ការរចនាផលិតផលបោះពុម្ព ដូចជា គូរវាសព្រាង គំនូរព្រាង សំណាក ។ល។
- សកម្មភាពក្រាហ្វិកដទៃទៀត ដូចជា ពុម្ពលិច ពុម្ពតែម អក្សរប្រៃល ថតចម្លង បោះ ខ្ទង ធ្វើឲ្យអក្សរគ្រើម ការធ្វើឲ្យលោង និងស្រោប ការតម្រៀបពុម្ពអក្សរ និងធ្វើឲ្យមានគន្លាក់ ធ្វើឲ្យមានស្នាម។

១៨២ ការផលិតសារឡើងវិញ នូវសារឯកសារដែលបានថតចម្លងទុក

១៨២០ ១៨២០០ ការផលិតសារឡើងវិញ នូវសារឯកសារដែលបានចម្លងទុក

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលចេញពីច្បាប់ចម្លងដើមនៃសុសវែរ ឌីស និងកាស្សែតជាចម្រៀង ឬការថតចម្លងសំឡេងផ្សេងទៀតសារឡើងវិញ
- កម្មន្តសាលចេញពីច្បាប់ចម្លងដើមនៃឯកសារ ឌីស និងកាស្សែតដែលមានរូបដែលមានចលនា និងការថតវីដេអូដទៃទៀតសារឡើងវិញ
- កម្មន្តសាលចេញពីច្បាប់ចម្លងដើមនៃសហ្វវែរ និងទិន្នន័យនៅលើ
- ឌីស និងកាស្សែតសារឡើងវិញ

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលសម្ភារៈដែលបានបោះពុម្ពសារឡើងវិញ (មើល ១៨១១)
- ការបោះពុម្ពផ្សាយនូវកម្មវិធីកុំព្យូទ័រ(សូហ្វវែរ) (មើល ៥៨២០)
- ផលិតកម្ម និងការចែកចាយនូវរូបភាពដែលមានចលនា កាស្សែតវីដេអូ និងខ្សែភាពយន្តនៅលើ ឌីវីឌី ឬប្រព័ន្ធផ្សព្វផ្សាយស្រដៀងគ្នា (មើល ៥៩១១, ៥៩១២, ៥៩១៣)
- កម្មន្តសាលសារឡើងវិញ នូវខ្សែភាពយន្តរូបភាពដែលមានចលនា សម្រាប់ការចែកចាយតាមរោងកុន (មើល ៥៩១២)
- កម្មន្តសាលចេញពីច្បាប់ចម្លងដើមនៃឯកសារ ឬសម្ភារៈជាសំឡេង (មើល ៥៩២០)។

ជំពូក គ ៖ កម្មន្តសាល

ផ្នែក ១៩ ៖ កម្មន្តសាលធ្យូងភក់និងផលិតផលកាកសំណល់ប្រេងកាតផៅចម្រាញ់រួច

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
១៩១			**កម្មន្តសាលផលិតផលឡធ្យូងភក់**
	១៩១០	១៩១០០	កម្មន្តសាលផលិតផលឡដុតធ្យូងភក់

ថ្នាក់នេះរាប់បញ្ចូល៖

- ប្រតិបត្តិការឡធ្យូងភក់
- ផលិតកម្មធ្យូងភក់ និងពាក់កណ្តាលធ្យូងភក់
- ផលិតកម្មជ័រធ្យូង និងធ្យូងភក់ស្អិត
- ផលិតកម្មឧស្ម័នពីឡធ្យូងភក់
- ផលិតកម្មរ៉ែធ្យូងថ្ម និងជ័រធ្យូងលីញីត
- ការពូតដុំធ្យូងភក់។

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
១៩២			**កម្មន្តសាលចម្រាញ់ប្រេងកាត**
	១៩២០	១៩២០០	កម្មន្តសាលចម្រាញ់ប្រេងកាត

ថ្នាក់នេះរាប់បញ្ចូល៖

- ផលិតផលប្រេងកាតសម្រាប់គ្រឿងម៉ាស៊ីន៖ សាំង ប្រេងកាតសម្រាប់ដុត ។ល។
- ផលិតផលប្រេងកាតផ្សេងទៀត៖ ប្រេងឥន្ធនៈស្រាល មធ្យម និងធ្ងន់ ឧស្ម័នអេតាន ប្រូប៉ាន ប៊ុយតាន ។ល។
- ផលិតផលប្រេងរំអិល ឬខ្លាញ់គោដែលបានមកពីកាកសំណល់ប្រេង។

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	១៩២៩	១៩២៩០	កម្មន្តសាលផលិតផលប្រេងកាតផ្សេងទៀត

ថ្នាក់នេះរាប់បញ្ចូល៖

- ផលិតផលសម្រាប់ឧស្សាហកម្មគីមី ប្រេងកាត និងកៅស៊ូសម្រាប់ចាក់ក្រាលថ្នល់
- កម្មន្តសាលផលិតផលផ្សេងៗទៀត៖ ប្រេងស្ពីរីតស ប្រេងវ៉ាស៊ីលីន ក្រមួនប៉ារ៉ាហ្វីន ចាហួយប្រេងកាត ។ល។
- ផលិតផលដុំធ្យូងថ្មរឹង និងដុំធ្យូងថ្មលីញីតសម្រាប់ដុត
- ផលិតផលប្រេងកាតដុំ
- ការលាយប្រេងជីវឥន្ធនៈ៖ ការលាយអាកុលជាមួយប្រេងកាត (ហ្គាសូហូល)។

ជំពូក គ ៖ កម្មន្តសាល
ផ្នែក ២០ ៖ កម្មន្តសាលគីមី និងផលិតផលគីមី

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
២០១			**កម្មន្តសាលគីមីមូលដ្ឋានជីនិងសមាសធាតុនីត្រូហ្សែន ប្លាស្ទិកនិងសារធាតុសំយោគ និងក្នុងទម្រង់បឋម**
	២០១១		កម្មន្តសាលគីមីមូលដ្ឋាន
		២០១១១	កម្មន្តសាលអុកស៊ីសែននិងអ៊ីដ្រូហ្សែន អាសេទីឡែន
		២០១១៩	កម្មន្តសាល គីមីមូលដ្ឋានដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល កម្មន្តសាលគីមីដោយប្រើប្រាស់ការកែច្នៃជាមូលដ្ឋាន ដូចជាការបំបែកដោយកម្តៅ និងការបិត។ លទ្ធផលដែលសម្រេចបានពីការកែច្នៃទាំងអស់នេះ ជាធម្មតាគឺការញែកធាតុគីមី ឬការញែកសមាសធាតុដែលកំណត់តាមវិធីគីមី។

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ឧស្ម័នរាវ ឬឧស្ម័នមិនមែនសរីរាង្គដែលបណ្ណែន សម្រាប់ឧស្សាហកម្ម ឬវេជ្ជសាស្រ្ត៖
  - ឧស្ម័នធាតុដើម
  - ខ្យល់រាវ ឬខ្យល់បណ្ណែន
  - ឧស្ម័នធ្វើឲ្យត្រជាក់
  - ល្បាយឧស្ម័នឧស្សាហកម្ម
  - ឧស្ម័នដែលគ្មានប្រតិកម្មគីមី ដូចជា កាបោនឌីអុកស៊ីត
  - ឧស្ម័នដែលបំបែកចេញពីគេ
- កម្មន្តសាល ល័ក្តជ្រលក់ពណ៌ និងជាតិពណ៌ ពីប្រភពណាក៏ដោយក្នុងទម្រង់មូលដ្ឋាន ឬទម្រង់បង្ខាប់
- កម្មន្តសាលជាតុគីមី
- កម្មន្តសាលអាស៊ីដមិនមែនសរីរាង្គ លើកលែងអាស៊ីដនីទ្រិច
- កម្មន្តសាលអាល់កាលីស ទឹកក្បុង និងបាសមិនមែនសរីរាង្គដើមដទៃទៀត លើកលែងតែអាម៉ូញាក់
- កម្មន្តសាលសមាសធាតុមិនមែនសរីរាង្គដទៃទៀត

- កម្មន្តសាលគីមីសរីរាង្គមូលដ្ឋាន៖
    - o អាស៊ីត្លិក អ៊ីដ្រូកាបោនទាំងឆ្អែត និងមិនឆ្អែត
    - o ស៊ីត្លិក អ៊ីដ្រូកាបោន ទាំងឆ្អែត និងមិនឆ្អែត
    - o អាស៊ីដម៉ូណូ និងប៉ូលីកាបូស៊ីលិក រាប់បញ្ចូល អាស៊ីដអាសេទិច
    - o សមាសធាតុដែលមានមុខងារអុកស៊ីហ្សែន ដទៃទៀតរាប់បញ្ចូល អាល់ដេហ៊ីដ (aldehydes) កេតូន(ketones) គីណូន(quinones) និងការលាយគ្នា ឬ សមាសធាតុប៉ូលីអុកស៊ីហ្សែន
    - o គ្លីសេរ៉ុលសំយោគ
    - o សមាសធាតុសរីរាង្គមុខងារជានីត្រូហ្សែន រាប់បញ្ចូល អាមីនេ
    - o ការធ្វើឲ្យឡើងមេនៃស្ករអំពៅ ពោត ឬស្រជៀងគ្នាដើម្បីផលិតអាកុល និងអេស្ទែរ
    - o សមាសធាតុសរីរាង្គផ្សេងទៀត រាប់បញ្ចូល ផលិតផលពីការបិតឈើ (ឧ. ធ្យូង) ។ល។
- កម្មន្តសាលទឹកបិត
- កម្មន្តសាលផលិតផលក្លិនក្រអូបសំយោគ
- ការដុតដែកពីរីត (iron pyrites)

ថ្នាក់នេះក៏រាប់បញ្ចូលនូវ៖

- កម្មន្តសាលផលិតផលប្រើប្រាស់ ដូចជាប្រភេទជាភ្នាក់ងារបំភ្លឺហ្លួយអិររ៉េសង់ (fluorescent) ឬលុយមីណូហ្វរ(luminophores)
- ការចម្រាញ់រ៉ែអ៊ុយរ៉ានីញ៉ូម និងរ៉ែធរីញ៉ូម និងផលិតកម្មធាតុឥន្ទនៈសម្រាប់ រ៉េអាក់ទ័រនុយក្លេអ៊ែរ។

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ការចម្រាញ់យកសារធាតុមេតាន អេតាន ប៊ុយតាន និងប្រូប៉ាន (មើល ០៦២០)
- កម្មន្តសាល ឧស្ម័នឥន្ទនៈ ដូចជា អេតាន ប៊ុយតាន ឬប្រូប៉ាន ក្នុងការចម្រាញ់ប្រេងកាត (មើល ១៩២១)
- កម្មន្តសាល ជីនីត្រូហ្សែន និងសមាសធាតុនីត្រូហ្សែន (មើល ២០១២)
- កម្មន្តសាលអាម៉ូញាក់ (មើល ២០១២)
- កម្មន្តសាល អាម៉ូនីញ៉ូមក្លរិច (មើល ២០១២)
- កម្មន្តសាលនីទ្រិច និងប៉ូតាស្យូមនីត្រាត(មើល ២០១២)
- កម្មន្តសាល អាម៉ូនីញ៉ូមកាបូណាត(មើល ២០១២)
- កម្មន្តសាល ប្លាស្ទិកក្នុងទម្រង់បឋម(មើល ២០១៣)
- កម្មន្តសាល កៅស៊ូសំយោគទម្រង់បឋម (មើល ២០១៣)
- កម្មន្តសាល ល័ក្តជ្រលក់ពណ៌ និងជាតិពណ៌រៀបចំរួច (មើល ២០២២)
- កម្មន្តសាល គ្លីសេរ៉ុលឆៅ(មើល ២០២៣)
- កម្មន្តសាល ប្រេងក្រអូបធម្មជាតិ (មើល ២០២៩)
- កម្មន្តសាល ទឹកបិតមានក្លិនក្រអូប (មើល ២០២៩)
- កម្មន្តសាល អាស៊ីដសាលីស៊ីលិក និង អូ-អាសេទីលសាលីស៊ីលិក (O-acetylsalicylic) (មើល ២១០១)។

២០១២ ២០១២០ កម្មន្តសាល ជី និងសមាសជាតុនីត្រូហ្សែន

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលជី៖
    - ជីធ្វើពីនីត្រូហ្សែន ទោល ឬសមាស ពីហ្វូសស្វាត ឬប៉ូតាស
    - អ៊ុយរ៉េ អំបិលរ៉ែហ្វូសស្វាត ឬអំបិលរ៉ែប៉ូតាស្យូមពីធម្មជាតិ
- កម្មន្តសាល ផលិតផលនីត្រូហ្សែនផ្សំគ្នា៖
    - អាស៊ីដនីទ្រិក និងអាស៊ីដស៊ុលហ្វ៉ូនីទ្រិក អាម៉ូញាក់ អាម៉ូនីញ៉ូម ក្លរិច អាម៉ូញ៉ូមកាបូណាត នីទ្រិច និងប៉ូតាស្យូមនីត្រាត ។

ក្រុមនេះក៏រាប់បញ្ចូលផងដែរនូវ៖

- កម្មន្តសាល ជីដាក់ផើងរុក្ខជាតិលាយជាមួយឈើពុក ដែលជាជាតុផ្សំសំខាន់
- កម្មន្តសាល ជីដាក់ផើងរុក្ខជាតិលាយចម្រុះជាមួយជីធម្មជាតិ ខ្សាច់ ដីឥដ្ឋ និងជាតុខនិជ ។

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ការជីកយករ៉ែហ្គាណូ (guano) (មើល ០៨៩១)
- កម្មន្តសាល ផលិតផលជាតិគីមីកសិកម្ម ដូចជា ថ្នាំកំចាត់សត្វចង្រៃ (មើល ២០២១)
- ប្រតិបត្តិការធ្វើជីកំប៉ុស (មើល ៣៨២១) ។

២០១៣ ២០១៣០ កម្មន្តសាល ប្លាស្ទិក និងកៅស៊ូសំយោគក្នុងទម្រង់បឋម

ថ្នាក់នេះរាប់បញ្ចូលនូវកម្មន្តសាលជ័រ វត្ថុជាតុប្លាស្ទិក និង អេឡាស្តូមែរទែម្ហូប្លាស្ទិកមិនទាន់ចម្អិន ការលាយ និងច្របល់ជ័រតាមតម្រូវការ ក៏ដូចជា កម្មន្តសាលជ័រសំយោគមិនតាមតម្រូវការ។

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ប្លាស្ទិកក្នុងទម្រង់បឋម៖
    - ប៉ូលីមែរ រាប់បញ្ចូល អេទីឡែន ប្រូពីឡែន ស្ទីរ៉ែន វីនីលក្លរិច វីនីលអាសេតាត និងអាគ្រីលីក
    - ប៉ូលីយ៉ាមីត
    - ហ្វេណូលិក និង ជ័រអេប៉ូស៊ីដ និង ប៉ូលីអ៊ុយរ៉េតាន
    - អាល់គិត និង ជ័រប៉ូលីយេស្ទី និង ប៉ូលីអេទែរ
    - ស៊ីលីកូន
    - ការប្តូរអ៊ីយ៉ុង (ion-exchangers) ផ្អែកលើប៉ូលីមែរ
- កម្មន្តសាល កៅស៊ូសំយោគក្នុងទម្រង់បឋម៖
    - កៅស៊ូសំយោគ
    - ហ្វាកទីស (factice សារជាតុធ្វើកៅស៊ូស្វិត)
- កម្មន្តសាល កៅស៊ូសំយោគ លាយជាមួយកៅស៊ូធម្មជាតិ ឬកៅស៊ូស្អិត (ឧ. បាឡាតា

(Balata))

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរនូវ៖

- កម្មន្តសាល សែលុយឡូស និងជាតុគីមីក្លាយរបស់វា

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល សរសៃសិប្បនិម្មិត ឬសរសៃសំយោគ សរសៃធ្មារ និងអំបោះ (មើល ២០៣០)
- កម្មេចកំទីនៃផលិតផលប្លាស្ទិក (មើល ៣៨៣០)។

២០២ កម្មន្តសាលផលិតផលគីមីដទៃទៀត

២០២១ ២០២១០ កម្មន្តសាល ថ្នាំកំចាត់សត្វចង្រៃនិង ផលិតផលគីមីកសិកម្មដទៃទៀត

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ថ្នាំកំចាត់សត្វល្អិត ថ្នាំសម្លាប់កណ្តុរ ថ្នាំសម្លាប់ផ្សិត ថ្នាំសម្លាប់ស្មៅ
- កម្មន្តសាល ថ្នាំការពារសត្វស៊ី ថ្នាំសម្រួលការលូតលាស់របស់រុក្ខជាតិ
- កម្មន្តសាល ថ្នាំសម្លាប់មេរោគ (ប្រើក្នុងកសិកម្ម និងផ្សេងទៀត)
- កម្មន្តសាល ផលិតផលជាតិគីមីកសិកម្មដទៃដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល ជី និងសមាសធាតុនីត្រូហ្សែន (មើល ២០១២)។

២០២២ ២០២២០ កម្មន្តសាលនៃថ្នាំលាបពណ៌ វ៉ែរនី (ថ្នាំធ្វើឲ្យរលោង) និងថ្នាំទ្រនាប់ប្រហាក់ប្រហែល ទឹកថ្នាំបោះពុម្ព និងម៉ាស្ទិក

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ថ្នាំលាបពណ៌ និងវ៉ែរនី ថ្នាំលាបឲ្យភ្លឺ(enamels) ឬម្រក្សណ៍ខ្មុក (lacquers)
- កម្មន្តសាល ជាតិពណ៌ ឬល័ក្តជ្រលក់រៀបចំរួច សារជាតុធ្វើឲ្យស្រអាប់ និងធ្វើឲ្យមានពណ៌
- កម្មន្តសាល ថ្នាំលាបឲ្យភ្លឺ និងថ្នាំលាបឲ្យរលោង ថ្នាំទ្រនាប់កុល្លាភាជន៍ (engobes)ផលិតផលប្រហាក់ប្រហែល
- កម្មន្តសាល ម៉ាស្ទិក
- កម្មន្តសាល ជ័រលាយសម្រាប់បៀក និងជ័របៀកផ្ទៃលើដែលមិនធន់កម្តៅ ឬជ័រប្រហាក់ប្រហែល
- កម្មន្តសាល ទឹកសម្រាប់លាយ ពីសមាសធាតុសរីរាង្គ និង ទឹកលាយថ្នាំលាបពណ៌ឲ្យរាវ (Thinners)

- កម្មន្តសាលថ្នាំលាបពណ៌លាយរួច ឬលាងវ៉ែរនីចេញ
- កម្មន្តសាល ទឹកថ្នាំបោះពុម្ព

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល វត្ថុសម្រាប់ជ្រលក់ពណ៌ និងជាតិពណ៌ (មើល ២០១១)
- កម្មន្តសាល ទឹកថ្នាំសរសេរ និងសម្រាប់គូរ (មើល ២០២៩)។

២០២៣ ២០២៣០ កម្មន្តសាល សាប៊ូដុំម្សៅសាប៊ូគ្រឿងសម្អាតនិងប៉ូលា គ្រឿងក្រអូប និងគ្រឿងសម្អាង

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ភ្នាក់ងារសរីរាង្គសកម្មលើផ្ទៃ
- កម្មន្តសាល សាប៊ូដុំ
- កម្មន្តសាល ក្រដាស ក្រដាសទន់ ក្រដាសទក់ (felt) ។ល។ ដែលពាស ឬស្រោបដោយសាប៊ូដុំ ឬម្សៅសាប៊ូ
- កម្មន្តសាល គ្លីសេរ៉ុលឆៅ
- កម្មន្តសាល គ្រឿងសកម្មលើផ្ទៃ៖
  - ម្សៅលាងសម្អាតជាសណ្ឋានរឹង ឬរាវ និងម្សៅសាប៊ូ
  - សាប៊ូលាងចាន
  - ទឹកបន្ទន់សាច់ក្រណាត់
- កម្មន្តសាល ផលិតផលសម្អាត និងធ្វើឲ្យភ្លឺរលោង៖
  - គ្រឿងក្រអូប ឬបំបាត់ក្លិនក្នុងបន្ទប់
  - ក្រមួនសិប្បនិម្មិត និងក្រមួនដែលផ្សំរួច
  - ថ្នាំប៉ូលា និងក្រែមសម្រាប់ខាត់ស្បែក
  - ថ្នាំប៉ូលា និងក្រែមសម្រាប់ខាត់ឈើ
  - ថ្នាំប៉ូលារថយន្ត កញ្ចក់ និងលោហធាតុ
  - ម្សៅស្ងួត និងម្សៅខាប់សម្រាប់ខាត់ស្អាត រួមបញ្ចូលទាំង ក្រដាស ក្រដាសទន់ ។ល។ ដែលពាស ឬស្រោបម្សៅទាំងនេះពីលើ
- កម្មន្តសាល ទឹកអប់ និង គ្រឿងសម្អាង៖
  - ទឹកអប់ និងទឹកអប់ក្លិនស្រាល
  - គ្រឿងសម្អាង និងគ្រឿងតុបតែងកាយ
  - ថ្នាំការពារកម្ដៅថ្ងៃ និងថ្នាំលាបពេលអាំងថ្ងៃ
  - ថ្នាំលាបក្រចកដៃ និង ក្រចកជើង
  - សាប៊ូកក់សក់ ថ្នាំលាបពណ៌សក់ ថ្នាំធ្វើឲ្យសក់រួញ និងសក់ត្រង់
  - ថ្នាំដុសធ្មេញ និង ថ្នាំប្រើប្រាស់ក្នុងការធ្វើអនាម័យមាត់ធ្មេញ រួមទាំងដាក់ធ្មេញ
  - ថ្នាំកោរពុកមាត់ រាប់បញ្ចូលទាំង ថ្នាំលាបមុន និងក្រោយពេលកោរ
  - ថ្នាំបំបាត់ក្លិន និងអំបិលដុះខ្លួន
  - ថ្នាំជម្រុះរោម ឬសក់

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល ការញែក ឬសមាសធាតុដែលបានកំណត់ដោយវិធីគីមី (មើល ២០១១)
- កម្មន្តសាល គ្លីសេរ៉ុល ដែលជាសារធាតុសំយោគពីផលិតផលប្រេងឥន្ធនៈ (មើល ២០១១)
- ការចម្រោះ និងចម្រាញ់ប្រេងក្រអូបពីធម្មជាតិ (មើល ២០២៩)។

២០២៩ កម្មន្តសាល ផលិតផលគីមីដទៃទៀតដែលពុំបានរាប់បញ្ចូល

២០២៩១ កម្មន្តសាល កាំជ្រួច

២០២៩៩ កម្មន្តសាល ផលិតផលគីមីដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ម្សៅរំសេវ
- កម្មន្តសាល នៃគ្រឿងផ្ទុះ និងគ្រឿងរំសេវ រាប់បញ្ចូល កឹបផ្ទុះ ឈ្នួនបំផ្ទុះ គ្រាប់បែកផ្សែងពណ៌ ។ល។
- កម្មន្តសាល ការហ្សេឡាទីន(gelatine) និងកម្លាយ(derivatives) របស់វាដូចជា៖ ការបង់ស្អិត រាប់បញ្ចូល ការ និងបង់ស្អិតពីកៅស៊ូជាមូលដ្ឋាន
- កម្មន្តសាល នៃការចម្រាញ់ចេញពីផលិតផលក្លិនក្រអូបធម្មជាតិ
- កម្មន្តសាល ពពួកមានជាតិជ័រ
- កម្មន្តសាល ទឹកបិតមានក្លិនក្រអូប
- កម្មន្តសាល ល្បាយនៃផលិតផលដែលមានក្លិនក្រអូបសម្រាប់ កម្មន្តសាលទឹកអប់ ឬម្ហូបអាហារ
- កម្មន្តសាល បន្ទះថតរូប ហ្វីល ក្រដាសផ្តិតរូប និងសម្ភារៈសម្រាប់ផ្តិតរូបថត
- កម្មន្តសាល សារធាតុគីមីប្រើក្នុងការផ្តិតរូប
- កម្មន្តសាល សារធាតុគីមីផ្សេងៗទៀត៖
  - ប៉េបតូន (Peptones) កម្លាយប៉េបតូន (Peptone Derivatives) សារធាតុប្រូតេអ៊ីនផ្សេងទៀត និងកម្លាយរបស់វាដែលពុំបានរាប់បញ្ចូល
  - ប្រេងក្រអូប
  - ប្រេង និងខ្លាញ់ដែលផ្លាស់ប្តូរដោយវិធីគីមី
  - វត្ថុធាតុដែលប្រើក្នុងផលិតកម្មសម្រេចចុងក្រោយនៃវាយនភ័ណ្ឌ និងស្បែក
  - ម្សៅ និងម្សៅខាប់ ដែលប្រើសម្រាប់ការផ្សារ ការផ្សារនឹងលោហធាតុ ឬការផ្សារដោយភ្លើងរំលាយ
  - សារធាតុប្រើក្នុងការលត់លោហធាតុ
  - សារធាតុបន្ថែមនៅក្នុងស៊ីម៉ងត៍
  - កាបោនសកម្ម សារធាតុបន្ថែមក្នុងប្រេងរំអិល សារធាតុជំរុញកៅស៊ូដែលផ្សំស្រេច កាតាលីស និងផលិតផលគីមីដទៃទៀត ប្រើក្នុងឧស្សាហកម្ម
  - សារធាតុប្រឆាំងនឹងការសឹករេចរិល សារធាតុប្រឆាងកំណក
  - សមាសធាតុប្រើក្នុងការវិភាគរោគសញ្ញា ឬក្នុងមន្ទីរពិសោធន៍

ថ្នាក់នេះក៏រាប់បញ្ចូលនូវ៖

- កម្មន្តសាល ទឹកថ្នាំសរសេរ និងទឹកថ្នាំគំនូរ
- កម្មន្តសាល ឈើគូស

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល ផលិតផលកំណត់ដោយវិធីគីមីជាសំណុំ (មើល ២០១១)
- កម្មន្តសាល ទឹកបិត (មើល ២០១១)
- កម្មន្តសាល គ្រឿងក្រអូបសំយោគ (មើល ២០១១)
- កម្មន្តសាល ទឹកថ្នាំបោះពុម្ព (មើល ២០២២)
- កម្មន្តសាល ទឹកអប់ និងគ្រឿងសម្អិតសម្អាង (មើល ២០២៣)
- កម្មន្តសាល ជាតិស្អិតពីមូលដ្ឋានអាស្វាល (Asphalt-based) (មើល ២៣៩៩)។

២០៣ កម្មន្តសាល សរសៃសំយោគ

២០៣០ ២០៣០០ កម្មន្តសាល សរសៃសំយោគ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល សរសៃអំបោះវេញធ្មារសំយោគ ឬសិប្បនិម្មិត
- កម្មន្តសាល សរសៃសំឡីសំយោគ ឬសិប្បនិម្មិតមិនទាន់ពន្លា សិត ឬកែច្នៃផ្សេងទៀតមុនពេលវេ
- កម្មន្តសាល សរសៃសំឡីសំយោគ ឬសិប្បនិម្មិត រួមទាំងចេស ដែលស្វិតខ្លាំង
- កម្មន្តសាល ចេសទោល ឬបន្ទះខ្សែសំយោគ ឬសិប្បនិម្មិត

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ការវែសរសៃសំយោគ ឬសិប្បនិម្មិត (មើល ១៣១១)
- កម្មន្តសាល អំបោះធ្វើពីសរសៃសំឡីសំយោគ ឬសិប្បនិម្មិតមិនទាន់កែច្នៃ (មើល ១៣១១)។

ជំពូក គ ៖ កម្មន្តសាល

ផ្នែក ២១ ៖ កម្មន្តសាល ឱសថសារធាតុគីមីសម្រាប់ព្យាបាលនិងផលិតផលថ្នាំធ្វើពីរុក្ខជាតិ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
២១០			**កម្មន្តសាល ឱសថសារធាតុគីមីសម្រាប់ព្យាបាល និងផលិតផលឱសថធ្វើពីរុក្ខជាតិ**
	២១០០	២១០០០	កម្មន្តសាល ឱសថសារធាតុគីមីសម្រាប់ព្យាបាល និងផលិតផលឱសថធ្វើពីរុក្ខជាតិ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល សារធាតុសកម្មដែលអាចធ្វើជាឱសថបានដើម្បីប្រើឲ្យមានប្រយោជន៍ក្នុងកម្មន្តសាលនៃឱសថ ៖ អង់ទីប្យូទិក វីតាមីនធម្មអាស៊ីដសាលីស៊ីលិក និង អូ-អាសេទីលសាលីស៊ីលិក (O-acetylsalicylic) ។ល។
- ការកែច្នៃឈាម
- កម្មន្តសាលនៃការព្យាបាល៖
  - o អង់ទីសេរ៉ា(Antisera) និងផ្នែកខ្លះក្នុងឈាម
  - o ថ្នាំបង្ការជំងឺ (វ៉ាក់សាំង)
  - o ការព្យាបាលចម្រុះ រួមមានទាំង ការព្យាបាលដោយប្រើមេរោគ
- កម្មន្តសាល ផលិតផលថ្នាំពន្យារកំណើតបែបគីមីសម្រាប់ការប្រើប្រាស់ខាងក្រៅ និងឱសថពន្យារកំណើតដោយប្រើអរម៉ូន
- កម្មន្តសាល សារធាតុសម្រាប់វិនិច្ឆ័យជំងឺ រាប់បញ្ចូលទាំងការធ្វើតេស្តមើលលទ្ធផលមានផ្ទៃពោះ
- កម្មន្តសាល ជាតិវិទ្យុសកម្មក្នុងសារធាតុវិនិច្ឆ័យជំងឺក្នុងរាងកាយ
- កម្មន្តសាល ឱសថជីវបច្ចេកវិជ្ជា

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរ៖

- កម្មន្តសាល ស្ករសុទ្ធដែលមានជាតិគីមី
- ការកែច្នៃក្រពេញ និងកម្មន្តសាល សារធាតុដែលចម្រាញ់ចេញពីក្រពេញ។ល។
- កម្មន្តសាល សំឡី ស្បៃ ស្បៃរុំរបួស ស៊ីម៉ងត៍ សម្រាប់ប្រើក្នុងផ្នែកវិជ្ជសាស្ត្រ ។ល។
- កម្មន្តសាល នៃការរៀបចំនូវផលិតផលធ្វើពីរុក្ខជាតិ (លម្អិត បែងចែកគុណភាព កិន) សម្រាប់ប្រើប្រាស់ជាឱសថ

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលនៃការគ្រាំរុក្ខជាតិ (ជីអង្កាម វើវែន (vervain) ខាម៉ូម៉ាយ ។ល។) (មើល ១០៧៩)
- កម្មន្តសាល សារធាតុសម្រាប់ប៉ះធ្មេញ និងស៊ីម៉ងត៍ប្រើលើបធ្មេញ (មើល ៣២៥០)
- កម្មន្តសាល ស៊ីម៉ងត៍ប្រើដើម្បីធ្វើឲ្យឆ្អឹងមានទ្រង់ទ្រាយដើមវិញ (មើល ៣២៥០)
- ការលក់ដុំនូវផលិតផលឱសថ (មើល ៤៧២២)
- ការស្រាវជ្រាវ និងការវិវឌ្ឍឱសថ និងឱសថជីវបច្ចេកវិជ្ជា (មើល ៧២១០)
- ការវេចខ្ចប់ឱសថ (មើល ៨២៩២)។

ជំពូក គ ៖ កម្មន្តសាល

ផ្នែក ២២ ៖ កម្មន្តសាល ផលិតផលពីកៅស៊ូនិងប្លាស្ទិក

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
២២១			**កម្មន្តសាល ផលិតផលពីកៅស៊ូ**
	២២១១	២២១១០	កម្មន្តសាល សំបកកង់ និង ពោះវៀនកង់និងការចាក់ពុម្ពឡើងវិញ និងការធ្វើជាថ្មីនៃកៅស៊ូកង់

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល សំបកកង់សម្រាប់យានជំនិះ បរិក្ខារ ម៉ាស៊ីនចល័ត យន្តហោះ ឧបករណ៍ក្មេងលេង គ្រឿងសង្ហារិម និងសម្រាប់ការប្រើប្រាស់ផ្សេងទៀត៖
    - សំបកកង់មានខ្យល់
    - សំបកកង់តាន់រឹង ឬសំបកកង់មានស្នូលទន់
- កម្មន្តសាល ពោះវៀនកង់
- កម្មន្តសាល ក្រឡាកង់ ដែលអាចដោះដូរបាន ទ្រនាប់ថាសកង់ បន្ទះដុំពកសម្រាប់ចាក់ពុម្ពក្រឡាកង់ជាថ្មី ។ល។
- ការធ្វើសំបកកង់ជាថ្មី និងចាក់ពុម្ពជាថ្មី

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល វត្ថុធាតុសម្រាប់ជួសជុលពោះវៀនកង់ (មើល ២២១៩)
- ការជួសជុលសំបកកង់ និងពោះវៀនកង់ ដាក់ ឬប្តូរសំបកកង់ (មើល ៤៥២០)។

	២២១៩	២២១៩០	កម្មន្តសាល នៃ ផលិតផលកៅស៊ូដទៃទៀត

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ផលិតផលដទៃទៀតធ្វើពីជ័រកៅស៊ូធម្មជាតិ ឬសំយោគ មិនទាន់ចម្អិន ចម្អិនរួច ឬធ្វើឲ្យរឹង៖
    - បន្ទះកៅស៊ូ សន្លឹកកៅស៊ូ ចម្រៀកកៅស៊ូ ជាដុំទ្រវែង ឬរាងផ្សេងៗទៀត
    - បំពង់ ទុយោ ទុយោទន់
    - ខ្សែពាននាំ ឬខ្សែពានអូស ឬខ្សែក្រវាត់
    - គ្រឿងអនាម័យធ្វើពីកៅស៊ូ៖ ស្រោមអនាម័យ ក្បាលដោះសម្រាប់ក្មេង ដបទឹកក្តៅ ។ល។
    - ផ្នែកនៃសម្លៀកបំពាក់ធ្វើពីកៅស៊ូ (ប្រសិនបើវាជាប់គ្នាតែមួយ មិនមែនដេរភ្ជាប់)
    - ចេស និងខ្សែព្ួរកៅស៊ូ
    - អំបោះ និងផ្ទាំងក្រណាត់ដែលពាសកៅស៊ូ
    - កង គ្រឿងខ្ចៅ ត្រា ធ្វើពីកៅស៊ូ
    - រ៉ូឡូដែលស្រោបកៅស៊ូ
    - ពូកកៅស៊ូដែលបញ្ចេញ-បញ្ចូលខ្យល់បាន
    - បាឡុងដែលបញ្ចេញ-បញ្ចូលខ្យល់បាន

- o កម្មន្តសាល ប្រាសកៅស៊ូ
- o កម្មន្តសាល ខ្នែងបំពង់ពីកៅស៊ូរឹង
- o កម្មន្តសាល ក្រាសសិតសក់ ដង្កៀបកៀបសក់ ឧបករណ៍រមូរសក់ និង សម្ភារៈ ប្រហាក់ប្រហែលគ្នាធ្វើពីកៅស៊ូរឹង

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរនូវ៖

- កម្មន្តសាល វត្ថុជាតុជូសជុលពីកៅស៊ូ
- កម្មន្តសាល ផ្ទាំងក្រណាត់វាយនភ័ណ្ឌដែលបញ្ជោក ពាស ស្រោប អ៊ុតស្រទាប់ជាមួយកៅស៊ូ ដែលកៅស៊ូគឺជាធាតុផ្សំសំខាន់
- កម្មន្តសាល ពូកទឹកធ្វើពីកៅស៊ូ
- កម្មន្តសាលា មួកងូតទឹក និងអៀមធ្វើពីកៅស៊ូ
- កម្មន្តសាល សម្លៀកបំពាក់ សម្រាប់ពាក់នៅកន្លែងសើម និងសម្លៀកបំពាក់មុជទឹកធ្វើពីកៅស៊ូ
- កម្មន្តសាល ប្រដាប់ភេទធ្វើពីកៅស៊ូ

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល ក្រណាត់លួសសម្រាប់ធ្វើសំបកកង់ (មើល ១៣៩៩)
- កម្មន្តសាល សម្លៀកបំពាក់ពីក្រណាត់ដែលយឺត (មើល ១៤១១)
- កម្មន្តសាល ស្បែកជើងកៅស៊ូ (មើល ១៥២០)
- កម្មន្តសាល ការ និង បង់ស្អិតធ្វើពីកៅស៊ូ (មើល ២០២៩)
- កម្មន្តសាល បន្ទះពកធ្វើក្រឡាសំបកកង់ (មើល ២២១១)
- កម្មន្តសាល ក្បូន និងទូកដែលបញ្ចេញ-បញ្ចូលខ្យល់បាន (មើល ៣០១១ ៣០១២)
- កម្មន្តសាល ពូកដែលមិនស្រោបកៅស៊ូសែលុយឡូ (មើល ៣១០០)
- កម្មន្តសាល សម្ភារៈកីឡាពីកៅស៊ូ លើកលែងសម្លៀកបំពាក់ (មើល ៣២៣០)
- កម្មន្តសាល ល្បែងលេង និងឧបករណ៍ក្មេងលេង (រាប់បញ្ចូលទាំង អាងទឹកតូចសម្រាប់ក្មេង ទូកកៅស៊ូដែលអាចបញ្ចូលខ្យល់បានសម្រាប់ក្មេង សត្វធ្វើពីកៅស៊ូដែលអាចបញ្ចូលខ្យល់បាន បាល់ និងរបស់របរស្រដៀងគ្នា) (មើល ៣២៤០)
- ការកែច្នៃសំណល់កៅស៊ូ (មើល ៣៨៣០)។

២២២ **កម្មន្តសាល ផលិតផលធ្វើពីប្លាស្ទិក**

២២២០ ២២២០០ កម្មន្តសាល គ្រឿងសំណង់ធ្វើពីប្លាស្ទិក

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល គ្រឿងសំណង់ធ្វើពីប្លាស្ទិក៖
  - ទ្វារ បង្អួច គ្រោង ទនាំង វាំងនន ក្តារបិទជញ្ជាំង ធ្វើពីប្លាស្ទិក
  - ធុងទឹក អាងស្តុកទឹក
  - កម្រាលក្រាលលើផ្ទៃដើរ សម្រាប់ជញ្ជាំង ឬសម្រាប់ពិតានជារមូរ ឬទ្រង់ទ្រាយជាការ៉ូធ្វើពីប្លាស្ទិក
  - សម្ភារៈអនាម័យធ្វើពីប្លាស្ទិកដូចជា ៖
  - រ៉ូប៊ីណេផ្កាឈូក អាងងូតទឹក អាងលាងមុខ ចានបង្គន់ ឧបករណ៍កាច់ទឹក ធ្វើពីប្លាស្ទិក ។ល។
- កម្មន្តសាល កម្រាលឥដ្ឋដែលអាចឃើតរលាស់ ដូចជា វីនីល (vinyl) លីណូលៀម (linoleum) ។ល។

២២២១ ២២២១០ កម្មន្តសាល សម្ភារៈប្លាស្ទិកប្រើសម្រាប់ការវេចខ្ចប់ឥវ៉ាន់

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល សម្ភារៈប្លាស្ទិកសម្រាប់ការវេចខ្ចប់ម្ហូបអាហារ៖
  - ថង់ ការ៉ុង ធុង ប្រអប់ កេស ធុងការ ធុងមូល ដប ធ្វើពីប្លាស្ទិក ។ល។

២២២២ ២២២២០ កម្មន្តសាល ផលិតផលប្លាស្ទិកសម្រេច

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ផលិតផលប្លាស្ទិកសម្រេច៖
  - បំពង់ ទុយោ ទុយោទន់ និងរ៉ាគរទុយោពីប្លាស្ទិក
- កម្មន្តសាល គ្រឿងប្រើប្រាស់ក្នុងការទទួលទានអាហារ ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះបាយ និង សម្ភារៈបន្ទប់ទឹក ធ្វើពីប្លាស្ទិក ។

២២២៩ ២២២៩០ កម្មន្តសាល ផលិតផលប្លាស្ទិកដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ផលប្លាស្ទិកពាក់កណ្តាលសម្រេច៖
  - បន្ទះ សន្លឹក ដុំ សន្លឹកស្តើង សន្លឹកស្តើងខ្លាំង បន្ទះវែងប្លាស្ទិក ។ល។ (ទោះជាស្អិតដោយខ្លួនឯង ឬមិនស្អិតក៏ដោយ) ។

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរ៖

- សន្លឹកស្តើង ឬសន្លឹកសេឡូហាន (cellophane) ប្លាស្ទិកស្តើងសម្រាប់ខ្ចប់ម្ហូប
- កម្មន្តសាល ថ្មសិប្បនិម្មិត (ដូចជា ថ្មម៉ាបសិប្បនិម្មិត)
- កម្មន្តសាល សញ្ញាសំគាល់ធ្វើពីប្លាស្ទិក (មិនប្រើអគ្គិសនី)
- កម្មន្តសាល ផលិតផលធ្វើពីប្លាស្ទិកចម្រុះ៖
    - មួកធ្វើពីប្លាស្ទិក គ្រឿងអ៊ីសូឡង់ផ្នែកនៃគ្រឿងបំភ្លឺ សម្ភារៈសម្រាប់ការិយាល័យ ឬសាលារៀន ផ្នែកនៃសម្លៀកបំពាក់ (ប្រសិនបើភ្ជាប់គ្នាតែមួយ មិនមែនដេរភ្ជាប់) គ្រឿងប្រើជាមួយ គ្រឿងសង្ហារិម រូបបដិមា ខ្សែពានអូស ឬខ្សែពាននាំ បង់ស្អិត ក្រដាសប្លាស្ទិកបិទជញ្ជាំង ពុម្ពស្បែកជើង ប្រដាប់ដាក់បារី ក្រាសសិតសក់ ឧបករណ៍អ៊ុតសក់ សម្ភារៈក្មេងលេងកំសាន្ត ធ្វើពីប្លាស្ទិក ។ល។

ជំពូក គ ៖ កម្មន្តសាល
ផ្នែក ២៣ ៖ កម្មន្តសាល ផលិតផលពីរ៉ែអលោហៈដទៃទៀត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
២៣១			**កម្មន្តសាល កញ្ចក់និងផលិតផលពីកញ្ចក់**
	២៣១០	២៣១០០	កម្មន្តសាល កញ្ចក់ និងផលិតផលពីកញ្ចក់

ថ្នាក់នេះរាប់បញ្ចូលនូវកម្មន្តសាលកញ្ចក់ គ្រប់ទម្រង់ ទោះជាធ្វើតាមវិធីណាក៏ដោយ និងកម្មន្តសាលនៃរបស់របរធ្វើពីកញ្ចក់ ។

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល កញ្ចក់រាបស្មើ រាប់បញ្ចូលទាំង កញ្ចក់បញ្ចុះខ្សែលោហធាតុមានពណ៌ និងពណ៌ស្រាល
- កម្មន្តសាល កញ្ចក់រឹងស្វិត ឬកញ្ចក់រាបស្មើដែលអ៊ុតទ្រនាប់
- កម្មន្តសាល កញ្ចក់ជាដុំទ្រវែង ឬជាបំពង់
- កម្មន្តសាល ដុំកញ្ចក់ក្រាល
- កម្មន្តសាល កញ្ចក់ឆ្លុះមុខ
- កម្មន្តសាល កញ្ចក់អ៊ីសូឡង់មានច្រើនស្រទាប់
- កម្មន្តសាល ដប និងធុងផ្សេងទៀតធ្វើពីកញ្ចក់ ឬគ្រីស្តាល់
- កម្មន្តសាល កែវផឹកទឹក និងកែវប្រើប្រាស់ក្នុងផ្ទះផ្សេងទៀត ឬរបស់របរធ្វើពី គ្រីស្តាល់
- កម្មន្តសាល សំឡីកញ្ចក់ រាប់បញ្ចូលទាំង ផលិតផលពីសំឡីខ្សែន កញ្ចក់ និងមិនមែនត្បាញដទៃទៀត
- កម្មន្តសាល គ្រឿងកញ្ចក់សម្រាប់ប្រើក្នុងមន្ទីរពិសោធន៍ ផ្នែកអនាម័យ និងផ្នែកឱសថ
- កម្មន្តសាល កញ្ចក់នាឡិកាព្យួរជញ្ជាំង និងនាឡិកាដៃ កញ្ចក់វ៉ែនតា និងធាតុអុបទិច តែមិនមែនដំណើរការជាអុបទិក
- កម្មន្តសាល គ្រឿងកញ្ចក់ដែលប្រើក្នុងកម្មន្តសាល គ្រឿងអលង្ការកាឡៃ
- កម្មន្តសាល អ៊ីសូឡង់ពីកញ្ចក់ និងគ្រឿងដំឡើងអ៊ីសូឡង់ពីកញ្ចក់
- កម្មន្តសាល កញ្ចក់ប្រអប់សម្រាប់អំពូលភ្លើង
- កម្មន្តសាល រូបចម្លាក់ធ្វើពីកញ្ចក់

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល ក្រណាត់ត្បាញធ្វើពីសរសៃកញ្ចក់ (មើល ១៣១២)
- កម្មន្តសាល ធាតុផ្សំពីអុបទិក ដែលដំណើរការជាអុបទិក (មើល ២៦៧)
- កម្មន្តសាល សរសៃកាបហ្វៃបឺអុបទិកសម្រាប់ការបញ្ជូនទិន្នន័យ ឬបញ្ជូនទិន្នន័យបន្តផ្ទាល់រូបភាព (មើល ២៧៣១)
- កម្មន្តសាល ឧបករណ៍ក្មេងលេងធ្វើពីកញ្ចក់ (មើល ៣២៤០)
- កម្មន្តសាល ស៊ីរ៉ាំង និងបរិក្ខារក្នុងមន្ទីរពិសោធន៍វេជ្ជសាស្ត្រផ្សេងទៀត (មើល ៣២៥០)។

២៣៩ **កម្មន្តសាល ផលិតផលពីរ៉ែអលោហៈ ដែលពុំបានរាប់បញ្ចូល**

២៣៩១ ២៣៩១០ កម្មន្តសាល ផលិតផលធន់កម្តៅ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល បាយអ បេតុងធន់កម្តៅ ។ល។
- កម្មន្តសាល ផលិតផលសេរាមិកធន់កម្តៅ៖
  - o សេរាមិកអ៊ីសូឡង់កម្តៅ ពីហ្វូស៊ីលស៊ីលីកាត
  - o ឥដ្ឋ ផ្ទាំងឥដ្ឋ និង ក្បឿង ដែលធន់កម្តៅ ។ល។
  - o ឡសម្ភាធ ចានសម្រាប់ដាក់វត្ថុដុត ទ្រនាប់ចង្ក្រាន ក្បាលតបំពង់លូ ទុយោ លូ ។ល។

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរនូវ៖

- កម្មន្តសាល របស់ធន់កម្តៅមាន សារធាតុម៉ាញ៉េស៊ីត ដូឡូមីត
- ឬក្រូមីត។

២៣៩២ កម្មន្តសាល សំភារៈសំណង់ធ្វើពីដីឥដ្ឋ

២៣៩២១ កម្មន្តសាល ក្បឿងប្រក់ដំបូល

២៣៩២២ កម្មន្តសាល ឥដ្ឋ

២៣៩២៣ កម្មន្តសាល កម្រាលក្រាលធ្វើពីដីឥដ្ឋដុត

២៣៩២៩ កម្មន្តសាល សម្ភារៈសំណង់ធ្វើពីដីឥដ្ឋ ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ចង្ក្រានកម្តៅផ្ទះ ឬការ៉ូជញ្ជាំងពីសេរាមិកមិនធន់កម្តៅ ការ៉ូម៉ូសាអ៊ីក (រៀបចេញជារូបសត្វ ផ្សេងៗ) ។ល។
- កម្មន្តសាល ដុំឥដ្ឋក្រាលពីសេរាមិកមិនធន់កម្តៅ
- កម្មន្តសាល សម្ភារៈសំណង់ធ្វើពីដីឥដ្ឋមិនធន់កម្តៅ ៖
  - o កម្មន្តសាល ឥដ្ឋសេរាមិក ក្បឿងប្រក់ដំបូល បំពង់បង្ហុយផ្សែង លូ បំពង់ ចានខ្សែភ្លើង ។ល។
- កម្មន្តសាល ដុំឥដ្ឋដុំរៀបការ៉ូពីដីឥដ្ឋដុត
- កម្មន្តសាល គ្រឿងចាប់ភ្ជាប់ពីសេរាមិក (sanitary fixture)

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល ថ្មសិប្បនិម្មិត (ដូចជា ថ្មម៉ាប) (មើល ២២២៩)
- កម្មន្តសាល ផលិតផលសេរាមិកធន់កម្តៅ (មើល ២៣៩១)។

២៣៩៣   ២៣៩៣០   កម្មន្តសាល ផលិតផលពីព័រសឺឡែន និងសេរាមិកដទៃទៀត

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល សម្ភារៈប្រើប្រាស់លើតុ និងឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ និងសម្ភារៈប្រើប្រាស់ក្នុងបន្ទប់ទឹកដទៃទៀត
- កម្មន្តសាល រូបចម្លាក់ និងរបស់របរតុបតែងពីសេរាមិកដទៃទៀត
- កម្មន្តសាល អ៊ីសូឡង់អគ្គិសនី និងចានអ៊ីសូឡង់ពីសេរាមិក
- កម្មន្តសាល មេដែកពីសេរាមិក និងពីរ៉ែដែលមានជាតិមេដែកច្រើន
- កម្មន្តសាល ផលិតផលសេរាមិក ប្រើប្រាស់ក្នុងបន្ទប់ពិសោធន៍គីមី និងឧស្សាហកម្ម
- កម្មន្តសាល ថូ ក្រឡសេរាមិក និងរបស់របរស្រដៀងគ្នាសម្រាប់ការដឹកជញ្ជូន និងវេចខ្ចប់ទំនិញ
- កម្មន្តសាល គ្រឿងសង្ហារិមធ្វើពីសេរាមិក
- កម្មន្តសាល ផលិតផលធ្វើពីសេរាមិក ដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល ថ្មសិប្បនិម្មិត (ដូចជា ថ្មម៉ាប) (មើល ២២២៩)
- កម្មន្តសាល ផលិតផលពីសេរាមិកធន់កម្ដៅ (មើល ២៣៩១)
- កម្មន្តសាល សម្ភារៈសំណង់ធ្វើពីកុលាលភាជន៍ (មើល ២៣៩២)
- កម្មន្តសាល គ្រឿងចាប់ភ្ជាប់ពីសេរាមិក (sanitary fixture) (មើល ២៣៩២)
- ការផលិតមេដែកលោហធាតុ (មើល ២៥៩៩)
- កម្មន្តសាល នៃគ្រឿងអលង្ការកាឡៃ (មើល ៣២១២)
- កម្មន្តសាល ឧបករណ៍ក្មេងលេងពីសេរាមិក (មើល ៣២៤០)
- កម្មន្តសាល ធ្មេញសិប្បនិម្មិត (មើល ៣២៥០)។

២៣៩៤   កម្មន្តសាល ស៊ីម៉ងត៍កំបោរប្លាស្ទ័រ

២៣៩៤១   កម្មន្តសាល ស៊ីម៉ងត៍

២៣៩៤២   កម្មន្តសាល កំបោរ

២៣៩៤៩   កម្មន្តសាល ស៊ីម៉ងត៍កំបោរប្លាស្ទ័រដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ក្លាំងគែរ និង ស៊ីម៉ងត៍អ៊ីដ្រូលិក (ប្រើក្នុងទឹកបាន) រាប់បញ្ចូលទាំង ស៊ីម៉ងត៍ពរឡង់ (ស៊ីម៉ងត៍ពីថ្មកំបោរ និងម្នាងសិលា) ស៊ីម៉ងត៍អាលុយមីញ៉ូម ស៊ីម៉ងត៍ស្លេក និងស៊ីម៉ងត៍ស៊ុបពែហ្វូសស្វាត
- កម្មន្តសាល កំបោររស់ កំបោរងាប់ កំបោរអ៊ីដ្រូលិក (កំបោរធ្វើជាបាយអអាចប្រើក្នុងទឹកបាន)
- កម្មន្តសាល ប្លាស្ទ័របានមកពីការដុតម្នាងសិលា ឬដុតស៊ុលហ្វាត
- កម្មន្តសាល ដូឡូមីតដុត

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល បាយអកំបោរ ឬបេតុងដែលធន់កម្តៅ ។ល។ (មើល ២៣៩១)
- កម្មន្តសាល របស់របរធ្វើពីស៊ីម៉ងត៍ (មើល ២៣៩៥)
- កម្មន្តសាល របស់របរធ្វើពីប្លាស្ទ័រ (មើល ២៣៩៥)
- កម្មន្តសាល បេតុងលាយរួច ឬបេតុងលាយស្ងួតរួច និងបាយអកំបោរ (មើល ២៣៩៥)
- កម្មន្តសាល ស៊ីម៉ងត៍ប្រើប្រាស់ក្នុងវិស័យទន្តសាស្ត្រ (មើល ៣២៥០)។

២៣៩៥ ២៣៩៥០ កម្មន្តសាល របស់របរប្រើប្រាស់ធ្វើពីកំបោរ ស៊ីម៉ងត៍និងប្លាស្ទ័រ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល បេតុងមិនទាន់ចាក់ពុម្ព ស៊ីម៉ងត៍ ឬរបស់របរធ្វើពីថ្មសិប្បនិម្មិតដែលប្រើប្រាស់ក្នុងវិស័យសំណង់៖
  - ក្បឿង ផ្ទាំងថ្ម ឥដ្ឋ បន្ទះ សន្លឹក ប៉ាណែល បំពង់ សសរគ្រឹះ ។ល។
- កម្មន្តសាល គ្រោងសំណង់ដែលសង់ទុករួចសម្រាប់ការសាងសង់ ឬវិស្វកម្មសំណង់ស៊ីវិលធ្វើពីស៊ីម៉ងត៍ បេតុង ឬពីថ្មសិប្បនិម្មិត
- កម្មន្តសាល របស់របរធ្វើពីប្លាស្ទ័រប្រើប្រាស់ក្នុងវិស័យសំណង់៖
  - ផ្ទាំង សន្លឹក ប៉ាណែល ។ល។
- កម្មន្តសាល សម្ភារៈសំណង់ធ្វើពីសារធាតុរុក្ខជាតិ (កម្ទេចឈើ ចំបើង ត្រែង បបុស) បញ្ចូលគ្នាជាមួយស៊ីម៉ងត៍ ប្លាស្ទ័រ ឬល្បាយដទៃទៀត
- កម្មន្តសាល របស់របរពីស៊ីម៉ងត៍លាយអាបេស្តូ (Asbestos) ឬស៊ីម៉ងត៍លាយសរសៃសែលុយឡូ ឬសារធាតុស្រដៀងគ្នានេះ៖
  - សន្លឹកហ្វីប្រូ បន្ទះ ប៉ាណែលដទៃទៀត ការ៉ូ បំពង់ លូ ធុង ស្នូក អាងទឹក ចានកាធុន ថូ គ្រឿងសង្ហារិម គ្រោងបង្អួច ។ល។
- កម្មន្តសាល ផលិតផលដទៃទៀតធ្វើពីបេតុង ប្លាស្ទ័រ ស៊ីម៉ងត៍ ឬថ្មសិប្បនិម្មិត៖
  - រូបចម្លាក់ គ្រឿងសង្ហារិម ក្បាច់ចម្លាក់ ថូផ្កា ផើងផ្កា ។ល។
- កម្មន្តសាល ម្សៅបាយអកំបោរ
- កម្មន្តសាល បេតុងលាយរួច និងបេតុងលាយស្ងួតរួច បាយអកំបោរ

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល ស៊ីម៉ងត៍ធន់កម្តៅ និងបាយអរកំបោរធន់កម្តៅ (មើល ២៣៩១)។

២៣៩៦ ២៣៩៦០ ការកាត់សូន និងកែច្នៃផលិតផលធ្វើអំពីថ្ម

ថ្នាក់នេះរាប់បញ្ចូល៖

- ការកាត់ថ្ម ការសូន និងកែច្នៃថ្មដើម្បីប្រើប្រាស់ក្នុងសំណង់ ក្នុងកន្លែងបញ្ចុះសព ធ្វើផ្លូវ ប្រក់ដំបូល ។ល។
- កម្មន្តសាល គ្រឿងសង្ហារិមធ្វើពីថ្ម

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ផលិតកម្ម ក្នុងការកាត់ថ្មជាផ្ទាំង ឧទាហរណ៍ សកម្មភាពការដ្ឋានជីកយកថ្ម (មើល ០៨១០)
- ផលិតកម្ម ថ្មត្បាល់កិន ថ្មឆាប និងផលិតផលស្រដៀងនេះ (មើល ២៣៩៩)
- រាល់សកម្មភាពចម្លាក់ថ្ម (មើល ៩០០០)។

២៣៩៩ ២៣៩៩០ កម្មន្តសាលនៃផលិតផលរ៉ែអលោហៈ ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ថ្មត្បាល់កិន ថ្មឆាប ឬថ្មប៉ូលា និងផលិតផលថ្មឆាបពីធម្មជាតិ និងសិប្បនិម្មិត ផលិតផលខាត់រំលីញ រាប់បញ្ចូល ផលិតផលខាត់រំលីញដែលភ្ជាប់លើរបស់ទន់ (ដូចជា ក្រដាសខាត់)
- កម្មន្តសាល វត្ថុធាតុកកិត និង របស់របរទាំងនោះដែលមិនចាប់ជំឡើងជាមួយសារធាតុរ៉ែមូលដ្ឋាន ឬជាមួយសែលលុយឡូ
- កម្មន្តសាល វត្ថុធាតុរ៉ែអ៊ីសូឡង់៖
    - o សរសៃស្លេក (Slag Wool) សរសៃថ្ម (Stone Wool) និងសរសៃពីរ៉ែ ស្រដៀងគ្នា គ្រាប់ដីឥដ្ឋលុញធន់នឹងកម្តៅ និង របស់របរអ៊ីសូឡង់កម្តៅស្រដៀងគ្នា អ៊ីសូឡង់សំឡេង ឬវត្ថុធាតុកាត់បន្ថយសំឡេង
- កម្មន្តសាល របស់របរធ្វើពីសារធាតុរ៉ែផ្សេងៗ ៖
    - o មីកាច្នៃ និងរបស់របរធ្វើពីមីកា ពីធ្យូង (Peat)ពីក្រាហ្វិត (ផ្សេងទៀតក្រៅពីគ្រឿងអគ្គិសនី) ។ល។
- កម្មន្តសាល របស់របរធ្វើពីអាស្វាល (Asphalt)ឬវត្ថុស្រដៀងគ្នា ដូចជា របស់ស្អិត (Adhesive)ពីមូលដ្ឋានអាស្វាល កៅស៊ូស្អិតពីធ្យូងថ្ម ។ល។
- សរសៃកាបោន និងក្រាហ្វិត និងផលិតផលរបស់វា (លើកលែងតែ អេឡិចត្រូដ និង ឧបករណ៍អគ្គិសនី)

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល សរសៃកញ្ចក់ និងផលិតផលពីសរសៃកញ្ចក់មិនមែនត្បាញ (មើល ២៣១០)
- កម្មន្តសាល វែងទ្រនាប់ធ្វើពីកាបោន ឬក្រាហ្វិត (មើល ២៨១៩)។

ជំពូក គ ៖ កម្មន្តសាល
ផ្នែក ២៤ ៖ កម្មន្តសាល លោហធាតុមូលដ្ឋាន

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
២៤១			**កម្មន្តសាល ដែកមូលដ្ឋាននិងដែកថែប**
	២៤១០	២៤១០០	កម្មន្តសាល ដែកមូលដ្ឋាន និងដែកថែប

ថ្នាក់នេះរាប់បញ្ចូលប្រតិបត្តិការនៃការបំប្លែង ដោយធ្វើរេដុកកម្មរ៉ែដែក ដោយឡផ្ទុះ និងឡបន្សុទ្ធប្រើអុកស៊ីហ្សែន ឬសំណល់ដែក និងកម្ទេចកម្ទីដែក ក្នុងឡដុតអគ្គិសនី ឬដោយធ្វើរេដុកកម្មរ៉ែដែកដោយផ្ទាល់ ឬដោយមិនបាច់ឲ្យរលាយទៅជាដែកថែបទេ ដោយគ្រាន់តែយកទៅរំលាយ និងចម្រាញ់នៅក្នុងឡចាក់ ដើម្បីចាក់ពុម្ពផលិតជាផលិតផលពាក់កណ្តាលសម្រេច ដូចជា ដែកបន្ទះ សន្លឹក ចម្រៀក ដើមជ្រុង ដើមមូល ដែកសរសៃ បំពង់ និងមានមុខកាត់ប្រហោងផ្សេងៗទៀត។

ថ្នាក់នេះរាប់បញ្ចូល៖

- ប្រតិបត្តិការឡផ្ទុះ ឡបន្សុទ្ធដែកថែប ការកិន និងកិនបង្ហើយ
- ផលិតកម្មដែកស្អិត និង ស្ពីជើឡាយសិន មានជាតិម៉ង់កាណែសខ្ពស់ជាដុំៗ ឬជារាងបឋមផ្សេងៗទៀត
- ផលិតកម្ម ដែកសំលោហៈ
- ផលិតកម្ម ផលិតផលដែលពីដែក ដែលធ្វើតាមវិធីរេដុកកម្មផ្ទាល់លើដែក និងផលិតផលដែកស្ពោតដទៃទៀត
- ផលិតកម្ម ដែកដែលបន្សុទ្ធពិសេសដោយការធ្វើអេឡិកត្រូលីត និងការកែច្នៃបែបគីមីដទៃទៀត
- ផលិតកម្មដែកជាគ្រាប់តូច និងម្សៅ
- ផលិតកម្ម ដែកថែបជាដុំ និងជារូបរាងបឋមផ្សេងទៀត
- ការស្លរំលាយឡើងវិញ នូវកម្ទេចដុំដែក ឬដែកថែប
- ផលិតកម្មដែកថែបពាក់កណ្តាលសម្រេច
- កម្មន្តសាល ផលិតផលដែកថែបសំប៉ែត ដែលបានមកតាមវិធីកិនក្តៅ និងកិនត្រជាក់
- កម្មន្តសាល ដែកថែបដើមជ្រុង និងដើមមូលតាមវិធីកិនក្តៅ
- កម្មន្តសាល ដែកថែបមានមុខកាត់ប្រហោងតាមវិធីកិនក្តៅ
- កម្មន្តសាល ដែកថែបដើមជ្រុង និងមុខកាត់តាន់តាមវិធីហូតត្រជាក់ ឆាប ឬក្រឡឹង
- កម្មន្តសាល ដែកថែបមានមុខកាត់ប្រហោង តាមវិធីពត់រាងត្រជាក់ ឬបត់ដោយសង្កត់ដែកថែបបន្ទះ
- កម្មន្តសាល លួសដែកថែប ដោយវិធីហូតត្រជាក់ ឬហូតម្សួល
- កម្មន្តសាល បន្ទះដែកថែបសង្កត់ភ្លី និង ដែកថែបមានមុខកាត់ប្រហោង និង និងផ្សារតំណ
- កម្មន្តសាល ដែកថែបផ្លូវដែក (ផ្លូវដែកមិនទាន់តំឡើង)
- កម្មន្តសាល ដែកថែបជាបំពង់ ឬទុយោមុខតំណ ឬមានមុខកាត់ប្រហោងតាមវិធីកិនក្តៅ ប៉ែនក្តៅ ហូតក្តៅ ឬដោយវិធីហូតត្រជាក់ ឬកិនត្រជាក់
- កម្មន្តសាល បំពង់ដែកថែបមានមុខតំណផ្សារបានមកពីការពត់រាងត្រជាក់ ឬក្តៅ និងផ្សារ ដើម្បីសម្រាប់ទុកផ្សារ ឬកែច្នៃបន្តទៀត ដោយវិធីហូតត្រជាក់ ឬកិនត្រជាក់ ឬផលិតតាម

ការពត់រាងក្តៅ ផ្សារ និងបង្រួម
- កម្មន្តសាល រ៉ាគរ បំពង់ដែកថែប ដូចជា៖
    - តំណងបំពង់ភ្ជាប់គ្នា មានផ្ទៃតើមរាប តំណមានមុខសឹកបញ្ចូលគ្នា
    - កែង ឬតេ តបំពង់ដោយផ្សារ
    - កែង ឬតេ តបំពង់មានខ្សែខ្ចៅ
    - រ៉ាគរសឹកតបំពង់ដោយផ្សារ

ថ្នាក់នេះមិនរាប់បញ្ចូល៖
- កម្មន្តសាល បំពង់ ទុយោ និងវត្ថុមានមុខកាត់ប្រហោង និងរ៉ាគរបំពង់ពីដែកស្លចាក់ពុម្ព (មើល ២៤៣១)
- កម្មន្តសាល បំពង់ ឬទុយោដែលគ្មានមុខតំណផ្សារដែកថែបដែលបានមកពីវិធីចាក់ពុម្ពបង្វិល (មើល ២៤៣១)
- កម្មន្តសាល រ៉ាគរបំពង់ ឬទុយោពីដែកថែបស្លចាក់ពុម្ព (មើល ២៤៣១)។

២៤២ កម្មន្តសាល លោហធាតុមូលដ្ឋានមានតម្លៃ និងលោហធាតុមិនមែនជាដែកដទៃទៀត

២៤២០ ២៤២០០ កម្មន្តសាល លោហធាតុមូលដ្ឋានមានតម្លៃ និងលោហធាតុមិនមែនជាដែកដទៃទៀត

ថ្នាក់នេះរាប់បញ្ចូល៖
- ផលិតកម្មលោហធាតុមូលដ្ឋានមានតម្លៃ៖
    - ផលិតកម្ម និងការចម្រាញ់លោហធាតុមានតម្លៃ ដែលមិនទាន់កែច្នៃ និងកែច្នៃរួច៖ មាស ប្រាក់ ប្លាទីន ។ល។ ពីរ៉ែ និងកម្ទេចកម្ទី
- ផលិតកម្មសំលោហៈមានតម្លៃ
- ផលិតកម្មផលិតផលពាក់កណ្តាលសម្រេចពីលោហធាតុមានតម្លៃ
- ផលិតកម្មប្រាក់កិនពាសលើលោហធាតុមូលដ្ឋាន
- ផលិតកម្មមាសកិនពាសលើលោហធាតុមូលដ្ឋាន ឬប្រាក់ ឬលោហធាតុមូលដ្ឋាន
- ផលិតកម្មនៃប្លាទីន និង លោហធាតុថ្នាក់ប្លាទីន កិនពាសលើមាស ប្រាក់ ឬលោហធាតុមូលដ្ឋាន
- ផលិតកម្មអាលុយមីញ៉ូមពីអាលុយមីញ៉ូមអុកស៊ីត
- ផលិតកម្មអាលុយមីញ៉ូមតាមវិធីចម្រាញ់បែបអេឡិកត្រូលីតពីសំណល់ ឬកម្ទេចកម្ទីអាលុយមីញ៉ូម
- ផលិតកម្មសំលោហៈអាលុយមីញ៉ូម
- ពាក់កណ្តាលកម្មន្តសាលអាលុយមីញ៉ូម
- ផលិតកម្មសំណ ស័ង្កសី និងសំណប៉ាហាំងពីរ៉ែ
- ផលិតកម្មនៃសំណ ស័ង្កសី និងសំណប៉ាហាំងតាមវិធីចម្រាញ់ អេឡិកត្រូលីតពីសំណល់ ឬ

ពីកម្ទេចកម្ទីសំណ ស័ង្កសី និងសំណប៉ាហាំង

- ផលិតកម្មសំលោហៈសំណ ស័ង្កសី សំណប៉ាហាំង
- ពាក់កណ្ដាលកម្មន្តសាលសំណ ស័ង្កសី និងសំណប៉ាហាំង
- ផលិតកម្មទង់ដែងពីរ៉ែ
- ផលិតកម្មទង់ដែង ដោយវិធីចម្រាញ់អេឡិកត្រូលីតពីសំណល់ និងកម្ទេចកម្ទី ទង់ដែង
- ផលិតកម្មសំលោហៈទង់ដែង
- កម្មន្តសាល សរសៃលួស ឬបន្ទះហ្វុយស៊ីប
- ពាក់កណ្ដាលកម្មន្តសាលទង់ដែង
- ផលិតកម្មក្រូម ម៉ង់កាណែស នីកែល ។ល។ ពីរ៉ែ ឬពីអុកស៊ីត
- ផលិតកម្មក្រូម ម៉ង់កាណែស នីកែល ។ល។ ដោយវិធីអេឡិកត្រូ-លីត និងពីការចម្រាញ់អាលុយមីណូទែរមិកនៃក្រូម ម៉ង់កាណែស នីកែល ។ល។ កាកសំណល់ និងកម្ទេចកម្ទី
- ផលិតកម្មសំលោហៈក្រូម ម៉ង់កាណែស នីកែល ។ល។
- ពាក់កណ្ដាលកម្មន្តសាលក្រូម ម៉ង់កាណែស នីកែល ។ល។
- ផលិតកម្មបន្ទះសរសៃចាក់ពីនីកែល (Mattes of nickel)
- ផលិតកម្មលោហធាតុអ៊ុយរ៉ាញ៉ូមពីអ៊ុយរ៉ាញ៉ូមអុកស៊ីត ឬរ៉ែដទៃទៀត
- ការរំលាយ និងចម្រាញ់អ៊ុយរ៉ាញ៉ូម

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរនូវ៖

- កម្មន្តសាល ខ្សែលួសលោហធាតុទាំងនេះដោយវិធីហូត
- ផលិតកម្មអាលុយមីញ៉ូមអុកស៊ីត (អាលុយមីណា)
- ផលិតកម្មសន្លឹកអាលុយមីញ៉ូមសម្រាប់ខ្ចប់
- កម្មន្តសាល ស្រទាប់ស្តើងអាលុយមីញ៉ូម (សំណប៉ាហាំង) ពីអាលុយមីញ៉ូម (សំណប៉ាហាំង) ជាធាតុផ្សំសំខាន់
- កម្មន្តសាល ស្រទាប់សន្លឹកស្តើងពីលោហធាតុមានតម្លៃ។

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ការស្លចាក់ពុម្ពលោហធាតុមិនមែនដែក (មើល ២៤៣២)
- កម្មន្តសាល គ្រឿងអលង្ការពីលោហធាតុមានតម្លៃ (មើល ៣២១១)។

២៤៣ ការស្លចាក់ពុម្ពលោហធាតុ

២៤៣១ ២៤៣១០ ការស្លចាក់ពុម្ពដែកនិងដែកថែប

ថ្នាក់នេះរាប់បញ្ចូលការស្លចាក់ពុម្ពដែក និងដែកថែប ដូចជា សកម្មភាពក្នុងឧស្សាហកម្មស្លចាក់ពុម្ពដែក និងដែកថែប។

ថ្នាក់នេះរាប់បញ្ចូល៖

- ការស្លចាក់ពុម្ពផលិតផលដែកពាក់កណ្តាលសម្រេច
- ការស្លចាក់ពុម្ពដែកហ្វុងប្រផេះ
- ការស្លចាក់ពុម្ពដែកហ្វុងក្រាហ្វីតស្វ៊ែរ៉ូអ៊ីត
- ការស្លចាក់ពុម្ពផលិតផលដែកហ្វុងដែលអាចផែបាន
- ការស្លចាក់ពុម្ពផលិតផលដែកថែបពាក់កណ្តាលសម្រេច
- ការស្លចាក់ពុម្ពផលិតផលដែកថែបហ្វុង
- កម្មន្តសាល បំពង់ ទុយោ ដែកថែបគ្មានមុខតំណតាមវិធីចាក់ពុម្ពបង្វិល
- កម្មន្តសាលរ៉ាគរបំពង់ ឬទុយោធ្វើពីដែកថែបហ្វុង។

២៤៣២ ២៤៣២០ ការស្លចាក់ពុម្ពលោហធាតុមិនមែនដែក

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ផលិតផលពាក់កណ្តាលសម្រេចពីអាលុយមីញ៉ូម ម៉ាញ៉េស្យូម ទីតានីញ៉ូម ស័ង្កសី ។ល។
- ការស្លចាក់ពុម្ព នៃលោហធាតុហ្វុងស្រាល
- ការស្លចាក់ពុម្ព នៃលោហធាតុហ្វុងធ្ងន់
- ការស្លចាក់ពុម្ព នៃលោហធាតុហ្វុងមានតម្លៃ
- ការស្លចាក់ពុម្ព សង្កត់នៃលោហធាតុហ្វុងមិនមែនដែក។

ជំពូក គ ៖ កម្មន្តសាល
ផ្នែក ២៥ ៖ កម្មន្តសាល ផលិតផលពីលោហធាតុកែច្នៃលើកលែងម៉ាស៊ីននិងបរិក្ខារ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
២៥១			**កម្មន្តសាល ផលិតផលគ្រោងពីលោហធាតុធុងអាងស្តុកទឹកនិងម៉ាស៊ីនបង្កើតចំហាយទឹក**
	២៥១១		កម្មន្តសាល ផលិតផលគ្រោងពីលោហធាតុ
		២៥១១១	កម្មន្តសាល ផលិតផលគ្រោងគ្រោងទ្វារគ្រោងបង្អួច
		២៥១១២	កម្មន្តសាល ស៊ុមរូបថតស៊ុមកញ្ចក់
		២៥១១៩	កម្មន្តសាល ផលិតផលគ្រឿងគ្រោងពីលោហធាតុដទៃទៀត

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល គ្រោង ឬគ្រោងឆ្អឹងទម្រលោហធាតុសម្រាប់សំណង់ និងគ្រឿងបំណែករបស់វា (ប៉ម បង្គោល គ្រោងដំបូល ឬគ្រោងទ្រទម្ងន់ដែលខ្វែងរួច ស្ពាន ។ល។)
- កម្មន្តសាល គ្រោងឆ្អឹងទម្រធ្វើពីលោហធាតុសម្រាប់ប្រើប្រាស់ក្នុងឧស្សាហកម្ម (គ្រោងទម្រឡស្លដែក បរិក្ខាលើកដាក់យួរ ។ល។)
- កម្មន្តសាល សំណង់ដែលបានសាងសង់ទុករួចភាគច្រើនធ្វើពីលោហធាតុ៖
    - ជម្រកតូចៗ គំរូសម្រាប់តាំងបង្ហាញ ។ល។
- កម្មន្តសាល ទ្វារ បង្អួច និងស៊ុម ក្បាំងបង្អួច ទ្វាររបងពីលោហធាតុ
- របាំងខណ្ឌចែកបន្ទប់ដែលធ្វើពីលោហធាតុ សម្រាប់ចាប់ភ្ជាប់ពីកម្រាលឡើងទៅលើ

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល គ្រឿងបំណែកនាវា ឬឡចំហាយថាមពល (មើល ២៥១៣)
- កម្មន្តសាល កំណល់ផ្លូវដែក (មើល ២៥៩៩)
- កម្មន្តសាល ផ្នែកផ្សេងៗនៃនាវា (មើល ៣០១១)។

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	២៥១២	២៥១២០	កម្មន្តសាល ធុងអាងនិងកុងតេណឺពីលោហធាតុ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល អាង ធុង និងកុងតេណឺពីលោហធាតុស្រដៀងគ្នា នៃប្រភេទដែលជាធម្មតាត្រូវបានដំឡើង និងចាប់ភ្ជាប់សម្រាប់ការស្តុក ឬប្រើប្រាស់ក្នុងផលិតកម្ម
- កម្មន្តសាល ធុងលោហធាតុសម្រាប់ផ្ទុកឧស្ម័នមានសម្ពាធ ឬ ឧស្ម័នរាវ
- កម្មន្តសាល ម៉ាស៊ីនកម្តៅក្នុងផ្ទះ និងរ៉ាដ្យាទ័រ

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល ធុងតូច ប៉ោត កំប៉ុង ធុងមានដៃយួរ ប្រអប់ ។ល។ ពីលោហធាតុ ដែលជាធម្មតាប្រើក្នុងការយួរ និងខ្ចប់ទំនិញ (មើល ២៥៩៤)
- កម្មន្តសាល កុងតេណឺសម្រាប់ដឹកជញ្ជូន (មើល ២៩២០)
- កម្មន្តសាល រថក្រោះ (យានយន្តយោធាពាសដែក) (មើល ៣០៤០)។

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	២៥១៣	២៥១៣០	កម្មន្តសាល ម៉ាស៊ីនបង្កើតចំហាយទឹក លើកលែង ម៉ាស៊ីនកម្តៅក្នុងផ្ទះ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ម៉ាស៊ីនបង្កើតចំហាយទឹក ឬចំហាយដទៃទៀត
- កម្មន្តសាល គ្រឿងបន្សំបន្ថែមសម្រាប់ប្រើជាមួយម៉ាស៊ីនបង្កើតចំហាយទឹក៖
    - o កុងដង់សាទ័រ (condensers) ប្រដាប់សន្សំសំចៃថាមពល (economisers) ប្រដាប់បង្កើនកម្តៅចំហាយទឹក (superheaters) ប្រដាប់ចាប់យកចំហាយទឹក (steam collectors) ប្រដាប់ផ្ទុកចំហាយទឹក (accumulators)
- កម្មន្តសាល រ៉េអាក់ទ័រនុយក្លេអ៊ែរ លើកលែងគ្រឿងបំបែក អ៊ីសូតូប
- កម្មន្តសាល គ្រឿងបំណែកនៃនាវាសមុទ្រ និងឡចំហាយថាមពល

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល ម៉ាស៊ីនកម្តៅក្នុងផ្ទះ និងរ៉ាដ្យាទ័រ (មើល ២៥១២)
- កម្មន្តសាល កុំប្លេ ឡចំហាយ-ទួរប៊ីន (boiler-turbine sets) (មើល ២៨១១)
- កម្មន្តសាល គ្រឿងបំបែកអ៊ីសូតូប (មើល ២៨២៩)។

២៥២　　　　　**កម្មន្តសាល អាវុធនិងគ្រាប់រំសេវ**

២៥២០　　២៥២០០　　កម្មន្តសាល អាវុធនិងគ្រាប់រំសេវ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល អាវុធធុនធ្ងន់ (កាំភ្លើងធំ កាំភ្លើងចល័ត ទម្របាញ់រ៉ុកកែត កាំភ្លើងបាញ់ក្នុងទឹកប្រឆាំងនាវា កាំភ្លើងយន្តធុនធ្ងន់)
- កម្មន្តសាល អាវុធធុនស្រាល (រ៉េវ៉ុលវែរ កាំភ្លើងខ្លី កាំភ្លើងយន្តធុនស្រាល)
- កម្មន្តសាល កាំភ្លើងប្រើខ្យល់ ឬឧស្ម័ន និងពីស្តុលឡេ
- កម្មន្តសាល គ្រាប់រំសេវធ្វើសង្គ្រាម ។

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរនូវ៖

- កម្មន្តសាល កាំភ្លើងប្រមាញ់ កីឡា ឬកាំភ្លើងខ្លីតូចសម្រាប់ការពារខ្លួន និងគ្រាប់រំសេវ
- កម្មន្តសាល គ្រឿងផ្ទុះ ដូចជា គ្រាប់បែក មីន និងគ្រាប់បែកប្រឆាំងនាវា ។

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល កឹបផ្ទុះ ឈ្នួនផ្ទុះ ឬគ្រាប់បែកផ្សែងពណ៌(មើល ២០២៩)
- កម្មន្តសាល កាំបិតស្នៀត ដាវ ចំពុះទុង ។ល។ (មើល ២៥៩៣)
- កម្មន្តសាល រថពាសដែកសម្រាប់ដឹកជញ្ជូនក្រដាសប្រាក់ ឬវត្ថុមានតម្លៃ (មើល ២៩១០)
- កម្មន្តសាល យានអវកាស (មើល ៣០៣០)
- កម្មន្តសាល រថក្រោះ និងរថចម្បាំងដទៃទៀត (មើល ៣០៤០)។

២៥៩　　　　　**កម្មន្តសាល ផលិតផលលោហធាតុកែច្នៃដទៃទៀត និងសកម្មភាពជាងដែក**

២៥៩១　　២៥៩១០　　ការដំ ការសង្កត់ការវាយកាត់និងការកិនលោហធាតុជារាង លោហកម្មម្សៅលោហធាតុ

ថ្នាក់នេះរាប់បញ្ចូល៖

- ការដំ ការសង្កត់ ការវាយកាក់ ការកិនជារាង
- ការស្លរំលាយម្សៅលោហធាតុ ៖ ផលិតកម្មវត្ថុធ្វើពីលោហធាតុដោយផ្ទាល់ពីម្សៅលោហធាតុ តាមវិធីប្រព្រឹត្តកម្មកម្ដៅ ឬប្រើសម្ពាធសង្កត់

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ការផលិតម្សៅលោហធាតុ (មើល ២៤១០ ២៤២០)។

២៥៩២ ២៥៩២០ ប្រព្រឹត្តិកម្ម និងការពាសលោហធាតុ ការក្រឡឹង

ថ្នាក់នេះរាប់បញ្ចូល៖

- ការជ្រលក់ អាណូដរូបនីយកម្មលោហធាតុ ។ល។
- ប្រព្រឹត្តកម្មកម្ដៅលោហធាតុ
- ក្រឡុកដោយរំញ័រ បាញ់ខ្សាច់ ក្រឡុកដោយរង្វិល ការសម្អាតលោហធាតុ
- ការដាក់ពណ៌ និងឆ្លាក់លោហធាតុ
- ការស្រោបលោហធាតុដោយអលោហធាតុ៖
    - ពាសដោយប្លាស្ទិក ដោយស្រទាប់អេណាមែលធ្វើឲ្យភ្លឺ ដោយស្រទាប់ទឹកថ្នាំគីមី ។ល។
- ការធ្វើឲ្យរឹង ការខាត់ដោយលោហធាតុឲ្យភ្លឺ (ខាត់ដោយប្រើក្រណាត់ទន់)
- ការចោះរន្ធ ក្រឡឹងវិល ក្រឡឹងចម្រុះ ធ្វើឲ្យសឹករិចរិល ឈូសឲ្យផ្ទៃរាបស្មើ រំលីង រុស ពង្រាប អារ ឆាប សំលៀង ប៉ូលា ផ្សារ តភ្ជាប់ ។ល។ នៃការងារជាងដែក
- ការកាត់ និងសរសេរលើលោហធាតុដោយកាំរស្មីឡាស៊ែរ

ថ្នាក់នេះមិនរាប់បញ្ចូល៖

- សកម្មភាព បោះដែកលើក្រចកជើងសេះ (មើល ០១៦២)
- កិន ពាសលោហធាតុមានតម្លៃលើលោហធាតុមូលដ្ឋាន ឬលោហធាតុផ្សេងទៀត (មើល ២៤២០)។

២៥៩៣ ២៥៩៣០ កម្មន្តសាល គ្រឿងកាំបិតឧបករណ៍ដៃនិងគ្រឿងដែកប្រើប្រាស់ទូទៅ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល គ្រឿងកាំបិតប្រើប្រាស់ក្នុងផ្ទះ ដូចជា កាំបិត សម ស្លាបព្រា ។ល។
- កម្មន្តសាល គ្រឿងកាំបិតដទៃទៀត៖
    - កាំបិតចិញ្ច្រាំសាច់ និងកាំបិតកាប់សាច់
    - ឡាមកោរ និងផ្លែឡាម
    - កន្ត្រៃ និងតុងជីកាត់សក់
- កម្មន្តសាល កាំបិត និងផ្លែកាំបិតកាត់សម្រាប់ប្រើក្នុងម៉ាស៊ីន ឬគ្រឿងមេកានិកផ្សេងៗ
- កម្មន្តសាល ឧបករណ៍ដៃ ដូចជា ដង្កាប់ ទួរណឺវីស ។ល។
- កម្មន្តសាល ឧបករណ៍ដៃកសិកម្មមិនប្រើថាមពល
- កម្មន្តសាល រណារ និងផ្លែរណារ រាប់បញ្ចូលទាំង ផ្លែរណារខ្សែ និងផ្លែរណារច្រវាក់
- កម្មន្តសាល ឧបករណ៍ដែលអាចដោះដូរបាន សម្រាប់ឧបករណ៍ដៃ ទោះជាប្រើ ឬមិនប្រើថាមពលក៏ដោយ ឬសម្រាប់ម៉ាស៊ីនឧបករណ៍៖ ផ្លែស្វាន ផ្លែពន្លាក ផ្លែម៉ាស៊ីនក្រឡឹង ។ល។
- កម្មន្តសាល ឧបករណ៍សង្កត់
- កម្មន្តសាល ឧបករណ៍ជាងដំដែក ៖ ចង្ក្រានដុតដែក ទ្រនាប់ដំដែក ។ល។
- កម្មន្តសាល ប្រអប់ពុម្ព និងពុម្ព (លើកលែង តែពុម្ពចាក់ដុំដែក)
- កម្មន្តសាល អង្កំ ដង្កៀប
- កម្មន្តសាល សោត្រដោក សោ កូនសោ ត្រចៀកទ្វារ និងវត្ថុស្រដៀងគ្នានឹងគ្រឿងដែកសម្រាប់សំណង់ សម្រាប់គ្រឿងសង្ហារិម និងសម្រាប់យានជំនិះ ។ល។
- កម្មន្តសាល កាំបិតស្នៀត ដាវ ចំពុះទុង ។ល។

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល គ្រឿងប្រើប្រាស់ដែលមានប្រហោង (ឆ្នាំង កំសៀវ ។ល។) គ្រឿងប្រើប្រាស់ក្នុងផ្ទះបាយ (ចានគោម ថាស ។ល។) ឬគ្រឿងប្រើប្រាស់មានរាងសំប៉ែត (ចានសំប៉ែត ចាន ទ្រនាប់ ។ល។) (មើល ២៥៩៩)
- កម្មន្តសាល ឧបករណ៍ដៃដោយថាមពល (មើល ២៨១៨)
- កម្មន្តសាល ពុម្ពចាក់ដុំលោហធាតុ (មើល ២៨២៣)
- កម្មន្តសាល គ្រឿងកាំបិតពីលោហធាតុមានតម្លៃ (មើល ៣២១១)។

២៥៩៤ ២៥៩៤០ កម្មន្តសាល ធុងមានដៃយួរ កំប៉ុងធុងធំនិងកុងតេណឺ ស្រដៀងគ្នាធ្វើពីលោហធាតុ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ធុងមានដៃយួរ កំប៉ុង ធុងធំ ប៉ោត ប្រអប់
- កម្មន្តសាល កំប៉ុងតូចៗ និងកំប៉ុងសម្រាប់ដាក់ផលិតផលម្ហូបអាហារ បំពង់ និងប្រអប់ដែលអាចបត់បាន
- កម្មន្តសាល គ្រឿងគន្លឹះទ្វារធ្វើពីលោហធាតុ។

២៥៩៥ ២៥៩៥០ កម្មន្តសាល ផលិតផលខ្សែច្រវ៉ាក់រ៉ឺស័រនិងរឺសមួល (លើកលែងខ្សែកាបធ្វើពីលោហធាតុ)

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល របស់របរធ្វើពីលួសសរសៃ ៖ លួសបន្លា លួសរបង លួសសំណាញ់ធំ លួសសំណាញ់តូច ក្រណាត់លោហធាតុ ។ល។
- កម្មន្តសាល ប៊ូឡុង ខ្ចៅ អេគ្រូ និងផលិតផលមានខ្សែខ្ចៅស្រដៀងគ្នា
- កម្មន្តសាល រ៉ឺស័រ (លើកលែង រ៉ឺស័រនាឡិកាដៃ)៖
    - ចន្ទាស រ៉ឺស័រមានរាងជាខ្សែខ្ចៅ រ៉ឺស័រជាដងរមួល
    - សន្លឹកចន្ទាស
- កម្មន្តសាល ច្រវ៉ាក់ លើកលែងតែច្រវ៉ាក់អូសម៉ាស៊ីន។

២៥៩៩ កម្មន្តសាល ផលិតផលពីលោហធាតុកែច្នៃ ដទៃទៀតដែលពុំបានរាប់បញ្ចូល

២៥៩៩១ កម្មន្តសាល ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ

២៥៩៩៩ កម្មន្តសាល ផលិតផលពីលោហធាតុកែច្នៃ ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ខ្សែកាបលោហធាតុ បន្ទះសំណាញ់លោហធាតុ និងរបស់របរប្រហាក់ប្រហែលគ្នា
- កម្មន្តសាល ខ្សែកាបលោហធាតុគ្មានអ៊ីសូឡង់ ឬមានអ៊ីសូឡង់ ប៉ុន្តែមិនអាចប្រើប្រាស់សម្រាប់ចម្លងចរន្តអគ្គិសនី
- កម្មន្តសាល ដែកគោល និងកន្លាស់
- កម្មន្តសាល ដែកគោលមីន កាក់ទ្រនាប់ក្បាលខ្ចៅ និងផលិតផល ស្រដៀងគ្នាដែលគ្មានខ្សែខ្ចៅ
- កម្មន្តសាល ផលិតផលពីម៉ាស៊ីនក្រឡឹងស្វយប្រវត្តិ

- កម្មន្តសាល របស់របរប្រើក្នុងផ្ទះពីលោហធាតុ៖
  - គ្រឿងប្រើប្រាស់មានរាងសំប៉ែត ៖ ចានទាប ចានទ្រនាប់ ។ល។
  - គ្រឿងប្រើប្រាស់ដែលមានរាងប្រហោង ៖ ឆ្នាំង កំសៀវ ។ល។
  - គ្រឿងប្រើប្រាស់សម្រាប់បរិភោគ ៖ ចានគោម ថាស ។ល។
  - ខ្ទះឆាក្រឡុម ខ្ទះឆាសំប៉ែត និងគ្រឿងសម្ភារៈប្រើប្រាស់សម្រាប់តុបរិភោគ និងឧបករណ៍ផ្ទះបាយដទៃទៀតដែលមិនប្រើអគ្គិសនី
  - ប្រដាប់ប្រដារតូចៗ ប្រើប្រាស់ក្នុងផ្ទះបាយប្រើដោយដៃ និងគ្រឿងបន្សំ
  - ទ្រនាប់ដុសលាងឆ្នាំពីលោហធាតុ
- កម្មន្តសាល អាងងូតទឹក អាងលុបមុខ អាងលាងចាន/លាងដៃ និងរបស់របរស្រដៀងគ្នា
- កម្មន្តសាល ផលិតផលពីលោហធាតុប្រើក្នុងការិយាល័យ លើកលែងគ្រឿងសង្ហារិម
- កម្មន្តសាល ទូដែក ប្រអប់សុវត្ថិភាព ទ្វារការពារគ្រាប់កាំភ្លើង ។ល។
- កម្មន្តសាល របស់របរពីលោហធាតុដទៃទៀត៖
  - ស្លាបចក្រកប៉ាល់ និងផ្លែស្លាបចក្រ
  - យុថ្កា
  - កណ្តឹង
  - កំណល់ផ្លូវដែក
  - ទំពក់មានគន្លឹះបិទ-បើក ទំពក់ក្បាលខ្សែក្រវ៉ាត់ ទំពក់ស្នូចឥវ៉ាន់
- កម្មន្តសាល ស្បោងធ្វើពីលោហធាតុស្តើង
- កម្មន្តសាល មេដែកធក់
- កម្មន្តសាល បំពង់ទឹកក្តៅពីលោហធាតុ និងដប
- កម្មន្តសាល ផ្លាកសញ្ញាពីលោហធាតុ (មិនប្រើអគ្គិសនី)
- កម្មន្តសាល ផ្លាកភ្ជាប់សម្លៀកបំពាក់ និងគ្រឿងសម្គាល់ខ្លួនយោធាធ្វើពីលោហធាតុ
- កម្មន្តសាល គ្រឿងអ៊ុតសក់ ដងធ័ត្រ និងឆ្អឹងធ័ត្រ ក្រាសសិតសក់ ពីលោហធាតុ

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាល មេដែកធក់សេរាមិក និងពីរ៉ែដែលមានជាតិមេដែកច្រើន (មើល ២៣៩៣)
- កម្មន្តសាល ធុង និងអាងស្តុកទឹក (មើល ២៥១២)
- កម្មន្តសាល ដាវ ចំពុះទុង (មើល ២៥៩៣)
- កម្មន្តសាល រ៉ឺស័រសម្រាប់នាឡិកាប៉ោល និងនាឡិកាដៃ (មើល ២៦៥២)
- កម្មន្តសាល ខ្សែលួស និងខ្សែកាបសម្រាប់ចម្លងចរន្តអគ្គិសនី (មើល ២៧៣២)
- កម្មន្តសាល ច្រវ៉ាក់អូសម៉ាស៊ីន (មើល ២៨១៤)
- កម្មន្តសាល រទេះដាក់ឥវ៉ាន់ក្នុងហាងលក់ទំនិញ (មើល ៣០៩៩)
- កម្មន្តសាល គ្រឿងសង្ហារិមធ្វើពីលោហធាតុ (មើល ៣១០០)
- កម្មន្តសាល សម្ភារៈកីឡា (មើល ៣២៣០)
- កម្មន្តសាល ហ្គេម និងឧបករណ៍ក្មេងលេង (មើល ៣២៤០)។

ជំពូក គ ៖ កម្មន្តសាល
ផ្នែក ២៦ ៖ កម្មន្តសាល ផលិតផលកុំព្យូទ័រអេឡិចត្រូនិកនិងអុបទិក

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
២៦១			**កម្មន្តសាល គ្រឿងបង្គុំអេឡិចត្រូនិក**
	២៦១០		កម្មន្តសាល សន្ទះ និងបំពង់ អេឡិចត្រូនិក
		២៦១០១	កម្មន្តសាល សន្ទះ និងបំពង់ អេឡិចត្រូនិក

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល អំពូលអេឡិចត្រុង
- កម្មន្តសាល គ្រឿងភ្ជាប់អេឡិចត្រូនិក
- ក្រុមនេះក៏រាប់បញ្ចូលផងដែរនូវ ៖
- កម្មន្តសាល ខ្សែព្រីនធើ ខ្សែម៉ូនីទ័រ ខ្សែយូអេសប៊ីខ្សែតភ្ជាប់គ្នា ។ល។

២៦១០២ កម្មន្តសាល សឺមីកុងឌុចទ័រ និងគ្រឿងបង្គុំអេឡិចត្រូនិកដទៃទៀត

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល កាប៉ាស៊ីទ័រអេឡិចត្រូនិក
- កម្មន្តសាល រ៉េស៊ីស្ទរអេឡិចត្រូនិក
- កម្មន្តសាល មីក្រូប្រសេសស័រ
- កម្មន្តសាល ប៉ែរព្រីនធីតសៀគ្វីប៊ិត
- កម្មន្តសាល សៀគ្វីបង្រួម (អាណាឡូក ឌីជីថល ឬហាយប្រ៊ីត)
- កម្មន្តសាល ឌីយ៉ូតត្រង់ស៊ីស្ទ័រ និងគ្រឿងភ្ជាប់ពាក់ព័ន្ធផ្សេងទៀត
- កម្មន្តសាល អាំងឌុចទ័រ (ដូចជា បូប៊ីន ត្រង់ស្វូ) ប្រភេទគ្រឿងបង្គុំ អេឡិចត្រូនិក
- កម្មន្តសាល គ្រីស្តាល់អេឡិចត្រូនិក និងគ្រឿងដំឡើងពីគ្រីស្តាល់
- កម្មន្តសាល សូឡេណូអ៊ីត កុងតាក់ និងឧបករណ៍បំប្លែងសម្រាប់គ្រឿង អេឡិចត្រូនិក
- កម្មន្តសាល គ្រាប់ឡុកឡាក់ ឬវ៉ាហ្វើ សឺមីកុងឌុចទ័រ ពាក់កណ្តាលសម្រេច ឬសម្រេច
- កម្មន្តសាល កាតអ៊ីនធើហ្វេស (ឧ. សំឡេង រូបភាព បណ្តាញឧបករណ៍ល្បឿន ម៉ូឌឹម)
- កម្មន្តសាល គ្រឿងបង្គុំបញ្ចេញរូបភាព (ប្លាស្មា ប៉ូលីមែរ អិលស៊ីឌី)
- កម្មន្តសាល ឌីយ៉ូតបញ្ចេញពន្លឺ (LED)
- ការផ្ទុកគ្រឿងបង្គុំនៅក្នុងបន្ទះសៀគ្វីបោះពុម្ព (PCB)។

២៦២ កម្មន្តសាល កុំព្យូទ័រនិងគ្រឿងតភ្ជាប់ជាមួយកុំព្យូទ័រ

២៦២០ កម្មន្តសាល និង/ឬ តំឡើងកុំព្យូទ័រអេឡិចត្រូនិក

២៦២០១ កម្មន្តសាល និង/ឬ តំឡើងកុំព្យូទ័រអេឡិចត្រូនិក

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល កុំព្យូទ័រខ្នាតធំ
- កម្មន្តសាល កុំព្យូទ័រចល័ត
- កម្មន្តសាល គ្រោងសំខាន់របស់កុំព្យូទ័រ
- កម្មន្តសាល កុំព្យូទ័រយួរដៃ (ឧ. PDA)
- កម្មន្តសាល សើហ្វវើ ។

២៦២០២ កម្មន្តសាល គ្រឿងបន្លាស់កុំព្យូទ័រ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ឌីសជ្រាយម៉ាញ៉េទិក ហ្លាសជ្រាយ និងគ្រឿងផ្ទុកច្រើនមុខដទៃទៀត
- កម្មន្តសាល ឌីសជ្រាយអុបទិក (ឧ. CD-RW, CD-ROM, DVD-ROM, DVDRW)
- កម្មន្តសាល ព្រីនធើ
- កម្មន្តសាល ម៉ូនីទ័រ
- កម្មន្តសាល បន្ទះវាយអក្សរ (ឃីប៊ត)
- កម្មន្តសាល កណ្តុរ (Mouse) ដៃកាន់បញ្ជាហ្គេម គ្រឿងបន្ទាប់បន្សំឃ្លីបញ្ជា
- កម្មន្តសាល កន្លែងបំពាក់កុំព្យូទ័រក្នុងគោលបំណងពិសេស
- កម្មន្តសាល ម៉ាស៊ីនស្កែន រាប់បញ្ចូលទាំង ម៉ាស៊ីនស្កែនសញ្ញាឆ្នូត
- កម្មន្តសាល ម៉ាស៊ីនអានកាត
- កម្មន្តសាល មួកវ៉ែនតាបង្ហាញពីរូបភាពពិត
- កម្មន្តសាល ឧបករណ៍បញ្ចាំងតនឹងកុំព្យូទ័រ (video beamers)
- ក្រុមនេះក៏រាប់បញ្ចូលផងដែរនូវ ៖
- កម្មន្តសាល កន្លែងបំពាក់កុំព្យូទ័រ ដូចជា ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ កុំព្យូទ័រគណនាសាច់ប្រាក់ ដែលមិនដំណើរការដោយមេកានិក
- កម្មន្តសាល ឧបករណ៍មួយដែលមានមុខងារច្រើនសម្រាប់ប្រើក្នុងការិយាល័យ ដូចជា ម៉ាស៊ីនហ្វាក់ ស្កែន និងថតចម្លង រួមបញ្ចូលគ្នា។

២៦៣ កម្មន្តសាល បរិក្ខារទូរគមនាគមន៍

២៦៣១ កម្មន្តសាល បរិក្ខារទូរគមនាគមន៍

២៦៣១០ កម្មន្តសាល បរិក្ខារទូរគមនាគមន៍ (លើកលែងបរិក្ខារទូរគមនាគមន៍ឥតខ្សែ)

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល បរិក្ខារទូរស័ព្ទ និងម៉ាស៊ីនហ្វាក់ រាប់បញ្ចូល ម៉ាស៊ីនឆ្លើយតបស្វយប្រវត្តិលើទូរស័ព្ទ
- កម្មន្តសាល ទូរស័ព្ទឥតខ្សែ
- កម្មន្តសាល បរិក្ខារដោះដូរជាលក្ខណៈឯកជន (ទូរសព្ទប្រើជាឯកជនក្នុងក្រុមហ៊ុន)
- កម្មន្តសាល បរិក្ខារទូរគមនាគមន៍ផ្ទុកទិន្នន័យ ដូចជា ល្បែងសង់ស្ពានដែលប្រើប្រព័ន្ធកុំព្យូទ័រ(bridges) ឧបករណ៍បញ្ជូនទិន្នន័យនៅក្នុងប្រព័ន្ធកុំព្យូទ័រ(routers) និងឧបករណ៍ភ្ជាប់ប្រព័ន្ធកុំព្យូទ័រមួយទៀតដែលមានមុខងារផ្សេងគ្នា(gateways)
- កម្មន្តសាល ម៉ូដឹម និងបរិក្ខារបញ្ជូនទិន្នន័យ។

២៦៣២ ២៦៣២០ កម្មន្តសាល បរិក្ខារទូរគមនាគមន៍ឥតខ្សែ

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល ឧបករណ៍ទទួលសារខ្នាតតូចៗ
- កម្មន្តសាលទូរសព្ទដៃ
- កម្មន្តសាល បរិក្ខារទូគមនាគមន៍ចល័ត។

២៦៣៩ ២៦៣៩០ កម្មន្តសាល បរិក្ខារទូរគមនាគមន៍ ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាល បរិក្ខារតភ្ជាប់នៃមណ្ឌលកណ្តាល
- កម្មន្តសាល អង់តែនបញ្ជូន និងអន់តែនទទួលទិន្នន័យ
- កម្មន្តសាល បរិក្ខារទូរទស្សន៍ខ្សែកាប
- កម្មន្តសាល ស្ទូឌីយោវិទ្យុ និងទូរទស្សន៍ និងបរិក្ខារផ្សាយវិទ្យុ រាប់បញ្ចូលទាំងកាមេរ៉ាទូរទស្សន៍
- កម្មន្តសាល ប្រព័ន្ធប្រកាសអាសន្នពេលមានមនុស្សឆ្លងកាត់ និងមានអគ្គិភ័យតាមការបញ្ជូនសញ្ញាទៅស្ថានីយត្រួតពិនិត្យ
- កម្មន្តសាល ឧបករណ៍បញ្ជូនទិន្នន័យតាមវិទ្យុ និងទូរទស្សន៍
- កម្មន្តសាល ឧបករណ៍បញ្ជូនទិន្នន័យតាមកាំរស្មី (ឧបករណ៍បញ្ជាពីចម្ងាយ)។

២៦៤　　　　　　កម្មន្តសាល គ្រឿងប្រើប្រាស់អេឡិចត្រូនិក

- កម្មន្តសាលគ្រឿងសង្ហារិមសម្រាប់ព្រះវិហារសាសនាសាលារៀន និង ភោជនីយដ្ឋាន
- កម្មន្តសាលគ្រឿងសង្ហារិមការិយាល័យ
- កម្មន្តសាលគ្រឿងសង្ហារិមផ្ទះបាយ
- កម្មន្តសាលគ្រឿងសង្ហារិមសម្រាប់បន្ទប់គេងបន្ទប់ទទួលភ្ញៀវនិងសួនច្បារ ។ល។
- កម្មន្តសាលឃ្លប់ទូសម្រាប់ម៉ាស៊ីនដេរទូរទស្សន៍ ។ល។
- កម្មន្តសាលកៅអីវែងសម្រាប់បន្ទប់ពិសោធន៍ កៅអីមូលគ្មានបង្អែក និងកៅអីក្នុងបន្ទប់ពិសោធន៍ (ឧ. ទូនិងតុ)

ថ្នាក់នេះរួមបញ្ចូល៖

- ការងារសម្រេច ដូចជា៖ ការដាក់កម្រាលកៅអីមានបង្អែក និងកៅអី
- កាងារសម្រេចគ្រឿងសង្ហារិមដូចជា៖បាញ់ថ្នាំលាប់ថ្នាំប៉ូលានិងដាក់កម្រាល
- កម្មន្តសាលគ្រែមិនទាន់ដាក់ពូក
- កម្មន្តសាលពូក៖
  - ពូករ៉ឺស័រឬពូកញាត់ (ក្រណាត់ ឬគ) ឬពូកញាត់ខាងក្នុងនូវវត្ថុធាតុ ផ្សេងៗ
  - ពូកប្លាស្ទិកកៅស៊ូ
- រទេះរុញសម្រាប់តុបតែងភោជនីយដ្ឋាន ដូចជា៖រទេះដាក់បង្អែមរទេះដាក់ម្ហូបអាហារ

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលខ្នើយកើយ ពូកអង្គុយខ្នើយរចនាសម្រាប់តុបតែងកម្រាលដេកមានច្រើនស្រទាប់និងភួយ (មើល ១៣៩២)
- កម្មន្តសាលពួកកៅស៊ូបញ្ចូលខ្យល់ (មើល ២២១៩)
- កម្មន្តសាលគ្រឿងសង្ហារិមធ្វើពីសេរ៉ាមិកបេតុងនិងថ្ម (មើល ២៣៩៣, ២៣៩៥,និង ២៣៩៦)
- កម្មន្តសាលគ្រឿងចាប់ចង្កៀងបំភ្លឺ ឬចង្កៀង (មើល ២៧៤០)
- កម្មន្តសាលក្តារខៀន (មើល ២៨១៧)
- កម្មន្តសាលកៅអីរថយន្តកៅអីរថភ្លើងនិងកៅអីយន្តហោះ
- (មើល ២៩៣០, ៣០២០, និង ៣០៣០)
- ការចាប់ភ្ជាប់គ្រឿងសង្ហារិម ការដំឡើងជញ្ជាំងខណ្ឌនិងការដំឡើងគ្រឿងសង្ហារិមជាបរិក្ខារមន្ទីពិសោធន៍ (មើល ៤៣៣០)។

ជំពូក គ ៖ កម្មន្តសាល
ផ្នែក ៣២ ៖ កម្មន្តសាលផ្សេងៗទៀត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៣២១			**កម្មន្តសាលវតនភណ្ឌគ្រឿងអលង្ការនិងរបស់របរពាក់ព័ន្ធ**
	៣២១១		កម្មន្តសាលវតនភណ្ឌនិងរបស់របរពាក់ព័ន្ធដែលធ្វើពីវត្ថុធាតុមានតម្លៃនិងពាក់កណ្តាលមានតម្លៃ
		៣២១១១	កម្មន្តសាលវតនភណ្ឌ និងរបស់របរពាក់ព័ន្ធដែលធ្វើពីមាស
		៣២១១២	កម្មន្តសាលវតនភណ្ឌ និងរបស់របរពាក់ព័ន្ធដែលធ្វើពីប្រាក់
		៣២១១៣	កម្មន្តសាលវតនភណ្ឌ និងរបស់របរពាក់ព័ន្ធដែលធ្វើពីថ្ម
		៣២១១៩	កម្មន្តសាលវតនភណ្ឌដទៃទៀត និងរបស់របរពាក់ព័ន្ធដែលធ្វើពីវត្ថុធាតុមានតម្លៃ និងពាក់កណ្តាលមានតម្លៃដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូល៖

- ផលិតកម្មកែច្នៃគុជ
- ផលិតកម្មត្បូងថ្មមានតម្លៃនិងពាក់កណ្តាលមានតម្លៃក្នុងសភាពកែច្នៃ ដោយរួមមានការកែច្នៃថ្មមានគុណភាពជាឧស្សាហកម្ម និងសំយោគ ឬការកែច្នៃឡើងវិញនូវត្បូងថ្មមានតម្លៃ និងពាក់កណ្តាលមានតម្លៃ
- ការកែច្នៃពេជ្រ
- កម្មន្តសាលវតនភ័ណនៃលោហធាតុមានតម្លៃឬលោហធាតុមូលដ្ឋានស្រោបដោយលោហធាតុមានតម្លៃ ឬត្បូងថ្មមានតម្លៃឬពាក់កណ្តាលមានតម្លៃឬផ្សំឡើងដោយលោហធាតុមានតម្លៃជាមួយនឹងត្បូងថ្មមានតម្លៃ ឬពាក់កណ្តាលមានតម្លៃ ឬវត្ថុធាតុផ្សេងៗ
- កម្មន្តសាលជាងទងនៃលោហធាតុមានតម្លៃ ឬលោហធាតុមូលដ្ឋានស្រោបជាមួយនឹងលោហធាតុមានតម្លៃ ដូចជា៖
    - គ្រឿងកែវពែងគ្រឿងចានគ្រឿងឆ្នាំងសម្ភារៈបន្ទប់ទឹកសម្ភារៈការិយាល័យ ឬសម្ភារៈសាសនា។ល។
- កម្មន្តសាលប្រភេទលោហធាតុមានតម្លៃសម្រាប់ប្រើប្រាស់ក្នុងមន្ទីរពិសោធន៍ ឬក្នុងបច្ចេកទេស (លើកលែងតែឧបករណ៍ និងគ្រឿងបំណែក) ដូចជា៖ឆ្នាំងស្លចាក់ពុម្ពលោហធាតុ ខ្នុរក្លរអាណូតស្រោបលោហធាតុ ។ល។
- កម្មន្តសាលខ្សែនាឡិកាដៃកងពាក់នៅដៃខ្សែពាក់ព្យួរនាឡិកាប្រអប់បារីពីលោហធាតុមានតម្លៃ
- កម្មន្តសាលកាក់ រួមទាំងប្រាក់កាក់ រូបិយបណ្ណ ទោះជាធ្វើពីលោហធាតុ មានឬគ្មានតម្លៃ

ថ្នាក់នេះរួមបញ្ចូលផងដែរនូវ៖

- ការឆ្លាក់ផលិតផលប្រើផ្ទាល់ខ្លួនពីលោហធាតុដែលមាន និងគ្មានតម្លៃ

ថ្នាក់នេះមិនរាប់បញ្ចូលនូវ៖

- កម្មន្តសាលខ្សែនាឡិកាដែលមិនមែនលោហធាតុ (ក្រណាត់ ស្បែកប្លាស្ទិក ។ល។) (មើល ១៥១២)

- កម្មន្តសាលលោហធាតុមូលដ្ឋានពាសជាមួយលោហធាតុមានតម្លៃ (លើកលែងតែគ្រឿងអលង្ការកាឡៃ) (មើលផ្នែក ២៥)
- កម្មន្តសាលតួនាឡិកា (មើល ២៦៥២)
- កម្មន្តសាលខ្សែនាឡិកាពីលោហធាតុ (គ្មានតម្លៃ) (មើល ៣២១២)
- កម្មន្តសាលគ្រឿងអលង្ការកាឡៃ(មើល ៣២១២)។

៣២១២ ៣២១២០ កម្មន្តសាលគ្រឿងអលង្ការកាឡៃនិងអលង្ការស្រដៀងគ្នា

ថ្នាក់នេះរួមបញ្ចូល៖

- កម្មន្តសាលគ្រឿងអលង្ការតុបតែងសិប្បនិមិត្ត ឬកាឡៃ៖
  - ចិញ្ចៀន ខ្សែដៃ ខ្សែក និងគ្រឿងអលង្ការស្រដៀងគ្នា ដែលធ្វើពីលោហធាតុមូលដ្ឋានពាសជាមួយលោហធាតុមានតម្លៃ
  - គ្រឿងអលង្ការបំពាក់ដោយត្បូងថ្មកាឡៃ ដូចជា៖ ថ្មត្បូងកាឡៃ ពេជ្រកាឡៃ និងវត្ថុស្រដៀងគ្នា
- កម្មន្តសាលខ្សែនាឡិកាដៃពីលោហធាតុ (លើកលែងតែពីលោហធាតុមានតម្លៃ)

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលគ្រឿងអលង្ការពីលោហធាតុមានតម្លៃ ឬស្រោបជាមួយលោហធាតុមានតម្លៃ (មើល ៣២១១)
- កម្មន្តសាលគ្រឿងអលង្ការបំពាក់ដោយត្បូងថ្មពិតប្រាកដ (មើល ៣២១១)
- កម្មន្តសាលខ្សែនាឡិកាពីលោហធាតុមានតម្លៃ (មើល ៣២១១)។

៣២២ កម្មន្តសាលឧបករណ៍តន្ត្រី

៣២២០ កម្មន្តសាលឧបករណ៍តន្ត្រី

៣២២០១ កម្មន្តសាលឧបករណ៍តន្ត្រីប្រពៃណី

៣២២០៩ កម្មន្តសាលឧបករណ៍តន្ត្រី ដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូលនូវ៖

- កម្មន្តសាលឧបករណ៍តន្ត្រីប្រើខ្សែ
- កម្មន្តសាលឧបករណ៍តន្ត្រីប្រើខ្សែមានក្តាចុច(keyboard) សម្រាប់ចុចរួមទាំងព្យ៉ាណូស្វ័យប្រវត្តិ
- កម្មន្តសាលអ៊ិកប្រើបំពង់ ដោយមានបន្ទះចុចរួមទាំងអកជាន់ (harmoniums) និងឧបករណ៍តន្ត្រីមានបន្ទះចុចស្រដៀងគ្នា និងមានអណ្តាតពីលោហធាតុ
- កម្មន្តសាលអាក់គកដេអុងនិងឧបករណ៍តន្ត្រីស្រដៀង រួមទាំងអ៊ិកផ្លុំ
- កម្មន្តសាលឧបករណ៍តន្ត្រីប្រើខ្យល់
- កម្មន្តសាលឧបករណ៍តន្ត្រីដោយគោះឬដំ
- កម្មន្តសាលឧបករណ៍តន្ត្រីដែលបញ្ចេញសំឡេងដោយអគ្គិសនី
- កម្មន្តសាលប្រអប់ភ្លេង អ៊ិកសម្រាប់លេងកម្សាន្ត ឧបករណ៍តន្ត្រីដែលបញ្ចេញសំឡេង

ដោយសារចំហាយ ទឹកឬខ្យល់បណ្តែន ។ល។

- កម្មន្តសាលគ្រឿងបន្ទាប់បន្សំឧបករណ៍តន្ត្រីនិងគ្រឿងបន្លាស់ ដូចជា៖
    - ឧបករណ៍កំណត់ចង្វាក់ភ្លេងចំពាមបញ្ចេញសូរខ្ញុំបំពង់បន្លឺសំឡេងកាត ថាស និងបំពង់រ៉ូឡូសម្រាប់ឧបករណ៍ដើរដោយមេកានិក ដោយស្វ័យប្រវត្ត ។ល។

ថ្នាក់នេះក៏រាប់បញ្ចូលផងដែរនូវ៖

- កម្មន្តសាលកញ្ចែស្នែងផ្លុំនិងឧបករណ៍ឲ្យសញ្ញាបញ្ចេញសំឡេងដោយផ្លុំ

ថ្នាក់នេះ មិនរាប់បញ្ចូលនូវ៖

- ផលិតកម្ម និងថតសំឡេងឡើងវិញនិងកាសែតថាសវីដេអូ (មើល ១៨២០)
- កម្មន្តសាលមីក្រូហ្វូនអំភ្លីធុងបាសកាសស្តាប់និងគ្រឿងបន្សំស្រដៀងគ្នាដទៃទៀត (មើល ២៦៤៩)
- កម្មន្តសាលម៉ាស៊ីនចាក់ថាសម៉ាញ៉េនិងឧបករណ៍ស្រដៀងគ្នាដទៃទៀត
- (មើល ២៦៤២)
- កម្មន្តសាលឧបករណ៍ភ្លេងសម្រាប់ក្មេងលេង (មើល ៣២៤០)
- ការរៀបអិកឡើងវិញនិងឧបករណ៍តន្ត្រីបូរាណដទៃទៀត (មើល ៣៣១៩)
- ការថតផ្សាយឡើងវិញជាកាសែតឬថាសសំឡេងនិងវីដេអូ (មើល ៥៩២០)
- ការរឹតខ្នង់ព្យាណូ (មើល ៩៥២៩)។

៣២៣ កម្មន្តសាលសម្ភារៈកីឡា

៣២៣០ ៣២៣០០ កម្មន្តសាលសម្ភារៈកីឡា

ក្នុងថ្នាក់នេះរួមមានកម្មន្តសាលសម្ភារៈកីឡានិងអត្តពលកម្ម (លើកលែងតែសម្លៀកបំពាក់ និងស្បែកជើងកីឡា)។

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលរបស់របរ និងបរិក្ខារសម្រាប់កីឡាលេងនៅវាល និងក្នុងរោងកីឡាពីគ្រប់វត្ថុធាតុ ដូចជា៖
    - កូនបាល់រឹង ទន់និងមានខ្យល់
    - រ៉ាក់កែតដំបងនិងរ៉ាក់កែតសំណាញ់
    - ស្គីប្រដាប់រឹតនិងជើងទ្រស្គី
    - ស្បែកជើងស្គី
    - បន្ទះក្តារមានក្តោងនិងបន្ទះក្តារជិះលើទឹក
    - សម្ភារៈកីឡានេសាទរួមទាំងកន្ត្រកសំណាញ់មានដងសម្រាប់ដាក់ត្រី
    - សម្ភារៈកីឡាប្រមាញ់កីឡាឡើងភ្នំ។ល។
- ស្រោមដៃនិងមួកកីឡាធ្វើពីស្បែក
- ស្បែកជើងរអិលលើទឹកកកស្បែកជើងមានកង់ ។ល។
- ធ្នូ និងស្នា

- បរិក្ខារសម្រាប់មជ្ឈមណ្ឌលកីឡាកាយសម្ព័ន្ធកីឡាកាយវប្បកម្ម ឬកីឡាអត្តពលកម្ម

ថ្នាក់នេះមិនរាប់បញ្ចូល ៖

- កម្មន្តសាលទូកក្តោង(មើល១៣៩២)
- កម្មន្តសាលសម្លៀកបំពាក់កីឡា (មើល១៤១១)
- កម្មន្តសាលកែបសេះនិងបង្ហៀរសេះ (មើល ១៥១២)
- កម្មន្តសាលខ្សែតីនិងរំពាត់វាយសេះ(មើល ១៥១២)
- កម្មន្តសាលស្បែកជើងកីឡា (មើល ១៥២០)
- កម្មន្តសាលអាវុធនិងគ្រាប់រំសេវសម្រាប់កីឡា (មើល ២៥២០)
- កម្មន្តសាលដែកលើកទម្ងន់ (មើល២៥៩៩)

- កម្មន្តសាលបរិក្ខាសម្រាប់កីឡាបូលីងស្វ័យប្រវត្តិ (មើល ២៨២៩)
- កម្មន្តសាលយានសម្រាប់កីឡាក្រៅពីគៀរអ៊ិល និងស្រដៀងគ្នា (មើលផ្នែក ២៩ និង ៣០)
- កម្មន្តសាលទូក (មើល៣០១២)
- កម្មន្តសាលតុប៊ីយ៉ា (មើល ៣២៤០)
- កម្មន្តសាលឆ្នុកចុកត្រចៀកនិងសម្រាប់ការពារសំឡេង (ឧ. សម្រាប់ការហែលទឹកនិងការពារសម្លេង) (មើល ៣២៩០)។

៣២៤ កម្មន្តសាលហ្គេមនិងប្រដាប់ប្រដាក្មេងលេខ

៣២៤០ ៣២៤០០ កម្មន្តសាលហ្គេមនិងប្រដាប់ប្រដាក្មេងលេង

ក្នុងថ្នាក់នេះរួមមានកម្មន្តសាលតុក្កតាប្រដាប់ប្រដាក្មេងលេងនិងហ្គេម (រួមទាំងហ្គេមអេឡិចត្រូនិក) គំរូម៉ូដែលបំព្រួញទំហំពិត និងយានជំនិះក្មេង (លើកលែងតែកង់ និងត្រីចក្រយានធ្វើពីលោហធាតុ) ។

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលតុក្កតានិងសម្លៀកបំពាក់តុក្កតា គ្រឿងបំណែក និងគ្រឿងបន្សំ
- កម្មន្តសាលរូបសំណាក់តូចៗមានចលនា
- កម្មន្តសាលរូបសំណាក់សត្វសម្រាប់ក្មេងលេង
- កម្មន្តសាលឧបករណ៍ភ្លេងក្មេងលេង
- កម្មន្តសាលសន្លឹកបៀរ
- កម្មន្តសាលបន្ទះក្តារហ្គេម និងហ្គេមស្រដៀងគ្នា
- កម្មន្តសាលហ្គេមអេឡិចត្រូនិក ដូចជា៖ អុក ។ល។
- កម្មន្តសាលគំរូដែលបំព្រួញទំហំពិត និងគំរូម៉ូដែលកម្សាន្តស្រដៀងគ្នារថភ្លើងអគ្គិសនីនិងកំប្លេសំណង់ផ្សេងៗ ។ល។

- កម្មន្តសាលហ្គេមដោយប្រើកាក់បីយ៉ាគុពិសេសសម្រាប់ល្បែងកាស៊ីណូ។ល។
- កម្មន្តសាលគ្រឿងសម្រាប់កម្សាន្តសប្បាយតុហ្គេមឬល្បែងលេងកម្សាន្តក្នុងជំរុំផ្សេងៗទៀត
- កម្មន្តសាលប្រដាប់ប្រដាក្មេងលេងមានកង់អាចជិះបានរួមទាំងកង់និងត្រីចក្រយានប្លាស្ទិក
- កម្មន្តសាលរូបផ្គុំនិងរបស់ស្រដៀងគ្នា ។

ថ្នាក់នេះមិនរាប់បញ្ចូល៖

- កម្មន្តសាលវីដេអូហ្គេមសម្រាប់កម្សាន្ត (មើល ២៦៤៩)
- កម្មន្តសាលកង់ជិះ (មើល ៣០៩២)
- ការសរសេរ និងបោះផ្សាយនូវកម្មវិធីវីដេអូហ្គេមកម្សាន្ត (មើល ៥៨២០ និង ៦២០១) ។

៣២៥ កម្មន្តសាលឧបករណ៍ និងគ្រឿងផ្គត់ផ្គង់សម្រាប់វេជ្ជសាស្ត្រ និងទន្តសាស្ត្រ

៣២៥០ ៣២៥០០ កម្មន្តសាលឧបករណ៍ និងគ្រឿងផ្គត់ផ្គង់សម្រាប់វេជ្ជសាស្ត្រ និងទន្តសាស្ត្រ

ក្នុងថ្នាក់នេះរួមមានកម្មន្តសាលបរិធានមន្ទីរពិសោធន៍ ឧបករណ៍វះកាត់ និងវេជ្ជសាស្ត្រ គ្រឿងបរិក្ខារ និងគ្រឿងផ្គត់ផ្គង់ការវះកាត់បរិក្ខារ និងគ្រឿងផ្គត់ផ្គង់ទន្តសាស្ត្រសម្ភារៈកែលំអរធ្មេញធ្មេញសិប្បនិម្មិត រួមមានទាំងកម្មន្តសាល គ្រឿងសង្ហារិមសម្រាប់វេជ្ជសាស្ត្រ ទន្តសាស្ត្រ និងគ្រឿងសង្ហារិមស្រដៀងគ្នា ដែលប្រើមុខងារពិសេសបន្ថែមដូចជា៖ កៅអីពេទ្យធ្មេញដែលភ្ជាប់ជាមួយប្រព័ន្ធអ៊ីដ្រូលិក។

ថ្នាក់នេះរាប់បញ្ចូល៖

- កម្មន្តសាលក្រណាត់គ្របពេលវះកាត់ចេសដេរនិងក្រងាសប្រើពេលវះកាត់
- កម្មន្តសាលសម្ភារៈរឹបធ្មេញនិងស៊ីម៉ង់ត៍ប៉ះធ្មេញ (លើកលែងតែការសម្រាប់បិតធ្មេញសិប្បនិមិត្តដែលអាចដកចេញចូលបាន) ក្រមួនពុម្ពធ្មេញនិងបាយអស្វូន្យពុម្ពធ្មេញដទៃទៀត
- កម្មន្តសាលស៊ីម៉ង់ត៍តឆ្អឹងឡើងវិញ
- កម្មន្តសាលចង្ក្រានសម្រាប់មន្ទីពិសោធន៍ទន្តសាស្ត្រ
- កម្មន្តសាលម៉ាស៊ីនសម្អាតដោយប្រព័ន្ធ អ៊ុលត្រាសូនិកប្រើក្នុងមន្ទីពិសោធន៍
- កម្មន្តសាលឧបករណ៍សម្លាប់មេរោគក្នុងបន្ទីពិសោធន៍
- កម្មន្តសាលបរិធានមន្ទីពិសោធន៍ ប្រភេទបិទយកចំហាយ និងសង់ទ្រីហ្វុយ ប្រើក្នុងមន្ទីពិសោធន៍
- កម្មន្តសាលគ្រឿងសង្ហារិមសម្រាប់វេជ្ជសាស្ត្រវះកាត់ទន្តសាស្ត្រឬបសុពេទ្យ ដូចជា៖ តុវះកាត់, តុពិនិត្យជំងឺ, គ្រែពេទ្យភ្ជាប់ជាមួយប្រព័ន្ធមេកានិក, កៅអីពេទ្យធ្មេញ
- កម្មន្តសាលបន្ទះតឆ្អឹងនិងវីសចាប់ឆ្អឹងសឺរាំងម្ជុលចាក់ថ្នាំ ទុយោសុងបំពង់សុងចាក់ចូលទៅក្នុងខ្លួន។ល។
- កម្មន្តសាលឧបករណ៍ទន្តសាស្ត្រ (រួមទាំងកៅអីពេទ្យធ្មេញមានភ្ជាប់ដោយបរិក្ខាពេទ្យធ្មេញ
- កម្មន្តសាលធ្មេញសិប្បនិម្មិតបង្គោលធ្មេញ។ល។និងរបស់របរផ្សេងទៀតដែលធ្វើនៅក្នុង

មន្ទីពិសោធន៍ទន្តសាស្ត្រ

- កម្មន្តសាលឧបករណ៍សម្រាប់ព្យាបាលការបាក់ឆ្អឹងឬគ្រេចថ្លោះនិងអវយវៈសិប្បនិម្មិត
- កម្មន្តសាលកែវភ្នែក (សិប្បនិម្មិត)
- កម្មន្តសាលសីតុណ្ហមាត្រសម្រាប់វេជ្ជសាស្ត្រ
- កម្មន្តសាលបរិក្ខារទាក់ទងនឹងចក្ខុរោគវ៉ែនតាមើលអក្សរវ៉ែនតាការពារពន្លឺកញ្ចក់វ៉ែនតាវាស់ភ្នែកកញ្ចក់ដាក់ក្នុងភ្នែក វ៉ែនតាសុវត្ថិភាព

ថ្នាក់នេះមិនរាប់បញ្ចូលនូវ៖

- កម្មន្តសាលការបិតធ្មេញសិប្បនិម្មិត (ដោះចេញចូលបាន) (មើល ២០២៣)
- កម្មន្តសាលសំឡីកំប្រេសជ្រលក់ថ្នាំរួចសម្រាប់រុំរបួស ។ល។ (មើល ២១០១)
- កម្មន្តសាលបរិក្ខាវេជ្ជសាស្ត្រប្រើអគ្គិសនី និងបរិក្ខាព្យាបាលដោយអគ្គិសនី(មើល ២៦៦០)
- កម្មន្តសាលកៅអីមានកង់រុញ (មើល ៣០៩២)។

៣២៩ កម្មន្តសាលដទៃទៀតដែលពុំបានរាប់បញ្ចូល

៣២៩០ ៣២៩០០ កម្មន្តសាលដទៃទៀតដែលពុំបានរាប់បញ្ចូល

ថ្នាក់នេះរាប់បញ្ចូលនូវ៖

- កម្មន្តសាលបរិក្ខាការពារសុវត្ថិភាព ដូចជា៖
    - កម្មន្តសាលសម្លៀកបំពាក់ធន់នឹងភ្លើងនិងសម្លៀកបំពាក់ការពារ សុវត្ថិភាព
    - កម្មន្តសាលខ្សែក្រវាត់ការពារសុវត្ថិភាពអ្នកឡើងបង្គោលភ្លើង និងខ្សែក្រវ៉ាត់ដទៃទៀតសម្រាប់ប្រើក្នុងពេលបំពេញការងារ
    - កម្មន្តសាលអាវពោងស្នោ
- កម្មន្តសាលមួកធ្វើពីប្លាស្ទិករឹងនិងបរិក្ខាសុវត្ថិភាពផ្ទាល់ខ្លួន ដទៃទៀតធ្វើពីប្លាស្ទិក (ឧ. មួកការពារកីឡាអត្តពលកម្ម)
    - កម្មន្តសាលឈុតសម្លៀកបំពាក់អ្នកពន្លត់អគ្គិភ័យ
    - កម្មន្តសាលមួកដែកសុវត្ថិភាពនិងឧបករណ៍សុវត្ថិភាពផ្ទាល់ខ្លួនធ្វើពីដែកដទៃទៀត
    - កម្មន្តសាលឆ្នុកការពារត្រចៀកនិងសម្លេង (ឧ. សម្រាប់ពេលហែលទឹក និងការពារសំឡេង)
    - កម្មន្តសាលស្រោមមុខការពារឧស្ម័ន
- កម្មន្តសាលអំបោសនិងច្រាសរួមទាំងច្រាសដែលផ្គុំជាផ្នែកនៃម៉ាស៊ីនប្រើដោយដៃក្នុងការសម្អាតផ្ទៃកំរាលអំបោសជូតក្តារនិងអំបោសស្លាបសត្វដក់សម្រាប់លាបថ្នាំបន្ទះលាបថ្នាំនិងរ៉ូឡូលាបថ្នាំអំបោសដទៃទៀត។ល។

- កម្មន្តសាលប្រាសផុសសម្លៀកបំពាក់ និងស្បែកជើង
- កម្មន្តសាលប៊ិចនិងខ្មៅដៃគ្រប់ប្រភេទដែលមាន ឬគ្មានមេកានិក
- កម្មន្តសាលបណ្តូលខ្មៅដៃ
- កម្មន្តសាលត្រាវាយកាលបរិច្ឆេទបិទតែម និងវាយលេខគ្រឿងបោះពុម្ពដោយដៃឬធ្លាក់តួរអក្សរ ផុសចេញកំប្លេម៉ាស៊ីនបោះពុម្ពដោយដៃខ្សែបន្ទះខ្មៅសម្រាប់ម៉ាស៊ីនវាយអង្គុលីលេខ និងប្រអប់ទឹកត្រា
- កម្មន្តសាលភូគោល
- កម្មន្តសាលឆ័ត្រឆ័ត្រការពារកំដៅថ្ងៃឈើច្រត់ដើរឈើទ្រអង្គុយ
- កម្មន្តសាលឡេវឡេវកិប ខ្សែរូត
- កម្មន្តសាលដែកកេះ
- កម្មន្តសាលរបស់របរប្រើប្រាស់ផ្ទាល់ខ្លួន ដូចជា៖ ខ្សៀរ ស្រ្បៃបាញ់ខ្លួនបំពង់ទឹកក្តៅនិងបំពង់សុញ្ញអាកាសដទៃទៀតប្រើសម្រាប់ផ្ទាល់ខ្លួនឬប្រើក្នុងផ្ទះ សក់ក្លែងក្លាយពុកមាត់ក្លែងក្លាយរោមភ្នែកក្លែងក្លាយ
- កម្មន្តសាលរបស់របរផ្សេងទៀត ដូចជា៖ ទៀន ទៀនតូចសម្រាប់អុជក្នុងពិធីបុណ្យ និងទៀនស្រដៀងគ្នា បាច់ផ្កា កម្រងផ្កានិងកន្ត្រកផ្កា ផ្កាសិប្បនិមិត្ត ផ្លែឈើនិងស្លឹកឈើ របស់កំប្លែងងនិងរូបតុក្កតាតូចៗ កន្ត្រកចាក់ដោយដៃនិងកញ្ច្រែងវែងដោយដៃ រូបសំណាករាងមនុស្សសម្រាប់ជាងកាត់ដេរ(ម៉ានីកាំង) មឈូសបញ្ចុះសព ។ល។
- សកម្មភាពដេរញាត់បំប៉ោងរូបសំណាកសត្វឲ្យទៅជារូបភាពដើម

ថ្នាក់នេះមិនរាប់បញ្ចូលនូវ៖

- កម្មន្តសាលប្រឆេះដែកកេះ (មើល ១៣៩៩)
- កម្មន្តសាលសម្លៀកបំពាក់ធ្វើការនៅការដ្ឋាន និងឈុតសម្លៀកបំពាក់បំពេញការងារសេវាកម្ម (ឧ. អាវពាក់ក្នុងមន្ទីពិសោធន៍ សម្លៀកបំពាក់ធ្វើការទូទៅឯកសណ្ឋាន) (មើល ១៤១១)
- កម្មន្តសាលរូបតុក្កតាតូចៗធ្វើពីក្រដាស (មើល ១៧០៩)
- កម្មន្តសាលរូបតុក្កតាតូចៗធ្វើពីប្លាស្ទិក (មើល ២២២៩)។

ជំពូក គ ៖ កម្មន្តសាល
ផ្នែក ៣៣ ៖ ការជួសជុលនិងដំឡើងម៉ាស៊ីន និងគ្រឿងបរិក្ខាររបស់ម៉ាស៊ីន

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៣៣១			**ការជួសជុលផលិតផលម៉ាស៊ីននិងគ្រឿងបរិក្ខាលោហធាតុកែច្នៃ**
	៣៣១១	៣៣១១០	ការជួសជុលផលិតផលលោហធាតុកែច្នៃ

ក្នុងថ្នាក់នេះ រាប់បញ្ចូលនូវការជួសជុល និងថែទាំផលិតផលលោហធាតុកែច្នៃឋិតក្នុងផ្នែក ២៥ ។

ថ្នាក់នេះរាប់បញ្ចូលនូវ៖
- ការជួសជុលធុងធ្វើពីលោហធាតុអាងស្តុកនិងប៉ោត
- ការជួសជុលនិងការថែទាំបំពង់ទុយោនិងខ្សែបំពង់
- ការជួសជុលឧបករណ៍ចល័តផ្សារភ្ជាប់គ្នា
- ការជួសជុលទូកដឹកទំនិញធ្វើពីដែកថែប
- ការជួសជុលនិងការថែទាំម៉ាស៊ីនបង្កើតចំហាយទឹកឬចំហាយដទៃទៀត
- ការជួសជុល និងការថែទាំគ្រឿងបន្សំបន្ថែមដែលប្រើជាមួយម៉ាស៊ីនបង្កើតចំហាយទឹក ដូចជា៖
    - កង់ដង់សាទ័រប្រដាប់សន្សំសំចៃថាមពលប្រដាប់បង្កើនកម្តៅចំហាយទឹកប្រដាប់ចាប់យកចំហាយទឹក ប្រដាប់ផ្ទុកចំហាយទឹក
- ការជួសជុលនិងការថែទាំរេអាក់ទ័រនុយក្លេអែរលើកលែងគ្រឿងបំបែកអ៊ីសូតុប
- ការជួសជុលនិងការថែទាំគ្រឿងបន្ទាប់បន្សំរបស់នាវាសមុទ្រនិងឡចំហាយថាមពល
- ការជួសជុលម៉ាស៊ីនកម្តៅក្នុងផ្ទះនិងរ៉ាដ្យាទ័រ
- ការជួសជុលនិងការថែទាំអាវុធនិងយុទ្ធភណ្ឌ (រួមមានការជួសជុលកាំភ្លើងកីឡានិងកាំភ្លើងសម្រាប់កម្សាន្ត)

ថ្នាក់នេះមិនរាប់បញ្ចូល៖
- ការជួសជុលប្រព័ន្ធបង្កើតកម្តៅ។ល។(មើល ៤៣២២)
- ការជួសជុលគ្រឿងបរិក្ខាសោមេកានិកទូសុវត្ថិភាព។ល។ (មើល ៨០២០)។

៣៣១២   ៣៣១២០   ការជួសជុលគ្រឿងម៉ាស៊ីន

ថ្នាក់នេះរួមបញ្ចូល ការជួសជុលនិងថែទាំគ្រឿងម៉ាស៊ីន និងឧបករណ៍សម្រាប់ការងារឧស្សាហកម្ម ដូចជា ការសំលៀងឬដំឡើងកាំបិតនិងរណារ ពាណិជ្ជកម្ម និងឧស្សាហកម្មសេវាកម្មជួសជុល តាមរយៈការផ្សារ (ឧ. ខាងរថយន្តនិងទូទៅ) ការជួសជុលគ្រឿងម៉ាស៊ីននិងឧបករណ៍ សម្រាប់ការងារកសិកម្មនិងឧស្សាហកម្មធុនធ្ងន់ (ឧ.ប្រដាប់លើកដាក់អ៊ីវ៉ាន់ និងឧបករណ៍សម្រាប់លើកដាក់សម្ភារៈដទៃផ្សេងទៀត គ្រឿងម៉ាស៊ីន ឧបករណ៍ម៉ាស៊ីនធ្វើឲ្យត្រជាក់ជាលក្ខណៈពាណិជកម្ម គ្រឿងម៉ាស៊ីនឧបករណ៍សំណង់ និងរុករករ៉ែ) គ្រឿងម៉ាស៊ីន និងឧបករណ៍បង្គុំសម្រាប់ផ្នែក ២៨ ។

ថ្នាក់នេះរួមបញ្ចូល៖

- ការជួសជុល និងការថែទាំម៉ាស៊ីនមិនមែនរថយន្ត ឧ.ម៉ាស៊ីនកប៉ាល់ឬរថភ្លើង
- ការជួសជុល និងការថែទាំម៉ាស៊ីនប៉ូមនិងឧបករណ៍ពាក់ព័ន្ធដទៃទៀត
- ការជួសជុលនិងការថែទាំឧបករណ៍ដែលដើរដោយថាមពលរាវ
- ការជួសជុលសន្ទះបិទបើក
- ការជួសជុលធាតុផ្សំនៃស្ពឺចក្រនិងឧបករណ៍បើកបរ
- ការជួសជុល និងការថែទាំឡកំដៅដំណើរការសម្រាប់ឧស្សាហកម្ម
- ការជួសជុល និងការថែទាំឧបករណ៍សម្រាប់លើកដាក់សម្ភារៈ
- ការជួសជុលនិងថែការទាំឧបករណ៍ធ្វើឲ្យត្រជាក់សម្រាប់ការងារពាណិជ្ជកម្ម និងឧបករណ៍បន្សុទ្ធខ្យល់
- ការជួសជុលនិងការថែទាំគ្រឿងម៉ាស៊ីនសម្រាប់គោលបំណងពាណិជ្ជកម្មទូទៅ
- ការជួសជុលគ្រឿងបរិក្ខារដំណើរការដោយដៃ
- ការជួសជុល និងការថែទាំឧបករណ៍និងគ្រឿងបរិក្ខារម៉ាស៊ីនកាត់និងស្រោបដែក
- ការជួសជុល និងការថែទាំគ្រឿងបរិក្ខារម៉ាស៊ីនដទៃទៀត
- ការជួសជុល និងការថែទាំត្រាក់ទ័រកសិកម្ម
- ការជួសជុល និងការថែទាំគ្រឿងម៉ាស៊ីនកសិកម្មនិង គ្រឿងម៉ាស៊ីនរុក្ខកម្ម និងកាប់ឈើ
- ការជួសជុល និងការថែទាំគ្រឿងម៉ាស៊ីនក្រឡឹងដែក
- ការជួសជុលនិងការថែទាំគ្រឿងម៉ាស៊ីនសម្រាប់ការងាររុករករ៉ែសំណង់និង ប្រេងនិងឧស្ម័ន
- ការជួសជុលនិងការថែទាំគ្រឿងម៉ាស៊ីនសម្រាប់កែច្នៃអាហារភេសជ្ជៈនិងថ្នាំជក់
- ការជួសជុល និងការថែទាំគ្រឿងម៉ាស៊ីនវាយនភ័ណ្ឌនិង ផលិតកម្មស្បែក
- ការជួសជុលនិងការថែទាំគ្រឿងម៉ាស៊ីនសម្រាប់ផលិតក្រដាស
- ការជួសជុលនិងការថែទាំគ្រឿងម៉ាស៊ីនប្រើសម្រាប់គោលបំណងពិសេសដទៃទៀតនៃផ្នែក ២៨
- ការជួសជុលនិងការថែទាំឧបករណ៍ថ្លឹងទម្ងន់
- ការជួសជុល និងការថែទាំម៉ាស៊ីនលក់ទំនិញដើរដោយស្វ័យប្រវត្តិ
- ការជួសជុលនិងការថែទាំម៉ាស៊ីនរាប់ប្រាក់
- ការជួសជុល និងការថែទាំម៉ាស៊ីនថតចម្លងឯកសារ
- ការជួសជុលម៉ាស៊ីនគិតលេខមិនថាជានិងមិនមែនជាអេឡិចត្រូនិក
- ការជួសជុលអង្គលីលេខ

ថ្នាក់នេះមិនរាប់បញ្ចូលនូវ៖

- ការដំឡើងជួសជុលនិងថែទាំនូវ ឧបករណ៍ធ្វើឲ្យមានកម្តៅ និងឧបករណ៍កម្តៅផ្សេងដទៃទៀត (មើល ៤៣២២)
- ការដំឡើងជួសជុលនិងថែទាំ ជណ្តើរយន្តនិងជណ្តើរយោង (មើល ៤៣២៩)។

៣៣១៣ ៣៣១៣០ ការជួសជុលឧបករណ៍អេឡិចត្រូនិកនិងអុបទិក

ថ្នាក់នេះមានរាប់បញ្ចូល នូវការជួសជុលនិងថែទាំ របស់របរដែលផលិតក្នុងក្រុម ២៦៥ ២៦៦ និង ២៦៧ លើកលែងតែរបស់របរ ដែលចាត់ទុកថាជារបស់របរប្រើប្រាស់ក្នុងផ្ទះ។

ថ្នាក់នេះរួមបញ្ចូលនូវ៖

- ការជួសជុលនិងថែទាំឧបករណ៍វាស់វែងធ្វើតេស្ត រកទិស និងត្រួតពិនិត្យ នៃថ្នាក់២៦៥ ដែលមានដូចជា៖
  - គ្រឿងបរិក្ខាម៉ាស៊ីនយន្តហោះ
  - បរិក្ខារធ្វើតេស្តការបញ្ចេញផ្សែងយានយន្ត
  - ឧបករណ៍ឧតុនិយម
  - បរិក្ខារត្រួតពិនិត្យ និងធ្វើតេស្តលក្ខណៈរូបអេឡិចត្រូនិកនិងគីមី
  - ឧបករណ៍អង្កេតស្ទាប់ស្ទង់
  - ឧបករណ៍រុករកការសាយភាយនិងតាមដានកាំរស្មី
- ការជួសជុល និងថែទាំបរិក្ខារបំភាយកាំរស្មីអេឡិកត្រូវេជ្ជសាស្ត្រនិងព្យាបាលដោយអគ្គីសនី នៃថ្នាក់ ២៦៦០ ដែលមានដូចជា៖
  - បរិក្ខាររូបភាពរ៉េសូណង់ម៉ាញ៉េទិក
  - បរិក្ខារពេទ្យអ៊ុលត្រាសំឡេង
  - បរិក្ខារជំនួយចលនាបេះដូងបង្កប់នៅក្នុងខ្លួន (បេះដូងសិប្បនិមិត្ត)
  - គ្រឿងជួយក្នុងការស្តាប់
  - បរិក្ខារអេឡិកត្រូកាឌីយ៉ូក្រាហ្វ
  - បរិក្ខារពេទ្យ ឆ្លុះពិនិត្យដោយអគ្គិសនី
  - បរិធានបំភាយកាំរស្មី
- ការជួសជុលនិងថែទាំឧបករណ៍និងបរិក្ខារអុបទិកនៃក្រុម ២៦៧ ក្នុងករណីដែលប្រើប្រាស់សម្រាប់ការងារពាណិជ្ជកម្ម មានដូចជា៖
  - កែវយឹតជិត
  - មីក្រូទស្សន៍ (លើកលែងអេឡិត្រុងប្រូតុង)
  - កែវយឹតឆ្ងាយ
  - ព្រីសនិងកញ្ចក់ឡង់ទី (លើកលែងសម្រាប់ចក្ខុសាស្ត្រ)
  - ឧបករណ៍ថតរូប

ថ្នាក់នេះមិនរាប់បញ្ចូលនូវ៖

- ការជួសជុលនិងថែទាំម៉ាស៊ីនថតចម្លង (មើល ៣៣១២)
- ការជួសជុលនិងថែទាំកុំព្យូទ័រនិងគ្រឿងតភ្ជាប់ជាមួយកុំព្យូទ័រ (មើល ៩៥១១)
- ការជួសជុលនិងថែទាំឧបករណ៍បញ្ចាំងរូបភាពចលនា និងស្លាយ (មើល ៩៥១១)
- ការជួសជុលនិងថែទាំឧបករណ៍ទំនាក់ទំនង (មើល ៩៥១២)
- ការជួសជុលនិងថែទាំទូរទស្សន៍និងវីដេអូលក្ខណៈជាពាណិជ្ជកម្ម (មើល ៩៥១២)
- ការជួសជុលកាម៉េរ៉ាវីដេអូប្រភេទប្រើប្រាស់ជាគ្រួសារ (មើល ៩៥២១)
- ការជួសជុលនាឡិកាដៃ និងនាឡិកាព្យួរ (មើល ៩៥២៩)។

៣៣១៤ ៣៣១៤០ ការជួសជុលបរិក្ខារអគ្គិសនី

ថ្នាក់នេះ រាប់បញ្ចូលនូវការជួសជុល និងថែទាំរបស់របរក្នុងផ្នែក ២៧ លើកលែងតែរបស់របរនៃក្រុម ២៧៥ (បរិក្ខារផ្ទះបាយ)។

ថ្នាក់នេះរាប់បញ្ចូល៖

- ការជួសជុលនិងថែទាំត្រង់ស្វូថាមពលត្រង់ស្វូបរិធានចែកចាយ និងគ្រួតពិនិត្យចរន្តអគ្គិសនី
- ការជួសជុលនិងថែទាំម៉ូទ័រអគ្គិសនីម៉ាស៊ីនភ្លើងនិងកុំប្លេម៉ូទ័រ
- ការជួសជុលនិងថែទាំកុងតាក់និងប្រព័ន្ធបញ្ជាកុងតាក់
- ការជួសជុលនិងថែទាំរីឡេ និងឧបករណ៍គ្រួតពិនិត្យក្នុងឧស្សាហកម្ម
- ការជួសជុល និងថែទាំថ្មពិល និងអាគុយ
- ការជួសជុលនិងថែទាំបរិក្ខារអគ្គិសនីបំភ្លឺ
- ការជួសជុលនិងថែទាំគ្រឿងតខ្សែភ្លើង ទោះជាមិនចម្លងចរន្តអគ្គិសនីឬចម្លងចរន្តអគ្គិសនីក្តីសម្រាប់សៀគ្វីអគ្គិសនី

ថ្នាក់នេះមិនរាប់បញ្ចូលនូវ៖

- ការជួសជុលនិងថែទាំនូវ កុំព្យូទ័រនិងគ្រឿងតភ្ជាប់ជាមួយកុំព្យូទ័រ (មើល ៩៥១១)
- ការជួសជុលនិងថែទាំបរិក្ខាទូរគមនាគមន៍ (មើល ៩៥១២)
- ការជួសជុលនិងថែទាំគ្រឿងប្រើប្រាស់អេឡិចត្រូនិក (មើល ៩៥២១)
- ការជួសជុលនាឡិកាដៃនិងនាឡិកាព្យួរ (មើល ៩៥២៩)។

៣៣១៥　៣៣១៥០　ការជួសជុលបរិក្ខាដឹកជញ្ជូន (លើកលែងតែយានយន្ត) ផ្សេងៗទៀត

ថ្នាក់នេះរាប់បញ្ចូល នូវការជួសជុលនិងថែទាំបរិក្ខារដឹកជញ្ជូន ដែលឋិតក្នុងផ្នែក ៣០លើកលែងតែម៉ូតូនិងកង់។ ទោះជាយ៉ាងណាក៏ដោយ ការផ្តុំឡើងវិញ ឬសំណង់កប៉ាល់ ក្បាលរថភ្លើងយានរត់លើផ្លូវដែក និងយន្តហោះត្រូវបានចាត់ចូលក្នុងផ្នែក ៣០ ។

ថ្នាក់នេះរាប់បញ្ចូល៖

- ការជួសជុល និងថែទាំជាប្រចាំចំពោះកប៉ាល់
- ការជួសជុលនិងថែទាំទូកកម្សាន្ត
- ការជួសជុលនិងថែទាំក្បាលរថភ្លើងនិងយានរត់លើផ្លូវដែក (លើកលែងការសាងសង់ឡើងវិញ ឬការផ្តុំឡើងវិញ)
- ការជួសជុលនិងថែទាំយន្តហោះ (លើកលែងការសាងសង់ឡើងវិញនិងការផ្តុំឡើងវិញ)
- ការជួសជុលនិងថែទាំម៉ាស៊ីនយន្តហោះ
- ការជួសជុលយាន និងរទេះអូសដោយសត្វ

ថ្នាក់នេះ មិនរាប់បញ្ចូល៖

- ការសាងសង់ឡើងវិញនូវកប៉ាល់ (មើល ៣០១១)
- ការសាងសង់ឡើងវិញនូវក្បាលម៉ាស៊ីននិងយានរត់លើផ្លូវដែក (មើល ៣០២០)
- ការសាងសង់ឡើងវិញនូវយន្តហោះ (មើល ៣០៣០)
- ការជួសជុលម៉ាស៊ីនកប៉ាល់និងរថភ្លើង (មើល ៣៣១២)
- ការថ្លឹងទម្ងន់កប៉ាល់និងការកំទេចចោល (មើល ៣៨៣០)
- ការជួសជុលនិងថែទាំម៉ូតូ (មើល ៤៥៤០)
- ការជួសជុលទោចក្រយាននិងរទេះរុញសម្រាប់អ្នកពិការ (មើល ៩៥២៩)។

៣៣១៩　៣៣១៩០　ការជួសជុលឧបករណ៍ដទៃផ្សេងទៀត

ថ្នាក់នេះរាប់បញ្ចូល នូវការជួសជុលនិងថែទាំ ឧបករណ៍ដែលមិនគ្របដណ្តប់ក្នុងថ្នាក់នៃជំពូកនេះ។

ថ្នាក់នេះរួមបញ្ចូល៖

- ការជួសជុលសំណាញ់នេសាទ រួមទាំងការប៉ះសំណាញ់
- ការជួសជុលខ្សែពួរគ្រឿងក្តោងនាំងសំពត់ និងសំពត់លាបជ័រកុំឲ្យលិចទឹក
- ការជួសជុលថង់ផ្ទុកជីនិងជាតិគីមី
- ការជួសជុលឬកែកុនបន្ទះឈើ ទូក ឬធុងដឹកទំនិញនិងឧបករណ៍ដទៃទៀត
- ការជួសជុលម៉ាស៊ីនដាក់កាក់និងហ្គេមដាក់កាក់ដទៃទៀត
- ការស្តារឡើងវិញនូវបរិក្ខារនិងឧបករណ៍តន្ត្រីបុរាណដទៃទៀត

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ការជួសជុលគ្រឿងសង្ហារិមសម្រាប់តាមផ្ទះនិងការិយាល័យនិងការជំឡើងឡើងវិញនូវ

គ្រឿងសង្ហារិម (មើល ៩៥២៤)

- ការជួសជុលទោចក្រយាននិងរទេះរុញសម្រាប់អ្នកពិការ (មើល ៩៥២៩)
- ការជួសជុលនិងប៉ះសម្លៀកបំពាក់ (មើល ៩៥២៩)។

៣៣២ ការដំឡើងផ្គុំជាម៉ាស៊ីននិងគ្រឿងបរិក្ខារម៉ាស៊ីន

៣៣២០ ៣៣២០០ ការដំឡើងគ្រឿងម៉ាស៊ីននិងគ្រឿងបរិក្ខារម៉ាស៊ីន

ក្នុងថ្នាក់នេះរាប់បញ្ចូលនូវ ការដំឡើងពិសេសនៃគ្រឿងម៉ាស៊ីន។ ទោះជាយ៉ាងនេះក្តីការដំឡើងគ្រឿងបរិក្ខា ដែលផ្គុំបានជាបំណែកមួយនៃអាគារ ឬចនាប្រហាក់ប្រហែលគ្នានេះមានដូចជា ការដំឡើងជណ្តើរយន្តខ្សែភ្លើង ប្រព័ន្ធប្រកាសអាសន្នពេលមានចោរចូលឬប្រព័ន្ធម៉ាស៊ីនត្រជាក់ គឺត្រូវបានចាត់ចូលចំណាត់ថ្នាក់សំណង់។

ថ្នាក់នេះរាប់បញ្ចូល៖

- ការដំឡើងគ្រឿងម៉ាស៊ីនឧស្សាហកម្មសម្រាប់សហគ្រាសឧស្សាហកម្ម
- ការដំឡើងគ្រឿងបរិក្ខារត្រួតពិនិត្យដំណើរការឧស្សាហកម្ម
- ការដំឡើងគ្រឿងបរិក្ខារឧស្សាហកម្មដទៃទៀត មានដូចជា៖
    - o គ្រឿងបរិក្ខាទូរគមនាគមន៍
    - o ស៊ុមទូទៅនិងស៊ុមកុំព្យូទ័រប្រហាក់ប្រហែល
    - o គ្រឿងបរិក្ខារបំភាយកាំរស្មីនិងអេឡិចត្រូវេជ្ជសាស្ត្រ ។ល។
- ការរុះរើគ្រឿងម៉ាស៊ីននិងគ្រឿងបរិក្ខារធុនធំ
- សកម្មភាពរបស់ម៉ាស៊ីនកិនស្រូវ
- ម៉ាស៊ីនគ្រឿងក្តោង
- ការដំឡើងឧបករណ៍កីឡាប៊ូលីង

ថ្នាក់នេះមិនរាប់បញ្ចូល៖

- ការដំឡើងខ្សែភ្លើងនិងប្រព័ន្ធប្រកាសអាសន្នពេលមានចោរ (មើល ៤៣២១)
- ការដំឡើងប្រព័ន្ធម៉ាស៊ីនត្រជាក់ (មើល ៤៣២២)
- ការដំឡើងជណ្តើរជនជណ្តើរយន្តប្រអប់ទ្វារបិទបើកដោយស្វ័យប្រវត្តិប្រព័ន្ធសម្រាប់សុញ្ញអាកាស ។ល។ (មើល ៤៣២៩)
- ការដំឡើងទ្វារជណ្តើរតូបលក់ដូរគ្រឿងសង្ហារិម។ល។ (មើល ៤៣៣០)
- ការដំឡើងកុំព្យូទ័រប្រើប្រាស់ផ្ទាល់ខ្លួន (មើល ៦២០៩) ។

ជំពូក ឃ ៖ ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយទឹក និងប្រព័ន្ធខ្យល់ត្រជាក់

កម្រិត	ច.ស.វ.ក
ជំពូក	១
ផ្នែក	១
ក្រុម	៣
ថ្នាក់	៣
ថ្នាក់រង	៨

ជំពូកនេះរួមមានសកម្មភាពផ្គត់ផ្គង់ថាមពលអគ្គិសនី ឧស្ម័នធម្មជាតិ ចំហាយទឹក ទឹកក្តៅ និងប្រភេទដូចគ្នានេះ តាមរយៈបណ្តាញបញ្ជូនអចិន្ត្រៃយ៍ ដូចជា ខ្សែបណ្តាញបញ្ជូនមេ និងបំពង់។ ទំហំនៃបណ្តាញបញ្ជូននេះ មិនត្រូវបានកំណត់នោះទេ ដោយរួមមាន ការចែកចាយអគ្គិសនី ឧស្ម័ន ទឹកក្តៅ និងប្រភេទដូចគ្នានេះ នៅក្នុងសួនឧស្សាហកម្ម និងអគារលំនៅឋាន។ ដូច្នេះ ជំពូកនេះផ្តោតទៅលើ ការប្រតិបត្តិរោងចក្រអគ្គិសនីនិងឧស្ម័ន ដែលផលិត គ្រប់គ្រង និងចែកចាយ នូវអគ្គិសនីនិងឧស្ម័ន។ ការផ្គត់ផ្គង់ចំហាយទឹក និងប្រព័ន្ធខ្យល់ត្រជាក់ ក៏ត្រូវបានរាប់បញ្ចូលនៅក្នុងជំពូកនេះផងដែរ។

ជំពូកនេះរាប់បញ្ចូលសកម្មភាពផ្គត់ផ្គង់ថាមពលអគ្គិសនី ឧស្ម័នធម្មជាតិ ចំហាយទឹក និងទឹកក្តៅ។ ជំពូកនេះមិនរាប់បញ្ចូលនូវប្រតិបត្តិការរោងចក្រទឹកស្អាត រោងចក្រកែច្នៃទឹកស្អុយទេ(មើលផ្នែក ៣៦ និង ៣៧) និងការដឹកជញ្ជូនឧស្ម័នតាមបំពង់(ក្នុងរយៈចម្ងាយឆ្ងាយ)។

ផ្នែក ៣៥ ៖ ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយទឹក និងប្រព័ន្ធខ្យល់ត្រជាក់

ផ្នែកនេះរាប់បញ្ចូលការផលិត ការបញ្ជូន និងចែកចាយថាមពលអគ្គិសនី ការផលិត ឧស្ម័ន និងការចែកចាយឥន្ទនៈដែលជាឧស្ម័នតាមរយៈបណ្តាញបញ្ជូនមេ និងការផ្គត់ផ្គង់ចំហាយទឹក និងប្រព័ន្ធខ្យល់ត្រជាក់។

ក្រុម ៣៥១ ៖ ការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី

ក្រុមនេះរួមបញ្ចូលការផលិតថាមពលអគ្គិសនីខ្នាតធំ ការបញ្ជូនថាមពលពីរោងចក្រផលិតថាមពលអគ្គិសនីទៅអនុស្ថានីយ និងការចែកចាយទៅឲ្យអ្នកប្រើប្រាស់ចុងក្រោយ។

ក្រុម ៣៥២ ៖ ការផលិតឧស្ម័ន និងការចែកចាយឧស្ម័នឥន្ទនៈតាមបណ្តាញបំពង់បង្ហូរមេ

ក្រុមនេះរាប់បញ្ចូលការផលិតឧស្ម័ន និងការចែកចាយឧស្ម័នធម្មជាតិ ឬឧស្ម័នសំយោគ ទៅកាន់អ្នកប្រើប្រាស់ តាមរយៈប្រព័ន្ធបណ្តាញបំពង់បង្ហូរមេ។ ឈ្មួញកណ្តាល ឬអ្នកលក់ឧស្ម័ន ដែលចាត់ចែងការលក់ឧស្ម័នតាមរយៈប្រព័ន្ធចែកចាយដែលគ្រប់គ្រងដោយអ្នកដទៃទៀត ក៏ត្រូវបានរាប់បញ្ចូលនៅក្នុងក្រុមនេះផងដែរ។

ការប្រតិបត្តិដាច់ដោយឡែក នូវបណ្តាញបំពង់ឧស្ម័នក្នុងរយៈចម្ងាយឆ្ងាយដែលភ្ជាប់អ្នកផលិត និងអ្នកចែកចាយឧស្ម័ន ឬភ្ជាប់រវាងមណ្ឌលចែកចាយនានានៅក្នុងទីប្រជុំជននោះ មិនត្រូវបានរាប់បញ្ចូលនៅក្នុងក្រុមនេះទេ ហើយវាត្រូវបានចាត់ទៅក្នុងក្រុមសកម្មភាពដឹកជញ្ជូនឧស្ម័នតាមបំពង់ដទៃទៀតវិញ។

ក្រុម ៣៥៣ ៖ ការផ្គត់ផ្គង់ចំហាយទឹក និងប្រព័ន្ធខ្យល់ត្រជាក់

ក្រុមនេះរួមមានការផលិត ការប្រមូល និងការចែកចាយចំហាយទឹក និងទឹកក្តៅសម្រាប់យកទៅកម្តៅ ផលិតថាមពល និងសម្រាប់គោលដៅផ្សេងៗ, ការផលិតនិងចែកចាយខ្យល់ត្រជាក់, ការផលិតនិងចែកចាយទឹកត្រជាក់សម្រាប់យកទៅស្ដំ, ការផលិតទឹកកក រួមទាំងទឹកកកសម្រាប់ប្រើក្នុងអាហារ និងទឹកកកមិនមែនសម្រាប់ប្រើក្នុងអាហារ(យកទៅស្ដំ)។

ជំពូក ឃ ៖ ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយទឹក និងប្រព័ន្ធខ្យល់ត្រជាក់
ផ្នែក ៣៥ ៖ ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយទឹក និងប្រព័ន្ធខ្យល់ត្រជាក់

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៣៥១			**ការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី**
	៣៥១០[១]		ការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី
		៣៥១០១	ការប្រតិបត្តិការនៃរោងចក្រផលិតថាមពលអគ្គិសនី[២]
		៣៥១០២	ការប្រតិបត្តិការនៃការបញ្ជូនថាមពលអគ្គិសនី
		៣៥១០៣	ការប្រតិបត្តិការនៃការចែកចាយថាមពលអគ្គិសនី
៣៥២			**ការផលិតឧស្ម័ន និងការចែកចាយឧស្ម័នឥន្ទនៈតាមបណ្តាញបញ្ជូនមេ**
	៣៥២០[៣]		ការផលិតឧស្ម័ន និងការចែកចាយឥន្ទនៈឧស្ម័នតាមបណ្តាយបញ្ជូនមេ
		៣៥២០០	ការផលិតឧស្ម័ន ការចែកចាយឧស្ម័នឥន្ទនៈតាមបណ្តាញបំពង់បង្ហូរមេ
៣៥៣			**ការផ្គត់ផ្គង់ចំហាយទឹក និងប្រព័ន្ធខ្យល់ត្រជាក់**
	៣៥៣០		ការផ្គត់ផ្គង់ចំហាយទឹក និងប្រព័ន្ធខ្យល់ត្រជាក់
		៣៥៣០០	ការផ្គតផ្គង់ចំហាយទឹក និងប្រព័ន្ធខ្យល់ត្រជាក់
		៣៥៣០១	ប្រតិបត្តិការរោងចក្រផលិតថាមពលចំហាយ
		៣៥៣០២	ប្រតិបត្តិការនៃការបញ្ជូនថាមពលចំហាយ
		៣៥៣០៣	ប្រតិបត្តិការនៃការចែកចាយ និងលក់ថាមពលចំហាយ

(១) **មិនរាប់បញ្ចូល** ការផលិតអគ្គិសនីតាមរយៈការដុតកាកសំណល់ (មើល ៣៨២១០)។

(២) **រាប់បញ្ចូល**
(ក) កម្តៅ
(ខ) បរិមាណូស៊ីវិល
(គ) វារីអគ្គិសនី
(ឃ) ទួប៊ីនឧស្ម័ន
(ង) ប្រេងម៉ាស៊ូត ប្រេងខ្មៅ និងថាមពលកកើតឡើងវិញ

(៣) **មិនរាប់បញ្ចូល**
(ក) ការប្រតិបត្តិការឡដុតកាកសំណល់ធ្យូងថ្ម (មើល ១៩១០០)
(ខ) ការផលិតផលិតផលតេលសិលាដែលបានចម្រាញ់ (មើល ១៩២០១)
(គ) ការផលិតឧស្ម័នសម្រាប់ឧស្សាហកម្ម (មើល ២០១១១)
(ឃ) ការលក់ដុំប្រេងឥន្ទនៈឧស្ម័ន (មើល ៤៦៦១៩)
(ង) ការលក់រាយឧស្ម័នប្រកដប (មើល ៤៧៧៣៥)
(ច) ការលក់ប្រេងឥន្ទនៈផ្ទាល់ (មើល ៤៧៩៩១)
(ឆ) ការដឹកជញ្ជូនឧស្ម័នតាមបណ្តាញបំពង់(ចម្ងាយឆ្ងាយ) (មើល ៤៩៣០០)។

ជំពូក ខ ៖ ការផ្គត់ផ្គង់ទឹកស្អាត ការគ្រប់គ្រង និងការកែច្នៃទឹកស្អុយ និងកាកសំណល់

កម្រិត	ច.ស.វ.ក
ជំពូក	១
ផ្នែក	៤
ក្រុម	៦
ថ្នាក់	៨
ថ្នាក់រង	៨

ជំពូកនេះរាប់បញ្ចូលនូវបណ្តាសកម្មភាព ដែលទាក់ទងទៅនឹងការគ្រប់គ្រង (ដោយរាប់បញ្ចូលការប្រមូល ការធ្វើប្រព្រឹត្តិកម្ម ការចម្ងាត់មេរោគ និងការបញ្ចេញចោល) ប្រភេទកាកសំណល់ផ្សេងៗ ដូចជា កាកសំណល់រឹងឬទន់ ដែលបានមកពីគ្រួសារ ឬឧស្សាហកម្ម ព្រមទាំងទីកន្លែងកខ្វក់។ ជាតុចេញនៃដំណើរការធ្វើប្រព្រឹត្តិកម្មទឹកស្អុយ ឬកាកសំណល់ អាចត្រូវបានបោះចោល ឬក្លាយជាជាតុចូល សម្រាប់ដំណើរការផលិតកម្មដទៃទៀត។ សកម្មភាពផ្គត់ផ្គង់ទឹកស្អាត ក៏ត្រូវបានបញ្ចូលក្នុងជំពូកនេះផងដែរ ដោយសកម្មភាពទាំងនោះ ជារឿយៗត្រូវបានធ្វើឡើង ដោយមានទំនាក់ទំនងជាមួយការធ្វើប្រព្រឹត្តិកម្មទឹកស្អុយ ឬធ្វើឡើងដោយអង្គភាពដែលចូលរួមក្នុងការប្រោះទឹកស្អុយ។

ផ្នែក ៣៦ ៖ ការប្រមូល ការធ្វើប្រព្រឹត្តិកម្ម និងការផ្គត់ផ្គង់ទឹក

ផ្នែកនេះរាប់បញ្ចូលនូវការប្រមូល ការធ្វើប្រព្រឹត្តិកម្ម និងការចែកចាយទឹក សម្រាប់តម្រូវការតាមឧស្សាហកម្ម និងគ្រួសារ។ ការប្រមូលទឹកពីប្រភពផ្សេងៗ និងការចែកចាយតាមមធ្យោបាយផ្សេងៗក៏ត្រូវបានរាប់បញ្ចូលផងដែរ។

ក្រុម ៣៦០ ៖ ការប្រមូល ការធ្វើប្រព្រឹត្តិកម្ម និងការផ្គត់ផ្គង់ទឹក

ក្រុមនេះរាប់បញ្ចូលសកម្មភាពប្រមូល ធ្វើប្រព្រឹត្តិកម្ម និងចែកចាយទឹក សម្រាប់តម្រូវការតាមឧស្សាហកម្ម និងគ្រួសារ។ ការប្រមូលទឹកពីប្រភពផ្សេងៗ និងការចែកចាយតាមមធ្យោបាយផ្សេងៗ ក៏ត្រូវបានរាប់បញ្ចូលផងដែរ។ ការប្រតិបត្តិប្រព័ន្ធស្រោចស្រពក៏ត្រូវបានរាប់បញ្ចូលផងដែរ។ ទោះជាយ៉ាងនេះក្តី ការផ្តល់សេវាកម្មប្រព័ន្ធស្រោចស្រព តាមរយៈឧបករណ៍ស្រោចស្រព និងសេវាកម្មគាំទ្រវិស័យកសិកម្មស្រដៀងគ្នានេះពុំត្រូវបានរាប់បញ្ចូលនោះទេ។

ជំពូក ង ៖ ការផ្គត់ផ្គង់ទឹកស្អាត ការគ្រប់គ្រងនិងកែច្នៃទឹកស្អុយនិងកាកសំណល់
ផ្នែក ៣៦ ៖ ការប្រមូល ការធ្វើប្រព្រឹត្តិកម្ម និងការផ្គត់ផ្គង់ទឹក

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៣៦០			ការប្រមូល ការធ្វើប្រព្រឹត្តិកម្ម និងការផ្គត់ផ្គង់ទឹក
	៣៦០០[១]		សកម្មភាពប្រមូល ធ្វើប្រព្រឹត្តិកម្ម និងចែកចាយទឹក សម្រាប់តម្រូវការតាមឧស្សាហកម្ម និងគ្រួសារ
		៣៦០០០	ការបន្សុទ្ធ និងការចែកចាយទឹកសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត[២]

(១) **រាប់បញ្ចូល** ការចែកចាយទឹកដោយរថយន្តដឹកទឹក

មិនរាប់បញ្ចូល
- (ក) ការប្រតិបត្តិការឧបករណ៍ធារាសាស្ត្រ សម្រាប់គោលបំណងកសិកម្ម (មើល ០១៦១០)
- (ខ) ការធ្វើប្រព្រឹត្តិកម្មទឹកស្អុយដើម្បីបង្ការការបំពុល (មើល ៣៧០០០)
- (គ) ដឹកជញ្ជូនទឹកតាមរយៈបណ្តាញបំពង់(ចម្ងាយឆ្ងាយ) (មើល ៤៩៣០០)។

(២) **រាប់បញ្ចូល** ការប្រតិបត្តិការប្រឡាយប្រព័ន្ធស្រោចស្រព និងផលិតកម្មទឹកងាយយកតាមខ្លួនដោយការបង្កួតទឹកដែលមានជាតិប្រៃ។

ផ្នែក ៣៧ ៖ ប្រព័ន្ធទឹកស្អុយ

ផ្នែកនេះរាប់បញ្ចូល ការប្រតិបត្តិប្រព័ន្ធបង្ហូរឬកន្លែងធ្វើប្រព្រឹត្តិកម្មទឹកស្អុយ ដែលប្រមូល ធ្វើប្រព្រឹត្តិកម្ម និងបញ្ចេញចោលនូវទឹកស្អុយ។

ក្រុម ៣៧០ ៖ ប្រព័ន្ធទឹកស្អុយ

ក្រុមនេះរាប់បញ្ចូល ការប្រតិបត្តិប្រព័ន្ធបង្ហូរឬធ្វើប្រព្រឹត្តិកម្មទឹកស្អុយ ការប្រមូលនិងការដឹកជញ្ជូនទឹកស្អុយ ដែលបញ្ចេញចោលពីគ្រួសារឬឧស្សាហកម្ម ពីអ្នកប្រើប្រាស់ម្នាក់ឬច្រើននាក់ ព្រមទាំងទឹកភ្លៀងផង តាមរយៈបណ្តាញទឹកស្អុយ អ្នកប្រមូល អាងស្តុក និងមធ្យោបាយដឹកជញ្ជូនដទៃទៀត(ឡានបូមលូ ។ល។) ការស្តារនិងសម្អាតរណ្តៅឬអាងស្តុកលាមក និងអាងឬរណ្តៅស្តុកទឹកស្អុយ ការផ្តល់សេវាកម្មដាក់ថ្នាំគីមីក្នុងបង្គន់ ការធ្វើប្រព្រឹត្តិកម្មទឹកស្អុយ (រួមមាន ទឹកស្អុយដែលបញ្ចេញចោលពីគ្រួសារឬឧស្សាហកម្ម ទឹកស្អុយបញ្ចេញមកពីអាងហែលទឹក។ល។) តាមរយៈដំណើរការរូបសាស្ត្រ គីមីសាស្ត្រ និងជីវសាស្ត្រ ដូចជា ការបន្សាប ការពិនិត្យ ការធ្វើប្រព្រឹត្តិកម្មការបង្កកំណរ។ល។ និងការថែទាំនិងសម្អាតបំពង់និងលូ រាប់ទាំងការបុកចូលបំពង់លូផងដែរ។

ជំពូក ង ៖ ការផ្គត់ផ្គង់ទឹកស្អាត ការគ្រប់គ្រងនិងកែច្នៃទឹកស្អុយនិងកាកសំណល់

ផ្នែក ៣៧ ៖ ប្រព័ន្ធទឹកស្អុយ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៣៧០			**ប្រព័ន្ធទឹកស្អុយ**
	៣៧០០		ប្រព័ន្ធទឹកស្អុយ
		៣៧០០០	ប្រព័ន្ធទឹកស្អុយនិងសកម្មភាពស្រដៀងគ្នា[១]

(១) **រាប់បញ្ចូល**

(ក) ការប្រតិបត្តិប្រព័ន្ធបង្ហូរឬប្រព័ន្ធទឹកស្អុយ

(ខ) ការប្រមូលនិងការដឹកជញ្ជូនទឹកស្អុយដែលបញ្ចេញចោលពីគ្រួសារឬឧស្សាហកម្ម ពីអ្នកប្រើប្រាស់ម្នាក់ឬច្រើននាក់ ព្រមទាំងទឹកភ្លៀងផងតាមរយៈបណ្តាញទឹកស្អុយអ្នកប្រមូល អាងស្តុកនិងមធ្យោបាយដឹកជញ្ជូនដទៃទៀត (ឡានបូមលូ ។ល។)

(គ) ការស្តារនិងសម្អាត រណ្តៅឬអាងស្តុកលាមកនិងអាងឬរណ្តៅស្តុកទឹកស្អុយ ការផ្តល់សេវាកម្មដាក់ថ្នាំគីមីក្នុងបង្គន់

(ឃ) ប្រព័ន្ធទឹកស្អុយ (រួមមានទឹកស្អុយដែលបញ្ចេញចោលពីគ្រួសារឬឧស្សាហកម្ម ទឹកស្អុយបញ្ចេញមកពីអាងហែលទឹក ។ល។) តាមរយៈដំណើរការរូបសាស្ត្រ គីមីសាស្ត្រ និងជីវសាស្ត្រ ដូចជា ការបន្សាប ការពិនិត្យ ការធ្វើប្រព្រឹត្តិកម្ម ការបង្កកំណរ ។ល។

(ង) ការថែទាំនិងសម្អាតបំពង់និងលូ រាប់ទាំងការបុកចូលបំពង់លូផងដែរ។

ផ្នែក ៣៨ ៖ សកម្មភាពប្រមូល ការធ្វើប្រព្រឹត្តិកម្មសម្អាត និងបញ្ចេញចោលកាកសំណល់, ការកែច្នៃកាកសំណល់

ផ្នែកនេះរាប់បញ្ចូលការប្រមូល ការធ្វើប្រព្រឹត្តិកម្មសម្អាត និងការបញ្ចេញចោលសារធាតុកាកសំណល់។ ផ្នែកនេះរាប់បញ្ចូលផងដែរនូវការដឹកសម្ភារៈកាកសំណល់ក្នុងស្រុក និងការប្រតិបត្តិឧបករណ៍កែច្នៃកាកសំណល់ សម្រាប់ធ្វើជាវត្ថុធាតុដើមប្រើប្រាស់ឡើងវិញ (ឧ. រោងចក្រដែលញែកយកវត្ថុធាតុដើមដែលអាចប្រើប្រាស់ឡើងវិញចេញពីកាកសំណល់)។

ក្រុម ៣៨១ ៖ ការប្រមូលកាកសំណល់

ក្រុមនេះរាប់បញ្ចូល ការប្រមូលកាកសំណល់ពីគ្រួសារ និងអាជីវកម្មដោយមធ្យោបាយនានា ដូចជា ធុងសំរាម ធុងសំរាមមានកង់ និងវត្ថុផ្ទុកផ្សេងៗ ។ល។ ក្រុមនេះរាប់បញ្ចូលផងដែរនូវការប្រមូលកាកសំណល់ដែលមាន និងគ្មានគ្រោះថ្នាក់ ដូចជា៖ កាកសំណល់ពីគ្រួសារ ថ្មពិលដែលប្រើរួច សារជាតុខ្លាញ់ និងប្រេងចម្អិនអាហារដែលប្រើរួច កាកសំណល់ប្រេងរំអិលបានពីកប៉ាល់ និងប្រេងរំអិលដែលប្រើរួចនៅតាមយានដ្ឋានរួមទាំងកាកសំណល់ពីសំណង់និងកម្ទេចកំទីពីការវាយកម្ទេចអគារ។

ក្រុម ៣៨២ ៖ ការធ្វើប្រព្រឹត្តិកម្មសម្អាត និងបញ្ចេញចោលកាកសំណល់

ក្រុមនេះរាប់បញ្ចូលការបញ្ចេញចោលនិងធ្វើប្រព្រឹត្តិកម្មសម្អាតកាកសំណល់មុនពេលបញ្ចេញចោល(ដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន) នូវកាកសំណល់គ្រប់ប្រភេទ ដោយប្រើមធ្យោបាយខុសៗគ្នា ដូចជា ការធ្វើប្រព្រឹត្តិកម្មកាកសំណល់សរីរាង្គ ដើម្បីយកទៅបោះចោល ការធ្វើប្រព្រឹត្តិកម្ម និងការបោះចោល នូវសត្វស្លាប់ឬរស់ ដែលមានផ្ទុកសារជាតុពុល និងកាកសំណល់ដែលមានមេរោគឆ្លងផ្សេងទៀត ការធ្វើប្រព្រឹត្តិកម្មនិងបញ្ចេញចោល នូវកាកសំណល់វិទ្យុសកម្មពីមន្ទីរពេទ្យនានា ។ល។ ការបញ្ចេញចោលកាកសំណល់លើដីឬក្នុងទឹក, ការកប់ឬភ្ជួរដីលុបកាកសំណល់ ការបោះចោលសម្ភារៈដែលប្រើរួច ដូចជា ទូទឹកកក ជាដើមដើម្បីបំផ្លាញកាកសំណល់ដែលបង្កគ្រោះថ្នាក់ ការដុតបំផ្លាញចោលកាកសំណល់។ ក្រុមនេះក៏រាប់បញ្ចូលផងដែរ នូវការផលិតអគ្គីសនី ដែលបានមកពីការដុតកាកសំណល់។

ក្រុមនេះមិនរាប់បញ្ចូលការធ្វើប្រព្រឹត្តិកម្ម និងការបញ្ចេញចោលទឹកស្អុយនោះទេ (មើល ៣៧០០)។

ក្រុម ៣៨៣ ៖ ការកែច្នៃកាកសំណល់

ក្រុមនេះរាប់បញ្ចូល ការកែច្នៃកាកសំណល់លោហធាតុនិងមិនមែនលោហធាតុ កម្ទេច កំទីអេតចាយ និងរបស់របរផ្សេងៗទៀត ឲ្យទៅជាវត្ថុធាតុដើមបន្ទាប់បន្សំ តាមរយៈដំណើរការ បំប្លែងផ្នែកគីមីឬមេកានិច។ ក្រុមនេះរាប់បញ្ចូលផងដែរ ការទាញយកវត្ថុធាតុដែលអាចប្រើប្រាស់ឡើងវិញពីកាកសំណល់តាមរយៈការញែក និងចែកវត្ថុធាតុដែលអាចប្រើប្រាស់បានចេញពីគំនរកាកសំណល់ដែលគ្មានគ្រោះថ្នាក់(ដូចជាសំរាម) និងការញែក និងចែកវត្ថុធាតុដែលអាចប្រើប្រាស់បានវិញដែលនៅលាយឡំជាមួយគ្នា ដូចជា ក្រដាស ថង់ប្លាស្ទិក សម្បកកំប៉ុងភេសជ្ជៈ និងលោហធាតុឲ្យទៅតាមប្រភេទផ្សេងៗគ្នា។

ឧទាហរណ៍នៃដំណើរការបំប្លែងផ្នែកគីមីឬមេកានិច ដែលត្រូវបានអនុវត្តនោះ មានដូចជា ការប្រើគ្រឿងចក្រកិនកាកសំណល់លោហធាតុ ដូចជា រថយន្តម៉ាស៊ីនបោក សម្លៀកបំពាក់ កង់ ដែលបានប្រើរួច ។ល។ ដោយមានការញែក និងចែកចេញពីគ្នាជាបន្តបន្ទាប់ ការកម្ទេចយានយន្ត កុំព្យូទ័រ ទូរទស្សន៍ និងឧបករណ៍ដទៃទៀត ដើម្បីទាញយកវត្ថុធាតុដើមដែលអាចប្រើប្រាស់ឡើងវិញ ការកាត់គ្រោងដែកធំៗ ដោយប្រើគ្រឿងចក្រ ដូចជា ទូររថភ្លើងជាដើម ការជ្រៀកកាកសំណល់លោហធាតុ និងយានយន្តឈប់ប្រើ ។ល។ វិធីសាស្ត្រមេកានិចដទៃទៀត ដូចជា ការកាត់ ការសង្កត់ ដើម្បីឲ្យតូច ការជ្រៀកបំបែកកប៉ាល់ ការទាញយកលោហធាតុចេញពីកាកសំណល់រូបថត ដូចជា ល្បាយសូលុយស្យុងឬក៏ហ្វីល និងក្រដាសរូបថត ការទាញយកជ័រកៅស៊ូ ដូចជា សម្បកកង់ដែលប្រើរួច ដើម្បីផលិតជាវត្ថុធាតុដើមបន្ទាប់បន្សំ ការញែកនិងរុំសារធាតុប្លាស្ទីក ដើម្បីធ្វើជាវត្ថុធាតុដើមបន្ទាប់បន្សំ សម្រាប់ធ្វើបំពង់ទីប ផើងផ្កា ជើងទម្រ និងរបស់របរផ្សេងៗទៀត ការកែច្នៃ(ការសម្អាត ការរំលាយនិងការកិន) នូវកាកសំណល់ថង់ប្លាស្ទិកឬជ័រកៅស៊ូ ដើម្បីឲ្យទៅជាគ្រាប់តូចល្អិត ការកម្ទេច ការសម្អាត និងការញែក នូវកាកសំណល់កែវ ការកម្ទេច ការសម្អាត និងការញែក នូវកាកសំណល់ដទៃទៀត ដូចជា ការកម្ទេចកាកសំណល់ដើម្បីទទួលបានវត្ថុធាតុដើមបន្ទាប់បន្សំ ការកែច្នៃប្រេងសម្រាប់ចម្អិននិងសារធាតុខ្លាញ់ដែលប្រើរួច ឲ្យក្លាយជាវត្ថុធាតុដើមបន្ទាប់បន្សំ ការកែច្នៃកាកសំណល់ម្ហូបអាហារផ្សេងៗ ដូចជា ភេសជ្ជៈនិងថ្នាំជក់ និងសារធាតុសំណល់ ឲ្យក្លាយទៅជាវត្ថុធាតុដើមបន្ទាប់បន្សំ។

ជំពូក ង ៖ ការផ្គត់ផ្គង់ទឹកស្អាត ការគ្រប់គ្រង និងកែច្នៃទឹកស្អុយនិងកាកសំណល់

ផ្នែក ៣៨ ៖ សកម្មភាពប្រមូល ធ្វើប្រព្រឹត្តិកម្មសម្អាត និងបញ្ចេញចោលកាកសំណល់, ការកែច្នៃកាកសំណល់

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៣៨១			**ការប្រមូលកាកសំណល់**
	៣៨១១[១]		ការប្រមូលកាកសំណល់ដែលមិនគ្រោះថ្នាក់
		៣៨១១០	ការប្រមូលកាកសំណល់រឹង ដែលគ្មានគ្រោះថ្នាក់ (ដូចជា សំរាម)
	៣៨១២[២]		ការប្រមូលកាកសំណល់ដែលមានគ្រោះថ្នាក់
		៣៨១២០	ការប្រមូលកាកសំណល់ដែលមានគ្រោះថ្នាក់[៣]

(១) **រាប់បញ្ចូល** កាកសំណល់ពីគ្រួសារនិងអាជីវកម្ម ដោយប្រើប្រាស់ធុងសំរាម ធុងសំរាមមានកង់ និង វត្ថុផ្ទុកផ្សេងៗ ។ល។

មិនរាប់បញ្ចូល
(ក) ការប្រមូលកាកសំណល់មានគ្រោះថ្នាក់ (មើល ៣៨១២០)
(ខ) ការកប់ចោលក្នុងដីនូវកាកសំណល់ដែលមិនបង្កគ្រោះថ្នាក់ (មើល ៣៨២១)
(គ) ការប្រតិបត្តិការរោងចក្រញែកវត្ថុធាតុ ដែលអាចយកមកប្រើប្រាស់ឡើងវិញដែលបានដាក់លាយឡំគ្នា(ដូចជា ក្រដាស ថង់ប្លាស្ទិក ។ល។) ទៅតាមប្រភេទផ្សេងៗគ្នា (មើល ៣៨៣០)។

(២) **មិនរាប់បញ្ចូល** ការកម្ចាត់ជាតិពុលនិងជាតុកខ្វក់ និងការសម្អាត នូវអគារដែលកខ្វក់ ទីកន្លែងយករ៉ែ ដីនិងទឹកក្នុងដី ជាឧទាហរណ៍ ការយកចេញរូបធាតុដែលមិនឆេះ(មើល ៣៩០០)។

(៣) **រាប់បញ្ចូល**
(ក) ប្រេងរំអិលដែលប្រើរួច បានមកពីការដឹកជញ្ជូនឬយានដ្ឋាន កាកសំណល់ជីវសាស្រ្តដែលមានគ្រោះថ្នាក់ ថ្មពិលដែលប្រើរួច ។ល។
(ខ) ការប្រមូលនិងបំប្លែងកាកសំណល់នុយក្លេអ៊ែរដែលមានជាតុវិទ្យុសកម្ម។

ជំពូក ង ៖ ការផ្គត់ផ្គង់ទឹកស្អាត ការគ្រប់គ្រងនិងកែច្នៃទឹកស្អុយនិងកាកសំណល់

ផ្នែក ៣៨ ៖ សកម្មភាពប្រមូល ធ្វើប្រព្រឹត្តិកម្មសម្អាត និងបញ្ចេញចោលកាកសំណល់, ការកែច្នៃកាកសំណល់

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៣៨២[១]			**ការធ្វើប្រព្រឹត្តិកម្មសម្អាត និងបញ្ចេញចោលកាកសំណល់**
	៣៨២១[២]		ការធ្វើប្រព្រឹត្តិកម្មសម្អាតនិងបញ្ចេញចោលកាកសំណល់ដែលគ្មានគ្រោះថ្នាក់
		៣៨២១០	ការធ្វើប្រព្រឹត្តិកម្មសម្អាត និងបញ្ចេញចោលកាកសំណល់ដែលគ្មានគ្រោះថ្នាក់[៣]
	៣៨២២[៤]		ការធ្វើប្រព្រឹត្តិកម្មសម្អាត និងបញ្ចេញចោលកាកសំណល់ដែលមានគ្រោះថ្នាក់
		៣៨២២០	ការធ្វើប្រព្រឹត្តិកម្មសម្អាត និងបញ្ចេញចោលកាកសំណល់ដែលមានគ្រោះថ្នាក់[៥]

(១) **មិនរាប់បញ្ចូល** ការធ្វើប្រព្រឹត្តិកម្មសម្អាតនិងបញ្ចេញចោលកាកសំណល់ទឹក (មើល ៣៧០០)។

(២) **មិនរាប់បញ្ចូល**
(ក) ការដុតកាកសំណល់ដែលមានគ្រោះថ្នាក់ (មើល ៣៨២២)
(ខ) ការប្រតិបត្តិការរោងចក្រដែលលាយវត្ថុធាតុដែលអាចយកមកប្រើប្រាស់ឡើងវិញដែលបានដាក់លាយឡំគ្នា(ដូចជា ក្រដាស ថង់ប្លាស្ទិក។ល។) និងចែកតាមប្រភេទផ្សេងៗគ្នា (មើល ៣៨៣០)
(គ) ការធ្វើឲ្យអស់ជាតុដែលបង្កគ្រោះថ្នាក់ការសម្អាតដីនិងទឹក ការកាត់បន្ថយឥទ្ធិពលនៃសារធាតុដែលមានជាតិពុល (មើល ៣៩០០០)។

(៣) **រាប់បញ្ចូល**
(ក) ផលិតកម្មអគ្គីសនីតាមរយៈការដុតកាកសំណល់
(ខ) ការបំប្លែងកាកសំណល់សរីរាង្គសម្រាប់បញ្ចេញចោល
(គ) ការទាញយកថាមពលពីដំណើរការដុតកាកសំណល់ដែលគ្មានគ្រោះថ្នាក់
(ឃ) ការប្រតិបត្តិការកន្លែងដាក់ដីកំប៉ុស្តិ៍
(ង) ផលិតកម្មដីកំប៉ុស្តិ៍ពីកាកសំណល់សរីរាង្គ។

(៤) **មិនរាប់បញ្ចូល**
(ក) ការដុតកាកសំណល់ដែលគ្មានគ្រោះថ្នាក់ (មើល ៣៨២១)
(ខ) ការកំចាត់សារធាតុដែលបង្កគ្រោះថ្នាក់ការសម្អាតដីនិងទឹក ការកាត់បន្ថយឥទ្ធិពលនៃសារធាតុដែលមានជាតិពុល (មើល ៣៩០០)។

(៥) **រាប់បញ្ចូល**
(ក) ការបញ្ចេញចោលទំនិញដែលប្រើរួច ដូចជា ទូទឹកកក ដើម្បីលុបបំបាត់កាកសំណល់ដែលបង្កគ្រោះថ្នាក់
(ខ) ការបំប្លែងនិងបញ្ចេញចោលកាកសំណល់វិទ្យុសកម្មពីមន្ទីរពេទ្យ
(គ) ការបំប្លែងនិងបញ្ចេញចោលនូវ សារធាតុពុល កាកសំណល់ដែលមានមេរោគឆ្លង។

ជំពូក ង ៖ ការផ្គត់ផ្គង់ទឹកស្អាត ការគ្រប់គ្រងនិងកែច្នៃទឹកស្អុយនិងកាកសំណល់

ផ្នែក ៣៨ ៖ សកម្មភាពប្រមូល ធ្វើប្រព្រឹត្តិកម្មសម្អាត និងបញ្ចេញចោលកាកសំណល់, ការកែច្នៃកាកសំណល់

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៣៨៣			**ការកែច្នៃកាកសំណល់**
	៣៨៣០[១]		ការកែច្នៃកាកសំណល់
		៣៨៣០០	ការកែច្នៃកាកសំណល់[២]

(១) **រាប់បញ្ចូល** ការទាញយកវត្ថុធាតុល្អចេញពីកាកសំណល់ដើម្បីមកប្រើឡើងវិញដោយធ្វើតាមរូបភាពនៃការញែក និងចែកវត្ថុធាតុដែលអាចយកមកប្រើជាថ្មី ឲ្យដាច់ចេញពីកាកសំណល់គ្រោះថ្នាក់(ដូចជា សំរាម) ឬញែកចែកវត្ថុធាតុដែលនៅលាយឡំគ្នា ដូចជាក្រដាសថង់ប្លាស្ទីក ។ល។

មិនរាប់បញ្ចូល
- (ក) ការផលិតផលិតផលសម្រេចថ្មីពី (ទោះជាបាន ឬមិនបានផលិតដោយខ្លួនឯង) ចេញពីវត្ថុធាតុដើមលោហៈបន្ទាប់បន្សំ ដូចជាការធ្វើសាច់ក្រដាសពីកាកសំណល់ការធ្វើក្រដាសកាកសំណល់ក្រដាស ការចាក់ក្រឡាសម្បកកង់ឡើងវិញ ឬផលិតដែកចេញពីកម្ទេចដែក (មើលថ្នាក់ដូចគ្នានេះនៅក្នុងជំពូក «គ» កម្មន្តសាល)
- (ខ) ការរំលាយឡើងវិញនូវកាកសំណល់ដែលមានជាតិដែកនិងកម្ទេចដែក (មើល ២៤១០៩)
- (គ) ការបំប្លែង និងបញ្ចេញចោលកាកសំណល់គ្មានគ្រោះថ្នាក់ (មើល ៣៨២១០)
- (ឃ) ការបំប្លែងកាកសំណល់សរីរាង្គសម្រាប់បញ្ចេញចោល (មើល ៣៨២១០)
- (ង) ការទាញយកថាមពល ពីដំណើរការដុតកាកសំណល់ដែលគ្មានគ្រោះថ្នាក់ (មើល ៣៨២១០)
- (ច) ការបញ្ចេញចោលនូវទំនិញដែលបានប្រើប្រាស់រួចដូចជាទូទឹកកក ជាដើមដើម្បីលុបបំបាត់កាកសំណល់មានគ្រោះថ្នាក់ (មើល ៣៨២២០)
- (ឆ) ការបំប្លែងនិងបញ្ចេញចោលកាកសំណល់មានជាតិពុល និងកាកសំណល់កខ្វក់ (មើល ៣៨២២០)
- (ញ) ការបំបែកយានយន្តកុំព្យូទ័រទូរទស្សន៍ និងឧបករណ៍ដទៃទៀតដើម្បីទទួលបាននិងលក់វិញនូវផ្នែកណាដែលអាចប្រើបាន (មើលជំពូក«ឆ»)
- (ដ) ការលក់ដុំនូវវត្ថុធាតុដែលអាចប្រើប្រាស់ឡើងវិញបាន (មើល ៤៦៦៩)។

(២) **រាប់បញ្ចូល**
- (ក) ការកម្ទេចដោយគ្រឿងចក្រ ចំពោះកាកសំណល់លោហធាតុដូចជា រថយន្ត ម៉ាស៊ីនបោកសម្លៀកបំពាក់ កង់ នាវា ។ល។ ដោយមានការញែកនិងចែក
- (ខ) ការពុះច្រៀករថយន្តដោយដំណើរការមេកានិច
- (គ) ការចម្រាញ់កំប៉ុងយកមកប្រើប្រាស់ឡើងវិញ

រាប់បញ្ចូល ការកៀបកបាល់ ការកម្ទេច ការចម្រាញ់សរសៃអំបោះវាយនតណ្ឌមកប្រើវិញ ។ល។

មិនរាប់បញ្ចូល ការបំបែកយានយន្ត កុំព្យូទ័រ ទូរទស្សន៍ និងឧបករណ៍ដទៃទៀតដើម្បីទទួលបាន និងលក់វិញនូវផ្នែកណាដែលអាចប្រើបាន (មើល ៤៦៦៥២)។

ផ្នែក ៣៩ ៖ សកម្មភាពប្រព្រឹត្តិកម្មសម្អាត និងសេវាកម្មគ្រប់គ្រងកាកសំណល់ដទៃទៀត

ផ្នែកនេះរាប់បញ្ចូល ការផ្តល់សេវាកម្មប្រព្រឹត្តិកម្មសម្អាត ជាឧទាហរណ៍ ការសម្អាតនូវអគារនិងទីកន្លែងដែលកខ្វក់ ដី ទឹកក្រោមដីឬលើដី។

ក្រុម ៣៩០ ៖ សកម្មភាពប្រព្រឹត្តិកម្មសម្អាត និងសេវាកម្មគ្រប់គ្រងកាកសំណល់ដទៃទៀត

ក្រុមនេះរាប់បញ្ចូល ការកម្ចាត់ជាតុកខ្វក់ពីដីនិងទឹកក្រោមដី នៅឯទីតាំងដែលមានការបំពុលទាំងនៅទីតាំងដើមធម្មជាតិនិងមិនមែនទីតាំងដើមធម្មជាតិ ដោយប្រើប្រាស់វិធីសាស្ត្រ ដូចជា មេកានិច គីមីសាស្ត្រ ឬជីវសាស្ត្រ ការកម្ចាត់ជាតុកខ្វក់ពីទីតាំងឬរោងចក្រឧស្សាហកម្ម រួមមាន ទីតាំងនិងរោងចក្រនុយក្លេអ៊ែរ ការកម្ចាត់សារជាតុកខ្វក់ និងការសម្អាតផ្ទៃទឹកបន្ទាប់ពីមានការបំពុលដោយចៃដន្យ ដូចជា តាមរយៈការប្រមូលជាតិពុល ឬតាមរយៈការប្រើប្រាស់ជាតិគីមី ការសម្អាតការកំពប់ប្រេង និងការបំពុលផ្សេងៗនៅលើគោក លើផ្ទៃទឹក ក្នុងសមុទ្រនិងមហាសមុទ្រ រួមមាន តំបន់ឆ្នេរ ការកាត់បន្ថយឥទ្ធិពលសារជាតុដែលមិនឆេះ ថ្នាំលាប និងសារជាតុមានជាតិពុលផ្សេងៗទៀត ការបោសសម្អាតគ្រាប់មីនកប់ក្នុងដី និងវត្ថុដូចគ្នានេះ (រួមទាំងការបំផ្ទុះ) និងសកម្មភាពត្រួតពិនិត្យការបំពុល ដែលលក្ខណៈឯកទេសឯទៀត។

ជំពូក ង ៖ ការផ្គត់ផ្គង់ទឹកស្អាត ការគ្រប់គ្រង និងកែច្នៃទឹកស្អុយ និងកាកសំណល់
ផ្នែក ៣៩ ៖ សកម្មភាពប្រព្រឹត្តិកម្មសម្អាត និងសេវាកម្មគ្រប់គ្រងកាកសំណល់ដទៃទៀត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៣៩០			**សកម្មភាពប្រព្រឹត្តិកម្មសម្អាត និងសេវាកម្មគ្រប់គ្រងកាកសំណល់ដទៃទៀត**
	៣៩០០(១)		សកម្មភាពប្រព្រឹត្តិកម្មសម្អាត និងសេវាកម្មគ្រប់គ្រងកាកសំណល់ដទៃទៀត
		៣៩០០០	សកម្មភាពប្រព្រឹត្តិកម្មសម្អាតនិងសេវាកម្មគ្រប់គ្រងកាកសំណល់ដទៃទៀត(២)

(១) **រាប់បញ្ចូល**
(ក) ការកម្ចាត់ជាតុកខ្វក់ពីដីនិងទឹកក្រោមដីនៅឯទីតាំងដែលមានការបំពុល ទាំងនៅទីតាំងដើមធម្មជាតិនិងមិនមែនទីតាំងដើមធម្មជាតិ ដោយប្រើប្រាស់វិធីសាស្ត្រ ដូចជាមេកានិចគីមីសាស្ត្រ ឬជីវសាស្ត្រ
(ខ) ការកម្ចាត់ជាតុកខ្វក់ពីទីតាំងឬរោងចក្រឧស្សាហកម្មរួមមានទីតាំងនិងរោងចក្រនុយក្លេអ៊ែរ
(គ) ការកម្ចាត់សារធាតុកខ្វក់ និងការសម្អាតផ្ទៃទឹកបន្ទាប់ពីមានការបំពុលដោយចៃដន្យ ដូចជាតាមរយៈការប្រមូលជាតិពុល ឬតាមរយៈការប្រើប្រាស់ជាតិគីមី
(ឃ) ការសម្អាតការកំពប់ប្រេង និងការបំពុលផ្សេងៗនៅលើគោក លើផ្ទៃទឹកក្នុងសមុទ្រនិងមហាសមុទ្រ រួមមានតំបន់ឆ្នេរ
(ង) ការបន្ថយឥទ្ធិពលសារធាតុដែលមិនឆេះថ្នាំលាបនិងសារធាតុមានជាតិពុលផ្សេងៗទៀត
(ច) ការបោសសម្អាតគ្រាប់មីនកប់ក្នុងដី និងវត្ថុដូចគ្នានេះ (រួមទាំងការបំផ្ទុះ)
(ឆ) សកម្មភាពត្រួតពិនិត្យការបំពុលដែលលក្ខណៈឯកទេសឯទៀត។

មិនរាប់បញ្ចូល
(ក) ការកម្ចាត់ជាតិពុលនិងបញ្ចេញចោលកាកសំណល់ដែលគ្មានគ្រោះថ្នាក់ (មើល ៣៨២១០)
(ខ) ការកម្ចាត់ជាតិពុលនិងបញ្ចេញចោលកាកសំណល់ដែលគ្មានគ្រោះថ្នាក់ (មើល ៣៨២២០)
(គ) ការសម្អាតខាងក្រៅផ្ទះ និងការស្រោចទឹកសម្អាតថ្នល់ (មើល ៨១២៩៩)។

(២) **រាប់បញ្ចូល** ការសម្អាតនូវអគារនិងទីតាំងកខ្វក់ ដែលស្ថិតនៅលើដីនិងទឹក។

ជំពូក ច ៖ សំណង់

កម្រិត	ច.ស.វ.ក
ជំពូក	១
ផ្នែក	៣
ក្រុម	៨
ថ្នាក់	១១
ថ្នាក់រង	៣៤

ជំពូកនេះរាប់បញ្ចូល សកម្មភាពសាងសង់ទូទៅ និងសាងសង់ឯកទេសផ្សេងៗទៀតសម្រាប់ការងារវិស្វកម្មស៊ីវិល និងសំណង់។ វារាប់បញ្ចូលការងារសង់ថ្មី ការជួសជុល ការសង់បន្ថែម និងការកែលម្អ ការសាងសង់គ្រោងអគារនិងរចនាសម្ព័ន្ធដែលដំឡើងរួចនៅនឹងកន្លែង និងការសាងសង់ជាបណ្ដោះអាសន្ន។

សំណង់ទូទៅគឺជាការសាងសង់លំនៅឋានទាំងមូល អគារការិយាល័យ ហាងនិងអគារសាធារណៈ និងអគារសេវាកម្មសាធារណៈផ្សេងៗ អគារកសិដ្ឋាន។ល។ ឬ វាជាការសាងសង់ការងារវិស្វកម្មស៊ីវិល ដូចជា ផ្លូវសម្រាប់យានយន្ត ផ្លូវ ស្ពាន ផ្លូវក្រោមដី ផ្លូវរថភ្លើង ព្រលាន យន្តហោះ កំពងផែ គម្រោងផ្លូវទឹក ប្រព័ន្ធស្រោចស្រព ប្រព័ន្ធទឹកស្អុយ អគារឧស្សាហកម្ម បណ្ដាញទុយោ បណ្ដាញអគ្គីសនី កន្លែងសម្រាប់កីឡា។ល។

កិច្ចការនេះអាចធ្វើឡើងដោយខ្លួនឯង ឬដោយទទួលកម្រៃឈ្នួល ឬដោយម៉ៅការ។ ផ្នែកខ្លះនៃការងារ ឬពេលខ្លះការអនុវត្តការងារទាំងស្រុង អាចត្រូវបានម៉ៅការបន្ត។ អង្គភាព មួយដែលទទួលខុសត្រូវទាំងស្រុង លើគម្រោងសាងសង់មួយ ត្រូវបានចាត់ថ្នាក់នៅក្នុងជំពូកនេះ។

ការជួសជុលអគារ និងការងារវិស្វកម្ម ក៏ត្រូវបានរាប់បញ្ចូលផងដែរ។

ជំពូកនេះរាប់បញ្ចូល ការបញ្ចប់ការសាងសង់អគារទាំងស្រុង(ផ្នែក ៤១) ការបញ្ចប់ការសាងសង់ទាំងស្រុងនូវការងារសំណង់វិស្វកម្មស៊ីវិល(ផ្នែក៤២)ព្រមទាំងសកម្មភាពសាងសង់ឯកទេសប្រសិនបើជាផ្នែកមួយនៃដំណើរការសាងសង់ទាំងមូល (ផ្នែក ៤៣)។ ការជួលឧបករណ៍សាងសង់រួមទាំងប្រតិបត្តិករ គឺត្រូវបានចាត់ថ្នាក់ជាមួយសកម្មភាពជាក់លាក់ ដែលឧបករណ៍ទាំងនេះបានចូលរួមពាក់ព័ន្ធ។

ជំពូកនេះក៏រាប់បញ្ចូល ការអភិវឌ្ឍគម្រោងសាងសង់អគារ ឬការងារវិស្វកម្មស៊ីវិល ដោយរួមបញ្ចូលគ្នា នូវមធ្យោបាយផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និងរូបសាស្ត្រ ដើម្បីសម្រេចបានគម្រោងសាងសង់ សម្រាប់លក់នាពេលខាងមុខ។ ប្រសិនបើសកម្មភាពគម្រោងសាងសង់ទាំងនោះ ត្រូវធ្វើឡើងមិនមែនក្នុងគោលដៅសម្រាប់លក់ទេ ប៉ុន្តែសម្រាប់ប្រតិបត្តិការ ផ្ទាល់ខ្លួន (ដូចជាការជួលទីតាំងក្នុងអគារ សកម្មភាពផលិតក្នុងរោងចក្រនេះ។ល។) អង្គភាពនេះមិនត្រូវបានចាត់ថ្នាក់នៅក្នុងផ្នែកនេះទេ ប៉ុន្តែចាត់ថ្នាក់តាមសកម្មភាពប្រតិបត្តិការរបស់ខ្លួន (ដូចជា ផ្នែកអចលនទ្រព្យ ឧស្សាហកម្ម។ល។)។

ផ្នែក ៤១ ៖ ការសាងសង់សំណង់អគារ

ជំពូកនេះរាប់បញ្ចូលសកម្មភាពសាងសង់ទូទៅគ្រប់ប្រភេទ។ ជំពូកនេះរាប់បញ្ចូលការងារសាងសង់ថ្មី ការជួសជុល ការសង់បន្ថែម និងការកែលម្អ ការដំឡើងគ្រោងអគារ និងរចនាសម្ព័ន្ធនៅនឹងកន្លែង និងការសាងសង់ជាបណ្ដោះអាសន្ន។

ការសាងសង់សំណង់សាធារណៈថវិកាពរដ្ឋាភិបាល សំណង់សាធារណៈថវិកាវិស័យឯកជន សំណង់លំនៅឋាន សំណង់ឧស្សាហកម្ម សំណង់ពាណិជ្ជកម្ម សំណង់ទេសចរណ៍ និងសំណង់វិនិយោគ ក៏រួមបញ្ចូលក្នុងផ្នែកនេះដែរ។

ក្រុម ៤១០ ៖ ការសាងសង់សំណង់អគារ

ក្រុមនេះរាប់បញ្ចូលការសាងសង់ចប់ទាំងស្រុងនូវអគារលំនៅឋាន ឬអគារមិនមែនលំនៅឋាន ធ្វើឡើងដោយខ្លួនឯង ឬដោយទទួលកម្រៃឈ្នួល ឬដោយម៉ៅការ ។ វាអាចមានការប្រើប្រាស់សេវាកម្មផ្សេងៗពីប្រភពខាងក្រៅសម្រាប់គម្រោងសាងសង់ទាំងមូល ឬផ្នែក ណាមួយ។ ប្រសិនបើមានការសាងសង់ផ្នែកឯកទេសណាមួយនៃដំណើរការសាងសង់នេះត្រូវបានធ្វើឡើងនោះវាត្រូវបានចាត់ថ្នាក់ទៅក្នុងផ្នែក ៤៣ វិញ។

ផ្នែក ច ៖ សំណង់

ផ្នែក ៤១ ៖ ការសាងសង់អគារ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៤១០			**ការសាងសង់សំណង់អគារ**
	៤១០០[១]		ការសាងសង់សំណង់អគារ
		៤១០០១	សំណង់សាធារណៈថវិកាពរដ្ឋាភិបាល[២]
		៤១០០២	សំណង់សាធារណៈថវិកាវិស័យឯកជន[៣]
		៤១០០៣	សំណង់លំនៅឋាន[៤]
		៤១០០៤	សំណង់ឧស្សាហកម្ម[៥]
		៤១០០៥	សំណង់ពាណិជ្ជកម្ម[៦]
		៤១០០៦	សំណង់ទេសចរណ៍[៧]
		៤១០០៧	សំណង់វិនិយោគ[៨]
		៤១០០៨	សំណង់អគារផ្សេងៗទៀតដែលមិនបានរាប់បញ្ចូល[៩]

(១) **រាប់បញ្ចូល** សំណង់លំនៅឋានគ្រប់ប្រភេទដូចជា៖ ផ្ទះល្វែង ភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ផ្ទះឈើលើថ្មក្រោមស្រមាប់គ្រួសារមួយ អគារស្នាក់នៅរួម និងអគារខ្ពស់ អគារសហកម្មសិទ្ធិ អគារស្នាក់នៅរួមបណ្តុំលំនៅឋានមានលក្ខណៈដូចបុរី បេងថ្ម និង ផ្សេងៗ។

(ក) ការកែលម្អ និងរចនាម៉ូដឡើងវិញ នូវរចនាសម្ព័ន្ធលំនៅឋានដែលមានស្រាប់

(ខ) ការសង់សាងសង់ចប់ទាំងស្រុងនូវអគារលំនៅឋាន ឬអគារមិនមែនលំនៅឋានធ្វើឡើងដោយខ្លួនឯង ឬដោយទទួលកម្រៃឈ្នួល ឬដោយម៉ៅការ ។

មិនរាប់បញ្ចូល

(ក) ការដំឡើងគ្រឿងបង្គុំសំណង់ ដែលដំឡើងរួចស្រេចពីរោងចក្រ និងដែលមិនមែនធ្វើពីស៊ីម៉ង់ត៍ (មើលផ្នែក ១៦ និង២៥)

(ខ) សំណង់គ្រឹះស្ថានឧស្សាកម្ម វៀរលែងតែអគារ (មើល ៤២៩០)

(គ) សកម្មភាពវិស្វកម្មនិងស្ថាបត្យកម្ម (មើល ៧១១០)

(ឃ) សកម្មភាពគ្រប់គ្រងគម្រោងទាក់ទងនឹងសំណង់ (មើល ៧១១០២)។

(២) រាប់បញ្ចូល សំណង់សាធារណៈថវិកាពរដ្ឋាភិបាលមានដូចជា៖ សាលារៀនសាធារណៈ មន្ទីរពេទ្យ អគាររដ្ឋបាលសាធារណៈ សំណង់សាធារណៈផ្សេងៗ វត្តអារ៉ាម និងផ្សេងៗ

(៣) **រាប់បញ្ចូល** សំណង់សាធារណៈថវិកាពរដ្ឋាភិបាលមានដូចជា៖ សាលារៀន មន្ទីរពេទ្យ អគាររដ្ឋបាល ពហុកីឡដ្ឋាន ចំណតរថយន្ត កំពង់ផែ វិហាសាសនា និងផ្សេងៗ។

(៤) រាប់បញ្ចូល សំណង់លំនៅឋានមានដូចជា៖ ផ្ទះល្វែង ភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ផ្ទះឈើ ផ្ទះឈើលើថ្មក្រោម អគារសហកម្មសិទ្ធិ អគារស្នាក់នៅរួម បណ្តុំលំនៅឋានមានលក្ខណៈដូចជាបុរី បេងថ្ម និង ផ្សេងៗ។

(៥) រាប់បញ្ចូល សំណង់ឧស្សាហកម្មមានដូចជា៖ រោងចក្រ សិប្បកម្មខ្នាតតូច វារីអគ្គិសនី ឃ្លាំង និងផ្សេងៗ។

(៦) រាប់បញ្ចូល សំណង់ពាណិជ្ជកម្មមានដូចជា៖ អគារការិយាល័យ ធនាគារ ស្ថានីយប្រេងឥន្ធនៈ ភោជនីយដ្ឋាន អគារពហុមុខងារ និងផ្សេងៗ ។

(៧) រាប់បញ្ចូល សំណង់ទេសចរណ៍មានដូចជា៖ ក្លឹបកំសាន្ត កាស៊ីណូ រមណីយដ្ឋាន សួនសត្វ សណ្ឋាគារ ផ្ទះសំណាក់និងផ្សេងៗ។

(៨) រាប់បញ្ចូល សំណង់វិនិយោគមានដូចជា៖ ព្រលានយន្តហោះ តំបន់សេដ្ឋកិច្ចពិសេស ស្ថានីយវិទ្យុ និងស្ថានីយទូរទស្សន៍ផ្សេងៗ។

(៩) **រាប់បញ្ចូល** ការស្តារជួសជុលឡើងវិញនូវអគារ និងទីតាំងប្រវត្តិសាស្ត្រ។

ផ្នែក ៤២ ៖ វិស្វកម្មស៊ីវិល

ផ្នែកនេះរាប់បញ្ចូលសំណង់ទូទៅសម្រាប់ការងារវិស្វកម្មស៊ីវិល។ វារាប់បញ្ចូលការងារ សាងសង់ថ្មី ការជួសជុល ការងារសង់បន្ថែម និងការកែលម្អ ការដំឡើងគ្រោងអគារនិងរចនាសម្ព័ន្ធនៅលើទីតាំង និងការសាងសង់ជាបណ្តោះអាសន្ន។

វារាប់បញ្ចូលនូវគម្រោងសំណង់ធំៗ ដូចជាផ្លូវសម្រាប់យានយន្ត ផ្លូវ ស្ពាន ផ្លូវក្រោមដី ផ្លូវរថភ្លើង ផ្លូវយន្តហោះ ព្រលានយន្តហោះ កំពង់ផែ និងគម្រោងផ្លូវទឹកផ្សេងៗ ប្រព័ន្ធស្រោចស្រព ប្រព័ន្ធបង្ហូរទឹកស្អុយ អគារឧស្សាហកម្ម បណ្តាញទុយោ បណ្តាញអគ្គិសនី កន្លែងសម្រាប់កីឡា។ល។ កិច្ចការទាំងនេះអាចធ្វើឡើងដោយខ្លួនឯង ឬដោយទទួលកម្រៃឈ្នួល ឬដោយម៉ៅការ។ ផ្នែកខ្លះនៃការងារនោះ ឬការងារទាំមូលពេលខ្លះអាចម៉ៅការបន្តផងដែរ។

ក្រុម ៤២១ ៖ សំណង់ផ្លូវរថភ្លើង និងផ្លូវថ្នល់

ក្រុមនេះរាប់បញ្ចូលការស្ថាបនាផ្លូវថ្នល់ ផ្លូវជាតិ ផ្លូវលំ ផ្លូវសម្រាប់រថយន្ត និងផ្លូវថ្មើរជើងផ្សេងៗ ការងារផ្នែកផ្ទៃលើនៃផ្លូវធំៗ ផ្លូវ ផ្លូវលំ ស្ពាន ឬផ្លូវក្រោមដី ការសាងសង់ស្ពាន រួមទាំងស្ពានសម្រាប់ផ្លូវខ្ពស់ៗផុតពីដី ការសាងសង់ផ្លូវរថភ្លើងក្រោមដី ការសាងសង់ផ្លូវដែក និងការសាងសងផ្លូវយន្តយោះក្នុងព្រលាន។

ក្រុម ៤២២ ៖ សំណង់នៃគម្រោងសេវាកម្មសាធារណៈ

វារាប់បញ្ចូលបណ្តាញចែកចាយ និងអគារដែលពាក់ព័ន្ធ និងរចនាសម្ព័ន្ធពាក់ព័ន្ធនានា ដែលជាផ្នែកសំខាន់នៃប្រព័ន្ធទាំងនេះ។

ក្រុម ៤២៩ ៖ សំណង់នៃគម្រោងវិស្វកម្មស៊ីវិលដទៃទៀត

ក្រុមនេះរាប់បញ្ចូល សំណង់ឧស្សាហកម្មនានា វៀរលែងតែអគារ, ការសាងសង់ផ្លូវទឹក កំពង់ផែ ការងារសំណង់នៅទន្លេ ការងារនៅចំណតនាវាតូចៗ ទំនប់ ទំនប់ទឹក ទំនប់ទប់ប្រាំង ការបូមស្អាផ្លូវទឹក ការងារសំណង់ក្រៅពីសង់អគារ ការបែងចែកដីដោយមានការធ្វើឲ្យដីមានលក្ខណៈប្រសើរជាងមុន។

ផ្នែក ច ៖ សំណង់

ផ្នែក ៤២ ៖ វិស្វកម្មស៊ីវិល

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៤២១			**សំណង់ផ្លូវរថភ្លើង និងផ្លូវថ្នល់**
	៤២១០[១]		សំណង់ផ្លូវរថភ្លើង និងផ្លូវថ្នល់
		៤២១០១	សំណង់ផ្លូវ ថ្នល់ ស្ពាន និងផ្លូវក្រោមដី[២]
		៤២១០២	សំណង់ផ្លូវដែក
		៤២១០៣	សំណង់ព្រលានយន្តហោះ និងផ្លូវហោះហើរ
		៤២១០៩	សំណង់ផ្លូវរថភ្លើង និងផ្លូវថ្នល់ផ្សេងៗទៀតដែលមិនបានរាប់បញ្ចូល
៤២២			**សំណង់នៃគម្រោងសេវាកម្មសាធារណៈ**
	៤២២០[៣]		សំណង់នៃគម្រោងសេវាកម្មសាធារណៈ
		៤២២០១	សំណង់គម្រោងសេវាទឹកស្អាត ទឹកស្អុយ ប្រេង និងឧស្ម័ន
		៤២២០២	សំណង់គម្រោងសេវាកម្មអគ្គីសនី និងទូរគមនាគមន៍
		៤២២០៩	សំណង់គម្រោងសេវាកម្មសាធារណៈផ្សេងៗទៀតដែលមិនបានរាប់បញ្ចូល
៤២៩			**សំណង់នៃគម្រោងវិស្វកម្មស៊ីវិលដទៃទៀត**
	៤២៩០[៤]		សំណង់នៃគម្រោងវិស្វកម្មស៊ីវិលដទៃទៀត លើកលែងតែអគារ
		៤២៩០១	សំណង់នៃពាងចក្រចម្រាញ់ស្ករស
		៤២៩០៩	សំណង់នៃគម្រោងវិស្វកម្មនានាផ្សេងដ៏ទៃទៀតដែលមិនបានរាប់បញ្ចូល

(១) **មិនរាប់បញ្ចូល**
(ក) ការបំពាក់ភ្លើងតាមផ្លូវ និងសញ្ញាអេឡិចត្រូនិច (មើល ៤៣២១០)
(ខ) សកម្មភាពស្ថាបត្យកម្ម (មើល ៧១១០១) និងសកម្មភាពវិស្វកម្មផ្សេងៗ (មើល ៧១១០២)
(គ) សកម្មភាពគ្រប់គ្រងសំណង់ដែលទាក់ទងនឹងការងារវិស្វកម្មស៊ីវិល (មើល ៧១១០២)។

(២) **រាប់បញ្ចូល** សំណង់ផ្លូវយន្តហោះ នៅអាកាសយានដ្ឋាន។

(៣) **រាប់បញ្ចូល** ការបែងចែកដីដោយមានការធ្វើឲ្យប្រសើរជាងមុន (ដូចជា ការសង់ផ្លូវថ្នល់បន្ថែមឬហេដ្ឋារចនាសម្ព័ន្ធទឹក អគ្គីសនី។ល។)

មិនរាប់បញ្ចូល សកម្មភាពគ្រប់គ្រងគម្រោងដែលទាក់ទងការងារវិស្វកម្មស៊ីវិល (មើល ៧១១០២)

រាប់បញ្ចូល ការសាងសង់ពាងចក្រថាមពល ការខួងអណ្តូងទឹក និងស្ថានីយបូមទឹក។

(៤) **មិនរាប់បញ្ចូល** សកម្មភាពគ្រប់គ្រងគម្រោងដែលទាក់ទងទៅនឹងការងារវិស្វកម្មស៊ីវិល (មើល ៧១១០២)

រាប់បញ្ចូល
(ក) ការសាងសងបន្ថែមផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធ ។ល។
(ខ) ការបែងចែកដីដោយមានការធ្វើឲ្យប្រសើរជាងមុន
(គ) ការងារចាក់ពង្រីកផ្ទៃដីទៅក្នុងទឹក
(ឃ) សំណង់ប្រព័ន្ធបង្ហូរទឹក និងទំនប់ទឹក

(ង) សំណង់នៅសមុទ្រ និងទឹកសាប (កំពង់ផែស្ពានចូលនាវា ចំណាត់នាវា)

(ច) សំណង់គម្រោងវិស្វកម្មស៊ីវិលផ្សេងៗ (ដូចជាកន្លែងហាត់កីឡា ប្រព័ន្ធកន្លែងក្មេងលេង)

(ឆ) ការបូមស្តារទន្លេ និងផ្លូវទឹកនានាដើម្បីឲ្យទូលាយ។

ផ្នែក ៤៣ ៖ សកម្មភាពសាងសង់ឯកទេស

ផ្នែកនេះរាប់បញ្ចូល សកម្មភាពសាងសង់ឯកទេស (ពាណិជ្ជកម្មពិសេស) ឧទាហរណ៍ ការសាងសង់ផ្នែកខ្លះនៃសំណង់និងការងារវិស្វកម្មស៊ីវិល ដោយពុំមានការទទួលខុសត្រូវចំពោះគម្រោងទាំងមូល។ ជាទូទៅ វាមានលក្ខណៈជាឯកទេសក្នុងផ្នែកណាមួយ ដែលជាលក្ខណៈទូទៅនៃរចនាសម្ព័ន្ធផ្សេងៗគ្នា ដែលតម្រូវឲ្យមានជំនាញ ឬឧបករណ៍ឯកទេស ដូចជា ការខួងដី ការងារសង់គ្រឹះ ការងាររគ្រោង ការងារចាក់បេតុង ការរៀបឥដ្ឋ ការដាក់ជើងទម្រ ការចាក់គ្រឹះ ការប្រក់ដំបូល។ល។ ត្រូវបានអនុវត្ត។ ការសាងសង់រចនាសម្ព័ន្ធលោហធាតុ ក៏ត្រូវបានរាប់បញ្ចូលក្នុងផ្នែកនេះផងដែរ ដោយហេតុថាផ្នែកទាំងនេះ មិនមែនផលិតដោយអង្គភាពតែមួយ។ សកម្មភាពសាងសង់ឯកទេស គឺជាធម្មតាត្រូវបានធ្វើឡើងតាមរយៈការម៉ៅការបន្ត ប៉ុន្តែជាពិសេសនៅក្នុងជួសជុលសំណង់ ម្ចាស់ទ្រព្យជាអ្នកធ្វើផ្ទាល់។ សកម្មភាពតុបតែងបង្ហើយការសាងសង់ និងការបញ្ចប់ការសាងសង់អគារ ក៏រាប់បញ្ចូលផងដែរ។ ការជួលឧបករណ៍សាងសង់ រួមទាំងប្រតិបត្តិករ គឺត្រូវចាត់ថ្នាក់ជាមួយសកម្មភាពសាងសង់ដែលពាក់ព័ន្ធ។

សកម្មភាពការងារដំឡើងប្រពន្ធ័សេវាកម្មសាធារណៈនានា ដែលធ្វើឲ្យសំណង់អាចមានដំណើរការនោះ ក៏ត្រូវរាប់បញ្ចូលផងដែរ។ សកម្មភាពទាំងនោះតែងតែធ្វើឡើងនៅទីកន្លែងសាងសង់ ទោះបីជាផ្នែកខ្លះនៃកិច្ចការនេះ អាចត្រូវបានធ្វើនៅកន្លែងឯកទេស។ វាក៏រាប់បញ្ចូលសកម្មភាពតប្រព័ន្ធទឹក ការដំឡើងប្រព័ន្ធកម្តៅ ប្រព័ន្ធម៉ាស៊ីនត្រជាក់ អង់តែន ប្រព័ន្ធរោទិ៍ និងកិច្ចការផ្នែកអេឡិចត្រូនិច ប្រព័ន្ធក្បាលស្រោចស្រព ជណ្តើរយោង និងជណ្តើរយន្ត ។ល។ វាក៏រាប់បញ្ចូលកិច្ចការការពារ (ទឹក កម្តៅ សំឡេង) កិច្ចការលោហធាតុសន្លឹក កិច្ចការក្លាស្សេមានលក្ខណៈអាជីវកម្ម កិច្ចការបំពាក់ប្រព័ន្ធបំភ្លឺ និងប្រព័ន្ធសញ្ញាសម្រាប់ផ្លូវថ្នល់ ផ្លូវដែក ព្រលានយន្តហោះ កំពង់ផែ។ល។ សកម្មភាពជួសជុលសម្រាប់សកម្មភាពដូចលើកឡើងខាងលើ ក៏រាប់បញ្ចូលផងដែរ។

សកម្មភាពដើម្បីបញ្ចប់ការសាងសង់អគារ រួមមាន សកម្មភាពដែលរួមចំណែកដល់ការបញ្ចប់ ឬការបង្ហើយសំណង់មួយ ដូចជា ការលាបថ្នាំកំបោរបាយអ ការលាបពណ៌កម្រាលនិងឥដ្ឋ ឬសម្ភារៈស្រោបជញ្ជាំង ដូចជា ផ្ទៃក្តារ កម្រាលព្រំក្រដាសបិទជញ្ជាំង។ល។ ការចាក់ខ្សាច់ធ្វើកម្រាល ការបង្ហើយការងារផ្នែកជាងឈើ ការងារផ្នែកសំឡេង ការសម្អាតផ្ទៃខាងក្រៅ ។ល។ សកម្មភាពជួសជុល សកម្មភាពដូចបានរៀបរាប់ខាងលើ ក៏រាប់បញ្ចូលផងដែរ។

ក្រុម ៤៣១ ៖ ការវាយកម្ទេច និងការរៀបចំការដ្ឋាន

ក្រុមនេះរួមមាន សកម្មភាពក្នុងការរៀបចំការដ្ឋាន សម្រាប់សកម្មភាពសាងសង់បន្តបន្ទាប់ ជាអាទិ៍ ការរើចេញរចនាសម្ព័ន្ធដែលមានសម្រាប់។

ក្រុម ៤៣២ ៖ សកម្មភាពដំឡើងអគ្គិសនី ប្រព័ន្ធទឹក និងសកម្មភាពដំឡើងផ្សេងៗទៀត

ក្រុមនេះរាប់បញ្ចូលសកម្មភាពដំឡើងនានា ដែលគាំទ្រដំណើរការរបស់អគារ ដែលរួមមានការដំឡើងប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក (ប្រព័ន្ធទឹកស្អាត ឧស្ម័ន និងទឹកស្អុយ) ប្រព័ន្ធកម្តៅ និងប្រព័ន្ធម៉ាស៊ីនត្រជាក់ ជណ្តើរយន្ត។ល។

ក្រុម ៤៣៣ ៖ ការបញ្ចប់ និងការបង្ហើយការសាងសង់អគារ

ផ្នែកនេះរាប់បញ្ចូល ការលាបថ្នាំ និងការលម្អផ្នែកខាងក្នុងនិងខាងក្រៅនៃអគារ ឬគម្រោងសាងសង់ផ្សេងៗទៀតដែលរួមមាន សម្ភារៈបន្ទះក្តារស្តើង ការដំឡើងទ្វារ (វៀរលែងតែទ្វារស្វ័យប្រវត្តិ ឬទ្វាររឹល) បង្អួចទ្វារនិងគ្រោងបង្អួចដែលធ្វើពីឈើ និងសម្ភារៈផ្សេងៗទៀត ការដំឡើងសម្ភារៈចង្ក្រានបាយ ជណ្តើរ ការរៀបចំតុបតែងហាង និងសកម្មភាពដូចគ្នានេះ ការបំ

ពាក់គ្រឿងសង្ហារិម ការបញ្ចប់កិច្ចការផ្ទៃខាងក្នុង ដូចជា ការដាក់ពិដាន ការគ្រប់ជញ្ជាំងដោយបន្ទះឈើ ផ្នែកដែលអាចរំកិលបាន។ល។ ការក្រាល ប្រក់ ព្យួរ ឬតុបតែងលម្អក្នុងអគារឬគម្រោងសាងសង់ដទៃទៀត ការលាបថ្នាំអគារទាំងខាងក្នុងនិងខាងក្រៅ ការលាបថ្នាំរចនាសម្ព័ន្ធវិស្វកម្មស៊ីវិល ការបំពាក់កែវ កញ្ចក់។ល។ ការសម្អាតអគារថ្មីបន្ទាប់ពីសាងសង់រួច និងការបំពាក់សម្ភារៈខាងក្នុងក្នុងហាង ផ្ទះចល័ត ទូក។ល។

ក្រុម ៤៣៩ ៖ សកម្មភាពសាងសង់ឯកទេសដទៃទៀត

ក្រុមនេះរួមមាន សកម្មភាពសាងសង់ឯកទេសនៅក្នុងផ្នែកណាមួយ ដែលជាលក្ខណៈទូទៅនៃរចនាសម្ព័ន្ធប្រភេទផ្សេងៗ ដោយតម្រូវឲ្យមានជំនាញ ឬឧបករណ៍ឯកទេស កិច្ចការផ្នែកខាងក្រោមផ្ទៃ ការសាងសង់អាងទឹកខាងក្រៅអគារ ការសម្អាតដោយចំហាយ ការបាញ់ខ្សាច់ និងសកម្មភាពស្រដៀងគ្នា សម្រាប់ផ្នែកខាងក្រៅនៃអគារ និងការជួលម៉ាស៊ីនស្ទូច រួមជាមួយប្រតិបត្តិករ។

ផ្នែក ច ៖ សំណង់

ផ្នែក ៤៣ ៖ សកម្មភាពសាងសង់ឯកទេស

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្ដីអធិប្បាយ
៤៣១			**ការវាយកម្ទេច និងការរៀបចំការដ្ឋាន**
	៤៣១១		ការវាយកម្ទេច
		៤៣១១០	ការវាយកម្ទេចឬបំផ្លាញ អគារនិងរចនាសម្ព័ន្ធផ្សេងៗទៀត
	៤៣១២[(១)]		ការរៀបចំការដ្ឋាន
		៤៣១២១	ការសម្អាតការដ្ឋានសំណង់សម្រាប់ការសាងសង់ ឬយករ៉ែ[(២)]
		៤៣១២២	ការបោសសម្អាតមីន
		៤៣១២៩	ការរៀបចំការដ្ឋានសំណង់ដទៃទៀតដែលមិនបានរាប់បញ្ចូល

(១) **មិនរាប់បញ្ចូល**
- (ក) ការខួងអណ្តូងប្រេងកាត និងឧស្ម័ន (មើល ០៦១០ និង ០៦២០)
- (ខ) ការសាកល្បងខួងនិងចោះរន្ធ សម្រាប់ប្រតិបត្តិការរុករករ៉ែ (ក្រៅពីការទាញយកប្រេងនិងឧស្ម័ន) (មើល ០៩៩០០)
- (គ) ការសម្អាតជាតិពុលពីដី (មើល ៣៩០០០)
- (ឃ) ការខួងអណ្តូងទឹក (មើល ៤២២០១)
- (ង) ការខួង (មើល ៤៣៩០)
- (ច) ការរុករកប្រេងនិងឧស្ម័ន ការអង្កេតភូមិសាស្ត្រ (មើល ៧១១០៣)។

(២) **រាប់បញ្ចូល**
- (ក) ការជីក ការចាក់បំពេញដី ការពង្រាបដី ការកំណត់ប្រភេទដីនៃការដ្ឋានសំណង់ ការជីករណ្តៅ ការយកថ្មចេញ ការបំផ្ទុះ។ល។
- (ខ) ការចាក់ដីបំពេញក្នុងទឹកដើម្បីពង្រីកផ្ទៃដី
- (គ) ការជួលម៉ាស៊ីនឈូសដីដើម្បីឈូសដី
- (ឃ) ការយកចេញ និងការអភិវឌ្ឍ និងការរៀបចំទីតាំងនិងរ៉ែ (វៀរលែងតែ ប្រេងនិងឧស្ម័ន)
- (ង) កិច្ចការដែលបានធ្វើដើម្បីបង្កើត ឬរៀបចំទីតាំងសម្រាប់យករ៉ែដែក។

ផ្នែក ច ៖ សំណង់

ផ្នែក ៤៣ ៖ សកម្មភាពសាងសង់ឯកទេស

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៤៣២			**សកម្មភាពតម្លើងប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក និងសកម្មភាពដំឡើងផ្សេងៗទៀត**
	៤៣២១(១)		ការតម្លើងប្រព័ន្ធអគ្គិសនី
		៤៣២១១	ការតម្លើងប្រព័ន្ធការមេរ៉ាសុវត្ថិភាព
		៤៣២១៩	ការតម្លើងប្រព័ន្ធអគ្គិសនីផ្សេងៗដ៏ទៃទៀតដែលមិនបានរាប់បញ្ចូល
	៤៣២២(២)		ការតម្លើងប្រព័ន្ធទឹក ប្រព័ន្ធម៉ាស៊ីត្រជាក់ ប្រព័ន្ធកម្តៅ
		៤៣២២១	ការដំឡើងប្រព័ន្ធកម្តៅប្រើអគ្គិសនី
		៤៣២២២	ការតម្លើងប្រព័ន្ធកម្តៅប្រើប្រពន្ធ័សូឡា
	៤៣២៩(៣)		ការតម្លើងសំណង់ដទៃទៀត
		៤៣២៩១	ការតម្លើងជណ្តើរយន្តក្នុងអគារ
		៤៣២៩៩	ការតម្លើងសំណង់ដទៃទៀតដែលមិនបានរាប់បញ្ចូល

(១) **រាប់បញ្ចូល** ប្រព័ន្ធពន្លឺ ការតខ្សែបណ្តាញកុំព្យូទ័រ និងទូរទស្សន៍ខ្សែកាប ការតខ្សែទូរគមនាគមន៍ កញ្ច្រែងផ្កាយរណប ការតឧបករណ៍អេឡិចត្រូនិច និងសម្ភារៈប្រើប្រាស់ក្នុងផ្ទះ ប្រព័ន្ធសំឡេងរោទ៍អគ្គីភ័យនិងសន្តិសុខ។

មិនរាប់បញ្ចូល (ក) ការសាងសង់ខ្សែបណ្តាញអគ្គីសនី និងទូរគមនាគមន៍ (មើល ៤២២០២០)

(ខ) ការពិនិត្យ ឬការបញ្ជាពីចម្ងាយ នូវប្រព័ន្ធសន្តិសុខអេឡិចត្រូនិច ដូចជា ចោរ ប្រព័ន្ធរោទិ៍អគ្គីភ័យ ដែលរួមមានទាំងការជួសជុលថែទាំ (មើល ៨០២០០)។

(២) **រាប់បញ្ចូល** ជួសជុល ថែទាំជណ្តើរយោង និងជណ្តើរយន្ត។

(៣) **រាប់បញ្ចូល** ប្រព័ន្ធពន្លឺ ការតខ្សែបណ្តាញកុំព្យូទ័រ និងទូរទស្សន៍ខ្សែកាប ការតខ្សែរទូរគមនាគមន៍ កញ្ច្រែងផ្កាយរណប ការដំឡើងប្រព័ន្ធសន្តិសុខ។

រាប់បញ្ចូល ការដំឡើងជណ្តើរយោង និងជណ្តើរយន្ត ការដំឡើងឧបករណ៍នានា ក្រៅពីប្រព័ន្ធម៉ាស៊ីនត្រជាក់ ប្រព័ន្ធកម្តៅ ប្រព័ន្ធទុយោទឹក ប្រព័ន្ធអេឡិចត្រូនិច ឬក្រៅពីការដំឡើងគ្រឿងចក្រឧស្សាហកម្មនៅក្នុងអគារ និងរចនាសម្ព័ន្ធសំណង់ស៊ីវិល ដោយរួមមានការជួសជុល និងថែទាំ

មិនរាប់បញ្ចូល ការដំឡើងគ្រឿងចក្រឧស្សាហកម្ម (មើល ៣៣២០០)។

ផ្នែក ច ៖ សំណង់

ផ្នែក ៤៣ ៖ សកម្មភាពសាងសង់ឯកទេស

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៤៣៣			**ការបញ្ចប់ និងការបង្ហើយការសាងសង់អគារ**
	៤៣៣០[១]		ការបញ្ចប់ និងការបង្ហើយការសាងសង់អគារ
		៤៣៣០១	ការលាបថ្នាំនិងកិច្ចការពាក់ព័ន្ធ
		៤៣៣០២	ឥដ្ឋក្រាលជញ្ជាំង និងកម្រាល ឬក្រាលនិងសម្ភារៈផ្សេងៗ
		៤៣៣០៣	ផ្នែកជាងឈើ
		៤៣៣០៤	ការសម្អាតអគារថ្មីបន្ទាប់ពីសាងសង់
		៤៣៣០៩	ការបញ្ចប់ និងបង្ហើយការសាងសង់អគារដទៃទៀតដែលមិនបានរាប់បញ្ចូល

(១) **រាប់បញ្ចូល**

(ក) ការលាបថ្នាំនិងលម្អផ្នែកខាងក្នុងនិងខាងក្រៅនៃអគារឬគម្រោងសាងសង់ផ្សេងៗទៀត ដែលរួមមាន សម្ភារៈបន្ទះក្តាស្តើង

(ខ) ការបំពាក់ទ្វា បង្អួច គ្រោងទ្វារ ចង្ក្រាន និងជណ្តើរ

(គ) ការលាបថ្នាំផ្ទៃខាងក្នុង និងខាងក្រៅ

(ឃ) ការបំពាក់កញ្ចក់។ល។

(ង) ការសម្អាតអគារថ្មី បន្ទាប់ពីការសាងសង់

(ច) ការរៀបកម្រាលឥដ្ឋ និងសេរ៉ាមិចជញ្ជាំងបេតុងនិងថ្ម

(ឆ) ការក្រាលកម្រាលឈើ ឬឈើជារូបក្រឡា

(ជ) កម្រាល និងកម្រាលជញ្ជាំងពីម្នាងសិលា ថ្មក្រានិត ថ្មម៉ាប

(ឈ) ក្រដាសបិតជញ្ជាំង

មិនរាប់បញ្ចូល

(ក) ការដំឡើងទ្វាស្វ័យប្រវត្តិ ឬទ្វារបង្វិល (មើល ៤៣២៩០)

(ខ) ការសម្អាតផ្ទៃខាងក្នុងអគារ និងរចនាសម្ព័ន្ធអគារដទៃទៀត (មើល ៨១២១)

(គ) ការសម្អាតឯកទេសនៃផ្ទៃខាងក្នុង និងខាងក្រៅនៃអគារ (មើល ៨១២៩៩)

(ឃ) សកម្មភាពរបស់អ្នករចនាផ្ទៃខាងក្នុងនៃអគារ (មើល ៧៤១១០)

(ង) ការដំឡើង និងជួសជុលគ្រឿងសង្ហារិមដែលជាប់តែឯង (មើល ៩៥២៤០)។

ផ្នែក ច ៖ សំណង់

ផ្នែក ៤៣ ៖ សកម្មភាពសាងសង់ឯកទេស

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៤៣៩			**សកម្មភាពសាងសង់ឯកទេសដទៃទៀត**
	៤៣៩០[១]		សកម្មភាពសាងសង់ឯកទេសដទៃទៀត
		៤៣៩០១	ការជួលម៉ាស៊ីន និងឧបករណ៍សំណង់
		៤៣៩០៩	សកម្មភាពសាងសង់ឯកទេសដទៃទៀតដែលមិនបានរាប់បញ្ចូល

(១) **រាប់បញ្ចូល**

(ក) ការសាងសង់គ្រឹះ និងកិច្ចការនៅក្រោមផ្ទៃ

(ខ) ការជួលម៉ាស៊ីនស្ទូចដោយមានប្រតិបត្តិករ

(គ) ការរៀបថ្ម និងរៀបឥដ្ឋ

(ឃ) ការសង់អាងហែលទឹកនៅក្រៅផ្ទះ

(ង) សកម្មភាពសាងសង់ដែលមានជំនាញនៅក្នុងផ្នែកណាមួយដែលមានជាទូទៅក្នុងរចនាសម្ព័ន្ធប្រភេទផ្សេង ដោយតម្រូវឲ្យមានជំនាញឬឧបករណ៍ឯកទេស

(ច) កិច្ចការការពារទឹក និងការជ្រាប

(ឆ) ការបំបាត់សំណើមក្នុងអគារ

(ជ) ការខួងដី

(ឈ) ការពុតដែក

(ញ) ការប្រក់ដំបូលសម្រាប់អគារលំនៅឋាន

(ដ) ការសាងសង់បំពង់ផ្សែង និងឡឧស្សាហកម្ម

(ឋ) កិច្ចការដែលតម្រូវឲ្យមានអ្នកឯកទេសដែលចាំបាច់ត្រូវមានជំនាញក្នុងការឡើងទីខ្ពស់ និងការប្រើប្រាស់ឧបករណ៍ដែលពាក់ព័ន្ធ ដូចជា ការធ្វើការនៅទីខ្ពស់

(ឌ) ការដាក់ជើងទម្រ ឡើងទីខ្ពស់

(ឍ) ការសម្អាតដោយចំហាយ ការបាញ់ខ្សាច់។ល។

មិនរាប់បញ្ចូល ការជួលឧបករណ៍ និងគ្រឿងចក្រសំណង់ ដោយមិនមានប្រតិបត្តិករ។ល។

ជំពូក ឆ ៖ អាជីវកម្មលក់ដុំ លក់រាយ ជួសជុលយានយន្ត និងម៉ូតូគ្រប់ប្រភេទ

កម្រិត	ច.ស.វ.ក
ជំពូក	១
ផ្នែក	៣
ក្រុម	២០
ថ្នាក់	៤៨
ថ្នាក់រង	១៤៤

ជំពូកនេះរាប់បញ្ចូល ការលក់ដុំនិងលក់រាយ (ឧ. ការលក់ដោយគ្មានការបំប្លែងពីទម្រង់ដើម) ទំនិញប្រភេទណាមួយ ហើយផ្តល់នូវសេវាកម្មអមនឹងការលក់ទំនិញ។ ការលក់ដុំនិងការលក់រាយ គឺជាជំណាក់កាលចុងក្រោយនៅក្នុងការចែកចាយទំនិញ។ ជំពូកនេះក៏បានរាប់បញ្ចូលការជួសជុលម៉ូតូនិងយានយន្តផងដែរ។

ការលក់ដុំ ការលក់រាយ និងការជួសជុលម៉ូតូនិងយានយន្ត ការលក់ដុំ(លើកលែងតែការលក់ម៉ូតូនិងយានយន្ត) និងការលក់រាយ (លើកលែងតែការលក់ម៉ូតូនិងយានយន្ត) ក៏ត្រូវបានរាប់បញ្ចូលនៅក្នុងជំពូកនេះផងដែរ។

ការលក់ដោយគ្មានបំប្លែងពីភាពដើមដែលត្រូវបានចាត់ទុកថាជាសកម្មភាពបន្ទាប់បន្សំ រាប់បញ្ចូលប្រតិបត្តិការធម្មតា (ឬការរៀបចំត្រួតពិនិត្យ) ដែលពាក់ព័ន្ធទៅនឹងពាណិជ្ជកម្ម ដូចជាការរៀបផលិតផលតាមប្រភេទ ការចាត់ថ្នាក់គុណភាពផលិតផល និងការផ្គុំដំឡើងទំនិញ ការលាយទំនិញ (ដូចជាស្រាឬខ្សាច់) ការច្រកក្នុងដប (ទាំងបាននិងមិនបានសម្អាតដបជាមុន) ការវេចខ្ចប់ និងការបំបែកទំនិញពីដុំធំហើយវេចខ្ចប់ឡើងវិញជាដុំតូចៗសម្រាប់ការចែកចាយ ការស្តុកទំនិញ (ទោះជាគ្មានឬមានរក្សាទុកនៅកន្លែងត្រជាក់និងបង្កក) ការសម្អាតនិងសម្ងួតផលិតផលកសិកម្ម, ការកាត់ចេញឈើក្តារឬសន្លឹកលោហធាតុដែលជាសកម្មភាពបន្ទាប់បន្សំ។

ផ្នែក ៤៥ រាប់បញ្ចូលគ្រប់សកម្មភាពទាំងអស់ ដែលទាក់ទងទៅនឹងការលក់និងការ ជួសជុលយានយន្តនិងម៉ូតូ ចំណែកឯផ្នែក ៤៦ និងផ្នែក ៤៧ រាប់បញ្ចូលសកម្មភាពលក់ផ្សេងទៀតទាំងអស់។ ភាពខុសគ្នារវាងផ្នែក ៤៦ (ការលក់ដុំ) និងផ្នែក ៤៧ (ការលក់រាយ) គឺផ្អែកលើប្រភេទអតិថិជនដែលច្រើនជាងគេ។

ការលក់ដុំជាការលក់បន្ត (លក់ដោយមិនបំប្លែងពីទម្រង់ដើម) ទំនិញថ្មីឬទំនិញប្រើរួចទៅឲ្យអ្នកលក់រាយ អ្នកប្រើប្រាស់ដែលមានលក្ខណៈជាឧស្សាហកម្មជំនួញ ស្ថាប័នឬអាជីព, ឬលក់ទៅឲ្យអ្នកលក់ដុំផ្សេងៗទៀត ឬពាក់ព័ន្ធការធ្វើជាភ្នាក់ងារឬឈ្មួញកណ្តាលនៅក្នុងការទិញទំនិញ ឬលក់ទំនិញទៅឲ្យអ្នកប្រើប្រាស់ឬក្រុមហ៊ុន។ ប្រភេទអាជីវកម្មចម្បងរាប់បញ្ចូលទាំងឈ្មួញលក់ទំនិញដុំ ជាឧទាហរណ៍ អ្នកលក់ដុំដែលមានសិទ្ធិលើទំនិញដែលពួកគេលក់ រួមមានឈ្មួញលក់ដុំ អ្នកចែកចាយលក្ខណៈជាឧស្សាហកម្ម អ្នកនាំចូល អ្នកនាំចេញ ហើយនិងសមាគមទិញទំនិញមានលក្ខណៈសហការគ្នា សាខាលក់និងការិយាល័យលក់ (ប៉ុន្តែមិនមែនជាហាងលក់រាយ) ដែលបានស្ថិតនៅក្រោមរោងចក្រឬអង្គភាពជីករ៉ែ ដែលនៅដាច់ដោយឡែកពីរោងចក្រឬកន្លែងរុករករ៉ែ ដែលមានគោលដៅលក់ផលិតផល ហើយការិយាល័យទាំងនោះមិនមែនគ្រាន់តែទទួលយកការបញ្ជាទិញនិងដឹកជញ្ជូនទំនិញដោយផ្ទាល់ពីរោងចក្រឬកន្លែងជីករករ៉ែប៉ុណ្ណោះទេ។ ការលក់ដុំក៏រាប់បញ្ចូលផងដែរនូវឈ្មួញកណ្តាល

លក់ទំនិញ ឈ្មួញទំនិញ និងភ្នាក់ងារដែលយកកម្រៃជើងសារនិងអ្នកផ្គុំដំឡើង អ្នកទិញនិងសមាគមទិញទំនិញមានលក្ខណៈសហការគ្នាក្នុងការលក់ផលិតផលកសិដ្ឋាន។ ជាទូទៅអ្នកលក់ដុំធ្វើការផ្គុំដំឡើងរៀបតាមប្រភេទនិងចាត់ថ្នាក់គុណភាពជាលក្ខណៈរូបវន្តនូវទំនិញធំៗ បំបែកទំនិញពីដុំធំៗ វេចខ្ចប់ឡើងវិញជាដុំតូចៗសម្រាប់ការចែកចាយលក់ ឧ. ឱសថ ស្តុកទុក ក្លាស្សេ ចែកចាយ និងដំឡើងទំនិញ ចូលរួមក្នុងការផ្សព្វផ្សាយលក់សម្រាប់អតិថិជនរបស់ពួកគេ និងចូលរួមក្នុងការរចនាស្លាកសញ្ញា។

ការលក់រាយ គឺជាការលក់បន្ត (ការលក់ដោយគ្មានបំលែងទម្រង់ដើម) ទំនិញថ្មីឬទំនិញប្រើប្រាស់រួច ទៅឲ្យអ្នកប្រើប្រាស់ជាបុគ្គល ឬគ្រួសារ លក់នៅតាមហាងផ្សារទំនើបលក់ទំនិញចម្រុះ លក់តាមការបញ្ជាទិញតាមការផ្ញើសារ លក់តាមផ្ទះ ដើរលក់តូចតាច សហគមន៍អ្នកប្រើប្រាស់ កន្លែងដេញថ្លៃលក់។ល។ អ្នកលក់រាយភាគច្រើនមានសិទ្ធិលើទំនិញរបស់ពួកគេ ប៉ុន្តែអ្នកខ្លះធ្វើជាភ្នាក់ងារយកកម្រៃជើងសារនិងលក់ក្នុងលក្ខណៈផ្ញើ ឬលក់យកកម្រៃជើងសារ។

ផ្នែក ៤៥ ៖ ការលក់ដុំ ការលក់រាយ និងការជួសជុលយានយន្តនិងទោចក្រយានយន្ត

ផ្នែកនេះរាប់បញ្ចូលសកម្មភាពទាំងអស់ (លើកលែងតែការផលិតនិងការជួល) ទាក់ទងទៅនឹងទោចក្រយានយន្ត យានយន្ត ដោយរាប់បញ្ចូលទាំងឡូរីនិងឡានដឹកទំនិញ ដែលមានដូចជាការលក់ដុំនិងលក់រាយ នូវយានយន្តថ្មីនិងប្រើប្រាស់រួច ការជួសជុលនិងការថែទាំយានយន្ត ហើយនិងការលក់ដុំនិងលក់រាយនូវគ្រឿងបន្លាស់និងគ្រឿងបន្ទាប់បន្សំ នៃទោចក្រយានយន្តនិងយានយន្ត។ ផ្នែកនេះក៏រាប់បញ្ចូលផងដែរនូវសកម្មភាពរបស់ភ្នាក់ងារយកកម្រៃជើងសារដែលទាក់ទងទៅនឹងការលក់ដុំ និងលក់រាយយានយន្ត។ ក្នុងផ្នែកនេះក៏រាប់បញ្ចូលសកម្មភាព ដូចជាការលាងការសម្អាត ការប៉ូលាយានយន្តផងដែរ។ល។

ផ្នែកនេះមិនបានរាប់បញ្ចូលការលក់រាយប្រេងសាំង ផលិតផលប្រេងរំអិល ផលិតផលស្ងួត ឬការជួលទោចក្រយានយន្ត និងយានយន្តនោះទេ។

ក្រុម ៤៥១ ៖ ការលក់យានយន្ត

ក្រុមនេះរាប់បញ្ចូលការលក់ដុំនិងលក់រាយយានយន្តថ្មីនិងប្រើប្រាស់រួច ការលក់ដុំនិង លក់រាយយានយន្តសម្រាប់ជិះចូលផ្លូវពិបាកៗ (ដូចជារថយន្តហ្ស៊ីប។ល។) ការលក់ដុំនិងលក់រាយដោយភ្នាក់ងារយកកម្រៃជើងសារ និងការលក់រថយន្តដោយដេញថ្លៃ។

ក្រុម ៤៥២ ៖ ការថែទាំនិងការជួសជុលយានយន្ត

ក្រុមនេះរាប់បញ្ចូលការថែទាំនិងជួសជុលយានយន្ត ការជួសជុលកៅស៊ូកង់ឡាននិងពោះវៀនកង់ ការកម្ចាត់ច្រែះ ការដំឡើងគ្រឿងបន្លាស់និងគ្រឿងបន្ទាប់បន្សំ ដែលមិនបានដំឡើងពីរោងចក្រ។

ក្រុម ៤៥៣ ៖ ការលក់គ្រឿងបន្លាស់យានយន្តនិងគ្រឿងបន្ទាប់បន្សំ

ក្រុមនេះរាប់បញ្ចូលការលក់ដុំនិងលក់រាយរាល់គ្រឿងបន្លាស់យានយន្ត គ្រឿងបន្លាស់ គ្រឿងបរិក្ខារ ឧបករណ៍ និងគ្រឿងបន្ទាប់បន្សំសម្រាប់យានយន្ត។

ក្រុម ៤៥៤ ៖ ការលក់ ថែទាំ និងជួសជុលទោចក្រយានយន្ត និងគ្រឿងបន្លាស់និងគ្រឿងបន្ទាប់បន្សំដែលពាក់ព័ន្ធ

ក្រុមនេះរាប់បញ្ចូលការលក់ដុំនិងលក់រាយទោចក្រយានយន្តដូចជា៖ កង់មានម៉ាស៊ីន ការលក់ដុំនិងលក់រាយគ្រឿងបន្លាស់និងគ្រឿងបន្ទាប់បន្សំរបស់ទោចក្រយានយន្ត (ដោយរាប់បញ្ចូលការលក់ដោយភ្នាក់ងារយកកម្រៃជើងសារ និងកន្លែងបញ្ជាទិញតាមសារ) ហើយនិងការថែទាំនិងការជួសជុលយានយន្ត។

ជំពូក ធ ៖ អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទ

ផ្នែក ៤៥ ៖ ការលក់ដុំ ការលក់រាយ និងការជួសជុលយានយន្តនិងទោចក្រយានយន្ត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៤៥១			**ការលក់យានយន្ត**
	៤៥១០[១]		លក់ដុំនិងរាយយានយន្តថ្មីៗ និងយានយន្តប្រើប្រាស់រួច
		៤៥១០១	លក់ដុំនិងរាយនូវយានយន្តថ្មី
		៤៥១០២	លក់ដុំនិងរាយនូវយានយន្តដែលប្រើប្រាស់រួច
		៤៥១០៣	លក់នូវយានយន្តថ្មីសម្រាប់ឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម[២]
		៤៥១០៤	លក់នូវយានយន្តប្រើរួចសម្រាប់ឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម
៤៥២			**ការថែទាំ និងការជួសជុលយានយន្ត**
	៤៥២០[៣]		ការថែទាំ និងការជួសជុលយានយន្ត
		៤៥២០១	ការថែទាំ និងការជួសជុលយានយន្ត រួមទាំងការសណ្តោងយានយន្ត
		៤៥២០២	លាបថ្នាំ និងបាញ់ថ្នាំ។ល។
		៤៥២០៣	លាង និងប៉ូលាយានយន្ត
		៤៥២០៤	ជួសជុលកៅអីយានយន្ត
		៤៥២០៥	ជួសជុលកង់ និងពោះវៀនកង់ការផ្លាស់ប្តូរ ឬការប៉ះពោះវៀនធ្លាយ
		៤៥២០៦	ការដំឡើងគ្រឿងបន្លាស់ និងគ្រឿងបន្ទាប់បន្សំផ្សេងៗដែលមិនបានដំឡើងពីរោងចក្រ
៤៥៣			**ការលក់គ្រឿងបន្លាស់យានយន្ត និងគ្រឿងបន្ទាប់បន្សំ**
	៤៥៣០[៤]		ការលក់គ្រឿងបន្លាស់យានយន្ត និងគ្រឿងបន្ទាប់បន្សំ
		៤៥៣០០	ការលក់ដុំនិងលក់រាយរាល់គ្រឿងបន្លាស់យានយន្ត គ្រឿងបន្លាស់ គ្រឿងបរិក្ខារ ឧបករណ៍ និងគ្រឿងបន្ទាប់បន្សំសម្រាប់យានយន្ត[៥]

(១) **មិនរាប់បញ្ចូល** (ក) ការលក់ដុំ និងលក់រាយគ្រឿងបន្លាស់ និងគ្រឿងបន្ទាប់បន្សំសម្រាប់បំពាក់យានយន្ត (មើល ៤៥៣០០)
(ខ) ការជួលយានយន្ត រួមទាំងអ្នកបើកបរ (មើល ៤៩២២៣)
(គ) ការជួលរថយន្តដឹកទំនិញ រួមអ្នកបើកបរ (មើល ៤៩២៣០)
(ឃ) ការជួលយានយន្ត រថយន្តដឹកទំនិញដោយមិនមានអ្នកបើកបរ (មើល ៧៧១០)។

(២) **រាប់បញ្ចូល** ការលក់រថយន្តដឹកទំនិញ រថយន្តសណ្តោង ពាក់កណ្តាលសណ្តោងត្រាក់ទ័រ។ល។

(៣) **មិនរាប់បញ្ចូល** ការអ៊ិតក្រឡាសម្បកកង់ថ្មី ឬការធ្វើសម្បកកង់រថយន្តជាថ្មី (មើល ២២១១០)។

(៤) **មិនរាប់បញ្ចូល** ការលក់រាយប្រេងឥន្ធនៈយានយន្ត (មើល ៤៧៣០០)។

(៥) **រាប់បញ្ចូល** ការលក់ដុំនិងលក់រាយកៅស៊ូកង់ពោះវៀនកង់ ក្បាលប៊ូស៊ីអាគុយ ឧបករណ៍ភ្លើង និងគ្រឿងបន្លាស់អគ្គិសនី។

ជំពូក ធ ៖ អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទ
ផ្នែក ៤៥ ៖ ការលក់ដុំ ការលក់រាយ និងការជួសជុលយានយន្តនិងទោចក្រយានយន្ត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៤៥៤			**ការលក់ថែទាំនិងជួសជុលទោចក្រយានយន្ត និងគ្រឿងបន្លាស់និងគ្រឿងបន្ទាប់បន្សំដែលពាក់ព័ន្ធ**
	៤៥៤០[១]		ការលក់ថែទាំនិងជួសជុលទោចក្រយានយន្ត និងគ្រឿងបន្លាស់និងគ្រឿងបន្ទាប់បន្សំដែលពាក់ព័ន្ធ
		៤៥៤០១	លក់ដុំនិងលក់រាយនូវទោចក្រយានយន្ត រួមទាំងកង់មានម៉ាស៊ីន
		៤៥៤០២	លក់ដុំនិងលក់រាយ រួមទាំងការកម្ម៉ង់តាមសារនូវគ្រឿងបន្លាស់និងគ្រឿងបន្ទាប់បន្សំទោចក្រយានយន្ត
		៤៥៤០៣	ជួសជុលនិងថែទាំទោច្រកយានយន្ត

(១) **មិនរាប់បញ្ចូល**
(ក) លក់ដុំកង់ គ្រឿងបន្លាស់ និងគ្រឿងបន្ទាប់បន្សំ (មើល ៤៦៤៩១)
(ខ) លក់រាយកង់ គ្រឿងបន្លាស់ និងគ្រឿងបន្ទាប់បន្សំ (មើល ៤៧៦៣៤)
(គ) ការជួលទោចក្រយានយន្ត (មើល ៧៧៣០២)
(ឃ) ជួសជុលនិងថែទាំកង់ (មើល ៩៥២៩១)។

ផ្នែក ៤៦ ៖ អាជីវកម្មលក់ដុំ លើកលែងតែយានយន្តនិងទោចក្រយានយន្ត

ផ្នែកនេះរាប់បញ្ចូលអាជីវកម្មលក់ដុំដោយខ្លួនឯង ឬយកប្រាក់កម្រៃ ឬដោយផ្អែកលើកិច្ចសន្យា (អាជីវកម្មកម្រៃជើងសារ) ដែលទាក់ទងទៅនឹងការធ្វើជំនួញលក់ដុំក្នុងស្រុក ព្រម ទាំងការធ្វើជំនួញលក់ដុំក្រៅស្រុក (ការនាំចូល/ការនាំចេញ)។

ការលក់ដុំគឺជាការលក់បន្ត (លក់ដោយមិនបំប្លែងពីទម្រង់ដើម) ទំនិញថ្មីឬទំនិញប្រើរួចទៅឲ្យអ្នកលក់រាយ រវាងអាជីវកម្ម ដូចជាអ្នកប្រើប្រាស់អាជីព ឬស្ថាប័ន អ្នកប្រើប្រាស់បែបពាណិជ្ជកម្ម អ្នកប្រើប្រាស់ឧស្សាហកម្ម ឬរួមមានការធ្វើជាភ្នាក់ងារ ឬឈ្មួញកណ្តាលនៅក្នុងការទិញទំនិញឬលក់ទំនិញទៅឲ្យអ្នកប្រើប្រាស់ឬក្រុមហ៊ុន។ ប្រភេទអាជីវកម្មចម្បងរាប់បញ្ចូលទាំងឈ្មួញលក់ទំនិញដុំ ឧ.អ្នកលក់ដុំដែលមានសិទ្ធិលើទំនិញដែលពួកគេលក់ រួម មានឈ្មួញលក់ដុំ អ្នកចែកចាយលក្ខណៈជាឧស្សាហកម្ម អ្នកនាំចូល អ្នកនាំចេញ ហើយនិងសមាគមទិញទំនិញមានលក្ខណៈសហការគ្នា សាខាលក់និងការិយាល័យលក់ (ប៉ុន្តែមិនមែន ជាហាងលក់រាយ) ដែលស្ថិតនៅក្រោមរោងចក្រឬអង្គភាពជីករ៉ែ ដែលនៅដាច់ដោយឡែកពីរោងចក្រឬកន្លែងរុករករ៉ែដែលមានគោលដៅលក់ផលិតផល ហើយការិយាល័យទាំងនោះ មិនមែនគ្រាន់តែទទួលយកការបញ្ជាទិញនិងដឹកជញ្ជូនទំនិញដោយផ្ទាល់ពីរោងចក្រ ឬកន្លែងជីករករ៉ែប៉ុណ្ណោះទេ។ ការលក់ដុំក៏រាប់បញ្ចូលផងដែរនូវឈ្មួញកណ្តាលលក់ទំនិញ ឈ្មួញ ទំនិញ និងភ្នាក់ងារដែលយកកម្រៃជើងសារ និងអ្នកផ្តុំដំឡើង អ្នកទិញនិងសមាគមទិញទំនិញ មានលក្ខណៈសហការគ្នាក្នុងការលក់ផលិតផលកសិដ្ឋាន។

ជាទូទៅអ្នកលក់ដុំ ធ្វើការផ្តុំដំឡើង រៀបផលិតផលតាមប្រភេទ និងចាត់ថ្នាក់គុណភាពជារូបវន្តនូវទំនិញធំៗ បំបែកទំនិញពីដុំធំៗ វេចខ្ចប់ឡើងវិញជាដុំតូចៗសម្រាប់ការចែកចាយ លក់ ឧ. ឱសថ ស្តុកទុក ក្លាស្សេចែកចាយ និងដំឡើងទំនិញ ចូលរួមក្នុងការផ្សព្វផ្សាយលក់ សម្រាប់អតិថិជនរបស់ពួកគេ និងចូលរួមក្នុងការរចនាស្លាកសញ្ញា។

ផ្នែកនេះមិនរាប់បញ្ចូលនូវការលក់ដុំយានយន្តនិងទោចក្រយានយន្ត រថយន្តវ៉ែន និងទោចក្រយានយន្ត ព្រមទាំងគ្រឿងបន្លាប់បន្សំរបស់យានយន្តនោះទេ (មើលផ្នែក ៤៥)។ ដូចគ្នាផងដែរ វាមិនរាប់បញ្ចូលការជួលទំនិញ (មើលផ្នែក ៧៧) និងការខ្ចប់នូវទំនិញរឹងនិងការច្រកទំនិញរាវ ឬឧស្ម័នក្នុងដប រាប់បញ្ចូលទាំងការលាយច្របល់និងច្រោះផងសម្រាប់ភាគី ទីបី (មើល ៨២៩២)។

ក្រុម ៤៦១ ៖ ការលក់ដុំដោយទទួលប្រាក់កម្រៃឬផ្អែកលើកិច្ចសន្យា

ក្រុមនេះរាប់បញ្ចូលសកម្មភាពរបស់ភ្នាក់ងារទទួលកម្រៃជើងសារ ឈ្មួញលក់ទំនិញបន្ត និងអ្នកលក់ដុំផ្សេងៗទៀត ដែលធ្វើពាណិជ្ជកម្មជំនួសអ្នកដទៃ សកម្មភាពទាំងអស់របស់ អ្នកដែលពាក់ព័ន្ធក្នុងការនាំឱ្យអ្នកលក់និងអ្នកទិញជួបគ្នា ឬធ្វើប្រតិបត្តិការពាណិជ្ជកម្មជំនួស ម្ចាស់ដើម ដោយរួមមានតាមប្រពន្ធ័អ៊ីនធឺណិត ភ្នាក់ងារដែលពាក់ព័ន្ធក្នុងការលក់វត្ថុធាតុ ដើមកសិកម្មសត្វរស់ វត្ថុធាតុដើមវាយនភ័ណ្ឌនិងផលិតផលពាក់កណ្តាលសម្រេច លក់ប្រេង ឥន្ធនៈ រ៉ែ លោហៈធាតុ និងសារធាតុគីមីសម្រាប់ឧស្សាហកម្ម ដែលរួមមានជី, លក់អាហារ ភេសជ្ជៈ និងថ្នាំជក់ ផលិតផលវាយនភ័ណ្ឌ សម្លៀកបំពាក់ពោមសត្វនិងផលិតផលពាក់នៅ ជើងនិងទំនិញធ្វើអំពីស្បែកសត្វ លក់ឈើហុប និងគ្រឿងសំណង់ លក់គ្រឿងម៉ាស៊ីនរួមមានគ្រឿងម៉ាស៊ីនការិយាល័យនិងកុំព្យូទ័រ បរិក្ខារឧស្សាហកម្ម កប៉ាល់និងយន្តហោះ លក់គ្រឿងសង្ហារឹម ទំនិញប្រើប្រាស់ក្នុងផ្ទះ និងសម្ភារៈរឹង។ សកម្មភាពនានាដែលរួមមានកន្លែងលក់ដុំតាមការដេញថ្លៃ ក៏ត្រូវបានរួមបញ្ចូលផងដែរ។

ក្រុម ៤៦២ ៖ ការលក់ដុំវត្ថុធាតុដើមកសិកម្មនិងសត្វរស់

ក្រុមនេះរាប់បញ្ចូលការលក់ដុំគ្រាប់ធញ្ញជាតិនិងគ្រាប់ពូជការលក់ដុំផ្លែឈើដែលសម្បូរ ជាតិប្រេង ការលក់ដុំផ្កានិងរុក្ខជាតិ ការលក់ដុំផលិតផលថ្នាំជក់មិនទាន់កែច្នៃ ការលក់ដុំសត្វ រស់ ការលក់ដុំផលិតផលស្បែក ការលក់ដុំស្បែកសត្វ និងការលក់ដុំវត្ថុធាតុដើមកសិកម្ម កាក សំណល់កសិកម្មនិងផលិតផលបន្ទាប់បន្សំកសិកម្ម ដើម្បីយកធ្វើចំណីសត្វ។

ក្រុម ៤៦៣ ៖ ការលក់ដុំអាហារភេសជ្ជៈនិងថ្នាំជក់

ក្រុមនេះរាប់បញ្ចូលការលក់ដុំផ្លែឈើនិងបន្លែ ការលក់ដុំផលិតផលធ្វើពីទឹកដោះគោ ការលក់ដុំស៊ុតនិងផលិតផលធ្វើពីស៊ុត ការលក់ដុំប្រេងនិងខ្លាញ់ដែលបរិភោគបានមានប្រភព មកពីសត្វឬបន្លែ ការលក់ដុំនូវសាច់និងផលិតផលធ្វើពីសាច់ ការលក់ដុំផលិតផលធ្វើពីត្រី ការលក់ដុំស្ករស សូកូឡា ស្ករគ្រាប់ ការលក់ដុំផលិតផលនំប៉ុង ការលក់ដុំភេសជ្ជៈ ការលក់ ដុំកាហ្វេ តែកាកាវ និងគ្រឿងផ្សំ និងការលក់ដុំផលិតផលថ្នាំជក់។ ថ្នាក់នេះរាប់បញ្ចូលផងដែរ នូវការទិញស្រាចំនួនច្រើន និងការច្រកក្នុងដបដោយមិនបំប្លែងពីទម្រង់ដើម និងការលក់ដុំ ចំណីសម្រាប់សត្វចិញ្ចឹម។

ក្រុម ៤៦៤ ៖ ការលក់ដុំនូវទំនិញប្រើប្រាស់ក្នុងផ្ទះ

ក្រុមនេះរាប់បញ្ចូល ការលក់ដុំនូវទំនិញប្រើប្រាស់ក្នុងផ្ទះរួមមាន ផលិតផលវាយនភ័ណ្ឌ។

ក្រុម ៤៦៥ ៖ ការលក់ដុំគ្រឿងម៉ាស៊ីន ឧបករណ៍ និងសម្ភារៈផ្គត់ផ្គង់ផ្សេងៗ

ក្រុមនេះរាប់បញ្ចូលការលក់ដុំកុំព្យូទ័រ ឧបករណ៍ទូរគមនាគមន៍ គ្រឿងម៉ាស៊ីនឯកទេសគ្រប់ប្រភេទសម្រាប់គ្រប់ឧស្សាហកម្ម និងគ្រឿងម៉ាស៊ីនផ្សេងៗប្រើប្រាស់ក្នុងគោលដៅទូទៅ។

ក្រុម ៤៦៦ ៖ ការលក់ដុំឯកទេសផ្សេងៗ

ក្រុមនេះរាប់បញ្ចូលសកម្មភាពអ្នកលក់ដុំឯកទេសផ្សេងៗទៀតមិនបានចាត់ទៅក្នុង ក្រុមដទៃទៀតនៅក្នុងផ្នែកនេះ។ ក្រុមនេះរាប់បញ្ចូលផងដែរនូវការលក់ដុំផលិតផលពាក់កណ្តាលសម្រេច លើកលែងតែផលិតផលកសិកម្មផ្សេងៗទៀត និងផលិតផលដែលមិនមែនសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។

ក្រុម ៤៦៩ ៖ ជំនួញលក់ដុំដោយមិនមានឯកទេស

ក្រុមនេះរួមបញ្ចូល ការលក់ដុំទំនិញផ្សេងៗ ដោយគ្មានឯកទេសជាក់លាក់។

ជំពូក ធ ៖ អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទ
ផ្នែក ៤៦ ៖ អាជីវកម្មលក់ដុំ លើកលែងតែយានយន្តនិងទោចក្រយានយន្ត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៤៦១			**ការលក់ដុំដោយទទួលប្រាក់កម្រៃ ឬផ្អែកលើកិច្ចសន្យា**
	៤៦១០[១]		ការលក់ដុំដោយទទួលប្រាក់កម្រៃ ឬផ្អែកលើកិច្ចសន្យា
		៤៦១០០	ការលក់ដុំដោយទទួលប្រាក់កម្រៃ ឬផ្អែកលើកិច្ចសន្យា
៤៦២			**ការលក់ដុំវត្ថុធាតុដើមកសិកម្មនិងសត្វរស់**
	៤៦២០[២]		ការលក់ដុំវត្ថុធាតុដើម និងសត្វ ៨៩៣
		៤៦២០១	លក់ដុំជ័រកៅស៊ូ
		៤៦២០២	លក់ដុំប្រេងដូង
		៤៦២០៣	លក់ដុំឈើកែច្នៃមូល និងឈើកែច្នៃជាបន្ទះ
		៤៦២០៤	លក់ដុំផ្កានិងរុក្ខជាតិ
		៤៦២០៥	លក់ដុំសត្វ
		៤៦២០៩	លក់ដុំផលិតផលកសិកម្មផ្សេងទៀត

(១) **មិនរាប់បញ្ចូល** (ក) អាជីវកម្មលក់ដុំផ្ទាល់ខ្លួន (មើលពី ៤៦២ ដល់ ៤៦៩)
(ខ) សកម្មភាពរបស់ភ្នាក់ងារសេវាធានារ៉ាប់រង (មើល ៦៦២២១)
(គ) សកម្មភាពរបស់ភ្នាក់ងារអចលនទ្រព្យ (មើល ៦៨២០១)។

(២) **មិនរាប់បញ្ចូល** លក់ដុំសរសៃអំបោះវាយនភណ្ឌ (មើល ៤៦៦៤)។

ជំពូក ធ ៖ អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទ
ផ្នែក ៤៦ ៖ អាជីវកម្មលក់ដុំ លើកលែងតែយានយន្តនិងទោចក្រយានយន្ត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៤៦៣			**ការលក់ដុំអាហារភេសជ្ជៈនិងថ្នាំជក់**
	៤៦៣១		ការលក់ដុំសាច់ត្រី ផ្លែឈើ និងបន្លែ
		៤៦៣១១	ការលក់ដុំសាច់ បក្សី និងស៊ុត
		៤៦៣១២	ការលក់ដុំត្រី និងគ្រឿងសមុទ្រ
		៤៦៣១៣	ការលក់ដុំផ្លែឈើ
		៤៦៣១៤	ការលក់ដុំបន្លែ
	៤៦៣២		ការលក់ដុំអាហារ ភេសជ្ជៈ និងថ្នាំជក់ដទៃទៀត
		៤៦៣២១	ការលក់ដុំស្រូវ អង្ករ គ្រាប់ធញ្ញជាតិ ម្សៅមី និងស្ករ
		៤៦៣២២	ការលក់ដុំផលិតផលដែលធ្វើពីទឹកដោះគោ
		៤៦៣២៣	ការលក់ដុំផលិតផលផ្អែម (នំ ស្ករគ្រាប់)
		៤៦៣២៤	ការលក់ដុំនំ នំប៉័ង និងបណ្តាលផលិតផលនំប៉័ង
		៤៦៣២៥	ការលក់ដុំកាហ្វេ តែ កាកាវនិងភេសជ្ជៈផ្សេងទៀត
		៤៦៣២៦	ការលក់ដុំស្រាបៀរ ស្រាក្រហមនិងស្រា[១]
		៤៦៣២៧	លក់ដុំថ្នាំជក់ បារី និងស៊ីហ្គា
		៤៦៣២៨	លក់ដុំនូវអាហារគ្រប់ប្រភេទ[២]

(១) **មិនរាប់បញ្ចូល** ការលាយស្រា (មើល ១១០២) ឬស្រាបិត(មើល ១១០១០)។

(២) **រាប់បញ្ចូល** មី ស្បែក និងផលិតផលពាក់ព័ន្ធប្រេងចម្អិន ម្សៅកំប៉ុង គ្រឿងផ្សំ ។ល។

ជំពូក ធ ៖ អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទ
ផ្នែក ៤៦ ៖ អាជីវកម្មលក់ដុំ លើកលែងតែយានយន្តនិងទោចក្រយានយន្ត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៤៦៤			**ការលក់ដុំទំនិញប្រើប្រាស់ក្នុងផ្ទះ**
	៤៦៤១(១)		ការលក់ដុំផលិតផលវាយនភ័ណ្ឌ សម្លៀកបំពាក់ និងផលិតផលសម្រាប់ពាក់នឹងជើង
		៤៦៤១១	ការលក់ដុំអំបោះនិងក្រណាត់
		៤៦៤១២	ការលក់ដុំក្រណាត់ខ្មៀន កន្សែងពោះគោ និងភួយ ។ល។
		៤៦៤១៣	ការលក់ដុំសម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំ(២)
		៤៦៤១៤	ការលក់ដុំផលិតផលសម្រាប់ពាក់នឹងជើង
		៤៦៤១៩	ការលក់ដុំផលិតផលវាយនភ័ណ្ឌ និងសម្លៀកបំពាក់(៣)
	៤៦៤២		ការលក់ដុំផលិតផលឱសថ និងផលិតផលប្រើក្នុងបន្ទប់ទឹក
		៤៦៤២១	ការលក់ដុំផលិតផលឱសថ និងផលិតផលសុខាភិបាល
		៤៦៤២២	ការលក់ដុំទឹកអប់ គ្រឿងសម្អាង និងសាប៊ូ
	៤៦៤៣		ការលក់ដុំសម្ភារៈកីឡា ល្បែងលេង ស្បែក និងផលិតផលសម្រាប់ការធ្វើដំណើរ និងឧបករណ៍ភ្លេង
		៤៦៤៣១	ការលក់ដុំកង់ គ្រឿងបន្លាស់កង់ និងគ្រឿងបន្ទាប់បន្សំ
		៤៦៤៣២	ការលក់ដុំផលិតផលរូបថត និងផលិតផលអុបទិក(៤)
		៤៦៤៣៣	ការលក់ដុំផលិតផលស្បែក និងសម្ភារៈសម្រាប់ធ្វើដំណើរ(៥)
		៤៦៤៣៤	ការលក់ដុំឧបករណ៍តន្ត្រី ល្បែងលេង ប្រដាប់ក្មេងលេង និងសម្ភារៈកីឡា(៦)
	៤៦៤៤		ការលក់ដុំផលិតផលសិប្បកម្ម នាឡិកាដៃ នាឡិកា និងគ្រឿងអលង្ការ
		៤៦៤៤១	ការលក់ដុំផ្កាសិប្បនិម្មិត និងផលិតផលសិប្បកម្ម
		៤៦៤៤២	លក់ដុំផ្កា និងដើមឈើដែលកាត់ចេញពីដើម
		៤៦៤៤៣	លក់ដុំនាឡិកាដៃ នាឡិកា និងគ្រឿងអលង្ការ

(១) **មិនរាប់បញ្ចូល** (ក)លក់ដុំគ្រឿងអលង្ការ (មើល ៤៦៤៥៣) និងផលិតផលស្បែក (មើល ៤៦៤៤៤)
(ខ) លក់ដុំសរសៃអំបោះវាយនភ័ណ្ឌ (មើល ៤៦៦៤៤)។

(២) **រាប់បញ្ចូល** សម្លៀកបំពាក់កីឡា ស្រោមដៃ ក្រវ៉ាត់ក និងខ្សែរឹត។

(៣) **រាប់បញ្ចូល** (ក) លក់ដុំផលិតផលវាយនភ័ណ្ឌ សម្លៀកបំពាក់ និងផលិតផលពាក់នឹងជើង
(ខ) លក់ដុំធ័ត្រ
(គ) លក់ដុំម្ជុលដេរខ្សែអំបោះដេរ។ល។

មិនរាប់បញ្ចូល ការលក់ដុំកម្ទេចកំទីនិងកាក់សំណល់សរសៃវាយនភ័ណ្ឌ (មើល ៤៦៦៤៤)។

(៤) **រាប់បញ្ចូល** វ៉ែនតាការពារពន្លឺព្រះអាទិត្យ កែវយឺត កែវពង្រីក។ល។

(៥) **មិនរាប់បញ្ចូល** ការលក់ដុំស្បែកជើង (មើល ៤៦៤១៤)។

(៦) **មិនរាប់បញ្ចូល** លក់ដុំកង់ លក់គ្រឿងបន្លាស់ និងគ្រឿងបន្ទាប់បន្សំ។

ជំពូក ធ ៖ អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទ
ផ្នែក ៤៦ ៖ អាជីវកម្មលក់ដុំ លើកលែងតែយានយន្តនិងទោចក្រយានយន្ត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	៤៦៤៩[១]		ការលក់ដុំសម្ភារៈប្រើប្រាស់ក្នុងផ្ទះដទៃទៀត
		៤៦៤៩១	ការលក់ដុំគ្រឿងសង្ហារិមប្រើប្រាស់ក្នុងផ្ទះ
		៤៦៤៩២	ការលក់ដុំគ្រឿងឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ
		៤៦៤៩៣	ការលក់ដុំសម្ភារៈការិយាល័យ សៀវភៅ ទស្សនាវដ្ដី កាសែត
		៤៦៤៩៩	ការលក់ដុំនិងរាយគ្រឿងប្រើប្រាស់ក្នុងផ្ទះ[២]
៤៦៥			**ការលក់ដុំគ្រឿងម៉ាស៊ីនឧបករណ៍និងសម្ភារៈផ្គត់ផ្គង់ផ្សេងៗ**
	៤៦៥១[៣]		លក់ដុំកុំព្យូទ័រសម្ភារៈបន្ទាប់បន្សំកុំព្យូទ័រនិងកម្មវិធី
		៤៦៥១០	ការលក់ដុំកុំព្យូទ័រ សម្ភារៈបន្ទាប់បន្សំកុំព្យូទ័រ និងកម្មវិធី
	៤៦៥២[៤]		ការលក់ដុំឧបករណ៍ទូរគមនាគមន៍ គ្រឿងអេឡិចត្រូនិក និងគ្រឿងបន្លាស់
		៤៦៥២១	ការលក់ដុំទូរស័ព្ទ និងឧបករណ៍ទូរគមនាគមន៍រួមទាំងទូរស័ព្ទដៃ។ល។
		៤៦៥២២	ការលក់ដុំខ្សែអាត់ទទេ ឌីសផ្ទុកទិន្នន័យស៊ីឌី និងវីស៊ីឌី
		៤៦៥២៩	ការលក់ដុំ ឧបករណ៍អេឡិចត្រូនិកដទៃទៀត[៥]

(១) **រាប់បញ្ចូល** (ក) លក់ដុំស៊ីឌី វីស៊ីឌី កាសែតដែលថតបញ្ចូលរួច
(ខ) លក់ដុំស៊ីឌី វីស៊ីឌី កាសែតដែលមិនទាន់ថតបញ្ចូលរួច
(គ) លក់ដុំឧបករណ៍ផ្សាយសម្រាប់វិទ្យុ និងទូរទស្សន៍។

មិនរាប់បញ្ចូល លក់ដុំគ្រឿងសង្ហារិមការិយាល័យ (មើល ៤៦៥៩២)។

(២) **រាប់បញ្ចូល** (ក) ឧបករណ៍វិទ្យុ និងទូរទស្សន៍
(ខ) ម៉ាស៊ីនថតសម្លេង និងវីឌីអូ និងម៉ាស៊ីនចាក់ស៊ីឌី និងវីស៊ីឌី
(គ) ប្រដាប់លេងវីឌីអូហ្គេម
(ឃ) ឧបករណ៍បំភ្លឺ
(ង) គ្រឿងកែវ ចាន និងសម្ភារៈរៀបចំហូបអាហារ។

(៣) **មិនរាប់បញ្ចូល** (ក) លក់ដុំគ្រឿងបន្លាស់អេឡិចត្រូនិក (មើល ៤៦៥២)
(ខ) លក់ដុំឧបករណ៍ និងគ្រឿងម៉ាស៊ីនប្រើក្នុងការិយាល័យ (លើកលែងតែកុំព្យូទ័រ និងឧបករណ៍បន្ទាប់បន្សំ) (មើល ៤៦៥៩១)។

(៤) **មិនរាប់បញ្ចូល** (ក) លក់ដុំស៊ីឌី វីស៊ីឌី កាសែតដែលថតបញ្ចូលរួច (មើល ៤៦៤៩៩)
(ខ) លក់ដុំគ្រឿងអេឡិចត្រូនិកសម្រាប់អ្នកប្រើប្រាស់ (មើល ៤៦៤៩៩)
(គ) លក់ដុំកុំព្យូទ័រ និងឧបករណ៍បន្ទាប់បន្សំកុំព្យូទ័រ (មើល ៤៦៥១០)។

(៥) **រាប់បញ្ចូល** បន្ទះមីក្រូឈីប និងសៀគ្វី។

ជំពូក ឆ ៖ អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទ
ផ្នែក ៤៦ ៖ អាជីវកម្មលក់ដុំ លើកលែងតែយានយន្តនិងទោចក្រយានយន្ត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	៤៦៥៣[១]		ការលក់ដុំគ្រឿងម៉ាស៊ីនឧបករណ៍ និងបរិក្ខារផ្គត់ផ្គង់កសិកម្ម
		៤៦៥៣១	ការលក់ដុំគ្រឿងម៉ាស៊ីន ឧបករណ៍ និងបរិក្ខារផ្គត់ផ្គង់កសិកម្ម[២]
	៤៦៥៩[៣]		ការលក់ដុំគ្រឿងម៉ាស៊ីន និងឧបករណ៍ផ្សេងៗទៀត
		៤៦៥៩១	ការលក់ដុំម៉ាស៊ីនប្រើក្នុងការិយាល័យ និងឧបករណ៍សម្រាប់អាជីវកម្ម លើកលែងតែលក់ដុំកុំព្យូទ័រនិងឧបករណ៍បន្ទាប់បន្សំកុំព្យូទ័រ
		៤៦៥៩២	ការលក់ដុំគ្រឿងសង្ហារិមការិយាល័យ
		៤៦៥៩៩	ការលក់ដុំម៉ាស៊ីនផ្សេងៗសម្រាប់ប្រើប្រាស់នៅក្នុងឧស្សាហកម្ម ពាណិជ្ជកម្ម និងប្រព័ន្ធបង្ហាញផ្លូវ ព្រមទាំងសេវាកម្មផ្សេងៗ[៤]

(១) **មិនរាប់បញ្ចូល** លក់យានយន្តសម្រាប់ឧស្សាហកម្មពាណិជ្ជកម្មនិងកសិកម្ម។

(២) **រាប់បញ្ចូល** លក់ដុំនង្គ័ល ឧបករណ៍បាច់ជីធម្មជាតិ ឧបករណ៍ដាក់គ្រាប់ពូជម៉ាស៊ីនច្រូតកាត់ ម៉ាស៊ីនបោកម៉ាស៊ីនបែនស្រូវ ម៉ាស៊ីនថៃរក្សាបក្សី ម៉ាស៊ីនថៃរក្សាឃ្មុំ។

(៣) **មិនរាប់បញ្ចូល**
- (ក) លក់ដុំយានយន្ត រ៉េមកសណ្តោង រថយន្តវ៉ែន (មើល ៤៥១០)
- (ខ) លក់ដុំគ្រឿងបន្លាស់យានយន្ត (មើល ៤៥៣០០)
- (គ) លក់ដុំទោចក្រយានយន្ត (មើល ៤៥៤០)
- (ឃ) លក់ដុំកង់ (មើល ៤៦៤៤១)
- (ង) លក់ដុំកុំព្យូទ័រនិងគ្រឿងបន្ទាប់បន្សំកុំព្យូទ័រ (មើល ៤៦៥១០)
- (ច) លក់ដុំគ្រឿងបន្លាស់អេឡិចត្រូនិក ទូរស័ព្ទ ឧបករណ៍ទំនាក់ទំនង (មើល ៤៦៥២)។

(៤) **រាប់បញ្ចូល**
- (ក) លក់ដុំជណ្តើរយន្ត ជណ្តើរយោង ម៉ាស៊ីនត្រជាក់ ឧបករណ៍ពន្លត់អគ្គីភ័យ និងឧបករណ៍សន្តិសុខ
- (ខ) លក់ដុំឧបករណ៍សម្រាប់យន្តហោះនាវា និងគ្រឿងបន្ទាប់បន្សំ និងឧបករណ៍ដឹកជញ្ជូនផ្សេងៗទៀត។

ជំពូក ឆ ៖ អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទ
ផ្នែក ៤៦ ៖ អាជីវកម្មលក់ដុំ លើកលែងតែយានយន្តនិងទោចក្រយានយន្ត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៤៦៦			**ការលក់ដុំឯកទេសផ្សេងៗ**
	៤៦៦១		ការលក់ដុំផលិតផលឥន្ធនៈរឹង រាវ និងឧស្ម័ន និងផលិតផលពាក់ព័ន្ធ
		៤៦៦១១	ការលក់ដុំប្រេងសាំង ប្រេងម៉ាស៊ូត ប្រេងរំអិល ។ល។
		៤៦៦១២	ការលក់ដុំឧស្ម័នឥន្ធនៈរាវ
		៤៦៦១៩	ការលក់ដុំផលិតផលឥន្ធនៈរឹង រាវ និងឧស្ម័ន និងផលិតផលពាក់ព័ន្ធ[១]
	៤៦៦២[២]		ការលក់ដុំលោហៈធាតុ និងរ៉ែលោហៈធាតុ
		៤៦៦២០	ការលក់ដុំផលិតផល និងរ៉ែលោហៈធាតុពាក់កណ្តាលសម្រេចដែលមានជាតិដែក និងគ្មានជាតិដែក
	៤៦៦៣		ការលក់ដុំសម្ភារៈសំណង់ សម្ភារៈរឹងឧបករណ៍និងបរិក្ខារប្រព័ន្ធទឹក និងប្រព័ន្ធកំដៅ
		៤៦៦៣១	ការលក់ដុំឈើហុប ឈើអារ ក្តារបន្ទះ បន្ទះក្តារស្តើងនិងផលិតផលពាក់ព័ន្ធ
		៤៦៦៣២	ការលក់ដុំថ្នាំលាប និងថ្នាំលាបឈើឲ្យរលោង
		៤៦៦៣៣	ការលក់ដុំឧបករណ៍ និងសម្ភារៈសំណង់[៣]
		៤៦៦៣៤	ការលក់ដុំគ្រឿងសម្រាប់បន្ថែមភ្ជាប់លើអគារ ឬសង្ហារឹម
		៤៦៦៣៥	ការលក់ដុំម៉ាស៊ីនទឹកក្តៅ និងឧបករណ៍អនាម័យ និងម៉ាស៊ីនកម្តៅទឹក[៤]

(១) **រាប់បញ្ចូល** លក់ដុំធ្យូងដុត ធ្យូងថ្ម អុស ឈើដុតបំប្លែងជាឥន្ធនៈ ប្រេងចំហេះ ខ្លាញ់ចំហេះ។

(២) **មិនរាប់បញ្ចូល** លក់ដុំកម្ទេចកំទីដែក (មើល ៤៦៦៩១)។

(៣) **រាប់បញ្ចូល** (ក) លក់ដុំសម្ភារៈសំណង់ ដូចជាខ្សាច់ ថ្មក្រាល ស៊ីម៉ង់ ឬ បាយអរ
(ខ) លក់ដុំក្រដាសបិតជញ្ជាំង កញ្ចក់រាប និងកម្រាល។

(៤) **មិនរាប់បញ្ចូល** លក់ដុំសម្ភារៈបន្ទប់ទឹក អាងទឹកលុបមុខ បង្គន់ សម្ភារៈអនាម័យធ្វើពីព័រស៊ីឡែន បំពង់ទុយោ ប្រដាប់បំពាក់លើអគារឬសង្ហារិមក្បាលរ៉ូប៊ីនេ មុខតំណរ ទុយោជ័រ។ល។

ជំពូក ឆ ៖ អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទ
ផ្នែក ៤៦ ៖ អាជីវកម្មលក់ដុំ លើកលែងតែយានយន្តនិងទោចក្រយានយន្ត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៤៦៦			**ការលក់ដុំឯកទេសផ្សេងៗ**
	៤៦៦៤		ការលក់ដុំផលិតផលគីមី និងសារធាតុគីមី
		៤៦៦៤១	ការលក់ដុំសារធាតុគីមីសម្រាប់ឧស្សាហកម្ម(១)
		៤៦៦៤២	ការលក់ដុំជី និងផលិតផលគីមីកសិកម្ម
		៤៦៦៤៣	ការលក់ដុំសម្ភារៈធ្វើពីប្លាស្ទិកមិនទាន់កែច្នៃ
		៤៦៦៤៤	ការលក់ដុំសរសៃអំបោះវាយនភ័ណ្ឌ។ល។
		៤៦៦៤៥	ការលក់ដុំក្រដាសក្នុងចំនួនច្រើន និងសម្ភារៈវេចខ្ចប់
	៤៦៦៥(២)		ការលក់ដុំកាកសំណល់ និងកំទេចកម្ទី
		៤៦៦៥១	លក់ដុំកាកសំណល់ និងកំទេចកម្ទី(៣)
		៤៦៦៥២	ការរុះកម្ទេចរថយន្ត កុំព្យូទ័រ ទូរទស្សន៍ និងឧបករណ៍ផ្សេងៗទៀតដើម្បីយក និងលក់បន្តនូវផ្នែកណាមួយដែលប្រើប្រាស់បាន(៤)
		៤៦៦៥៩	ការលក់ដុំកម្ទេចកំទី កាកសំណល់ និងផលិតផលផ្សេងៗ
៤៦៩			**ជំនួញលក់ដុំដោយមិនមានឯកទេស**
	៤៦៩០		ជំនួញលក់ដុំមិនមានឯកទេស(ការលក់ដុំទំនិញច្រើនប្រភេទដោយមិនមានឯកទេសណាមួយ)
		៤៦៩០០	ការលក់ដុំសម្រាប់ទំនិញទូទៅការលក់ដុំទំនិញច្រើនប្រភេទដោយមិនមានឯកទេសណាមួយ

(១) **រាប់បញ្ចូល** លក់ដុំល័ក្ខ ទឹកថ្នាំបោះពុម្ព ប្រេងចាំបាច់ ឧស្ម័នឧស្សាហកម្ម ការគីមី សារធាតុធ្វើពណ៌ ជ័រទឹកសំយោគ មេតាណុល ជ័រចំហេះ មេក្លិន មេរសជាតិ សូដា អំបិលឧស្សាហកម្ម អាស៊ីត និងស៊ុលផួរ ម្សៅជំឡូងមិនមែនផលិតពីវត្ថុធាតុដើម។ល។

(២) **មិនរាប់បញ្ចូល** (ក) ការប្រមូលកាក់សំណល់តាមគ្រួសារនិងឧស្សាហកម្ម (មើល ៣៨១)

(ខ) ការកែច្នៃសំរាម មិនមែនសម្រាប់ការយកទៅប្រើបន្តនៅក្នុងដំណើរការឧស្សាហកម្ម ប៉ុន្តែដើម្បីយកទៅបញ្ចេញចោល (មើល ៣៨២)

(គ) ការកែច្នៃកាកសំណល់និងកម្ទេចកម្ទី និងវត្ថុធាតុផ្សេងទៀតឲ្យក្លាយទៅជាវត្ថុធាតុដើមបន្ទាប់បន្សំ នៅពេលដែលតម្រូវឲ្យមានដំណើរការបំប្លែងពិតប្រាកដ (វត្ថុធាតុដើមបន្ទាប់បន្សំដែលចេញមក គឺសមស្របសម្រាប់ការប្រើនៅក្នុងដំណើរការផលិតកម្មឧស្សាហកម្ម ប៉ុន្តែវាមិនមែនជាផលិតផលសម្រេចនេះទេ) (មើល ៣៨៣០)

(ឃ) ការរុះកម្ទេចរថយន្ត កុំព្យូទ័រ ទូរស្សន៍ និងឧបករណ៍ផ្សេងៗដើម្បីទាញយកគ្រឿងដែលអាចប្រើបាន (មើល ៣៨៣០០)

(ង) ការជ្រៀករថយន្តដោយដំណើរការមេកានិច (មើល ៣៨៣០០)

(ច) ការបំបែកនាវា (មើល ៣៨៣០០)

(ឆ) ការលក់រាយទំនិញជជុះ (មើល៤៧៧៤)។

(៣) **រាប់បញ្ចូល** ប្រមូលទុក ញែក ស្តុក និងចែកចាយ ប៉ុន្តែមិនមានដំណើរការបំប្លែងពិតប្រាកដ។

(៤) **មិនរាប់បញ្ចូល** ការរុះកម្ទេចរថយន្ត កុំព្យូទ័រ ទូរស្សន៍ និងឧបករណ៍ផ្សេងៗដើម្បីទាញយកសម្ភារៈ។

ផ្នែក៤៧ ៖ អាជីវកម្មលក់រាយ លើកលែងតែយានយន្តនិងទោចក្រយានយន្ត

ផ្នែកនេះរាប់បញ្ចូលការលក់បន្ត (លក់ដោយគ្មានបំលែងទម្រង់ដើម) នៃផលិតផលថ្មីនិងផលិតផលប្រើប្រាស់រួច ទៅឲ្យសាធារណជន សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនឬក្នុងគ្រួសារ ឬតាមហាងលក់ទំនិញ អគារលក់ទំនិញ តូបលក់ទំនិញ កន្លែងបញ្ជាទិញតាមសារ អ្នកដើរលក់ រាយ និងអ្នកប្រើប្រាស់ជាក្រុម។ល។

អាជីវកម្មលក់រាយគឺត្រូវបានចាត់ថ្នាក់ជាសំខាន់តាមប្រភេទនៃទីតាំងលក់ (អាជីវកម្មលក់រាយនៅក្នុងហាង (ពីក្រុម ៤៧១ ដល់ ៤៧៧), អាជីវកម្មលក់រាយមិននៅក្នុងហាង (ពីក្រុម៤៧៨ ដល់ ៤៧៩)។ អាជីវកម្មលក់រាយនៅក្នុងហាងរាប់បញ្ចូលការលក់រាយទំនិញប្រើប្រាស់រួច (ថ្នាក់រង ៤៧៧៤)។ សម្រាប់ការលក់រាយនៅក្នុងហាង វាមានភាពខុសគ្នាឆ្ងាយរវាងការលក់រាយឯកទេស (ក្រុម ៤៧២ ដល់ ៤៧៧) និងការលក់រាយមិនឯកទេស (ក្រុម ៤៧១)។ ក្រុមខាងលើគឺត្រូវបានបែងចែកបន្តទៀត ទៅតាមក្រុមផលិតផលដែលបានលក់។ ការលក់មិនឆ្លងតាមរយៈហាងគឺត្រូវបានបែងចែកបន្តទៀត ដោយយោងទៅលើទម្រង់នៃអាជីវកម្ម ដូចជាការលក់រាយនៅតាមតូបនិងលក់នៅតាមទីផ្សារ (ក្រុម ៤៧៨) ហើយការលក់រាយមិនតាមហាងផ្សេងៗទៀតដូចជាការលក់តាមការផ្ញើសារ ការលក់ដល់ផ្ទះ ការលក់តាមម៉ាស៊ីន លក់រាយ ។ល។ (ក្រុម ៤៧៩)។

ទំនិញដែលលក់នៅក្នុងផ្នែកនេះ គឺត្រូវបានកម្រិតត្រឹមទំនិញធម្មតាសម្រាប់អ្នកប្រើ ប្រាស់ ឬទំនិញលក់រាយ។ ហេតុដូចនេះ ទំនិញដែលជាធម្មតាមិនត្រូវបានចាត់ចូលក្នុងអាជីវកម្មលក់រាយ ដូចជាគ្រាប់ធញ្ញជាតិ រ៉ែ គ្រឿងម៉ាស៊ីនឧស្សាហកម្មផ្សេងៗទៀតមិនត្រូវបានរាប់បញ្ចូលទេ។ ផ្នែកនេះរាប់បញ្ចូលអង្គភាពដែលពាក់ព័ន្ធក្នុងការលក់ទៅឲ្យសាធារណជន តាមការដាក់តាំងបង្ហាញទំនិញផលិតផល ដូចជាកុំព្យូទ័រ សម្ភារៈប្រើប្រាស់ការិយាល័យ ថ្នាំ លាបឬឈើបើទោះបីជាការលក់ទាំងនេះមិនសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឬក្នុងគ្រួសារក៏ដោយ ។ ផ្នែកនេះក៏អាចរួមមានការកែច្នៃទំនិញ ប៉ុន្តែវាត្រឹមតែជាផ្នែកអមដល់ការលក់ ដូចជាការ ញែក ការវេចខ្ចប់ទំនិញឡើងវិញ ការដំឡើងនូវប្រដាប់ប្រដាផលិតផលប្រើក្នុងផ្ទះផ្សេងៗ ទៀត។

ផ្នែកនេះរាប់បញ្ចូលផងដែរការលក់រាយតាមភ្នាក់ងារទទួលកម្រៃជើងសារ និងសកម្មភាពកន្លែងលក់ដេញថ្លៃ។

ផ្នែកនេះមិនរាប់បញ្ចូលកសិផលដែលលក់ដោយកសិករ (មើលផ្នែក ០១) ការផលិត និងការលក់ទំនិញ ដែលត្រូវបានចូលទៅក្នុងការផលិតនៅក្នុងផ្នែក ១០ ដល់ ៣២ ការលក់យានយន្ត ទោចក្រយានយន្ត និងគ្រឿងបន្លាស់ (មើលផ្នែក ៤៥) ការជួញដូរគ្រាប់ធញ្ញជាតិ រ៉ែប្រេងឆៅ គីមីឧស្សាហកម្មដែកនិងដែកថែប និងឧបករណ៍និងគ្រឿងយន្តឧស្សាហកម្ម (មើលផ្នែក ៤៦) ការលក់អាហារនិងភេសជ្ជៈសម្រាប់បរិភោគនៅនឹងកន្លែង និងខ្ចប់យកទៅ ឆ្ងាយ (មើលផ្នែក៥៦) និងការជួលទំនិញសម្រាប់ប្រើផ្ទាល់ខ្លួន និងនៅក្នុងផ្ទះឲ្យទៅ សាធារណជន (មើល ៧៧២)។

ក្រុម ៤៧១ ៖ ការលក់រាយនៅក្នុងហាងដែលមិនឯកទេស

ក្រុមនេះ រាប់បញ្ចូលការលក់រាយនូវស្រឡាយផលិតផលមួយចំនួននៅក្នុងកន្លែងតែមួយ (ហាងមិនឯកទេស) ដូចជាផ្សារទំនើប ឬហាងទំនើបលក់ទំនិញធំៗ។

ក្រុម ៤៧២ ៖ ការលក់រាយអាហារភេសជ្ជៈនិងថ្នាំជក់នៅក្នុងហាងឯកទេស

ក្រុមនេះ រាប់បញ្ចូលការលក់រាយនៅក្នុងហាងដែលមានឯកទេសលក់ផលិតផលអាហារភេសជ្ជៈឬថ្នាំជក់។

ក្រុម ៤៧៣ ៖ ការលក់រាយប្រេងឥន្ធនៈយានយន្តនៅក្នុងហាងឯកទេស

ក្រុមនេះ រាប់បញ្ចូលការលក់រាយនូវប្រេងឥន្ធនៈសម្រាប់យានយន្តនិងទោចក្រយានយន្ត ហើយនិងការលក់រាយផលិតផលប្រេងរំអិល និងផលិតផលស្ងំយានយន្ត។

ក្រុម ៤៧៤ ៖ ការលក់រាយឧបករណ៍ផ្នែកព័ត៌មាន និងទំនាក់ទំនងនៅក្នុងហាងឯកទេស

ក្រុមនេះ រាប់បញ្ចូលការលក់រាយឧបករណ៍ផ្នែកព័ត៌មាននិងទំនាក់ទំនងដូចជាកុំព្យូទ័រ និងគ្រឿងបន្ទាប់បន្សំឧបករណ៍ទូរគមនាគមន៍ និងគ្រឿងអេឡិចត្រូនិក សម្រាប់អ្នកប្រើប្រាស់ ដែលលក់ដោយហាងឯកទេស។

ក្រុម ៤៧៥ ៖ ការលក់រាយឧបករណ៍ប្រើប្រាស់ក្នុងគ្រួសារផ្សេងៗក្នុងហាងឯកទេស

ក្រុមនេះ រាប់បញ្ចូលការលក់រាយឧបករណ៍ប្រើប្រាស់ក្នុងគ្រួសារដូចជាផលិតផល វាយនភណ្ឌ ផលិតផលផ្នែករឹងកម្រាលព្រំគ្រឿងអេឡិចត្រូនិក ឬគ្រឿងសង្ហារិមដែលមានលក់នៅក្នុងហាងឯកទេស។

ក្រុម ៤៧៦ ៖ ការលក់រាយទំនិញវប្បធម៌ និងកម្សាន្តនៅក្នុងហាងឯកទេស

ក្រុមនេះរាប់បញ្ចូលការលក់នៅក្នុងហាងឯកទេសដែលលក់ទំនិញវប្បធម៌ និងទំនិញកម្សាន្តដូចជាសៀវភៅកាសែតតន្ត្រី វីដេអូសម្ភារៈកីឡា ហ្គេមនិងប្រដាប់ក្មេងលេង។

ក្រុម ៤៧៧ ៖ ការលក់រាយទំនិញផ្សេងៗទៀតនៅក្នុងហាងឯកទេស

ក្រុមនេះ រាប់បញ្ចូលនូវការលក់នៅក្នុងហាងឯកទេសដែលលក់ស្រទ្បាយផលិតផលជាក់លាក់ ដែលមិនបានរួមបញ្ចូលទៅក្នុងផ្នែកដទៃទៀតនៃចំណាត់ថ្នាក់ផលិតផលនេះ ដូច ជាសម្លៀកបំពាក់ ផលិតផលពាក់នឹងជើង ផលិតផលធ្វើពីស្បែក ផលិតផលថ្នាំពេទ្យនិងសុខភាព នាឡិកា វត្ថុអនុស្សាវរីយ៍ សម្ភារៈសម្អាត អាវុធ ផ្កា សត្វចិញ្ចឹមលេង និងផលិតផលផ្សេងទៀត។ វាក៏រាប់បញ្ចូលផងដែរ នូវការលក់រាយផលិតផលប្រើប្រាស់រួចនៅក្នុងហាងឯកទេស។

ក្រុម ៤៧៨ ៖ ការលក់រាយនៅតាមតូបនិងទីផ្សារ

ក្រុមនេះរាប់បញ្ចូល នូវការលក់រាយផលិតផលថ្មី ឬផលិតផលជជុះ នៅក្នុងតូបចល័តនៅតាមផ្លូវសាធារណៈ ឬនៅកន្លែងទីផ្សារអចល័តណាមួយ។

ក្រុម ៤៧៩ ៖ ការលក់រាយមិននៅក្នុងហាងតូបឬទីផ្សារ

ក្រុមនេះរាប់បញ្ចូល សកម្មភាពលក់រាយតាមរយៈកន្លែងទិញតាមសារ លក់តាមប្រព័ន្ធអ៊ីនធឺណិត ការលក់ដល់ផ្ទះ ការលក់តាមម៉ាស៊ីនលក់រាយ។ល។

ជំពូក ធ ៖ អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទ
ផ្នែក ៤៧ ៖ អាជីវកម្មលក់រាយ លើកលែងតែយានយន្តនិងទោចក្រយានយន្ត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៤៧១			**ការលក់រាយក្នុងហាងមិនឯកទេស**
	៤៧១១		ការលក់រាយក្នុងហាងមិនឯកទេស ភាគច្រើនជាចំណីអាហារ ភេសជ្ជៈ ឬផលិតផលថ្នាំជក់
		៤៧១១១	ហាងលក់គ្រឿងទេស
		៤៧១១២	ផ្សារទំនើប
		៤៧១១៣	ផ្សារទំនើបខ្នាតតូច(១)
	៤៧១៩		លក់រាយផ្សេងទៀតនៅក្នុងហាងដែលមិនឯកទេស
		៤៧១៩១	ផ្សារលក់ទំនិញធំៗដែលមាន ឬមិនមានផ្សារទំនើប(២)
		៤៧១៩២	ការលក់រាយនៅក្នុងហាងមិនឯកទេស
៤៧២			**ការលក់រាយអាហារ ភេសជ្ជៈ និងថ្នាំជក់ក្នុងហាងឯកទេស**
	៤៧២១(៣)		ការលក់រាយអាហារនៅក្នុងហាងឯកទេស
		៤៧២១១	ការលក់រាយនូវអង្ករ ម្សៅ គ្រាប់ធញ្ញជាតិ និងស្ករ
		៤៧២១២	ការលក់រាយបន្លែ និងផ្លែឈើស្រស់ ឬរក្សាទុកក្រៀម
		៤៧២១៣	ការលក់រាយសាច់ និងផលិតផលសាច់ (រួមទាំងបក្សី)
		៤៧២១៤	ការលក់រាយត្រី គ្រឿងសមុទ្រ និងផលិតផលដូចនេះ
		៤៧២១៥	ការលក់រាយ ផលិតផលនំប៉័ង
		៤៧២១៦	ការលក់រាយផលិតផលស្ករគ្រាប់ និងនំ
		៤៧២១៧	ការលក់រាយមី ស្បែក និងផលិតផលអាហារផ្សេងទៀតធ្វើពីម្សៅមី និងសណ្តែកសៀង
		៤៧២១៩	ការលក់រាយនូវផលិតផលអាហារផ្សេងៗ
	៤៧២២		ការលក់រាយភេសជ្ជៈនៅក្នុងហាងឯកទេស
		៤៧២២១	ការលក់រាយនូវស្រាបៀរ ស្រា និងគ្រឿងស្រវឹងផ្សេងទៀត
		៤៧២២២	ការលក់រាយនូវតែ កាហ្វេ និងភេសជ្ជៈផ្សេងទៀត
		៤៧២២៣	ការលក់រាយភេសជ្ជៈ និងទឹកច្រកដប
	៤៧២៣		លក់រាយនូវផលិតផលថ្នាំជក់នៅក្នុងហាងឯកទេស
		៤៧២៣០	លក់រាយផលិតផលថ្នាំជក់និងថ្នាំជក់

(១) ភាគច្រើនលក់ទំនិញមានស្លាកយីហោ ជាទូទៅ មាននៅក្នុងទីក្រុងធំៗពេលខ្លះបើក ២៤ ម៉ោង។

(២) ជាហាងធម្មតា ដែលមិនមានលក់អាហារភេសជ្ជៈ និងផលិតផលថ្នាំជក់ភាគច្រើនទេ។

(៣) **មិនរាប់បញ្ចូល** ការផលិតផលិតផលនំប៉័ង(ដូចជាការដុតនំនៅក្នុងអគារ)(មើល១០៧១)។

ជំពូក ធ ៖ អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទ
ផ្នែក ៤៧ ៖ អាជីវកម្មលក់រាយ លើកលែងតែយានយន្តនិងទោចក្រយានយន្ត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៤៧៣			**ការលក់រាយប្រេងឥន្ធនៈយានយន្តនៅក្នុងហាងឯកទេស**
	៤៧៣០[១]		ការលក់រាយប្រេងឥន្ធនៈយានយន្តនៅក្នុងហាងឯកទេស
		៤៧៣០០	លក់រាយនូវប្រេងឥន្ធនៈសម្រាប់យានយន្ត ឬទោច្រកយានយន្ត[២]
៤៧៤			**ការលក់រាយឧបករណ៍ផ្នែកព័ត៌មាន និងទំនាក់ទំនងនៅក្នុងហាងឯកទេស**
	៤៧៤១[៣]		ការលក់រាយនូវកុំព្យូទ័រ គ្រឿងកុំព្យូទ័រ កម្មវិធីកុំព្យូទ័រ និងឧបករណ៍ទំនាក់ទំនងផ្សេងទៀតនៅក្នុងហាងឯកទេស
		៤៧៤១១	ការលក់រាយនូវកុំព្យូទ័រ និងឧបករណ៍បន្ទាប់បន្សំ[៤]
		៤៧៤១២	ការលក់រាយឧបករណ៍លេងហ្គេម
		៤៧៤១៣	ការលក់រាយកម្មវិធីសម្រាប់ប្រើទូទៅ រួមមានវីឌីអូហ្គេម
		៤៧៤១៤	ការលក់រាយទូរស័ព្ទដៃ និងឧបករណ៍ទូរគមនាគមន៍ផ្សេងៗ
	៤៧៤២		លក់រាយឧបករណ៍វីឌីអូ និងសោតទស្សន៍នៅក្នុងហាងឯកទេស
		៤៧៤២១	ការលក់រាយគ្រឿងវិទ្យុ និងទូរទស្សន៍
		៤៧៤២២	ការលក់រាយម៉ាស៊ីនចាក់ និងម៉ាស៊ីនថតស៊ីឌី និងឌីវីឌី និងឧបករណ៍បំពងសម្លេង និងឧបករណ៍សម្លេង
៤៧៥			**ការលក់រាយឧបករណ៍ប្រើប្រាស់ក្នុងគ្រួសារផ្សេងៗក្នុងហាងឯកទេស**
	៤៧៥១[៥]		ការលក់រាយផលិតផលវាយនភណ្ឌនៅក្នុងហាងឯកទេស
		៤៧៥១០	ការលក់រាយផលិតផលវាយភ័ណ្ឌ ក្រណាត់ និងអំបោះសម្រាប់ចាក់[៦]
	៤៧៥២		ការលក់រាយសម្ភារៈផ្នែករឹង ថ្នាំលាប និងកែវនៅក្នុងហាងឯកទេស
		៤៧៥២០	ការលក់រាយសម្ភារៈផ្នែករឹង ថ្នាំលាប និងកែវ[៧]

(១) **មិនរាប់បញ្ចូល** (ក) លក់ដុំរបស់ប្រេងឥន្ធនៈ (មើល ៤៦៦១)
(ខ) លក់រាយប្រេងឥន្ធនៈ ជាមួយនិងអាហារ ភេសជ្ជៈ។ល។ ដោយភាគច្រើនលក់អាហារ និងភេសជ្ជៈ (មើល ៤៧១១)
(គ) លក់រាយឧស្ម័នឥន្ធនៈរាវសម្រាប់ចម្អិននិងកំដៅ (មើល ៤៧៧៣៥)។

(២) **រាប់បញ្ចូល** លក់រាយផលិតផលប្រេងរំអិល និងផលិតផលស្អំសម្រាប់យានយន្ត។

(៣) **មិនរាប់បញ្ចូល** លក់រាយឌីស និងការសែតមិនទាន់ថតបញ្ចូល (មើល ៤៧៦២)។

(៤) **រាប់បញ្ចូល** លក់រាយម៉ាស៊ីនបោះពុម្ពម៉ាស៊ីនស្កែន។ល។

(៥) **មិនរាប់បញ្ចូល** លក់រាយសម្លៀកបំពាក់ (មើល ៤៧៧១)។

(៦) **រាប់បញ្ចូល** ម្ជុលដេរអំបោះដេរ។ល។

(៧) **រាប់បញ្ចូល** (ក) សម្ភារៈសំណង់
(ខ) សម្ភារៈ ឬឧបករណ៍ដំឡើងដោយខ្លួនឯង
(គ) លក់ម៉ាស៊ីនកាត់ស្មៅ។

ជំពូក ធ ៖ អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទ
ផ្នែក ៤៧ ៖ អាជីវកម្មលក់រាយ លើកលែងតែយានយន្តនិងទោចក្រយានយន្ត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	៤៧៥៣		ការលក់រាយកម្រាលព្រំ ក្រណាត់ជូតជើង សម្ភារៈក្រាលកម្រាល និងជញ្ជាំង នៅក្នុងហាងឯកទេស
		៤៧៥៣១	ការលក់រាយកម្រាលព្រំ និងក្រណាត់ជូតជើង
		៤៧៥៣២	ការលក់រាយវាំងនន និងវាំងននសំណាញ់
		៤៧៥៣៣	ការលក់រាយក្រដាសបិតជញ្ជាំង ឥដ្ឋស៊ីរ៉ាមិច និងកម្រាលផ្សេងៗ
	៤៧៥៩[១]		ការលក់រាយឧបករណ៍អេឡិចត្រូនិកប្រើប្រាស់ក្នុងផ្ទះ និងគ្រឿងសង្ហារិម ឧបករណ៍បំភ្លឺ និងឧបករណ៍ដទៃទៀត នៅក្នុងហាងឯកទេស
		៤៧៥៩១	ការលក់រាយគ្រឿងសង្ហារិមនៅក្នុងផ្ទះ[២]
		៤៧៥៩២	ការលក់រាយគ្រឿងបំភ្លឺ
		៤៧៥៩៣	ការលក់រាយសម្ភារៈប្រើក្នុងផ្ទះបាយ កាំបិត ចង្ក្រាន កែវ ចាន និងឆ្នាំង
		៤៧៥៩៤	ការលក់រាយឧបករណ៍ប្រើក្នុងផ្ទះ
		៤៧៥៩៥	ការលក់រាយឧបករណ៍តន្ត្រីសៀវភៅភ្លេង
		៤៧៥៩៦	ការលក់រាយប្រព័ន្ធសុវត្ថិភាព[៣]
		៤៧៥៩៩	ការលក់រាយឧបករណ៍និងសម្ភារៈប្រើក្នុងគ្រួសារដែលមិនបានរាប់ចូល
៤៧៦			**ការលក់រាយទំនិញវប្បធម៌ និងកម្សាន្តនៅក្នុងហាងឯកទេស**
	៤៧៦១[៤]		ការលក់រាយសៀវភៅ កាសែត សម្ភារៈការិយាល័យក្នុងហាងឯកទេស
		៤៧៦១១	ការលក់រាយឧបករណ៍ និងបរិក្ខារប្រើក្នុងការិយាល័យ
		៤៧៦១២	ការលក់រាយសៀវភៅ កាសែត សម្ភារៈការិយាល័យ
	៤៧៦២		ការលក់រាយតន្ត្រីនិងវីឌីអូ នៅក្នុងហាងឯកទេស[៥]
		៤៧៦២០	ការលក់រាយតន្ត្រី និងវីឌីអូ ដែលថតដាក់ឌីស វីស៊ីឌី និងឌីវីឌី
	៤៧៦៣		ការលក់រាយឧបករណ៍កីឡានៅក្នុងហាងឯកទេស
		៤៧៦៣១	ការលក់រាយទំនិញ និងឧបករណ៍កីឡា រួមមានប្រដាប់ស្ទូចត្រី
		៤៧៦៣២	ការលក់រាយទំនិញសម្រាប់បោះជំរុំ
		៤៧៦៣៣	ការលក់រាយទូក និងឧបករណ៍ពាក់ព័ន្ធ
		៤៧៦៣៤	ការលក់រាយកង់ និងគ្រឿងបន្លាស់ និងគ្រឿងបន្ទាប់បន្សំ

(១) **មិនរាប់បញ្ចូល** លក់រាយវត្ថុបុរាណ (មើល ៤៧៧៤៣)។
(២) **រាប់បញ្ចូល** គ្រឿងសង្ហារិមធ្វើពីផ្តៅ និងឈើ។
(៣) **រាប់បញ្ចូល** គ្រឿងចាក់សោ សុវត្ថិភាព បន្ទប់រក្សាសុវត្ថិភាពក្រោមដី។
(៤) **មិនរាប់បញ្ចូល** លក់រាយសៀវភៅចាស់ប្រើប្រាស់រួច ឬសៀវភៅបុរាណ (មើល ៤៧៧៤)។
(៥) **រាប់បញ្ចូល** កាសែត និងកាសែតវីឌីអូមិនទាន់ថតចម្លងចូល។

ជំពូក ធ ៖ អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទ
ផ្នែក ៤៧ ៖ អាជីវកម្មលក់រាយ លើកលែងតែយានយន្តនិងទោចក្រយានយន្ត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	៤៧៦៤[១]		ការលក់រាយហ្គេម និងប្រដាប់ក្មេងលេងនៅក្នុងហាងឯកទេស
		៤៧៦៤០	ការលក់រាយហ្គេម និងប្រដាប់ក្មេងលេខ ធ្វើពីគ្រប់សារធាតុ
៤៧៧			**ការលក់រាយទំនិញផ្សេងៗទៀតនៅក្នុងហាងឯកទេស**
	៤៧៧១[២]		ការលក់រាយសម្លៀកបំពាក់ ផលិតផលពាក់នឹងជើង និងផលិតផលស្បែកនៅក្នុងហាងឯកទេស
		៤៧៧១១	ការលក់រាយសម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំ[៣]
		៤៧៧១២	ការលក់រាយផលិតផលពាក់នឹងជើង
	៤៧៧២		ការលក់រាយឱសថគ្រឿងសម្អាង ផលិតផលប្រើក្នុងបង្គន់នៅក្នុងហាងឯកទេស
		៤៧៧២១	ហាងមានឯកទេសលក់រាយឱសថ
		៤៧៧២២	ហាងមានឯកទេសលក់រាយទឹកអប់ និងគ្រឿងសម្អាង
	៤៧៧៣		ការលក់រាយផលិតផលថ្មីផ្សេងៗទៀតនៅក្នុងហាងឯកទេស
		៤៧៧៣១	ការលក់រាយឧបករណ៍រូបថត និងឧបករណ៍កំណត់ទីតាំងជាក់លាក់
		៤៧៧៣២	ការលក់រាយនាឡិកាដៃ នាឡិការព្យួរជញ្ជាំង និងគ្រឿងអលង្ការ
		៤៧៧៣៣	ការលក់រាយផ្កា រុក្ខជាតិ គ្រាប់ពូជ ជី
		៤៧៧៣៤	ការលក់រាយវត្ថុអនុស្សាវរីយ៍ ផលិតផលសិប្បកម្ម សម្ភារៈសាសនា
		៤៧៧៣៥	ការលក់រាយប្រេងឥន្ធនៈប្រើក្នុងផ្ទះ ឧស្ម័នដប ធ្យូង អុស
		៤៧៧៣៦	ការលក់រាយវ៉ែនតា និងផលិតផលអុបទិកផ្សេងៗទៀត[៤]
		៤៧៧៣៧	ការលក់រាយត្រី សត្វចិញ្ចឹម និងចំណីសម្រាប់សត្វចិញ្ចឹម

(១) **មិនរួមបញ្ចូល** (ក) លក់រាយប្រដាប់លេងវីឌីអូហ្គេម (មើល ៤៧៤១៣)
(ខ) លក់រាយកម្មវិធីទូទៅ រួមមានវីដេអូហ្គេម (មើល ៤៧៤១៤)។

(២) **មិនរួមបញ្ចូល** លក់រាយផលិតផលវាយនភ័ណ្ឌ (មើល ៤៧៥១០)។

(៣) **រួមបញ្ចូល**លក់រាយស្រោមដៃ ក្រវ៉ាត់កប្រដាប់រឹត។ល។

(៤) **រួមបញ្ចូល**សកម្មភាពរបស់ជាងវ៉ែនតា។

ជំពូក ធ ៖ អាជីវកម្មលក់ដុំនិងលក់រាយ ជួសជុលយានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទ
ផ្នែក ៤៧ ៖ អាជីវកម្មលក់រាយ លើកលែងតែយានយន្តនិងទោចក្រយានយន្ត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	៤៧៧៤(១)		ការលក់រាយផលិតផលជជុះ
		៤៧៧៤១	ការលក់រាយសៀវភៅជជុះ
		៤៧៧៤២	ការលក់រាយផលិតផលអគ្គិសនី និងអេឡិចត្រូនិកជជុះ
		៤៧៧៤៣	ការលក់រាយវត្ថុបុរាណ
		៤៧៧៤៩	ការលក់រាយផលិតផលជជុះផ្សេងៗ(២)
៤៧៨			**ការលក់រាយនៅតាមតូបនិងទីផ្សារ**
	៤៧៨១(៣)		ការលក់រាយអាហារ ភេសជ្ជៈ ថ្នាំជក់នៅតាមតូប និងក្នុងផ្សារ
		៤៧៨១០	ការលក់រាយអាហារ ភេសជ្ជៈ ថ្នាំជក់នៅតាមតូប និងទីផ្សារ
	៤៧៨២		ការលក់រាយផលិតផលវាយណភ័ណ្ឌ សម្លៀកបំពាក់ ផលិតផលពាក់នឹងជើងនៅតាមតូប និងទីផ្សារ
		៤៧៨២០	ការលក់រាយផលិតផលវាយណភណ្ឌ សម្លៀកបំពាក់ ផលិតផលពាក់នឹងជើងនៅតាមតូប និងទីផ្សារ
	៤៧៨៩		ការលក់ទំនិញផ្សេងៗនៅតាមតូប និងទីផ្សារ
		៤៧៨៩១	ការលក់រាយកម្រាលព្រំ និងកម្រាលជើងនៅតាមតូប ឬទីផ្សារ
		៤៧៨៩២	ការលក់រាយសៀវភៅនៅតាមតូប ឬទីផ្សារ
		៤៧៨៩៣	ការលក់រាយហ្គេម និងប្រដាប់ក្មេងលេងនៅតាមតូប ឬទីផ្សារ
		៤៧៨៩៤	ការលក់រាយគ្រឿងបរិក្ខារប្រើក្នុងផ្ទះ និងគ្រឿងអេឡិចត្រូនិកសម្រាប់អ្នកប្រើប្រាស់នៅតាមតូប ឬទីផ្សារ
		៤៧៨៩៥	ការលក់រាយតន្ត្រី និងវីឌេអូនៅតាមតូប ឬទីផ្សារ
៤៧៩			**ការលក់រាយ ឬជួលមិននៅក្នុងហាងតូប ឬទីផ្សារ**
	៤៧៩១		ការលក់រាយតាមកន្លែងបញ្ជាទិញតាមសារ ឬតាមអ៊ីនធឺណិត
		៤៧៩១១	ការលក់រាយតាមប្រព័ន្ធតាមសារ ឬតាមអ៊ីនធឺណិត
		៤៧៩១២	**សកម្មភាព**ជួល ឬផ្លាស់ប្តូរទំនិញ ឬសេវាតាមប្រព័ន្ធអេឡិចត្រូនិក
	៤៧៩៩(៤)		លក់រាយផ្សេងទៀតដែលមិននៅក្នុងហាង តូប ឬទីផ្សារ
		៤៧៩៩៩	លក់រាយផ្សេងៗទៀតដែលមិននៅក្នុងហាង តូប ឬទីផ្សារ(៥)

(១) **មិនរាប់បញ្ចូល** (ក) លក់រាយយានយន្តជជុះ (មើល ៤៥១០)
(ខ) សកម្មភាពនៃហាងបញ្ចាំ (មើល ៦៤៩២១)។

(២) **រាប់បញ្ចូល** លក់រាយតែមប្រៃសណីយ៍ និងកាក់។

(៣) **មិនរាប់បញ្ចូល** លក់រាយអាហារដែលចម្អិនស្រាប់ សម្រាប់ទទួលទានភ្លាម (អ្នកលក់អាហារចល័ត) (មើល ៥៦១០)។

(៤) **មិនរាប់បញ្ចូល** ចែកចាយផលិតផលថ្មីដោយតូប (មើលក្រុម ៤៧១ ដល់ ៤៧៧)។

(៥) **រាប់បញ្ចូល** លក់ដោយផ្ទាល់ប្រេងឥន្ធនៈ ការផ្ញើម៉ាយីតជីងជាបណ្តាញ។

ជំពូក ជ ៖ ការដឹកជញ្ជូន និងការស្តុកទុក

កម្រិត	ច.ស.វ.ក
ជំពូក	១
ផ្នែក	៥
ក្រុម	១១
ថ្នាក់	២០
ថ្នាក់រង	៣៧

ជំពូកនេះរាប់បញ្ចូលការផ្តល់ការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរទាំងបាន ឬមិនបានគ្រោងទុក តាមរយៈផ្លូវដែក បំពង់ ផ្លូវគោក ផ្លូវទឹក ឬផ្លូវអាកាស និងសកម្មភាពពាក់ព័ន្ធ ដូចជាកន្លែងចំណត កន្លែងចាក់ចេញនិងមកដល់ ការទុកដាក់ទំនិញ និងការស្តុកទុក។ល។ ជំពូកនេះក៏រាប់បញ្ចូលផងដែរនូវការជួលយានដឹកជញ្ជូនរួមទាំងអ្នកបញ្ជា ឬអ្នកបើកបរ។ វាក៏រាប់បញ្ចូលផងដែរនូវសកម្មភាពបញ្ញើ និងប្រៃសណីយ៍។

ជំពូកនេះមិនរាប់បញ្ចូលការជួសជុល និងថែទាំយានយន្ត និងយានដឹកជញ្ជូនដទៃផ្សេងទៀត (មើលថ្នាក់ ៤៥២០ និង ៣៣១៥ រៀងគ្នា) ការសាងសង់ ការជួសជុលថែទាំ និងជួសជុលផ្លូវ ផ្លូវដែក ចំណតនាវា វាលយន្តហោះ (មើលថ្នាក់ ៤២១០ និង៤២៩០) ព្រមទាំងការជួលយានយន្តដឹកជញ្ជូនដោយគ្មានអ្នកបញ្ជា ឬអ្នកបើកបរ (មើលថ្នាក់ ៧៧១០និង ៧៧៣០)។

ផ្នែក ៤៩ ៖ ការដឹកជញ្ជូនតាមផ្លូវគោក និងតាមប្រព័ន្ធបំពង់

ផ្នែកនេះរាប់បញ្ចូល ការដឹកជញ្ជូនទំនិញ និងអ្នកដំណើរ តាមផ្លូវគោក និងផ្លូវដែក ព្រមទាំងការដឹកជញ្ជូនទំនិញតាមបំពង់។

ក្រុម ៤៩១ ៖ ការដឹកជញ្ជូនតាមផ្លូវដែក

ក្រុមនេះរាប់បញ្ចូលនូវការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរតាមផ្លូវដែកដោយប្រើប្រាស់ បណ្តាញមេផ្លូវដែកដែលជាធម្មតាលាតសន្ធឹងលើតំបន់ភូមិសាស្ត្រដ៏វែង។ ការដឹកជញ្ជូនទំនិញតាមផ្លូវដែក លើផ្លូវដែកក្នុងរយៈចម្ងាយខ្លី ក៏រាប់បញ្ចូលផងដែរ។

ក្រុមនេះមិនរាប់បញ្ចូលការដឹកជញ្ជូនអ្នកដំណើរនៅទីប្រជុំជន និងតំបន់ជាយក្រុងតាម ផ្លូវគោក (មើល ៤៩២១) សកម្មភាពពាក់ព័ន្ធដូចជាផ្លាស់ប្តូរផ្លូវដែក និងទាញទូរថភ្លើង (មើល ៥២២១) និងការប្រតិបត្តិហេដ្ឋារចនាសម្ព័ន្ធផ្លូវដែក (មើល ៥២២១)។

ក្រុម ៤៩២ ៖ ការដឹកជញ្ជូនតាមផ្លូវគោកផ្សេងទៀត

ក្រុមនេះរាប់បញ្ចូលនូវសកម្មភាពដឹកជញ្ជូនតាមផ្លូវគោកទាំងអស់លើកលែងតែការដឹក ជញ្ជូនតាមផ្លូវដែក។ ប៉ុន្តែក្រុមនេះក៏រាប់បញ្ចូលផងដែរនូវការដឹកជញ្ជូនតាមផ្លូវដែកដែលជាផ្នែកមួយនៃប្រព័ន្ធដឹកជញ្ជូននៅទីប្រជុំជននិងតំបន់ជាយក្រុង។

ក្រុម ៤៩៣ ៖ ការដឹកជញ្ជូនតាមប្រព័ន្ធបំពង់

ក្រុមនេះរាប់បញ្ចូលនូវការដឹកជញ្ជូនឧស្ម័ន វត្ថុរាវ ទឹក ល្បាយលាយ និងទំនិញផ្សេងទៀតតាមប្រព័ន្ធបំពង់ និងនូវការប្រតិបត្តិស្ថានីយបូម។

ជំពូក ជ ៖ ការដឹកជញ្ជូន និងការស្តុកទុក
ផ្នែក ៤៩ ៖ ការដឹកជញ្ជូនតាមផ្លូវគោក និងតាមប្រព័ន្ធបំពង់

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៤៩១			**ការដឹកជញ្ជូនតាមផ្លូវដែក**
	៤៩១១[(១)]		ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវដែក ឬវាងទីប្រជុំជន
		៤៩១១០	ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវដែកវាងទីប្រជុំជន
	៤៩១២[(២)]		ការដឹកជញ្ជូនទំនិញតាមផ្លូវដែក
		៤៩១២០	ការដឹកជញ្ជូនទំនិញតាមផ្លូវដែកវាងទីប្រជុំជន តំបន់ជាយក្រុង វាងទីប្រជុំជន
៤៩២			**ការដឹកជញ្ជូនតាមផ្លូវគោកផ្សេងទៀត**
	៤៩២១		ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវគោកនៅទីប្រជុំជន និងតំបន់ជាយក្រុង
		៤៩២១១	សេវាកម្មរថយន្តដឹកអ្នកដំណើរនៅក្រុង
	៤៩២២		ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវគោកផ្សេងទៀត
		៤៩២២១	សេវាកម្មរថយន្តដឹកអ្នកដំណើរតាមជនបទ និងវាងទីក្រុង
		៤៩២២២	សេវាកម្មរថយន្តឈ្នួល និងរថយន្តទំនើប
		៤៩២២៣	ការជួលរថយន្តដោយមានអ្នកបើកបរ
		៤៩២២៤	រ៉ឺម៉កម៉ូតូ[(៣)]
		៤៩២២៥	ម៉ូតូឌុប
		៤៩២២៩	ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវគោកផ្សេងទៀត[(៤)]

(១) **មិនរាប់បញ្ចូល** សកម្មភាពចំណតអ្នកដំណើរ (មើល ៥២២១១)។

(២) **មិនរាប់បញ្ចូល** ស្តុកទុក និងការស្តុកទំនិញក្នុងឃ្លាំង (មើល ៥២១០០) សកម្មភាពចំណតទំនិញ (មើល ៥២២១១) ការទុកដាក់ទំនិញ (មើល ៥២២៤)។

(៣) ត្រូវបានគេហៅថា “តុក តុក”។

(៤) **រាប់បញ្ចូល** ការជួលយន្តហោះ សេវាកម្មរថយន្តដឹកជញ្ជូនម្តងម្កាល និងក្នុងរយៈខ្លី និងយានចម្លងនៅវាលយន្តហោះ។

ជំពូក ជ ៖ ការដឹកជញ្ជូន និងការស្តុកទុក
ផ្នែក ៤៩ ៖ ការដឹកជញ្ជូនតាមផ្លូវគោក និងតាមប្រព័ន្ធបំពង់

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	៤៩២៣[១]		ការដឹកជញ្ជូនទំនិញតាមផ្លូវគោក
		៤៩២៣០	ការដឹកជញ្ជូនទំនិញតាមផ្លូវគោក
៤៩៣			**ការដឹកជញ្ជូនតាមប្រព័ន្ធបំពង់**
	៤៩៣០[២]		ការដឹកជញ្ជូនតាមប្រព័ន្ធបំពង់
		៤៩៣០០	ការដឹកជញ្ជូនតាមប្រព័ន្ធបំពង់

(១) **រាប់បញ្ចូល**
- (ក) ការដឹកជញ្ជូនឈើហុប ស្តុក និងយានយន្ត
- (ខ) ការដឹកជញ្ជូនវត្ថុធំៗ និងទំនិញភ្លាសេ្ទ
- (គ) ការដឹកជញ្ជូនធំៗ ដូចជាការដឹកតាមរថយន្តស៊ីទែន (ឧ. រថយន្តស៊ីទែនដឹកប្រេងដូង)
- (ឃ) ការដឹកជញ្ជូនកាកសំណល់ សម្ភារៈកាក់សំណល់ ដោយមិនមានការប្រមូល ឬបញ្ចេញចោល
- (ង) ការជួលរថយន្តដឹកទំនិញដោយមានអ្នកបើកបរ
- (ច) ការដឹកជញ្ជូនទំនិញដោយយានទាញដោយសត្វ ឬមនុស្ស

មិនរាប់បញ្ចូល
- (ក) ការដឹកជញ្ជូលឈើហុបនៅក្នុងព្រៃ ជាផ្នែកនៃប្រតិបត្តិការកាប់ឈើ (មើល ០២៤០១)
- (ខ) ការចែកចាយទឹកដោយដឹកតាមរថយន្ត (មើល ៣៦០០)
- (គ) ការប្រតិបត្តិការអាគារចំណតសម្រាប់ទុកដាក់ទំនិញ (មើល ៥២២១១)
- (ឃ) សេវាកម្មកម្មវេចខ្ចប់ និងដាក់ក្នុងកេសឈើសម្រាប់ដឹកជញ្ជូន(មើល ៥២២៩៩)
- (ង) សកម្មភាពសេវាប្រៃសណីយ៍ (មើល ៥៣១០០) និងសកម្មភាពបញ្ញើ (មើល ៥៣២០០)
- (ច) ការដឹកជញ្ជូនកាកសំណល់ ជាផ្នែករួមនៃសកម្មភាពប្រមូលកាកសំណល់ (មើល ៣៨១១ ៣៨១២)។

(២) **រាប់បញ្ចូល**
- (ក) ការដឹកជញ្ជូនឧស្ម័ន វត្ថុរាវ ទឹក ល្បាយ និងទំនិញតាមប្រព័ន្ធបំពង់
- (ខ) ការប្រតិបត្តិការស្ថានីយបូមទឹក

មិនរាប់បញ្ចូល
- (ក) ការបែងចែកឧស្ម័នពីធម្មជាតិ ឬឧស្ម័នដែលផលិត ទឹក ឬចំហាយ (មើល ៣៥២០ ៣៥៣០ ៣៦០០)
- (ខ) ដឹកជញ្ជូនទឹកវត្ថុរាវដោយរថយន្ត។ល។(មើល៤៩២៣)។

ផ្នែក ៥០ ៖ ការដឹកជញ្ជូនតាមផ្លូវទឹក

ផ្នែកនេះរាប់បញ្ចូលនូវការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរតាមផ្លូវទឹកទាំងបាន និងមិនបានគ្រោងទុក។ វាក៏រាប់បញ្ចូលផងដែរនូវប្រតិបត្តិការអូសនិងរុញទូក ការធ្វើដំណើរខ្លីៗ ទូកជិះមើលទេសភាព សាឡាង យាន្តឈ្នួលតាមទឹក។ល។ ទោះបីជាទីកន្លែង គឺជាសូចនាករ មួយដែលបញ្ជាក់ពីភាពខុសគ្នារវាងការដឹងជញ្ជូនតាមសមុទ្រ និងផ្លូវទឹកសាបក្តី ប្រភេទនាវា ដែលបានប្រើប្រាស់ គឺជាកត្តាសម្រេច។ ការដឹកជញ្ជូនទាំងអស់នៅលើនាវាឆ្ពោះទៅកាន់ សមុទ្រត្រូវបានចាត់ថ្នាក់ក្នុងក្រុម ៥០១ ខណៈដែលការដឹកជញ្ជូនដោយប្រើនាវាផ្សេងៗទៀត គឺត្រូវចាត់ថ្នាក់ចូលក្នុងក្រុម ៥០២។

ផ្នែកនេះមិនរាប់បញ្ចូលសកម្មភាពភោជនីយដ្ឋាន រង្គសាលនៅលើនាវា (មើលថ្នាក់ ៥៦១០ និង ៥៦៣០) ប្រសិនបើវាធ្វើឡើងដោយអង្គភាពដាច់ដោយឡែក។

ក្រុម ៥០១ ៖ ការដឹកជញ្ជូននៅទឹកសមុទ្រជ្រៅ និងក្បែរតំបន់ឆ្នេរ

ក្រុមនេះរាប់បញ្ចូល ការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរលើនាវា ដែលសម្រាប់ប្រតិបត្តិការនៅទឹកសមុទ្រជ្រៅ និងក្បែរតំបន់ឆ្នេរ។ វាក៏រាប់បញ្ចូលផងដែរ ការដឹកជញ្ជូនទំនិញឬអ្នកដំណើរនៅតាមបឹងធំៗ។ល។ នៅពេលដែលប្រើប្រាស់ប្រភេទនាវាស្រដៀងគ្នានេះ។

ក្រុម ៥០២ ៖ ការដឹកជញ្ជូនតាមផ្លូវទឹកសាប

ក្រុមនេះរាប់បញ្ចូលនូវការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរតាមផ្លូវទឹកសាបដែលពាក់ព័ន្ធ ទៅនឹងនាវាដែលមិនមានលក្ខណៈសមស្រប សម្រាប់ការដឹកជញ្ជូនតាមផ្លូវសមុទ្រ។

ជំពូក ជ ៖ ការដឹកជញ្ជូន និងការស្តុកទុក
ផ្នែក ៥០ ៖ ការដឹកជញ្ជូនតាមផ្លូវទឹក

ក្រុម	ថ្នាក់	ថ្នាក់រង	ការអធិប្បាយ
៥០១			**ការដឹកជញ្ជូននៅទឹកសមុទ្រជ្រៅ និងក្បែរតំបន់ឆ្នេរ**
	៥០១១[១]		ការដឹកជញ្ជូនអ្នកដំណើរតាមទឹកសមុទ្រជ្រៅ និងក្បែរតំបន់ឆ្នេរ
		៥០១១០	ការដឹកជញ្ជូនអ្នកដំណើរតាមទឹកសមុទ្រជ្រៅ និងក្បែរតំបន់ឆ្នេរ
	៥០១២[២]		ការដឹកជញ្ជូនតំបន់តាមទឹកសមុទ្រជ្រៅ និងក្បែរតំបន់ឆ្នេរ
		៥០១២០	ការដឹកជញ្ជូនតំបន់តាមទឹកសមុទ្រជ្រៅ និងក្បែរតំបន់ឆ្នេរ
៥០២			**ការដឹកជញ្ជូនតាមផ្លូវទឹកសាប**
	៥០២១		ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវទឹកសាប
		៥០២១១	សាឡាង
		៥០២១២	ការដឹកជញ្ជូនអ្នកដំណើរតាមទន្លេ ព្រែក បឹង និងផ្លូវទឹកសាបដទៃទៀត រួមមានទាំងនៅក្នុងកំពង់ផែ
		៥០២១៣	ការជួលទូកជិះកម្សាន្តដោយមានអ្នកបើកបរសម្រាប់ដឹកជញ្ជូននៅផ្លូវទឹកសាប
	៥០២២		ការដឹកជញ្ជូនទំនិញតាមផ្លូវទឹកសាប
		៥០២២០	ការដឹកជញ្ជូនអ្នទំនិញតាមទន្លេ ព្រែក បឹង និងផ្លូវទឹកសាបដទៃទៀត រួមមានទាំងនៅក្នុងផែ

(១) **មិនរាប់បញ្ចូល**
(ក) សកម្មភាពវង្គសាលនិងភោជនីយដ្ឋានលើនាវា ដែលផ្តល់ដោយអង្គភាពមួយដាច់ដោយឡែក (មើល ៥៦១០ និង ៥៦៣០)
(ខ) ប្រតិបត្តិការការស៊ីណូបណ្តែតទឹក (មើល៩២០០០)។

(២) **មិនរាប់បញ្ចូល**
(ក) ការស្តុកទំនិញ (មើល ៥២១០)
(ខ) ការប្រតិបត្តិកំពង់ផែ និងសកម្មភាពបន្ថែមផ្សេងទៀត (ឧ. ចំណតផែ ការបើកបរនាវា ការបើកបរសាឡង់ ការស្រោចស្រង់នាវា) (មើល ៥២២២)
(គ) ការទុកដាក់ទំនិញ (មើល ៥២២៤) ។

ផ្នែក ៥១ ៖ ការដឹកជញ្ជូនតាមផ្លូវអាកាស

ផ្នែកនេះរាប់បញ្ចូលការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរតាមផ្លូវអាកាស ឬតាមអវកាស។

ផ្នែកនេះមិនរាប់បញ្ចូលត្រួតពិនិត្យអាកាសយាន ឬម៉ាស៊ីនអាកាសយាន (មើលថ្នាក់ ៣៣១៥) និងសកម្មភាពគាំទ្រនានា ដូចជាប្រតិបត្តិការអាកាសយានដ្ឋាន (មើលថ្នាក់ ៥២២៣)។ ផ្នែកនេះមិនរាប់បញ្ចូលសកម្មភាពដែលប្រើប្រាស់អាកាសយាន មិនមែនក្នុងគោលបំណងសម្រាប់ការដឹកជញ្ជូន ដូចជា ការស្រោចដំណាំ (មើលថ្នាក់ ០១៦១) ការផ្សាយពាណិជ្ជកម្មពីលើអាកាស (មើលថ្នាក់ ៧៣១០) ឬការថតពីលើអាកាស (មើលថ្នាក់ ៧៤២០)។

ក្រុម ៥១១ ៖ ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស

ក្រុមនេះរាប់បញ្ចូល ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស លើផ្លូវហោះហើរធម្មតា និងលើជើងហោះហើរតាមកម្មវិធី (ជើងហោះហើរជាប្រក្រតី) និងក្រៅកម្មវិធី (ជើងហោះហើរជួល) សម្រាប់អ្នកដំណើរ ការហោះហើរសម្រាប់កម្សាន្ត ឬមើលទេសភាព, ការជួលអាកាសយានដឹកជញ្ជូនផ្លូវអាកាសរួមទាំងប្រតិបត្តិករ ក្នុងគោលបំណងសកម្មភាពដឹកអ្នកដំណើរតាមផ្លូវអាកាស និងសកម្មភាពអាកាសចរជាទូទៅ ដូចជា ការដឹកជញ្ជូនអ្នកដំណើរដោយក្លឹបហោះហើរផ្លូវអាកាសសម្រាប់ការបង្ហាត់បង្រៀន ឬដំណើរកម្សាន្តជាដើម។

ក្រុម ៥១២ ៖ ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាស

ក្រុមនេះរាប់បញ្ចូលការដឹកជញ្ជូនទំនិញតាមផ្លូវអាកាស លើផ្លូវហោះហើរធម្មតា និងលើជើងហោះហើរតាមកម្មវិធី និងការដឹកជញ្ជូនទំនិញតាមផ្លូវអាកាសក្រៅកម្មវិធី (ជើងហោះហើរជួល) និងការបាញ់បង្ហោះផ្កាយរណប និងយានអវកាស។

ជំពូក ជ ៖ ការដឹកជញ្ជូន និងការស្តុកទុក

ផ្នែក ៥១ ៖ ការដឹកជញ្ជូនតាមផ្លូវអាកាស

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៥១១			**ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស**
	៥១១០[១]		ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស
		៥១១០០	ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសអន្តរជាតិ
		៥១១០១	ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសក្នុងស្រុក
៥១២			**ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាស**
	៥១២០		ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាស
		៥១២០០	ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាសអន្តរជាតិ
		៥១២០១	ការដឹកជញ្ជូនទំនិញតាមផ្លូវអាកាសក្នុងស្រុក

(១) **រាប់បញ្ចូល**

(ក) ជួលជើងហោះហើរសម្រាប់អ្នកដំណើរ (ឧ. ឧទ្ធម្ភាគចក្រ។ល។)

(ខ) ការហោះហើរមើលទេសភាព និងកម្សាន្ត

(គ) សកម្មភាពអាកាសចរណ៍ទូទៅ (ឧ. ការដឹកជញ្ជូនអ្នកដំណើរដោយក្លឹបផ្លូវអាកាសសម្រាប់ការបង្ហាត់បង្រៀន ឬដំណើរកម្សាន្ត)។

ផ្នែក ៥២ ៖ ការស្តុកទំនិញក្នុងឃ្លាំង និងសកម្មភាពគាំទ្រការដឹកជញ្ជូន

ផ្នែកនេះរាប់បញ្ចូល ការស្តុកទំនិញក្នុងឃ្លាំង និងសកម្មភាពគាំទ្រការដឹកជញ្ជូន ដូចជា ការប្រតិបត្តិហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ដូចជា ព្រលានយន្តហោះ កំពង់ផែ ផ្លូវក្រោមដីស្ពាន ។ល។) សកម្មភាពរបស់ភ្នាក់ងារដឹកជញ្ជូន និងការទុកដាក់ទំនិញ។

ក្រុម ៥២១ ៖ ការស្តុកទំនិញក្នុងឃ្លាំង និងការស្តុកទុក

ក្រុមនេះរាប់បញ្ចូលប្រតិបត្តិការទីកន្លែងស្តុកទំនិញ និងឃ្លាំងទំនិញ សម្រាប់ទំនិញគ្រប់ប្រភេទ ការស្តុកទំនិញក្នុងតំបន់ពាណិជ្ជកម្មក្រៅប្រទេស និងការបង្កក។

ក្រុម ៥២២ ៖ សកម្មភាពគាំទ្រការដឹកជញ្ជូន

ក្រុមនេះរាប់បញ្ចូលនូវសកម្មភាពគាំទ្រការដឹកជញ្ជូនទំនិញ និងអ្នកដំណើរ ដូចជាការប្រតិបត្តិផ្នែកមួយហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ឬសកម្មភាពដែលទាក់ទងទៅនឹងការដឹកជញ្ជូនទំនិញ ភ្លាមៗមុន ឬក្រោយការដឹកជញ្ជូន ឬនៅចន្លោះនៃការដឹកជញ្ជូនជាដំណាក់ៗ។ ការថែទាំ និងប្រតិបត្តិការទីកន្លែងសម្រាប់ការដឹកជញ្ជូនទាំងអស់ក៏រាប់បញ្ចូលផងដែរ។

ជំពូក ជ ៖ ការដឹកជញ្ជូន និងការស្តុកទុក
ផ្នែក ៥២ ៖ ការស្តុកទំនិញក្នុងឃ្លាំង និងសកម្មភាពគាំទ្រការដឹកជញ្ជូន

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៥២១			ការស្តុកទំនិញក្នុងឃ្លាំង និងការស្តុកទុក
	៥២១០[១]		ការស្តុកទំនិញក្នុងឃ្លាំង និងការស្តុកទុក
		៥២១០០	សេវាកម្មស្តុកទំនិញក្នុងឃ្លាំង និងការស្តុកទុក
៥២២			**សកម្មភាពគាំទ្រការដឹកជញ្ជូន**
	៥២២១[២]		សកម្មភាពសេវាកម្មអមសម្រាប់ការដឹកជញ្ជូនផ្លូវគោក
		៥២២១១	ប្រតិបត្តិការទីកន្លែងចំណត[៣]
		៥២២១២	ប្រតិបត្តិការផែស្ងួត
		៥២២១៣	ប្រតិបត្តិការកន្លែងចំណតសម្រាប់យានយន្ត[៤]
		៥២២១៩	សកម្មភាពសេវាកម្មអមផ្សេងៗទៀតសម្រាប់ការដឹកជញ្ជូនផ្លូវគោកដែលមិនបានរាប់បញ្ចូល[៥]

(១) **រាប់បញ្ចូល**
(ក) ប្រតិបត្តិការឃ្លាំងទំនិញនិងកន្លែងស្តុកទំនិញគ្រប់ប្រភេទ៖ប្រតិបត្តិការស៊ីឡូផ្ទុកគ្រាប់ធម្មជាតិ ឃ្លាំងទំនិញទូទៅ ការដឹកជញ្ជូនទំនិញ ឃ្លាំងទំនិញត្រជាក់ អាងស្តុកទំនិញ។ល។
(ខ) ឃ្លាំងស្តុកទំនិញក្នុងតំបន់ពាណិជ្ជកម្មក្រៅប្រទេស
(គ) ត្រជាក់កម្រិតខ្លាំង

មិនរាប់បញ្ចូល
(ក) កន្លែងចំណតសម្រាប់យានយន្ត (មើល ៥២២១៣)
(ខ) ការប្រតិបត្តិការទីតាំងឃ្លាំងទំនិញផ្ទាល់ខ្លួន (មើល ៦៨១០២)
(គ) ការជួលកន្លែងទំនេរ (មើល ៦៨១០)។

(២) **មិនរាប់បញ្ចូល** ការទុកដាក់ទំនិញ (មើល ៥២២៤)។

(៣) **រាប់បញ្ចូល** ប្រតិបត្តិការទីតាំងចំណតនានា ដូចជាស្ថានីយរថភ្លើង ស្ថានីយរថយន្តក្រុង ស្ថានីយទុកដាក់ទំនិញ សកម្មភាពចំណតដឹកជញ្ជូនទំនិញ។ល។

(៤) **មិនរាប់បញ្ចូល** សេវាកម្មប្រមូលកាក់ថ្លៃចត ឬការប្រមូលថ្លៃចតរថយន្តតាមទីចំណត ឬផ្លូវ (មើល ៨២៩៩០)។

(៥) **រាប់បញ្ចូល** ការពង្រាវឧស្ម័ន ក្នុងគោលដៅសម្រាប់ការដឹកជញ្ជូន។

ជំពូក ជ ៖ ការដឹកជញ្ជូន និងការស្តុកទុក

ផ្នែក ៥២ ៖ ការស្តុកទំនិញក្នុងឃ្លាំង និងសកម្មភាពគាំទ្រការដឹកជញ្ជូន

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	៥២២២(១)		សកម្មភាពសេវាកម្មអមសម្រាប់ការដឹកជញ្ជូនតាមផ្លូវទឹក
		៥២២២១	សេវាកម្មប្រតិបត្តិការកំពង់ផែ
		៥២២២២	សេវាកម្មជួយស្រង់ និងការដាក់បណ្តែតទឹកកប៉ាល់ឡើងវិញ
		៥២២២៩	សកម្មភាពសេវាកម្មអមផ្សេងទៀតសម្រាប់ការដឹកជញ្ជូនតាមផ្លូវទឹកដែលមិនបានរាប់បញ្ចូល
	៥២២៣ (២)		សកម្មភាពសេវាកម្មអមសម្រាប់ការដឹកជញ្ជូនតាមផ្លូវអាកាស
		៥២២៣០	សកម្មភាពសេវាកម្មអមសម្រាប់ការដឹកជញ្ជូនតាមផ្លូវអាកាស

(១) **មិនរាប់បញ្ចូល** (ក) ការទុកដាក់ទំនិញ (មើល ៥២២៤)

(ខ) ការប្រតិបត្តិការផ្លូវសមុទ្រ (មើល៩៣២៩)។

(២) **មិនរាប់បញ្ចូល** (ក) ការទុកដាក់ទំនិញ (មើល ៥២២៤)

(ខ) ការប្រតិបត្តិការសាលាបង្រៀនការហោះហើរ (មើល ៨៥៤៩)

រាប់បញ្ចូល **ការ**ប្រតិបត្តិការចំណតក្នុងព្រលានយន្តហោះ។ល។

ជំពូក ជ ៖ ការដឹកជញ្ជូន និងការស្តុកទុក
ផ្នែក ៥២ ៖ ការស្តុកទំនិញក្នុងឃ្លាំង និងសកម្មភាពគាំទ្រការដឹកជញ្ជូន

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	៥២២៤[១]		ការទុកដាក់ទំនិញ
		៥២២៤០	ការទុកដាក់ទំនិញ
	៥២២៩[២]		សកម្មភាពគាំទ្រដល់ការដឹកជញ្ជូនដទៃផ្សេងទៀត
		៥២២៩១	ការបញ្ជូនទំនិញ
		៥២២៩២	ការចេញ និងផ្តត់ផ្គងឯកសារដឹកជញ្ជូន
		៥២២៩៣	សកម្មភាពភ្នាក់ងាររៀបចំឯកសារគយ
		៥២២៩៩	សកម្មភាពគាំទ្រការដឹកជញ្ជូនដទៃផ្សេងទៀតដែលមិនបានរាប់បញ្ចូល[៣]

(១) **រាប់បញ្ចូល** ការលើកដាក់ និងលើកចេញទំនិញ ឬឥវ៉ាន់របស់អ្នកដំណើរ ដោយមិនគិតពីការប្រើប្រាស់ប្រភេទនៃការដឹកជញ្ជូនសម្រាប់សេវាកម្មដឹកជញ្ជូន និងលើកដាក់ទំនិញ

មិនរាប់បញ្ចូល ប្រតិបត្តិការកន្លែងចំណត (មើល៥២២១ ៥២២២ និង៥២២៣)។

(២) **រាប់បញ្ចូល** ប្រមូល និងដឹកជញ្ជូនទំនិញ និងការរៀបជាក្រុមការបញ្ជូនទំនិញ ប្រព័ន្ធរួម

មិនរាប់បញ្ចូល
- (ក) សកម្មភាពបញ្ញើ (មើល ៥៣២០)
- (ខ) ការផ្តល់ការធានារ៉ាប់រងដល់ការដឹកជញ្ជូន ផ្លូវគោក សមុទ្រ អាកាស និងម៉ូទ័រ(មើល ៦៥១២)
- (គ) សកម្មភាពរបស់ភ្នាក់ងារទេសចរណ៍ (មើល ៧៩១១០)
- (ឃ) សកម្មភាពប្រតិបត្តិករទេសចរណ៍ (មើល ៧៩១២០)
- (ង) សកម្មភាពជំនួយអ្នកទេសចរណ៍ (មើល ៧៩៩០០)។

(៣) **រាប់បញ្ចូល**
- (ក) ប្រតិបត្តិការទុកដាក់ទំនិញ (ឧ. ការដាក់កេសឈើជាបណ្តោះអាសន្នដើម្បីការពារទំនិញក្នុងអំឡុងពេលឆ្លងកាត់ ការយកចេញពីកេស ការផ្តល់គំរូទំនិញ ការថ្លឹងទំនិញ)
- (ខ) សកម្មភាពវេចខ្ចប់ដែលអមសម្រាប់ការដឹកជញ្ជូន។

ផ្នែក ៥៣ ៖ សកម្មភាពសេវាកម្មប្រៃសណីយ៍ និងបញ្ញើ

ផ្នែកនេះរាប់បញ្ចូល សកម្មភាពសេវាកម្មប្រៃសណីយ៍ និងបញ្ញើ ដូចជា ការទៅប្រមូល ការដឹកជញ្ជូន ការចែកចាយសំបុត្រ និងកញ្ចប់បញ្ញើនៅក្រោមការរៀបចំផ្សេងៗ។ សេវាកម្ម ចែកចាយសំបុត្រ និងសេវាកម្មអ្នកផ្ញើសំបុត្រក្នុងស្រុក ក៏រួមបញ្ចូលផងដែរ។

ក្រុម ៥៣១ ៖ សកម្មភាពសេវាកម្មប្រៃសណីយ៍

ក្រុមនេះរាប់បញ្ចូល សកម្មភាពប្រតិបត្តិការសេវាកម្មប្រៃសណីយ៍ ក្រោមកាតព្វកិច្ចសេវាកម្មកម្មជាសកល។ សកម្មភាពទាំងឡាយ រួមមានការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មជាសកល រួមមានទីតាំងលក់រាយ កន្លែងបែងចែកតាមប្រភេទនិងរៀបចំ និងផ្លូវរបស់ អ្នកប្រមូលបញ្ញើ និងការបែងចែកសំបុត្រ។ ការបែងចែកបញ្ញើរាប់បញ្ចូលសំបុត្រប្រៃសណីយ៍ដូចជា សំបុត្រ កាតប្រៃសណីយ៍ ក្រដាសបោះពុម្ព (កាសែត កាលិកបត្រ សម្ភារៈផ្សាយពាណិជ្ជកម្ម។ល។) កញ្ចប់តូចៗ ឯកសារ ឬទំនិញ។ វាក៏រាប់បញ្ចូលផងដែរសេវាកម្មចាំបាច់ដទៃផ្សេងទៀតដើម្បីគាំទ្រដល់កាតព្វកិច្ចសេវាកម្មជាសកល។

ក្រុម ៥៣២ ៖ សកម្មភាពអ្នកផ្តល់សេវាកម្មបញ្ញើ

ក្រុមនេះរាប់បញ្ចូល សកម្មភាពអ្នកផ្តល់សេវាកម្មបញ្ញើ ដែលមិនប្រតិបត្តិនៅក្រោម កាតព្វកិច្ចសេវាកម្មជាសាកល។

ជំពូក ជ ៖ ការដឹកជញ្ជូន និងការស្តុកទុក
ផ្នែក ៥៣ ៖ សកម្មភាពសេវាកម្មប្រៃសណីយ៍ និងបញ្ញើ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៥៣១			**សកម្មភាពសេវាកម្មប្រៃសណីយ៍**
	៥៣១០		សកម្មភាពសេវាកម្មប្រៃសណីយ៍
		៥៣១០០	សកម្មភាពសេវាកម្មប្រៃសណីយ៍(១)
៥៣២			**សកម្មភាពអ្នកផ្តល់សេវាកម្មបញ្ញើ**
	៥៣២០ (២)		សកម្មភាពអ្នកផ្តល់សេវាកម្មបញ្ញើ
		៥៣២០០	សកម្មភាពអ្នកផ្តល់សេវាកម្មបញ្ញើ ក្រៅពីសកម្មភាពប្រៃសណីយ៍ជាតិ(៣)

(១) **រាប់បញ្ចូល** ប្រមូល ដឹកជញ្ជូន បែងចែក (ក្នុងប្រទេសឬក្រៅប្រទេស) សំបុត្រ និងកញ្ចប់ឥវ៉ាន់។ សកម្មភាពនេះរាប់បញ្ចូលការលក់តែមប្រៃសណីយ ការប្រមូលសំបុត្រនិងកញ្ចប់ឥវ៉ាន់ពីប្រអប់សំបុត្រសាធារណៈឬពីការិយាល័យប្រៃសណីយ៍ ហើយធ្វើការបែងចែក និង ប្រគល់ទទួល។ វាក៏រាប់បញ្ចូលផងដែរសកម្មភាពដូចជា ការរៀបតាមប្រភេទសំបុត្រ ការជួលប្រអប់សំបុត្រ សេវាកម្មប្រៃសណីយ៍មិនចែកដល់កន្លែង។ល។

(២) **មិនរាប់បញ្ចូល** ការដឹកជញ្ជូនទំនិញ (មើលថ្នាក់ ៤៩១២ ៤៩២៣ ៥០១២ ៥០២២ និង៥១២០) (យោងតាមប្រភេទមធ្យោបាយដឹកជញ្ជូន)។

(៣) **រាប់បញ្ចូល** ការប្រមូល ដឹកជញ្ជូន និងប្រគល់សំបុត្រ និងប្រភេទសំបុត្រធម្មតាតូចៗ កញ្ចប់ឥវ៉ាន់តូចៗ ។ វាអាចរួមមានមធ្យោបាយដឹកជញ្ជូនមួយ ឬច្រើនប្រភេទ ហើយសកម្មភាពអាចត្រូវបានធ្វើឡើងតាមរយៈមធ្យោបាយដឹកជញ្ជូនឯកជន ឬសាធារណៈ។

ជំពូក ឈ ៖ សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ

កម្រិត	ច.ស.វ.ក
ជំពូក	១
ផ្នែក	២
ក្រុម	៦
ថ្នាក់	៧
ថ្នាក់រង	២១

ជំពូកនេះរាប់បញ្ចូល ការផ្គត់ផ្គង់កន្លែងស្នាក់នៅសម្រាប់ការស្នាក់នៅរយៈពេលខ្លី ដល់ភ្ញៀវនិងអ្នកដំណើរផ្សេងទៀត ហើយនិងមានការផ្គត់ផ្គង់អាហារ និងភេសជ្ជៈពេញលេញ សម្រាប់ទទួលភ្លាមៗ។ ចំនួន និងប្រភេទសេវាកម្មបន្ថែម ដែលមាននៅក្នុងជំពូកនេះ អាចមានការប្រែប្រួលខ្លាំង។

ជំពូកនេះមិនរាប់បញ្ចូលការផ្តល់ការស្នាក់នៅរយៈពេលវែង ដែលជាលំនៅឋានចម្បង ដែលវាត្រូវបានចាត់ថ្នាក់ក្នុងសកម្មភាពអចលនវត្ថុ (ជំពូក "ថ")។ ជំពូកនេះក៏មិនរាប់បញ្ចូលការរៀបចំអាហារ ឬភេសជ្ជៈសម្រាប់ទទួលទានភ្លាមៗ ឬអាចលក់តាមរយៈកន្លែងចែកចាយឯករាជ្យ ដូចជា តាមរយៈសកម្មភាពអាជីវកម្មលក់ដុំ ឬលក់រាយ។ ការរៀបចំម្ហូបអាហារទាំងនេះត្រូវបានចាត់ថ្នាក់ក្នុងជំពូក កម្មន្តសាល (ជំពូក«គ»)។

ផ្នែក ៥៥ ៖ សេវាកម្មស្នាក់នៅ

ផ្នែកនេះរាប់បញ្ចូល ការផ្តល់សេវាកម្មស្នាក់នៅ សម្រាប់ភ្ញៀវ និងអ្នកដំណើរផ្សេងទៀត។ ផ្នែកនេះក៏រាប់បញ្ចូលផងដែរការផ្តល់ការស្នាក់នៅរយៈពេលវែង សម្រាប់សិស្ស និស្សិត កម្មករ និងបុគ្គលស្រដៀងគ្នានេះ។ កន្លែងខ្លះអាចផ្តល់តែសេវាកម្មស្នាក់នៅ ខណៈពេលដែល កន្លែងផ្សេងទៀតផ្តល់ទាំងការរៀបចំកន្លែងស្នាក់នៅ ម្ហូបអាហារ និងសកម្មភាពកម្សាន្ត។

ផ្នែកនេះមិនរាប់បញ្ចូល សកម្មភាពទាំងឡាយណា ដែលទាក់ទងទៅនឹងការផ្តល់ការ ស្នាក់នៅចម្បងរយៈពេលយូរនៅតាមទីតាំងនានា ដូចជា ផ្ទះជួលប្រចាំខែឬប្រចាំឆ្នាំដែលបានចាត់ថ្នាក់ក្នុងជំពូក អចលនវត្ថុ (ជំពូក«ថ»)។

ក្រុម ៥៥១ ៖ សកម្មភាពសេវាកម្មស្នាក់នៅ

ក្រុមនេះរាប់បញ្ចូលការផ្តល់ការស្នាក់នៅ ជាទូទៅប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍ ជាគោលការណ៍សម្រាប់ភ្ញៀវស្នាក់នៅរយៈពេលខ្លី។ វារាប់បញ្ចូលការផ្តល់កន្លែងស្នាក់នៅ ដែលមានបំពាក់គ្រឿងបរិក្ខារក្នុងបន្ទប់ភ្ញៀវ និងបន្ទប់ធំ ឬកន្លែងស្នាក់នៅពេញលេញរួមទាំងផ្ទះបាយ ដោយមាន ឬគ្មានសេវាកម្មថែទាំផ្ទះប្រចាំថ្ងៃ ឬទៀងទាត់ផ្សេងៗ ហើយជារឿយៗ វាអាចរាប់បញ្ចូលសេវាកម្មបន្ថែមមួយចំនួនទៀត ដូចជាសេវាកម្មអាហារនិងភេសជ្ជៈ ចំណត សេវាកម្មបោកអ៊ុត អាងហែលទឹក និងបន្ទប់ហាត់ប្រាណ ទីតាំងកម្សាន្ត និងទីតាំងធ្វើសន្និសីទ និងសន្និបាត។

ក្រុម ៥៥២ ៖ កន្លែងបោះជុំរំ ចំណតយានយន្តទេសចរណ៍ និងសណ្តោង

ក្រុមនេះរាប់បញ្ចូលការផ្តល់កន្លែងស្នាក់នៅនៅក្នុងទីតាំងបោះជុំរំ ចំណតរ៉ឺម៉ក ជុំរំ កម្សាន្ត និងជុំរំស្ទូចត្រីនិងបរបាញ់ សម្រាប់ភ្ញៀវស្នាក់នៅរយៈពេលខ្លី, ការផ្តល់ទីកន្លែងនិងទីតាំងសម្រាប់យានយន្តជិះកម្សាន្ត។

ក្រុម ៥៥៩ ៖ ការស្នាក់នៅផ្សេងៗទៀត

ក្រុមនេះរាប់បញ្ចូល ការផ្តល់កន្លែងស្នាក់នៅបណ្តោះអាសន្ន ឬរយៈពេលវែង ក្នុងបន្ទប់នៅតែមួយឬបន្ទប់នៅជាមួយគ្នា ឬអន្តេវាសិកដ្ឋាន សម្រាប់សិស្ស និស្សិត កម្មករអន្តោប្រវេសន៍ (តាមរដូវកាល) និងបុគ្គលផ្សេងៗ។

ជំពូក ឈ ៖ សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ

ផ្នែក ៥៥ ៖ សេវាកម្មស្នាក់នៅ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៥៥១			**សកម្មភាពសេវាកម្មស្នាក់នៅ**
	៥៥១០[១]		សកម្មភាពសេវាកម្មស្នាក់នៅ
		៥៥១០១	សណ្ឋាគារ និងសណ្ឋាគាររីសត
		៥៥១០២	ម៉ូតែល
		៥៥១០៣	សណ្ឋាគារ អាផាតមិន
		៥៥១០៤	ផ្ទះសំណាក់ ផ្ទះជួល[២]
		៥៥១០៥	ផ្ទះស្នាក់អាស្រ័យ
		៥៥១០៩	សកម្មភាពសេវាកម្មស្នាក់នៅ ដទៃទៀតដែលពុំបានរាប់បញ្ចូល
៥៥២			**កន្លែងបោះជុំរំ ចំណតយានយន្តទេសចរណ៍ និងសណ្តោង**
	៥៥២០		កន្លែងបោះជុំរំ ចំណតយានយន្តទេសចរណ៍ និងសណ្តោង
		៥៥២០០	កន្លែងបោះជុំរំ ចំណតសម្រាប់យានយន្តទេសចរណ៍
៥៥៩			**ការស្នាក់នៅផ្សេងៗទៀត**
	៥៥៩០		ការស្នាក់នៅផ្សេងៗទៀត
		៥៥៩០១	កន្លែងស្នាក់នៅរបស់និស្សិត និងអន្តេវាសិកដ្ឋានសម្រាប់សិស្ស
		៥៥៩០៩	អន្តេវាសិកដ្ឋានផ្សេងៗទៀង[៣]

(១) **មិនរាប់បញ្ចូល** ការផ្តល់ផ្ទះនិងផ្ទះល្វែងដែលមាន ឬមិនបំពាក់បរិក្ខារសម្រាប់ការប្រើប្រាស់អចិន្ត្រៃយ៍ ជាទូទៅជាប្រចាំខែ ឬប្រចាំឆ្នាំ (មើលផ្នែក ៦៨)។

(២) **រាប់បញ្ចូល** គ្រែស្នាក់នៅ និងអាហារពេលព្រឹក។

(៣) **រាប់បញ្ចូល** ផ្ទះសំណាក់ បន្ទប់ និងផ្ទះសម្រាប់កម្មករ។

ផ្នែក ៥៦ ៖ សកម្មភាពសេវាកម្មអាហារ និងភេសជ្ជៈ

ផ្នែកនេះរាប់បញ្ចូល សកម្មភាពសេវាកម្មអាហារនិងភេសជ្ជៈ ដោយផ្តល់អាហារ ឬភេសជ្ជៈពេញលេញ សម្រាប់ការទទួលទានភ្លាម ទោះជានៅក្នុងភោនីយដ្ឋាន បែបប្រពៃណី ភោជនីយដ្ឋានបម្រើសេវាកម្មដោយខ្លួនឯង ឬភោជនីយដ្ឋានខ្ចប់យកទៅទទួលទាននៅក្រៅ ទោះជាតូបបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ដោយមានឬគ្មានកន្លែងអង្គុយក៏ដោយ។ កត្តាកំណត់គឺអាស្រ័យលើអាហារ ដែលផ្តល់សម្រាប់ការទទួលទានភ្លាមៗ មិនមែនអាស្រ័យលើប្រភេទទីតាំង ដែលផ្តល់អាហារនោះទេ។

ផ្នែកនេះមិនរាប់បញ្ចូល ការផលិតអាហារដែលមិនអាចទទួលទានភ្លាម ឬមិនបានត្រៀមសម្រាប់ទទួលទានភ្លាមៗ ឬការផលិតម្ហូបអាហារដែលបម្រុងទុកដែលមិនត្រូវបានចាត់ទុកជាអាហារ (មើលផ្នែក ១០ ៖ ការផលិតផលិតផលម្ហូបអាហារ និងផ្នែក១១ ៖ ការផលិត ភេសជ្ជៈ)។ ផ្នែកនេះក៏មិនបានរាប់បញ្ចូល ការលក់អាហារដែលមិនផលិតខ្លួនឯង ដែលមិនត្រូវបានចាត់ទុកថាជាអាហារ ឬការលក់អាហារដែលមិនសម្រាប់ការទទួលទាន (មើលជំពូក «ឆ» អាជីវកម្មលក់ដុំ និងលក់រាយ)។

ក្រុម ៥៦១ ៖ សកម្មភាពសេវាកម្មភោជនីដ្ឋាន និងសេវាកម្មផ្គត់ផ្គង់អាហារចល័ត

ក្រុមនេះរាប់បញ្ចូលការផ្តល់សេវាកម្មអាហារដល់អតិថិជន ទោះជាអតិថិជនត្រូវបានបម្រើអាហារខណៈដែលចូលអង្គុយចាំ ឬអតិថិជនបម្រើដោយខ្លួនឯង ទោះជាពួកទទួលទានអាហារដែលបានរៀបចំទុកនៅនៅទីតាំង វេចខ្ចប់យកទៅក្រៅ ឬមានសេវាកម្មយកទៅដល់ផ្ទះក៏ដោយ ។ វារាប់បញ្ចូលការរៀបចំនិងការបម្រើអាហារសម្រាប់ការទទួលទានភ្លាមៗ ពីយានយន្តដែលមានម៉ាស៊ីន ឬរទេះដែលគ្មានម៉ាស៊ីន។

ក្រុម ៥៦២ ៖ ការផ្គត់ផ្គងម្ហូបអាហារដល់កម្មវិធី និងសកម្មភាពសេវាកម្មអាហារផ្សេងៗ

ក្រុមនេះរួមមានសកម្មភាពផ្គត់ផ្គង់អាហារសម្រាប់កម្មវិធីនីមួយៗ ឬសម្រាប់រយៈពេលជាក់លាក់ណាមួយ និងប្រតិបត្តិការផ្តល់សម្បទានអាហារ ដូចជានៅកន្លែងកីឡា ឬទីតាំងប្រហាក់ប្រហែលគ្នា។

ក្រុម ៥៦៣ ៖ សកម្មភាពបម្រើភេសជ្ជៈ

ក្រុមនេះរួមមានការរៀបចំនិងបម្រើភេសជ្ជៈសម្រាប់ទទួលទានភ្លាមៗនៅនឹងកន្លែង។

ជំពូក ឈ ៖ សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ
ផ្នែក ៥៦ ៖ សកម្មភាពសេវាកម្មអាហារ និងភេសជ្ជៈ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៥៦១			**សកម្មភាពសេវាកម្មភោជនីដ្ឋាន និងសេវាកម្មផ្គត់ផ្គង់អាហារចល័ត**
	៥៦១០[១]		សកម្មភាពសេវាកម្មភោជនីដ្ឋាន និងសេវាកម្មអាហារចល័ត
		៥៦១០១	ភោជនីដ្ឋាន និងកន្លែងស៊ីផឹករង្គសាល
		៥៦១០២	កន្លែងលក់អាហាររហ័ស[២]
		៥៦១០៣	ហាងលក់ការ៉េម និងការដើរលក់តាមរថយន្ត
		៥៦១០៤	រទេះចល័តលក់អាហារ
		៥៦១០៥	ស្តង់លក់ម្ហូបអាហារ អ្នកដើរលក់ និងការរៀបចំលក់ម្ហូបអាហារនិង ភេសជ្ជៈក្នុងផ្សារ
៥៦២			**ការផ្គត់ផ្គង់ម្ហូបអាហារដល់កម្មវិធី និងសកម្មភាពសេវាកម្មអាហារផ្សេងៗ**
	៥៦២១[៣]		ការផ្គត់ផ្គង់ម្ហូបដល់កម្មវិធី
		៥៦២១០	ការផ្គត់ផ្គង់ម្ហូបដល់កម្មវិធី
	៥៦២៩		សកម្មភាពផ្តល់សេវាកម្មម្ហូបអាហារដទៃទៀត
		៥៦២៩០	សកម្មភាពផ្តល់សេវាកម្មម្ហូបអាហារដទៃទៀត[4]
៥៦៣			**សកម្មភាពបម្រើភេសជ្ជៈ**
	៥៦៣០[៥]		សកម្មភាពបម្រើភេសជ្ជៈ
		៥៦៣០១	តៀមស្រា រង្គសាល ឌីស្កូ បៀរហ្គាដិន និងហាងខារ៉ាអូខេ
		៥៦៣០២	ហាងតែ និងកាហ្វេ
		៥៦៣០៣	តូបលក់ភេសជ្ជៈ
		៥៦៣០៤	រទេះលក់ភេសជ្ជៈ ចល័ត
		៥៦៣០៩	កន្លែងផ្តល់សេវាកម្មភេសជ្ជៈ និងអាហារផ្សេងៗ ដែលមិនរាប់បញ្ចូល

(១) **មិនរាប់បញ្ចូល** ការប្រតិបត្តិការសម្បទាននៃកន្លែងទទួលទាន (មើល ៥៦២៩០)។

(២) **រាប់បញ្ចូល** ហាងលក់ចំណីហូបចុកសម្រាប់ហូបលេង។

(៣) **មិនរាប់បញ្ចូល**
- (ក) ការផលិតអាហារងាយខូចសម្រាប់ការលក់បន្ត (មើល ១០៧៩៩)
- (ខ) ការលក់រាយអាហារងាយខូច (មើលផ្នែក ៤៧)។

(៤) **រាប់បញ្ចូល**
- (ក) ប្រតិបត្តិការហាងអាហារ និងហាងកាហ្វេ (ដូចជាសម្រាប់រោងចក្រ ការិយាល័យ មន្ទីរពេទ្យ ឬសាលារៀន) មានលក្ខណៈសម្បទាន
- (ខ) អ្នកម៉ៅការសេវាកម្មម្ហូបអាហារ សម្រាប់ក្រុមហ៊ុនដឹកជញ្ជូន
- (គ) ប្រតិបត្តិការនៃ្លងលក់អាហារនៅទីលានហាត់កីឡាឬសកម្មភាពប្រហាក់ប្រហែល ដែលមានលក្ខណៈជាសម្បទាន

មិនរាប់បញ្ចូល
- (ក) ការផលិតអាហារដែលងាយខូចសម្រាប់ការលក់បន្ត (មើល ១០៧៩០)
- (ខ) ការលក់រាយអាហារដែលងាយខូច (មើលផ្នែក ៤៧)។

(៥) **មិនរាប់បញ្ចូល**
- (ក) ការលក់បន្តភេសជ្ជៈដែលកញ្ចប់ និងរៀបចំទុក (មើល ៤៧១១, ៤៧២២, ៤៧៨១, ៤៧៩៩)
- (ខ) ប្រតិបត្តិការកន្លែងឌីស្កូ និងរាំកំសាន្តដោយគ្មានបម្រើភេសជ្ជៈ (មើល ៩៣២៩៩)។

ជំពូក ញ ៖ ព័ត៌មានវិទ្យា និងទូរគមនាគមន៍

កម្រិត	ច.ស.វ.ក
ជំពូក	១
ផ្នែក	៦
ក្រុម	១៣
ថ្នាក់	២៣
ថ្នាក់រង	២៨

ជំពូកនេះរាប់បញ្ចូលការផលិត និងការចែកចាយផលិតផលព័ត៌មាន និងវប្បធម៌ ការផ្តល់មធ្យោបាយបញ្ជូន ឬចែកចាយផលិតផលទាំងនេះរាប់ទាំងទិន្នន័យ ឬទូរគមនាគមន៍ សកម្មភាពព័ត៌មានវិទ្យា និងសកម្មភាពដំណើរការទិន្នន័យ និងសេវាកម្មព័ត៌មានផ្សេងទៀត។

ជំពូកនេះ ក៏រាប់បញ្ចូលផងដែរនូវ សកម្មភាពបោះផ្សាយ សកម្មភាពចេញផ្សាយភាពយន្ត ការផលិតកម្មវិធីទូរទស្សន៍ និងវីដេអូ សកម្មភាពថតសំឡេងនិងចេញផ្សាយតន្ត្រី សកម្មភាពផ្សាយបង្កើតកម្មវិធី ទូរគមនាគមន៍ ការបង្កើតកម្មវិធីកុំព្យូទ័រ ការពិគ្រោះយោបល់សកម្មភាពពាក់ព័ន្ធ និងសកម្មភាពសេវាកម្មព័ត៌មាន។

សមាសភាគសំខាន់ៗនៃជំពូកនេះរួមមាន ៖ សកម្មភាពបោះផ្សាយ (ផ្នែក ៥៨) ដោយរាប់បញ្ចូលការចេញផ្សាយកម្មវិធីកុំព្យូទ័រ សកម្មភាពភាពយន្ត និងការថតសំឡេង (ផ្នែក ៥៩) សកម្មភាពនៃការផ្សាយវិទ្យុនិងទូរទស្សន៍ និងការបង្កើតកម្មវិធី (ផ្នែក៦០) សកម្មភាពទូរគមនាគមន៍ (ផ្នែក ៦១) សកម្មភាពព័ត៌មានវិទ្យា (ផ្នែក ៦២) និងសកម្មភាពសេវាកម្មព័ត៌មានផ្សេងទៀត (ផ្នែក ៦៣)។

ការចេញផ្សាយរួមមាន ការទទួលបានសិទ្ធិអ្នកនិពន្ធដើម្បីបង្កើតមាតិកា (ផលិតផលព័ត៌មាន) និងការផ្តល់មាតិកានេះឲ្យទៅដល់សាធារណជន តាមរយៈការផលិតឡើងវិញ និងការចែកចាយមាតិកានេះក្នុងទម្រង់ផ្សេងៗ។ ទម្រង់ទាំងអស់នៃការចេញផ្សាយ (ដូចជា ការបោះពុម្ពលើក្រដាស ជាទម្រង់អេឡិចត្រូនិច ជាសំឡេង នៅលើអ៊ីនធឺណិត ជាផលិតផលពហុផ្សព្វផ្សាយដូចជា ស៊ីឌីរ៉ូម សំណៅយោង និងសៀវភៅ។ល។) ត្រូវបានបញ្ចូលក្នុងផ្នែក នេះ។

សកម្មភាពពាក់ព័ន្ធនឹងការផលិត និងការចែកចាយកម្មវិធីទូរទស្សន៍ មាននៅក្នុងផ្នែក ៥៩, ៦០, និង៦១ ឆ្លុះបញ្ចាំងដំណាក់កាលផ្សេងៗនៅក្នុងដំណើរការនេះ។ សមាសភាគនីមួយៗដូចជាភាពយន្ត និងស៊េរីទូរទស្សន៍។ល។ ត្រូវបានបង្កើតដោយសកម្មភាពនៅក្នុងផ្នែក ៥៩ ចំណែកឯការបង្កើតស្ថានីយ៍ទូរទស្សន៍បំពាក់ដោយកម្មវិធីពេញលេញមួយ ដែលទាញចេញពីសមាសភាគនៅក្នុងផ្នែក ៥៩ ឬដោយសមាសភាគផ្សេងទៀត (ដូចជាការបង្កើតកម្មវិធីផ្សាយព័ត៌មានទាន់ហេតុការណ៍) ត្រូវបានដាក់បញ្ចូលទៅក្នុងផ្នែក ៦០។ ផ្នែក ៦០ នេះក៏រាប់បញ្ចូល ការផ្សាយកម្មវិធីដែលផលិតដោយផលិតករទាំងនេះដែរ។ ការចែកផ្សាយទូរទស្សន៍ដែលបំពាក់ដោយកម្មវិធីពេញលេញមួយ ដែលបង្កើតដោយភាគីទីបី (ឧ. ដោយគ្មានការកែប្រែមាតិកាណាមួយ) ត្រូវបានដាក់បញ្ចូលទៅក្នុងផ្នែក ៦១។ ការចែកផ្សាយនៅក្នុងផ្នែក ៦១ នេះ អាចធ្វើទៅបានតាមរយៈប្រព័ន្ធចាក់ផ្សាយ ផ្កាយរណប ឬខ្សែកាប។

ផ្នែក ៥៨ ៖ សកម្មភាពបោះផ្សាយ

ផ្នែកនេះរាប់បញ្ចូលការបោះពុម្ពផ្សាយសៀវភៅ សៀវភៅផ្សត់ឃោសនា ខិតបណ្ណ វចនានុក្រម សព្វវចនាធិប្បាយ សៀវភៅផែនទី ផែនទី និងប្លង់ ការបោះពុម្ពផ្សាយកាសែត ព្រឹត្តិបត្រ និងកាលិកបត្រ ការបោះពុម្ពផ្សាយសៀវភៅរាយឈ្មោះ បញ្ជីអាសយដ្ឋាន និងការបោះពុម្ពផ្សាយផ្សេងទៀត ព្រមទាំងការចេញផ្សាយកម្មវិធីកុំព្យូទ័រ។

ការបោះផ្សាយរួមមាន ការទទួលបានសិទ្ធិអ្នកនិពន្ធដើម្បីបង្កើតមាតិកា (ផលិតផលព័ត៌មាន) និងការផ្តល់មាតិកានេះឱ្យទៅដល់សាធារណជន តាមរយៈការផលិតឡើងវិញ និងការចែកចាយមាតិកានេះក្នុងទម្រង់ផ្សេងៗ។ ទម្រង់ទាំងអស់នៃការបោះផ្សាយ (ដូចជា ការបោះពុម្ពលើក្រដាស ជាទម្រង់អេឡិចត្រូនិច ឬជាសំឡេង នៅលើអ៊ីនធឺណិត ជាផលិតផលពហុផ្សព្វផ្សាយដូចជា ឌីសអុបទិក សំណៅយោង និងសៀវភៅ។ល។) លើកលែងតែការចេញផ្សាយភាពយន្ត ត្រូវបានបញ្ចូលក្នុងផ្នែកនេះ។

ផ្នែកនេះមិនរាប់បញ្ចូលការចេញផ្សាយភាពយន្ត កាសែតវីដេអូ និងភាពយន្តនៅក្នុងឌីវីឌី ឬប្រព័ន្ធផ្សព្វផ្សាយប្រហាក់ប្រហែល (ផ្នែក ៥៩) និងការផលិតចម្លងតាមច្បាប់ដើមសម្រាប់ការថតទុក ឬសម្ភារៈសំឡេង (ផ្នែក ៥៩)។ ផ្នែកនេះក៏មិនរាប់បញ្ចូលផងទេ ការបោះពុម្ព (មើល ១៨១១) និងការផលិតឡើងវិញក្នុងទ្រង់ទ្រាយធំ នូវប្រព័ន្ធផ្សព្វផ្សាយដែលបានថតទុក (មើល ១៨២០)។

ក្រុម ៥៨១ ៖ ការបោះពុម្ពផ្សាយសៀវភៅ កាលិកបត្រ និងសកម្មភាពបោះពុម្ពផ្សាយផ្សេងទៀត

ក្រុមនេះរាប់បញ្ចូលសកម្មភាពបោះពុម្ពផ្សាយសៀវភៅ កាសែត ទស្សនាវដ្តី និងកាលិកបត្រផ្សេងៗ សៀវភៅរាយឈ្មោះ បញ្ជីអាសយដ្ឋាន និងស្នាដៃផ្សេងទៀត ដូចជា រូបថត ចម្លាក់ ប្រៃសណីយ៍បត្រ តារាងពេលវេលា ទម្រង់ ប័ណ្ណប្រកាស និងការផលិតឡើងវិញនូវស្នាដៃសិល្បៈ។ ស្នាដៃទាំងនេះមានចរិតលក្ខណៈជាភាពច្នៃប្រឌិតខាងបញ្ញា ដែលជាលក្ខខណ្ឌដើម្បីអភិវឌ្ឍស្នាដៃទាំងនេះ ហើយជាទូទៅត្រូវបានការពារដោយសិទ្ធិអ្នកនិពន្ធ។

ក្រុម ៥៨២ ៖ ការចេញផ្សាយកម្មវិធីកុំព្យូទ័រ

ក្រុមនេះរាប់បញ្ចូលការចេញផ្សាយកម្មវិធីកុំព្យូទ័រដែលបង្កើតរួចស្រាប់ (មិនមែនតាមការតម្រូវរបស់អតិថិជន) ដូចជា ប្រព័ន្ធប្រតិបត្តិការ កម្មវិធីសម្រាប់អាជីវកម្មនិងកម្មវិធីផ្សេងទៀត និងកម្មវិធីហ្គេមកុំព្យូទ័រសម្រាប់គ្រប់ទម្រង់។

ជំពូក ៣ ៖ ព័ត៌មានវិទ្យា និងទូរគមនាគមន៍
ផ្នែក ៥៨ ៖ សកម្មភាពបោះផ្សាយ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៥៨១			**ការបោះពុម្ពផ្សាយសៀវភៅ កាលិកបត្រ និងសកម្មភាពបោះពុម្ពផ្សាយផ្សេងទៀត**
	៥៨១១[១]		ការបោះពុម្ពផ្សាយសៀវភៅ
		៥៨១១០	ការបោះពុម្ពផ្សាយសៀវភៅ សៀវភៅផ្ទត់ឃោសនា និងការបោះពុម្ពផ្សាយផ្សេងទៀត[២]
	៥៨១២		ការបោះពុម្ពផ្សាយសៀវភៅវាយឈ្មោះ និងបញ្ជីអាសយដ្ឋាន
		៥៨១២០	ការបោះពុម្ពផ្សាយបញ្ជីអាសយដ្ឋាន សៀវភៅលេខទូរស័ព្ទ និងសៀវភៅវាយឈ្មោះផ្សេងទៀត។ល។
	៥៨១៣		ការបោះពុម្ពផ្សាយកាសែត ព្រឹត្តិបត្រ និងកាលិកបត្រ
		៥៨១៣០	ការបោះពុម្ពផ្សាយកាសែត ព្រឹត្តិបត្រ ទស្សនាវដ្តី និងកាលិកបត្រក្នុងទម្រង់ជាក្រដាស ឬ អេឡិចត្រូនិច[៣]

(១) **រាប់បញ្ចូល** សកម្មភាពបោះពុម្ពសៀវភៅជាក្រដាស អេឡិចត្រូនិច ឌីសអុបទិក ការបង្ហាញជាអេឡិចត្រូនិច ។ល។ ឬក្នុងទម្រង់ជាខ្សែអាត់ ឬនៅលើអ៊ីនធឺណិត។

មិនរាប់បញ្ចូល
- (ក) ការផលិតភូគោល (មើល ៣២៩០០)
- (ខ) ការបោះពុម្ពផ្សាយសម្ភារៈផ្សាយពាណិជ្ជកម្ម (មើល ៥៨១៩០)
- (គ) ការបោះពុម្ពផ្សាយសៀវភៅភ្លេង និងតន្ត្រី (មើល ៥៩២០)
- (ឃ) សកម្មភាពរបស់អ្នកនិពន្ធឯករាជ្យ (មើល ៩០០០៤)។

(២) **រាប់បញ្ចូល**
- (ក) ការបោះពុម្ពផ្សាយខិតប័ណ្ណ និងការបោះពុម្ពស្រដៀងនេះ ដូចជាការបោះពុម្ពផ្សាយវចនានុក្រម និងសព្វវចនាធិប្បាយ
- (ខ) ការបោះពុម្ពផ្សាយសៀវភៅផែនទី ផែនទី និងប្លង់
- (គ) ការបោះពុម្ពផ្សាយសៀវភៅខ្សែអាត់សំឡេង
- (ឃ) ការបោះពុម្ពផ្សាយសព្វវចនាធិប្បាយ។ល។ នៅក្នុងឌីសអុបទិក។

(៣) **រាប់បញ្ចូល**
- (ក) ការផ្សាយតាមអ៊ីនធឺណិត និងការបោះពុម្ពផ្សាយតារាងពេលវេលាកម្មវិធីវិទ្យុ និងទូរទស្សន៍
- (ខ) ការបោះពុម្ពផ្សាយកាសែតផ្សាយពាណិជ្ជកម្ម។

ជំពូក ៣ ៖ ព័ត៌មានវិទ្យា និងទូរគមនាគមន៍
ផ្នែក ៥៨ ៖ សកម្មភាពបោះផ្សាយ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	៥៨១៩(១)		សកម្មភាពបោះពុម្ពផ្សាយផ្សេងៗ
		៥៨១៩០	ការបោះពុម្ពផ្សាយសៀវភៅម៉ូដ រូបថត ចម្លាក់ និងប្រៃសណីយ៍បត្រ លិខិតបដិសណ្ឋារកិច្ច ទម្រង់ ប័ណ្ណប្រកាស ការផលិតឡើងវិញនូវស្នាដៃសិល្បៈ សម្ភារៈផ្សាយពាណិជ្ជកម្ម និងសម្ភារៈបោះពុម្ពផ្សេងៗទៀត ដែលពុំបានរាប់បញ្ចូល
៥៨២			**ការចេញផ្សាយកម្មវិធីកុំព្យូទ័រ**
	៥៨២០(២)		ការចេញផ្សាយកម្មវិធីកុំព្យូទ័រដែលបង្កើតរួចស្រាប់ (មិនមែនតាមការតម្រូវរបស់អតិថិជន)
		៥៨២០១	ការចេញផ្សាយកម្មវិធីហ្គេម
		៥៨២០២	**ការចេញផ្សាយកម្មវិធីមិនមែនហ្គេម**
		៥៨២០៩	ការចេញផ្សាយកម្មវិធីកុំព្យូទ័រដែលបង្កើតរួចស្រាប់ដែលមិនបានរាប់បញ្ចូល(៣)

(១) **មិនរាប់បញ្ចូល** (ក) ការលក់រាយកម្មវិធីកុំព្យូទ័រ (មើល ៤៧៤១)
(ខ) ការបោះពុម្ពផ្សាយកាសែតផ្សាយពាណិជ្ជកម្ម (មើល ៥៨១៣០)។

(២) **មិនរាប់បញ្ចូល** (ក) ការផលិតឡើងវិញនូវកម្មវិធីកុំព្យូទ័រ (មើល១៨២០)
(ខ) ការលក់រាយកម្មវិធីកុំព្យូទ័រដែលមិនមែនតាមការតម្រូវរបស់អតិថិជន (មើល ៤៧៤១៤)
(គ) ការផលិតកម្មវិធីកុំព្យូទ័រដែលមិនពាក់ព័ន្ធនឹងការបោះផ្សាយ (មើល ៦២០១០)។

(៣) **រាប់បញ្ចូល** ការចេញផ្សាយកម្មវិធីកុំព្យូទ័រ សម្រាប់ការកម្សាន្តហ្គេមវីឌីអូ ហ្គេមកុំព្យូទ័រ និងប្រព័ន្ធប្រតិបត្តិការ។

ផ្នែក ៥៩ ៖ សកម្មភាពចេញផ្សាយភាពយន្ត ការផលិតកម្មវិធីទូរទស្សន៍និងវីដេអូ សកម្មភាពថតសំឡេងនិងចេញផ្សាយតន្ត្រី

ផ្នែកនេះរាប់បញ្ចូលការផលិតភាពយន្តសម្រាប់ ឬមិនសម្រាប់រោងភាពយន្ត មានទម្រង់ជាហ្វីល កាសែតវីដេអូ ឬឌីសសម្រាប់ការចាក់បញ្ចាំងផ្ទាល់នៅក្នុងរោងភាពយន្ត ឬការចាក់ផ្សាយតាមទូរទស្សន៍ សកម្មភាពគាំទ្រផ្នែកនេះរួមមានការកែសម្រួលខ្សែភាពយន្ត ការកាត់ត និងការបញ្ចូលសំឡេង។ល។ ការចែកចាយភាពយន្ត និងផលិតផលផ្សេងៗក្នុងវិស័យភាពយន្តទៅដល់វិស័យនានា ព្រមទាំងការបញ្ចាំងភាពយន្ត ឬផលិតផលផ្សេងៗក្នុងវិស័យភាពយន្ត។ ផ្នែកនេះក៏រាប់បញ្ចូលផងដែរនូវការទិញ និងការលក់ភាពយន្ត ឬសិទ្ធិចែកចាយផលិតផលផ្សេងៗក្នុងវិស័យភាពយន្ត។

ផ្នែកនេះក៏រាប់បញ្ចូលសកម្មភាពនៃការថតសំឡេងដូចជាផលិតកម្មនៃការថតសំឡេងច្បាប់ដើម ការបញ្ចេញ ការផ្សព្វផ្សាយ និងការចែកចាយផលិតផលទាំងនេះ ការចេញផ្សាយតន្ត្រី ព្រមទាំងសកម្មភាពនៃសេវាកម្មថតសំឡេងនៅក្នុងស្ទូឌីយោ ឬកន្លែងផ្សេងទៀត។

ក្រុម ៥៩១ ៖ សកម្មភាពភាពយន្ត កម្មវិធីទូរទស្សន៍ និងវីដេអូ

ក្រុមនេះរាប់បញ្ចូលការផលិតភាពយន្ត សម្រាប់ឬមិនសម្រាប់រោងភាពយន្ត មានទម្រង់ជាហ្វីល កាសែតវីដេអូ ឌីវីឌី ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ដូចជាការចែកចាយបែបឌីជីថល សម្រាប់ការចាក់បញ្ចាំងផ្ទាល់នៅក្នុងរោងភាពយន្ត ឬសម្រាប់ការចាក់ផ្សាយតាមទូរទស្សន៍ សកម្មភាពគាំទ្ររួមមានការកែសម្រួលខ្សែភាពយន្ត ការកាត់ត និងការបញ្ចូលសំឡេង។ល។ ការចែកចាយភាពយន្តឬផលិតផលផ្សេងៗក្នុងវិស័យភាពយន្ត(កាសែតវីដេអូ ឌីវីឌី។ល។)ទៅដល់វិស័យនានាព្រមទាំងការចាក់បញ្ចាំងផ្សាយ។ ការទិញនិងការលក់ភាពយន្ត ឬសិទ្ធិចែកចាយផលិតផលផ្សេងៗក្នុងវិស័យភាពយន្តត្រូវបានរាប់បញ្ចូលផងដែរ។

ក្រុម ៥៩២ ៖ សកម្មភាពថតសំឡេង និងចេញផ្សាយតន្ត្រី

ក្រុមនេះរាប់បញ្ចូលសកម្មភាពផលិតកម្មនៃការថតសំឡេងច្បាប់ដើម ដូចជាខ្សែអាត់ ស៊ីឌី ការបញ្ចេញ ការផ្សព្វផ្សាយ និងការចែកចាយផលិតផលថតសំឡេងទាំងនេះទៅដល់អ្នកលក់ដុំ អ្នកលក់រាយ ឬសាធារណជនផ្ទាល់។ សកម្មភាពទាំងនេះអាចត្រូវបាន ឬមិនត្រូវបានបញ្ចូលជាមួយផលិតកម្មនៃការថតសំឡេងមេនៅក្នុងអង្គភាពតែមួយ។ បើសិនជាមិនត្រូវ បានបញ្ចូលជាមួយគ្នា អង្គភាពដែលអនុវត្តសកម្មភាពទាំងនេះត្រូវតែទទួលបានសិទ្ធិផលិតឡើងវិញ និងសិទ្ធិចែកចាយនូវការថតសំឡេងដើមនេះ។ ក្រុមនេះរាប់បញ្ចូលសកម្មភាពសេវាកម្មថតសំឡេងនៅក្នុងស្ទូឌីយោ ឬកន្លែងផ្សេងៗទៀត រាប់បញ្ចូលទាំងការផលិតកម្មវិធីវិទ្យុ ខ្សែអាត់សម្រាប់ភាពយន្ត និងកម្មវិធីទូរទស្សន៍ដែលថតទុក (មិនផ្សាយផ្ទាល់) ជាដើម។

ក្រុមនេះក៏រាប់បញ្ចូលផងដែរនូវសកម្មភាពចេញផ្សាយតន្ត្រី ដូចជាសកម្មភាពទទួលបាន និងចុះបញ្ជីសិទ្ធិអ្នកនិពន្ធសម្រាប់ការតែងតន្ត្រី ការផ្សព្វផ្សាយ ការផ្តល់សិទ្ធិ និងការប្រើប្រាស់ការតែងតន្ត្រីទាំងនេះ សម្រាប់ការថតសំឡេង វិទ្យុ ទូរទស្សន៍ ភាពយន្ត ការសម្តែងផ្ទាល់ ការបោះពុម្ពលើក្រដាស និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត។ អង្គភាពទាំងឡាយណាដែលពាក់ព័ន្ធនឹងសកម្មភាពទាំងនេះអាចជាម្ចាស់សិទ្ធិអ្នកនិពន្ធ ឬដើរតួនាទីជាអ្នករដ្ឋបាលក្នុងនាមជាម្ចាស់នៃសិទ្ធិអ្នកនិពន្ធតន្ត្រីនេះ។ ក្រុមនេះក៏រាប់បញ្ចូលការចេញផ្សាយតន្ត្រី និងសៀវភៅភ្លេង។

ជំពូក ញ ៖ ព័ត៌មានវិទ្យា និងទូរគមនាគមន៍

ផ្នែក ៥៩ ៖ សកម្មភាពចេញផ្សាយភាពយន្ត ការផលិតកម្មវិធីទូរទស្សន៍និងវីដេអូ សកម្មភាពថតសំឡេងនិងចេញផ្សាយតន្ត្រី

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៥៩១			**សកម្មភាពភាពយន្ត កម្មវិធីទូរទស្សន៍ និងវីដេអូ**
	៥៩១១[១]		សកម្មភាពផលិតភាពយន្ត កម្មវិធីទូរទស្សន៍ និងវីដេអូ
		៥៩១១០	សកម្មភាពផលិតភាពយន្ត កម្មវិធីទូរទស្សន៍ និងវីដេអូ[២]
	៥៩១២[៣]		សកម្មភាពក្រោយការផលិតភាពយន្ត កម្មវិធីទូរទស្សន៍ និងវីដេអូ
		៥៩១២០	សកម្មភាពក្រោយការផលិតភាពយន្ត កម្មវិធីទូរទស្សន៍ និងវីដេអូ[៤]

(១) **មិនរាប់បញ្ចូល**

(ក) ការចម្លងខ្សែភាពយន្ត (លើកលែងតែការផលិតឡើងវិញនូវខ្សែភាពយន្តសម្រាប់ការចែកចាយតាមរោងភាពយន្ត) ព្រមទាំងការផលិតឡើងវិញនូវកាសែតខ្សែអាត់ វីដេអូ ស៊ីឌី ឌីវីឌី ពីច្បាប់ចម្លងមេ (មើល ១៨២០)

(ខ) ការលក់ដុំកាសែតវីដេអូ ស៊ីឌី និងឌីវីឌីដែលបានថតទុកជាមុន (មើល ៤៦៥២៥)

(គ) ការលក់ដុំកាសែតវីដេអូ និងស៊ីឌីមិនទាន់ថតចម្លង (មើល ៤៦៥២៥)

(ឃ) ការលក់រាយកាសែតវីដេអូ ស៊ីឌី និងឌីវីឌី (មើល ៤៧៦២០)

(ង) សកម្មភាពក្រោយការផលិត (មើល ៥៩១២០)

(ច) ការផលិតឡើងវិញនូវខ្សែភាពយន្តសម្រាប់ការចែកចាយតាមរោងភាពយន្ត (មើល ៥៩១២)

(ឆ) ការថតសំឡេង និងការថតសៀវភៅទៅជាកាសែតខ្សែអាត់ (មើល ៥៩២០)

(ជ) ការបង្កើតកម្មវិធីស្ថានីយទូរទស្សន៍ពេញលេញមួយ (មើល ៦០២០)

(ឈ) ការចាក់ផ្សាយតាមទូរទស្សន៍ (មើល ៦០២០)

(ញ) ការកែសម្រួលខ្សែភាពយន្តក្រៅពីសម្រាប់ឧស្សាហកម្មភាពយន្ត (មើល ៧៤២០០)

(ដ) សកម្មភាពឯកជនរបស់ភ្នាក់ងារ ឬទីភ្នាក់ងាររោងភាពយន្ត ឬសិល្បៈ (មើល ៧៤៩០០)

(ឋ) ការជួលកាសែតវីដេអូ និងឌីវីឌីទៅដល់សាធារណជនទូទៅ (មើល ៧៧២២០)

(ឌ) ការផ្តល់ការផ្សាយតាមតម្រូវការនៃការផ្សាយផ្ទាល់កម្មវិធីទូរទស្សន៍ (ដែលកើតឡើងក្នុងពេលតំណាលគ្នា) ស្តីពីការប្រជុំ សន្និសិទ។ល។ (មើល ៨២៩៩០)

(ឍ) សកម្មភាពផ្ទាល់ខ្លួនរបស់តារាសម្តែង អ្នកគូររូបថ្លុក អ្នកដឹកនាំរឿង អ្នករចនាឆាក និងអ្នកជំនាញបច្ចេកទេស (មើល ៩០០០)។

(២) **រាប់បញ្ចូល** (ក) ការផលិតសារពាណិជ្ជកម្មសម្រាប់វិទ្យុ ទូរទស្សន៍ និងភាពយន្ត

(ខ) ការផ្សាយពាណិជ្ជកម្មដែលមិនធ្វើតាមរយៈមធ្យោបាយចាក់ផ្សាយ និង សកម្មភាពរបស់បណ្ណាល័យដែលរក្សាទុកខ្សែអាត់ភាពយន្ត។ល។

(៣) **មិនរាប់បញ្ចូល** (ក) ការចម្លងខ្សែភាពយន្ត (លើកលែងតែការផលិតឡើងវិញនូវខ្សែភាពយន្ត សម្រាប់ការចែកចាយតាមរោងរោងភាពយន្ត) ព្រមទាំងការផលិតឡើងវិញនូវ កាសែតខ្សែអាត់ វីដេអូ ស៊ីឌី ឌីវីឌី ពីច្បាប់ចម្លងមេ (មើល ១៨២០)។

(ខ) ការលក់ដុំកាសែតវីដេអូ ស៊ីឌី និងឌីវីឌីដែលបានថតទុកជាមុន (មើល ៤៦៥២៥)

(គ) ការលក់ដុំកាសែតវីដេអូ និងស៊ីឌីមិនទាន់ថតចម្លង (មើល ៤៦៥២៥)

(ឃ) ការលក់រាយកាសែតវីដេអូ ស៊ីឌី និងឌីវីឌី (មើល ៤៧៦២០)

(ង) ការកែសម្រួលខ្សែភាពយន្តក្រៅពីសម្រាប់ឧស្សាហកម្មភាពយន្ត (មើល ៧៤២០០)

(ច) ការជួលកាសែតវីដេអូ និងឌីវីឌីទៅដល់សាធារណជនទូទៅ (មើល ៧៧២២០)

(ឆ) សកម្មភាពផ្ទាល់ខ្លួនរបស់តារាសម្តែង អ្នកគូររូបកំប្លែង អ្នកដឹកនាំរឿង អ្នក រចនាឆាក និងអ្នកជំនាញបច្ចេកទេស (មើល ៩០០០)។

(៤) **រាប់បញ្ចូល** សកម្មភាពដូចជាការកែសម្រួល ការផ្ទេរខ្សែភាពយន្ត/កាសែត ការដាក់ចំណងជើង ការដាក់ចំណងជើងរង ការផ្តល់កិត្តិយសដល់អ្នកចូលរួមក្នុងផលិតកម្មភាពយន្ត ការផ្តល់ ការផ្សាយតាមតម្រូវការ ក្រាហ្វិកដែលផលិតដោយកុំព្យូទ័រ ការបង្កើតចលនា និងកែលម្អពិសេស ការអភិវឌ្ឍនិងកែលម្អខ្សែភាពយន្ត សកម្មភាពរបស់ទីពិសោធន៍ ខ្សែភាពយន្ត និងសកម្មភាពរបស់ទីពិសោធន៍ពិសេសផ្នែកភាពយន្តជីវចល។

ជំពូក ៣ ៖ ព័ត៌មានវិទ្យា និងទូរគមនាគមន៍

ផ្នែក ៥៩ ៖ សកម្មភាពចេញផ្សាយភាពយន្ត ការផលិតកម្មវិធីទូរទស្សន៍និងវីដេអូ សកម្មភាពថតសំឡេងនិងចេញផ្សាយតន្ត្រី

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	៥៩១៣[១]		សកម្មភាពចែកចាយភាពយន្ត កម្មវិធីទូរទស្សន៍ និងវីដេអូ
		៥៩១៣០	សកម្មភាពចែកចាយភាពយន្ត កម្មវិធីទូរទស្សន៍ និងវីដេអូ[២]
	៥៩១៤		សកម្មភាពចាក់បញ្ចាំងភាពយន្ត
		៥៩១៤០	ប្រតិបត្តិការរបស់រោងភាពយន្ត សកម្មភាពចាក់បញ្ចាំងភាពយន្ត[៣]
៥៩២			**សកម្មភាពថតសំឡេង និងចេញផ្សាយតន្ត្រី**
	៥៩២០[៤]		សកម្មភាពថតសំឡេង និងចេញផ្សាយតន្ត្រី
		៥៩២០០	សកម្មភាពថតសំឡេង និងចេញផ្សាយតន្ត្រី

(១) **មិនរាប់បញ្ចូល**
- (ក) ការចម្លងខ្សែភាពយន្ត (លើកលែងតែការផលិតឡើងវិញនូវខ្សែភាពយន្តសម្រាប់ការចែកចាយតាមរោងភាពយន្ត) ព្រមទាំងការផលិតឡើងវិញនូវកាសែតខ្សែអាត់ វីដេអូ ស៊ីឌី ឌីវីឌី ពីច្បាប់ចម្លងមេ (មើល ១៨២០)
- (ខ) ការផលិតឡើងវិញនូវខ្សែភាពយន្តសម្រាប់ការចែកចាយតាមរោងភាពយន្ត (មើល ៥៩១២)។

(២) **រាប់បញ្ចូល**
- (ក) សកម្មភាពនៃការស្វែងរកសិទ្ធិចែកចាយ និងការចែកចាយខ្សែភាពយន្ត ការសែតវីដេអូ ឌីវីឌី និងផលិតផលប្រហាក់ប្រហែល ទៅឲ្យរោងភាពយន្ត បណ្តាញនិងស្ថានីយទូរទស្សន៍ និងអ្នកតាំងពិព័រណ៍
- (ខ) ការស្វែងរកសិទ្ធចែកចាយខ្សែភាពយន្ត កាសែតវីដេអូ និងឌីវីឌី។

(៣) **រាប់បញ្ចូល** ការបញ្ចាំងខ្សែភាពយន្ត ឬវីដេអូនៅក្នុងរោងភាពយន្ត នៅក្នុងទីវាល ឬកន្លែងចាក់បញ្ចាំងផ្សេងទៀត និងក្លឹបរោងភាពយន្ត។

(៤) **រាប់បញ្ចូល**
- (ក) ការផលិតឧបករណ៍ថតសំឡេងដើម ដូចជាកាសែតខ្សែអាត់ ស៊ីឌី
- (ខ) សកម្មភាពសេវាកម្មថតសំឡេងនៅក្នុងស្ទូឌីយោ ឬកន្លែងផ្សេងៗទៀត ដូចជាការផលិតកម្មវិធីវិទ្យុ ខ្សែអាត់សម្រាប់ភាពយន្ត និងទូរទស្សន៍ដែលថតទុកជាមុន (មិនផ្សាយផ្ទាល់) ជាដើម
- (គ) សកម្មភាពចេញផ្សាយតន្ត្រី ដូចជាសកម្មភាពទទួលបាន និងចុះបញ្ជីសិទ្ធិអ្នកនិពន្ធសម្រាប់ការតែងតន្ត្រី ការផ្សព្វផ្សាយ ការផ្តល់សិទ្ធិ និងការប្រើប្រាស់ការតែងតន្ត្រីទាំងនេះ សម្រាប់ការថតសំឡេង វិទ្យុ ទូរទស្សន៍ ភាពយន្ត ការសម្តែងផ្ទាល់ ការបោះពុម្ពលើក្រដាស និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត ការចែកចាយការថតសំឡេងទៅដល់អ្នកលក់ដុំ អ្នកលក់រាយ ឬសាធារណជនដោយផ្ទាល់។

ផ្នែក ៦០ ៖ សកម្មភាពផ្សាយ និងបង្កើតកម្មវិធី

ផ្នែកនេះរាប់បញ្ចូលសកម្មភាពបង្កើតមាតិកា ឬការទិញកម្មសិទ្ធិដើម្បីចែកចាយមាតិកា និងផ្សព្វផ្សាយមាតិកានោះជាបន្តបន្ទាប់ ដូចជា តាមវិទ្យុ ទូរទស្សន៍ កម្មវិធីកម្សាន្ត ព័ត៌មាន និងការពិភាក្សាជាដើម។ ទិន្នន័យផ្សាយដែលត្រូវបានបញ្ចូលជាមួយការផ្សាយវិទ្យុ ឬទូរទស្សន៍ ក៏ត្រូវបានរាប់បញ្ចូលផងដែរ។ ការផ្សាយអាចធ្វើទៅបាន ដោយប្រើប្រាស់បច្ចេកវិទ្យាផ្សេងៗ ដូចជា តាមរយៈរលកធាតុអាកាស ផ្កាយរណប បណ្តាញខ្សែកាប ឬអ៊ីនធឺណិត។ ផ្នែកនេះក៏រាប់បញ្ចូលផងដែរ នូវការផលិតកម្មវិធីដែលជាធម្មតាការផ្សាយមានលក្ខណៈចង្អៀត (មានដែនកំណត់ ដូចជាកម្មវិធីព័ត៌មានកីឡា អប់រំ ឬកម្មវិធីសម្រាប់យុវជន) ដោយផ្អែកតាមការភ្ជាប់សេវា ឬកម្រៃឈ្នួលជាមួយភាគីទីបី សម្រាប់ការផ្សាយជាបន្តបន្ទាប់ដល់សាធារណជន។

ផ្នែកនេះមិនរាប់បញ្ចូលការចែកចាយកម្មវិធីតាមខ្សែកាប ឬកម្មវិធីភ្ជាប់សេវាផ្សេងទៀតនោះទេ (មើលផ្នែក ៦១)។

ក្រុម ៦០១ ៖ ការផ្សាយវិទ្យុ

ក្រុមនេះរាប់បញ្ចូលសកម្មភាពផ្សាយរលកសំឡេង តាមរយៈស្ទូឌីយោការផ្សាយវិទ្យុ និងឧបករណ៍បញ្ជូនកម្មវិធីសំឡេងទៅដល់សាធារណជន សមាជិក ឬអ្នកភ្ជាប់សេវា។ សកម្មភាពរបស់បណ្តាញវិទ្យុ ដូចជា ការតម្លើង និងបញ្ជូនកម្មវិធីសំឡេងទៅដល់សមាជិក ឬអ្នកភ្ជាប់សេវាតាមរយៈការផ្សាយតាមរលកធាតុអាកាស ខ្សែកាប ឬផ្កាយរណប ក៏ត្រូវបានរាប់បញ្ចូលផងដែរ។

សកម្មភាពផ្សាយវិទ្យុតាមអ៊ីនធឺណិត (ស្ថានីយវិទ្យុអ៊ីនធឺណិត) ក៏ត្រូវបានរាប់បញ្ចូលនៅក្នុងក្រុមនេះផងដែរ។ ជាមួយគ្នានេះដែរ ទិន្នន័យផ្សាយដែលបញ្ចូលគ្នាជាមួយការផ្សាយវិទ្យុក៏ត្រូវបានរាប់បញ្ចូលផងដែរ។

ក្រុម ៦០២ ៖ សកម្មភាពបង្កើតកម្មវិធី និងការផ្សាយទូរទស្សន៍

ក្រុមនេះរាប់បញ្ចូលការបង្កើតស្ថានីយទូរទស្សន៍ដែលបំពាក់ដោយកម្មវិធីពេញលេញមួយ ដែលទាញចេញពីសមាសភាគនៃកម្មវិធីដែលទិញ (ឧ. ខ្សែភាពយន្ត ភាពយន្តឯកសារ ជាដើម) សមាសភាគនៃកម្មវិធីដែលផលិតដោយខ្លួនឯង (ឧ. ព័ត៌មានក្នុងស្រុក របាយការណ៍ផ្សាយផ្ទាល់) ឬជាការបញ្ចូលគ្នានៃសមាសភាគពីរខាងលើនេះ។

ស្ថានីយទូរទស្សន៍ដែលបំពាក់ដោយកម្មវិធីពេញលេញនេះ អាចចាក់ផ្សាយដោយអង្គភាពដែលផលិត ឬផលិតសម្រាប់បញ្ជូនឲ្យចាក់ផ្សាយដោយភាគីទីបី ដូចជាក្រុមហ៊ុនខ្សែ កាប ឬអ្នកផ្តល់សេវាកម្មទូរទស្សន៍តាមផ្កាយរណប។

ការបង្កើតកម្មវិធីអាចមានលក្ខណៈទូទៅ ឬឯកទេស (ឧ. មានដែនកំណត់ ដូចជា កម្មវិធីព័ត៌មាន កីឡា ការអប់រំ ឬកម្មវិធីសម្រាប់យុវជន) អាចផ្សាយដល់អ្នកប្រើប្រាស់ដោយសេរី ឬអាចផ្សាយដោយផ្អែកលើមូលដ្ឋាននៃការភ្ជាប់សេវាតែប៉ុណ្ណោះ។

ការបង្កើតកម្មវិធីរបស់ស្ថានីយដែលបម្រើវីដេអូតាមតម្រូវការ និងទិន្នន័យផ្សាយដែលបញ្ចូលជាមួយការផ្សាយទូរទស្សន៍ក៏ត្រូវបានរាប់បញ្ចូលផងដែរ។

ជំពូក ៣ ៖ ព័ត៌មានវិទ្យា និងទូរគមនាគមន៍
ផ្នែក ៦០ ៖ សកម្មភាពផ្សាយ និងបង្កើតកម្មវិធី

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៦០១			**ការផ្សាយវិទ្យុ**
	៦០១០[(១)]		ការផ្សាយវិទ្យុ
		៦០១០០	ការផ្សាយវិទ្យុ
៦០២			**សកម្មភាពបង្កើតកម្មវិធី និងការផ្សាយទូរទស្សន៍**
	៦០២០[(២)]		សកម្មភាពបង្កើតកម្មវិធី និងការផ្សាយទូរទស្សន៍
		៦០២០០	សកម្មភាពបង្កើតកម្មវិធី និងការផ្សាយទូរទស្សន៍

(១) **រាប់បញ្ចូល**
(ក) ការផ្សាយរលកសំឡេងតាមរយៈស្ទូឌីយោផ្សាយវិទ្យុ និងឧបករណ៍សម្រាប់បញ្ជូនកម្មវិធីសំឡេងទៅសាធារណជន សមាជិក ឬអ្នកភ្ជាប់សេវា
(ខ) សកម្មភាពរបស់បណ្តាញវិទ្យុដូចជា ការតម្លើង និងបញ្ជូនកម្មវិធីសំឡេងទៅដល់សមាជិក ឬអ្នកភ្ជាប់សេវាតាមរយៈការផ្សាយតាមរលកធាតុអាកាស ខ្សែកាប ឬផ្កាយរណប
(គ) សកម្មភាពផ្សាយវិទ្យុតាមអ៊ីនធឺណិត (ស្ថានីយវិទ្យុ អ៊ីនធឺណិត)
(ឃ) ទិន្នន័យផ្សាយដែលបញ្ចូលគ្នាជាមួយការផ្សាយវិទ្យុ។

មិនរាប់បញ្ចូល ការផលិតកម្មវិធីវិទ្យុដែលថតទុកជាមុន (មើល ៥៩២០)។

(២) **រាប់បញ្ចូល**
(ក) ការបង្កើតស្ថានីយទូរទស្សន៍ដែលបំពាក់ដោយកម្មវិធីពេញលេញមួយ ដែលទាញចេញពីសមាសភាគនៃកម្មវិធីដែលទិញ (ឧ. ខ្សែភាពយន្ត ភាពយន្តឯកសារ ជាដើម) សមាសភាគនៃកម្មវិធីដែលផលិតដោយខ្លួនឯង (ឧ. ព័ត៌មាន ក្នុងស្រុក របាយការណ៍ផ្សាយផ្ទាល់) ឬជាការបញ្ចូលគ្នានៃសមាសភាគពីរខាងលើនេះ
(ខ) ការបង្កើតកម្មវិធីរបស់ស្ថានីយដែលបម្រើវីដេអូតាមតម្រូវការ
(គ) ទិន្នន័យផ្សាយដែលបញ្ចូលជាមួយការផ្សាយទូរទស្សន៍។

មិនរាប់បញ្ចូល
(ក) ការផលិតធាតុផ្សំនៃកម្មវិធីទូរទស្សន៍ (ឧ. ខ្សែភាពយន្ត ភាពយន្តឯកសារ ការផ្សាយពាណិជ្ជកម្ម) (មើល ៥៩១១)
(ខ) ការផ្តុំសេវាកម្មស្ថានីយទូរទស្សន៍ជាកញ្ចប់ និងការចែកចាយកញ្ចប់សេវាកម្មនោះតាមរយៈខ្សែកាប ឬផ្កាយរណបទៅដល់ទស្សនិកជន (មើលផ្នែក ៦១)។

ផ្នែក ៦១ ៖ ទូរគមនាគមន៍

ផ្នែកនេះរាប់បញ្ចូលនូវសកម្មភាពសេវាកម្មពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ និងសេវាកម្មពាក់ព័ន្ធផ្សេងទៀតជាអាទិ៍ ដូចជា៖ ការបញ្ជូនសំឡេង ការបញ្ជូនទិន្នន័យ (អត្ថបទ រូបភាព សារសម្លេង និងវីដេអូ)។ ឧបករណ៍ដែលបម្រើឲ្យសកម្មភាព ខាងលើទាំងនេះអាចផ្អែកលើបច្ចេកវិទ្យាទោល (អាណាឡូក)និងបច្ចេកវិទ្យាឌីជីតថល ។ សកម្មភាពដែលត្រូវបានចាត់ថ្នាក់ នៅក្នុងផ្នែកនេះ សំដៅដល់សកម្មភាពនៃការបញ្ជូនមាតិកា ប៉ុន្តែមិនសំដៅដល់សកម្មភាពនៃការបង្កើតមាតិកាទេ។ ការបែង ចែកបែបនេះ គឺផ្អែកលើប្រភេទនៃឧបករណ៍ (ទូរគមនាគមន៍ ឬមិនមែន) ។ សកម្មភាពគ្រប់គ្រង និងបែងចែកធនធានវិសាល គមន៍ហ្វ្រេកង់វិទ្យុ ការគ្រប់គ្រង និងបែងចែកក្បាលលេខទូរស័ព្ទ និងលេខកូដទូរគមនាគមន៍ ការផលិត ការនាំចូល ការនាំចេញ និងចែកចាយគ្រឿងសម្ភារៈបរិក្ខាទូរគមនាគមន៍ ការផ្តល់ការអនុញ្ញាតស្ថាបនា និងថែទាំបណ្តាញហេដ្ឋារចនាសម្ព័ន្ធទូរគមនា គមន៍ ការផ្តល់អជ្ញាបណ្ណ វិញ្ញាបនបត្រ និងលិខិតអនុញ្ញាតបំពេញប្រតិបត្តិការក្នុងវិស័យទូរគមនាគមន៍ ការគ្រប់គ្រងការចុះ ឈ្មោះប្រើប្រាស់ឈ្មោះដែនជាតិ និងការធ្វើនិយ័តកម្មក្នុងវិស័យទូរគមនាគមន៍។

ក្នុងករណីនៃការបញ្ជូនតាមរលកហ្វ្រេកង់ទូរទស្សន៍ ចំណុចនេះអាចរាប់បញ្ចូលការប្រមាច់បញ្ចូលគ្នានូវប៉ុស្តិ៍ទូរទស្សន៍ ដែលមានកម្មវិធីពេញលេញ (ដែលបង្កើតនៅក្នុងផ្នែក ៦០) ទៅជាកញ្ចប់កម្មវិធីសម្រាប់ការចែកចាយ។

ក្រុម ៦១១ ៖ សកម្មភាពទូរគមនាគមន៍ប្រើខ្សែ

ក្រុមនេះរាប់បញ្ចូលសកម្មភាពជាអាទិ៍ ប្រតិបត្តិការ ការថែទាំ ឬការផ្តល់ការប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍សម្រាប់ ការបញ្ជូនសំឡេង និងការបញ្ជូនទិន្នន័យ (អត្ថបទ រូបភាព សម្លេង និងវីដេអូ) ដោយប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ប្រើខ្សែ។ ឧបករណ៍ដែលបម្រើឲ្យសកម្មភាពខាងលើទាំងនេះផ្អែកលើបច្ចេកវិទ្យាទោល (អាណាឡូក) និងបច្ចេកវិទ្យាឌីជីតថល។

សកម្មភាពទាំងនេះរួមមាន៖ (១) ប្រតិបត្តិការ និងការថែរទាំឧបករណ៍ទូរគមនាគមន៍ដើម្បីផ្តល់ទំនាក់ទំនងពីចំណុច មួយទៅចំណុចមួយទៀតតាមខ្សែកាប ឬការរួមបញ្ចូលគ្នាខ្សែរត់លើដី (២) ប្រតិបត្តិការប្រព័ន្ធបញ្ជូនតាមខ្សែកាប ។ល។ សម្រាប់ ការចែកចាយទិន្នន័យ និង (៣) ការផ្តល់ទូរលេខ និងទំនាក់ទំនងមិនប្រើសំឡេងផ្សេងទៀតដោយប្រើឧបករណ៍ផ្ទាល់ ។

ការជាវទិន្នន័យអ៊ីនធឺណិត និងការផ្តល់សេវាកម្មទូរគមនាគមន៍ដោយប្រើប្រាស់ទូរគមនាគមន៏ឥតខ្សែ(លើកលែងតែ ផ្កាយរណប) ទៅដល់អ្នកប្រើប្រាស់ត្រូវបានរាប់បញ្ចូលនៅក្នុងក្រុមនេះ។

ក្រុមនេះក៏រាប់បញ្ចូលការផ្តល់សេវាកម្មអ៊ីនធឺណិតដោយប្រតិបត្តិករសេវាទូរស័ព្ទដែលប្រើប្រព័ន្ធទូរគមនាគមន៍ប្រើខ្សែ ផងដែរ។

ក្រុម ៦១២ ៖ សកម្មភាពទូរគមនាគមន៍ប្រើប្រាស់បច្ចេកវិទ្យាវិទ្យុគមនាគមន៍

ក្រុមនេះរាប់បញ្ចូលសកម្មភាពជាអាទិ៍ ប្រតិបត្តិការ ការថែទាំ ឬការផ្តល់ការប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍សម្រាប់បញ្ជូនសំឡេង និងការបញ្ជូនទិន្នន័យ (អត្ថបទ រូបភាព សំលេង និងវីដេអូ) ដោយប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ឥតខ្សែ។ ឧបករណ៍ទាំងនេះផ្តល់នូវការបញ្ជូនគ្រប់ទិសដៅតាមរយៈហ្វ្រេកង់វិទ្យុ ហើយឧបករណ៍ដែលបម្រើឲ្យសកម្មភាពខាងលើទាំងនេះអាចផ្អែកលើការប្រើប្រាស់បច្ចេកវិទ្យាទោល (អាណាឡូក) និងបច្ចេកវិទ្យាឌីជីថល។ សកម្មភាពថែទាំ និងប្រតិបត្តិប្រព័ន្ធថែទាំ និងទាញទិន្នន័យពីអង្គចងចាំ ព្រមទាំងបណ្តាញទូរគមនាគមន៍ចល័តនិងឥតខ្សែផ្សេងៗ ត្រូវបានរាប់បញ្ចូលក្នុងផ្នែកនេះ។

ការទិញសមត្ថភាពភ្ជាប់ និងបណ្តាញពីកម្មសិទ្ធិករ និងប្រតិបត្តិករនៃបណ្តាញ និងការផ្តល់ប្រតិបត្តិការទូរគមនាគមន៍ប្រើប្រាស់បច្ចេកវិទ្យាវិទ្យុគមនាគមន៍(លើកលែងតែផ្កាយរណប)ដោយប្រើប្រាស់សមត្ថភាពនេះទៅដល់អាជីវកម្ម និងទៅតាមផ្ទះ ត្រូវបានរាប់បញ្ចូលនៅក្នុងក្រុមនេះ។

ក្រុមនេះក៏រាប់បញ្ចូលផងដែរ នូវការផ្តល់សេវាកម្មអ៊ីនធឺណិត ដោយប្រតិបត្តិករដែលប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ប្រើប្រាស់បច្ចេកវិទ្យាវិទ្យុគមនាគមន៍។

ក្រុម ៦១៣ ៖ សកម្មភាពទូរគមនាគមន៍ផ្កាយរណប

ក្រុមនេះរាប់បញ្ចូលសកម្មភាពនៃការប្រតិបត្តិ ការថែរក្សា ឬការផ្តល់ការប្រើប្រាស់ឧបករណ៍សម្រាប់បញ្ជូនសំឡេង ទិន្នន័យ អត្ថបទ សូរស័ព្ទ និងវីដេអូ ដោយប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ផ្កាយរណប។

ក្រុមនេះក៏រាប់បញ្ចូលការបញ្ជូនកម្មវិធីជារូបភាព សំឡេង ឬអត្ថបទ ដែលទទួលបានពីបណ្តាញខ្សែកាប ស្ថានីយទូរទស្សន៍ក្នុងស្រុក ឬបណ្តាញវិទ្យុ ទៅដល់អតិថិជន តាមរយៈប្រព័ន្ធផ្កាយរណបបញ្ជូនដល់ផ្ទះ។ ជាទូទៅអង្គភាពដែលចាត់ថ្នាក់ក្នុងក្រុមនេះ មិនបង្កើតសម្ភារៈផលិតកម្មវិធីនោះទេ។

ក្រុមនេះក៏រាប់បញ្ចូលផងដែរ នូវការផ្តល់សេវាកម្មអ៊ីនធឺណិត ដោយប្រតិបត្តិករដែលប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ផ្កាយរណប។

ក្រុម ៦១៩ ៖ សកម្មភាពទូរគមនាគមន៍ផ្សេងទៀត

ក្រុមនេះរាប់បញ្ចូល ការផ្គត់ផ្គង់កម្មវិធីទូរគមនាគមន៍ឯកទេស ដូចជាការឃ្លាំមើល ផ្កាយរណប ទូរមាត្រវិធីនៃទំនាក់ទំនង និងប្រតិបត្តិការស្ថានីយរ៉ាដា ការប្រតិបត្តិស្ថានីយចំណុចផ្កាយរណប និងឧបករណ៍ពាក់ព័ន្ធដែលប្រតិបត្តិការភ្ជាប់ទៅនឹងប្រព័ន្ធទំនាក់ទំនងនៅលើដីមួយឬច្រើនកន្លែង ដែលមានសមត្ថភាពបញ្ជូន ឬទទួលទូរគមនាគមន៍ពីប្រព័ន្ធផ្កាយ រណប ការផ្តល់សេវាកម្មអ៊ីនធឺណិតតាមរយៈបណ្តាញរវាងអតិថិជន និងអ្នកផ្តល់សេវាកម្ម ដែលបណ្តាញនេះមិនមែនជាកម្មសិទ្ធិរបស់ ឬគ្រប់គ្រងដោយអ្នកផ្តល់សេវាកម្ម ដូចជាការផ្តល់សេវាកម្មអ៊ីនធឺណិតមានខ្សែជាដើម ការផ្តល់សេវាទូរស័ព្ទនិងអ៊ីនធឺណិតនៅកន្លែងដែលបើកទូលាយដល់សាធារណជន និងការផ្តល់សេវាទូរគមនាគមន៍តាមរយៈបណ្តាញភ្ជាប់ទូរគមនាគមន៍ដែលមានស្រាប់ដូចជាការផ្តល់សេវាកម្មវីអូអាយភី (VOIP: ពិធីសាអ៊ីនធឺណិតដោយសំឡេង) និងអ្នកលក់បន្តនូវសេវាទូរគមនាគមន៍ (ឧ. ការទិញ និងការលក់បន្តនូវសមត្ថភាពបណ្តាញដោយគ្មានការផ្តល់សេវាកម្មបន្ថែម)។

ជំពូក ញ ៖ ព័ត៌មានវិទ្យា និងទូរគមនាគមន៍
ផ្នែក ៦១ ៖ ទូរគមនាគមន៍

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៦១១			**សកម្មភាពទូរគមនាគមន៍មានខ្សែ**
	៦១១០		សកម្មភាពទូរគមនាគមន៍មានខ្សែ
		៦១១០០(១)	ប្រតិបត្តិការទូរគមនាគមន៍មានខ្សែ
៦១២			**សកម្មភាពទូរគមនាគមន៍ប្រើប្រាស់បច្ចេកវិទ្យាវិទ្យុគមនាគមន៍**
	៦១២០		សកម្មភាពទូរគមនាគមន៍ប្រើប្រាស់បច្ចេកវិទ្យាវិទ្យុគមនាគមន៍
		៦១២០០(២)	ប្រតិបត្តិការទូរគមនាគមន៍ប្រើប្រាស់បច្ចេកវិទ្យាវិទ្យុគមនាគមន៍

(១) **រាប់បញ្ចូល**

(ក) ការប្រតិបត្តិ ការថែរក្សា ឬការផ្តល់ការប្រើប្រាស់ឧបករណ៍ សម្រាប់បញ្ជូនសំឡេង ទិន្នន័យ អត្ថបទ សូរស័ព្ទ និងវីដេអូ ដោយប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍មានខ្សែ រាប់បញ្ចូលការប្រតិបត្តិ និងការថែរក្សាឧបករណ៍ផ្លាស់ប្តូរ និងបញ្ជូន ដើម្បីផ្តល់ទំនាក់ទំនងពីចំណុចមួយទៅចំណុចមួយទៀតតាមរយៈខ្សែរត់លើដីវលកបញ្ជូនខ្លី ឬការរួមបញ្ចូលគ្នារវាងខ្សែរត់លើដី និងឧបករណ៍ផ្កាយរណប ការប្រតិបត្តិប្រព័ន្ធបញ្ជូនតាមខ្សែកាប (ឧ. សម្រាប់ការចែកចាយទិន្នន័យ និងរលកសញ្ញាទូរទស្សន៍) និងការផ្តល់ទូរលេខ និងទំនាក់ទំនងមិនប្រើសំឡេងផ្សេងទៀត ដោយប្រើឧបករណ៍ផ្ទាល់របស់ពួកគេ

(ខ) ការទិញសមត្ថភាពភ្ជាប់ និងបណ្តាញពីកម្មសិទ្ធិករ និងប្រតិបត្តិករនៃបណ្តាញ និងការផ្តល់ប្រតិបត្តិការទូរគមនាគមន៍ ដោយប្រើប្រាស់សមត្ថភាពនេះទៅដល់អាជីវកម្ម និងទៅតាមផ្ទះ

(គ) ការផ្តល់សេវាកម្មអ៊ីនធឺណិត ដោយប្រតិបត្តិករដែលប្រើប្រព័ន្ធទូរគមនាគមន៍មានខ្សែ។

មិនរាប់បញ្ចូល អ្នកលក់បន្តនូវប្រតិបត្តិការទូរគមនាគមន៍ (មើល ៦១៩០)។

(២) **រាប់បញ្ចូល**

(ក) ការប្រតិបត្តិ ការថែរក្សា ឬការផ្តល់ការប្រើប្រាស់ឧបករណ៍សម្រាប់បញ្ជូនសំឡេង ទិន្នន័យ អត្ថបទ សូរស័ព្ទ និងវីដេអូ ដោយប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ប្រើប្រាស់បច្ចេកវិទ្យាវិទ្យុគមនាគមន៍

(ខ) ការថែរក្សា និងប្រតិបត្តិបណ្តាញទូរគមនាគមន៍ចល័តនិងប្រើប្រាស់បច្ចេកវិទ្យាវិទ្យុគមនាគមន៍ផ្សេងទៀត

(គ) ការទិញសមត្ថភាពភ្ជាប់ និងបណ្តាញពីកម្មសិទ្ធិករ និងប្រតិបត្តិករនៃបណ្តាញ និងការផ្តល់ប្រតិបត្តិការទូរគមនាគមន៍ប្រើប្រាស់បច្ចេកវិទ្យាវិទ្យុគមនាគមន៍ (លើកលែងតែផ្កាយរណប) ដោយប្រើប្រាស់សមត្ថភាពនេះទៅដល់អាជីវកម្ម និងទៅតាមផ្ទះ

(ឃ) ការផ្តល់សេវាកម្មអ៊ីនធឺណិតដោយប្រតិបត្តិករដែលប្រើប្រព័ន្ធទូរគមនាគមន៍ប្រើប្រាស់បច្ចេកវិទ្យាវិទ្យុគមនាគមន៍។

មិនរាប់បញ្ចូល អ្នកលក់បន្តនូវប្រតិបត្តិការទូរគមនាគមន៍ (មើល ៦១៩០)។

ជំពូក ៣ ៖ ព័ត៌មានវិទ្យា និងទូរគមនាគមន៍
ផ្នែក ៦១ ៖ ទូរគមនាគមន៍

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៦១៣			**ប្រតិបត្តិការទូរគមនាគមន៍តាមប្រព័ន្ធផ្កាយរណប**
	៦១៣០[១]		ប្រតិបត្តិការទូរគមនាគមន៍តាមប្រព័ន្ធផ្កាយរណប
		៦១៣០០	ប្រតិបត្តិការទូរគមនាគមន៍តាមប្រព័ន្ធផ្កាយរណប
៦១៩			**សកម្មភាពទូរគមនាគមន៍ផ្សេងទៀត**
	៦១៩០[២]		សកម្មភាពទូរគមនាគមន៍ផ្សេងទៀត
		៦១៩០១	ហាងកាហ្វេអ៊ីនធឺណិត ការផ្តល់សេវាកម្មអ៊ីនធឺណិតនៅកន្លែងដែលបើកទូលាយដល់សាធារណជន
		៦១៩០៩	សកម្មភាពទូរគមនាគមន៍ផ្សេងទៀតដែលពុំបានរាប់បញ្ចូល

(១) **រាប់បញ្ចូល**
- (ក) ការប្រតិបត្តិ ការថែរក្សា ឬការផ្តល់ការប្រើប្រាស់ឧបករណ៍សម្រាប់បញ្ជូនសំឡេង ទិន្នន័យ អត្ថបទ សូរស័ព្ទ និងវីដេអូ ដោយប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ផ្កាយរណប
- (ខ) ការបញ្ជូនកម្មវិធីជារូបភាព សំឡេង ឬអត្ថបទដែលទទួលពីបណ្តាញខ្សែកាបស្ថានីយទូរទស្សន៍ក្នុងស្រុក ឬបណ្តាញវិទ្យុទៅដល់អតិថិជនតាមរយៈប្រព័ន្ធផ្កាយរណបបញ្ជូនដល់ផ្ទះ (ជាទូទៅ អង្គភាពដែលចាត់ថ្នាក់ក្នុងក្រុមនេះមិនបង្កើតសម្ភារៈផលិតកម្មវិធីនោះទេ)
- (គ) ការផ្តល់សេវាកម្មអ៊ីនធឺណិតដោយប្រតិបត្តិករដែលប្រើប្រព័ន្ធទូរគមនាគមន៍ផ្កាយរណប។

មិនរាប់បញ្ចូល អ្នកលក់បន្តនូវប្រតិបត្តិការទូរគមនាគមន៍ (មើល ៦១៩០៣)។

(២) **រាប់បញ្ចូល**
- (ក) ការផ្គត់ផ្គង់កម្មវិធីទូរគមនាគមន៍ឯកទេស (ឧ. ការឃ្លាំមើលផ្កាយរណបទូរមាត្រវិធីនៃទំនាក់ទំនង និងប្រតិបត្តិការស្ថានីយរ៉ាដា)
- (ខ) ប្រតិបត្តិការស្ថានីយចំណុចផ្កាយរណប និងឧបករណ៍ពាក់ព័ន្ធដែលប្រតិបត្តិការភ្ជាប់ទៅនឹងប្រព័ន្ធទំនាក់ទំនងនៅលើដីមួយឬច្រើនកន្លែង ដែលមានសមត្ថភាពបញ្ជូន ឬទទួលទូរគមនាគមន៍ពីប្រព័ន្ធផ្កាយរណប
- (គ) ការផ្តល់សេវាកម្មអ៊ីនធឺណិតតាមរយៈបណ្តាញរវាងអតិថិជន និងអ្នកផ្តល់សេវាកម្ម ដែលបណ្តាញនេះមិនមែនជាកម្មសិទ្ធិរបស់ ឬគ្រប់គ្រងដោយអ្នកផ្តល់សេវាកម្ម (ឧ. ការផ្តល់សេវាកម្មអ៊ីនធឺណិតមានខ្សែ។ល។)
- (ឃ) ការផ្តល់សេវាទូរស័ព្ទ និងអ៊ីនធឺណិតនៅកន្លែងដែលបើកទូលាយដល់សាធារណជន
- (ង) ការផ្តល់សេវាទូរគមនាគមន៍តាមរយៈបណ្តាញភ្ជាប់ទូរគមនាគមន៍ដែលមានស្រាប់ ដូចជាការផ្តល់សេវាកម្មវីអូអាយភី (VOIP: ពិធីសាអ៊ីនធឺណិតដោយសំឡេង)
- (ច) អ្នកលក់បន្តនូវសេវាទូរគមនាគមន៍ (ឧ. ការទិញ និងការលក់បន្តនូវសមត្ថភាពបណ្តាញដោយគ្មានការផ្តល់សេវាកម្មបន្ថែម)។

មិនរាប់បញ្ចូល ការផ្តល់សេវាកម្មអ៊ីនធឺណិតដោយប្រតិបត្តិករនៃប្រព័ន្ធទូរគមនាគមន៍ (មើល ៦១១០, ៦១២០, ៦១៣០)។

ផ្នែក ៦២ ៖ ការបង្កើតកម្មវិធីកុំព្យូទ័រ ការពិគ្រោះយោបល់ និងសកម្មភាពពាក់ព័ន្ធ

ផ្នែកនេះរាប់បញ្ចូលនូវ សកម្មភាពនៃការផ្តល់ជំនាញការ ខាងផ្នែកព័ត៌មានវិទ្យា ដូចជាការសរសេរ ការកែសម្រួល ការសាកល្បង និងការថែទាំកម្មវិធីកុំព្យូទ័រដើម្បីបំពេញតម្រូវការរបស់ក្រុមអតិថិជនគោលដៅណាមួយ ការធ្វើផែនការ និងការរចនាប្រព័ន្ធកុំព្យូទ័រដែលរួមបញ្ចូលផ្នែករឹង ផ្នែកទន់ និងបច្ចេកវិទ្យាទំនាក់ទំនង ការគ្រប់គ្រង និងការប្រតិបត្តិប្រព័ន្ធកុំព្យូទ័រ ឬឧបករណ៍ដំណើរការទិន្នន័យរបស់អតិថិជននៅនឹងកន្លែង ការផ្តល់ប្រព័ន្ធឬឧបករណ៍សម្រាប់សេវាកម្មបង្ហោះវែបសាយ និងដំណើរការទិន្នន័យ និងសកម្មភាពវិជ្ជាជីវៈ និងបច្ចេកទេស ដែលពាក់ព័ន្ធនឹងកុំព្យូទ័រដទៃទៀត។

ក្រុម ៦២០ ៖ ការបង្កើតកម្មវិធីកុំព្យូទ័រ ការពិគ្រោះយោបល់ និងសកម្មភាពពាក់ព័ន្ធ

ក្រុមនេះរាប់បញ្ចូលនូវ សកម្មភាពនៃការផ្តល់ជំនាញការ ខាងផ្នែកព័ត៌មានវិទ្យា ដូចជាការសរសេរ ការកែសម្រួល ការសាកល្បង និងការថែទាំកម្មវិធីកុំព្យូទ័រដើម្បីបំពេញតម្រូវការរបស់ក្រុមអតិថិជនគោលដៅណាមួយ ការធ្វើផែនការ និងការរចនាប្រព័ន្ធកុំព្យូទ័រដែលរួមបញ្ចូលផ្នែករឹង ផ្នែកទន់ និងបច្ចេកវិទ្យាទំនាក់ទំនង ការគ្រប់គ្រង និងការប្រតិបត្តិប្រព័ន្ធកុំព្យូទ័រឬឧបករណ៍ដំណើរការទិន្នន័យរបស់អតិថិជននៅនឹងកន្លែង ការផ្តល់ប្រព័ន្ធឬឧបករណ៍សម្រាប់សេវាកម្មបង្ហោះវែបសាយ និងដំណើរការទិន្នន័យ និងសកម្មភាពវិជ្ជាជីវៈ និងបច្ចេកទេស ដែលពាក់ព័ន្ធនឹងកុំព្យូទ័រដទៃទៀត។

ជំពូក ៣ ៖ ព័ត៌មានវិទ្យា និងទូរគមនាគមន៍
ផ្នែក ៦២ ៖ ការបង្កើតកម្មវិធីកុំព្យូទ័រ ការពិគ្រោះយោបល់ និងសកម្មភាពពាក់ព័ន្ធ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៦២០			**ការបង្កើតកម្មវិធីកុំព្យូទ័រ ការពិគ្រោះយោបល់ និងសកម្មភាពពាក់ព័ន្ធ**
	៦២០១[១]		សកម្មភាពបង្កើតកម្មវិធីកុំព្យូទ័រ
		៦២០១០	សកម្មភាពបង្កើតកម្មវិធីកុំព្យូទ័រ[២]
	៦២០២[៣]		សកម្មភាពពិគ្រោះយោបល់កុំព្យូទ័រ និងការគ្រប់គ្រងសម្ភារៈកុំព្យូទ័រ
		៦២០២០	សកម្មភាពពិគ្រោះយោបល់កុំព្យូទ័រ និងការគ្រប់គ្រងសម្ភារៈកុំព្យូទ័រ[៤]
	៦២០៩[៥]		សកម្មភាពព័ត៌មានវិទ្យា និងសេវាកម្មកុំព្យូទ័រផ្សេងទៀត
		៦២០៩០	សកម្មភាពសេវាកម្មព័ត៌មានវិទ្យាផ្សេងទៀត ដែលពុំបានរាប់បញ្ចូល[៦]

(១) **រាប់បញ្ចូល** (ក) ការបង្កើតរចនាសម្ព័ន្ធ និងមាតិកា និង/ឬការសរសេរកូដកុំព្យូទ័រដើម្បីបង្កើត និងអនុវត្តកម្មវិធីផ្នែកទុនរបស់ប្រព័ន្ធកុំព្យូទ័រ (រាប់បញ្ចូលការធ្វើបច្ចុប្បន្នកម្ម និងការជួសជុល) កម្មវិធីផ្នែកទន់ (រាប់បញ្ចូលការធ្វើបច្ចុប្បន្នកម្ម និងការជួសជុល) បណ្តុំទិន្នន័យ និងវែបសាយ

(ខ) ការបង្កើតកម្មវិធីកុំព្យូទ័រដែលបំពេញតាមតម្រូវការរបស់អតិថិជន (ឧ. ការកែតម្រូវ និងការកែរូបសណ្ឋានកម្មវិធីដែលមានស្រាប់មួយឲ្យបំពេញមុខងារតាមបរិបទប្រព័ន្ធព័ត៌មានរបស់អតិថិជន)។

មិនរាប់បញ្ចូល (ក) ការចេញផ្សាយកម្មវិធីកុំព្យូទ័រដែលបានបង្កើតស្រាប់ (មើល ៥៨២០)

(ខ) ការធ្វើផែនការ និងការរចនាប្រព័ន្ធកុំព្យូទ័រដែលរួមបញ្ចូលផ្នែករឹង ផ្នែកទន់ និងបច្ចេកវិទ្យាទំនាក់ទំនង បើទោះបីជាការផ្តល់សេវាកម្មផ្នែកទន់ជាសកម្មភាពស្នូល (មើល ៦២០២០)។

(២) **រាប់បញ្ចូល** (ក) សកម្មភាពសរសេរ កែសម្រួល សាកល្បង និងថែទាំកម្មវិធីកុំព្យូទ័រដើម្បីបំពេញតម្រូវការរបស់ក្រុមអតិថិជនគោលដៅណាមួយ (ការបង្កើតកម្មវិធីកុំព្យូទ័រដែលបំពេញតាមតម្រូវការរបស់អតិថិជន)

(ខ) ការផលិតកម្មវិធីកុំព្យូទ័រដែលមិនជាប់ទាក់ទងជាមួយនឹងការចេញផ្សាយ

(គ) ការសរសេរកម្មវិធីកុំព្យូទ័រសម្រាប់ការកម្សាន្តហ្គេមវីដេអូ

(ឃ) ការរចនា និងការបង្កើតវែបសាយ។

(៣) **រាប់បញ្ចូល** (ក) ការធ្វើផែនការ និងការរចនាប្រព័ន្ធកុំព្យូទ័រដែលរួមបញ្ចូលផ្នែករឹង ផ្នែកទន់ និងបច្ចេកវិទ្យាទំនាក់ទំនង

(ខ) ការផ្តល់សេវាកម្មគ្រប់គ្រង និងប្រតិបត្តិការប្រព័ន្ធកុំព្យូទ័រ ឬឧបករណ៍ដំណើរការទិន្នន័យរបស់អតិថិជននៅនឹងកន្លែង ព្រមទាំងសេវាកម្មគាំទ្រដែលពាក់ព័ន្ធ។

(៤) **រាប់បញ្ចូល** ការផ្តល់សេវាកម្មគ្រប់គ្រង និងប្រតិបត្តិការប្រព័ន្ធកុំព្យូទ័រ ឬឧបករណ៍ដំណើរការទិន្នន័យរបស់អតិថិជននៅនឹងកន្លែង។

មិនរាប់បញ្ចូល (ក) ការលក់ផ្នែករឹង ឬផ្នែកទន់របស់កុំព្យូទ័រដាច់ដោយឡែកពីគ្នា (មើល ៤៦៥១, ៤៧៤១)

(ខ) ការតម្លើងកុំព្យូទ័រធំៗ និងកុំព្យូទ័រប្រភេទស្រដៀងគ្នានេះដាច់ដោយឡែកពីគ្នា (មើល ៣៣២០)

(គ) ការតម្លើងកុំព្យូទ័រផ្ទាល់ខ្លួនដាច់ដោយឡែក (មើល ៦២០៩០)

(ឃ) ការតម្លើងកម្មវិធីកុំព្យូទ័រដាច់ដោយឡែក (មើល ៦២០៩០)។

(៥) **មិនរាប់បញ្ចូល** (ក) ការតម្លើងកុំព្យូទ័រធំៗ និងកុំព្យូទ័រប្រភេទស្រដៀងគ្នានេះដាច់ដោយឡែកពីគ្នា (មើល ៣៣២០)

(ខ) ការបង្កើតកម្មវិធីកុំព្យូទ័រ (មើល ៦២០១០)

(គ) ការពិគ្រោះយោបល់ផ្នែកកុំព្យូទ័រ (មើល ៦២០២០)

(ឃ) ការគ្រប់គ្រងឧបករណ៍កុំព្យូទ័រ (មើល ៦២០២០)

(ង) ការដាក់ឲ្យដំណើរការ និងបំប្លែងទិន្នន័យ (មើល ៦៣១១)។

(៦) **រាប់បញ្ចូល** (ក) ការសង្គ្រោះឡើងវិញនូវការខូចខាតរបស់កុំព្យូទ័រ

(ខ) ការតម្លើងកុំព្យូទ័រផ្ទាល់ខ្លួន

(គ) ការតម្លើងកម្មវិធីកុំព្យូទ័រ។

ផ្នែក ៦៣ ៖ សកម្មភាពសេវាកម្មព័ត៌មាន

ផ្នែកនេះរាប់បញ្ចូលសកម្មភាពនៃប្រព័ន្ធស្វែងរកតាមអ៊ីនធឺណិត (web search portal) សកម្មភាពបំប្លែងទិន្នន័យ និងការដាក់ដំណើរការលើអ៊ីនធឺណិត ព្រមទាំងសកម្មភាពផ្សេងទៀត ដែលមានតួនាទីចម្បងសម្រាប់ផ្តល់ព័ត៌មាន។

ក្រុម ៦៣១ ៖ ការបំប្លែងទិន្នន័យ ការដាក់ដំណើរការលើអ៊ីនធឺណិតនិងសកម្មភាពពាក់ព័ន្ធ និងប្រព័ន្ធស្វែងរកតាម អ៊ីនធឺណិត

ក្រុមនេះរាប់បញ្ចូល ការផ្តល់សេវាកម្មប្រព័ន្ធឬឧបករណ៍ សម្រាប់សកម្មភាពនៃការដាក់ដំណើរការលើអ៊ីនធឺណិត ការបំប្លែងទិន្នន័យ និងសកម្មភាពដែលពាក់ព័ន្ធ ព្រមទាំងការផ្តល់សេវាកម្មស្វែងរកនៅលើអ៊ីនធឺណិត និងប្រព័ន្ធស្វែងរកលើអ៊ីនធឺណែតផ្សេងទៀត។

ក្រុម ៦៣៩ ៖ សកម្មភាពសេវាកម្មព័ត៌មានផ្សេងទៀត

ក្រុមនេះរាប់បញ្ចូលសកម្មភាពរបស់ទីភ្នាក់ងារព័ត៌មាន និងសកម្មភាពសេវាកម្មព័ត៌មានដទៃទៀត។

ជំពូក ៣ ៖ ព័ត៌មានវិទ្យា និងទូរគមនាគមន៍
ផ្នែក ៦៣ ៖ សកម្មភាពសេវាកម្មព័ត៌មាន

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៦៣១			**ការបំប្លែងទិន្នន័យ ការដាក់ដំណើរការលើអ៊ីនធឺណិតនិងសកម្មភាពពាក់ព័ន្ធ និងប្រព័ន្ធស្វែងរកតាមអ៊ីអ៊ីនធឺណិត**
	៦៣១១		ការបំប្លែងទិន្នន័យ ការដាក់ដំណើរការលើអ៊ីអ៊ីនធឺណិតនិងសកម្មភាពពាក់ព័ន្ធ
		៦៣១១១	មជ្ឈមណ្ឌលទិន្នន័យ
		៦៣១១២	សេវាដាក់ដំណើរការលើអ៊ីអ៊ីនធឺណិត
		៦៣១១៩	ការបំប្លែងទិន្នន័យ ការវិភាគទិន្នន័យនិងសកម្មភាពពាក់ព័ន្ធ ពុំបានរាប់បញ្ចូល[១]
	៦៣១២		ប្រព័ន្ធស្វែងរកតាមអ៊ីអ៊ីនធឺណិត
		៦៣១២០	ប្រព័ន្ធស្វែងរកតាមអ៊ីអ៊ីនធឺណិត[២]
៦៣៩			**សកម្មភាពសេវាកម្មព័ត៌មានផ្សេងទៀត**
	៦៣៩១[៣]		សកម្មភាពរបស់ទីភ្នាក់ងារព័ត៌មាន
		៦៣៩១០	បណ្តាញផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពរបស់ទីភ្នាក់ងារព័ត៌មាន ដូចជាការផ្តល់ព័ត៌មាន រូបភាព និងសាច់រឿងទៅដល់ប្រព័ន្ធផ្សព្វផ្សាយ
	៦៣៩៩[៤]		សកម្មភាពសេវាកម្មព័ត៌មានផ្សេងទៀត ដែលពុំបានរាប់បញ្ចូល
		៦៣៩៩០	សកម្មភាពសេវាកម្មព័ត៌មានផ្សេងទៀត ដែលពុំបានរាប់បញ្ចូល

(១) **រាប់បញ្ចូល** ការបង្ហោះវែបសាយ ការដាក់ដំណើរការកម្មវិធី ការផ្តល់សេវាកម្មវិធីកុំព្យូទ័រ និងឧបករណ៍កុំព្យូទ័រខ្នាតធំដែលប្រើប្រាស់ក្នុងពេលរួមគ្នាជាមួយអតិថិជន។ របាយការណ៍បំប្លែងទិន្នន័យពេញលេញ និងរបាយការណ៍ជំនាញ ដែលទាញចេញពីទិន្នន័យផ្តល់ឲ្យ ដោយអតិថិជន ឬការផ្តល់សេវាកម្មបំប្លែងទិន្នន័យស្វ័យប្រវត្តិ និងការបញ្ចូលទិន្នន័យ ក៏ត្រូវបានរាប់បញ្ចូលផងដែរ។

(២) **រាប់បញ្ចូល** ប្រតិបត្តិការវែបសាយដែលប្រើប្រព័ន្ធស្វែងរក ដើម្បីបង្កើតនិងរក្សាបណ្តុំទិន្នន័យដ៏ធំនៃអាសយដ្ឋានអ៊ីនធឺណិត និងមាតិកានៅក្នុងទម្រង់ដែលងាយស្រួលស្វែងរក។ ប្រតិបត្តិការវែបសាយផ្សេងទៀតដែលដើរតួនាទីជាប្រព័ន្ធស្វែងរកតាមអ៊ីនធឺណិត ដូចជាវែបសាយរបស់ប្រព័ន្ធផ្សព្វផ្សាយដែលផ្តល់មាតិកាដែលបានធ្វើបច្ចុប្បន្នកម្មជាប្រចាំ។

(៣) **រាប់បញ្ចូល** បណ្តាញផ្សព្វផ្សាយព័ត៌មាន និងសកម្មភាពរបស់ទីភ្នាក់ងារព័ត៌មាន ដូចជា ការផ្តល់ព័ត៌មាន រូបភាព និងសាច់រឿងទៅដល់ប្រព័ន្ធផ្សព្វផ្សាយ។

មិនរាប់បញ្ចូល
- (ក) សកម្មភាពរបស់អ្នកកាសែតខាងរូបភាពឯករាជ្យ (មើល៧៤២០០)
- (ខ) សកម្មភាពរបស់អ្នកកាសែតឯករាជ្យ (មើល ៩០០០៤)
- (គ) សកម្មភាពរបស់បណ្ណាល័យ និងបណ្ណសារដ្ឋាន (មើល ៩១០១)។

(៤) **រាប់បញ្ចូល**
- (ក) សេវាកម្មព័ត៌មានតាមទូរស័ព្ទ
- (ខ) សេវាកម្មស្វែងរកព័ត៌មានដោយផ្អែកលើកិច្ចសន្យា ឬការបង់ថ្លៃឈ្នួល

(គ) សេវាកម្មប្រមូលផ្តុំព័ត៌មាន និងសេវាកម្មប្រមូលផ្តុំសារព័ត៌មាន។ល។

មិនរាប់បញ្ចូល សកម្មភាពរបស់មណ្ឌលហៅទូរស័ព្ទ (មើល ៨២២០០)។

ជំពូក ង ៖ សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង

កម្រិត	ច.ស.វ.ក
ជំពូក	១
ផ្នែក	៣
ក្រុម	១០
ថ្នាក់	១៨
ថ្នាក់រង	៣៤

ជំពូកនេះរាប់បញ្ចូលសកម្មភាពសេវាកម្មហិរញ្ញវត្ថុ សកម្មភាពធានារ៉ាប់រង ធានារ៉ាប់រងបន្ត និងមូលនិធិសោធននិវត្តន៍ និងសកម្មភាពគាំទ្រដល់សេវាកម្មហិរញ្ញវត្ថុ។

ជំពូកនេះក៏រាប់បញ្ចូលផងដែរ នូវសកម្មភាពនៃការកាន់កាប់ទ្រព្យសម្បត្តិ ដូចជា ៖ សកម្មភាពរបស់ក្រុមហ៊ុនភាគហ៊ុន និងសកម្មភាពរបស់មូលនិធិវិនិយោគ មូលនិធិ និងស្ថាប័នហិរញ្ញវត្ថុប្រហាក់ប្រហែល។

ផ្នែក ៦៤ ៖ សកម្មភាពសេវាកម្មហិរញ្ញវត្ថុ លើកលែងតែការធានារ៉ាប់រងនិងមូលនិធិសោធននិវត្តន៍

ផ្នែកនេះរាប់បញ្ចូលសកម្មភាពនៃការទទួលបាន និងការបែងចែកបន្តនូវមូលនិធិ ក្នុងគោលបំណង ដែលមិនមែនសម្រាប់ការធានារ៉ាប់រង ឬមូលនិធិសោធននិវត្តន៍ ឬកាតព្វកិច្ចផ្នែកសន្តិសុខសង្គម។

ក្រុម ៦៤១ ៖ អន្តរការីកម្មរូបិយវត្ថុ

ក្រុមនេះរាប់បញ្ចូលការទទួលបានមូលនិធិ ក្នុងទម្រង់ជាប្រាក់បញ្ញើ ដែលអាចផ្ទេរបាន ដូចជា ៖ មូលនិធិដែលបានកំណត់តាមលក្ខខណ្ឌជារូបិយវត្ថុ និងទទួលបានលើមូលដ្ឋានប្រចាំ ថ្ងៃពីប្រភពមិនមែនហិរញ្ញវត្ថុ ដែលមិនមែនជាប្រតិបត្តិការរបស់ធនាគារកណ្តាល។

ក្រុម ៦៤២ ៖ សកម្មភាពរបស់ក្រុមហ៊ុនហូលឌីង

ក្រុមនេះរាប់បញ្ចូលសកម្មភាពរបស់ក្រុមហ៊ុនហូលឌីង។ ក្នុងន័យនេះ អង្គភាពដែលគ្រប់គ្រងទ្រព្យសម្បត្តិ (មានសិទ្ធិគ្រប់គ្រងដើមទុន) របស់ក្រុមសម្ព័ន្ធសាជីវកម្ម ហើយសកម្មភាពចម្បងរបស់អង្គភាពគឺធ្វើជាម្ចាស់ក្រុមហ៊ុន។ ក្រុមហ៊ុនហូលឌីងនៅក្នុងក្រុមសម្ព័ន្ធនេះ មិនផ្តល់សេវាកម្មផ្សេងទៀត ទៅដល់អាជីវកម្មដែលពួកគេគ្រប់គ្រងដើមទុននោះទេ។ ក្នុងន័យនេះ ពួកគេមិនអភិបាល ឬគ្រប់គ្រងអង្គភាពណានីមួយរបស់អាជីវកម្មនោះទេ។

ក្រុម ៦៤៣ ៖ មូលនិធិវិនិយោគ មូលនិធិ និងស្ថាប័នហិរញ្ញវត្ថុប្រហាក់ប្រហែល

ក្រុមនេះរាប់បញ្ចូលនីតិបុគ្គល បង្កើតឡើងដើម្បីប្រមូលមូលបត្រ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗក្នុងនាមភាគទុនិក ឬអត្ថគាហក ដោយមិនផ្តល់ការគ្រប់គ្រងឡើយ។ ផលបត្រត្រូវបានតម្រូវ ទៅតាមតម្រូវការរបស់អតិថិជន ដើម្បីសម្រេចបានគោលបំណងវិនិយោគជាក់លាក់ ដូចជា ពិពិធកម្មហានិភ័យ អត្រាចំណេញ និងភាពប្រែប្រួលនៃតម្លៃ។ ស្ថាប័នទាំងនេះទទួលបានចំណូលតាមរយៈការប្រាក់ ភាគលាភ និងចំណូលពីទ្រព្យសម្បត្តិផ្សេងៗ ប៉ុន្តែស្ថាប័នទាំងនេះមិនមានការងារ និងចំណូលឬមានតិចតួចពីការផ្តល់សេវាកម្ម។

ក្រុម ៦៤៩ ៖ សកម្មភាពសេវាកម្មហិរញ្ញវត្ថុផ្សេងទៀត លើកលែងតែសកម្មភាពធានារ៉ាប់រងនិងមូលនិធិសោធននិវត្តន៍

ក្រុមនេះរាប់បញ្ចូលសកម្មភាពសេវាកម្មហិរញ្ញវត្ថុ លើកលែងតែសកម្មភាពសេវាកម្ម ដែលត្រូវបានផ្តល់ដោយស្ថាប័នរូបិយវត្ថុ។

ជំពូក ដ ៖ សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង
ផ្នែក ៦៤ ៖ សកម្មភាពសេវាកម្មហិរញ្ញវត្ថុ លើកលែងតែការធានារ៉ាប់រងនិងមូលនិធិសោធននិវត្តន៍

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៦៤១			**អន្តរការិយកម្មរូបិយវត្ថុ**
	៦៤១១		ធនាគារកណ្តាល
		៦៤១១០	ធនាគារកណ្តាល
	៦៤១៩		អន្តរការិយកម្មរូបិយវត្ថុផ្សេងទៀត
		៦៤១៩១	ធនាគារពាណិជ្ជ
		៦៤១៩២	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ
៦៤២			**សកម្មភាពរបស់ក្រុមហ៊ុនហូលឌិង**
	៦៤២០[(១)]		សកម្មភាពរបស់ក្រុមហ៊ុនហូលឌិង
		៦៤២០០	សកម្មភាពរបស់ក្រុមហ៊ុនហូលឌិង
៦៤៣			**មូលនិធិវិនិយោគ មូលនិធិ និងស្ថាប័នហិរញ្ញវត្ថុប្រហាក់ប្រហែល**
	៦៤៣០		មូលនិធិវិនិយោគ មូលនិធិ និងស្ថាប័នហិរញ្ញវត្ថុប្រហាក់ប្រហែល
		៦៤៣០០[(២)]	មូលនិធិវិនិយោគ មូលនិធិ និងស្ថាប័នហិរញ្ញវត្ថុប្រហាក់ប្រហែល
៦៤៩			**សកម្មភាពសេវាកម្មហិរញ្ញវត្ថុផ្សេងទៀត លើកលែងតែសកម្មភាពធានារ៉ាប់រង និងមូលនិធិសោធននិវត្តន៍**
	៦៤៩១[(៣)]		ភតិសន្យាហិរញ្ញវត្ថុ
		៦៤៩១០	សកម្មភាពភតិសន្យាហិរញ្ញវត្ថុ

(១) **មិនរាប់បញ្ចូល** ការគ្រប់គ្រងក្រុមហ៊ុននិងសហគ្រាសយ៉ាងសកម្ម ការធ្វើផែនការយុទ្ធសាស្ត្រ និងការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមហ៊ុន (មើល ៧០១០ និង ៧០២០)។

(២) **រាប់បញ្ចូល** ក្រុមហ៊ុនផ្តល់ទុនវិនិយោគ ធនាគារឧស្សាហកម្ម ក្លឹបវិនិយោគ ក្រុមហ៊ុនទទួលបញ្ញាំ។ល។

មិនរាប់បញ្ចូល
- (ក) មូលនិធិ និងមូលនិធិវិនិយោគដែលរកចំណូលពីការលក់ទំនិញ ឬសេវា
- (ខ) សកម្មភាពរបស់ក្រុមហ៊ុនភាគហ៊ុន (មើល ៦៤២០០)
- (គ) មូលនិធិសោធននិវត្តន៍ (មើល ៦៥៣០០)
- (ឃ) ការគ្រប់គ្រងមូលនិធិ (មើល ៦៦៣០)។

(៣) **មិនរាប់បញ្ចូល** ភតិសន្យាប្រតិបត្តិការ (មើលផ្នែក ៧៧) យោងទៅតាមប្រភេទទំនិញសម្រាប់ភតិសន្យា

រាប់បញ្ចូល ភតិសន្យាដែលលក្ខខណ្ឌគ្របដណ្តប់ស្ទើរតែទាំងស្រុងនៃអាយុកាលរបស់ទ្រព្យសម្បត្តិ ហើយភតិកៈទទួលបាននូវផលប្រយោជន៍ទាំងអស់ និងហ៊ានប្រថុយយកហានិភ័យដែលពាក់ព័ន្ធនឹងកម្មសិទ្ធិនៃទ្រព្យសម្បត្តិនោះ។

ជំពូក ដ ៖ សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង
ផ្នែក ៦៤ ៖ សកម្មភាពសេវាកម្មហិរញ្ញវត្ថុ លើកលែងតែការធានារ៉ាប់រង និងមូលនិធិសោធននិវត្តន៍

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	៦៤៩២[១]		ការផ្តល់ឥណទានផ្សេងទៀត
		៦៤៩២១	ធនាគារឯកទេស[២]
		៦៤៩២២	គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ[៣]
		៦៤៩២៣	គ្រឹះស្ថានឥណទានជនបទ
		៦៤៩២៤	ក្រុមហ៊ុន ឬហាងទទួលបញ្ចាំ[៤]
		៦៤៩២៥	អ្នកចងការប្រាក់
		៦៤៩២៩	ភ្នាក់ងារផ្តល់ឥណទានផ្សេងទៀត ដែលពុំបានរាប់បញ្ចូល
	៦៤៩៩[៣]		សកម្មភាពសេវាកម្មហិរញ្ញវត្ថុផ្សេងទៀតលើកលែងតែសកម្មភាពធានារ៉ាប់រង និងមូលនិធិសោធននិវត្តន៍ ដែលពុំបានរាប់បញ្ចូល
		៦៤៩៩១	ក្រុមហ៊ុនមូលធនឯកជន រាប់បញ្ចូលទាំងក្រុមហ៊ុនផ្តល់ទុនវិនិយោគ
		៦៤៩៩២	ការិយាល័យតំណាងរបស់ធនាគារបរទេស
		៦៤៩៩៩	សកម្មភាពសេវាកម្មហិរញ្ញវត្ថុផ្សេងទៀត លើកលែងតែសកម្មភាពធានារ៉ាប់រង និងមូលនិធិសោធននិវត្តន៍ ដែលពុំបានរាប់បញ្ចូល

(១) **មិនរាប់បញ្ចូល** ភតិសន្យាខាងប្រតិបត្តិការ (មើលផ្នែក ៧៧) យោងទៅតាមប្រភេទទំនិញសម្រាប់ភតិសន្យា។

(២) **រាប់បញ្ចូល** **សហព័ន្ធឥណទាន**

(៣) មិនទទួលប្រាក់បញ្ញើ។

(៤) អាជីវកម្មទទួលបញ្ចាំ ទិញ និងលក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។

(៥) **មិនរាប់បញ្ចូល** (ក) ភតិសន្យាហិរញ្ញវត្ថុ (មើល ៦៤៩១០)
(ខ) ការជួញដូរមូលបត្រក្នុងនាមអ្នកដទៃ (មើល ៦៦១២១)
(គ) ពាណិជ្ជកម្ម ភតិសន្យា និងការជួលអចលនទ្រព្យ (មើលផ្នែក ៦៨)
(ឃ) ការប្រមូលបំណុលដោយមិនមែនទិញបំណុល (មើល ៨២៩១០)។

ផ្នែក ៦៥ ៖ ការធានារ៉ាប់រង ការធានារ៉ាប់រងបន្ត និងមូលនិធិសោធននិវត្តន៍ លើកលែងតែកាតព្វកិច្ចផ្នែកសន្តិសុខសង្គម

ផ្នែកនេះរាប់បញ្ចូល ការធានាទិញធនលាភប្រចាំគ្រា និងបណ្ណសន្យារ៉ាប់រង និងការវិនិយោគបុព្វលាភធានារ៉ាប់រង ដើម្បីបង្កើតផលបត្រទ្រព្យសកម្មហិរញ្ញវត្ថុ ដែលនឹងប្រើប្រាស់ដើម្បីទាមទារសំណងមកវិញនាពេលអនាគត។ ការផ្តល់សេវាកម្មធានារ៉ាប់រង និងធានារ៉ាប់រងបន្តដោយផ្ទាល់ ត្រូវបានរាប់បញ្ចូលនៅក្នុងផ្នែកនេះ។

ក្រុម ៦៥១ ៖ ការធានារ៉ាប់រង

ក្រុមនេះរាប់បញ្ចូលការធានារ៉ាប់រងអាយុជីវិត និងការធានារ៉ាប់រងបន្តអាយុជីវិតដោយមានឬគ្មានការសន្សំច្រើនសន្ទឹកសន្ធាប់ និងការធានារ៉ាប់រងទូទៅ។

ក្រុម ៦៥២ ៖ ការធានារ៉ាប់រងបន្ត

ក្រុមនេះរាប់បញ្ចូលសកម្មភាពនៃការចាប់យកហានិភ័យទាំងស្រុង ឬមួយផ្នែកនៃគោលនយោបាយធានារ៉ាប់រងដែលមានស្រាប់ ដែលត្រូវបានធានាដើមដំបូងដោយភ្នាក់ងារធានារ៉ាប់រងផ្សេងទៀត។

ក្រុម ៦៥៣ ៖ មូលនិធិសោធននិវត្តន៍

ក្រុមនេះរាប់បញ្ចូលនីតិបុគ្គល (ឧ. មូលនិធិ ផែនការ និង/ឬកម្មវិធី) ដែលបង្កើតឡើងដើម្បីផ្តល់នូវអត្ថប្រយោជន៍ប្រាក់ចំណូលពេលចូលនិវត្តន៍ ដល់និយោជិត ឬសមាជិករបស់អ្នកឧបត្ថម្ភមូលនិធិសោធននិវត្តន៍។ ក្រុមនេះរាប់បញ្ចូលផែនការសោធននិវត្តន៍ ដែលមានការកំណត់អត្ថប្រយោជន៍ជាក់លាក់ ព្រមទាំងផែនការសោធននិវត្តន៍ ដោយឡែកដែលអត្ថប្រយោជន៍ត្រូវបានកំណត់ តាមរយៈវិភាគទានរបស់សមាជិកម្នាក់ៗ។

ជំពូក ជ ៖ សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង
ផ្នែក ៦៥ ៖ ការធានារ៉ាប់រង ការធានារ៉ាប់រងបន្ត និងមូលនិធិសោធននិវត្តន៍ លើកលែងតែកាតព្វកិច្ចផ្នែកសន្តិសុខសង្គម

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៦៥១[(១)]			**ការធានារ៉ាប់រង**
	៦៥១១		ការធានារ៉ាប់រងអាយុជីវិត
		៦៥១១០	ការធានារ៉ាប់រងអាយុជីវិត
	៦៥១២		ការធានារ៉ាប់រងទូទៅ
		៦៥១២០	ការធានារ៉ាប់រងទូទៅ
៦៥២			**ការធានារ៉ាប់រងបន្ត**
	៦៥២០		ការធានារ៉ាប់រងបន្ត
		៦៥២០១	ការធានារ៉ាប់រងបន្តទូទៅ
		៦៥២០២	ការធានារ៉ាប់រងបន្តអាយុជីវិត
៦៥៣			**មូលនិធិសោធននិវត្តន៍**
	៦៥៣០[(២)]		មូលនិធិសោធននិវត្តន៍
		៦៥៣០០	មូលនិធិសោធននិវត្តន៍

(១) **រាប់បញ្ចូល** ធានារ៉ាប់រងខ្នាតតូច។

(២) **រាប់បញ្ចូល**
(ក) ផែនការអត្ថប្រយោជន៍និយោជិត
(ខ) ផែនការនិងមូលនិធិសោធននិវត្តន៍
(គ) ផែនការចូលនិវត្តន៍
(ឃ) សន្តិសុខសង្គមដែលមិនមែនជាកាតព្វកិច្ច

មិនរាប់បញ្ចូល
(ក) ការគ្រប់គ្រងមូលនិធិសោធននិវត្តន៍ (មើល ៦៦៣០)
(ខ) គម្រោងកាតព្វកិច្ចផ្នែកសន្តិសុខសង្គម (មើល ៨៤៣០)។

ផ្នែក ៦៦ ៖ សកម្មភាពគាំទ្រដល់សកម្មភាពសេវាកម្មហិរញ្ញវត្ថុ និងធានារ៉ាប់រង

ផ្នែកនេះរាប់បញ្ចូលការផ្តល់សេវាកម្មដែលពាក់ព័ន្ធ ឬទាក់ទងយ៉ាងជិតស្និទ្ធ ទៅនឹងសកម្មភាពសេវាកម្មហិរញ្ញវត្ថុ ប៉ុន្តែសេវាកម្មទាំងនេះ មិនមែនជាសេវាកម្មហិរញ្ញវត្ថុនោះទេ។ បំណែងចែកចម្បងនៃផ្នែកនេះ គឺផ្អែកតាមប្រភេទនៃប្រតិបត្តិការហិរញ្ញវត្ថុ ឬមូលនិធិគាំទ្រ។

ក្រុម ៦៦១ ៖ សកម្មភាពគាំទ្រដល់សកម្មភាពសេវាកម្មហិរញ្ញវត្ថុ លើកលែងតែការធានារ៉ាប់រង និងមូលនិធិសោធននិវត្តន៍

ក្រុមនេះរាប់បញ្ចូលការផ្តល់ទីផ្សាររូបវន្ត ឬទីផ្សារអេឡិចត្រូនិកក្នុងគោលបំណងសម្រួលដល់ការទិញនិងលក់នូវះភាគហ៊ុន អុបហ្សិន(សិទ្ធិទិញឬលក់ភាគហ៊ុននៅក្នុងរយៈពេលណាមួយតាមតម្លៃកំណត់)សញ្ញាប័ណ្ណ ឬកិច្ចសន្យាវត្ថុជាតុដើម។

ក្រុម ៦៦២ ៖ សកម្មភាពគាំទ្រដល់សេវាកម្មធានារ៉ាប់រង និងមូលនិធិសោធននិវត្តន៍

ក្រុមនេះរាប់បញ្ចូលការដើរតួនាទីជាភ្នាក់ងារ (ឧ. ឈ្មួញកណ្តាល) នៅក្នុងការលក់ ធនលាភប្រចាំគ្រា និងបណ្ណសន្យារ៉ាប់រង, ឬការផ្តល់សេវាកម្មអត្ថប្រយោជន៍ សម្រាប់និយោជិតនិងការធានារ៉ាប់រងផ្សេងទៀត និងសេវាកម្មពាក់ព័ន្ធនឹងសោធននិវត្តន៍ដូចជា ៖ សកម្មភាពវាយតម្លៃលើការទាមទារសំណងធានារ៉ាប់រង និងសកម្មភាពដំណើរ ការរដ្ឋបាលលើការទាមទារសំណងធានារ៉ាប់រងដោយភាគីទីបី។

ក្រុម ៦៦៣ ៖ សកម្មភាពគ្រប់គ្រងមូលនិធិ

ក្រុមនេះរាប់បញ្ចូលសកម្មភាពគ្រប់គ្រងផលបត្រ និងមូលនិធិ ដោយផ្អែកលើកម្រៃ ឬកិច្ចសន្យា សម្រាប់បុគ្គល ក្រុមហ៊ុន ឬស្ថាប័នផ្សេងៗ។

ជំពូក ដ ៖ សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង
ផ្នែក ៦៦ ៖ សកម្មភាពគាំទ្រដល់សកម្មភាពសេវាកម្មហិរញ្ញវត្ថុ និងធានារ៉ាប់រង

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្ដីអធិប្បាយ
៦៦១			**សកម្មភាពគាំទ្រដល់សកម្មភាពសេវាកម្មហិរញ្ញវត្ថុ លើកលែងតែការធានារ៉ាប់រង និងមូលនិធិសោធននិវត្តន៍**
	៦៦១១[១]		រដ្ឋបាលទីផ្សារហិរញ្ញវត្ថុ
		៦៦១១១	ផ្សារមូលបត្រ
		៦៦១១២	ផ្សារជួញដូរផលិតផល
	៦៦១២[២]		អន្តរការិយកម្មនៃកិច្ចសន្យាមូលបត្រនិងវត្ថុធាតុដើម
		៦៦១២១	ពាណិជ្ជករ(ឈ្មួញជើងសារ) និងអ្នកធានាទិញមូលបត្រ[៣]
		៦៦១២២	កិច្ចសន្យាជួញដូរផលិតផល ឬការងារជើងសារជួញដូរផលិតផល
		៦៦១២៣	សេវាកម្មប្តូរប្រាក់[៤]
	៦៦១៩[៥]		សកម្មភាពផ្សេងទៀតដែលគាំទ្រដល់សកម្មភាពសេវាកម្មហិរញ្ញវត្ថុ
		៦៦១៩១	ពាណិជ្ជករ និងអន្តរការីលោហធាតុមាស
		៦៦១៩២	អ្នកដំណើរការតតិយភាគី[៦]
		៦៦១៩៣	គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់
		៦៦១៩៩	សកម្មភាពផ្សេងទៀតដែលគាំទ្រដល់សកម្មភាពសេវាកម្មហិរញ្ញវត្ថុ

(១) **រាប់បញ្ចូល** (ក) ផ្សារភាគហ៊ុន និងផ្សារមូលបត្រ
(ខ) ផ្សារវត្ថុធាតុដើមតាមកិច្ចសន្យាអនាគត។

(២) **រាប់បញ្ចូល** **ឈ្មួញជើងសារ** និងពាណិជ្ជករភាគហ៊ុន សញ្ញាប័ណ្ណ និងផលិតផល
មិនរាប់បញ្ចូល
(ក) ប្រតិបត្តិការផ្ទាល់ខ្លួននៅក្នុងទីផ្សារហិរញ្ញវត្ថុ (មើល ៦៤៩៩)
(ខ) ការគ្រប់គ្រងផលបត្រ ដោយផ្អែកលើកម្រៃ ឬកិច្ចសន្យា (មើល ៦៦៣០)។

(៣) **រាប់បញ្ចូល** ជំនួញមូលបត្រ ដែលអាចបញ្ចូលជាមួយនឹងមុខងារទីប្រឹក្សាវិនិយោគ។

(៤) **រាប់បញ្ចូល** ប្រតិបត្តិកររាយនៅក្នុងទីផ្សារប្តូរប្រាក់

(៥) រាប់បញ្ចូល (ក) សេវាកម្មប្រឹក្សាវិនិយោគឯករាជ្យ
(ខ) សេវាកម្មពិគ្រោះយោបល់ហិរញ្ញវត្ថុឯករាជ្យ
មិនរាប់បញ្ចូល (ក) សកម្មភាពរបស់ភ្នាក់ងារធានារ៉ាប់រង ឬឈ្មួញជើងសារ ធានារ៉ាប់រង(មើល ៦៦២២)
(ខ) ការគ្រប់គ្រងមូលនិធិ (មើល ៦៦៣០)។

(៦) **រាប់បញ្ចូល** វេស្ទើនយូញៀន (Western Union) និង ម៉ាន់នីក្រាម (MoneyGram)

ជំពូក ជ ៖ សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង
ផ្នែក ៦៦ ៖ សកម្មភាពគាំទ្រដល់សកម្មភាពសេវាកម្មហិរញ្ញវត្ថុ និងធានារ៉ាប់រង

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៦៦២			**សកម្មភាពគាំទ្រដល់សេវាកម្មធានារ៉ាប់រង និងមូលនិធិសោធននិវត្តន៍**
	៦៦២១[១]		ការវាយតម្លៃហានិភ័យ និងការខូចខាត
		៦៦២១០	ការស៊ើបអង្កេតការខាតបង់ផ្នែកធានារ៉ាប់រង
	៦៦២២		សកម្មភាពរបស់ភ្នាក់ងារ និងអន្តរការីធានារ៉ាប់រង
		៦៦២២១	សកម្មភាពរបស់ភ្នាក់ងារធានារ៉ាប់រង
		៦៦២២២	សកម្មភាពរបស់អន្តរការីធានារ៉ាប់រង
	៦៦២៩[២]		សកម្មភាពផ្សេងទៀតគាំទ្រដល់សេវាកម្មធានារ៉ាប់រង និងមូលនិធិសោធននិវត្តន៍
		៦៦២៩០	សកម្មភាពផ្សេងទៀតគាំទ្រដល់សេវាកម្មធានារ៉ាប់រង និងមូលនិធិសោធននិវត្តន៍
៦៦៣			**សកម្មភាពគ្រប់គ្រងមូលនិធិ**
	៦៦៣០		សកម្មភាពគ្រប់គ្រងមូលនិធិ
		៦៦៣០០	សកម្មភាពគ្រប់គ្រងមូលនិធិ[៣]

(១) **មិនរាប់បញ្ចូល** (ក) ការវាយតម្លៃអចលនទ្រព្យ (មើល ៦៨២០៣)
(ខ) ការវាយតម្លៃសម្រាប់គោលបំណងផ្សេងទៀត (មើល ៧៤៩០)
(គ) សកម្មភាពស៊ើបអង្កេត (មើល ៨០៣០)។

(២) **រាប់បញ្ចូល** សកម្មភាពដែលជាប់ពាក់ព័ន្ធ ឬមានទំនាក់ទំនងជិតស្និទ្ធទៅនឹងការធានារ៉ាប់រង និងមូលនិធិសោធននិវត្តន៍ (លើកលែងតែសកម្មភាពស៊ើបអង្កេតលើការទាមទារផលប្រយោជន៍ធានារ៉ាប់រង និងសកម្មភាពរបស់ភ្នាក់ងារធានារ៉ាប់រង) ដូចជា ការគ្រប់គ្រងទ្រព្យសំណល់ និងសេវាកម្មវាយតម្លៃនិងធ្វើផែនការទប់ស្កាត់ចំពោះឥទ្ធិពលហានិភ័យលើស្ថានភាពហិរញ្ញវត្ថុអនាគត។ល។

មិនរាប់បញ្ចូល សកម្មភាពការគ្រប់គ្រងការជួយសង្គ្រោះពាណិជ្ជកម្មតាមសមុទ្រ (មើល ៥២២២)។

(៣) **រាប់បញ្ចូល** ការគ្រប់គ្រងការវិនិយោគរបស់មូលនិធិសោធននិវត្តន៍។

ជំពូក ឋ ៖ សកម្មភាពអចលនទ្រព្យ

កម្រិត	ច.ស.វ.ក
ជំពូក	១
ផ្នែក	១
ក្រុម	២
ថ្នាក់	២
ថ្នាក់រង	៦

ជំពូកនេះរាប់បញ្ចូលអ្នកជួល ភ្នាក់ងារ ឬឈ្មួញកណ្តាល ចំពោះសកម្មភាពមួយ ឬច្រើន ក្នុងចំណោមបណ្តាសកម្មភាពជាច្រើនដូចជា ៖ ការលក់ ឬទិញអចលនទ្រព្យ ការជួលអចលនទ្រព្យ ការផ្តល់នូវសេវាកម្មអចលនទ្រព្យផ្សេងទៀតដូចជា ការវាយតម្លៃអចលនទ្រព្យ ឬការដើរតួជាភ្នាក់ងារអចលនទ្រព្យភាគីទីបី។ សកម្មភាពទាំងឡាយនៅក្នុងជំពូកនេះអាចត្រូវបានអនុវត្តចំពោះអចលនទ្រព្យផ្ទាល់ខ្លួន ឬអចលនទ្រព្យជួលពីគេ ហើយអាចអនុវត្តដោយផ្អែកលើការយកថ្លៃឈ្នួលជាក់ស្តែង ឬតាមកិច្ចសន្យា។ ជំពូកនេះក៏រាប់បញ្ចូលផងដែរនូវការសាងសង់អគារសម្រាប់ធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ឬសម្រាប់ធ្វើភតិសន្យា។

ជំពូកនេះក៏រាប់បញ្ចូលអ្នកគ្រប់គ្រងអចលនទ្រព្យផងដែរ។

ផ្នែក ៦៨ ៖ សកម្មភាពអចលនទ្រព្យ

ផ្នែកនេះរាប់បញ្ចូលសកម្មភាពអចលនទ្រព្យដោយប្រើអចលនទ្រព្យផ្ទាល់ខ្លួន ឬជួលពីគេ និងសកម្មភាពអចលនទ្រព្យអនុវត្តដោយផ្អែកលើការយកថ្លៃឈ្នួលជាក់ស្តែង ឬតាមកិច្ចសន្យា។

ក្រុម ៦៨១ ៖ សកម្មភាពអចលនទ្រព្យ ដោយប្រើអចលនទ្រព្យផ្ទាល់ខ្លួនឬជួលពីគេ

ក្រុមនេះរាប់បញ្ចូលនូវ ការទិញ ការលក់ ការជួល និងការធ្វើអាជីវកម្មអចលនទ្រព្យផ្ទាល់ខ្លួន ឬជួលពីគេ ការផ្តល់គេហដ្ឋាន ផ្ទះល្វែងដែលបាន ឬមិនបានបំពាក់គ្រឿងសង្ហារិម ឬអាប៉ាតឺម៉ង់ សម្រាប់ការស្នាក់នៅបែបអចិន្ត្រៃយ៍ដូចជា ប្រចាំខែ ឬប្រចាំឆ្នាំ ការអភិវឌ្ឍគម្រោងសាងសង់អគារសម្រាប់អាជីវកម្មផ្ទាល់ខ្លួន (ឧ. សម្រាប់ដាក់ជួលផ្ទៃទំនេរនៅក្នុងអគារ) ការបែងចែកអចលនទ្រព្យទៅជាឡូត៍ ដោយគ្មានកែលម្អដីធ្លី និងប្រតិបត្តិការលំនៅដ្ឋានស្នាក់នៅចល័ត។

ក្រុម ៦៨២ ៖ សកម្មភាពអចលនទ្រព្យ ដោយយកថ្លៃឈ្នួលជាក់ស្តែងឬតាមកិច្ចសន្យា

ក្រុមនេះរាប់បញ្ចូល ការផ្តល់សកម្មភាពសេវាកម្មអចលនទ្រព្យ ដោយផ្អែកលើការយកថ្លៃឈ្នួលជាក់ស្តែង ឬតាមកិច្ចសន្យា និងសេវាកម្មដែលពាក់ព័ន្ធផ្សេងទៀត។

ជំពូក ឋ ៖ សកម្មភាពអចលនទ្រព្យ
ផ្នែក ៦៨ ៖ សកម្មភាពអចលនទ្រព្យ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៦៨១			**សកម្មភាពអចលនទ្រព្យ ដោយប្រើអចលនទ្រព្យផ្ទាល់ខ្លួន ឬជួលពីគេ**
	៦៨១០[១]		សកម្មភាពអចលនទ្រព្យ ដោយប្រើអចលនទ្រព្យផ្ទាល់ខ្លួន ឬជួលពីគេ
		៦៨១០១[២]	ការទិញ ការលក់ ការជួល និងការធ្វើអាជីវកម្មអចលនទ្រព្យផ្ទាល់ខ្លួន ឬជួលពីគេ
		៦៨១០២	ការអភិវឌ្ឍគម្រោងសាងសង់អគារ សម្រាប់អាជីវកម្មផ្ទាល់ខ្លួន (ឧ. សម្រាប់ការដាក់ជួលផ្ទៃទំនេរនៅក្នុងអគារ[៣])
៦៨២			**សកម្មភាពអចលនទ្រព្យ ដោយយកថ្លៃឈ្នួលជាក់ស្តែង ឬតាមកិច្ចសន្យា**
	៦៨២០[៤]		សកម្មភាពអចលនទ្រព្យ ដោយយកថ្លៃឈ្នួលជាក់ស្តែង ឬតាមកិច្ចសន្យា
		៦៨២០១	សកម្មភាពរបស់ភ្នាក់ងារ ឬអន្តរការីអចលនទ្រព្យ[៥]
		៦៨២០២	ការគ្រប់គ្រងអចលនទ្រព្យ ដោយយកថ្លៃឈ្នួលជាក់ស្តែង ឬតាមកិច្ចសន្យា
		៦៨២០៣	សេវាកម្មវាយតម្លៃអចលនទ្រព្យ[៦]
		៦៨២០៩	សកម្មភាពអចលនទ្រព្យ ដោយយកថ្លៃឈ្នួលជាក់ស្តែង ឬតាមកិច្ចសន្យាដទៃទៀត ដែលពុំបានរាប់បញ្ចូល[៧]

(១) **មិនរាប់បញ្ចូល** (ក) ការអភិវឌ្ឍគម្រោងសាងសង់អគារសម្រាប់លក់ (មើល ៤១០០)
(ខ) ការពុះចែក និងកែលម្អដីឡូត៍ (មើល ៤២៩០)
(គ) ការដំណើរការសណ្ឋាគារ សណ្ឋាគារលំដាប់ខ្ពស់ និងកន្លែងស្នាក់នៅស្រដៀងនេះ (មើល ៥៥១០១)
(ឃ) ការដំណើរការកន្លែងបោះជំរំ ចំណតរថយន្តសណ្តោង និងកន្លែងស្នាក់នៅស្រដៀងនេះ (មើល ៥៥២០០)
(ង) ការដំណើរការផ្ទះស្នាក់នៅកម្មករ ផ្ទះមានបន្ទប់ជួលស្នាក់នៅ និងកន្លែងស្នាក់នៅស្រដៀងនេះ (មើល ៥៥៩០៩)។

(២) **រាប់បញ្ចូល** ការផ្តល់កន្លែងសម្រាប់គ្រាន់តែជាជម្រកបណ្តោះអាសន្នរបស់សត្វតែប៉ុណ្ណោះ។

(៣) **រាប់បញ្ចូល** (ក) ការបែងចែកអចលនទ្រព្យទៅជាឡូត៍ដោយគ្មានកែលម្អដីធ្លី
(ខ) ការដំណើរការលំនៅដ្ឋានស្នាក់នៅចល័ត។

(៤) **មិនរាប់បញ្ចូល** (ក) សកម្មភាពផ្នែកច្បាប់ (មើល ៦៩១០០)
(ខ) សេវាកម្មគាំទ្របរិក្ខារ (មើល ៨១១០០)
(គ) ការគ្រប់គ្រងបរិក្ខារ ដូចជានៅក្នុងមូលដ្ឋានយោធា ពន្ធនាគារ និងការគ្រប់គ្រងបរិក្ខារឯទៀត (លើកលែងតែការគ្រប់គ្រងបរិក្ខារកុំព្យូទ័រ) (មើល ៨១១០០)។

(៥) **រាប់បញ្ចូល** អន្តរការីនៅក្នុងការទិញ ការលក់ និងការជួលអចលនទ្រព្យ ដោយផ្អែកលើការយកថ្លៃឈ្នួលជាក់ស្តែង ឬតាមកិច្ចសន្យា។

(៦) **រាប់បញ្ចូល** ភ្នាក់ងារអចលនទ្រព្យភាគីទីបី។

(៧) **រាប់បញ្ចូល** ការដំណើរការអគារដែលបានកាន់កាប់។

ជំពូក ឌ ៖ សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស

កម្រិត	ច.ស.វ.ក
ជំពូក	១
ផ្នែក	៧
ក្រុម	១៤
ថ្នាក់	១៤
ថ្នាក់រង	១៥

ជំពូកនេះរាប់បញ្ចូលសកម្មភាពវិជ្ជាជីវៈឯកទេស វិទ្យាសាស្ត្រ និងបច្ចេកទេស។ សកម្មភាពទាំងនេះទាមទារឲ្យមានការបណ្តុះបណ្តាលកម្រិតខ្ពស់ និងការផ្តល់ចំណេះដឹង និងជំនាញឯកទេសទៅដល់អ្នកប្រើប្រាស់។

ជំពូកនេះរាប់បញ្ចូលសកម្មភាពវិជ្ជាជីវៈច្បាប់ និងគណនេយ្យ សកម្មភាពរបស់ការិយាល័យកណ្តាល សកម្មភាពពិគ្រោះយោបល់ផ្នែកគ្រប់គ្រង សកម្មភាពស្ថាបត្យកម្ម និងវិស្វកម្ម ការពិសោធនិងវិភាគបច្ចេកទេស ការស្រាវជ្រាវនិងអភិវឌ្ឍន៍វិទ្យាសាស្ត្រ ការផ្សាយពាណិជ្ជកម្មនិងការស្រាវជ្រាវទីផ្សារ សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេសផ្សេងទៀត និងសកម្មភាពបសុព្យាបាល។

ផ្នែក ៦៩ ៖ សកម្មភាពវិជ្ជាជីវៈច្បាប់ គណនេយ្យ និងសវនកម្ម

ផ្នែកនេះរាប់បញ្ចូលសកម្មភាពតំណាងផ្នែកច្បាប់ ដើម្បីការពារផលប្រយោជន៍ឲ្យភាគីមួយទល់នឹងភាគីមួយទៀតនៅនៅក្រៅប្រព័ន្ធតុលាការ ឬស្ថាប័នយុត្តិធម៌ផ្សេងទៀត ដែលអនុវត្ត ឬក្រោមការគ្រប់គ្រងពីបុគ្គលដែលជាសមាជិករបស់គណៈមេធាវីដូចជា៖ ការផ្តល់យោបល់ និងការធ្វើជាតំណាងនៅក្នុងរឿងក្តីរដ្ឋប្បវេណី រឿងព្រហ្មទណ្ឌ និងករណីវិវាទការងារ។ ផ្នែកនេះក៏រាប់បញ្ចូលផងដែរនូវការរៀបចំឯកសារផ្លូវច្បាប់ ដូចជា ៖លក្ខន្តិកៈក្រុមហ៊ុន កិច្ចព្រមព្រៀងដៃគូពាណិជ្ជកម្ម ឬឯកសារស្រដៀងគ្នានេះ ដែលទាក់ទងទៅនឹងការបង្កើតក្រុមហ៊ុន ប្រកាសនីយបត្រតក្កកម្ម(ប៉ាតង់)និងសិទ្ធិអ្នកនិពន្ធ ការរៀបចំលិខិតផ្ទេរសិទ្ធិ មរតកសាសន៍។ល។ ក៏ដូចជាសកម្មភាពផ្សេងទៀតរបស់សារការី អាជ្ញាសាលា មជ្ឈត្តករ អ្នកត្រួតពិនិត្យ និងអាជ្ញាកណ្តាល។ ផ្នែកនេះក៏រាប់បញ្ចូលសេវាកម្មគណនេយ្យ សេវាកម្មសវនកម្ម និងសេវាប្រហាក់ប្រហែលផ្សេងទៀត រួមទាំងសេវាជម្រះបញ្ជីក្រុមហ៊ុន។

ក្រុម ៦៩១ ៖ សកម្មភាពវិជ្ជាជីវៈច្បាប់

ក្រុមនេះរាប់បញ្ចូលសកម្មភាពតំណាងផ្នែកច្បាប់ ដើម្បីការពារផលប្រយោជន៍ឲ្យភាគីមួយទល់នឹងភាគីមួយទៀត នៅឬមិននៅចំពោះមុខ តុលាការឬស្ថាប័នយុត្តិធម៌ផ្សេងទៀត ដែលអនុវត្តដោយ ឬក្រោមការគ្រប់គ្រងពីបុគ្គលដែលជាសមាជិករបស់គណៈមេធាវី និងការផ្តល់ប្រឹក្សាទូទៅ និងការពិគ្រោះយោបល់ ការរៀបចំឯកសារផ្លូវច្បាប់ និងសកម្មភាពផ្សេងទៀតរបស់សារការី អាជ្ញាសាលា មជ្ឈត្តករ អ្នកត្រួតពិនិត្យ និងអាជ្ញាកណ្តាល។

ក្រុម ៦៩២ ៖ សកម្មភាពគណនេយ្យ សវនកម្ម និងការពិគ្រោះយោបល់ផ្នែកពន្ធ

សកម្មភាពគណនេយ្យពាក់ព័ន្ធនឹងការកត់ត្រា ការចាត់ថ្នាក់ ការវាស់វែង ការផ្តុំបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុ ការបង្ហាញព័ត៌មានហិរញ្ញវត្ថុ រួមបញ្ចូលទាំងសេវាពិនិត្យគណនេយ្យ ការបញ្ជាក់ សេវារៀបចំរបាយការណ៍ហិរញ្ញវត្ថុគំរូ និងសេវា

ប្រហាក់ប្រហែលផ្សេងទៀតរួមទាំងសេវាជម្រះបញ្ជីក្រុមហ៊ុន។ សកម្មភាពប្រឹក្សាយោបល់ និងតំណាងឲ្យអតិថិជន (ក្រៅពីតំណាងផ្នែកច្បាប់)នៅចំពោះមុខអជ្ញាធរពន្ធដារក៏ត្រូវបានរាប់បញ្ចូលផងដែរ។ សកម្មភាពសវនកម្មពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងវាយតម្លៃដោយឯករាជ្យ និងជាប្រព័ន្ធលើទិន្នន័យរបាយការណ៍ កំណត់ត្រា កិច្ចប្រតិបត្តិការ និងលទ្ធផលជាហិរញ្ញវត្ថុឬមិនមែនហិរញ្ញវត្ថុរបស់អង្គភាព សម្រាប់គោលបំណងជាក់លាក់មួយដោយអនុលោមតាមស្តង់ដារទាក់ទងនឹងសវនកម្ម និងស្តង់ដារពាក់ព័ន្ធជាធរមាន។

ជំពូក ឱ ៖ សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស
ផ្នែក ៦៩ ៖ សកម្មភាពវិជ្ជាជីវៈច្បាប់ និងគណនេយ្យ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៦៩១			**សកម្មភាពវិជ្ជាជីវៈច្បាប់**
	៦៩១០(១)		សកម្មភាពវិជ្ជាជីវៈច្បាប់
		៦៩១០០	សកម្មភាពវិជ្ជាជីវៈច្បាប់
៦៩២			**សកម្មភាពគណនេយ្យ សវនកម្ម និងការពិគ្រោះយោបល់ផ្នែកពន្ធ**
	៦៩២០(២)		សកម្មភាពគណនេយ្យ សវនកម្ម និងការពិគ្រោះយោបល់ផ្នែកពន្ធ
		៦៩២០០	សកម្មភាពគណនេយ្យ សវនកម្ម និងការពិគ្រោះយោបល់ផ្នែកពន្ធ

(១) **រាប់បញ្ចូល** (ក) សកម្មភាពតំណាងផ្នែកច្បាប់ ដើម្បីការពារផលប្រយោជន៍ឲ្យភាគីមួយទល់នឹងភាគីមួយទៀតនៅ ឬនៅក្រៅប្រព័ន្ធតុលាការ ឬស្ថាប័នយុត្តិធម៌ផ្សេងទៀតដែលអនុវត្តដោយ ឬក្រោមការគ្រប់គ្រងពីបុគ្គលដែលជាសមាជិករបស់គណៈមេធាវីដូចជា ៖

- ការផ្តល់យោបល់ និងការធ្វើជាតំណាងនៅក្នុងរឿងរដ្ឋប្បវេណី រឿងព្រហ្មទណ្ឌ ឬវិវាទការងារ

(ខ) ការផ្តល់ប្រឹក្សា និងពិគ្រោះយោបល់ទូទៅ ការរៀបចំឯកសារផ្លូវច្បាប់ ដូចជា ៖

- លក្ខន្តិកៈក្រុមហ៊ុន កិច្ចព្រមព្រៀងដៃគូពាណិជ្ជកម្ម ឬឯកសារប្រហាក់ប្រហែលគ្នានេះដែលទាក់ទងនឹងការបង្កើតក្រុមហ៊ុន
- ប្រកាសនីយបត្រតក្កកម្ម (ប៉ាតង់) និងសិទ្ធិអ្នកនិពន្ធ
- ការរៀបចំលិខិតផ្ទេរសិទ្ធិ លិខិតមរតកសាសន៍។ល។

(គ) សកម្មភាពផ្សេងទៀតរបស់សារការី មជ្ឈត្តករ អ្នកត្រួតពិនិត្យ និងអាជ្ញាកណ្តាល។

មិនរាប់បញ្ចូល សកម្មភាពតុលាការ(មើល ៨៤២៣២)។

(២) **រាប់បញ្ចូល** សកម្មភាពពាក់ព័ន្ធនឹងការកត់ត្រាប្រតិបត្តិការពាណិជ្ជកម្មរបស់អាជីវកម្ម ឬស្ថាប័នផ្សេងទៀត ការរៀបចំ ឬសវនកម្មគណនីហិរញ្ញវត្ថុ ការត្រួតពិនិត្យគណនី និងការបញ្ជាក់ពីភាពត្រឹមត្រូវនៃគណនីទាំងនេះ ការរៀបចំការប្រកាសពន្ធលើចំណូលបុគ្គល និងចំណូលអាជីវកម្ម។ សកម្មភាពប្រឹក្សាយោបល់ និងតំណាងឲ្យអតិថិជន (ក្រៅពី តំណាងផ្នែកច្បាប់) នៅចំពោះមុខអាជ្ញាធរពន្ធដារ ក៏ត្រូវបានរាប់បញ្ចូលផងដែរ។

មិនរាប់បញ្ចូល (ក) សកម្មភាពបំប្លែងទិន្នន័យ និងការរៀបតារាងទិន្នន័យ (មើល ៦៣១១០)

(ខ) ការពិគ្រោះយោបល់ផ្នែកគ្រប់គ្រង ដូចជា ការបង្កើតប្រព័ន្ធគណនេយ្យ កម្មវិធីគណនេយ្យថ្លៃដើម និងនីតិវិធីត្រួតពិនិត្យថវិកា (មើល ៧០២០)

(គ) ការប្រមូលវិក្កយបត្រ (មើល ៨២៩១០)។

ផ្នែក ៧០ ៖ សកម្មភាពរបស់ការិយាល័យកណ្តាល សកម្មភាពពិគ្រោះយោបល់ផ្នែកគ្រប់គ្រង

ផ្នែកនេះរាប់បញ្ចូលការផ្តល់យោបល់និងជំនួយ ដល់អាជីវកម្មនិងអង្គភាពនានា លើបញ្ហាគ្រប់គ្រង ដូចជា ៖ ការធ្វើផែនការយុទ្ធសាស្ត្រ និងការចាត់ចែងអង្គភាព ការធ្វើផែនការហិរញ្ញវត្ថុ និងថវិកា ការកំណត់គោលបំណងនិងគោលនយោបាយទីផ្សារ ការតាក់តែងគោលនយោបាយ ការអនុវត្ត និងការធ្វើផែនការខាងធនធានមនុស្ស ការធ្វើកាលវិភាគផលិតកម្ម និងការធ្វើ

ផែនការត្រួតពិនិត្យ។ ផ្នែកនេះក៏រាប់បញ្ចូលផងដែរនូវ ការមើលការខុសត្រូវ និង ការគ្រប់គ្រងអង្គភាពផ្សេងទៀតរបស់ក្រុមហ៊ុន ឬសហគ្រាសដដែល (៧. សកម្មភាពរបស់ការិយាល័យកណ្តាល)។

ក្រុម ៧០១ ៖ សកម្មភាពរបស់ការិយាល័យកណ្តាល

ក្រុមនេះរាប់បញ្ចូល ការពិនិត្យមើល និងការគ្រប់គ្រងអង្គភាពផ្សេងទៀតរបស់ក្រុមហ៊ុន ឬសហគ្រាសដដែល ការធ្វើផែនការយុទ្ធសាស្ត្រឬការចាត់ចែងអង្គភាព និងការកំណត់តួនាទីធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមហ៊ុន ឬសហគ្រាស ការត្រួតពិនិត្យសកម្មភាពប្រតិបត្តិការ និងការគ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃ របស់អង្គភាពដែលពាក់ព័ន្ធ។

ក្រុម ៧០២ ៖ សកម្មភាពពិគ្រោះយោបល់ផ្នែកគ្រប់គ្រង

ក្រុមនេះរាប់បញ្ចូល ការផ្តល់ប្រឹក្សាយោបល់ ការណែនាំ និងជំនួយផ្នែកប្រតិបត្តិការ ដល់អាជីវកម្ម និងអង្គភាពនានាទៅលើ ៖ បញ្ហាគ្រប់គ្រងដូចជា ការធ្វើផែនការយុទ្ធសាស្ត្រ និងការចាត់ចែងអង្គភាព ការធ្វើសេចក្តីសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ ការកំណត់គោលបំណងនិងគោលនយោបាយទីផ្សារ ការតាក់តែងគោលនយោបាយ ការអនុវត្ត និងការធ្វើផែនការខាងធនធានមនុស្ស ការធ្វើកាលវិភាគផលិតកម្ម និងការធ្វើផែនការត្រួតពិនិត្យ។

ការផ្តល់សេវាកម្មផ្នែកជំនួញនេះអាចរាប់បញ្ចូល ៖ ការផ្តល់ប្រឹក្សាយោបល់ ការណែនាំ និងជំនួយផ្នែកប្រតិបត្តិការដល់ក្រុមហ៊ុនឯកជន និងស្ថាប័នរដ្ឋ ពាក់ព័ន្ធនឹងសកម្មភាពទំនាក់ទំនងសាធារណៈនិងសកម្មភាពប្រាស្រ័យទាក់ទងសកម្មភាពបញ្ចុះបញ្ចូល(ឡបប៊ី) ការបង្កើតវិធីសាស្ត្រ ឬនីតិវិធីគណនេយ្យ ការបង្កើតកម្មវិធីគណនេយ្យថ្លៃដើម នីតិវិធីត្រួតពិនិត្យថវិកា និងការប្រឹក្សាយោបល់និងជំនួយ ដល់ក្រុមហ៊ុនឯកជននិងស្ថាប័នរដ្ឋ អំពីការធ្វើផែនការ ការចាត់ចែង ប្រសិទ្ធភាព និងការត្រួតពិនិត្យ ព័ត៌មានគ្រប់គ្រង។ល។

ជំពូក ឌ ៖ សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស
ផ្នែក ៧០ ៖ សកម្មភាពរបស់ការិយាល័យកណ្តាល សកម្មភាពពិគ្រោះយោបល់ផ្នែកគ្រប់គ្រង

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៧០១			**សកម្មភាពរបស់ការិយាល័យកណ្តាល**
	៧០១០[(១)]		សកម្មភាពរបស់ការិយាល័យកណ្តាល
		៧០១០០	សកម្មភាពរបស់ការិយាល័យកណ្តាល
៧០២			**សកម្មភាពពិគ្រោះយោបល់ផ្នែកគ្រប់គ្រង**
	៧០២០[(២)]		សកម្មភាពពិគ្រោះយោបល់ផ្នែកគ្រប់គ្រង
		៧០២០០	សកម្មភាពពិគ្រោះយោបល់ផ្នែកគ្រប់គ្រង

(១) **រាប់បញ្ចូល** ការមើលការខុសត្រូវ និងការគ្រប់គ្រងអង្គភាពនានារបស់ក្រុមហ៊ុន ឬសហគ្រាស ការត្រួតពិនិត្យប្រតិបត្តិការ និងការគ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃរបស់អង្គភាពដែលពាក់ព័ន្ធ រួមមានការិយាល័យកណ្តាល ការិយាល័យរដ្ឋបាលកណ្តាល ការិយាល័យសាជីវកម្មការិយាល័យស្រុកនិងតំបន់ និងការិយាល័យគ្រប់គ្រងសាខា។

មិនរាប់បញ្ចូល សកម្មភាពរបស់ក្រុមហ៊ុនកាន់កាប់ភាគហ៊ុន ដែលមិនជាប់ទាក់ទងនឹងការគ្រប់គ្រង (មើល ៦៤២០០)។

(២) **មិនរាប់បញ្ចូល**
- (ក) ការបង្កើតកម្មវិធីកំព្យូទ័រសម្រាប់ប្រព័ន្ធគណនេយ្យ (មើល ៦២០១០)
- (ខ) ការប្រឹក្សាយោបល់ និងតំណាងផ្នែកច្បាប់ (មើល ៦៩១០០)
- (គ) សកម្មភាពគណនេយ្យ ការកត់ត្រាគណនេយ្យ និងសវនកម្ម និងការពិគ្រោះយោបល់ផ្នែកពន្ធដារ (មើល ៦៩២០០)
- (ឃ) សកម្មភាពផ្នែកស្ថាបត្យកម្ម វិស្វកម្ម និងការប្រឹក្សាយោបល់បច្ចេកទេសផ្សេងទៀត (មើល ៧១១០១, ៧១១០២, ៧៤៩០០)
- (ង) សកម្មភាពផ្សាយពាណិជ្ជកម្ម (មើល ៧៣១០០)
- (ច) ការស្រាវជ្រាវទីផ្សារ និងការស្ទង់មតិសាធារណៈ (មើល ៧៣២០០)
- (ឆ) សេវាកម្មជ្រើសរើសបុគ្គលិក ឬសេវាកម្មពិគ្រោះយោបល់ស្វែងរកបុគ្គលិក (មើល ៧៨១០០)
- (ជ) សកម្មភាពពិគ្រោះយោបល់ខាងអប់រំ (មើល ៨៥៥០០)។

រាប់បញ្ចូល
- (ក) ការជ្រើសរើសពលករ និងការផ្តល់សេវាបុគ្គលិក
- (ខ) ការពិគ្រោះយោបល់ផ្នែកទំនាក់ទំនងសាធារណៈ។

ផ្នែក ៧១ ៖ សកម្មភាពស្ថាបត្យកម្ម និងវិស្វកម្ម ការពិសោធ និងវិភាគបច្ចេកទេស

ផ្នែកនេះរាប់បញ្ចូលការផ្តល់សេវាកម្មខាងស្ថាបត្យកម្ម វិស្វកម្ម ពង្រាងសំណង់ អធិការកិច្ចអគារ និងខាងការវាស់ស្ទង់ និងកំណត់ទីតាំង។ ផ្នែកនេះក៏រាប់បញ្ចូលផងដែរ នូវសេវាកម្មពិសោធន៍វិភាគផ្នែករូបសាស្ត្រ គីមីសាស្ត្រ និងសេវាកម្មពិសោធន៍វិភាគផ្សេងទៀត។

ក្រុម ៧១១ ៖ សកម្មភាពស្ថាបត្យកម្ម និងវិស្វកម្ម និងការពិគ្រោះយោបល់បច្ចេកទេស ដែលពាក់ព័ន្ធ

ក្រុមនេះរាប់បញ្ចូលការផ្តល់សេវាកម្មខាងស្ថាបត្យកម្ម វិស្វកម្ម ពង្រាងសំណង់ អធិការកិច្ចអគារ និងខាងការវាស់ស្ទង់ និងកំណត់ទីតាំងជាដើម។

ក្រុម ៧១២ ៖ ការពិសោធ និងវិភាគបច្ចេកទេស

ក្រុមនេះរាប់បញ្ចូល ៖ ការពិសោធផ្នែករូបសាស្ត្រ គីមីសាស្ត្រ និងការពិសោធវិភាគផ្សេងៗទៀត ទៅលើគ្រប់ប្រភេទសម្ភារៈ និងផលិតផល ការចេញវិញ្ញាបនបត្រទទួលស្គាល់ផលិតផល រួមមាន ទំនិញប្រើប្រាស់យានយន្ត យន្តហោះ ធុងសម្ពាធ ខ្យល់រោងចក្រនុយក្លេអ៊ែរ។ល។ ការត្រួតពិនិត្យសុវត្ថិភាពយានយន្តជាប្រចាំ ការពិសោធដោយប្រើសំណាក (ឧ.យន្តហោះ កប៉ាល់ ទំនប់។ល។) និងប្រតិបត្តិការទីពិសោធន៍របស់នគរបាល។

ជំពូក ឱ ៖ សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស
ផ្នែក ៧១ ៖ សកម្មភាពស្ថាបត្យកម្ម និងវិស្វកម្ម ការពិសោធ និងវិភាគបច្ចេកទេស

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៧១១			**សកម្មភាពស្ថាបត្យកម្មនិងវិស្វកម្មនិងការពិគ្រោះយោបល់បច្ចេកទេសដែលពាក់ព័ន្ធ**
	៧១១០[១]		សកម្មភាពស្ថាបត្យកម្មនិងវិស្វកម្មនិងការពិគ្រោះយោបល់បច្ចេកទេសដែលពាក់ព័ន្ធ
		៧១១០១	សេវាកម្មស្ថាបត្យកម្ម[២]
		៧១១០២	សេវាកម្មវិស្វកម្ម និងការពិគ្រោះយោបល់បច្ចេកទេសផ្សេងទៀត[៣]

(១) **មិនរាប់បញ្ចូល**
(ក) ការខួងសាកល្បងដែលទាក់ទងនឹងការរុករករ៉ែ (មើល ០៩១០០, ០៩៩០០)
(ខ) ការអភិវឌ្ឍឬចេញផ្សាយកម្មវិធីកុំព្យូទ័រពាក់ព័ន្ធ (មើល ៥៨២០០, ៦២០១០)
(គ) សកម្មភាពរបស់អ្នកពិគ្រោះយោបល់ផ្នែកកុំព្យូទ័រ (មើល ៦២០២០, ៦២០៩០)
(ឃ) ការពិសោធបច្ចេកទេស (មើល ៧១២០០)
(ង) សកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ ដែលទាក់ទងនឹងវិស្វកម្ម (មើល ៧២១០០)
(ច) ការរចនាខាងផ្នែកឧស្សាហកម្ម (មើល ៧៤១០០)
(ឆ) ការតុបតែងផ្នែកខាងក្នុងអគារ (មើល ៧៤១០០)
(ជ) ការថតរូបលំហអាកាស (មើល ៧៤២០០)។

(២) **រាប់បញ្ចូល** សកម្មភាពពិគ្រោះយោបល់ផ្នែកស្ថាបត្យកម្ម ដែលទាក់ទងនឹង ៖ ការរចនាអគារនិងពង្រាងសំណង់ ហើយជារឿយៗពាក់ព័ន្ធនឹងការគ្រប់គ្រងការសាងសង់ ការធ្វើផែនការនគរូបីយកម្មទីប្រជុំជននិងទីក្រុង, និងស្ថាបត្យកម្មទេសភាព។

(៣) **រាប់បញ្ចូល**
(ក) ការរចនាវិស្វកម្ម (ឧ. ការអនុវត្តច្បាប់រូបវិទ្យា និងគោលការណ៍វិស្វកម្មនៅក្នុងការរចនាម៉ាស៊ីន វត្ថុធាតុ ឧបករណ៍ ទ្រង់ទ្រាយ ដំណើរការ និងប្រព័ន្ធ) និងសកម្មភាពពិគ្រោះយោបល់សម្រាប់ ៖ សកម្មភាពដំណើរការម៉ាស៊ីន និងឧស្សាហកម្ម និងរោងចក្រឧស្សាហកម្ម គម្រោងដែលពាក់ព័ន្ធនឹងវិស្វកម្មស៊ីវិល វិស្វកម្មកម្លាំងទឹក វិស្វកម្មចរាចរណ៍, គម្រោងគ្រប់គ្រងទឹក ការធ្វើអន្តរកម្ម និងដំណើរការគម្រោងដែលទាក់ទងនឹងវិស្វកម្មអគ្គិសនីនិងអេឡិចត្រូនិច វិស្វកម្មរុករករ៉ែ វិស្វកម្មគីមី វិស្វកម្មខាងមេកានិចខាងឧស្សាហកម្ម និងខាងប្រព័ន្ធ និងវិស្វកម្មសុវត្ថិភាព សកម្មភាពគ្រប់គ្រងគម្រោងដែលពាក់ព័ន្ធនឹងសំណង់
(ខ) ការដាក់ឲ្យដំណើរការគម្រោងដែលប្រើប្រាស់ម៉ាស៊ីនត្រជាក់ ទូទឹកកក វិស្វកម្មខាងត្រួតពិនិត្យអនាម័យ និងការបំពុល និងវិស្វកម្មខាងសំឡេងនិងរំញ័រ។ល។
(គ) ការអង្កេតស្រាវជ្រាវខាងភូគព្ភរូបវន្តសាស្ត្រ ភូគព្ភសាស្ត្រ និងការរញ្ជួយដី
(ឃ) សកម្មភាពអង្កេតវិភាគផែនដីដូចជា ៖ សកម្មភាពអង្កេតដី និងព្រំប្រទល់ សកម្មភាពអង្កេតកម្លាំងទឹក សកម្មភាពអង្កេតផ្ទៃរងរបស់ដី និងសកម្មភាពគូរផែនទីនិងព័ត៌មានអំពីលំហ។

មិនរាប់បញ្ចូល ការខួង និងការជីកសាកល្បងដែលទាក់ទងនឹងនិស្សារណកម្មប្រេងនិងឧស្ម័ន ដែលត្រូវបានចាត់ថ្នាក់នៅក្នុងសកម្មភាពគាំទ្រ (មើល ០៩១០០) ដល់និស្សារណកម្មប្រេង និងឧស្ម័នធម្មជាតិ។

ជំពូក ឱ ៖ សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស
ផ្នែក ៧១ ៖ សកម្មភាពស្ថាបត្យកម្ម និងវិស្វកម្ម ការពិសោធ និងវិភាគបច្ចេកទេស

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៧១២			**ការពិសោធ និងវិភាគបច្ចេកទេស**
	៧១២០		ការពិសោធ និងវិភាគបច្ចេកទេស
		៧១២០០	ការពិសោធ និងវិភាគបច្ចេកទេស[១]

(១) **រាប់បញ្ចូល**

(ក) ការពិសោធផ្នែករូបសាស្ត្រ គីមីសាស្ត្រ និងការពិសោធវិភាគផ្សេងៗទៀត ទៅលើគ្រប់ប្រភេទសម្ភារៈ និងផលិតផល ៖
- ការពិសោធសូរស័ព្ទ និងរំញ័រ
- ការពិសោធជាតុផ្សំ និងភាពសុទ្ធរបស់រ៉ែ។ល។
- សកម្មភាពពិសោធន៍ក្នុងផ្នែកអនាម័យចំណីអាហារ រួមមាន ការពិសោធ និង ការត្រួតពិនិត្យសត្វ ទាក់ទងនឹងផលិតកម្មម្ហូបអាហារ
- ការពិសោធផ្នែកខាងក្រៅ និងសមត្ថភាពរបស់វត្ថុធាតុ ដូចជា ភាពខ្លាំង ភាពក្រាស់ ភាពជាប់បានយូរ ភាពចម្លងកម្តៅអគ្គិសនី និងវិទ្យុសកម្ម។ល។
- ការពិសោធលើលក្ខណៈសម្បត្តិ និងភាពអាចទុកចិត្តបាន
- ការពិសោធសមត្ថភាពម៉ាស៊ីន ៖ ម៉ូតូ រថយន្ត និងឧបករណ៍អគ្គិសនីដោយប្រើជាមួយឬមិនជាមួយ គំរូឬសំណាកនៃកប៉ាល់ យន្តហោះ និងទំនប់។ល។
- ការពិសោធដោយថតនៅត្រង់កន្លែងតំណ
- ការប្រមូលនិងវិភាគទិន្នន័យដើម្បីកំណត់បុព្វហេតុនៃភាពមិនដំណើរការនៅក្នុងវិស័យឧស្សាហកម្ម
- ការពិសោធនិងវាស់សូចនាករបរិស្ថាន ៖ ការបំពុលខ្យល់ និងការបំពុលទឹក។ល។

(ខ) ការចេញវិញ្ញាបនបត្រទទួលស្គាល់ផលិតផល រួមមាន ទំនិញប្រើប្រាស់ យានយន្ត យន្តហោះ ធុងសម្ពាធខ្យល់ រោងចក្រនុយក្លេអ៊ែរ។ល។

(គ) ការពិសោធផ្នែកវាយនភណ្ឌ

(ឃ) ប្រតិបត្តិការទីពិសោធន៍របស់នគរបាល

(ង) ការពិសោធមិនមែនផ្នែកវេជ្ជសាស្ត្រ

(ច) ការត្រួតពិនិត្យសុវត្ថិភាពយានយន្តជាប្រចាំ។

មិនរាប់បញ្ចូល

(ក) ការពិសោធសំណាកសត្វ (មើល ៧៥០០០)

(ខ) ការពិសោធផ្នែកវេជ្ជសាស្ត្រ (មើល ៨៦៩០១)។

ផ្នែក ៧២ ៖ ការស្រាវជ្រាវ និងអភិវឌ្ឍន៍វិទ្យាសាស្ត្រ

ផ្នែកនេះរាប់បញ្ចូល សកម្មភាពនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍បីប្រភេទ ៖ (១) ការស្រាវជ្រាវមូលដ្ឋានដូចជា ការងារពិសោធន៍ ឬការងារទ្រឹស្តីធ្វើឡើងជាចម្បងដើម្បីទទួលបានចំណេះដឹងថ្មីស្តីពីមូលដ្ឋានគ្រឹះរបស់បាតុភូត និងការពិតដែលអាច

សង្កេតបាន ដោយគ្មានគោលដៅជាក់លាក់សម្រាប់ការអនុវត្ត ឬប្រើប្រាស់ណាមួយឡើយ (២) ការស្រាវជ្រាវបែបអនុវត្តន៍ ៖ ការអង្កេតដើមដំបូងធ្វើឡើងដើម្បីទទួលបានចំណេះដឹងថ្មី ដែលមានទិសដៅសំខាន់ គឺឆ្ពោះទៅរកគោលបំណង ឬកម្មវត្ថុអនុវត្តន៍ជាក់លាក់ និង (៣) ការអភិវឌ្ឍបែបពិសោធន៍ ៖ ការងារជាប្រព័ន្ធ ដោយទាញយកមកប្រើនូវចំណេះដឹងដែលមានស្រាប់ ដែលទទួលបានពីការស្រាវជ្រាវ ឬការពិសោធជាក់ស្តែងមានទិសដៅឆ្ពោះទៅរកការផលិតវត្ថុធាតុ ផលិតផល និងឧបករណ៍ថ្មី ការតម្លើងដំណើរការ ប្រព័ន្ធ និងសេវាកម្មថ្មី និងការកែលម្អយ៉ាងច្រើនលើផលិតផលដែលបានផលិត និងតម្លើងស្រាប់។

សកម្មភាពនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍បែបពិសោធន៍នៅក្នុងផ្នែកនេះ ត្រូវបានបែងចែកជាពីរក្រុម ៖ វិទ្យាសាស្ត្រធម្មជាតិ និងវិស្វកម្ម និង វិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ។

ក្រុម ៧២១ ៖ ការស្រាវជ្រាវ និងអភិវឌ្ឍន៍បែបពិសោធន៍ ផ្នែកវិទ្យាសាស្ត្រធម្មជាតិ និងវិស្វកម្ម

ក្រុមនេះរាប់បញ្ចូល ការស្រាវជ្រាវនិងអភិវឌ្ឍន៍បែបពិសោធន៍ ផ្នែកវិទ្យាសាស្ត្រធម្មជាតិ និងវិស្វកម្មដូចជា៖ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ផ្នែកវិទ្យាសាស្ត្រធម្មជាតិ ការស្រាវជ្រាវនិងអភិវឌ្ឍន៍ផ្នែកវិស្វកម្មនិងបច្ចេកវិទ្យា ការស្រាវជ្រាវ និងអភិវឌ្ឍន៍ផ្នែកវិទ្យាសាស្ត្រវេជ្ជសាស្ត្រ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ផ្នែកជីវបច្ចេកវិទ្យា ការស្រាវជ្រាវ និងអភិវឌ្ឍន៍ផ្នែកវិទ្យាសាស្ត្រកសិកម្ម និងការស្រាវជ្រាវ និងអភិវឌ្ឍន៍អន្តរឯកទេសដែលសង្កត់ធ្ងន់លើផ្នែកវិទ្យាសាស្ត្រ ធម្មជាតិ និងវិស្វកម្ម។

ក្រុម ៧២២ ៖ ការស្រាវជ្រាវ និងអភិវឌ្ឍន៍បែបពិសោធន៍ ផ្នែកវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ

ក្រុមនេះរាប់បញ្ចូល ការស្រាវជ្រាវនិងអភិវឌ្ឍន៍ផ្នែកវិទ្យាសាស្ត្រសង្គម ការស្រាវជ្រាវនិងអភិវឌ្ឍន៍ផ្នែកមនុស្សសាស្ត្រ និងការស្រាវជ្រាវ និងអភិវឌ្ឍន៍អន្តរឯកទេសដែលសង្កត់ធ្ងន់លើផ្នែកវិទ្យាសាស្ត្រសង្គម និងមនុស្សសាស្ត្រ។

ជំពូក ឧ ៖ សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស
ផ្នែក ៧២ ៖ ការស្រាវជ្រាវ និងអភិវឌ្ឍន៍វិទ្យាសាស្ត្រ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៧២១			**ការស្រាវជ្រាវ និងអភិវឌ្ឍន៍បែបពិសោធន៍ ផ្នែកវិទ្យាសាស្ត្រធម្មជាតិនិងវិស្វកម្ម**
	៧២១០		ការស្រាវជ្រាវ និងអភិវឌ្ឍន៍បែបពិសោធន៍ ផ្នែកវិទ្យាសាស្ត្រធម្មជាតិ និងវិស្វកម្ម
		៧២១០០	ការស្រាវជ្រាវ និងអភិវឌ្ឍន៍បែបពិសោធន៍ផ្នែកវិទ្យាសាស្ត្រធម្មជាតិនិងវិស្វកម្ម(១)
៧២២			**ការស្រាវជ្រាវនិងអភិវឌ្ឍន៍បែបពិសោធន៍ផ្នែកវិទ្យាសាស្ត្រសង្គមនិងមនុស្សសាស្ត្រ**
	៧២២០(២)		ការស្រាវជ្រាវនិងអភិវឌ្ឍន៍បែបពិសោធន៍ផ្នែកវិទ្យាសាស្ត្រសង្គមនិងមនុស្សសស្ត្រ
		៧២២០០	ការស្រាវជ្រាវនិងអភិវឌ្ឍន៍បែបពិសោធន៍ផ្នែកវិទ្យាសាស្ត្រសង្គមនិងមនុស្សសស្ត្រ

(១) **រាប់បញ្ចូល** សេវាកម្មខាងការស្រាវជ្រាវ និងអភិវឌ្ឍន៍បែបពិសោធន៍ ផ្នែកគីមីវិទ្យានិងជីវវិទ្យា។

រាប់បញ្ចូល ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ផ្នែកឱសថសាស្ត្រនិងឱសថជីវសាស្ត្រ។

រាប់បញ្ចូល ការស្រាវជ្រាវ និងអភិវឌ្ឍន៍អន្តរឯកទេស ដែលសង្កត់ធ្ងន់លើផ្នែកវិទ្យាសាស្ត្រធម្មជាតិ និងវិស្វកម្ម។

(២) **មិនរាប់បញ្ចូល** ការស្រាវជ្រាវទីផ្សារ (មើល ៧៣២០០)។

ផ្នែក ៧៣ ៖ ការផ្សាយពាណិជ្ជកម្ម និងការស្រាវជ្រាវទីផ្សារ

ផ្នែកនេះរាប់បញ្ចូល ការបង្កើតយុទ្ធនាការផ្សាយពាណិជ្ជកម្ម និងការដាក់ការផ្សាយ ពាណិជ្ជកម្មទាំងនេះនៅតាមកាលិកបត្រ កាសែត វិទ្យុ និងទូរទស្សន៍ ឬតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត ព្រមទាំងការរចនាការដាក់តាំងបង្ហាញ និងវេបសាយ។

ក្រុម ៧៣១ ៖ ការផ្សាយពាណិជ្ជកម្ម

ក្រុមនេះរាប់បញ្ចូល ការផ្តល់សេវាកម្មផ្សាយពាណិជ្ជកម្មគ្រប់ប្រភេទ (តាមរយៈសមត្ថភាពផ្ទៃក្នុង ឬកិច្ចសន្យាបន្ត) រួមមាន ការផ្តល់ប្រឹក្សាយោបល់ សេវាកម្មច្នៃប្រតិដ្ឋនិងការផលិតសម្ភារៈផ្សាយពាណិជ្ជកម្ម ការធ្វើផែនការ និងការទិញប្រព័ន្ធផ្សព្វផ្សាយ។

ក្រុម ៧៣២ ៖ ការស្រាវជ្រាវទីផ្សារ និងការស្ទង់មតិសាធារណៈ

ក្រុមនេះរាប់បញ្ចូល ការអង្កេតទៅលើសក្តានុពលទីផ្សារ ការទទួលស្គាល់និងការបន្សាំផលិតផលទៅក្នុងទីផ្សារ និងឥរិយាបថទិញទំនិញរបស់អតិថិជន ក្នុងគោលបំណងនៃការផ្សព្វផ្សាយលក់ និងការអភិវឌ្ឍផលិតផលថ្មី ព្រមទាំងការវិភាគស្ថិតិនៃលទ្ធផលអង្កេតទាំងនេះ និងការអង្កេតមតិសាធារណជនអំពីបញ្ហានយោបាយ សេដ្ឋកិច្ច និងសង្គម និងការវិភាគស្ថិតិនៃការអង្កេតទាំងនេះ។

ជំពូក ឱ ៖ សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស
ផ្នែក ៧៣ ៖ ការផ្សាយពាណិជ្ជកម្ម និងការស្រាវជ្រាវទីផ្សារ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៧៣១			**ការផ្សាយពាណិជ្ជកម្ម**
	៧៣១០		ការផ្សាយពាណិជ្ជកម្ម
		៧៣១០០	ការផ្សាយពាណិជ្ជកម្ម(១)
៧៣២			**ការស្រាវជ្រាវទីផ្សារ និងការស្ទង់មតិសាធារណៈ**
	៧៣២០		ការស្រាវជ្រាវទីផ្សារ និងការស្ទង់មតិសាធារណៈ
		៧៣២០០	ការស្រាវជ្រាវទីផ្សារ និងការស្ទង់មតិសាធារណៈ(២)

(១) **រាប់បញ្ចូល**

(ក) ការបង្កើត និងការអនុវត្តយុទ្ធនាការផ្សាយពាណិជ្ជកម្ម (ការបង្កើត និងការដាក់ការផ្សាយពាណិជ្ជកម្ម នៅតាមកាសែត កាលិកបត្រ វិទ្យុ ទូរទស្សន៍ អ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត ការបង្កើត និងការដាក់ការផ្សាយពាណិជ្ជកម្មនៅខាងក្រៅអគារ ដូចជា ផ្ទាំងប្រកាស ការដាក់តាំងផ្សាយពាណិជ្ជកម្ម ព្រឹត្តិបត្រ និងប្រអប់ផ្សាយពាណិជ្ជកម្ម ការដាក់តាំងផលិតផល បន្ទប់បង្ហាញផលិតផល ការដាក់បង្ហាញតាមរថយន្ត និងរថយន្តក្រុង។ល។ ការដាក់បង្ហាញឲ្យឃើញតាមប្រព័ន្ធផ្សព្វផ្សាយ ដូចជា៖ ការលក់ម៉ោងនិងកន្លែងសម្រាប់ផ្សាយពាណិជ្ជកម្មរបស់ប្រព័ន្ធផ្សព្វផ្សាយ ការផ្សាយពាណិជ្ជកម្មតាមអាកាស (តាមយន្តបាឡុង។ល។) ការចែកចាយសម្ភារៈ ឬសំណាកផ្សាយពាណិជ្ជកម្ម ការផ្តល់កន្លែងផ្សាយពាណិជ្ជកម្មនៅលើផ្ទាំងផ្សាយពាណិជ្ជកម្ម។ល។ ការបង្កើតស្តង់ផ្សាយពាណិជ្ជកម្ម និងសម្ភារៈ និងកន្លែងផ្សាយពាណិជ្ជកម្មឯទៀត

(ខ) ការផ្តល់សេវាកម្មយុទ្ធនាការដើរទីផ្សារ (ម៉ាឃីធីង) និងការផ្សាយពាណិជ្ជកម្មផ្សេងទៀតក្នុងគោលបំណងទាក់ទាញ និងរក្សាអតិថិជន (ការផ្សព្វផ្សាយផលិតផល ការធ្វើម៉ាឃីតធីងនៅកន្លែងលក់ ការផ្សាយពាណិជ្ជកម្មដោយបញ្ជូនសន្លឹកប័ណ្ណតាមប្រៃសណីយ៍ និងការពិគ្រោះយោបល់ផ្នែកម៉ាឃីតធីង)

មិនរាប់បញ្ចូល

(ក) ការបោះពុម្ពផ្សាយសម្ភារៈផ្សាយពាណិជ្ជកម្ម (មើល ៥៨១៩០)

(ខ) ការផលិតសារពាណិជ្ជកម្មសម្រាប់វិទ្យុ ទូរទស្សន៍ និងខ្សែភាពយន្ត (មើល ៥៩១១០)

(គ) សកម្មភាពទំនាក់ទំនងសាធារណៈ (មើល ៧០២០០)

(ឃ) ការស្រាវជ្រាវទីផ្សារ (មើល ៧៣២០០)

(ង) ការថតផ្សាយពាណិជ្ជកម្ម (មើល ៧៤២០០)

(ច) អ្នករៀបចំសន្និបាត និងពិព័រណ៍ពាណិជ្ជកម្ម (មើល ៨២៣០០)

(ឆ) សកម្មភាពបញ្ជូនតាមប្រៃសណីយ៍ (ការផ្ញើរលិខិត ការជ្រើសរើសអាសយដ្ឋាន ។ល។) (មើល ៨២៩៩០)។

(២) **រាប់បញ្ចូល**

ការអង្កេតទៅលើសក្តានុពលទីផ្សារ ការទទួលស្គាល់និងការបន្សាំផលិតផលទៅក្នុងទីផ្សារ និងឥរិយាបថទិញទំនិញរបស់អតិថិជន ក្នុងគោលបំណងនៃការផ្សព្វផ្សាយលក់ និងការអភិវឌ្ឍផលិតផលថ្មី ព្រមទាំងការវិភាគស្ថិតិនៃលទ្ធផលអង្កេតទាំងនេះ, និងការអង្កេតមតិសាធារណៈជនអំពីបញ្ហានយោបាយ សេដ្ឋកិច្ច និងសង្គម និងការវិភាគស្ថិតិនៃការអង្កេតទាំងនេះ។

ផ្នែក ៧៤ ៖ សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេសផ្សេងទៀត

ផ្នែកនេះរាប់បញ្ចូលការផ្តល់សេវាកម្មវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស (លើកលែង តែសកម្មភាពផ្នែកច្បាប់ និងគណនេយ្យ សកម្មភាពផ្នែកស្ថាបត្យកម្ម និងវិស្វកម្ម ការពិសោធ និងការវិភាគបច្ចេកទេស សកម្មភាពផ្នែកគ្រប់គ្រង និងការពិគ្រោះយោបល់ផ្នែកគ្រប់គ្រង សកម្មភាពនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងការផ្សាយពាណិជ្ជកម្ម)។

អ្នកនិពន្ធដែលរៀបចំក្បួនសៀវភៅបច្ចេកទេស ឬសម្ភារៈផ្សេងទៀតដែលមានមាតិកាអំពីបច្ចេកទេស ត្រូវបានចាត់ចូលទៅក្នុងថ្នាក់ ៧៤៩០។

ក្រុម ៧៤១ ៖ សកម្មភាពរចនាឯកទេស

ក្រុមនេះរាប់បញ្ចូល ការរចនាម៉ូតដែលទាក់ទងនឹង វាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង គ្រឿងអលង្ការ គ្រឿងសង្ហារឹម និងការតែងលម្អផ្នែកខាងក្នុង និងទំនិញពេញនិយមផ្សេងទៀត ព្រមទាំងទំនិញប្រើប្រាស់ផ្ទាល់ខ្លួន ឬតាមផ្ទះ ការរចនាផ្នែកឧស្សាហកម្ម ដូចជា ការបង្កើត និងការអភិវឌ្ឍនៃការរចនាម៉ូត និងលក្ខណៈលម្អិតដើម្បីធ្វើឲ្យប្រសើរនូវការប្រើប្រាស់ តម្លៃ និងរូបរាងរបស់ផលិតផល រួមមាន ការកំណត់វត្ថុធាតុ ការសាងសង់ យន្តការ ទ្រង់ទ្រាយ ពណ៌ និងការសម្អាតផ្ទៃខាងក្រៅនៃផលិតផល ដោយគិតទៅដល់ចរិតលក្ខណៈ និងតម្រូវការរបស់មនុស្ស សុវត្ថិភាព ការចង់បានរបស់ទីផ្សារ និងប្រសិទ្ធភាពនៅក្នុងផលិតកម្ម ការបែងចែក ការប្រើប្រាស់ និងថែទាំ សេវាកម្មរបស់អ្នករចនាក្រាហ្វិច និងសកម្មភាពរបស់អ្នកតែងលម្អផ្នែកខាងក្នុង។

ក្រុម ៧៤២ ៖ សកម្មភាពថតរូប

ក្រុមនេះរាប់បញ្ចូលនូវ ៖ ការផលិតរូបថតសម្រាប់ពាណិជ្ជកម្ម និងសម្រាប់អ្នកប្រើប្រាស់ ដូចជា ការថតរូបសម្រាប់លិខិតឆ្លងដែន សាលារៀន និងអាពាហ៍ពិពាហ៍។ល។ ការថតរូបសម្រាប់គោលបំណងពាណិជ្ជកម្ម ការបោះពុម្ពផ្សាយ ការបង្ហាញម៉ូត អចលនទ្រព្យ ឬទេសចរណ៍ ការថតរូបពីលើអាកាស និងការថតវីដេអូនៃព្រឹត្តិការណ៍នានា (ការរៀបអាពាហ៍ពិពាហ៍ ការប្រជុំ។ល។) ការបំប្លែងហ្វីល ដូចជា ការអភិវឌ្ឍ ការបោះពុម្ព និងការពង្រីកពីហ្វីលដែលអតិថិជនថតមិនបានស្អាត ឬហ្វីលដែលថតហើយ ទីពិសោធន៍អភិវឌ្ឍន៍ហ្វីលនិងការបោះពុម្ពរូបថត ហាងថតរូបដែលផ្តិតយកក្នុងរយៈពេល១ម៉ោង (មិនមែនជាផ្នែកមួយនៃហាងលក់ម៉ាស៊ីនថតទេ) ការរៀបចំរូបថតបញ្ចាំងឬហ្វីល ការថតចម្លង និងការរក្សាទុកឬការស្តាបនាឡើងវិញនូវភាពភ្លឺ ដែលពាក់ព័ន្ធនឹងការថតរូប សកម្មភាពរបស់អ្នកកាសែតរូបថត និងការថតឯកសារដោយប្រើមីក្រូហ្វីល។

ក្រុម ៧៤៩ ៖ សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេសផ្សេងទៀត ដែលពុំបានរាប់បញ្ចូល

ក្រុមនេះរាប់បញ្ចូលសកម្មភាពសេវាកម្មជាច្រើន ដែលជាទូទៅផ្តល់ទៅឲ្យអតិថិជនផ្នែកពាណិជ្ជកម្ម។ ក្រុមនេះរាប់បញ្ចូលសកម្មភាព ដែលទាមទារនូវកម្រិតជំនាញវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេសជាន់ខ្ពស់ ប៉ុន្តែមិនរាប់បញ្ចូលមុខងារជំនួញប្រចាំថ្ងៃ ឬជាប្រចាំដែលជាធម្មតាមានរយៈពេលខ្លី។

ជំពូក ខ ៖ សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស
ផ្នែក ៧៤ ៖ សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេសផ្សេងទៀត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៧៤១			**សកម្មភាពរចនាឯកទេស**
	៧៤១០[១]		សកម្មភាពរចនាឯកទេស
		៧៤១០០	សកម្មភាពរចនាឯកទេស
៧៤២			**សកម្មភាពថតរូប**
	៧៤២០[២]		សកម្មភាពថតរូប
		៧៤២០០	សកម្មភាពថតរូប[៣]

(១) **រាប់បញ្ចូល** ការតែងលម្អផ្នែកខាងក្នុង ការរចនាក្រាហ្វិច ការរចនាម៉ូត និងការរចនាផ្នែកឧស្សាហកម្ម។

មិនរាប់បញ្ចូល
(ក) ការរចនា និងការបង្កើតកម្មវិធីទំព័រវែបសាយ (មើល ៦២០១)
(ខ) ការរចនាផ្នែកស្ថាបត្យកម្ម (មើល ៧១១០១)
(គ) ការរចនាផ្នែកវិស្វកម្ម (ឧ. ការអនុវត្តច្បាប់រូបវិទ្យា និងគោលការណ៍វិស្វកម្មនៅក្នុងការរចនាម៉ាស៊ីន វត្ថុធាតុ ឧបករណ៍ ទ្រង់ទ្រាយ ដំណើរការ និងប្រព័ន្ធ) (មើល ៧១១០២)។

(២) **មិនរាប់បញ្ចូល**
(ក) ការបំប្លែងហ្វីលខ្សែភាពយន្តដែលទាក់ទងនឹងឧស្សាហកម្មភាពយន្ត និងទូរទស្សន៍ (មើល ៥៩១២០)
(ខ) សកម្មភាពគូរផែនទី និងព័ត៌មានអំពីលំហ (មើល៧១១០២)

(៣) **រាប់បញ្ចូល**
(ក) ការផលិតរូបថតពាណិជ្ជកម្ម និងអ្នកប្រើប្រាស់ដូចជា ការថតរូបសម្រាប់លិខិតឆ្លងដែន សាលារៀន និងអាពាហ៍ពិពាហ៍។ល។ ការថតរូបសម្រាប់គោលបំណងពាណិជ្ជកម្ម ការបោះពុម្ពផ្សាយ ការបង្ហាញម៉ូត អចលនទ្រព្យ ឬទេសចរណ៍ ការថតរូបពីលើអាកាស និងការថតវីដេអូនៃព្រឹត្តិការណ៍នានា(ការរៀបអាពាហ៍ពិពាហ៍ ការប្រជុំ។ល។)
(ខ) ការបំប្លែងហ្វីល ដូចជា ការអភិវឌ្ឍ ការបោះពុម្ព និងការពង្រីកពីហ្វីលដែលអតិថិជនថតមិនបានស្អាត ឬហ្វីលដែលថតហើយ, ទីពិសោធន៍អភិវឌ្ឍន៍ហ្វីល និងការបោះពុម្ពរូបថត, ហាងថតរូបដែលផ្ដិតយកក្នុងរយៈពេល១ម៉ោង(មិនមែនជាផ្នែកមួយនៃហាងលក់ម៉ាស៊ីនថតទេ) ការរៀបចំរូបថតបញ្ចាំង ឬហ្វីល និងការថតចម្លង និងការរក្សាទុក ឬការស្ដាបនាឡើងវិញនូវភាពភ្លឺ ដែលពាក់ព័ន្ធនឹងការថតរូប
(គ) សកម្មភាពរបស់អ្នកកាសែតរូបថត
(ឃ) ការថតឯកសារដោយប្រើមីក្រូហ្វីល។

ជំពូក ឌ ៖ សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស
ផ្នែក ៧៤ ៖ សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេសផ្សេងទៀត

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៧៤៩			**សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេសផ្សេងទៀត ដែលពុំបានរាប់បញ្ចូល**
	៧៤៩០[១]		សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេសផ្សេងទៀត ដែលពុំបានរាប់បញ្ចូល
		៧៤៩០០	សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេសផ្សេងទៀត ដែលពុំបានរាប់បញ្ចូល

(១) **រាប់បញ្ចូល**

(ក) សកម្មភាពបកប្រែ
(ខ) ការពិគ្រោះយោបល់ផ្នែកសន្តិសុខ
(គ) សកម្មភាពរបស់អ្នកអង្កេតបែបបរិមាណ
(ឃ) សកម្មភាពរបស់ទីប្រឹក្សាដែលមិនមែនជាទីប្រឹក្សាផ្នែកស្ថាបត្យកម្ម វិស្វកម្ម និងគ្រប់គ្រង
(ង) ភ្នាក់ងារ ឬទីភ្នាក់ងារសិល្បៈ។

មិនរាប់បញ្ចូល

(ក) សកម្មភាពរបស់ឈ្មួញកណ្តាលអចលនទ្រព្យ (មើល ៦៨២០១)
(ខ) សកម្មភាពកត់ត្រាគណនេយ្យ (មើល ៦៩២០០)
(គ) សកម្មភាពរបស់ទីប្រឹក្សាផ្នែកគ្រប់គ្រង (មើល ៧០២០០)
(ឃ) សកម្មភាពរបស់ទីប្រឹក្សាផ្នែកស្ថាបត្យកម្ម (មើល ៧១១០១) និងសកម្មភាពរបស់ទីប្រឹក្សាផ្នែកវិស្វកម្ម (មើល ៧១១០២)
(ង) សកម្មភាពរចនាផ្នែកវិស្វកម្ម (មើល ៧១១០២)
(ច) ការដាក់បង្ហាញការផ្សាយពាណិជ្ជកម្ម និងការរចនាការផ្សាយពាណិជ្ជកម្មផ្សេងទៀត (មើល ៧៣១០០)
(ឆ) ការបង្កើតស្តង់ផ្សាយពាណិជ្ជកម្ម និងសម្ភារៈនិងកន្លែងផ្សាយពាណិជ្ជកម្មផ្សេងទៀត
(ជ) សកម្មភាពរចនាផ្នែកឧស្សាហកម្ម (មើល ៧៤១០)
(ឈ) សកម្មភាពរបស់អ្នករៀបចំសន្និបាត និងពិព័រណ៍ពាណិជ្ជកម្ម (មើល ៨២៣០០)
(ញ) សកម្មភាពរបស់អ្នកនិពន្ធសៀវភៅវិទ្យាសាស្ត្រ និងបច្ចេកទេស (មើល ៩០០០៤)
(ដ) សកម្មភាពរបស់អ្នកកាសែតឯករាជ្យ (មើល ៩០០០៤)។

ផ្នែក ៧៥ ៖ សកម្មភាពបសុព្យាបាល

ផ្នែកនេះរាប់បញ្ចូលការផ្តល់ការថែទាំសុខភាពសត្វ និងសកម្មភាពត្រួតពិនិត្យសម្រាប់សត្វនៅក្នុងកសិដ្ឋាន ឬសត្វចិញ្ចឹមកម្សាន្ត។ សកម្មភាពទាំងនេះអនុវត្តដោយបសុពេទ្យជំនាញបម្រើការងារនៅមន្ទីរបសុព្យាបាល ក៏ដូចជាការទៅពិនិត្យនៅឯកសិដ្ឋាន សុនខាគារ ឬនៅ តាមផ្ទះ និងនៅក្នុងបន្ទប់ពិគ្រោះជំងឺ និងបន្ទប់វះកាត់ផ្ទាល់ខ្លួន ឬកន្លែងដទៃទៀត។ ផ្នែកនេះ ក៏រាប់បញ្ចូលផងដែរ នូវសកម្មភាពរបស់រថយន្តគិលានសង្គ្រោះសត្វ។

ក្រុម ៧៥០ ៖ សកម្មភាពបសុព្យាបាល

ក្រុមនេះរាប់បញ្ចូលការផ្តល់ការថែទាំសុខភាពសត្វ និងសកម្មភាពត្រួតពិនិត្យសម្រាប់សត្វនៅក្នុងកសិដ្ឋាន ឬសត្វចិញ្ចឹមកម្សាន្ត។ សកម្មភាពទាំងនេះអនុវត្តដោយបសុពេទ្យជំនាញបម្រើការងារនៅមន្ទីរបសុព្យាបាល ក៏ដូចជាការទៅពិនិត្យនៅឯកសិដ្ឋាន សុនខាគារ ឬនៅតាមផ្ទះ និងនៅក្នុងបន្ទប់ពិគ្រោះជំងឺ និងបន្ទប់វះកាត់ផ្ទាល់ខ្លួន ឬកន្លែងដទៃទៀត។

ក្រុមនេះក៏រាប់បញ្ចូលផងដែរនូវសកម្មភាពរបស់ជំនួយការបសុពេទ្យ ឬបុគ្គលិកបសុពេទ្យផ្សេងទៀត សកម្មភាពពិនិត្យរោគសាស្ត្រ និងការធ្វើរោគវិនិច្ឆ័យផ្សេងទៀតដែលទាក់ទងនឹងសត្វ និងសកម្មភាពរបស់រថយន្តគិលានសង្គ្រោះសត្វ។

ជំពូក ឧ ៖ សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស
ផ្នែក ៧៥ ៖ សកម្មភាពបសុពេទ្យ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៧៥០			សកម្មភាពបសុព្យាបាល
	៧៥០០[១]		សកម្មភាពបសុព្យាបាល
		៧៥០០០	សកម្មភាពបសុព្យាបាល

(១) **រាប់បញ្ចូល**

(ក) ការថែទាំសុខភាពសត្វ និងសកម្មភាពត្រួតពិនិត្យសម្រាប់សត្វនៅក្នុងកសិដ្ឋាន

(ខ) ការថែទាំសុខភាពសត្វ និងសកម្មភាពត្រួតពិនិត្យសម្រាប់សត្វចិញ្ចឹមកម្សាន្ត។

សកម្មភាពទាំងនេះអនុវត្តដោយបសុពេទ្យជំនាញបម្រើការងារនៅមន្ទីរបសុព្យាបាល ក៏ដូចជាការទៅពិនិត្យនៅឯកសិដ្ឋាន សុនខាគារ ឬនៅតាមផ្ទះ និងនៅក្នុងបន្ទប់ពិគ្រោះជំងឺ និងបន្ទប់វះកាត់ផ្ទាល់ខ្លួន ឬកន្លែងដទៃទៀត

(គ) សកម្មភាពរបស់ជំនួយការបសុពេទ្យ ឬបុគ្គលិកបសុពេទ្យផ្សេងទៀត

(ឃ) សកម្មភាពពិនិត្យរោគសាស្ត្រ និងការធ្វើរោគវិនិច្ឆ័យផ្សេងទៀតដែលទាក់ទងនឹងសត្វ

(ង) សកម្មភាពរបស់រថយន្តគិលានសង្គ្រោះសត្វ

(ច) ការពិសោធសំណាកសត្វ។

មិនរាប់បញ្ចូល

(ក) សកម្មភាពចិញ្ចឹមសត្វនៅកសិដ្ឋានដោយគ្មានការថែទាំសុខភាព (មើល០១៦២០)

(ខ) សេវាកម្មពិសោធន៍ហ្វូងសត្វ សេវាកម្មកៀងសត្វ សេវាកម្មផ្តល់ចំណីសត្វ សេវាកម្មក្រៀវបសុបក្សី (មើល ០១៦២០)

(គ) សកម្មភាពដែលពាក់ព័ន្ធនឹងការបង្កាត់ពូជបែបសិប្បនិម្មិត (មើល ០១៦២០)

(ឃ) សកម្មភាពចិញ្ចឹមសត្វចិញ្ចឹមកម្សាន្ត ដោយគ្មានការថែទាំសុខភាព (មើល ៩៦០៩៤)។

ជំពូក ឍ ៖ សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ

កម្រិត	ច.ស.វ.ក
ជំពូក	១
ផ្នែក	៦
ក្រុម	១៩
ថ្នាក់	២៦
ថ្នាក់រង	៣៨

ជំពូកនេះរាប់បញ្ចូលសកម្មភាពនានា ដែលគាំទ្រដល់ប្រតិបត្តិការអាជីវកម្មទូទៅ។ សកម្មភាពទាំងនេះខុសគ្នាពីសកម្មភាពដែលមានចែងនៅក្នុងជំពូក «ឌ» ពីព្រោះគោលបំណងចម្បងនៃសកម្មភាពទាំងនេះ គឺមិនមែនការផ្ទេរចំណេះដឹងឯកទេសនោះទេ។

ជំពូកនេះរាប់បញ្ចូលនូវ ៖ សកម្មភាពនៃការជួលនិងភតិសន្យា សកម្មភាពពាក់ព័ន្ធនឹងការរកការងារ សកម្មភាពរបស់ទីភ្នាក់ងារទេសចរណ៍និងប្រតិបត្តិករទេសចរណ៍ សេវាកម្មកក់បម្រុងទុក និងសកម្មភាពពាក់ព័ន្ធ សកម្មភាពរក្សាសន្តិសុខនិងស៊ើបអង្កេត សកម្មភាពសេវាកម្មពាក់ព័ន្ធនឹងអគារនិងសោភ័ណភាព, និងសកម្មភាពរដ្ឋបាលការិយាល័យ គាំទ្រការិយាល័យ និងគាំទ្រអាជីវកម្មផ្សេងទៀត។

ផ្នែក ៧៧ ៖ សកម្មភាពជួល និងភតិសន្យា

ផ្នែកនេះរាប់បញ្ចូលការជួល និងភតិសន្យានូវទ្រព្យសកម្មរូបីយ៍ និងទ្រព្យសកម្មអរូបីយ៍មិនមែនហិរញ្ញវត្ថុ រួមមានមុខទំនិញរូបីយ៍ជាច្រើន ដូចជា រថយន្ត កុំព្យូទ័រ ទំនិញប្រើប្រាស់ និងម៉ាស៊ីននិងឧបករណ៍ឧស្សាហកម្ម ទៅឲ្យអតិថិជន ដើម្បីទទួលបានការបង់ថ្លៃជួលត្រឡប់មកវិញ។ ផ្នែកនេះត្រូវបានចែកចេញជា ៖ (១)ការជួលយានយន្ត (២)ការជួលឧបករណ៍កម្សាន្តនិងកីឡា និងឧបករណ៍ប្រើផ្ទាល់ខ្លួននិងសម្រាប់គ្រួសារ (៣)ភតិសន្យាប្រភេទម៉ាស៊ីន និងឧបករណ៍ដែលប្រើសម្រាប់ប្រតិបត្តិការអាជីវកម្ម រួមមាន សម្ភារៈដឹកជញ្ជូនផ្សេងៗ និង (៤)ភតិសន្យាផលិតផលកម្មសិទ្ធិបញ្ញា និងផលិតផលប្រហាក់ប្រហែល។

ផ្នែកនេះរាប់បញ្ចូលតែការផ្តល់ភតិសន្យាផ្នែកប្រតិបត្តិការប៉ុណ្ណោះ។ ផ្នែកនេះក៏រាប់បញ្ចូលផងដែរ នូវការអនុញ្ញាតឲ្យប្រើទ្រព្យសកម្ម ដូចជា ប័ណ្ណប៉ាតង់ ពាណិជ្ជសញ្ញា ម៉ាកយីហោ ឬកិច្ចព្រមព្រៀងសិទ្ធិប្រើយីហោផ្តាច់មុខ (ហ្វ្រែនឆាយស៍) ដែលការបង់សួយសារ ឬថ្លៃអាជ្ញាប័ណ្ណ ត្រូវទូទាត់ទៅឲ្យម្ចាស់កម្មសិទ្ធិនៃទ្រព្យសកម្មនេះ។

ផ្នែកនេះមិនរាប់បញ្ចូល សកម្មភាពភតិសន្យាហិរញ្ញវត្ថុ(មើល ៦៤៩១) ការជួលអចលនទ្រព្យ(មើលជំពូក«ឋ») និងការជួលឧបករណ៍ ដោយមានអមមកជាមួយនូវប្រតិបត្តិករ(មើលបណ្តាថ្នាក់ដែលត្រូវគ្នា ទៅតាមសកម្មភាពដែលប្រើឧបករណ៍នេះ ជាឧទាហរណ៍ សកម្មភាពសំណង់នៃជំពូក«ច» និងការដឹកជញ្ជូននៃជំពូក«ជ»)។

ក្រុម ៧៧១ ៖ ការជួល និងភតិសន្យាយានយន្ត

ក្រុមនេះរាប់បញ្ចូល ការជួលនិងភតិសន្យាខាងប្រតិបត្តិការ នូវប្រភេទយានយន្ត ដូចជារថយន្តដឹកអ្នកដំណើរ(មិនយកអ្នកបើកបរ) រថយន្តដឹកទំនិញ រថយន្តសណ្តោង និងរថយន្តសម្រាប់កម្សាន្ត។

ក្រុម ៧៧២ ៖ ការជួល និងភតិសន្យាទំនិញប្រើផ្ទាល់ខ្លួននិងសម្រាប់គ្រួសារ

ក្រុមនេះរាប់បញ្ចូល ការជួលទំនិញប្រើផ្ទាល់ខ្លួននិងសម្រាប់គ្រួសារ ព្រមទាំងការជួលសម្ភារៈកីឡានិងកម្សាន្ត និងកាសែតវីដេអូ។ សកម្មភាពជាទូទៅ រួមមានការជួលទំនិញក្នុងរយៈពេលខ្លី បើទោះបីជាពេលខ្លះការជួលទំនិញអាចមានរយៈពេលវែងក៏ដោយ។

ក្រុម ៧៧៣ ៖ ការជួល និងភតិសន្យាគ្រឿងយន្ត ឧបករណ៍ និងទំនិញរូបីយ៍ផ្សេងទៀត

ក្រុមនេះរាប់បញ្ចូល ការជួលនិងភតិសន្យាខាងប្រតិបត្តិការ ដោយមិនយកប្រតិបត្តិករ នូវគ្រឿងយន្តនិងឧបករណ៍ផ្សេងទៀត ដែលជាធម្មតាប្រើប្រាស់ជាទំនិញមូលធននៅក្នុងឧស្សាហកម្ម ការជួលនិងភតិសន្យាខាងប្រតិបត្តិការ នូវឧបករណ៍ដឹកជញ្ជូនតាមផ្លូវគោក(ក្រៅពីយានយន្ត) ដោយមិនយកអ្នកបើកបរ ការជួលនិងភតិសន្យាខាងប្រតិបត្តិការ នូវឧបករណ៍ដឹកជញ្ជូនតាមផ្លូវទឹក ដោយមិនយកប្រតិបត្តិករ ការជួលនិងភតិសន្យាខាងប្រតិបត្តិការ នូវឧបករណ៍ដឹកជញ្ជូនតាមផ្លូវអាកាស ដោយមិនយកប្រតិបត្តិករ ការជួលនិងភតិសន្យាខាងប្រតិបត្តិការ នូវគ្រឿងយន្តនិងឧបករណ៍សម្រាប់កសិកម្មនិងរុក្ខកម្ម ដោយមិនយកប្រតិបត្តិករ ការជួលនិងភតិសន្យាខាងប្រតិបត្តិការ នូវគ្រឿងយន្តនិងឧបករណ៍សម្រាប់ការងារសំណង់និងវិស្វកម្មស៊ីវិល ដោយមិនយកប្រតិបត្តិករ ការជួលនិងភតិសន្យាខាងប្រតិបត្តិការ នូវគ្រឿងយន្តនិងឧបករណ៍ការិយាល័យ ដោយមិនយកប្រតិបត្តិករ និងការជួលកន្លែងស្នាក់នៅឬការិយាល័យ ការជួលកុងតឺន័រ ការជួលកេសក្តារប៉ាឡែត និងការជួលសត្វ (ឧ. ហ្វូងសត្វ និងសេះប្រណាំង)។

ក្រុម ៧៧៤ ៖ភតិសន្យាផលិតផលកម្មសិទ្ធិបញ្ញា និងផលិតផលប្រហាក់ប្រហែល លើកលែងតែការងារដែលបានរក្សាសិទ្ធិ

ក្រុមនេះរាប់បញ្ចូលសកម្មភាពនៃការអនុញ្ញាតឲ្យអ្នកដទៃ ប្រើផលិតផលកម្មសិទ្ធិបញ្ញា និងផលិតផលប្រហាក់ប្រហែល ដែលការបង់សួយសារឬថ្លៃអាជ្ញាប័ណ្ណ ត្រូវទូទាត់ទៅឲ្យម្ចាស់ផលិតផល (គឺម្ចាស់កម្មសិទ្ធិនៃទ្រព្យសកម្ម)។ ភតិសន្យាផលិតផលទាំងនេះ អាចធ្វើឡើងក្រោមទម្រង់ជាច្រើន ដូចជាការអនុញ្ញាតឲ្យផលិតឡើងវិញ ការប្រើប្រាស់ក្នុងដំណើរការ ឬផលិតផលបន្តបន្ទាប់ទៀត ការប្រតិបត្តិអាជីវកម្មក្រោមសិទ្ធិប្រើយីហោផ្តាច់មុខ (ហ្វ្រែនឆាយ ស៍)។ល។ ម្ចាស់កម្មសិទ្ធិអាចជាឬមិនមែនជាអ្នកបង្កើតផលិតផលទាំងនេះ។

ជំពូក ឈ ៖ សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ
ផ្នែក ៧៧ ៖ សកម្មភាពជួល និងភតិសន្យា

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៧៧១			**ការជួល និងភតិសន្យាយានយន្ត**
	៧៧១០[១]		ការជួល និងភតិសន្យាយានយន្ត
		៧៧១០១	ការជួល និងភតិសន្យាខាងប្រតិបត្តិការ នូវរថយន្តដឹកអ្នកដំណើរ ដោយមិនយកអ្នកបើកបរ
		៧៧១០២	ការជួល និងភតិសន្យាខាងប្រតិបត្តិការ នូវរថយន្តដឹកទំនិញ រថយន្តសណ្តោង និងរថយន្តសម្រាប់កម្សាន្ត
៧៧២			**ការជួល និងភតិសន្យាទំនិញប្រើផ្ទាល់ខ្លួននិងសម្រាប់គ្រួសារ**
	៧៧២១[២]		ការជួល និងភតិសន្យាសម្ភារៈកម្សាន្តនិងកីឡា
		៧៧២១០	ការជួល និងភតិសន្យាសម្ភារៈកម្សាន្តនិងកីឡា
	៧៧២២		ការជួលកាសែតវីដេអូនិងឌីស
		៧៧២២០	ការជួលកាសែតវីដេអូ កាសែតខ្សែអាត់ ឌីសអុបទិក។ល។
	៧៧២៩[៣]		ការជួលនិងភតិសន្យា ទំនិញប្រើផ្ទាល់ខ្លួននិងសម្រាប់គ្រួសារដទៃទៀត
		៧៧២៩១	សំពត់តង់ តុ កៅអី និងឧបករណ៍ផ្សេងទៀតសម្រាប់ពិធីជប់លៀង និងពិធីផ្សេងៗ
		៧៧២៩២	សៀវភៅ ព្រឹត្តិបត្រ និងទស្សនាវដ្តី
		៧៧២៩៣	ផ្កា និងរុក្ខជាតិ
		៧៧២៩៩	ការជួល និងភតិសន្យាទំនិញប្រើផ្ទាល់ខ្លួន និងសម្រាប់គ្រួសារដទៃទៀត ដែលពុំបានរាប់បញ្ចូល[៤]

(១) **មិនរាប់បញ្ចូល** (ក) ការជួល ឬភតិសន្យាយានយន្ត (មើល ៤៩២២៥) ឬរថយន្តដឹកទំនិញដោយយកអ្នកបើកបរ (មើល ៤៩២៣០)
(ខ) ភតិសន្យាផ្នែកហិរញ្ញវត្ថុ (មើល ៦៤៩១០)។

(២) **រាប់បញ្ចូល** កង់ ទូក កៅអី និងធ័ត្រតាមឆ្នេរខ្សាច់
មិនរាប់បញ្ចូល (ក) ការជួលកាសែតវីដេអូនិងឌីស (មើល ៧៧២២០)
(ខ) ការជួលឧបករណ៍លំហែនិងកម្សាន្ត ដែលជាផ្នែកមួយយ៉ាងសំខាន់នៃសម្ភារៈកម្សាន្តទាំងមូល (មើល ៩៣២៩៩)។

(៣) **មិនរាប់បញ្ចូល** (ក) ការជួលរថយន្តតូច រថយន្តដឹកទំនិញ រថយន្តសណ្តោង និងរថយន្តកម្សាន្ត ដោយមិនយកអ្នកបើកបរ (មើល ៧៧១០១)
(ខ) ការជួលសម្ភារៈកម្សាន្តនិងកីឡា (មើល ៧៧២១)
(គ) ការជួលកាសែតវីដេអូនិងឌីស (មើល ៧៧២២០)
(ឃ) ការជួលម៉ូតូនិងរថយន្តទេសចរណ៍ ដោយមិនយកអ្នកបើកបរ (មើល ៧៧៣០១)
(ង) ការជួលគ្រឿងសង្ហារិមការិយាល័យ (មើល ៧៧៣០៥)
(ច) ការផ្តល់សេវាកម្មបោកសម្អាតកម្រាល ឯកសណ្ឋានការងារ និងសម្ភារៈពាក់ព័ន្ធ (មើល ៩៦០១៩)។

(៤) **រាប់បញ្ចូល** ការជួលទូរទស្សន៍ និងឧបករណ៍ជួសជុលផ្ទះ។

ជំពូក ឈ ៖ សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ
ផ្នែក ៧៧ ៖ សកម្មភាពជួល និងភតិសន្យា

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៧៧៣			**ការជួល និងភតិសន្យាគ្រឿងយន្ត ឧបករណ៍ និងទំនិញរូបីយ៍ផ្សេងទៀត**
	៧៧៣០[១]		ការជួល និងភតិសន្យាគ្រឿងយន្ត ឧបករណ៍ និងទំនិញរូបីយ៍ផ្សេងទៀត (ដោយមិនយកប្រតិបត្តិករ)
		៧៧៣០១	ការជួល និងភតិសន្យាខាងប្រតិបត្តិការ នូវឧបករណ៍ដឹកជញ្ជូនតាមផ្លូវគោក (ក្រៅពីយានយន្ត)[២]
		៧៧៣០២	ការជួល និងភតិសន្យាខាងប្រតិបត្តិការ នូវឧបករណ៍ដឹកជញ្ជូនតាមផ្លូវទឹក
		៧៧៣០៣	ការជួល និងភតិសន្យាខាងប្រតិបត្តិការ នូវគ្រឿងយន្តនិងឧបករណ៍ សម្រាប់កសិកម្មនិងរុក្ខកម្ម
		៧៧៣០៤	ការជួល និងភតិសន្យាខាងប្រតិបត្តិការ នូវគ្រឿងយន្តនិងឧបករណ៍ សម្រាប់សកម្មភាពសំណង់និងវិស្វកម្មស៊ីវិល[៣]
		៧៧៣០៥	ការជួល និងភតិសន្យាខាងប្រតិបត្តិការ នូវគ្រឿងយន្ត គ្រឿងសង្ហារិម និងឧបករណ៍ការិយាល័យ[៤]
		៧៧៣០៩	ការជួល និងភតិសន្យាគ្រឿងយន្ត ឧបករណ៍ និងទំនិញរូបីយ៍ដទៃទៀតដែលពុំបានរាប់បញ្ចូល[៥]

(១) **មិនរាប់បញ្ចូល** (ក) ការជួលគ្រឿងយន្ត និងឧបករណ៍គ្រប់ប្រភេទសម្រាប់កសិកម្ម(មើល ០១៦១០) និងរុក្ខកម្ម(មើល០២៤០០) ឬឧបករណ៍ដោយមានអមជាមួយនូវប្រតិបត្តិករ(មើល ០១៦១០, ០២៤០០ នៃផ្នែក ៤៣, ៥០, និង ៥១)

(ខ) ភតិសន្យាផ្នែកហិរញ្ញវត្ថុ (មើល ៦៤៩១០)

(គ) ការជួលទូក និងកង់កម្សាន្ត (មើល ៧៧២១០)។

(២) **រាប់បញ្ចូល** ការជួលម៉ូតូ រថយន្តទេសចរណ៍ និងរថយន្តសម្រាប់បោះជំរំ និងរថយន្តបើកលើផ្លូវដែក និងផ្លូវធម្មតា។ល។

(៣) **រាប់បញ្ចូល** ការជួល និងភតិសន្យាខាងប្រតិបត្តិការ នូវគ្រឿងយន្តនិងឧបករណ៍ សម្រាប់សកម្មភាពសំណង់ និងវិស្វកម្មស៊ីវិល ដោយមិនយកប្រតិបត្តិករ (ឧ. រថយន្តស្ទូច), រន្ទា និងទម្រការងារសំណង់ដែលមានស្រាប់ដោយគ្មានការបង្កើតនិងរុះរើ។

(៤) **រាប់បញ្ចូល** ការជួលកុំព្យូទ័រ និងឧបករណ៍បរិក្ខារកុំព្យូទ័រ ម៉ាស៊ីនថតចម្លង អង្គលីលេខ និងម៉ាស៊ីនវាយអត្ថបទ ឧបករណ៍ និងម៉ាស៊ីនគណនេយ្យ(ឧ. ម៉ាស៊ីនគិតលុយ ម៉ាស៊ីនគិតលេខអេឡិចត្រូនិក។ល។) និងគ្រឿងសង្ហារិមការិយាល័យ។

(៥) **រាប់បញ្ចូល** ការជួលកន្លែងស្នាក់នៅ ឬការិយាល័យ និងការជួលសត្វ ការជួលយន្តហោះ ម៉ាស៊ីននិងតួប៊ីន ឧបករណ៍ម៉ាស៊ីន ឧបករណ៍រុករករ៉ែនិងទាញយកប្រេង ឧបករណ៍ទាក់ទងនឹងវិទ្យុ ទូរទស្សន៍ និងគមនាគមន៍ជំនាញ ឧបករណ៍សម្រាប់ផលិតកម្មភាពយន្ត ឧបករណ៍វាស់ស្ទង់និងត្រួតពិនិត្យ និងគ្រឿងយន្តវិទ្យាសាស្ត្រ ពាណិជ្ជកម្ម និងឧស្សាហកម្មផ្សេងទៀត។

ជំពូក ឈ ៖ សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ
ផ្នែក ៧៧ ៖ សកម្មភាពជួល និងភតិសន្យា

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្ដីអធិប្បាយ
៧៧៤			**ភតិសន្យាផលិតផលកម្មសិទ្ធិបញ្ញា និងផលិតផលប្រហាក់ប្រហែល លើកលែងតែការងារដែលបានរក្សាសិទ្ធិ**
	៧៧៤០[១]		ភតិសន្យាផលិតផលកម្មសិទ្ធិបញ្ញា និងផលិតផលប្រហាក់ប្រហែល លើកលែងតែការងារដែលបានរក្សាសិទ្ធិ
		៧៧៤០០	ភតិសន្យាផលិតផលកម្មសិទ្ធិបញ្ញា និងផលិតផលប្រហាក់ប្រហែល លើកលែងតែការងារដែលបានរក្សាសិទ្ធិ[២]

(១) **មិនរាប់បញ្ចូល**

(ក) ការទិញសិទ្ធិ និងការបោះពុម្ពផ្សាយ (មើលផ្នែក ៥៨, ៥៩)

(ខ) ការផលិត ការផលិតឡើងវិញ និងការចែកចាយការងារដែលបានរក្សាសិទ្ធិរួចហើយ (ឧ. សៀវភៅ កម្មវិធីកុំព្យូទ័រ ភាពយន្ត) (មើលផ្នែក ៥៨, ៥៩)

(គ) ភតិសន្យាអចលនទ្រព្យ (មើលក្រុម ៦៨១)

(ឃ) ភតិសន្យាផលិតផលរូបីយ៍ (ទ្រព្យសកម្ម) (មើលក្រុម ៧៧១, ៧៧២, ៧៧៣)

(ង) ការជួលកាសែតវីដេអូ និងឌីស (មើល ៧៧២២០) និងសៀវភៅ (មើល ៧៧២៩២)។

(២) **រាប់បញ្ចូល**

(ក) ភតិសន្យាទ្រព្យសកម្មអរូបីយ៍មិនមែនហិរញ្ញវត្ថុ (លើកលែងតែការងារដែលបានរក្សាសិទ្ធិរួចហើយ ដូចជា សៀវភៅ ឬកម្មវិធីកុំព្យូទ័រ)

(ខ) ការទទួលបានសួយសារ ឬថ្លៃអាជ្ញាប័ណ្ណ ចំពោះការប្រើប្រាស់ប័ណ្ណប៉ាតង់ ពាណិជ្ជសញ្ញា ឬម៉ាកសញ្ញាសេវាកម្ម ម៉ាកយីហោ សិទ្ធិរុករករ៉ែ កិច្ចព្រមព្រៀងសិទ្ធិប្រើយីហោផ្តាច់មុខ និងទ្រព្យសកម្មអរូបិយ៍មិនមែនហិរញ្ញវត្ថុផ្សេងទៀត។

ផ្នែក ៧៨ ៖ សកម្មភាពពាក់ព័ន្ធនឹងការរកការងារ

ផ្នែកនេះរាប់បញ្ចូល សកម្មភាពចងក្រងឱកាសការងារ និងបញ្ជូនឬបញ្ចូលអ្នករក ការងារធ្វើឲ្យទៅធ្វើការងារ ដែលអ្នករកការងារធ្វើទាំងនោះពុំមែនជានិយោជិត របស់ទីភ្នាក់ងារការងារទេ សកម្មភាពផ្គត់ផ្គង់កម្មករទៅឲ្យអតិថិជនសម្រាប់រយៈពេលការងារកំណត់ណាមួយ ដើម្បីបំពេញបន្ថែមលើកម្លាំងពលកម្មរបស់អតិថិជន និងសកម្មភាពផ្តល់សេវាកម្មធនធាន មនុស្ស និងការគ្រប់គ្រងធនធានមនុស្ស សម្រាប់ស្ថាប័នឬអ្នកដទៃទៀតផ្អែកតាមកិច្ចសន្យា ឬ ការបង់ថ្លៃឈ្នួលជាក់ស្តែង។

ផ្នែកនេះក៏រាប់បញ្ចូលផងដែរនូវសកម្មភាពស្វែងរកនិងបញ្ជូនបុគ្គលិក និងទីភ្នាក់ងារស្វែងរកតួសម្តែង។

ផ្នែកនេះមិនរាប់បញ្ចូលសកម្មភាពរបស់ភ្នាក់ងារវិចិត្រករនីមួយៗទេ (មើល ៧៤៩០)។

ក្រុម ៧៨១ ៖ សកម្មភាពទីភ្នាក់ងារស្វែងរកការងារ

ក្រុមនេះរាប់បញ្ចូល សកម្មភាពចងក្រងឱកាសការងារ និងបញ្ជូនឬបញ្ចូលអ្នករកការងារធ្វើឲ្យទៅធ្វើការងារ ដែលអ្នករកការងារធ្វើទាំងនោះពុំមែនជានិយោជិត របស់ទីភ្នាក់ងារការងារទេ។

ក្រុម ៧៨២ ៖ សកម្មភាពទីភ្នាក់ងារស្វែងរកការងារបណ្តោះអាសន្ន

ក្រុមនេះរាប់បញ្ចូលសកម្មភាពនៃការផ្គត់ផ្គង់កម្មករទៅឲ្យអតិថិជន សម្រាប់រយៈពេលការងារកំណត់ណាមួយ ដើម្បីជំនួសឬបំពេញបន្ថែមជាបណ្តោះអាសន្ន ទៅលើកម្លាំងពលកម្មរបស់អតិថិជន ដែលកម្មករត្រូវផ្គត់ផ្គង់ឲ្យនោះជានិយោជិតរបស់អង្គភាពសេវាកម្មជំនួយបណ្តោះអាសន្ន។ ទោះជាយ៉ាងនេះក្តី អង្គភាពដែលចាត់ថ្នាក់នៅក្នុងក្រុមនេះ មិនផ្តល់ការគ្រប់គ្រងផ្ទាល់ ទៅលើនិយោជិតរបស់ខ្លួននៅកន្លែងការងាររបស់អតិថិជនឡើយ។

ក្រុម ៧៨៣ ៖ ការផ្តល់សេវាកម្មធនធានមនុស្សផ្សេងទៀត

ក្រុមនេះរាប់បញ្ចូល ការផ្តល់សេវាកម្មធនធានមនុស្សទៅឲ្យអតិថិជនជាអាជីវកម្ម។ ការផ្តល់សេវាកម្មធនធានមនុស្សនេះ ជាធម្មតាអនុវត្តក្នុងរយៈពេលវែងឬជាអចិន្ត្រៃយ៍ ហើយអង្គភាពដែលចាត់ថ្នាក់នៅក្នុងក្រុមនេះអាចអនុវត្តកាតព្វកិច្ចជាច្រើនទាក់ទងនឹងធនធាន មនុស្ស និងការគ្រប់គ្រងបុគ្គលិកដែលជាប់ពាក់ព័ន្ធនឹងការផ្តល់សេវាកម្មនេះ។ អង្គភាពដែលចាត់ថ្នាក់នៅក្នុងក្រុមនេះតំណាងឲ្យនិយោជក ក្នុងការកត់ត្រាបញ្ហាពាក់ព័ន្ធនឹងនិយោជិតដូច ជាបញ្ជីប្រាក់បៀវត្សរ៍ ពន្ធដារ និងបញ្ហាសារពើពន្ធ និងធនធានមនុស្សផ្សេងទៀតប៉ុន្តែអង្គភាពទាំងនេះមិនទទួលខុសត្រូវ ចំពោះការចាត់ចែងនិងការគ្រប់គ្រងនិយោជិតឡើយ។

ជំពូក ឈ ៖ សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ
ផ្នែក ៧៨ ៖ សកម្មភាពពាក់ព័ន្ធនឹងការរកការងារ

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៧៨១			**សកម្មភាពទីភ្នាក់ងារស្វែងរកការងារ**
	៧៨១០[១]		សកម្មភាពទីភ្នាក់ងារស្វែងរកការងារ
		៧៨១០០	សកម្មភាពទីភ្នាក់ងារស្វែងរកការងារ[២]
៧៨២			**សកម្មភាពទីភ្នាក់ងារស្វែងរកការងារបណ្តោះអាសន្ន**
	៧៨២០		សកម្មភាពទីភ្នាក់ងារស្វែងរកការងារបណ្តោះអាសន្ន
		៧៨២០០	សកម្មភាពទីភ្នាក់ងារស្វែងរកការងារបណ្តោះអាសន្ន[៣]
៧៨៣			**ការផ្តល់សេវាកម្មធនធានមនុស្សផ្សេងទៀត**
	៧៨៣០[៤]		ការផ្តល់សេវាកម្មធនធានមនុស្សផ្សេងទៀត
		៧៨៣០០	ការផ្តល់សេវាកម្មធនធានមនុស្សសម្រាប់អតិថិជនជាអាជីវកម្ម

(១) **មិនរាប់បញ្ចូល** សកម្មភាពរបស់ភ្នាក់ងារ ឬទីភ្នាក់ងារសម្តែងល្ខោនផ្ទាល់ខ្លួន ឬសិល្បៈ(មើល ៧៤៩០០)។

(២) **រាប់បញ្ចូល**
- (ក) សកម្មភាពចងក្រងឱកាសការងារ និងបញ្ជូនឬបញ្ចូលអ្នករកការងារធ្វើឲ្យទៅធ្វើការងារ ដែលអ្នករកការងារធ្វើទាំងនោះពុំមែនជានិយោជិតរបស់ទីភ្នាក់ងារការងារទេ
- (ខ) ការស្វែងរកបុគ្គលិក សកម្មភាពជ្រើសរើស និងស្វែងរកការងារ រួមមានសកម្មភាពជ្រើសរើសបុគ្គលិក និងស្វែងរកការងារ
- (គ) សកម្មភាពរបស់ទីភ្នាក់ងារនិងការិយាល័យរកតួសម្តែង ដូចជាទីភ្នាក់ងារស្វែងរកតួសម្តែង
- (ឃ) សកម្មភាពរបស់ទីភ្នាក់ងារស្វែងរកការងារតាមប្រព័ន្ធអ៊ីនធឺណិត។

(៣) **រាប់បញ្ចូល** ការផ្គត់ផ្គង់កម្មករទៅឲ្យអតិថិជន សម្រាប់រយៈពេលការងារកំណត់ណាមួយ ដើម្បីជំនួសឬបំពេញបន្ថែមជាបណ្តោះអាសន្ន ទៅលើកម្លាំងពលកម្មរបស់អតិថិជន ដែលកម្មករត្រូវផ្គត់ផ្គង់ឲ្យនោះជានិយោជិតរបស់អង្គភាពសេវាកម្មជំនួយបណ្តោះអាសន្ន ប៉ុន្តែអង្គភាពទាំងនេះមិនផ្តល់ការគ្រប់គ្រងផ្ទាល់ ទៅលើនិយោជិតរបស់ខ្លួននៅកន្លែងការងាររបស់អតិថិជនទេ ការផ្តល់សេវាកម្មធនធានមនុស្សដើម្បីជំនួសឬបំពេញបន្ថែមបណ្តោះអាសន្នទៅលើកម្លាំងពលកម្មរបស់អតិថិជន។

(៤) **មិនរាប់បញ្ចូល**
- (ក) ការផ្តល់សេវាកម្មមុខងារធនធានមនុស្សព្រមជាមួយការគ្រប់គ្រង ឬការធ្វើប្រតិបត្តិការអាជីវកម្ម (មើលថ្នាក់ក្នុងសកម្មភាពសេដ្ឋកិច្ចនីមួយៗនៃអាជីវកម្មនោះ)
- (ខ) ការផ្តល់សេវាកម្មធនធានមនុស្ស ដើម្បីជំនួសឬបំពេញបន្ថែមបណ្តោះអាសន្នទៅលើកម្លាំងពលកម្មរបស់អតិថិជន (មើល ៧៨២០០)។

ផ្នែក ៧៩ ៖ សកម្មភាពរបស់ទីភ្នាក់ងារទេសចរណ៍និងប្រតិបត្តិករទេសចរណ៍ សេវាកម្មកក់បម្រុងទុក និងសកម្មភាពពាក់ព័ន្ធ

ផ្នែកនេះរាប់បញ្ចូលនូវសកម្មភាពលក់សេវាកម្មធ្វើដំណើរ សេវាកម្មទេសចរណ៍ សេវាកម្មដឹកជញ្ជូន និងសេវាកម្មស្នាក់នៅ ទៅឲ្យអតិថជនទូទៅ និងអតិថិជនពាណិជ្ជកម្ម។ បន្ថែមលើនេះក៏មានសកម្មភាពរៀបចំ និងប្រមូលផ្តុំទេសចរណ៍ ដែលត្រូវបានលក់តាមរយៈទីភ្នាក់ងារទេសចរណ៍ ឬលក់ដោយផ្ទាល់ទៅឲ្យភ្នាក់ងារទេសចរណ៍ ដែលមានដូចជាប្រតិបត្តិករទេសចរណ៍ និងសេវាកម្មទេសចរណ៍ពាក់ព័ន្ធផ្សេងទៀត រាប់បញ្ចូលទាំងសេវាកម្មកក់បម្រុងទុកនានាផងដែរ។ សកម្មភាពមគ្គុទ្ទេសក៍ទេសចរណ៍ និងសកម្មភាពផ្សព្វផ្សាយទេសចរណ៍ ក៏ត្រូវបានរាប់បញ្ចូលផងដែរ។

ក្រុម ៧៩១ ៖ សកម្មភាពទីភ្នាក់ងារទេសចរណ៍ និងប្រតិបត្តិករទេសចរណ៍

ក្រុមនេះរាប់បញ្ចូលសកម្មភាពនានារបស់ភ្នាក់ងារដែលចូលរួមជាចម្បងនឹងការលក់សេវាកម្មធ្វើដំណើរ សេវាកម្មទេសចរណ៍ សេវាកម្មដឹកជញ្ជូន និងសេវាកម្មស្នាក់នៅ ទៅឲ្យអតិថិជនទូទៅ និងអតិថិជនពាណិជ្ជកម្ម ក៏ដូចជាសកម្មភាពរៀបចំ និងប្រមូលផ្តុំទេសចរណ៍ ដែលត្រូវបានលក់តាមរយៈទីភ្នាក់ងារទេសចរណ៍ឬលក់ដោយផ្ទាល់ទៅឲ្យភ្នាក់ងារទេស ចរណ៍ ដូចជាប្រតិបត្តិករទេសចរណ៍ជាដើម។

ក្រុម ៧៩៩ ៖ សេវាកម្មកក់បម្រុងទុកផ្សេងទៀត និងសកម្មភាពពាក់ព័ន្ធនានា

ក្រុមនេះរាប់បញ្ចូលនូវការផ្តល់សេវាកម្មកក់បម្រុងទុកផ្សេងទៀត ទាក់ទងនឹងទេស ចរណ៍ ដូចជា ការកក់បម្រុងទុកសម្រាប់ការដឹកជញ្ជូន សណ្ឋាគារ ភោជនីយដ្ឋាន រថយន្តជួល ការកម្សាន្ត និងកីឡា។ល។ បន្ថែមពីលើនេះក៏មានការផ្តល់នូវសេវាកម្មជួលកន្លែងស្នាក់នៅរយៈពេលខ្លីឲ្យទេសចរ សកម្មភាពលក់សំបុត្រសម្រាប់ការសម្តែងសិល្បៈ កីឡា និងល្បែង កម្សាន្តដទៃទៀត និងព្រឹត្តិការណ៍កម្សាន្ត។ វាក៏មានការផ្តល់ជំនួយដល់ទេសចរ ជាអាទិ៍ ការផ្តល់ព័ត៌មានទៅទេសចរនិងសកម្មភាពមគ្គុទ្ទេសក៍ទេសចរណ៍។ វាក៏មានផងដែរនូវសកម្មភាព ផ្សព្វផ្សាយទេសចរណ៍នានា។

ជំពូក ឍ ៖ សកម្មភាពរដ្ឋបាល និងសេវាគាំទ្រ

ផ្នែក ៧៩ ៖ សកម្មភាពរបស់ទីភ្នាក់ងារទេសចរណ៍ សកម្មភាពរបស់ប្រតិបត្តិករទេសចរណ៍ សេវាកម្មកក់បម្រុងទុក និងសកម្មភាពពាក់ព័ន្ធ

ក្រុម	ថ្នាក់	ថ្នាក់រង	ការអធិប្បាយ
៧៩១			**សកម្មភាពទីភ្នាក់ងារទេសចរណ៍ និងប្រតិបត្តិករទេសចរណ៍**
	៧៩១១		សកម្មភាពទីភ្នាក់ងារទេសចរណ៍[(១)]
		៧៩១១០	សកម្មភាពទីភ្នាក់ងារទេសចរណ៍
	៧៩១២		សកម្មភាពប្រតិបត្តិករទេសចរណ៍
		៧៩១២០	សកម្មភាពប្រតិបត្តិករទេសចរណ៍[(២)]
៧៩៩			**សេវាកម្មកក់បម្រុងទុកផ្សេងទៀត និងសកម្មភាពពាក់ព័ន្ធ**
	៧៩៩០[(៣)]		សេវាកម្មកក់បម្រុងទុកផ្សេងទៀត និងសកម្មភាពពាក់ព័ន្ធ
		៧៩៩០០	សេវាកម្មកក់បម្រុងទុកផ្សេងទៀត និងសកម្មភាពពាក់ព័ន្ធ[(៤)]

(១) **រាប់បញ្ចូល** សកម្មភាពរបស់ភ្នាក់ងារទេសចរណ៍ ដែលចូលរួមជាចម្បងនឹងការលក់សេវាកម្មធ្វើដំណើរ សេវាកម្មទេសចរណ៍ សេវាកម្មដឹកជញ្ជូន និងសេវាកម្មស្នាក់នៅ ក្រោមរូបភាពជាការលក់ដុំ ឬលក់រាយទៅឲ្យអតិថិជនទូទៅ និងអតិថិជនពាណិជ្ជកម្ម។

(២) **រាប់បញ្ចូល** សកម្មភាពរៀបចំ និងប្រមូលផ្តុំទេសចរណ៍ ដែលត្រូវបានលក់តាមរយៈភ្នាក់ងារទេសចរណ៍ ឬលក់ដោយផ្ទាល់តាមរយៈប្រតិបត្តិករទេសចរណ៍។ វាក៏រាប់បញ្ចូលផងដែរនូវសកម្មភាពមគ្គុទ្ទេសក៍ទេសចរណ៍។

(៣) **មិនរាប់បញ្ចូល** (ក) សកម្មភាពទីភ្នាក់ងារទេសចរណ៍ (មើល ៧៩១១០) និងសកម្មភាពប្រតិបត្តិករទេសចរណ៍ (មើល ៧៩១២០)
(ខ) ការរៀបចំ និងគ្រប់គ្រងព្រឹត្តិការណ៍ ដែលមានដូចជាការប្រជុំ សន្និបាត និងសន្និសីទ (មើល ៨២៣០)។

(៤) **រាប់បញ្ចូល** (ក) សកម្មភាពផ្សព្វផ្សាយ និងស្វែងយល់ពីទីផ្សាររបស់សេវា សម្រាប់សន្និបាត និងសម្រាប់អ្នកទស្សនាដោយផ្តល់ព័ត៌មាន និងផ្តល់ជំនួយដល់ស្ថាប័នដើម្បីរកកន្លែងស្នាក់នៅ
(ខ) មជ្ឈមណ្ឌលសន្និបាត និងកន្លែងកម្សាន្ត
(គ) សេវាកម្មជួលសហវិជិតរាជ្យ(ខុនដូ)រយៈពេលខ្លីឲ្យទេសចរ
(ឃ) សកម្មភាពភ្នាក់ងារលក់សំបុត្រ
(ង) សេវាកម្មកក់បម្រុងទុកផ្សេងទៀតទាក់ទងនឹងទេសចរណ៍។

ផ្នែក ៨០ ៖ សកម្មភាពរក្សាសន្តិសុខ និងស៊ើបអង្កេត

ផ្នែកនេះរាប់បញ្ចូលសេវាកម្មពាក់ព័ន្ធនឹងសន្តិសុខ ដូចជា ៖ សេវាកម្មស៊ើបអង្កេតនិងភ្នាក់ងារស៊ើបអង្កេត សេវាកម្មយាមកាមនិងល្បាត ការប្រមូលនិងដឹកជញ្ជូនប្រាក់ ប័ណ្ណចំណូល ឬវត្ថុមានតម្លៃផ្សេងទៀត ដោយផ្តល់នូវបុគ្គលិកនិងគ្រឿងបរិក្ខារ ដើម្បីការពារទ្រព្យសម្បត្តិទាំងនោះក្នុងពេលដឹកជញ្ជូន ប្រតិបត្តិការប្រព័ន្ធប្រកាសអាសន្នអេឡិចត្រូនិច ដូចជា ប្រកាសអាសន្នពីអគ្គិភ័យ និងចោរកម្ម ដែលសកម្មភាពទាំងនេះផ្តោតលើប្រព័ន្ធត្រួតពិនិត្យពីចម្ងាយ ហើយក៏រាប់បញ្ចូលសកម្មភាពលក់ដំឡើង និងជួសជុលផងដែរ។ ប្រសិនបើសកម្មភាពទាំងអម្បាលម៉ានរៀបរាប់ចុងក្រោយនេះ (គឺសកម្មភាពលក់ ដំឡើង និងជួសជុល) ត្រូវបានផ្តត់ផ្គង់ដាច់ដោយឡែកពីសមាសភាពសកម្មភាពដទៃទៀត នោះត្រូវចាត់ថ្នាក់ទៅក្នុងសកម្មភាពលក់រាយសំណង់។ល។ ទៅវិញ។

ក្រុម ៨០១ ៖ សកម្មភាពរក្សាសន្តិសុខឯកជន

ក្រុមនេះរាប់បញ្ចូលនូវ ការផ្តល់សកម្មភាពមួយឬច្រើន ដូចជា សេវាកម្មយាមកាមនិងល្បាត និងការប្រមូលនិងដឹកជញ្ជូនប្រាក់ ប័ណ្ណចំណូល ឬវត្ថុមានតម្លៃផ្សេងទៀត ដោយផ្តល់នូវបុគ្គលិកនិងគ្រឿងបរិក្ខារ ដើម្បីការពារទ្រព្យសម្បត្តិទាំងនោះក្នុងពេលដឹកជញ្ជូន។

ក្រុម ៨០២ ៖ សកម្មភាពសេវាកម្មប្រព័ន្ធសុវត្ថិភាព

ក្រុមនេះរាប់បញ្ចូលនូវការត្រួតពិនិត្យ ឬការត្រួតពិនិត្យពីចម្ងាយ លើប្រព័ន្ធប្រកាសអាសន្នអេឡិចត្រូនិច ដូចជា ប្រកាសអាសន្នពីចោរកម្មនិងអគ្គិភ័យ ហើយរាប់បញ្ចូលផងដែរនូវការថែទាំនិងដំឡើង ការជួសជុល ការសង់ឡើងវិញ និងកែសម្រួល គន្លឹះសោរ ទូដែក និងទូដែកសុវត្ថិភាព ប្រភេទជាគ្រឿងយន្ត ឬអេឡិចត្រូនិច។

ក្រុមដែលអនុវត្តនូវសកម្មភាពទាំងនេះ អាចនឹងត្រូវចូលរួមក្នុងការលក់ផងដែរ ដែលមានដូចជាប្រព័ន្ធសុវត្ថិភាព គន្លឹះសោរ ទូដែក និងទូដែកសុវត្ថិភាព ប្រភេទជាគ្រឿងយន្ត ឬអេឡិចត្រូនិច។

ក្រុម ៨០៣ ៖ សកម្មភាពស៊ើបអង្កេត

ក្រុមនេះរាប់បញ្ចូលសេវាកម្មស៊ើបអង្កេតនិងចារកម្ម និងសកម្មភាពរបស់ភ្នាក់ងារស៊ើបអង្កេតឯកជនទាំងអស់ ដោយមិនប្រកាន់អំពីប្រភេទអតិថិជន ឬគោលបំណងនៃការស៊ើបអង្កេតឡើយ។

ជំពូក ឈ ៖ សកម្មភាពរដ្ឋបាល និងសេវាគាំទ្រ
ផ្នែក ៨០ ៖ សកម្មភាពរក្សាសន្តិសុខ និងស៊ើបអង្កេត

ក្រុម	ថ្នាក់	ថ្នាក់រង	ការអធិប្បាយ
៨០១			**សកម្មភាពរក្សាសន្តិសុខឯកជន**
	៨០១០[១]		សកម្មភាពរក្សាសន្តិសុខឯកជន
		៨០១០០	សកម្មភាពរក្សាសន្តិសុខឯកជន[២]
៨០២			**សកម្មភាពសេវាកម្មប្រព័ន្ធសុវត្ថិភាព**
	៨០២០[៣]		សកម្មភាពសេវាកម្មប្រព័ន្ធសុវត្ថិភាព
		៨០២០០	សកម្មភាពសេវាកម្មប្រព័ន្ធសុវត្ថិភាព[៤]
៨០៣			**សកម្មភាពស៊ើបអង្កេត**
	៨០៣០		សកម្មភាពស៊ើបអង្កេត
		៨០៣០០	សកម្មភាពស៊ើបអង្កេត និងចារកម្ម[៥]

(១) **មិនរាប់បញ្ចូល** សកម្មភាពសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព (មើល ៨៤២៣)។

(២) **រាប់បញ្ចូល** ការផ្តល់សកម្មភាពមួយឬច្រើន ដូចជា សេវាកម្មយាមកាមនិងល្បាត និងការប្រមូល និងដឹកជញ្ជូនប្រាក់ ប័ណ្ណចំណូល ឬវត្ថុមានតម្លៃផ្សេងទៀត ដោយផ្តល់នូវបុគ្គលិក និងគ្រឿងបរិក្ខារ ដើម្បីការពារទ្រព្យសម្បត្តិទាំងនោះក្នុងពេលដឹកជញ្ជូន (ឧ. សេវាកម្មរថយន្តស្រោបដែក សេវាកម្មអង្គរក្សការពារ សេវាកម្មថតសំឡេង សេវាកម្មផ្តិតស្នាមម្រាមដៃ និងសេវាកម្មសន្តិសុខយាមកាម)។

(៣) **មិនរាប់បញ្ចូល**
- (ក) ការដំឡើងប្រព័ន្ធសុវត្ថិភាព (មើល ៤៣២១០)
- (ខ) ការលក់ប្រព័ន្ធសុវត្ថិភាព គន្លឹះសោរ ទូដែក និងទូដែកសុវត្ថិភាព ប្រភេទជាគ្រឿងយន្ត ឬអេឡិចត្រូនិច ដោយមិនផ្តល់សេវាកម្មត្រួតពិនិត្យ ដំឡើង ឬថែទាំ (មើល ៤៧៥៩៧)
- (គ) ទីប្រឹក្សាផ្នែករក្សាសន្តិសុខ (មើល ៧៤៩០០)
- (ឃ) សកម្មភាពសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព (មើល ៨៤២៣)
- (ង) ការផ្តល់សេវាកម្មចម្លងសោរ (មើល ៩៥២៩៩)។

(៤) **រាប់បញ្ចូល**
- (ក) សកម្មភាពលក់ ត្រួតពិនិត្យ ឬត្រួតពិនិត្យពីចម្ងាយនូវប្រព័ន្ធប្រកាសអាសន្នអេឡិចត្រូនិច (ឧ. ការប្រកាសអាសន្នអំពីចោរកម្ម និងអគ្គិភ័យ) រួមទាំងសេវាកម្មថែទាំផងដែរ
- (ខ) សកម្មភាពលក់ ដំឡើង ជួសជុល សង់ឡើងវិញ និងកែសម្រួល គន្លឹះសោរ ទូដែក និងទូដែកសុវត្ថិភាព ប្រភេទជាគ្រឿងយន្ត ឬអេឡិចត្រូនិច។

(៥) **រាប់បញ្ចូល** សកម្មភាពភ្នាក់ងារស៊ើបអង្កេតឯកជន ដែលមិនប្រកាន់អំពីប្រភេទអតិថិជន ឬគោលបំណងនៃការស៊ើបអង្កេត។

ផ្នែក ៨១ ៖ សកម្មភាពសេវាកម្មពាក់ព័ន្ធនឹងអគារ និងសោភ័ណភាព

ផ្នែកនេះរាប់បញ្ចូល សកម្មភាពផ្គត់ផ្គង់សេវាកម្មគាំទ្រទូទៅជាច្រើន ដូចជា ការផ្តល់សេវាកម្មគាំទ្រចម្រុះបែប ដល់ទីកន្លែងរបស់អតិថិជន ការសម្អាតផ្ទៃខាងក្នុងនិងខាងក្រៅនៃអគារគ្រប់ប្រភេទ ការសម្អាតម៉ាស៊ីនឧស្សាហកម្ម ការសម្អាតរថភ្លើង រថយន្តក្រុង យន្តហោះ។ល។ ការសម្អាតផ្ទៃខាងក្នុងយានយន្តដឹកឥន្ទនៈឬវត្ថុរាវផ្សេងទៀត តាមផ្លូវគោកនិងសមុទ្រ សកម្មភាពសម្លាប់មេរោគក្នុងអគារ នាវា រថភ្លើង។ល។ ការសម្អាតដប ការបោសសម្អាតផ្លូវ ការកៀរសម្អាតទឹកកកនិងព្រិល ការផ្តល់សេវាកម្មថែរក្សាសោភ័ណភាព រួមទាំងការផ្តល់សេវាកម្មទាំងអស់នេះ ដោយមានអមជាមួយនឹងការរចនាគម្រោងរៀបចំសោភ័ណភាព ឬសកម្មភាពសាងសង់ចិញ្ចើមផ្លូវសម្រាប់ថ្មើរជើង ជណ្តើរស្ពានសម្រាប់ឆ្លងផ្លូវ របង ស្រះ និងប្រភេទសំណង់ស្រដៀងនេះ។

ក្រុម ៨១១ ៖ សេវាកម្មគាំទ្រចម្រុះបែបដល់ទីកន្លែង

ក្រុមនេះរាប់បញ្ចូល ការផ្តល់សេវាកម្មគាំទ្រចម្រុះបែប ដល់ទីកន្លែងរបស់អតិថិជន ដូចជា ការសម្អាតទូទៅនៃផ្ទៃខាងក្នុងទីកន្លែង ការថែទាំ ការយកសំរាមទៅចោល ការរក្សាសន្តិសុខនិងយាមកាម ការរត់សំបុត្រ បដិសណ្ឋារកិច្ច ការបោកគក់ និងសេវាកម្មពាក់ព័ន្ធនានា ដើម្បីគាំទ្រដល់សកម្មភាពសម្រួលការងារដល់ទីកន្លែង។

អង្គភាពដែលបានចាត់ថ្នាក់នៅទីនេះ ផ្តល់តែបុគ្គលិកដើម្បីធ្វើសកម្មភាពគាំទ្រទាំងនេះប៉ុន្តែមិនពាក់ព័ន្ធឬទទួលខុសត្រូវ ចំពោះសកម្មភាពឬអាជីវកម្មចម្បងរបស់អតិថិជនឡើយ។

ក្រុម ៨១២ ៖ សេវាកម្មសម្អាត

ក្រុមនេះរាប់បញ្ចូល សកម្មភាពសម្អាតទូទៅនៃផ្ទៃខាងក្នុងអគារគ្រប់ប្រភេទ, ការសម្អាតផ្ទៃខាងក្រៅអគារ សកម្មភាពសម្អាតតាមឯកទេសសម្រាប់អគារ ឬសកម្មភាពសម្អាតតាមឯកទេសផ្សេងទៀត ការសម្អាតម៉ាស៊ីនឧស្សាហកម្ម ការសម្អាតយានយន្តដឹកឥន្ទនៈឬវត្ថុជាតុរាវ តាមផ្លូវគោកនិងសមុទ្រ សកម្មភាពសម្លាប់មេរោគ សម្រាប់អគារនិងម៉ាស៊ីនឧស្សាហកម្ម ការសម្អាតដប ការបោសសម្អាតផ្លូវ ការកៀរសម្អាតទឹកកកនិងព្រិល។

ក្រុមនេះមិនរាប់បញ្ចូលនូវ ការគ្រប់គ្រងកត្តាចង្រៃខាងកសិកម្ម (ផ្នែកកសិកម្ម) សកម្មភាពសម្អាតដោយចំហាយទឹកខាត់ខ្សាច់ និងសកម្មភាពប្រហាក់ប្រហែល សម្រាប់ផ្ទៃខាងក្រៅអគារ (ផ្នែកសំណង់) ការសម្អាតព្រំនិងកម្រាលព្រំដោយសាប៊ូ ការសម្អាតវាំងនននិងបាំង (ផ្នែកសេវាកម្មផ្សេងទៀត)។ ការសម្អាតអគារថ្មី ភ្លាមៗបន្ទាប់ពីសាងសង់រួច ក៏មិនត្រូវបានរាប់បញ្ចូលផងទេ (ផ្នែកសំណង់)។

ក្រុម ៨១៣ ៖ សេវាកម្មរៀបចំ និងថែរក្សាសោភ័ណភាព

ក្រុមនេះរាប់បញ្ចូលសកម្មភាពដាំ លម្អ និងថែទាំនូវ សួនច្បារ និងឧទ្យានសម្រាប់លំនៅដ្ឋានឯកជន និងសាធារណៈ អគារសាធារណៈ និងពាក់កណ្តាលសាធារណៈ (សាលា រៀន មន្ទីពេទ្យ អគាររដ្ឋបាល អគារវិហារសាសនា។ល។) បរិវេណសាលាក្រុង(សួនច្បារ តំបន់បៃតង កន្លែងបញ្ចុះសព។ល។) រុក្ខជាតិនៅតាមមហាវិថី(ផ្លូវថ្នល់ ផ្លូវរថភ្លើង ផ្លូវទឹក កំពង់ផែ) អគារឧស្សាហកម្ម និងអគារពាណិជ្ជកម្ម រុក្ខជាតិនៅតាមអគារ(សួនច្បារលើដំបូល រុក្ខជាតិនៅតាមយ៉ខាងមុខ សួនច្បារខាងក្នុងអគារ) បរិវេណកីឡា (ទីលានបាល់ទាត់ កន្លែងវាយកូនគោល។ល។) បរិវេណសួនកុមារ ទីធ្លាមានដាំស្មៅសម្រាប់គេងហាលថ្ងៃ និងសួន កម្សាន្តផ្សេងទៀត កន្លែងមានទឹកស្តុក និងទឹកហូរ (អាងទឹក ស្រះ អាងហែលទឹក ប្រឡាយ ផ្លូវទឹក ប្រព័ន្ធលូ) និងរុក្ខជាតិដាំដុះដើម្បីទប់ទល់នឹងការបំពងសំឡេង ខ្យល់ សំណឹក គំហើញ និងចំណាំងពន្លឺ។ ការថែទាំដីដើម្បីរក្សាឲ្យស្ថិតនៅក្នុងលក្ខខណ្ឌមានជីវចម្រុះល្អ ក៏ត្រូវបានរាប់បញ្ចូលផងដែរ។

ជំពូក ឈ ៖ សកម្មភាពរដ្ឋបាល និងសេវាគាំទ្រ
ផ្នែក ៨១ ៖ សកម្មភាពសេវាកម្មពាក់ព័ន្ធនឹងអគារ និងសោភ័ណភាព

ក្រុម	ថ្នាក់	ថ្នាក់រង	ការអធិប្បាយ
៨១១			**សេវាកម្មគាំទ្រចម្រុះបែបដល់ទីកន្លែង**
	៨១១០[១]		សេវាកម្មគាំទ្រចម្រុះបែបដល់ទីកន្លែង
		៨១១០០	សេវាកម្មគាំទ្រចម្រុះបែបដល់ទីកន្លែង[២]
៨១២			**សេវាកម្មសម្អាត**
	៨១២១[៣]		ការសម្អាតទូទៅចំពោះអគារ
		៨១២១០	ការសម្អាតទូទៅចំពោះអគារ

(១) **មិនរាប់បញ្ចូល**
(ក) ការផ្តល់សេវាកម្មគាំទ្រតែមួយមុខ ក្នុងចំណោមសេវាកម្មគាំទ្រទាំងនោះ (ឧ. សេវាកម្មសម្អាតទូទៅចំពោះផ្ទៃខាងក្នុង) ឬបំពេញមុខងារទោល (ឧ. ការកម្តៅ) (មើលថ្នាក់ដែលសមស្រប ទៅតាមសេវាកម្មដែលបានផ្តល់ឲ្យ)
(ខ) ការផ្តល់ការគ្រប់គ្រងនិងបុគ្គលិក សម្រាប់ប្រតិបត្តិការពេញលេញដល់ស្ថាប័នរបស់អតិថិជន (ឧ. សណ្ឋាគារ ភោជនីយដ្ឋាន អណ្តូងរ៉ែ ឬមន្ទីរពេទ្យ) (មើលថ្នាក់ដែលចែងអំពីអង្គភាពប្រតិបត្តិការបែបនេះ)
(គ) ការផ្តល់ការគ្រប់គ្រង និងប្រតិបត្តិការនៅនឹងកន្លែងដល់ប្រព័ន្ធកំព្យូទ័ររបស់អតិថិជន ឬដំណើរការបញ្ចូលទិន្នន័យ (មើល ៦២០២០)
(ឃ) ប្រតិបត្តិការកិច្ចសម្រួលការខាងកែតម្រូវ ផ្អែកតាមកិច្ចសន្យា ឬតាមការបង់ថ្លៃឈ្នួលជាក់ស្តែង (មើល ៨៤២៣៩)។

(២) **រាប់បញ្ចូល** ការផ្តល់នូវ សេវាកម្មគាំទ្រចម្រុះបែប ដល់ទីកន្លែងរបស់អតិថិជន (ឧ. ការសម្អាតផ្ទៃខាងក្នុងទូទៅ ការថែទាំ ការយកសំរាមបោះចោល សន្តិសុខនិងការយាមកាម ការបញ្ជូនសំបុត្រ បដិសណ្ឋារកិច្ច ការបោកគក់) និងសេវាពាក់ព័ន្ធដើម្បីគាំទ្រដល់ប្រតិបត្តិការនានានៅក្នុងទីកន្លែង ប៉ុន្តែមិនពាក់ព័ន្ធ ឬជាប់ទំនួលខុសត្រូវចំពោះសកម្មភាពឬអាជីវកម្មចម្បងរបស់អតិថិជន ការគ្រប់គ្រងទីកន្លែងនានា ដូចជា មូលដ្ឋានទ័ព ពន្ធនាគារ និងអគារ ឬទីកន្លែងផ្សេងទៀត (លែកលែងការគ្រប់គ្រងសម្ភារៈកំព្យូទ័រ)។

(៣) **មិនរាប់បញ្ចូល** សកម្មភាពសម្អាតតាមឯកទេសសម្រាប់ផ្ទៃខាងក្នុង (ឧ. ការសម្អាតបំពង់ផ្សែង ការសម្អាតជើងក្រាន ឡ ឡដុតសំរាម ផ្ទាំងដាំទឹក បំពង់បញ្ចូលខ្យល់ បំពង់ផ្សែង) (មើល ៨១២៩៩)។

ជំពូក ៧ ៖ សកម្មភាពរដ្ឋបាល និងសេវាគាំទ្រ

ផ្នែក ៨១ ៖ សកម្មភាពសេវាកម្មពាក់ព័ន្ធនឹងអគារ និងសោភ័ណភាព

ក្រុម	ថ្នាក់	ថ្នាក់រង	ការអធិប្បាយ
	៨១២៩[១]		សកម្មភាពសម្អាតអគារ និងសម្អាតខាងឧស្សាហកម្មផ្សេងទៀត
		៨១២៩១	សេវាសម្អាត និងថែទាំអាងហែលទឹក
		៨១២៩២	សកម្មភាពសម្លាប់មេរោគក្នុងអគារ
		៨១២៩៩	ការសម្អាតតាមឯកទេសផ្សេងទៀតលើអគារ និងការសម្អាតតំបន់ឧស្សាហកម្ម និងផ្លូវថ្នល់
៨១៣			**សកម្មភាពរៀបចំ និងថែរក្សាសោភ័ណភាព**
	៨១៣០[២]		សកម្មភាពរៀបចំ និងថែរក្សាសោភ័ណភាព
		៨១៣០០	សកម្មភាពរៀបចំ និងថែរក្សាសោភ័ណភាព[៣]

(១) **មិនរាប់បញ្ចូល**
(ក) ការគ្រប់គ្រងកត្តាចង្រៃខាងកសិកម្ម (មើល ០១៦១០)
(ខ) ការសម្អាតលូទឹកស្អុយ និងបំពង់បង្ហូរទឹក (មើល ៣៧០០០)
(គ) ការសម្អាតយានយន្ត ការលាងរថយន្ត (មើល ៤៥២០៣)។

(២) **មិនរាប់បញ្ចូល**
(ក) ផលិតកម្មសម្រាប់អាជីវកម្ម និងការដាំដុះសម្រាប់ធ្វើអាជីវកម្ម នូវរុក្ខជាតិដើមឈើ (មើលផ្នែក ០១ និង ០២) សកម្មភាពបណ្តុះកូនឈើ (លើកលែងតែការបណ្តុះកូនឈើព្រៃ) (មើល ០១៣០១)
(ខ) ការថែទាំដីឲ្យមានគុណភាពល្អសម្រាប់ការធ្វើកសិកម្ម (មើល ០១៦១០)
(គ) សកម្មភាពសាងសង់ដើម្បីសោភ័ណភាព (មើលជំពូក«ច»)
(ឃ) សកម្មភាពរចនា និងស្ថាបត្យកម្មខាងសោភ័ណភាព (មើល ៧១១០)
(ង) ប្រតិបត្តិការសួនច្បាររុក្ខជាតិ (មើល ៩១០៣១)

(៣) **រាប់បញ្ចូល**
(ក) ការដាំ លម្អ និងថែទាំនូវ សួនច្បារ និងឧទ្យានសម្រាប់លំនៅដ្ឋានឯកជន និងសាធារណៈ អគារសាធារណៈ និងពាក់កណ្តាលសាធារណៈ(សាលារៀន មន្ទីរពេទ្យ អគាររដ្ឋបាល អគារវិហារសាសនា។ល។) បរិវេណសាលាក្រុង(សួនច្បារ តំបន់បៃតង កន្លែងបញ្ចុះសព។ល។) រុក្ខជាតិនៅតាមមហាវិថី(ផ្លូវថ្នល់ ផ្លូវរថភ្លើង ផ្លូវទឹក កំពង់ផែ) អគារឧស្សាហកម្ម និងអគារពាណិជ្ជកម្ម
(ខ) រុក្ខជាតិនៅតាមអគារ (សួនច្បារលើដំបូល រុក្ខជាតិនៅតាមយ៉ខាងមុខ សួនច្បារខាងក្នុងអគារ)
(គ) បរិវេណកីឡា (ទីលានបាល់ទាត់ កន្លែងវាយកូនគោល។ល។) បរិវេណសួនកុមារ ទីធ្លាមានដាំស្មៅសម្រាប់គេងហាលថ្ងៃ និងសួនកម្សាន្តផ្សេងទៀត កន្លែងមានទឹកស្តុក និងទឹកហូរ(អាងទឹក ស្រះ អាងហែលទឹក ប្រឡាយ ផ្លូវទឹក ប្រព័ន្ធលូ) និងរុក្ខជាតិដាំដុះដើម្បីទប់ទល់នឹងការបំពងសំឡេង ខ្យល់ សំណឹក គំហើញ និងចំណាំងពន្លឺ។ ការថែទាំដីដើម្បីរក្សាឲ្យស្ថិតនៅក្នុងលក្ខខណ្ឌមានជីវចម្រុះល្អ ក៏ត្រូវបានរាប់បញ្ចូលផងដែរ។

ផ្នែក ៨២ ៖ សកម្មភាពខាងរដ្ឋបាលការិយាល័យ គាំទ្រការិយាល័យ និងគាំទ្រអាជីវកម្មផ្សេងទៀត

ផ្នែកនេះរាប់បញ្ចូលនូវ ការផ្ដល់សេវាកម្មរដ្ឋបាលការិយាល័យប្រចាំថ្ងៃ និងការផ្ដល់ជំនួយដល់អាជីវកម្មដែលកំពុងដំណើរការជាប្រចាំ ដោយផ្អែកតាមកិច្ចសន្យា ឬថ្លៃឈ្នួល។

ផ្នែកនេះក៏រាប់បញ្ចូលផងដែរនូវសកម្មភាពសេវាកម្មគាំទ្រគ្រប់ប្រភេទ ដែលផ្ដល់ទៅឲ្យសកម្មភាពអាជីវកម្ម ដទៃទៀតដែលពុំបានរាប់បញ្ចូល។

អង្គភាពដែលពាក់ព័ន្ធនៅក្នុងផ្នែកនេះ មិនផ្ដល់បុគ្គលិករបស់ខ្លួន ដើម្បីទៅបំពេញសកម្មភាពទាំងមូលរបស់អាជីវកម្មនោះទេ (ពោលគឺបំពេញតែចំណែកណាមួយ នៃសកម្មភាពនោះប៉ុណ្ណោះ)។

ក្រុម ៨២១ ៖ សកម្មភាពខាងរដ្ឋបាលការិយាល័យ និងសកម្មភាពគាំទ្រការិយាល័យ

ក្រុមនេះរាប់បញ្ចូលនូវការផ្ដល់សេវាកម្មរដ្ឋបាលការិយាល័យប្រចាំថ្ងៃ ដូចជាការធ្វើផែនការហិរញ្ញវត្ថុ ការធ្វើវិក្កយបត្រ និងរក្សាកំណត់ត្រា ការដឹកជញ្ជូនសម្ភារៈឬទំនិញ និងការបែងចែកបុគ្គលិក និងព័ស្ដុភារ ទៅឲ្យភាគីដទៃ ដោយផ្អែកតាមកិច្ចសន្យា ឬថ្លៃឈ្នួល។

ក្រុមនេះក៏រាប់បញ្ចូលផងដែរនូវសកម្មភាពគាំទ្រដល់ភាគីដទៃ ដោយផ្អែកតាមកិច្ចសន្យា ឬថ្លៃឈ្នួល ដែលសកម្មភាពគាំទ្រទាំងនេះជាសកម្មភាពដំណើរការគាំទ្រអាជីវកម្មប្រព្រឹត្តិទៅជាប្រចាំ ហើយដែលស្ថាប័នអាជីវកម្មទាំងនោះធ្លាប់បំពេញសកម្មភាពទាំងនោះដោយខ្លួនឯងកន្លងមក។

អង្គភាពដែលពាក់ព័ន្ធនៅក្នុងផ្នែកនេះ មិនផ្ដល់បុគ្គលិករបស់ខ្លួន ដើម្បីទៅបំពេញសកម្មភាពទាំងមូលរបស់អាជីវកម្មនោះទេ (ពោលគឺបំពេញតែចំណែកណាមួយនៃសកម្មភាពនោះប៉ុណ្ណោះ)។ បានន័យថាអង្គភាពដែលចូលរួមក្នុងចំណែកណាមួយនៃសកម្មភាពនោះត្រូវបានចាត់ថ្នាក់ដោយយោងតាមចំណែកនៃសកម្មភាពនោះ។

ក្រុម ៨២២ ៖ សកម្មភាពរបស់មជ្ឈមណ្ឌលការហៅទូរសព្ទ

ក្រុមនេះរាប់បញ្ចូល សកម្មភាពរបស់មជ្ឈមណ្ឌលការហៅចូល ពោលគឺឆ្លើយតបទូរសព្ទរបស់អតិថិជន ដោយប្រើប្រាស់ ប្រតិបត្តិករជាមនុស្ស ប្រព័ន្ធបញ្ជូនការហៅដោយស្វ័យប្រវត្តិ ប្រព័ន្ធភ្ជាប់ការហៅទៅនឹងកំព្យូទ័រ ប្រព័ន្ធឆ្លើយតបសំឡេងអន្តរកម្ម ឬវិធីសាស្រ្តប្រហាក់ប្រហែល ដើម្បីទទួលការបញ្ជាទិញ ផ្ដល់ព័ត៌មានពីផលិតផល ដោះស្រាយសំណូមពររបស់អតិថិជន ឬដោះស្រាយបណ្ដឹងពីអតិថិជន និងសកម្មភាពរបស់មជ្ឈមណ្ឌលការហៅចេញដោយប្រើវិធីសាស្ត្រស្រដៀងគ្នា ដើម្បីលក់ ឬផ្សព្វផ្សាយ នូវផលិតផលឬសេវាកម្មទៅឲ្យអតិថិជនសក្ដានុពល ស្រាវជ្រាវទីផ្សារឬស្ទង់មតិសាធារណៈ និងសកម្មភាពប្រហាក់ប្រហែល នេះ សម្រាប់អតិថិជន។

ក្រុម ៨២៣ ៖ សម្មភាពរៀបចំសន្និបាត និងពិព័រណ៍ពាណិជ្ជកម្ម

ក្រុមនេះរាប់បញ្ចូលការរៀបចំ ការផ្សព្វផ្សាយ ឬការគ្រប់គ្រងព្រឹត្តិការណ៍នានា ដូចជាពិព័រណ៍ពាណិជ្ជកម្មនិងជំនួញ សន្និបាត សន្និសីទ និងកិច្ចប្រជុំ ទោះបីជាមានឬមិនមានផ្ដល់នូវ ការគ្រប់គ្រងនិងបុគ្គលិក ដើម្បីដំណើរការព្រឹត្តិការណ៍ទាំងនេះនៅកន្លែងដែលកំពុងប្រារព្ធពិធីក៏ដោយ។

ក្រុម ៨២៩ ៖ សកម្មភាពសេវាកម្មគាំទ្រដល់អាជីវកម្ម ដទៃទៀតដែលពុំបានរាប់បញ្ចូល

ក្រុមនេះរាប់បញ្ចូលនូវ សកម្មភាពរបស់ភ្នាក់ងារប្រមូលប្រាក់បំណុល សកម្មភាពរបស់ការិយាល័យព័ត៌មានឥណទាន និងសកម្មភាពគាំទ្រគ្រប់ប្រភេទដែលផ្ដល់ឲ្យអាជីវកម្ម ដែលមិនត្រូវបានគេចាត់នៅក្នុងថ្នាក់ណាផ្សេងទៀត។

ជំពូក ឈ ៖ សកម្មភាពរដ្ឋបាល និងសេវាគាំទ្រ
ផ្នែក ៨២ ៖ សកម្មភាពខាងរដ្ឋបាលការិយាល័យ គាំទ្រការិយាល័យ និងគាំទ្រអាជីវកម្មផ្សេងទៀត

ក្រុម	ថ្នាក់	ថ្នាក់រង	ការអធិប្បាយ
៨២១			**សកម្មភាពខាងរដ្ឋបាលការិយាល័យ និងសកម្មភាពគាំទ្រការិយាល័យ**
	៨២១១[១]		សេវាកម្មចម្រុះបែបខាងរដ្ឋបាលការិយាល័យ
		៨២១១០	សេវាកម្មចម្រុះបែបខាងរដ្ឋបាលការិយាល័យ[២]
	៨២១៩[៣]		សកម្មភាពថតចម្លងឯកសារ សកម្មភាពរៀបចំឯកសារ និងសកម្មភាពឯកទេសផ្សេងទៀតសម្រាប់គាំទ្រការិយាល័យ
		៨២១៩១	សកម្មភាពថតចម្លងឯកសារ[៤]
		៨២១៩៩	សកម្មភាពរៀបចំឯកសារ និងសកម្មភាពឯកទេសផ្សេងទៀតសម្រាប់គាំទ្រការិយាល័យ[៥]

(១) **មិនរាប់បញ្ចូល** (ក) ការផ្តល់បុគ្គលិក ដើម្បីបំពេញសកម្មភាពទាំងមូល របស់ដំណើរការអាជីវកម្ម (មើលថ្នាក់ ដោយផ្អែកលើប្រភេទអាជីវកម្ម ដែលបានបំពេញសកម្មភាព)

(ខ) ការផ្តល់បុគ្គលិក ដើម្បីបំពេញចំណែកណាមួយ នៃសកម្មភាពទាំងនេះ (មើលថ្នាក់ ដោយផ្អែកលើសកម្មភាពពិសេសនោះ)។

(២) **រាប់បញ្ចូល** ការផ្តល់សេវាកម្មរដ្ឋបាលការិយាល័យប្រចាំថ្ងៃ ដូចជា ការធ្វើផែនការហិរញ្ញវត្ថុ ការធ្វើវិក្កយបត្រនិងរក្សាកំណត់ត្រា ការដឹកជញ្ជូនសម្ភារៈឬទំនិញនិងការបែងចែកបុគ្គលិក(សេវាកម្មរត់សំបុត្រ) និងព័ស្តុការ ដោយផ្អែកតាមកិច្ចសន្យា ឬថ្លៃឈ្នួល។

(៣) **មិនរាប់បញ្ចូល** (ក) ការបោះពុម្ពឯកសារ (ការបោះពុម្ពរហ័ស ការបោះពុម្ពដោយថត(អូហ្វសេត) ។ល។) (មើល ១៨១១)

(ខ) ការផ្សាយពាណិជ្ជកម្មតាមការចែកសំបុត្រដោយផ្ទាល់ (មើល ៧៣១០)

(គ) សេវាកម្មជវលេខឯកទេស ដូចជា ការធ្វើកំណត់ហេតុនៅក្នុងសាវនាការតុលាការ (មើល ៨២៩៩)

(ឃ) សេវាកម្មជវលេខសាធារណៈ (មើល៨២៩៩)

(៤) **រាប់បញ្ចូល** សេវាកម្មថតចម្លងឯកសារ ដោយគ្មានផ្តល់សេវាកម្មបោះពុម្ព ដូចជា ការបោះពុម្ពដោយថត ការបោះពុម្ពរហ័ស ការបោះពុម្ពឌីជីថល សេវាកម្មបោះពុម្ពដែលចាប់ផ្តើមពីការបង្កើតគំនូរព្រាងរហូតដល់ការបោះពុម្ពសម្រេច។

(៥) **រាប់បញ្ចូល** ការសសេរសំបុត្រ ឬសរសេរប្រវត្តិរូប។

ជំពូក ៧ ៖ សកម្មភាពរដ្ឋបាល និងសេវាគាំទ្រ
ផ្នែក ៨២ ៖ សកម្មភាពខាងរដ្ឋបាលការិយាល័យ គាំទ្រការិយាល័យ និងគាំទ្រអាជីវកម្មផ្សេងទៀត

ក្រុម	ថ្នាក់	ថ្នាក់រង	ការអធិប្បាយ
៨២២			**សកម្មភាពរបស់មជ្ឈមណ្ឌលការហៅទូរស័ព្ទ**
	៨២២០		សកម្មភាពរបស់មជ្ឈមណ្ឌលការហៅទូរស័ព្ទ
		៨២២០០	សកម្មភាពរបស់មជ្ឈមណ្ឌលការហៅទូរស័ព្ទ[(១)]
៨២៣			**សម្មភាពរៀបចំសន្និបាត និងពិព័រណ៌ពាណិជ្ជកម្ម**
	៨២៣០		សកម្មភាពរៀបចំសន្និបាត និងពិព័រណ៌ពាណិជ្ជកម្ម
		៨២៣០០	សកម្មភាពរៀបចំសន្និបាទ និងពិព័រណ៌ពាណិជ្ជកម្ម[(២)]

(១) **រាប់បញ្ចូល** (ក) សកម្មភាពរបស់មជ្ឈមណ្ឌលការហៅចូល ពោលគឺឆ្លើយតបទូរស័ព្ទរបស់អតិថិជន ដោយប្រើប្រាស់ ប្រតិបត្តិករជាមនុស្ស ប្រព័ន្ធបញ្ជូនការហៅដោយស្វ័យប្រវត្តិ ប្រព័ន្ធភ្ជាប់ការហៅទៅនឹងកំព្យូទ័រ ប្រព័ន្ធឆ្លើយតបសំឡេងអន្តរកម្ម ឬវិធីសាស្ត្រប្រហាក់ប្រហែល ដើម្បីទទួលការបញ្ជាទិញ ផ្តល់ព័ត៌មានពីផលិតផល ដោះស្រាយសំណូមពររបស់អតិថិជន ឬដោះស្រាយបណ្តឹងពីអតិថិជន

(ខ) សកម្មភាពរបស់មជ្ឈមណ្ឌលការហៅចេញ ដោយប្រើវិធីសាស្ត្រស្រដៀងគ្នា ដើម្បីលក់ឬផ្សព្វផ្សាយ នូវផលិតផលឬសេវាកម្ម ទៅឲ្យអតិថិជនសក្តានុពល ស្រាវជ្រាវទីផ្សារឬស្ទង់មតិសាធារណៈ និងសកម្មភាពប្រហាក់ប្រហែលនេះ សម្រាប់អតិថិជន។

(២) **រាប់បញ្ចូល** អ្នករៀបចំពិព័រណ៌ពាណិជ្ជកម្ម និងអាជីវកម្ម។

ជំពូក ឈ ៖ សកម្មភាពរដ្ឋបាល និងសេវាគាំទ្រ
ផ្នែក ៨២ ៖ សកម្មភាពខាងរដ្ឋបាលការិយាល័យ គាំទ្រការិយាល័យ និងគាំទ្រអាជីវកម្មផ្សេងទៀត

ក្រុម	ថ្នាក់	ថ្នាក់រង	ការអធិប្បាយ
៨២៩			**សកម្មភាពសេវាកម្មគាំទ្រដល់អាជីវកម្ម ដទៃទៀតដែលពុំបានរាប់បញ្ចូល**
	៨២៩១		សកម្មភាពភ្នាក់ងារប្រមូលប្រាក់បំណុល និងការិយាល័យព័ត៌មានឥណទាន
		៨២៩១០	សកម្មភាពភ្នាក់ងារប្រមូលប្រាក់បំណុល និងការិយាល័យព័ត៌មានឥណទាន(១)
	៨២៩២(២)		សកម្មភាពវេចខ្ចប់
		៨២៩២០	សកម្មភាពវេចខ្ចប់ដោយផ្អែកតាមកិច្ចសន្យាឬការបង់ថ្លៃឈ្នួល មិនប្រកាន់ថាប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិឬអត់
	៨២៩៩(៣)		សកម្មភាពសេវាគាំទ្រដល់អាជីវកម្ម ដទៃទៀតដែលពុំបានរាប់បញ្ចូល
		៨២៩៩០	សកម្មភាពសេវាគាំទ្រដល់អាជីវកម្ម ដទៃទៀតដែលពុំបានរាប់បញ្ចូល

(១) **រាប់បញ្ចូល**
(ក) ការប្រមូលប្រាក់សំណងចំពោះប្រាក់ដែលអតិថិជនប្តឹងទាមទារ និងប្រាក់ដែលអតិថិជនផ្ញើមក (ឧ. សេវាកម្មទូទាត់វិក្កយបត្រ ឬសេវាប្រមូលបំណុល)
(ខ) ការចងក្រងព័ត៌មាន ដូចជា ប្រវត្តិការងារនិងប្រវត្តិឥណទានរបស់បុគ្គល ប្រវត្តិឥណទានរបស់អាជីវកម្ម ហើយផ្តល់ព័ត៌មានទាំងនេះ ទៅឲ្យស្ថាប័នហិរញ្ញវត្ថុ អ្នកលក់រាយ និងភាគីផ្សេងទៀត ដែលត្រូវការវាយតម្លៃភាពទុកចិត្តបាន របស់បុគ្គលនិងអាជីវកម្មទាំងនោះ។

(២) **រាប់បញ្ចូល** ការវេចខ្ចប់សាច់ និងឱសថ
មិនរាប់បញ្ចូល
(ក) ការផលិតភេសជ្ជៈ និងទឹកបរិសុទ្ធ (មើល ១១០៤)
(ខ) សកម្មភាពវេចខ្ចប់ សម្រាប់សម្រួលដល់ការដឹកជញ្ជូន (មើល ៥២២៩៩)។

(៣) **រាប់បញ្ចូល**
(ក) ការផ្តល់របាយការណ៍ដែលសុក្រិត និងរបាយការណ៍ជរលេខ របស់សកម្មភាពសវនាការផ្ទាល់នៅនឹងកន្លែង និងការសរសេរសកម្មភាព សម្រាប់ជាចំណងជើងរត់បង្ហាញតាមកញ្ចក់ទូរទស្សន៍ ដែលកំពុងផ្សាយផ្ទាល់ អំពីកិច្ចប្រជុំ សន្និសីទ
(ខ) សេវាកម្មបង្ហាញបាកូដ និងសេវាកម្មបោះពុម្ពបាកូដ ព្រមទាំងសកម្មភាពធ្វើដោយផ្ទាល់
(គ) សេវាកម្មប្រមូលយកមកវិញ ឬរឹបអូសយកមកវិញ (ឧ. សេវាកម្មរឹបអូសយកផ្ទះមកវិញ នៅពេលអតិថិជនពុំមានលទ្ធភាពបង់រំលោះតទៅទៀត។ល។)
(ឃ) សេវាប្រមូលឈ្នួលចតរថយន្ត។

មិនរាប់បញ្ចូល
(ក) ការផ្តល់សេវាកម្មបកប្រែឯកសារ (មើល ៨២១៩៩)
(ខ) សកម្មភាពសរសេរឬអានអក្សរ សម្រាប់ជាចំណងជើងនៅក្នុងខ្សែភាពយន្ត ឬខ្សែអាត់ ឬសេវាកម្មសរសេរអក្សរចំណងជើងផ្សេងទៀត (មើល ៥៩១២០)។

ជំពូក ណ ៖ រដ្ឋបាលសាធារណៈ កិច្ចការពារសាធារណៈ និងកាតព្វកិច្ចសន្តិសុខសង្គម

កម្រិត	ច.ស.វ.ក
ជំពូក	១
ផ្នែក	១
ក្រុម	៣
ថ្នាក់	៧
ថ្នាក់រង	៩

ជំពូកនេះរាប់បញ្ចូលសកម្មភាពដែលមានលក្ខណៈពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋ ដែលជាធម្មតាដំណើរការដោយរដ្ឋបាលសាធារណៈ។ ទាំងនេះរួមមានការអនុម័ត និងការបកស្រាយច្បាប់ និងបទបញ្ញត្តិ ព្រមទាំងការគ្រប់គ្រងកម្មវិធីដែលពឹងផ្អែកលើពួកគេ លើសកម្មភាពច្បាប់ លើការយកពន្ធ លើការការពារជាតិ លើសណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាព លើសេវាកម្មអន្តោប្រវេសន៍ លើកិច្ចការបរទេស និងលើការគ្រប់គ្រងកម្មវិធីរដ្ឋាភិបាល។ ជំពូកនេះក៏រាប់បញ្ចូលសកម្មភាពកាតព្វកិច្ចសន្តិសុខសង្គមផងដែរ។ ឋានៈផ្លូវច្បាប់ ឬស្ថានភាពស្ថាប័នមិនមែនជាកត្តាកំណត់ថាតើសកម្មភាពមួយត្រូវចាត់ចូលទៅក្នុងជំពូកនេះនោះទេ ខុសពីសកម្មភាពជាក់លាក់ដូចដែលបានបញ្ជាក់ក្នុងកថាខណ្ឌមុនៗ នេះមានន័យថា សកម្មភាពដែលបានចាត់ថ្នាក់នៅកន្លែងណាមួយនៅក្នុង ចំណាត់ថ្នាក់ស្តង់ដារវិស័យសេដ្ឋកិច្ចម៉ាឡេស៊ី មិនស្ថិតនៅក្រោមផ្នែកនេះទេ ទោះបីជាបានអនុវត្តដោយបណ្តាអង្គភាពសាធារណៈក៏ដោយ។ ឧទាហរណ៍ ការគ្រប់គ្រងប្រព័ន្ធសាលារៀន (ដូចជាបទបញ្ជា ការត្រួតពិនិត្យ កម្មវិធីសិក្សា) ស្ថិតនៅក្រោមជំពូកនេះ ប៉ុន្តែការបង្រៀនមិននៅក្រោមជំពូកនេះទេ (មើលជំពូក«ត») និង ពន្ធនាគារ ឬមន្ទីរពេទ្យយោធាត្រូវបានចាត់ថ្នាក់ក្នុងផ្នែកសុខភាព (មើលជំពូក«ថ»)។ ស្រដៀងគ្នានេះដែរ សកម្មភាពមួយចំនួនក្នុងជំពូកនេះអាចត្រូវបានអនុវត្តដោយអង្គការមិនមែន រដ្ឋាភិបាល។

ផ្នែក ៨៤ ៖ រដ្ឋបាលសាធារណៈ កិច្ចការពារសាធារណៈ និងកាតព្វកិច្ចសន្តិសុខសង្គម

ផ្នែកនេះរាប់បញ្ចូលនូវការគ្រប់គ្រងរដ្ឋ និងគោលនយោបាយសេដ្ឋកិច្ចនិងសង្គមរបស់សហគមន៍ ការផ្តល់សេវាកម្មដល់សហគមន៍ទាំងមូល និងសកម្មភាពទាក់ទងនឹងកាតព្វកិច្ចសន្តិសុខសង្គម។

ក្រុម ៨៤១ ៖ ការគ្រប់គ្រងរដ្ឋ និងគោលនយោបាយសេដ្ឋកិច្ចនិងសង្គមរបស់សហគមន៍

ក្រុមនេះរាប់បញ្ចូលនូវការគ្រប់គ្រងទូទៅ (ដូចជា នីតិប្រតិបត្តិ នីតិប្បញ្ញត្តិ ការគ្រប់គ្រងហិរញ្ញវត្ថុ។ល។ នៅគ្រប់កម្រិតនៃរដ្ឋាភិបាល) និងការគ្រប់គ្រងផ្នែកជីវិតសេដ្ឋកិច្ច និងសង្គម។

ក្រុម ៨៤២ ៖ ការផ្តល់សេវាកម្មដល់សហគមន៍ទាំងមូល

ក្រុមនេះរាប់បញ្ចូលសកម្មភាពកិច្ចការបរទេស, សកម្មភាពការការពារ និងសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព។

ក្រុម ៨៤៣ ៖ សកម្មភាពទាក់ទងនឹងកាតព្វកិច្ចសន្តិសុខសង្គម

ក្រុមនេះរាប់បញ្ចូលនូវការផ្តល់មូលនិធិ និងការគ្រប់គ្រងកម្មវិធីសន្តិសុខសង្គមដែល បានផ្តល់ដោយរដ្ឋាភិបាល ដូចជាការព្យាបាលជំងឺ ការជានាប៉ាប់រងគ្រោះថ្នាក់ការងារ និងនិកម្មភាព ប្រាក់បំណាច់ចូលនិវត្តន៍ និងកម្មវិធីគ្របដណ្តប់ការបាត់បង់ប្រាក់ចំណូលដោយ សារមាតុភាព អសមត្ថភាពជាបណ្តោះអាសន្ន ស្ថានភាពមេម៉ាយ។ល។

ជំពូក ណ ៖ រដ្ឋបាលសាធារណៈ កិច្ចការពារសាធារណៈ និងកាតព្វកិច្ចសន្តិសុខសង្គម

ផ្នែក ៨៤ ៖ រដ្ឋបាលសាធារណៈ កិច្ចការពារសាធារណៈ និងកាតព្វកិច្ចសន្តិសុខសង្គម

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៨៤១			**ការគ្រប់គ្រងរដ្ឋ និងគោលនយោបាយសេដ្ឋកិច្ចនិងសង្គមរបស់សហគមន៍**
	៨៤១១[១]		សកម្មភាពគ្រប់គ្រងសាធារណៈទូទៅ
		៨៤១១០	សកម្មភាពគ្រប់គ្រងសាធារណៈទូទៅ (ទាំងមូល)
	៨៤១២[២]		បទប្បញ្ញត្តិសម្រាប់សកម្មភាពនៃការផ្តល់សេវាកម្មថែទាំសុខភាព អប់រំ វប្បធម៌ និងសេវាកម្មសង្គមផ្សេងទៀត មិនរួមបញ្ចូលសន្តិសុខសង្គម
		៨៤១២០	ការគ្រប់គ្រងរដ្ឋលើកម្មវិធីសេដ្ឋកិច្ចនិងសង្គមកិច្ច

(១) **រាប់បញ្ចូល**
- (ក) ការគ្រប់គ្រងនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ នៃថ្នាក់កណ្តាល ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន
- (ខ) ការគ្រប់គ្រង និងតាមដានកិច្ចការសារពើពន្ធ
- (គ) ការអនុវត្តថវិកា និងការគ្រប់គ្រងមូលនិធិសាធារណៈនិងបំណុលសាធារណៈ
- (ឃ) ការគ្រប់គ្រងទូទៅ (ជនស៊ីវិល) គោលការណ៍ស្រាវជ្រាវនិងអភិវឌ្ឍន៍ និងមូលនិធិពាក់ព័ន្ធ
- (ង) ការគ្រប់គ្រង និងប្រតិបត្តិការផែនការទាំងមូលរបស់សេដ្ឋកិច្ចនិងសង្គម និងសេវាកម្មផ្តល់ស្ថិតិ នៅគ្រប់កម្រិតនៃរដ្ឋាភិបាល។

មិនរាប់បញ្ចូល
- (ក) ប្រតិបត្តិការអគារដែលបានកាន់កាប់ ឬគ្រប់គ្រងដោយរដ្ឋាភិបាល (មើល ៦៨១០១ និង ៦៨២០៩)
- (ខ) ការគ្រប់គ្រងគោលការណ៍ស្រាវជ្រាវនិងអភិវឌ្ឍន៍ ដែលមានបំណងបង្កើនសុខមាលភាពផ្ទាល់ខ្លួន និងការគ្រប់គ្រងមូលនិធិពាក់ព័ន្ធ (មើល ៨៤១២៩)
- (គ) ការគ្រប់គ្រងគោលការណ៍ស្រាវជ្រាវនិងអភិវឌ្ឍន៍ ដែលមានបំណងបង្កើនសកម្មភាពសេដ្ឋកិច្ច និងភាពប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច (មើល ៨៤១៣៩)
- (ឃ) ការគ្រប់គ្រងគោលការណ៍ស្រាវជ្រាវ និងអភិវឌ្ឍន៍ ដែលទាក់ទងនឹងការការពារ និងការគ្រប់គ្រងមូលនិធិពាក់ព័ន្ធ (មើល ៨៤២២)
- (ង) ប្រតិបត្តិការនៃការថែរក្សាឯកសាររបស់រដ្ឋាភិបាល (មើល ៩១០១)។

(២) **មិនរាប់បញ្ចូល**
- (ក) សកម្មភាពបញ្ចេញចោលនិងកម្ទេចចោលទឹកកខ្វក់និងកាកសំណល់ (មើលផ្នែក ៣៧, ៣៨, និង ៣៩)
- (ខ) សកម្មភាពទាក់ទងនឹងកាតព្វកិច្ចសន្តិសុខសង្គម (មើល ៨៤៣០០)
- (គ) សកម្មភាពការអប់រំ (មើលផ្នែក ៨៥)
- (ឃ) សកម្មភាពទាក់ទងនឹងសុខភាពមនុស្ស (មើលផ្នែក ៨៦)
- (ង) សកម្មភាពរបស់បណ្ណាល័យ និងបណ្ណសារដ្ឋាន (ដំណើរការដោយឯកជន សារធារណៈ ឬរដ្ឋាភិបាល) (មើល ៩១០១)
- (ច) ដំណើរការសារមន្ទីរ និងស្ថាប័នវប្បធម៌ដទៃទៀត (មើល ៩១០២)
- (ឆ) សកម្មភាពកីឡា ឬការសម្រាកកំសាន្តដទៃទៀត (មើលផ្នែក ៩៣)។

ជំពូក ណ ៖ រដ្ឋបាលសាធារណៈ កិច្ចការពារសាធារណៈ និងកាតព្វកិច្ចសន្តិសុខសង្គម

ផ្នែក ៨៤ ៖ រដ្ឋបាលសាធារណៈ កិច្ចការពារសាធារណៈ និងកាតព្វកិច្ចសន្តិសុខសង្គម

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្ដីអធិប្បាយ
	៨៤១៣[(១)]		បទប្បញ្ញត្តិ និងការធ្វើឲ្យប្រតិបត្តិការអាជីវកម្មមានប្រសិទ្ធភាព
		៨៤១៣០	បទប្បញ្ញត្តិ និងការធ្វើឲ្យប្រតិបត្តិការអាជីវកម្មមានប្រសិទ្ធភាព
៨៤២			**ការផ្ដល់សេវាកម្មដល់សហគមន៍ទាំងមូល**
	៨៤២១[(២)]		កិច្ចការបរទេស
		៨៤២១០	កិច្ចការបរទេស
	៨៤២២[(៣)]		សកម្មភាពការការពារ
		៨៤២២០	សេវាកម្មការពារប្រជាពលរដ្ឋ និងយោធា

(១) **មិនរាប់បញ្ចូល** សកម្មភាពការស្រាវជ្រាវ និងពិសោធន៍ (មើលផ្នែក ៧២)

រាប់បញ្ចូល កិច្ចការរុករករ៉ែ និងធនធានក្រោមដី ដូចជាការរុករកស្រាវជ្រាវ ការអេកិរក្ស ការរកទីផ្សារ និងផ្នែកផ្សេងទៀតទាក់ទងនឹងការទាញយកធនធានក្រោមដី។

(២) **រាប់បញ្ចូល**
- (ក) ការគ្រប់គ្រង និងប្រតិបត្តិការរបស់ក្រសួងការបរទេស និងបេសកកម្មការទូត និងកុងស៊ុលនៅបរទេស ឬនៅការិយាល័យរបស់អង្គការអន្តរជាតិ
- (ខ) ការគ្រប់គ្រង ប្រតិបត្តិការ និងគាំទ្រដល់សេវាកម្មព័ត៌មាន និងវប្បធម៌ ដែលគ្រោងសម្រាប់បែងចែកលើសពីថ្នាក់ជាតិ
- (គ) ការគ្រប់គ្រងពាណិជ្ជកម្មក្រៅប្រទេស ហិរញ្ញវត្ថុអន្តរជាតិ និងកិច្ចការបច្ចេកទេសក្រៅប្រទេស

មិនរាប់បញ្ចូល សេវាកម្មជួយដល់គ្រោះមហន្តរាយអន្តរជាតិ ឬជនភៀសខ្លួនពីសង្គ្រាម (មើល ៨៨៩០៩)។

(៣) **រាប់បញ្ចូល**
- (ក) ការគ្រប់គ្រង ការតាមដាន និងប្រតិបត្តិការ របស់កងកម្លាំងយោធា និងកងកម្លាំងការពារដីគោក លើ/ក្នុងសមុទ្រ អាកាស និងលំហ
- (ខ) ការគ្រប់គ្រង ប្រតិបត្តិការ និងការគាំទ្រកងកម្លាំងការពារស៊ីវិល
- (គ) ការគាំទ្រដំណើរការរបស់ផែនការជាយថាភាព និងការអនុវត្តការងារដែលទទួលបានការចូលរួមពីស្ថាប័ន និងប្រជាពលរដ្ឋ។

មិនរាប់បញ្ចូល
- (ក) សកម្មភាពការស្រាវជ្រាវ និងពិសោធន៍ (មើលផ្នែក ៧២)
- (ខ) សកម្មភាពតុលាការយោធា (មើល ៨៤២៣៥)
- (គ) ការផ្ដល់សម្ភារៈសម្រាប់ប្រើក្នុងគ្រាអាសន្នក្នុងប្រទេស ក្នុងករណីមានគ្រោះមហន្តរាយពេលមានសន្តិភាពក្នុងប្រទេស (មើល ៨៥៣០)
- (ឃ) សកម្មភាពការអប់រំសម្រាប់សាលាយោធា សកលវិទ្យាល័យ និងបណ្ឌិតសភា (មើល ៨៥៣០)
- (ង) សកម្មភាពរបស់មន្ទីរពេទ្យយោធា (មើល៨៦១០)

ជំពូក ណ ៖ រដ្ឋបាលសាធារណៈ កិច្ចការពារសាធារណៈ និងកាតព្វកិច្ចសន្តិសុខសង្គម
ផ្នែក ៨៤ ៖ រដ្ឋបាលសាធារណៈ កិច្ចការពារសាធារណៈ និងកាតព្វកិច្ចសន្តិសុខសង្គម

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
	៨៤២៣[១]		សកម្មភាពសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព
		៨៤២៣១	សេវាកម្មនគរបាល
		៨៤២៣២[២]	តុលាការ

(១) **រាប់បញ្ចូល**

(ក) ការគ្រប់គ្រង និងប្រតិបត្តិការរបស់កងកម្លាំងនគរបាលប្រចាំការ និងកងជំនួយដែលគាំទ្រដោយអាជ្ញាធរសាធារណៈ និងរបស់កងកម្លាំងកំពង់ផែ ព្រំដែន ឆ្មាំឆ្នេរសមុទ្រ និងកងកម្លាំងនគរបាលពិសេសផ្សេងទៀត

(ខ) ការពន្លត់អគ្គីភ័យ និងការបង្ការអគ្គីភ័យ

(គ) ការគ្រប់គ្រង និងប្រតិបត្តិការរបស់តុលាការច្បាប់ព្រហ្មទណ្ឌ និងរដ្ឋប្បវេណី សាលាក្តីយោធា និងប្រព័ន្ធយុត្តិធម៌

(ឃ) ការផ្តល់យោបល់ និងការបកស្រាយច្បាប់

(ង) អាជ្ញាកណ្តាលសម្រាប់បណ្តឹងរដ្ឋប្បវេណី

(ច) ការគ្រប់គ្រងពន្ធនាគារ និងការផ្តល់សេវាកម្មកែខ្លួនឡើងវិញ ដែលរួមទាំងសេវាកម្មបុននីតិសម្បទាផងដែរ

(ឆ) ការផ្តល់សម្ភារៈប្រើប្រាស់ពេលមានគ្រោះអាសន្នក្នុងស្រុក ក្នុងករណីមានគ្រោះមហន្តរាយពេលមានសន្តិភាពក្នុងប្រទេស

មិនរាប់បញ្ចូល

(ក) ការផ្តល់យោបល់ និងការតំណាងលើសំណុំរឿងរដ្ឋប្បវេណី ព្រហ្មទណ្ឌ និងរឿងផ្សេងៗទៀត (មើល ៦៩១០)

(ខ) ប្រតិបត្តិការមន្ទីរពិសោធន៍របស់នគរបាល (មើល ៧១២០០)

(គ) ការគ្រប់គ្រង និងប្រតិបត្តិការរបស់កងកម្លាំងប្រដាប់អាវុធ (មើល ៨៤២២)

(ឃ) សកម្មភាពរបស់សាលាពន្ធនាគារ (មើល ៨៥)

(ង) សកម្មភាពរបស់មន្ទីរពេទ្យពន្ធនាគារ (មើល ៨៦១០)។

(២) **រាប់បញ្ចូល** សកម្មភាពរបស់សាលាក្តីយោធា។

ជំពូក ណ ៖ រដ្ឋបាលសាធារណៈ កិច្ចការពារសាធារណៈ និងកាតព្វកិច្ចសន្តិសុខសង្គម
ផ្នែក ៨៤ ៖ រដ្ឋបាលសាធារណៈ កិច្ចការពារសាធារណៈ និងកាតព្វកិច្ចសន្តិសុខសង្គម

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
		៨៤២៣៩	សេវាកម្មសណ្តាប់ធ្នាប់សាធារណៈ និងកិច្ចការទាក់ទងនឹងសុវត្ថិភាពដទៃទៀត[១]
៨៤៣			**សកម្មភាពកាតព្វកិច្ចសន្តិសុខសង្គម**
	៨៤៣០[២]		**សកម្មភាពកាតព្វកិច្ចសន្តិសុខសង្គម**
		៨៤៣០០	សកម្មភាពកាតព្វកិច្ចសន្តិសុខសង្គម

(១) **មិនរាប់បញ្ចូល** (ក) សេវាកម្មបង្ការ និងពន្លត់អគ្គិភ័យនៅព្រលានយន្តហោះ ដែលផ្តល់ឲ្យដោយអង្គភាពដែលមិនមានឯកទេស (មើល ៥២២៣០)

(ខ) សេវាកម្មពន្លត់ និងបង្ការភ្លើងឆេះព្រៃ (មើល ០២៤០០)

(គ) ការពន្លត់អគ្គិភ័យនៅតំបន់រុករកប្រេង និងឧស្ម័ន (មើល ០៩១០០)

រាប់បញ្ចូល (ក) ការពន្លត់ និងបង្ការអគ្គិភ័យ

(ខ) ការផ្តល់សម្ភារៈប្រើប្រាស់ក្នុងគ្រាអាសន្នក្នុងស្រុក ក្នុងករណីមានគ្រោះមហន្តរាយពេលមានសន្តិភាពក្នុងប្រទេស

(គ) សេវាកម្មត្រួតពិនិត្យ និងអង្កេតការនេសាទ

(ឃ) សេវាកម្មអន្តោប្រវេសន៍។

(២) **មិនរាប់បញ្ចូល** (ក) សន្តិសុខសង្គមមិនមែនជាកាតព្វកិច្ច (មើល ៦៥៣០)

(ខ) ការផ្តល់សេវាកម្មលើសុខមាលភាព (មើល ៨៨១០) និងការងារសង្គម (ដោយពុំផ្តល់កន្លែងស្នាក់នៅ) (មើល ៨៨៩០)។

ជំពូក ត ៖ ការអប់រំ

កម្រិត	ច.ស វ.ក
ជំពូក	១
ផ្នែក	១
ក្រុម	៥
ថ្នាក់	៨
ថ្នាក់រង	១៧

ជំពូកនេះរាប់បញ្ចូលនូវការអប់រំនៅគ្រប់កម្រិត ឬសម្រាប់វិជ្ជាជីវៈណាមួយ ដែលមានដូចជា ការអាន ការសរសេរ ការស្តាប់ ការមើល តាមរយៈវិទ្យុ និងទូរទស្សន៍ ឬមធ្យោបាយណាក៏ដោយ។ វារួមមានការអប់រំផ្តល់ដោយគ្រឹះស្ថានខុសៗគ្នានៅក្នុងប្រព័ន្ធអប់រំរាល់ថ្ងៃ សម្រាប់កម្រិតផ្សេងៗគ្នា ក៏ដូចជាសម្រាប់ការអប់រំមនុស្សពេញវ័យ វគ្គអក្ខរកម្ម។ល។ បន្ថែមពីលើនេះទៀតក៏មានសាលាយោធា និងបណ្ឌិតសភា សាលារបស់ពន្ធនាគារ។ល។ តាមកម្រិតនីមួយៗផងដែរ។ ជំពូកនេះរាប់បញ្ចូលទាំងការអប់រំសាធារណៈ និងទាំងឯកជន។ សម្រាប់កម្រិតនីមួយៗរបស់ការអប់រំថ្នាក់ដំបូងថ្នាក់បង្រៀនក៏មានការអប់រំពិសេសសម្រាប់សិស្សពិការ រាងកាយ ឬផ្លូវចិត្តផងដែរ។ ការបែងចែកប្រភេទរបស់ជំពូកនេះធ្វើឡើងដោយផ្អែកទៅលើកម្រិតនៃការអប់រំ ដូចដែលបានចែងនៅក្នុង ចំណាត់ថ្នាក់ស្តង់ដារអប់រំអន្តរជាតិ ឆ្នាំ១៩៩៧។ សកម្មភាពរបស់គ្រឹះស្ថានអប់រំចាត់ក្នុង ចំណាត់ថ្នាក់ស្តង់ដារអប់រំអន្តរជាតិ កម្រិត ០ និងកម្រិត ១ ត្រូវបានចាត់ក្នុងក្រុម ៨៥១ គ្រឹះស្ថានក្នុង ចំណាត់ថ្នាក់ស្តង់ដារអប់រំអន្តរជាតិ កម្រិត ២ និង ៣ ចាត់ក្នុងក្រុម ៨៥២ ចំណែកឯគ្រឹះស្ថានក្នុង ចំណាត់ថ្នាក់ស្តង់ដារអប់រំអន្តរជាតិ កម្រិត ៤ ៥ និង ៦ ក្នុងក្រុម ៨៥៣។

ជំពូកនេះក៏រាប់បញ្ចូលនូវការបង្ហាត់បង្រៀនទាក់ទងនឹងកីឡា និងសកម្មភាពសម្រាកកំសាន្ត ដូចជាល្បែងសាងសង់ស្ពានឬផ្ទះ ឬកីឡាវាយកូនហ្គោល និងសកម្មភាពគាំទ្រការអប់រំនានា។

ផ្នែក ៨៥ ៖ ការអប់រំ

ផ្នែកនេះរាប់បញ្ចូលមត្តេយ្យសិក្សានិងបឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា ការអប់រំ ផ្សេងទៀត និងសេវាគាំទ្រការអប់រំដទៃទៀត។

ក្រុម ៨៥១ ៖ មត្តេយ្យសិក្សានិងបឋមសិក្សា

ក្រុមនេះរាប់បញ្ចូលនូវការផ្តល់ការបណ្តុះបណ្តាលដល់កុមារ ដើម្បីឲ្យស៊ាំនឹងបរិស្ថានសាលា និងការបង្ហាត់បង្រៀនដល់សិស្សឲ្យចេះមូលដ្ឋាននៃការអាន សរសេរ ស្តាប់ និងនព្វន្ត រួមទាំងការយល់ដឹងជាបឋមលើមុខវិជ្ជាដទៃទៀត ដូចជា ប្រវត្តិវិទ្យា ភូមិវិទ្យា វិទ្យាសាស្ត្រធម្មជាតិ វិទ្យាសាស្ត្រសង្គម សិល្បៈ និងតន្ត្រី។ ការអប់រំបែបនេះជាទូទៅត្រូវបានផ្តល់ឲ្យកុមារ ក៏ប៉ុន្តែថ្នាក់អក្ខរកម្ម (ទោះបីជានៅក្នុង ឬនៅក្រៅប្រព័ន្ធអប់រំក៏ដោយ) ដែលមានមាតិកាស្រដៀងនឹងកម្មវិធីនៅបឋមសិក្សាដែរ តែសម្រាប់អ្នកដែលត្រូវបានចាត់ទុកថាមានវ័យចំណាស់ពេកសម្រាប់ថ្នាក់បឋម ក៏ត្រូវបានបញ្ចូលក្នុងក្រុមនេះដែរ។ វាក៏រាប់បញ្ចូលផងដែរនូវការផ្តល់កម្មវិធីសិក្សាកម្រិតស្រដៀងគ្នា ទៅដល់កុមារដែលត្រូវការការអប់រំពិសេស។ ការអប់រំអាចកើតមានឡើងនៅក្នុងថ្នាក់រៀន ឬតាមរយៈវិទ្យុ ទូរទស្សន៍ អ៊ិនធឺណែត ទំនាក់ទំនងទៅមក ឬនៅផ្ទះ។

ក្រុម ៨៥២ ៖ មធ្យមសិក្សា

ក្រុមនេះរាប់បញ្ចូលការផ្តល់ការអប់រំមធ្យមសិក្សាទូទៅ និងការអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ កម្រិតមធ្យមសិក្សា។

ក្រុម ៨៥៣ ៖ ឧត្តមសិក្សា

ក្រុមនេះរាប់បញ្ចូលការផ្តល់ការអប់រំកម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្រិតឧត្តមសិក្សា រួមទាំងការប្រគល់សញ្ញាប័ត្រថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ ឬថ្នាក់ក្រោយឧត្តមសិក្សា។ លក្ខខណ្ឌក្នុងការចូលរៀនគឺត្រូវមានយ៉ាងហោចណាស់សញ្ញាបត្រមធ្យមសិក្សា ឬកម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈដែលប្រហាក់ប្រហែលគ្នា។ ការអប់រំអាចកើតមានឡើងនៅក្នុងថ្នាក់រៀន ឬតាមរយៈវិទ្យុ ទូរទស្សន៍ អ៊ិនធឺណែត ឬទំនាក់ទំនងទៅមក។

ក្រុម ៨៥៤ ៖ ការអប់រំផ្សេងទៀត

ក្រុមនេះរាប់បញ្ចូលនូវការអប់រំបន្ត និងវគ្គអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈបន្ត សម្រាប់ជំនាញណាមួយ។ ការបង្ហាត់បង្ហាញអាចធ្វើឡើងដោយផ្ទាល់មាត់ ឬតាមរយៈការសរសេរ ហើយអាចធ្វើឡើងនៅក្នុងថ្នាក់រៀន ឬតាមរយៈវិទ្យុ ទូរទស្សន៍ អ៊ិនធឺណិត ទំនាក់ទំនងទៅវិញទៅមក ឬមធ្យោបាយផ្សេងៗ។ ក្រុមនេះក៏រាប់បញ្ចូលការផ្តល់ការបង្ហាត់បង្ហាញសម្រាប់ សកម្មភាពអត្តពលកម្មទៅដល់បុគ្គលឬដល់ក្រុម ការបង្ហាត់បង្ហាញជាភាសាបរទេស ការបង្ហាត់បង្រៀនសិល្បៈ រឿងល្ខោន ឬតន្ត្រី ឬវគ្គបណ្តុះបណ្តាលតាមឯកទេសផ្សេងទៀត (មិនអាចប្រៀបធៀបបាននឹងការអប់រំក្នុងក្រុម ៨៥១ ដល់ ៨៥៣ ទេ)។

ក្រុម ៨៥៥ ៖ សេវាគាំទ្រការអប់រំ

ក្រុមនេះរាប់បញ្ចូលនូវការផ្តល់សេវាអប់រំដោយមិនមានការបង្ហាត់បង្រៀន ដែលអាចគាំទ្រដំណើរការអប់រំ ឬប្រព័ន្ធអប់រំបាន ដូចជា ការប្រឹក្សាផ្នែកអប់រំ សេវាណែនាំផ្នែកអប់រំ សេវាកម្មវាយតម្លៃកម្រិតអប់រំ សេវារៀបចំការប្រឡង និងការរៀបចំកម្មវិធីផ្លាស់ប្តូរសិស្ស។

ជំពូក ត ៖ ការអប់រំ

ផ្នែក ៨៥ ៖ ការអប់រំ

ក្រុម	ថ្នាក់	ថ្នាក់រង	ការអធិប្បាយ
៨៥១			**មត្តេយ្យសិក្សានិងបឋមសិក្សា**
	៨៥១០[១]		មត្តេយ្យសិក្សានិងបឋមសិក្សា
		៨៥១០១	មត្តេយ្យសិក្សា[២]
		៨៥១០២	បឋមសិក្សា
៨៥២			**មធ្យមសិក្សា**
	៨៥២១[៣]		មធ្យមសិក្សាចំណេះទូទៅ
		៨៥២១១	មធ្យមសិក្សាបឋមភូមិ
		៨៥២១២	មធ្យមសិក្សាទុតិយភូមិ
	៨៥២២[៤]		ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈកម្រិតមធ្យមសិក្សា
		៨៥២២០	ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈកម្រិតមធ្យមសិក្សាបច្ចេកទេស និងវិជ្ជាជីវៈ[៥]
៨៥៣			**ឧត្តមសិក្សា**
	៨៥៣០[៦]		ឧត្តមសិក្សា
		៨៥៣០១	ការអប់រំបណ្តុះបណ្តាលកម្រិតឧត្តមសិក្សាក្នុងប្រពន្ធ័អប់រំចំណេះដឹងទូទៅ (រដ្ឋ)
		៨៥៣០២	ការអប់រំបណ្តុះបណ្តាលកម្រិតឧត្តមសិក្សាក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (ឯកជន)[៧]
		៨៥៣០៣	ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈកម្រិតឧត្តមសិក្សាបច្ចេកទេស និងអាជីព។

(១) **រាប់បញ្ចូល** (ក) ការអប់រំពិសេសសម្រាប់សិស្សពិការក្នុងកម្រិតនេះ

(ខ) កម្មវិធីអក្ខរកម្មសម្រាប់មនុស្សពេញវ័យ (ទោះបីជានៅក្នុង ឬនៅក្រៅប្រព័ន្ធអប់រំក៏ដោយ) ដែលមានមាតិកាស្រដៀងនឹងកម្មវិធីនៅបឋមសិក្សាដែរ តែសម្រាប់អ្នកដែលត្រូវបានចាត់ទុកថាមានវ័យចំណាស់ពេកសម្រាប់ថ្នាក់បឋម

មិនរាប់បញ្ចូល សកម្មភាពថែទាំក្មេងពេលថ្ងៃ (មើល ៨៨៩០២)។

(២) **រាប់បញ្ចូល** កន្លែងមើលកុមារ ផ្លូវសម្រាប់ក្មេងលេង និងមត្តេយ្យសាលា។

(៣) **រាប់បញ្ចូល** សាលាបង្ហាត់កីឡា និងសាលាសិល្បៈ។

(៤) **មិនរាប់បញ្ចូល** (ក) ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ កម្រិតក្រោយមធ្យមសិក្សា និងសាកលវិទ្យាល័យ (មើល ៨៥៣០)

(គ) សាលាបង្រៀនបើកបរ តែមិនសម្រាប់អ្នកបើកបរអាជីព (មើល ៨៥៤៩២)

(ឃ) វគ្គអប់រំបណ្តុះបណ្តាលការងារ ដែលជាផ្នែកមួយរបស់សកម្មភាពកិច្ចការសង្គមកិច្ចដោយមិនមានផ្តល់ជូនការស្នាក់នៅ (មើល ៨៨១០ និង៨៨៩០)។

(៥) **រាប់បញ្ចូល** (ក) ការបង្ហាត់បង្រៀនដល់មគ្គុទ្ទេសក៍ទេសចរ មេចុងភៅ ម្ចាស់ និង/ឬអ្នកគ្រប់គ្រងសណ្ឋាគារនិងភោជនីយដ្ឋាន

(ខ) ការអប់រំពិសេសដល់សិស្សពិការក្នុងកម្រិតនេះ

(គ) វគ្គបង្រៀនជួសជុលកុំព្យូទ័រ

(ឃ) សាលាបង្រៀនសម្អាង និងកាត់សក់។

(៦) **រាប់បញ្ចូល** (ក) ការអប់រំបណ្តុះបណ្តាលកម្រិតក្រោយមធ្យមសិក្សា និងឧត្តមសិក្សាក្នុងប្រព័ន្ធអប់រំចំណេះដឹងទូទៅ និងកម្រិតឧត្តមសិក្សាក្នុងប្រព័ន្ធអប់រំបណ្តុះបច្ចេកទេស និងវិជ្ជាជីវៈ

(ខ) សកម្មភាពអប់រំសម្រាប់សាលាយោធា វិទ្យាស្ថាន និងបណ្ឌិតសភា។

(៧) **រាប់បញ្ចូល** វិទ្យាស្ថានពាណិជ្ជកម្ម និងវិទ្យាស្ថានបច្ចេកទេសដទៃទៀត សាលាពេទ្យ។

ជំពូក ត ៖ ការអប់រំ

ផ្នែក ៨៥ ៖ ការអប់រំ

ក្រុម	ថ្នាក់	ថ្នាក់រង	ការអធិប្បាយ
៨៥៤			**ការអប់រំផ្សេងទៀត**
	៨៥៤១[១]		ការអប់រំកីឡា និងការកំសាន្ត
		៨៥៤១០	ការអប់រំកីឡា និងការកំសាន្ត[២]
	៨៥៤២		ការអប់រំវប្បធម៌
		៨៥៤២០	សាលាតន្ត្រី និងរបាំ និងការអប់រំវប្បធម៌ផ្សេងទៀត[៣]
	៨៥៤៩[៤]		ការអប់រំផ្សេងទៀតដែលមិនបានរាប់បញ្ចូល
		៨៥៤៩១	មជ្ឈមណ្ឌលសិក្សាឯកជនក្រៅម៉ោង
		៨៥៤៩២	សាលាបង្រៀនបើកបរ
		៨៥៤៩៣	ការអប់រំសាសនា
		៨៥៤៩៤	ការបណ្តុះបណ្តាលកុំព្យូទ័រ
		៨៥៤៩៥	ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មិនមានកម្រិត[៥]
		៨៥៤៩៩	ការអប់រំផ្សេងទៀតដែលមិនបានរាប់បញ្ចូល[៦]
៨៥៥			**សេវាគាំទ្រការអប់រំ**
	៨៥៥០[៧]		សេវាគាំទ្រការអប់រំ
		៨៥៥០០	សេវាគាំទ្រការអប់រំ

(១) **រាប់បញ្ចូល** ជំរំ និងសាលា ដែលបង្ហាត់អត្តពលកម្ម និងក្លឹបបង្ហាត់កីឡាពេលយប់និងពេលថ្ងៃ

មិនរាប់បញ្ចូល ការអប់រំផ្នែកវប្បធម៌ (មើល ៨៥៤២)។

(២) **រាប់បញ្ចូល** ការបង្ហាត់ក្បាច់គុន និងយោហ្គា។

(៣) **រាប់បញ្ចូល** ការបង្ហាត់សិល្បៈ និងសាលាបង្រៀនថតរូប (លើកលែងយកជាអាជីវកម្ម)។

(៤) **មិនរាប់បញ្ចូល** កម្មវិធីអក្ខរកម្មសម្រាប់មនុស្សពេញវ័យ (មើល ៨៥១០)។

(៥) **មិនរាប់បញ្ចូល** ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ កម្រិតមធ្យមសិក្សា (មើល ៨៥២២០) ឬកម្រិតឧត្តមសិក្សា (មើល ៨៥៣០)។

(៦) **រាប់បញ្ចូល** (ក) ការបង្រៀនភាសា និងជំនាញសន្ទនា ការបង្រៀនអានល្បឿនលឿន វគ្គបណ្តុះបណ្តាលការនិយាយជាសាធារណៈ សាលាបង្រៀនបើកយន្តហោះ

(ខ) ការបង្រៀនកាត់ខោអាវ និងដេរប៉ាក់។

(៧) **រាប់បញ្ចូល** សកម្មភាពប្រឹក្សាផ្នែកអប់រំ

មិនរាប់បញ្ចូល ការស្រាវជ្រាវ និងពិសោធន៍លើវិទ្យាសាស្ត្រសង្គមនិងមនុស្សសាស្ត្រ (មើល ៧២២០០)។

ជំពូក ថ ៖ សកម្មភាពទាក់ទងសុខភាព និងការងារសង្គមកិច្ច

កម្រិត	ច.ស.វ.ក
ជំពូក	១
ផ្នែក	៣
ក្រុម	៩
ថ្នាក់	៩
ថ្នាក់រង	២១

ជំពូកនេះរាប់បញ្ចូលនូវការផ្តល់សកម្មភាពទាក់ទងសុខភាព និងការងារសង្គមកិច្ច។ សកម្មភាពទាំងនោះរួមមានសកម្មភាពជាច្រើនប្រភេទផ្សេងៗគ្នា មានដូចជាការថែទាំសុខភាពដែលផ្តល់ដោយអ្នកមានវិជ្ជាជីវៈផ្នែកសុខភាពក្នុងមន្ទីរពេទ្យ និងគ្រឹះស្ថានសុខភាពដទៃទៀត រហូតដល់សកម្មភាពថែទាំសុខភាពតាមលំនៅដ្ឋានឯកជន ដែលនៅតែពាក់ព័ន្ធនឹងសកម្មភាពថែទាំសុខភាព និងការងារសង្គមកិច្ចកម្រិតណាមួយ ដោយមិនពាក់ព័ន្ធនឹងអ្នកមានវិជ្ជាជីវៈថែទាំសុខភាព។

ផ្នែក ៨៦ ៖ សកម្មភាពថែទាំសុខភាព

ផ្នែកនេះរាប់បញ្ចូលនូវសកម្មភាពព្យាបាលនៅមន្ទីរពេទ្យរយៈពេលខ្លី ឬវែង ការព្យាបាលទូទៅ ឬព្យាបាលតាមជំនាញការវះកាត់ មន្ទីរពេទ្យព្យាបាលជំងឺវិកលចរិតនិងជំងឺដោយសារការរំលោភបំពាន ជំងឺរ៉ាំរ៉ៃ ជំងឺដែលអាចបង្ការបាន មន្ទីរថែរក្សាមនុស្សចាស់ ទីជ្រកកោន មន្ទីរព្យាបាលអ្នកជំងឺផ្លូវចិត្ត មជ្ឈមណ្ឌលនីតិសម្បទា មន្ទីរពេទ្យឃ្លង់ និងគ្រឹះស្ថានថែទាំសុខភាពដទៃទៀត ដែលមានកន្លែងស្នាក់នៅ និងដែលផ្តល់ការវិនិច្ឆ័យរោគ និងការព្យាបាលដល់អ្នកជំងឺគេងពេទ្យ ទៅតាមលក្ខណ្ឌផ្សេងៗនៃជំងឺ។ ផ្នែកនេះក៏រាប់បញ្ចូលការផ្តល់ការពិគ្រោះ និងការព្យាបាលជំងឺទូទៅ ក៏ដូចជាតាមឯកទេស ដោយគ្រូពេទ្យជំនាញទូទៅ គ្រូពេទ្យឯកទេស និងគ្រូពេទ្យវះកាត់។ វាក៏មានទាំងការព្យាបាលមាត់ធ្មេញរបស់ទន្តពេទ្យជំនាញទូទៅ ឬទន្តពេទ្យឯកទេស និងសកម្មភាពកែតម្រង់ធ្មេញ។ បន្ថែមពីលើនេះទៀតផ្នែកនេះរាប់បញ្ចូលសកម្មភាពថែទាំសុខភាពមនុស្ស ដែលមិនបានអនុវត្តដោយមន្ទីរពេទ្យ ឬវេជ្ជបណ្ឌិត តែដោយបុគ្គលិកសង្គ្រោះបន្ទាន់ ដែលបានទទួលស្គាល់តាមផ្លូវច្បាប់ឲ្យព្យាបាលជំងឺ។

ក្រុម ៨៦១ ៖ សកម្មភាពនៅមន្ទីរពេទ្យ

ក្រុមនេះរាប់បញ្ចូលនូវសកម្មភាពព្យាបាលនៅមន្ទីរពេទ្យរយៈពេលខ្លី ឬវែង ដូចជាសកម្មភាពពិនិត្យ វិនិច្ឆ័យរោគ និងព្យាបាល របស់មន្ទីរពេទ្យទូទៅ (ឧ. មន្ទីរពេទ្យសហគមន៍ និងតំបន់ មន្ទីរពេទ្យនៃស្ថាប័នមិនរកប្រាក់ចំណេញ មន្ទីរពេទ្យសកលវិទ្យាល័យ មន្ទីរពេទ្យយោធា និងមន្ទីរពេទ្យក្នុងពន្ធនាគារ) និងរបស់មន្ទីរពេទ្យឯកទេស (ឧ. មន្ទីរពេទ្យព្យាបាលជំងឺផ្លូវចិត្តនិងជំងឺដោយសារការរំលោភបំពាន មន្ទីរពេទ្យសម្រាប់ជំងឺឆ្លង សម្ភព មន្ទីរពេទ្យឯកទេសព្យាបាលជំងឺរ៉ាំរ៉ៃ)។

សកម្មភាពទាំងនេះមានទិសដៅជាចម្បងព្យាបាលអ្នកជំងឺសម្រាកនៅមន្ទីរពេទ្យដែលត្រូវបានព្យាបាលក្រោមការត្រួតពិនិត្យដោយផ្ទាល់របស់វេជ្ជបណ្ឌិត។ សកម្មភាពនេះក៏រាប់បញ្ចូលនូវសេវាកម្មរបស់វេជ្ជបណ្ឌិត និងបុគ្គលិកសង្គ្រោះបន្ទាន់ សេវាកម្មមន្ទីរពិសោធន៍ និងឧបករណ៍បច្ចេកទេសផ្សេងៗ រួមទាំងសេវាកម្មព្យាបាលដោយវិទ្យុសកម្ម និងថ្នាំស្ពឹក ថ្នាំសន្លំ សេវាកម្មបន្ទប់សង្គ្រោះបន្ទាន់ សេវាកម្មផ្តល់បន្ទប់វះកាត់ សេវាឱសថ សេវាកម្មម្ហូបអាហារ និង សេវាកម្មសុខភាពដទៃ សេវាកម្មមជ្ឈមណ្ឌលរៀបចំផែនការគ្រួសារដែលផ្តល់ការព្យាបាល (ជាមួយនិងកន្លែងស្នាក់នៅ) ដូចជា ការគ្រៀវ និងការពន្លូតកូន។

ក្រុម ៨៦២ ៖ សកម្មភាពពិគ្រោះយោបល់ផ្នែកវេជ្ជសាស្ត្រ និងទន្តសាស្ត្រ

ក្រុមនេះរាប់បញ្ចូលនូវការពិគ្រោះ និងព្យាបាលជំងឺទូទៅ និងតាមឯកទេសដោយ គ្រូពេទ្យជំនាញទូទៅ គ្រូពេទ្យឯកទេស និងគ្រូពេទ្យវះកាត់ សកម្មភាពព្យាបាលមាត់ធ្មេញ ទូទៅ ឬតាមឯកទេស (ឧ. ទន្តសាស្ត្រ ទន្តសាស្ត្រផ្នែកបណ្តុលធ្មេញ និងធ្មេញកុមារ) ការ ព្យាបាលមាត់ ការតម្រង់ធ្មេញ និងមជ្ឈមណ្ឌលរៀបចំផែនការគ្រួសារ ដែលផ្តល់ការព្យាបាល (ជាមួយនិងកន្លែងស្នាក់នៅ) ដូចជាការគ្រៀវ និងការពន្លូតកូន។

សកម្មភាពទាំងនេះអាចត្រូវបានអនុវត្តនៅតាមផ្នែកឯកជនតាមក្រុមការងារ តាមមន្ទីរ ពេទ្យសម្រាប់អ្នកជំងឺមិនត្រូវការសម្រាកពេទ្យ និងតាមវេជ្ជគ្រឹះ ដែលមាននៅតាមរោងចក្រ សាលារៀន ផ្ទះមនុស្សចាស់ អង្គការទាក់ទងពលកម្ម និងសមាគម ក៏ដូចជានៅតាមគេហដ្ឋានអ្នកជំងឺ។

ក្រុមនេះក៏រាប់បញ្ចូលនូវការព្យាបាលមាត់ធ្មេញនៅបន្ទប់វះកាត់ និងសេវាកម្មប្រឹក្សាយោបល់ឯកជនដល់អ្នកជំងឺដែលសម្រាកនៅមន្ទីរពេទ្យ។

ក្រុម ៨៦៩ ៖ សកម្មភាពថែទាំសុខភាពផ្សេងទៀត

ក្រុមនេះរាប់បញ្ចូលនូវសកម្មភាពថែទាំសុខភាពរបស់មនុស្សដែលមិនត្រូវបានអនុវត្តដោយមន្ទីរពេទ្យ ឬដោយវេជ្ជបណ្ឌិត ឬទន្តបណ្ឌិត ដូចជាសកម្មភាពរបស់គិលានុបដ្ឋាយិកា ឆ្មប អ្នកព្យាបាលជំងឺដោយការធ្វើសរសៃឬហាត់ប្រាណ(ជាជាងដោយការប្រើឱសថ) ឬបុគ្គលិកសង្គ្រោះបន្ទាន់ដទៃទៀត ក្នុងផ្នែកចក្ខុវិទ្យា ផ្នែកការព្យាបាលដោយការហាត់ប្រាណក្នុងទឹក ផ្នែកការព្យាបាលដោយការធ្វើសរសៃ ផ្នែកការព្យាបាលដោយប្រើវិធីជាក់លាក់ណា មួយដើម្បីសម្រួលរាងកាយនិងផ្លូវចិត្ត ផ្នែកការព្យាបាលដោយប្រើវិធីសាស្ត្រសន្ទនា ផ្នែកការ ព្យាបាលជើង ផ្នែកការព្យាបាលដោយប្រើថ្នាំប្រភេទខ្សោយ ផ្នែកការព្យាបាលដោយចាប់ សរសៃនិងសន្លាក់ ផ្នែកការព្យាបាលដោយម្ចុលវិជ្ជាសាស្ត្រ។ល។

សកម្មភាពទាំងនេះអាចត្រូវអនុវត្តនៅតាមវេជ្ជគ្រឹះ ដែលមាននៅតាមរោងចក្រ សាលារៀន ផ្ទះសម្រាប់មនុស្សចាស់ អង្គការទាក់ទងពលកម្ម និងសមាគម និងនៅតាមលំនៅដ្ឋានរបស់អ្នកជំងឺក្រៅពីមន្ទីរពេទ្យ ក៏ដូចជានៅបន្ទប់ពិគ្រោះជំងឺផ្ទាល់ខ្លួន ផ្ទះអ្នកជំងឺ ឬកន្លែងផ្សេងទៀត។ សកម្មភាពនេះមិនពាក់ព័ន្ធនឹងការព្យាបាលទេ។

ក្រុមនេះក៏រាប់បញ្ចូលនូវសកម្មភាពនៃការព្យាបាលដោយជំនួយការទន្តបណ្ឌិត ដូចជា អ្នកព្យាបាលផ្នែកទន្តសាស្ត្រតាមឯកទេស គិលានុបដ្ឋាយិកាផ្នែកទន្តសាស្ត្រ និងអ្នកសម្អាតអនាម័យមាត់ធ្មេញ ដែលធ្វើការដោយឯករាជ្យ តែត្រូវបានពិនិត្យតាមដានជាប្រចាំដោយ ទន្ត បណ្ឌិត។ បន្ថែមពីលើនេះក៏រាប់បញ្ចូលសកម្មភាពរបស់មន្ទីរពិសោធន៍ ដូចជាមន្ទីរពិសោធន៍ កាំរស្មីអ៊ិក្ស មន្ទីរប្រមូលផ្តុំរូបហ្វីលថតសម្រាប់វិនិច្ឆ័យរោគផ្សេងៗ និងមន្ទីរវិភាគឈាម សកម្ម ភាពកន្លែងផ្ទុកឈាម កន្លែងផ្ទុកទឹកមេជីវិតមនុស្សប្រុស កន្លែងផ្ទុកសរីរាង្គមនុស្ស ។ល។ និងការដឹកជញ្ជូនអ្នកជំងឺតាមមធ្យោបាយនានារួមទាំងតាមយន្តហោះផងដែរ។ សេវាកម្មនេះ ជាទូទៅតែងតែផ្តល់ជូនសម្រាប់ការសង្គ្រោះបន្ទាន់។

ជំពូក ថ ៖ សកម្មភាពថែទាំសុខភាព និងការងារសង្គមកិច្ច
ផ្នែក ៨៦ ៖ សកម្មភាពថែទាំសុខភាព

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៨៦១			**សកម្មភាពនៅមន្ទីរពេទ្យ**
	៨៦១០[១]		សកម្មភាពនៅមន្ទីរពេទ្យ និងលំហែមាតុភាពនៅផ្ទះ
		៨៦១០១	សកម្មភាពមន្ទីរពេទ្យ
		៨៦១០២	សេវាកម្មមាតុភាពនៅផ្ទះ (នៅក្នុង ឬនៅក្រៅមន្ទីរពេទ្យ)
៨៦២			**សកម្មភាពពិគ្រោះយោបល់ផ្នែកវេជ្ជសាស្ត្រ និងទន្តសាស្ត្រ**
	៨៦២០[២]		សកម្មភាពពិគ្រោះយោបល់ផ្នែកវេជ្ជសាស្ត្រ និងទន្តសាស្ត្រ
		៨៦២០១	វេជ្ជគ្រឹះ និងសេវាកម្មព្យាបាលជំងឺទូទៅ
		៨៦២០២	សេវាកម្មព្យាបាលជំងឺដោយឯកទេស
		៨៦២០៣	សេវាកម្មផ្នែកទន្តសាស្ត្រ[៣]

(១) **រាប់បញ្ចូល** សកម្មភាពនៅមន្ទីរពេទ្យក្នុងពន្ធនាគារ

មិនរាប់បញ្ចូល
(ក) ការពិសោធ និងត្រួតពិនិត្យគ្រប់សម្ភារៈនិងផលិតផលទាំងអស់ លើកលែងទាក់ទងនឹងការព្យាបាល (មើល ៧១២០០)
(ខ) សកម្មភាពបសុពេទ្យ (មើល ៧៥០០០)
(គ) សកម្មភាពថែទាំសុខភាពដល់យោធាដែលកំពុងប្រតិបត្តិការ (មើល ៨៤២២)
(ឃ) សកម្មភាពព្យាបាលមាត់ធ្មេញទូទៅ ឬតាមឯកទេស ឧ. ទន្តសាស្ត្រ ទន្តសាស្ត្រផ្នែកបណ្តុលធ្មេញនិងធ្មេញកុមារ ការព្យាបាលមាត់ ការតម្រង់ធ្មេញ (មើល ៨៦២០៣)
(ង) សេវាកម្មឯកជនសម្រាប់ការពិគ្រោះយោបល់ជំងឺដល់អ្នកជំងឺសម្រាកនៅមន្ទីរពេទ្យ (មើល ៨៦២០)
(ច) មន្ទីរពិសោធន៍វេជ្ជសាស្ត្រ (មើល ៨៦៩០១) និងសកម្មភាពដឹកជញ្ជូនអ្នកជំងឺ (មើល ៨៦៩០៩)។

(២) **រាប់បញ្ចូល** ការពិគ្រោះ និងព្យាបាលជំងឺទូទៅ និងឯកទេស ដោយគ្រូពេទ្យជំនាញទូទៅ និងគ្រូពេទ្យឯកទេស និងគ្រូពេទ្យវះកាត់

មិនរាប់បញ្ចូល
(ក) ការផលិតធ្មេញសិប្បនិម្មិត ក្រាសធ្មេញពាក់សម្រាប់ជំនួសធ្មេញធម្មជាតិ និងអវយវៈសិប្បនិម្មិត ដោយមន្ទីរពិសោធន៍ទន្តសាស្ត្រ (មើល ៣២៥០)
(ខ) សកម្មភាពរបស់មន្ទីរពេទ្យសម្រាប់អ្នកជំងឺសម្រាកនៅពេទ្យ (មើល ៨៦១០)
(គ) សកម្មភាពជំនួយការពេទ្យ ដូចជាសកម្មភាពរបស់គិលានុប្បដ្ឋាយិកា និងអ្នកព្យាបាលជំងឺដោយការធ្វើសរសៃឬហាត់ប្រាណ(ជាជាងដោយការប្រើឱសថ) (មើល ៨៦៩០)។

(៣) **រាប់បញ្ចូល** សកម្មភាពព្យាបាលមាត់ធ្មេញទូទៅ ឬតាមឯកទេស ឧ. ទន្តសាស្ត្រ ទន្តសាស្ត្រផ្នែកបណ្តុលធ្មេញ។

ជំពូក ឋ ៖ សកម្មភាពថែទាំសុខភាព និងការងារសង្គមកិច្ច
ផ្នែក ៨៦ ៖ សកម្មភាពថែទាំសុខភាព

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៨៦៩			**សកម្មភាពថែទាំសុខភាពផ្សេងទៀត**
	៨៦៩០[១]		សកម្មភាពថែទាំសុខភាពផ្សេងទៀត
		៨៦៩០១	មន្ទីរពិសោធន៍[២]
		៨៦៩០២	ការព្យាបាលនិងថែទាំសុខភាពក្នុងពេលសម្រាលកូន
		៨៦៩០៣	សេវាកម្មព្យាបាលជំងឺដោយការធ្វើសរសៃឬហាត់ប្រាណ(ជាជាងដោយការប្រើឱសថ) និងព្យាបាលដោយប្រើវិធីជាក់លាក់ណាមួយដើម្បីសម្រួលរាងកាយនិងផ្លូវចិត្ត
		៨៦៩០៤	សេវាកម្មព្យាបាលដោយមូលវិជ្ជាសាស្ត្រ
		៨៦៩០៥	សេវាកម្មព្យាបាលដោយអ្នកតិណទេស
		៨៦៩០៩	សេវាកម្មព្យាបាលជំងឺផ្សេងទៀត ដែលមិនបានរាប់បញ្ចូល[៣]

(១) **មិនរាប់បញ្ចូល**
- (ក) ការផលិតធ្មេញសិប្បនិម្មិត ក្រាសធ្មេញពាក់សម្រាប់ជំនួសធ្មេញធម្មជាតិ និងអវយវៈសិប្បនិម្មិត ដោយមន្ទីរពិសោធន៍ផ្នែកទន្តសាស្ត្រ (មើល ៣២៥០)
- (ខ) ការប្តូរទីតាំងអ្នកជំងឺ ដោយគ្មានឧបករណ៍សង្គ្រោះជីវិត ឬបុគ្គលិកពេទ្យនៅជាមួយ (មើលផ្នែក ៤៩, ៥០ និង៥១)
- (គ) ការពិសោធមិនទាក់ទងនឹងវេជ្ជសាស្ត្រ (មើល ៧១២០០)
- (ឃ) សកម្មភាពពិសោធន៍ទាក់ទងនឹងអនាម័យចំណីអាហារ (មើល ៧១២០០)
- (ង) សកម្មភាពនៅមន្ទីរពេទ្យ (មើល ៨៦១០១)
- (ច) សកម្មភាពព្យាបាលជំងឺទូទៅ និងជំងឺមាត់ធ្មេញ
- (ឆ) ការថែទាំសុខភាពដោយគិលានុប្បដ្ឋាយិកា (មើល ៨៧១០)
- (ជ) ការធ្វើសរសៃជើង ឬផ្សេងពីនេះ (មើល ៩៦០៩១)។

(២) **រាប់បញ្ចូល** មន្ទីរពិសោធន៍កាំរស្មីអ៊ិក្ស និងមន្ទីរប្រមូលផ្តុំរូបហ្វីលថតសម្រាប់វិនិច្ឆ័យរោគផ្សេងៗ មន្ទីរវិភាគឈាម។

(៣) **រាប់បញ្ចូល** សកម្មភាពថែទាំសុខភាព ផ្តល់ដោយគិលានុប្បដ្ឋាយិកា ដោយអ្នកព្យាបាលជំងឺដោយការធ្វើសរសៃឬហាត់ប្រាណ(ជាជាងដោយការប្រើឱសថ) ឬដោយជំនួយការពេទ្យដទៃទៀត។

ផ្នែក ៨៧ ៖ សកម្មភាពថែទាំសុខភាពតាមលំនៅដ្ឋាន

ផ្នែកនេះរាប់បញ្ចូលនូវការថែទាំសុខភាពតាមលំនៅដ្ឋានរួមទាំងការថែទាំអ្នកជំងឺដោយ គិលានុបដ្ឋាយិកា ការត្រួតពិនិត្យ ឬការថែទាំផ្សេងទៀត តាមតម្រូវការរបស់អ្នកតាំងទីលំនៅ។ ទីកន្លែងជាផ្នែកសំខាន់មួយនៃការថែទាំនេះ ហើយវាមានលក្ខណៈលាយគ្នារវាងសេវាកម្មសុខភាពនិងសេវាកម្មសង្គមដែលសេវាកម្មសុខភាពភាគច្រើនសំដៅលើសេវាកម្មថែទាំដោយ គិលានុបដ្ឋាយិកា។

ក្រុម ៨៧១ ៖ សកម្មភាព ឬសម្ភារៈថែទាំសុខភាពតាមលំនៅដ្ឋាន

ក្រុមនេះរាប់បញ្ចូលនូវសកម្មភាពថែទាំមនុស្សចាស់នៅតាមផ្ទះ ថែទាំអ្នកទើបងើបពីឈឺនៅតាមផ្ទះសំរាកកាយនៅតាមផ្ទះដើម្បីថែទាំសុខភាព សម្ភារៈថែទាំសុខភាពនិងព្យាបាលនៅផ្ទះ។

ក្រុម ៨៧២ ៖ សកម្មភាពថែទាំអ្នកមានប្រាជ្ញាអន់ មានរោគផ្លូវចិត្ត និងការប៉ះពាល់ផ្លូវចិត្តដោយសារអំពើហិង្សា នៅតាមលំនៅដ្ឋាន

ក្រុមនេះរាប់បញ្ចូលនូវការផ្តល់ការថែទាំសុខភាពតាមផ្ទះ (ប៉ុន្តែមិនមានអាជ្ញាប័ណ្ណពីមណ្ឌលថែទាំសុខភាព) ដល់អ្នកដែលមានប្រាជ្ញាអន់ មានរោគផ្លូវចិត្ត និងមានការប៉ះពាល់សុខភាពផ្លូវចិត្តដោយអំពើហិង្សា។ គ្រឹះស្ថានផ្តល់ជាបន្ទប់ អាហារ ការគ្រប់គ្រងតាមដាននិងការពិគ្រោះជំងឺ និងការថែទាំសុខភាពមួយចំនួនទៀត។ ផ្នែកនេះក៏មានការថែទាំ និងព្យាបាលតាមផ្ទះសម្រាប់អ្នកជំងឺផ្លូវចិត្ត និងអ្នកប៉ះពាល់សុខភាពផ្លូវចិត្តបង្កឡើងដោយអំពើហិង្សា។

ក្រុម ៨៧៣ ៖ សកម្មភាពថែទាំសុខភាពតាមលំនៅដ្ឋានសំរាប់មនុស្សចាស់ និងជនពិការ

ក្រុមនេះរាប់បញ្ចូលនូវសេវាកម្មថែទាំសុខភាពតាមផ្ទះ និងលក្ខណៈជាបុគ្គល សម្រាប់មនុស្សចាស់ និងជនពិការដែលមិនអាចថែទាំខ្លួនឯងបាន និង/ឬអ្នកដែលមិនចង់រស់នៅតែឯង។ ការថែទាំទាំងនេះរួមមានបន្ទប់ អាហារ ការគ្រប់គ្រងតាមដាន និងជំនួយប្រចាំថ្ងៃ ដូចជាសេវាកម្មមើលថែរក្សាផ្ទះជាដើម។ ក្នុងករណីខ្លះ ក្រុមនេះក៏ផ្តល់នូវសេវាកម្មថែទាំតាមផ្ទះដែលមានជំនាញដោយគិលានុបដ្ឋាយិកា សម្រាប់អ្នករស់នៅតាមគ្រឹះស្ថានដាច់ដោយ ឡែកពីគ្នាផងដែរ។

ក្រុម ៨៧៩ ៖ សកម្មភាពថែទាំសុខភាពតាមលំនៅដ្ឋានផ្សេងទៀត

ក្រុមនេះរាប់បញ្ចូលនូវការផ្តល់សេវាកម្មថែទាំសុខភាពតាមផ្ទះ និងលក្ខណៈជាបុគ្គលសម្រាប់មនុស្សទាំងឡាយ (លើកលែងមនុស្សចាស់ និងជនពិការ) ដែលមិនអាចថែទាំខ្លួនឯងបាន ឬដែលមិនចង់រស់នៅតែឯង។

ក្រុមនេះរាប់បញ្ចូលនូវសកម្មភាពដែលផ្តល់ការថែទាំសុខភាព២៤ម៉ោង ដើម្បីផ្តល់ជាជំនួយសង្គមដល់កុមារ និងក្រុមមួយចំនួនដែលមានសមត្ថភាពតិចតួចក្នុងការថែទាំខ្លួនឯងបាន ប៉ុន្តែក្នុងខណៈដែលការព្យាបាល ឬការអប់រំមិនមែនជាកត្តាសំខាន់ ដូចជាមជ្ឈមណ្ឌលកុមារកំព្រា ផ្ទះនិងសណ្ឋាគារជួលសម្រាប់កុមារ ទីជម្រកសម្រាប់អ្នកគ្មានផ្ទះបណ្តោះអាសន្ន និងស្ថាប័នដែលថែទាំម្តាយដែលមិនបានរៀបការនិងកូនរបស់ពួកគេ។ សកម្មភាពទាំងនេះ អាចត្រូវបានអនុវត្តដោយស្ថាប័នរដ្ឋ ឬឯកជន។

ក្រុមនេះក៏រាប់បញ្ចូលសកម្មភាពផ្តល់ជាលំនៅដ្ឋានដាច់ដោយឡែកពីគេ សម្រាប់អ្នក ដែលមានបញ្ហាសង្គម ឬបញ្ហាផ្ទាល់ខ្លួន សម្រាប់អ្នកប្រព្រឹត្តបទល្មើសតូចតាច និងធ្ងន់ធ្ងរ និង ជាជំរំអប់រំវិន័យ។

ជំពូក ថ ៖ សកម្មភាពថែទាំសុខភាព និងការងារសង្គមកិច្ច
ផ្នែក ៨៧ ៖ សកម្មភាពថែទាំសុខភាពនៅតាមលំនៅដ្ឋាន

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៨៧១			**គ្រឹះស្ថានថែទាំសុខភាពនៅតាមលំនៅដ្ឋាន**
	៨៧១០[១]		គ្រឹះស្ថានថែទាំសុខភាពនៅតាមលំនៅដ្ឋាន
		៨៧១០០	គ្រឹះស្ថានថែទាំសុខភាពនៅតាមលំនៅដ្ឋាន
៨៧២			**សកម្មភាពថែទាំសុខភាពតាមលំនៅដ្ឋានដល់អ្នកមានប្រាជ្ញាអន់ មានរោគផ្លូវចិត្ត និង មានការប៉ះពាល់សុខភាពផ្លូវចិត្តដោយអំពើហិង្សា**
	៨៧២០[២]		សកម្មភាពថែទាំសុខភាពតាមលំនៅដ្ឋានដល់អ្នកមានប្រាជ្ញាអន់មានរោគផ្លូវចិត្ត និង មានការប៉ះពាល់សុខភាពផ្លូវចិត្តដោយអំពើហិង្សា
		៨៧២០១	មជ្ឈមណ្ឌលកែប្រែថ្នាំញៀន
		៨៧២០៩	សកម្មភាពថែទាំសុខភាពតាមលំនៅដ្ឋានផ្សេងទៀតដល់អ្នកមានប្រាជ្ញាអន់ដែលមិនបានរាប់បញ្ចូល

(១) **មិនរាប់បញ្ចូល** (ក) សេវាកម្មថែទាំតាមលំនៅដ្ឋានផ្តល់ដោយអ្នកជំនាញថែទាំសុខភាព (មើលផ្នែក ៨៦)
(ខ) ផ្ទះសម្រាប់មនុស្សចាស់ ដោយមិនមាន ឬមានការថែទាំសុខភាពតិចតួចបំផុត (មើល ៨៧៣០)
(គ) សកម្មភាពសង្គមកិច្ចរួមជាមួយនិងការផ្តល់កន្លែងស្នាក់នៅ ដូចជាមជ្ឈមណ្ឌលកុមារកំព្រា ផ្ទះនិងសណ្ឋាគារជួលសម្រាប់កុមារ ទីជម្រកសម្រាប់អ្នកគ្មានផ្ទះបណ្តោះអាសន្ន (មើល ៨៧៩០)។

(២) **មិនរាប់បញ្ចូល** សកម្មភាពសង្គមកិច្ចរួមជាមួយនិងការផ្តល់កន្លែងស្នាក់នៅ ដូចជាទីជម្រកសម្រាប់អ្នកគ្មានផ្ទះបណ្តោះអាសន្ន (មើល ៨៧៩០)។

ជំពូក ថ ៖ សកម្មភាពថែទាំសុខភាព និងការងារសង្គមកិច្ច
ផ្នែក ៨៧ ៖ សកម្មភាពថែទាំសុខភាពនៅតាមលំនៅដ្ឋាន

ក្រុម	ថ្នាក់	ថ្នាក់រង	សេចក្តីអធិប្បាយ
៨៧៣			**សកម្មភាពថែទាំសុខភាពតាមលំនៅដ្ឋានសម្រាប់មនុស្សចាស់ និងជនពិការ**
	៨៧៣០(៣)		សកម្មភាពថែទាំសុខភាពតាមលំនៅដ្ឋានសម្រាប់មនុស្សចាស់ និងជនពិការ
		៨៧៣០០	សកម្មភាពថែទាំសុខភាពតាមលំនៅដ្ឋានសម្រាប់មនុស្សចាស់ និងជនពិការ
៨៧៩			**សកម្មភាពថែទាំសុខភាពតាមលំនៅដ្ឋានផ្សេងទៀត**
	៨៧៩០(៤)		សកម្មភាពថែទាំសុខភាពតាមលំនៅដ្ឋានផ្សេងទៀត (សកម្មភាពនេះអាចត្រូវបានអនុវត្តដោយស្ថាប័នរដ្ឋ ឬឯកជន)
		៨៧៩០១	ការថែទាំកុមារតាមលំនៅដ្ឋាន (រួមនិងមណ្ឌលកុមារកំព្រាដែរ)
		៨៧៩០២	ការថែទាំសុខភាពតាមលំនៅដ្ឋានសម្រាប់មនុស្សពេញវ័យ ដែលមិនមែនជាមនុស្សចាស់ ឬជនពិការ

(១) **មិនរាប់បញ្ចូល**
(ក) ផ្ទះសម្រាប់មនុស្សចាស់ជាមួយនឹងការថែទាំសុខភាពដោយគិលានុបដ្ឋាយិកា (មើល ៨៧១០១)
(ខ) សកម្មភាពសង្គមកិច្ចរួមជាមួយនិងការផ្តល់កន្លែងស្នាក់នៅ តែការព្យាបាលជំងឺ ឬការស្នាក់នៅមិនមែនជាកត្តាសំខាន់ (មើល ៨៧៩០)។

(២) **រាប់បញ្ចូល** សកម្មភាពសង្គមកិច្ចរួមជាមួយនិងការផ្តល់កន្លែងស្នាក់នៅ តែការព្យាបាលជំងឺ ឬការស្នាក់នៅមិនមែនជាកត្តាសំខាន់ ៖
(ក) ដំណើរការជម្រកភៀសខ្លួនសម្រាប់ស្ត្រី
(ខ) សេវាកម្មនៅក្នុងកន្លែងស្នាក់របស់យុវជនដែលប្រព្រឹត្តទោស
(គ) ដំណើរការក្នុងកន្លែងស្នាក់នៅរបស់ជនពិការ

មិនរាប់បញ្ចូល
(ក) ការផ្តល់មូលនិធិ និងការគ្រប់គ្រងកម្មវិធីសុវត្ថិភាពសង្គម (មើល ៨៤៣០)
(ខ) គ្រឹះស្ថានថែទាំសុខភាព (មើល ៨៧១០)
(គ) សកម្មភាពថែទាំសុខភាពតាមលំនៅដ្ឋានសម្រាប់អ្នកមានប្រាជ្ញាអន់ មានរោគផ្លូវចិត្ត និងមានការប៉ះពាល់សុខភាពផ្លូវចិត្តដោយអំពើហិង្សា (មើល ៨៧២០)
(ឃ) សកម្មភាពថែទាំសុខភាពតាមលំនៅដ្ឋានសម្រាប់មនុស្សចាស់ ឬជនពិការ (មើល ៨៧៣០)
(ង) សកម្មភាពកេកូនចិញ្ចឹម (មើល ៨៨៩០៩)
(ច) សកម្មភាពក្នុងទីជម្រករយៈពេលខ្លីសម្រាប់ជនរងគ្រោះដោយគ្រោះមហន្តរាយ (មើល ៨៨៩០៩)។

ផ្នែក ៨៨ ៖ សកម្មភាពសង្គមកិច្ចដែលមិនផ្តល់កន្លែងស្នាក់នៅ

ផ្នែកនេះរាប់បញ្ចូលនូវការផ្តល់សេវាកម្មជំនួយសង្គមច្រើនប្រភេទដោយផ្ទាល់ទៅដល់អតិថិជន។ សកម្មភាពនៅក្នុងផ្នែកនេះមិនរាប់បញ្ចូលសេវាកម្មផ្តល់កន្លែងស្នាក់នៅទេ លើក លែងតែជាលក្ខណៈបណ្តោះអាសន្ន។

ក្រុម ៨៨១ ៖ សកម្មភាពសង្គមកិច្ចសម្រាប់មនុស្សចាស់ និងជនពិការដោយមិនផ្តល់កន្លែងស្នាក់នៅ

ក្រុមនេះរាប់បញ្ចូលនូវសេវាកម្មសង្គម ប្រឹក្សាយោបល់ សុខមាលភាព សេវាកម្មបញ្ជូន និងសេវាកម្មប្រហាក់ប្រហែលនេះ ដែលសម្រាប់តែមនុស្សចាស់ និងជនពិការ នៅផ្ទះរបស់ពួកគេ ឬកន្លែងផ្សេងទៀត ហើយត្រូវបានអនុវត្តដោយស្ថាប័នរដ្ឋ ឬដោយស្ថាប័នឯកជន អង្គការជួយខ្លួនឯងទោះជាអង្គការថ្នាក់តំបន់ ឬថ្នាក់ជាតិ និងដោយអ្នកឯកទេសផ្តល់នូវសេវាកម្មប្រឹក្សាយោបល់ ដូចជាការទៅលេងមនុស្សចាស់ និងជនពិការ សេវាកម្មថែទាំសុខភាពពេលថ្ងៃសម្រាប់មនុស្សចាស់ ឬជនពិការពេញវ័យ វគ្គអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងសកម្មភាពសម្រាប់នីតិសម្បទា ដល់ជនពិការ ដរាបណាការផ្តល់ការអប់រំមានកម្រិត។

ក្រុម ៨៨៩ ៖ សកម្មភាពសង្គមកិច្ចដោយមិនផ្តល់កន្លែងស្នាក់នៅ ដទៃទៀតដែលពុំបានរាប់បញ្ចូល

